# បង្កើត ការស្រាវជ្រាវនៅកម្ពុជា គំរូដែលកសាងសមត្ថភាព

ក្រុមស្រាវជ្រាវនៅកម្ពុជា

បោះពុម្ពដោយ

CAMBODIAN INSTITUTE FOR COOPERATION AND PEACE

ជំនួយជាថវិកាដោយ

GDN Global Development Network

# ការស្រាវជ្រាវនៅកម្ពុជា៖
# បង្កើតគំរូដែលកសាងសមត្ថភាព

ក្រុមស្រាវជ្រាវនៅកម្ពុជា

© ២០១៧ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និង សន្តិភាព
អ្នកបោះពុម្ព៖ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និង សន្តិភាព
អគារលេខ ២០៤ ផ្លូវ ១៩៦៦ ភូមិ ពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ប្រទេសកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ១២ ៨១ ៩៩ ៥៣
អ៊ីម៉ែល៖ cicp01@online.com.kh
www.cicp.org.kh

ការសិក្សាស្រាវជ្រាវមួយនេះត្រូវបានគាំទ្រដោយ បណ្តាញអភិវឌ្ឍន៍សាកល(GDN) និងជាផ្នែកមួយនៃគម្រោង "ការស្រាវជ្រាវ"។ ជំណាក់កាលស្រាវជ្រាវសាកល្បងនេះសិក្សាពីកត្តាដែលប៉ះពាល់បរិស្ថានស្រាវជ្រាវនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន១១។ ព័ត៌មានបន្ថែមអាចស្វែងរកបានតាមគេហទំព័រ www.gdn.int/dr។

ក្រុមស្រាវជ្រាវនៅប្រទេសកម្ពុជា

| | |
|---|---|
| ប្រធានស្រាវជ្រាវ | ពូ សុវចនា |
| សហប្រធានស្រាវជ្រាវ | សុខ សេរី (ចាកចេញពីក្រុមនៅខែតុលា ឆ្នាំ២០១៥) |
| អ្នកស្រាវជ្រាវ | Courtney WORK |
| អ្នកស្រាវជ្រាវ | Alice BEBAN |
| អ្នកស្រាវជ្រាវ | Kevin NAUEN |
| ជំនួយការអ្នកស្រាវជ្រាវ | ឃួន ជាវ៉ា |

ក្រុមស្រាវជ្រាវនៅប្រទេសកម្ពុជាទទួលខុសត្រូវទាំងស្រុងលើព័ត៌មាន និងមតិយោបល់នៅក្នុងរបាយការណ៍នេះ ហើយព័ត៌មាន និងមតិយោបល់ទាំងនេះមិនឆ្លុះបញ្ចាំងពីគំនិតរបស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និង សន្តិភាព និងបណ្តាញអភិវឌ្ឍន៍សាកលនោះឡើយ។

វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (វខសស)ជាវិទ្យាស្ថានសិក្សាស្រាវជ្រាវឯករាជ្យ អព្យាក្រឹត្យ និងមិនប្រកាន់បក្សសម្ព័ន្ធ ដែលស្ថិតនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ចាត់តាំងពីការកកើតនៅឆ្នាំ១៩៩៤ ជាអង្គការឯករាជ្យ និងក្រៅរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ***វខសស*** បានធ្វើការសិក្សាស្រាវជ្រាវ រៀបចំវេទិកា និងអភិវឌ្ឍន៍យុទ្ធសាស្ត្រក្នុងសមាហរណកម្មថ្នាក់តំបន់ និងការអភិវឌ្ឍសេដ្ឋកិច្ច។ គោលដៅរបស់***វខសស*** គឺចូលរួមក្នុងការកសាងប្រទេសកម្ពុជា និងតំបន់តាមរយៈគំនិតជាលក្ខណៈយុទ្ធសាស្ត្រ។ គោលបំណងរបស់ ***វខសស*** គឺដើម្បីបណ្តុះចំណាប់អារម្មណ៍ឲ្យបានទូលំទូលាយចំពោះការអភិវឌ្ឍប្រទេសកម្ពុជា និងជម្រុញការយកចិត្តទុកដាក់ឲ្យបានកាន់តែច្រើនក្នុងចំណោមសហគមន៍ដ៏ធំនៃបញ្ញាវ័ន្ត ដើម្បីរួមចំណែកក្នុងការសិក្សាស្រាវជ្រាវនៅក្នុងបរិបទវិទ្យាសាស្ត្រសង្គម ការទូត ប្រវត្តិសាស្ត្រ និងសង្គមសេដ្ឋកិច្ច ដើម្បីស្វែងយល់ឲបានច្រើនពីទស្សនវិស័យបច្ចុប្បន្ន និងអនាគតនៃប្រទេសកម្ពុជាអាស៊ីអាគ្នេយ៍ និងអាស៊ីទាំងមូល។ ជាចុងក្រោយ វខសសព្យាយាមផ្តល់ការវិភាគដែលផ្តល់ជាគំនិត និងការស៊ើបអង្កេតស៊ីជម្រៅជាលក្ខណៈទ្រឹស្តី ដើម្បីធ្វើឲ្យប្រសើរឡើងនូវគំនិតសាធារណៈអំពីសង្គមសេដ្ឋកិច្ច និងភាពប្រឈមនៃនយោបាយ និងសុវត្ថិភាពនៅក្នុងប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍។ ថ្ងៃនេះ វខសសបានក្លាយសមាជិកសកម្មនៃវិទ្យាស្ថានសិក្សាស្រាវថ្នាក់តំបន់នានា ស្តីអំពីសហប្រតិបត្តិការអន្តរជាតិ សុវត្ថិភាពថ្នាក់តំបន់ និងសមាហរណកម្មសេដ្ឋកិច្ច។

បណ្តាញអភិវឌ្ឍន៍សាកល (**បអស**) ជាអង្គការអន្តរជាតិសាធារណៈដែលជម្រុញការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រសង្គមនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងក្នុងអន្តរកាល។ អង្គការនេះជួយដល់អ្នកសិក្សាស្រាវជ្រាវឲ្យទទួលបានធនធានហិរញ្ញវត្ថុ ពត៌មាន សេវាកម្មបណ្តុះបណ្តាល និងទូន្មាន និងបណ្តាញសាកលនៃអ្នកសិក្សាស្រាវជ្រាវផ្នែកការអភិវឌ្ឍន៍។ អាស្រ័យហេតុនេះ បណ្តាញអភិវឌ្ឍន៍ សាកលចូលរួមចំណែក នៃការបង្កើតចំណេះដឹងដែលពាក់ព័ន្ធនឹងគោលនយោបាយទៅលើបញ្ហាអភិវឌ្ឍធំៗ និងទំនាក់ទំនងរវាងអ្នកសិក្សាស្រាវជ្រាវក្នុងស្រុក, អ្នកសិក្សាស្រាវជ្រាវថ្នាក់សាកល អ្នកតាក់តែងគោលនយោបាយ និងអ្នកពាក់ព័ន្ធផ្នែកអភិវឌ្ឍន៍ដ៏ទៃទៀត។

**(បអស)** ជាបណ្តាញមួយនៃបណ្តាញឆ្លងកាត់ទ្វីបជាច្រើន។ អង្គការនេះតភ្ជាប់អ្នកសិក្សាស្រាវជ្រាវជាសាកល។ អង្គការនេះធ្វើជាដៃគូជាមួយសាកលវិទ្យាល័យ, ស្ថាប័នសិក្សាស្រាវជ្រាវ, អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុក និងស្ថាប័នផ្តល់ជំនួយ ដែលមានឆន្ទះក្នុងការជម្រុញការកសាងសមត្ថភាព។ បអសជួយជ្រោមជ្រែង និងគ្រប់គ្រងគម្រោងសិក្សាស្រាវជ្រាវ ដែលមានគោលបំណងក្នុងការធ្វើឲ្យប្រសើរឡើងនូវស្តុក និងគុណភាពនៃការសិក្សាស្រាវជ្រាវ ដែលពាក់ព័ន្ធនឹងគោលនយោបាយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងក្នុងអន្តរកាល។

ការកសាងសមត្ថភាពសិក្សាស្រាវជ្រាវជាដំណើរការវែងឆ្ងាយ និងពាក់ព័ន្ធកត្តាជាច្រើន។ ដើម្បីសម្រេចគោលដៅរបស់ខ្លួន បអសជួយជ្រោមជ្រែងកម្មវិធីសិក្សាស្រាវជ្រាវ ដែលមានបំណងក្នុងការបង្កើតការសិក្សាស្រាវជ្រាវ ដែលពាក់ព័ន្ធនឹងគោលនយោបាយ និងមានគុណភាពខ្ពស់ ដើម្បីស្វែងរកវិធីក្នុងការប្រែក្លាយការសិក្សាស្រាវជ្រាវទៅជាអត្ថបទបោះពុម្ព អត្ថបទពិភាក្សា សន្និសិទ សិក្ខាសិលា ឬមធ្យោបាយផ្សព្វផ្សាយ ក៏ដូចជាការជជែកពិភាក្សាពីគោលនយោបាយ និងដំណើរការបង្កើតគោលនយោបាយ។

សន្និសិទស្តីអំពីការអភិវឌ្ឍសាកលប្រចាំឆ្នាំរបស់ **(បអស)** ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំនៅតំបន់ផ្សេងៗ និងមានប្រធានបទផ្សេងៗ។ សន្និសិទស្តីអំពីការអភិវឌ្ឍសាកលប្រចាំឆ្នាំនេះផ្តល់ដល់អ្នកសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ឱកាសដ៏កម្រ ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកសិក្សាស្រាវ ជ្រាវដទៃ និងជាមួយអ្នកសិក្សាស្រាវជ្រាវល្បីៗនៅក្នុងបរិបទសាកលមួយ ដែលមានប្រយោជន៍ដល់ការផ្លាស់ប្តូរគំនិតសិក្សា និងគោលនយោបាយ។

# ក្រុមស្រាវជ្រាវ

លោក ឮ សុវចនា គឺជាអនុប្រធានផ្នែកស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយនៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព។ លោកមានសញ្ញាបត្រអនុបណ្ឌិតផ្នែកកម្មវិធីសិក្សា និង សញ្ញាបត្របង្រៀនភាសាអង់គ្លេសមកពីទីក្រុង Portland រដ្ឋ Oregon នៃសហរដ្ឋអាមេរិក។ លោកបានបង្រៀនផ្នែកក្រមសីលធម៌ និងវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៣។ លោកបាននិពន្ធសៀវភៅជាច្រើនរួមមានដូចជា "សំឡេងនៃការផ្លាស់ប្តូរក្នុងកម្ពុជា" "សន្តិសុខមនុស្ស និងសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា" ជាមួយនឹងអ្នកស្រី Alice Beban (CICP 2015)។ លោកក៏បានបោះពុម្ពជំពូកផ្សេងៗគ្នាក្នុងសៀវភៅជាច្រើន និងអត្ថបទជាច្រើនទៀតដែលទាក់ទងជាមួយនឹងការអភិវឌ្ឍ នៅក្នុងប្រទេសកម្ពុជា ពាក់ព័ន្ធវិស័យអប់រំ និងសន្តិសុខមនុស្សផងដែរ។ ចំណាប់អារម្មណ៍ផ្នែកស្រាវជ្រាវរបស់លោករួមមាន ការអភិវឌ្ឍធនធានមនុស្ស សន្តិសុខមនុស្សជាតិ ការកសាងសហគមន៍ សង្គមវប្បធម៌ និងសន្តិសុខ នយោបាយក្នុងតំបន់អាស៊ីអាគ្នេយ៍។

លោក សុខ សេរី គឺជាសាស្ត្រាចារ្យពេញម៉ោងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកគឺជាសាស្ត្រាចារ្យ ធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលសិក្សាវិទ្យាសាស្ត្រ និង Ecology នៃសាកលវិទ្យាល័យ Washington នៅទីក្រុង Seattle សហរដ្ឋអាមេរិក ហើយលោកជាអ្នកប្រាជ្ញមួយរូបដែលបានធ្វើទស្សនកិច្ចនៅសាកលវិទ្យាល័យ Europe កណ្តាល នៃទីក្រុង Budapest ក្នុងប្រទេស Hungary។ លោកបានចូលរួមនៅក្នុងការស្រាវជ្រាវលើវិស័យជាច្រើន ហើយក៏បានបម្រើការងារជាអ្នកផ្តល់យោបល់ផ្នែកបច្ចេកទេស និងគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួនផងដែរ។ បច្ចុប្បន្ននេះលោកគឺជាទីប្រឹក្សាគាំទ្រដល់ការស្រាវជ្រាវ និងផ្នែក SPSS នៃសមាគមជាងត្នោត ហើយលោកក៏បានផ្តល់នូវការប្រឹក្សាយោបល់ជាច្រើនសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនផងដែរ។ លោកគឺជាអ្នកដឹកនាំការស្រាវជ្រាវគម្រោងស្រាវជ្រាវជាច្រើនក្នុងពេលបច្ចុប្បន្ននេះរួមមានដូចជា៖ "ការវិនិយោគវិស័យកសិកម្មរបស់ប្រទេសចិននៅក្នុងប្រទេសកម្ពុជា"ឱកាស និងបញ្ហាប្រឈមក្នុងការកាត់បន្ថយភាពក្រីក្រដែលគម្រោងនេះផ្តោតលើ ជាមួយនឹងមូលនិធិរបស់អង្គការ Oxfam ហុងកុង និងគម្រោង "ការអភិវឌ្ឍជីវភាពរស់នៅ និងការចូលរួមជាសាធារណៈនៅក្នុងការគ្រប់គ្រងវិស័យជលផលនៅក្នុងអាងទន្លេមេគង្គក្រោម៖ ដែលជាការសិក្សារូបភាពក្នុងចំណោមនិគមជនជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសឡាវ" ដែលគម្រោងនេះផ្តល់មូលនិធិដោយអង្គការទឹក ដី និងប្រព័ន្ធ Ecology៖ "ឧបករណ៍សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងទឹកទន្លេមេគង្គឆ្លងដែន និងធនធានទឹកនៅក្នុងប្រទេសកម្ពុជានិងប្រទេសឡាវ" ដែលផ្តល់មូលនិធិដោយអង្គការ UNESCO KEIZOOBUCHI Research fellowships។ លោកសុខ សេរី បានទទួលសញ្ញាបត្របណ្ឌិតពីសាកលវិទ្យាល័យហុងកុង Baptist (ទីក្រុងហុងកុងឆ្នាំ២០១៣)។ សម្គាល់៖លោកបណ្ឌិត សុខ សេរី បានលាលែងចេញពីតំណែង

ជាអ្នកអង្កេតសំខាន់មួយរូបនៅខែ តុលា ឆ្នាំ២០១៥ ដោយសារតែលោកត្រូវទទួលខុសត្រូវលើការងារក្នុងពេលបច្ចុប្បន្ន និងទទួលខុសត្រូវលើគ្រួសាររបស់លោក ។

លោកស្រី Courtney Work គឺជាអ្នកស្រាវជ្រាវជាន់ខ្ពស់ម្នាក់នៅវិទ្យាស្ថានសម្រាប់ការអភិវឌ្ឍ និងសន្តិភាពចាប់តាំងពីខែមករា ឆ្នាំ២០១៤មក។ លោកស្រីគឺជាអ្នកស្រាវជ្រាវជាន់ខ្ពស់ថ្នាក់ក្រោយបណ្ឌិតសម្រាប់គម្រោង Mosaic ដែលស្ថិតនៅក្រោមការត្រួតពិនិត្យតាមរយៈមជ្ឈមណ្ឌលដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពស្ថិតនៅតំបន់មួយនៅសាកលវិទ្យាល័យឈាងម៉ៃក្នុងប្រទេសថៃ និងតាមរយៈវិទ្យាស្ថានសិក្សាសង្គម នៃសាកលវិទ្យាល័យ ERASMUS នៅទីក្រុងឡាអេ។ លោកស្រីបានបញ្ចប់សញ្ញាបត្របណ្ឌិតនៅសាកលវិទ្យាល័យ Cornell ឆ្នាំ២០១៤ ដែលនៅទីនោះលោកស្រីបានបង្រៀនវគ្គដូចខាងក្រោម ៖ នរវិទ្យាសាសនា នរវិទ្យាអភិវឌ្ឍន៍ និងការសរសេរបែបស្រាវជ្រាវចាប់តាំងពី ឆ្នាំ២០០៧ ដល់ឆ្នាំ២០១៤។ លោកស្រីបានបោះពុម្ពអត្ថបទនៅក្នុងព្រឹត្តិបត្រស្រាវជ្រាវមួយចំនួននៅក្នុងផ្នែកសិក្សានៅអាស៊ីអាគ្នេយ៍ សាសនា និងការអភិវឌ្ឍ ហើយលោកស្រីបានសរសេរជំពូកសៀវភៅចំនួនពីរ ហើយក៏បានសរសេរនៅក្នុងឯកសារសន្និសីទជាច្រើន ដែលកំពុងរង់ចាំការបោះពុម្ពផ្សាយ។ ចំណាប់អារម្មណ៍ស្រាវជ្រាវរបស់លោកស្រីរួមមាន ផ្នែកនរវិទ្យាសាសនា ការអភិវឌ្ឍ និងបរិស្ថាន ប្រវត្តិសាស្ត្រនៃការបង្កើតនយោបាយនៅក្នុងអាស៊ីអាគ្នេយ៍ សេដ្ឋកិច្ចនយោបាយសហសម័យ និងការសិក្សាអំពីរំហូរប្រជាជននៅក្នុងតំបន់ និងអំណាចនៅអាស៊ីអាគ្នេយ៍។

លោកស្រី **Alice Beban** បានចាប់ផ្តើមធ្វើដំណើរ និងធ្វើការងារនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ២០០៥ ហើយបានធ្វើការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាស្តីអំពីគម្រោងកសិកម្មសរីរាង្គ និងការអភិវឌ្ឍកសិកម្មសរីរាង្គ ការឆ្លើយតបកម្រិតមូលដ្ឋានចំពោះការទទួលបានដីធ្លី និងកំណែទ្រង់ដីធ្លី។ លោកស្រីទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកសិក្សាអភិវឌ្ឍន៍អន្តរជាតិមកពីសាកលវិទ្យាល័យ MASSEY ក្នុងប្រទេសនូវែលសេឡង់។ បច្ចុប្បន្ន លោកស្រីគឺជាបេក្ខជនបណ្ឌិតនៅសាកលវិទ្យាល័យ Cornell ក្នុងទីក្រុង New York ផ្នែកសង្គមវិទ្យាអភិវឌ្ឍន៍។ ស្នាដៃថ្នាក់បណ្ឌិតរបស់លោកស្រីពិនិត្យមើលទៅលើការជាប់ពាក់ព័ន្ធនៃកំណែទម្រង់ដីធ្លីសម្រាប់បុរស និងស្ត្រីនៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា។ លោកស្រីបានសិក្សាស្រាវជ្រាវនៅក្នុងវិទ្យាស្ថានខ្មែរសម្រាប់កិច្ចសហប្រតិបត្តិការ និងសន្តិភាពដោយធ្វើការនៅក្នុងគម្រោងដែលទទួលបានមូលនិធិពីអង្គការ JICA ស្តីអំពីការយល់ឃើញអំពីសន្តិសុខមនុស្សជាតិ ហើយលោកស្រីកំពុងធ្វើការស្រាវជ្រាវមួយទាក់ទងនឹងគម្រោងដែលទទួលបានមូលនិធិ នៃការិយាល័យបរទេសរបស់ចក្រភពអង់គ្លេសស្តីអំពីសន្តិសុខ មនុស្ស និងសិទ្ធដីធ្លី។ លោកស្រីក៏បានចំណាយពេលវេលាជាច្រើនឆ្នាំធ្វើការក្នុងប្រទេសផ្សេងៗក្នុងទ្វីបអាស៊ី ហើយលោកស្រីក៏ជាអ្នកធ្វើការសិក្សាស្រាវជ្រាវក្នុងនាមជាមន្ត្រីគម្រោងសម្រាប់អង្គការមិនមែនរដ្ឋាភិបាលមួយក្នុងប្រទេស NewZealand ដោយបានធ្វើការសិក្សាស្រាវជ្រាវអំពីបញ្ហាយុត្តិធម៌សង្គម និងបរិស្ថាននៅក្នុងតំបន់ Pacific នៅទ្វីបអាស៊ី។

លោក **Kevin Nauen** គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រសង្គម និងទំនាក់ទំនងអន្តរជាតិ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ។ លោកមានសញ្ញាបត្រអនុបណ្ឌិតផ្នែកមនោគមវិទ្យា និងការវិភាគ ការពិភាក្សាមកពី ESSEX ហើយលោកបានបង្រៀននៅសាកលវិទ្យាល័យរដ្ឋនៅក្នុងទីក្រុង New York នៅសាកលវិទ្យាល័យ Binghamton និងសាកល វិទ្យាល័យNorthern Arizona ។ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ លោកមានឯកទេសលើមុខវិជ្ជាមួយចំនួនដូចជា៖ សិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ប្រជាធិបតេយ្យនិយតកម្ម សាកលភាវូបនីយកម្ម និង សេដ្ឋកិច្ច និងទ្រឹស្តីនយោបាយ។ លោកក៏ជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មួយរូបនៅ CICP ដែលលោកបានរួមចំណែកដល់គម្រោងស្តីអំពីការទទួលខុសត្រូវក្នុងការការពារ និងកំណែទម្រង់វិស័យសន្តិសុខ។ ការស្រាវជ្រាវថ្មីៗ នាពេលបច្ចុប្បន្នរបស់លោកផ្តោតទៅលើគណនេយ្យភាពសង្គម និងភាពជាមិត្តចាស់ នៃកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ។

លោក **ឃុន ជារ៉ា** ជាអ្នកស្រាវជ្រាវនៅ CICP ហើយនាពេលបច្ចុប្បន្នលោកពុងបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈនៅសាកលវិទ្យាល័យជាតិ Australia ក្នុងប្រទេស Australia។ លោកទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកសិក្សាអន្តរជាតិ និងបញ្ចប់ការសិក្សាដោយចំណាត់ថ្នាក់កិត្តិយសពី ដេប៉ាតឺម៉ង់សិក្សាអន្តរជាតិនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយលោកបានបញ្ចប់ផ្នែកច្បាប់មកពីសាកលវិទ្យាល័យកម្ពុជាក្នុង ឆ្នាំ២០១២។ ក្នុងរយៈពេល៤ ឆ្នាំចុងក្រោយនេះ លោក **ឃុន ជារ៉ា** បានធ្វើការជាអ្នករាយការណ៍ស្តីអំពីកិច្ចការបរទេស និងនយោបាយ សម្រាប់វិទ្យុសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ពេលថ្មីៗនេះ លោកត្រូវបានតែងតាំងជាមន្ត្រីស្រាវជ្រាវផ្នែកនយោបាយនៅស្ថានទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា។ លោកបាននិពន្ធនិងរួមនិពន្ធសៀវភៅជាច្រើន អត្ថបទបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រស្រាវជ្រាវ ឯកសារស្រាវជ្រាវ និងការបោះពុម្ពផ្សាយតាមប្រព័ន្ធអ៊ីនធើណិតដែលទាក់ទងនឹងបញ្ហាជាច្រើនដូចជា យុត្តិធម៌អន្តរកាល របបប្រល័យពូជសាសន៍ ខ្មែរក្រហម ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយ និងកំណែទម្រង់ប្រព័ន្ធ ផ្សព្វផ្សាយ សន្តិសុខតំបន់ ការអភិវឌ្ឍ នយោបាយ និងសេដ្ឋកិច្ច និងទំនាក់ទំនង អន្តរជាតិផងដែរ។

# មាតិកា


បុព្វកថា....................................................................................................1

អារម្ភកថា.................................................................................................. 2

សេចក្តីថ្លែងអំណរគុណ...................................................................................4

សេចក្តីសង្ខេប............................................................................................... 5

១.សេចក្តីផ្តើម.................................................................................................17

បញ្ហាប្រឈម ........................................................................................... 18

វិសាលភាពនៃការស្រាវជ្រាវ.......................................................................... 19

តួអង្គសំខាន់ៗ...............................................................................................20

គោលបំណង និងសំណួរ.................................................................................20

ការសង្ខេបរបកគំហើញសំខាន់ៗ ................................................................ 21

អតុល្យភាពយេនឌ័រ.......................................................................................22

គោលដៅរបស់ម្ចាស់ជំនួយបានរារាំងរាជរដ្ឋាភិបាល .......................................23

សិក្ខាសាលាដែលចែករំលែកផ្សព្វផ្សាយទិន្នន័យប៉ុន្តែមិនបានកសាងសមត្ថភាព ......................23

រដ្ឋាភិបាលមិនមានគោលបំណងធ្វើការស្រាវជ្រាវដូចអ្នកស្រាវជ្រាវនិងនិស្សិតទេ......................24

កិច្ចសហការរវាងស្ថាប័នឧត្តមសិក្សានិងអង្គការសង្គមស៊ីវិលដែលស្នើឡើងដោយភាគីទាំងពីរ.....24

បញ្ហាមូលនិធិ និងសមត្ថភាពមិនសូវមានភាពខុសគ្នាទេ....................................24

ការចាប់យកគោលនយោបាយពឹងផ្អែកទៅលើការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ.......................25

២.ក្របខ័ណ្ឌបញ្ញត្តិ និងវិធីសាស្ត្រស្រាវជ្រាវ ...........................................................26

គោលបំណងនៃការស្រាវជ្រាវ ........................................................................26

ក្របខ័ណ្ឌបញ្ញត្តិ៖ សកម្មភាពដែលមានចំណងភ្ជាប់គ្នាទៅវិញទៅមកចំនួនបី..........................26

ការសិក្សាស៊ីជម្រៅ .........................................................................................27

វិធីសាស្ត្រ.......................................................................................................29

វិធីសាស្ត្របង្កើតសំណើ ..................................................................................30

សម្រាប់គ្រឹះស្ថានឧត្តមសិក្សាសំណាករ...........................................................30

សម្រាប់សង្គមស៊ីវិលសំណាក ........ 31
សម្រាប់ក្រុមពិចារណាសំណាក ........ 32
ក្រសួងរបស់រាជរដ្ឋាភិបាលសំណាក ........ 32
សម្រាប់អង្គការម្ចាស់ជំនួយសំណាក ........ 32
ទិន្នន័យ និងឧបករណ៍សម្រាប់ស្ទង់មតិ ........ 34
ភាពកំហិតនៃការរចនាការស្រាវជ្រាវ ........ 36
៣.ការស្រាវជ្រាវឯកសារដែលមានស្រាប់ ........ 41
សង្គមស៊ីវិល ........ 41
បញ្ញត្តិគន្លឹះ ........ 43
មូលដ្ឋានគ្រឹះប្រវត្តិសាស្ត្រ ........ 44
ការធ្វើការបែងចែកតាមប្រភេទ និងការរួមវិភាគទាន ........ 47
សង្គមស៊ីវិលកំពុងផ្លាស់ប្តូររបត់ ........ 52
ឧត្តមសិក្សា ........ 64
ប្រវត្តិនៃការអភិវឌ្ឍឧត្តមសិក្សាក្នុងប្រទេសកម្ពុជា ........ 65
និន្នាការ និងសមាសធាតុស្ថាប័ននាពេលបច្ចុប្បន្ន ........ 69
៤.ស្រាវជ្រាវកម្រិតម៉ាក្រូលើបរិស្ថានវិទ្យាសាស្ត្រសង្គម ........ 73
ទិដ្ឋភាពទូទៅរបស់គោលនយោបាយស្រាវជ្រាវជាផ្លូវការ និងការតភ្ជាប់ជាមួយការ អនុវត្ត ........ 73
គោលនយោបាយតាមវិស័យរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ........ 74
ក្រសួងផែនការ ........ 77
ម្ចាស់ជំនួយ ........ 87
អង្គការក្រៅរដ្ឋាភិបាល / អង្គការសង្គមស៊ីវិល ........ 88
៥.កត្តាដែលលើកកម្ពស់ ឬរារាំងការងារស្រាវជ្រាវ ........ 100
តើការស្រាវជ្រាវត្រូវបានគេឱ្យតម្លៃ ឬអត់នៅប្រទេសកម្ពុជា? ........ 100
ការផ្តល់មូលនិធិ ........ 104
មូលនិធិនៃការស្រាវជ្រាវដែលអាចរកបាន ........ 104

កង្វះនៃការផ្តល់មូលនិធិនៅតែជាបញ្ហាប្រឈមចម្បងសម្រាប់អ្នកស្រាវជ្រាវភាគច្រើន ............ 105
ប្រាក់បៀវត្សរ៍ និងការលើកកម្ពស់ ............ 108
ការលើកទឹកចិត្តអ្នកស្រាវជ្រាវ ............ 109
ភាពលេចធ្លោនៃការស្រាវជ្រាវជាភាសាអង់គ្លេស ............ 111
សមត្ថភាពក្នុងការបង្កើតការស្រាវជ្រាវ ............ 112
បញ្ហាប្រឈមនៃការកែប្រែសមត្ថភាពក្នុងបរិស្ថានការងារស្រាវជ្រាវ ............ 112
ការបន្លំ និងលួចចម្លងជាបញ្ហាដែលប៉ះពាល់ក្នុងការអភិវឌ្ឍសមត្ថភាព ............ 114
ការអភិវឌ្ឍសមត្ថភាពរបស់អង្គការសង្គមស៊ីវិល (CSOs) ............ 115
គំនិតផ្តួចផ្តើមថ្មីរបស់មជ្ឈដ្ឋានខាងក្រៅ និងក្នុងស្រុកដើម្បីអភិវឌ្ឍសមត្ថភាព ............ 116
ទំហំការងារ ............ 119
ការរក្សាទុក ............ 121
បញ្ហាប្រឈមក្នុងការធានាឱ្យបាននូវគុណភាពនៃការស្រាវជ្រាវ ............ 122
គុណភាពទិន្នន័យ និងគោលការណ៍ណែនាំនៃក្រមសីលធម៌ ............ 122
ភាពរសើបផ្នែកនយោបាយ ............ 124
ការធ្វើទិនានុប្បវត្តិទិន្នន័យស្ថិតិនៅបណ្ណាល័យ និងធនធានគេហទំព័រ ............ 128
៦.ចំណុចសំខាន់ និងលក្ខណៈនៃការស្រាវជ្រាវ ............ 130
ប្រភេទនៃការស្រាវជ្រាវដែលបានធ្វើរួចរាល់នៅស្ថាប័នមួយចំនួន ............ 130
ចំណាប់អារម្មណ៍ក្នុងការស្រាវជ្រាវ ............ 134
ការស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ............ 136
ការពិគ្រោះយោបល់រយៈពេលខ្លីសម្រាប់ការស្រាវជ្រាវ ............ 137
បំណងប្រាថ្នារបស់ក្រុមអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ............ 138
ការសហការ ការដឹកនាំ ការស្រាវជ្រាវ និងវត្តមាននៃក្រុមអ្នកស្រាវជ្រាវ ............ 139
កិច្ចសហប្រតិបត្តិការអន្តរជាតិ ............ 142
ករណីសិក្សា៖ ការបណ្តុះបណ្តាលបរិស្ថានស្រាវជ្រាវ-រឿងរ៉ាវទាក់ទងនឹងអ្នកស្រាវជ្រាវពីនាក់ .. 143
៧.ការយល់ដឹងពីសារៈប្រយោជន៍នៃការស្រាវជ្រាវ ............ 146

ទស្សនៈរបស់និស្សិតទៅលើការស្រាវជ្រាវ ...... 146
ការយល់ឃើញរបស់និស្សិតជាច្រើន ...... 146
ការយល់ឃើញក្នុងបណ្ដាស្ថាប័នពាក់ព័ន្ធ ...... 147
សេចក្ដីសន្និដ្ឋាន ...... 149
៨. ការផ្សព្វផ្សាយ និងនីតិច្បាប់នៃការភ្ជាប់ទំនាក់ទំនងទៅការសិក្សាស្រាវជ្រាវសង្គម ...... 150
គេហទំព័រ Online ...... 150
ការបោះពុម្ពផ្សាយ ...... 151
ការបោះពុម្ពផ្សាយរក្សាទុកនៅផ្ទះ ...... 154
សិក្ខាសាលា/សន្និសីទ ...... 155
ការផ្សព្វផ្សាយស្រាវជ្រាវជាអន្តរជាតិ ...... 157
សក្ដានុពលនៃការស្រូបយកគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ...... 159
ករណីសិក្សានៃការស្រាវជ្រាវដើម្បីអន្តរកម្មគោលនយោបាយ និងផលប៉ះពាល់ ...... 162
សេចក្ដីបញ្ចប់ ...... 165
៩. អនុសាសន៍ពីអ្នកចូលរួមរបស់យើង ...... 167
ការលើកទឹកចិត្តលើការស្រាវជ្រាវ ...... 168
ការបង្កើនឱកាសក្នុងការទទួលបានពីឃ្លាំងផ្ទុកទិន្នន័យ អក្សរសិល្ប៍ និងឯកសារសិក្សាស្រាវជ្រាវ ...... 170
ការពង្រឹងកិច្ចសហការ ...... 171
ការសហការគ្នាតាមសាកលវិទ្យាល័យ ...... 171
ការបង្កើតស្តង់ដារថ្នាក់ជាតិក្នុងការស្រាវជ្រាវ ...... 173
១០.មតិយោបល់សម្រាប់ការសិក្សាស្រាវជ្រាវបន្ថែម ការអភិវឌ្ឍ និងការពង្រឹងសមត្ថភាព ...... 177
១១. សេចក្ដីបញ្ចប់ ...... 180
ឯកសារយោង ...... 184
Appendix ...... 189

# បុព្វកថា

វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និង សន្តិភាព (Cambodian Institute for Cooperation and Peace) មានសេចក្តីសោមនស្សរីករាយដែលបានចូលរួមបោះពុម្ព និងបកប្រែសៀវភៅ **ការស្រាវជ្រាវនៅកម្ពុជា៖ បង្កើតគំរូដែលកសាងសមត្ថភាព** (Doing Research in Cambodia: Making Models that Build Capacity) ជាភាសាខ្មែរ ក្រោមជំនួយឧបត្ថម្ភដោយ **បណ្តាញអភិវឌ្ឍន៍សាកល** (Global Development Network) ។

វិទ្យាស្ថានយល់ឃើញថា សៀវភៅនេះពិតជាមានសារៈសំខាន់ណាស់ដល់ស្ថាប័នរដ្ឋ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត និង វិទ្យាស្ថាននានាទាំងអស់នៅគ្រប់ទីកន្លែង ដើម្បីឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅពីស្ថានភាពបច្ចុប្បន្ន ដោយពឹងផ្អែកទៅលើទិន្នន័យជាក់ស្តែង ចៀសវាងបណ្តាពាក្យចចាមអារ៉ាម និងការឃោសនាមិនពិត។ និស្សិតកម្ពុជាក៏មានឱកាសយល់ដឹងនូវវិធីសាស្ត្រស្រាវជ្រាវ និងការប្រមូលទិន្នន័យ ឬយកទិន្នន័យនេះទុកធ្វើជាអំណះអំណាង។ ចំពោះសាស្ត្រាចារ្យនៅគ្រប់វិទ្យាស្ថានទាំងអស់ក៏អាចចូលរួមចែករំលែកផ្សព្វផ្សាយពីសារៈសំខាន់ទាំងអស់នៅក្នុងសៀវភៅនេះ ទៅដល់និស្សិត ជំនាន់ក្រោយនៅក្នុងវិទ្យាស្ថានដើម្បីធ្វើឱ្យសង្គមមានពន្លឺ ភ្លឺថ្លាជាងនេះទៅទៀតបានផងដែរ។

វិទ្យាស្ថានសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **បណ្តាញអភិវឌ្ឍន៍សាកល** (Global Development Network) ដែលបានផ្តល់ការឧបត្ថម្ភជាជំនួយក្នុងការងារបកប្រែ និងបោះពុម្ពសៀវភៅដ៏សំខាន់នេះ។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ អ្នកគ្រូ **សាយ ពុទ្ធី** លោកគ្រូ **សុខ លាំង** និង លោក **គង្គ សំភីវឌ្ឍនៈ** លោក **ផុន សុគង់** និងលោក **សោម សារុន** ជាអ្នកបកប្រែ និងកែសម្រួលរាល់កំហុសឆ្គងទាំងអស់នៅក្នុងសៀវភៅ **ការស្រាវជ្រាវនៅកម្ពុជា៖ បង្កើតគំរូដែលកសាងសមត្ថភាព** នេះប្រកបដោយជោគជ័យ។

វិទ្យាស្ថានយល់ឃើញថា ការបកប្រែនេះនៅមានការខ្វះចន្លោះចំពោះអត្ថន័យដែលពុំបានគ្រប់ជ្រុងជ្រោយនៅឡើយជាក់ជាមិនខាន។ អាស្រ័យហេតុនេះ វិទ្យាស្ថានសូមអភ័យទោសជាមុន ចំពោះការខ្វះចន្លោះដែលអាចកើតមានឡើងដោយថាហេតុក្នុងការបកប្រែនេះ។ ចំពោះអត្ថបទនៃសៀវភៅនេះ លោកអ្នក និង មិត្តអ្នកអាន ទាំងអស់អាចទាញយកបានតាមរយៈគេហទំព័រ www.cicp.org.kh ។

**ពូ សុវចនា**

ប្រធានក្រុមអ្នកស្រាវជ្រាវ<br>
វិទ្យាស្ថានខ្មែរសម្រាប់សប្រតិបត្តិការ និងសន្តិភាព

# អារម្ភកថា

វិធីសាស្ត្រដ៏សំខាន់មួយក្នុងចំណោមវិធីសាស្ត្រសំខាន់ៗជាច្រើនក្នុងការជួយឱ្យសាធារណជនបានយល់អំពីភាពខុសគ្នា រវាងពាក្យចចាមអារ៉ាម និងការពិតរវាងការឃោសនា និងទិន្នន័យរឹងផ្តល់ឱ្យពួកគាត់នូវលទ្ធភាពមួយក្នុងការធ្វើការស្រាវជ្រាវ ដែលមានសុពលភាព និងដើម្បីចែករំលែកនូវបេកគំហើញ បែបវិទ្យាសាស្ត្រទាំងអស់នេះនៅក្នុងសង្គម។ Shakespheare បានសរសេរថា ការពិតកើតឡើងពីការស្រាវជ្រាវដោយខ្លួនឯង ។ តាមន័យនេះ យើងត្រូវដឹងការពិតអំពីសង្គមរបស់យើងមុនពេលដែលយើងអាចស្គាល់ខ្លួនរបស់យើងច្បាស់ និងស្គាល់ជាតិរបស់យើងច្បាស់។ សរុបមក ប្រទេសកម្ពុជាត្រូវបានគេចាត់ថ្នាក់នៅក្នុងកម្រិតយ៉ាងទាបមួយទាក់ទងជាមួយនឹងនវានុវត្តន៍។ បើយោងតាមគម្រោងស្រាវជ្រាវមួយរបស់សាកលវិទ្យាល័យខលណែល INSEAD និង WIPO ក្នុងឆ្នាំ២០១៤ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី១០៦ ក្នុងចំណោមប្រទេសចំនួន ១៤៣ ទាក់ទងនឹងការកម្រិតនៃនវានុវត្តន៍។ លើសពីនេះទៅទៀត ការចំណាយ របស់រដ្ឋាភិបាលកម្ពុជាទៅលើការស្រាវជ្រាវនិងការអភិវឌ្ឍមានកម្រិតតិចទាបបំផុតគឺ0,០៥% នៃ GDP ត្រូវបានផ្តល់សម្រាប់បុព្វហេតុមួយនេះពីចន្លោះពីឆ្នាំ២០០០ ដល់ឆ្នាំ២០១០ (ធនាគារពិភពលោក២០១៣)។ កម្រិតទាបនៃការច្នៃប្រឌិតនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈចំនួនអ្នកស្រាវជ្រាវ ដែលមានតិចតួចនៅក្នុងប្រទេសកម្ពុជា។ ចំនួននេះត្រូវបានគេកំណត់ថាមានចំនួនអ្នកស្រាវជ្រាវតែ ១៧ នាក់ប៉ុណ្ណោះ សម្រាប់មនុស្ស១លាននាក់ នៃចន្លោះ រវាងឆ្នាំ ២០០០ ដល់ឆ្នាំ ២០១០ ។ សរុបមក និស្សិតដែលបានបញ្ចប់ការសិក្សានៅក្នុងប្រទេសកម្ពុជាមានការខ្វះខាតជំនាញផ្នែកបច្ចេកទេសនិងការគិតបែបត្រិះរិះពិចារណា ហើយការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជាស្ថិតក្នុងសភាពដែលត្រូវធ្វើតាមម្ចាស់ជំនួយជាច្រើននៅឡើយ (Kwok et al ., 2010)។ ដូច្នេះដើម្បីដំណើរការ ដើម្បីជាឧត្តមប្រយោជន៍របស់ខ្លួនយើងផ្ទាល់ យើងត្រូវប្រមូលព័ត៌មានដែលគួរឱ្យទុកចិត្តបានពីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ពីសហគមន៍ស្រាវជ្រាវដើម្បីកំណត់ជាគ្រឹះរបស់សង្គមដែលមិនមានការភ័យខ្លាចក្នុងការប្រឈមមុខជាមួយនឹងការពិត ដែលមិនស្រួលក្នុងចិត្ត។

គម្រោងស្រាវជ្រាវនេះ ស្វែងរកនូវសកម្មភាពស្រាវជ្រាវដែលធ្វើឡើងដោយគ្រឹះស្ថាន ឧត្តមសិក្សាអង្គការមិនមែនរដ្ឋាភិបាល និងក្រុមអ្នកគិតគូរពិចារណាព្រមទាំងពិនិត្យទៅលើកត្តាបុគ្គល និងកត្តាស្ថាប័នដែលមានឥទ្ធិពលទៅលើវប្បធម៌ធ្វើការស្រាវជ្រាវលើវិទ្យាសាស្ត្រសង្គម នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ ការសិក្សាលម្អិតមួយនេះ បានប្រើប្រាស់ជាដំបូងនូវវិធីសាស្ត្រដ៏ល្អមួយនៅក្នុង ការស្រាវជ្រាវ ដោយរួមបញ្ចូលទាំងសមាសធាតុដែលទាក់ទងជាមួយ (ការស្រាវជ្រាវបែបសកម្មភាព) ដែលមានការពាក់ពន្ធ័ជាមួយនឹងការបណ្តុះបណ្តាល និស្សិតកម្ពុជាវ័យក្មេង ដើម្បីជួយនៅក្នុងការរចនា ការស្រាវជ្រាវ និងការប្រមូលទិន្នន័យ ព្រមទាំងការបង្កើតនូវប្រព័ន្ធទិន្នន័យអន្តរកម្មថ្នាក់ជាតិមួយ និងសហគមន៍តាមប្រព័ន្ធអ៊ីនធើណិតមួយ ដែលនាំយកនូវអ្នកប្រាជ្ញជាច្រើនឱ្យបានមកជួបជុំ

គ្នា ដើម្បីសហប្រតិបត្តិការ ជាមួយគ្នា និង ចែករំលែកនូវការបោះពុម្ពផ្សាយ ព្រមទាំងឱកាសនៃការស្រាវជ្រាវ យើងក៏បានប្រើប្រាស់នូវវិធីសាស្ត្រដែលមានចម្រុះវិធី ដោយរួមបញ្ចូលទាំងការធ្វើការស្ទង់មតិ ការសម្ភាស និងការពិភាក្សា ហើយជាក្រុមដែលចេញមុខពីប្រភពចម្រុះគ្នាជាច្រើនដូចជា គ្រឹះស្ថានឧត្តមសិក្សា អង្គការមិនមែនរដ្ឋាភិបាល ក្រសួងរបស់រដ្ឋាភិបាលសំខាន់ៗ ក្រុមអ្នកគិតពិចារណា និងអង្គការម្ចាស់ជំនួយធំៗជាច្រើនដើម្បីបង្ហាញពន្យល់អំពីបញ្ហាប្រឈម និងឱកាសនៅក្នុងបរិបទដ៏ពិសេសមួយនៅក្នុងប្រទេសកម្ពុជា។ លទ្ធផលរបស់យើងបង្ហាញថា បរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាគឺកំពុងស្ថិតនៅដំណាក់កាលអន្តរកាល។ ការស្រាវជ្រាវពីមុនភាគច្រើននៅលើប្រធានបទនេះបានប្រើប្រាស់គុណវិធីបែបគុណវិស័យជាច្រើនទាំងស្រុង ដោយរួមមានភាគច្រើនជាករណីសិក្សា។ គម្រោងស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រចម្រុះ ដើម្បីទទួលបាននូវទិន្នន័យបែបគុណវិស័យ ព្រមទាំងធ្វើការពិនិត្យមើល ឆ្លងគ្នាទៅលើរបកគំហើញទាំងអស់នេះ ដោយប្រើប្រាស់ការវិភាគទិន្នន័យបែបបរិមាណវិស័យ ដែលការធ្វើបែបនេះអាចអនុញ្ញាតឱ្យយើងទាញបាននូវសេចក្តីសន្និដ្ឋាប្រកបដោយអត្ថន័យ ដែលមានការគាំទ្រពីទិន្នន័យដ៏ធំ។

យើងមានមោទនភាពក្នុងការលើកយករបាយការណ៍មួយនេះមកបង្ហាញ ដែលមានចំណងជើងថាការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជ៖ការបង្កើតនូវគម្រោងមួយដែលកសាងសមត្ថភាព ដោយក្តីសង្ឃឹមថា ការស្រាវជ្រាវនេះនឹងដើរតួនាទីជាជំហានមួយ និងជាគ្រឹះមួយសម្រាប់អនាគតអ្នកស្រាវជ្រាវជំនាន់ក្រោយនៅក្នុងប្រទេសកម្ពុជា។ ភាពវែងនៃរបាយកាណ៍មួយនេះគឺជះឥទ្ធិពលមកពីការសម្រេចចិត្តនៅ ក្នុងការបញ្ចូលសម្រង់ឃ្លាសម្តីរបស់អ្នកឆ្លើយតបដែលមានលក្ខណៈស៊ីជម្រៅដែលផ្តល់ឱ្យយើងនូវការយល់ដឹងដ៏រឹងមាំមួយអំពីបរិយាកាសស្រាវជ្រាវនាពេលបច្ចុប្បន្ន ក៏ដូចជាអនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែមទៀត ព្រមទាំងអនុសាសន៍សម្រាប់គំនិតផ្តួចផ្តើមផ្សេងៗផ្នែកគោលនយោបាយ។ វាជាក្តីសង្ឃឹមរបស់យើងដែលថា គម្រោងស្រាវជ្រាវមួយនេះនឹងរួមចំណែកដល់បរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាដែលកំពុងស្ថិតនៅក្នុងដំណាក់កាលអន្តរកាលនេះ ដោយរាប់បញ្ចូលទាំងការលើកទឹកចិត្តឱ្យមានការបណ្តុះ បណ្តាល ការផ្តល់មូលនិធិ និងឱកាសនៅក្នុងការចងបណ្តាញក្នុងចំណោមអ្នកស្រាវជ្រាវទាំងឡាយដើម្បីឱ្យអ្នកស្រាវជ្រាវវ័យក្មេងមិនត្រឹមតែអាចគិតថាការស្រាវជ្រាវគឺជាតម្រូការផ្នែកសិក្សាប៉ុណ្ណោះទេ តែវាថែមទាំងជាឱកាសមួយសម្រាប់ការគិតបែបច្នៃប្រឌិត និងការគិតដែលមានលក្ខណៈឯករាជ្យថែមទៀតផង។

# សេចក្តីថ្លែងអំណរគុណ

គម្រោងស្រាវជ្រាវនេះមិនអាចកើតមានឡើងបានទេ ប្រសិនបើគ្មានការគាំទ្រដោយសប្បុរសពីសាធារណជន និងស្ថាប័នជាច្រើនទេនោះ។ ក្រុមស្រាវជ្រាវសូមសម្តែងនូវអំណរគុណដោយក្តីស្មោះស្ម័គ្រចំពោះអង្គការបណ្តាញអភិវឌ្ឍន៍សាកល (GDN) ក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុ និងវិទ្យាស្ថានសម្រាប់ការកិច្ចសហប្រតិបត្តិការ និងសន្តិភាព (CICP) សម្រាប់ការគាំទ្រដ៏មានតម្លៃក្នុងការធ្វើការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់បែបនេះ ឱ្យក្លាយទៅជាការពិត។

ក្រុមស្រាវជ្រាវក៏សូមសម្តែងនូវកតញ្ញូតាធម៌ ដោយស្មោះអស់ពីដួងចិត្ត ដល់អ្នកឆ្លើយតបសំណួរច្រើនជាង៤៦៣នាក់ដែលរួមមាន សាកលវិទ្យាធិការសាកលវិទ្យាល័យ សាកលវិទ្យាធិការរងព្រឹទ្ធបុរស នាយក អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ សិស្ស មន្ត្រីក្រសួង វិទ្យាស្ថានស្រាវជ្រាវ ម្ចាស់ជំនួយសំខាន់ៗ និងតំណាងសង្គមស៊ីវិលដែលស្ម័គ្រចិត្តក្នុងការផ្តល់នូវគំនិត និងមតិយោបល់ដ៏មានប្រយោជន៍ និងចែករំលែកនូវការយល់ឃើញដ៏មានតម្លៃរបស់ពួកគាត់ទាក់ទងនឹងការអនុវត្តនាពេលបច្ចុប្បន្ននេះស្តីអំពីការធ្វើការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។ យើងក៏សូមថ្លែងអំណរគុណជាពិសេសផងដែរដល់សិស្ស និស្សិតទាំងអស់ដែលបានទទួលការបណ្តុះបណ្តាល ក្នុងនាមជាអ្នកជំនួយការអ្នកស្រាវជ្រាវ និងសូមថ្លែងអំណរគុណដល់អ្នកហាត់ការរបស់អង្គការ CICP នៅក្នុងការជួយជ្រោមជ្រែងក្នុងការស្ទង់មតិ ការសម្ភាស ការប្រមូលទិន្នន័យ ការបកប្រែ និងការវិភាគទិន្នន័យរួមជាមួយនឹងការចម្លងចេញពីការថតសំឡេងជាដើម។ ជាចុងក្រោយ សូមសម្តែងនូវការដឹងគុណចំពោះអ្នកគ្រប់គ្នាដែលបានចូលរួមការសិក្សាស្រាវជ្រាវនេះ ជាពិសេសដល់បណ្ណាធិការ អ្នកបកប្រែជាភាសាខ្មែរ និងដល់ទីប្រឹក្សាពីខាងក្រៅ ដែលបានចំណាយពេលវេលាដ៏មមាញឹករបស់ខ្លួនក្នុងការផ្តល់ជាមតិយោបល់ទៅលើរបាយការណ៍ និងទៅលើបេកគំហើញទាំងអស់នេះ។

# សេចក្តីសង្ខេប

"ការស្រាវជ្រាវបានបង្ហាញលទ្ធផលមួយដែលមានឥទ្ធិពលដល់សង្គម។ វាមិនត្រឹមតែជាការងាររបស់បុគ្គលម្នាក់ប៉ុណ្ណោះទេ តែវាក៏អាចជារបាយការណ៍របស់សង្គមមួយផងដែរ។ រាល់ពេលដែលគម្រោងស្រាវជ្រាវធ្វើចប់សព្វគ្រប់ យើងនឹងអាចដឹងថាការស្រាវជ្រាវពិតជាមានឥទ្ធិពលឱ្យគ្នាទៅវិញទៅមកបានយ៉ាងច្បាស់"។

*(សិស្សស្រី នៅភ្នំពេញ)*

នេះបើតាមការលើកឡើងរបស់និស្សិតវិទ្យាស្ថានភាសាបរទេសនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ យើងប្រើប្រយោគនេះដើម្បីសរសេរសេចក្តីសង្ខេបរបស់យើង ព្រោះវាបានគូសបញ្ជាក់នូវចំណុចសំខាន់ៗមួយចំនួននៃរបាយការណ៍នេះ។ ជាដំបូងគឺសិស្ស និស្សិត និងក្រុមអ្នកស្រាវជ្រាវមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការងារស្រាវជ្រាវ ហើយពួកគេក៏មានការយល់ដឹងពីតម្លៃនៃការស្រាវជ្រាវដែរ។ តាមការពិតក្នុងការកត់ត្រារបស់យើងនៅពេលធ្វើការសម្ភាសនោះ បានផ្តោតជាសំខាន់លើការពិភាក្សាជាក្រុម និងការស្ទង់មតិដែលផ្ទុយពីការបង្ហាញអារម្មណ៍ពិតរបស់អ្នកគ្រប់គ្រង និងមន្ត្រីនៅក្រសួងមួយចំនួនដែលបានលើកឡើងថា និស្សិតមិនឱ្យតម្លៃឬចាប់អារម្មណ៍លើការស្រាវជ្រាវនោះទេ។ គម្លាតរវាងក្រុមអ្នកស្រាវជ្រាវវ័យក្មេង និងអ្នកគ្រប់គ្រងដែលមានវ័យចំណាស់នេះ ធ្វើឱ្យអ្នកបង្កើតគោលនយោបាយមួយចំនួនបង្ហាញថា វាគឺជារបត់នៃការផ្លាស់ប្តូរក្នុងបរិស្ថានស្រាវជ្រាវមួយ។ ស្របពេលដែលការបណ្តុះបណ្តាលការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គម ការផលិត និងការផ្សព្វផ្សាយនៅកម្ពុជានៅមានកម្រិត របាយការណ៍នេះបានជំរុញម្ចាស់ជំនួយឱ្យបង្កើតកម្មវិធីមួយចំនួន ប៉ុន្តែក៏មានគំនិតផ្តួចផ្តើមបន្ថែមទៀតដើម្បីឱ្យមានការអភិវឌ្ឍចាប់តាំងពីថ្នាក់មូលដ្ឋានទៅដែរ។

រដ្ឋមន្ត្រី និងអ្នកគ្រប់គ្រងនៅកម្ពុជាមួយចំនួន ទម្លាប់រស់នៅជាមួយទីកន្លែងដែលមិនសូវឱ្យតម្លៃលើការងារស្រាវជ្រាវ សមត្ថភាពនៅមានកម្រិតទាប ហើយនិស្សិតក៏មិនចាប់អារម្មណ៍ធ្វើការងារនេះដែរ។ ប៉ុន្តែអ្វីដែលយើងបានរកឃើញនោះគឺក្រុមនិស្សិតដែលមានភាពសកម្ម ក៏ដូចជាក្រុមអ្នកស្រាវជ្រាវដែលគួរឱ្យចាប់អារម្មណ៍មួយក្រុម បានជំរុញឱ្យថ្នាក់ដឹកនាំរបស់នាយកដ្ឋានមានភាពច្នៃប្រឌិត រួមទាំងសាកលវិទ្យាធិការដែលមានបំណងនិងបានឱ្យតម្លៃលើការស្រាវជ្រាវហើយនោះ ធ្វើការស្រាវជ្រាវមួយប្រកបដោយសុចរិតភាព។

សេចក្តីផ្តើមខាងលើពិតជាមានសារៈសំខាន់ក្នុងការធ្វើដំណើរឆ្ពោះទៅរកការកសាងមូលដ្ឋានគ្រឹះដែលយើងមានស្រាប់ហើយនោះ។ ការស្រាវជ្រាវរបស់យើងបានបង្ហាញពីភាពរីកលូតលាស់នៃវិស័យអប់រំ និងការចាប់អារម្មណ៍របស់សមាជិកមហាវិទ្យាល័យ ដែលមានបំណងចូលរួមក្នុងសកម្មភាព

ស្រាវជ្រាវទាំងនោះ ប៉ុន្តែពួកគេមានបន្ទុកការងារច្រើន ហើយរចនាសម្ព័ន្ធរបស់ស្ថាប័នទើបតែចាប់ផ្តើមធ្វើការលើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវប៉ុណ្ណោះ។ ការសិក្សារបស់យើងក៏បានរកឃើញផងដែរ ពីភាពរស់រវើកនៃការស្រាវជ្រាវក្នុងវិស័យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែលបានផ្តល់មូលនិធិសម្រាប់បណ្តុះបណ្តាលការស្រាវជ្រាវ ក៏ដូចជាការកសាងសមត្ថភាព។ នៅក្នុងបរិស្ថាននៃការផ្លាស់ប្តូរនេះ យើងបានកំណត់អត្តសញ្ញាណនៃការអប់រំជាច្រើន ហើយប្រជាជនកម្ពុជាបានត្រៀមខ្លួនរួចជាស្រេចក្នុងការខិតខំប្រឹងប្រែងចែករំលែកការស្រាវជ្រាវ។ បញ្ហាប្រឈមនោះគឺទាក់ទងនឹងការផ្សារភ្ជាប់ពួកគេជាមួយនឹងឱកាសក្នុងការទទួលបានមូលនិធិ ការសហការ និងការកសាងសមត្ថភាពដើម្បីកាត់បន្ថយការិយាធិបតេយ្យ។

ការពិតទៅ សេចក្តីផ្តើមខាងលើនេះត្រូវបានលើកឡើងដោយស្ត្រីម្នាក់ ក្នុងគោលបំណងដើម្បីឱ្យមានការផ្លាស់ប្តូរបរិស្ថាននៃការស្រាវជ្រាវនៅកម្ពុជា។ សមាសភាពនៃអ្នកចូលរួមក្នុងការស្រាវជ្រាវរបស់យើងបានបង្ហាញពីភាពលម្អៀងទៅខាងបុរសយ៉ាងខ្លាំង នេះបើតាមការលើកឡើងទាក់ទងនឹងការសម្ភាស ឬការស្ទង់មតិនៅគ្រឹះស្ថានឧត្តមសិក្សាដែលមិនមានអ្នកឆ្លើយតបជាស្ត្រីណាម្នាក់នោះ។ សរុបមក បុរសដែលមាន សញ្ញាបត្រមកពីបរទេសគឺហាក់ដូចជាមានការទទួលស្គាល់ច្រើនក្នុងចំណោមអ្នកស្រាវជ្រាវនៅកម្ពុជា។ ភាពលម្អៀងនេះបានបង្ហាញពីភាពមិនស្មើគ្នាទាក់ទងនឹងការចូលរួមដំណើរការក្នុងការងាររដ្ឋបាលជាន់ខ្ពស់ និងការទទួលបានតំណែងក្នុងមហាវិទ្យាល័យ។ មួយវិញទៀត ពួកគេក៏មិនទទួលស្គាល់ជំនាញដែលផ្តល់ឱ្យស្ត្រី និងការអប់រំអ្នកស្រាវជ្រាវនៅកម្ពុជាដែរ។ ការសិក្សាទៅលើនិស្សិតមួយក្រុម មានតុល្យភាពយេនឌ័រនៅក្នុងក្រុម ហើយស្ត្រីវ័យក្មេងៗបានចូលរួមបញ្ចេញចំណាប់អារម្មណ៍របស់គេយ៉ាងពេញទំហឹង បន្ទាប់ពីពួកគេត្រូវបានស្ថាប័ន និងមិត្តភក្តិរបស់ខ្លួនទទួលស្គាល់។ បញ្ហាប្រឈមដែលកើតឡើងពាក់ព័ន្ធនឹងវិសមភាពយេនឌ័របានបង្ហាញពីស្ថានភាពពិតមួយសម្រាប់ក្រុមអ្នកស្រាវជ្រាវជាស្ត្រីនៅកម្ពុជា ប៉ុន្តែការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពស្រាវជ្រាវកំពុងមានការកើនឡើង ហើយត្រូវបានគេផ្តោតសំខាន់បន្ថែមទៀតដែរ។

ទិដ្ឋភាពផ្សេងទៀតនៃបរិស្ថានស្រាវជ្រាវមិនមានការផ្លាស់ប្តូរទេ។ ទាំងអស់នេះគឺជាបញ្ហាដែលនាំឱ្យមានការលំបាកក្នុងការចាប់យកទិន្នន័យ។ សម្រង់ពាក្យសម្តីខាងលើ ពិតជាមានន័យសំខាន់ណាស់ ដែលអាចឱ្យអ្នកផ្សេងទៀតចាប់យកការស្រាវជ្រាវនោះ មួយវិញទៀតវាក៏បានឆ្លុះបញ្ចាំងនូវភាពមិនពេញចិត្តនានារបស់ក្រុមអ្នកស្រាវជ្រាវនៅកម្ពុជាផងដែរ។ លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថាវាមិនមែនជាឯកសារឯកជនដែលប្រើប្រាស់សម្រាប់តែក្នុងក្រសួងរដ្ឋាភិបាល ឬសម្រាប់តែ "មនុស្សជាន់ខ្ពស់នោះប៉ុណ្ណោះទេ" វាក៏ជាទិនានុប្បវត្តិនៃការសិក្សាផងដែរ។ការស្រាវជ្រាវគឺជាសកម្មភាពសាធារណៈ ដែលបើកចំហនូវរាល់ទិន្នន័យទាំងឡាយ ហើយគុណភាពនៃការស្រាវជ្រាវត្រូវបានគេផលិតបានគ្រប់ទីកន្លែង។

បន្ថែមពីលើការខ្វះខាតគុណភាពក្នុងចំណោមក្រុមអ្នកស្រាវជ្រាវនៅកម្ពុជា ក៏មានចំណុចខ្វះខាតមួយចំនួនក្នុងកម្រិតស្ថាប័នទាក់ទងនឹងការវាយតម្លៃគោលនយោបាយ និងប្រសិទ្ធភាពរបស់គុណភាពនៃការស្រាវជ្រាវរបស់ពួកគេដែរ។ ក្នុងគោលនយោបាយលម្អិតរបស់ក្រសួងអប់រំ និងគ្រឹះស្ថានឧត្តមសិក្សា យើងមិនឃើញមានយន្តការដឹកនាំការស្រាវជ្រាវណាដែលនាំឱ្យស្ថាប័នទាំងនោះធ្វើការវាយតម្លៃដោយខ្លួនឯងនោះទេ។ ក្នុងករណីមួយចំនួនបានបង្ហាញយ៉ាងច្បាស់ថា មិនសូវមានការអនុវត្តលើគោលនយោបាយដែលមានស្រាប់ឡើយ ព្រោះពួកគេមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការងារនេះ។ មានការស្រាវជ្រាវដ៏ត្រឹមត្រូវមួយបានធ្វើឡើងក្នុងស្ថានភាពជាក់ស្តែងក្នុងសង្គម ហើយអាចជួយក្នុងការបង្កើតគោលនយោបាយដែលនាំឱ្យយើងទទួលបាន ក៏ដូចជាកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមួយចំនួននៃការបរាជ័យ។ លើសពីនេះទៅទៀត គោលនយោបាយដែលផ្តោតលើការស្រាវជ្រាវជាសំខាន់នឹងបង្ហាញលទ្ធផលល្អក្នុងការបែងចែកមូលនិធិដើម្បីចប់យកអ្វីដែលយើងចង់បាន។

គុណភាពនៃការស្រាវជ្រាវជាបញ្ហាមួយដែលមានសារៈសំខាន់ ពិសេសក្នុងបរិបទកម្ពុជា។ តាមរយៈការសិក្សារបស់យើងបានបង្ហាញជាតុផ្សំសំខាន់ៗចំនួនបីដែលបន្តកើតមានក្នុងការរារាំងគុណភាពនៃការស្រាវជ្រាវ។ បញ្ហាដំបូងនោះគឺទាក់ទងនឹងការកំណត់ពេលវេលាដែលមានរយៈពេលខ្លីក្នុងកិច្ចផ្តួចផ្តើមធ្វើការស្រាវជ្រាវដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយអន្តរជាតិ។ គម្រោងទាំងនេះអាចធ្វើឡើងចាប់ពីមួយខែទៅប្រាំឆ្នាំ និងមានការព្រួយបារម្ភខ្លាំងពីម្ចាស់ជំនួយក្នុងការចំណាយរបស់ក្រុមអ្នកស្រាវជ្រាវ និងការបង្កើតសំណួរផ្សេងៗ។ ឧបសគ្គទីពីរដែលនាំឱ្យធ្វើការស្រាវជ្រាវនោះគឺទាក់ទងនឹងអង្គការម្ចាស់ជំនួយដោយពឹងផ្អែកលើការពិគ្រោះយោបល់។ ជាទូទៅ អ្នកពិគ្រោះយោបល់មានការវិនិយោគតិចតួចណាស់ក្នុងគម្រោងស្រាវជ្រាវ ហើយជាញឹកញាប់ពួកគេមិនត្រូវបានគេដាក់ឈ្មោះក្នុងរបាយការណ៍ទាំងនោះទេ។ បញ្ហានេះវាមិនត្រឹមតែមានផលប៉ះពាល់ដល់គុណភាពនៃការស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបានរាំងស្ទះដល់ការកសាងសមត្ថភាពអ្នកស្រាវជ្រាវក្នុងស្រុកទៀតផង។ ឧបសគ្គទីបីគឺស្ថិតលើភាពគ្របដណ្តប់នៃភាសាអង់គ្លេសក្នុងបរិស្ថានការស្រាវជ្រាវដែលធ្វើឱ្យក្រុមអ្នកស្រាវជ្រាវមួយចំនួនអាចបោះបង់ចោលការផ្សព្វផ្សាយលទ្ធផលទៅកាន់សហគមន៍ នៅពេលដែលធ្វើតែភាសាអង់គ្លេសមួយមុខនោះ។

ការផ្សារភ្ជាប់ការផ្សព្វផ្សាយការស្រាវជ្រាវ និងគោលនយោបាយការស្រាវជ្រាវនៅមានកំណត់។ យើងបានបែងចែកវិធីសាស្ត្រដែលមានប្រសិទ្ធភាពជាបីប្រភេទសម្រាប់ជំរុញឱ្យមានទំនាក់ទំនងរវាងការស្រាវជ្រាវ និងគោលនយោបាយ។ ដំបូងនោះគឺការតស៊ូមតិ និងការផ្សព្វផ្សាយជាសាធារណៈពីភាពមិនគ្រប់គ្រាន់នៃគោលនយោបាយ ដោយផ្អែកលើភ័ស្តុតាងជាក់ស្តែងដែលបានប្រមូលតាមរយៈការស្រាវជ្រាវជាបឋមនោះ។ នេះជាវិធីសាស្ត្ររបស់អង្គការមិនមែនរដ្ឋាភិបាល។ វិធីសាស្ត្រដែលមានប្រសិទ្ធភាពទីពីរនោះគឺរក្សាមិត្តភាពជាមួយអ្នកបង្កើតគោលនយោយបាយ និងផ្តល់ឱ្យពួកគេនូវការ

ស្រាវជ្រាវណាដែលអាចប្រើប្រាស់បាន ប៉ុន្តែមិនត្រូវប្រកួតប្រជែងគោលបំណងរបស់ពួកគេទេ។ វាគឺជាវិធីសាស្ត្ររបស់ក្រុមអ្នកជំនាញ។ វិធីសាស្ត្រទីបីនោះគឺរួមបញ្ចូលអ្នកធ្វើគោលនយោបាយជាមួយមូលនិធិ ហើយក៏គួរតែផ្តល់ឱ្យពួកគេនូវការស្រាវជ្រាវណាដែលមិនប្រកួតប្រជែងជាមួយគោលបំណងរបស់ពួកគេដែរ។ នេះជាវិធីសាស្ត្ររបស់ម្ចាស់ជំនួយ។ ជាទូទៅ គ្រឹះស្ថានឧត្តមសិក្សាមានទំនាក់ទំនងទន់ខ្សោយយ៉ាងខ្លាំងជាមួយអ្នកធ្វើគោលនយោបាយ។ ប្រព័ន្ធផ្សព្វផ្សាយសង្គមបានកែលម្អសមត្ថភាពដើម្បីផ្សព្វផ្សាយការស្រាវជ្រាវ។ អ្នកស្រាវជ្រាវមួយចំនួនបានបោះពុម្ពផ្សាយ ឬធ្វើបទបង្ហាញការងាររបស់ពួកគេ ប៉ុន្តែការធ្វើទំនាក់ទំនងជាមួយក្រុមអ្នកបង្កើតគោលនយោបាយនៅមានកម្រិតទាបខ្លាំង។

អង្គសិក្ខាសាលា គឺជាយានមួយដ៏សំខាន់ក្នុងការស្វែងរកការស្រាវជ្រាវ ក្រៅពីភាគីពាក់ព័ន្ធ និងអ្នកបង្កើតគោលនយោបាយ។ទោះបីជាពួកគេមិនទទួលបានលទ្ធផលដូចដែលគេចង់បានក្តី ក៏ពួកគេបានទទួលការបណ្តុះបណ្តាល និងការកសាងសមត្ថភាពដែរ។ ខណៈពេលដែលការធ្វើសិក្ខាសាលាមានការចំណាយប្រាក់តិច និងប្រើប្រាស់កម្លាំងពលកម្មតិចដែរនោះ ពួកគេមិនបានធ្វើអ្វីឱ្យចេញជាលទ្ធផលទេ ដោយសារតែពួកគេខ្វះបទពិសោធន៍ក្នុងការទទួលយកការរៀនសូត្រទាំងនោះ។ ការធ្វើការស្រាវជ្រាវនេះអាចកសាងសមត្ថភាពបាន(CDRI:FD)។ និស្សិតមានការយល់ដឹងអំពីបញ្ហានេះ ហើយក៏បានបញ្ជាក់ដែរថា ការជំរុញឱ្យធ្វើការស្រាវជ្រាវគឺជា "ការផ្ទេរពីទ្រឹស្តីទៅជាការអនុវត្តជាក់ស្តែង" (SRU:SRT)។ អ្នកស្រាវជ្រាវវ័យក្មេងកម្ពុជា ដែលទទួលបានការបណ្តុះបណ្តាលវិធីសាស្ត្រនៃសកម្មភាពរបស់ពួកគេក្នុងការស្រាវជ្រាវបានបញ្ជាក់ពីបញ្ហានេះ។ ការផ្តល់ជូននូវមធ្យោបាយនានា ដល់សិស្ស និស្សិតដើម្បីធ្វើការអនុវត្តលើគម្រោងនៃការស្រាវជ្រាវបានបង្ហាញថា វាជាការលើកទឹកចិត្តដល់យុវវ័យឱ្យចូលរួមក្នុងសកម្មភាពស្រាវជ្រាវ ដែលអាចជួយកសាងក្រុមអ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀតបាន។ ដូចដែលការលើកឡើងរបស់និស្សិតមួយក្រុមក្នុងកិច្ចពិភាក្សាតុមូលបានប្រាប់យើងថា "បន្ទាប់ពីបានចូលរួមក្នុងកិច្ចពិភាក្សាតុមូល និស្សិតមួយចំនួនមានឆន្ទៈធ្វើការងារស្រាវជ្រាវ" (SRU:SRT)។

## ចំណុចមួយចំនួនដែលយើងបានរកឃើញ

**វិធីស្រាវជ្រាវ៖** អ្នកជំនាញក្នុងការប្រើប្រាស់វិធីសាស្ត្រវាស់ស្ទង់គុណភាពសម្រាប់ការស្រាវជ្រាវបានឱ្យក្រុមស្រាវជ្រាវរបស់យើងចូលរួមយ៉ាងសកម្មក្នុងការបង្កើតគំនិតច្នៃប្រឌិតនៃបរិស្ថានស្រាវជ្រាវយ៉ាងរស់រវើក។ ដំណើរការនេះតម្រូវឱ្យមានការសហការគ្នាបន្ថែមទៀត រវាងតួអង្គសំខាន់ៗក្នុងសហគមន៍ស្រាវជ្រាវនេះ។

**ដំណើរការផ្លាស់ប្តូរនៃបរិស្ថាន៖** តាមរយៈការពិភាក្សាដ៏ជិតស្និទ្ធមួយរវាងនិស្សិត និងក្រុមអ្នកស្រាវជ្រាវបានបង្ហាញពីភាពផ្ទុយគ្នាក្នុងការវាយតម្លៃរបស់អ្នកគ្រប់គ្រងមួយចំនួន ហើយពួកគេមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការងារស្រាវជ្រាវ។ វាបានបង្ហាញពីភាពផ្លាស់ប្តូរចាប់ពីថ្នាក់ក្រោមឡើងទៅ

លើ។ ប៉ុន្តែការកើនឡើងក្នុងការទទួលយកភាពសម្បូរបែបនៃទិដ្ឋភាពក្នុងទីសាធារណៈ និងការបង្កើនការឆ្លើយតបរបស់អ្នកបង្កើតគោលនយោបាយ ជាអត្ថប្រយោជន៍ដល់ការស្រាវជ្រាវ ហើយនៅតែបន្តមានការលើកឡើងជាសំណួរពីវិស័យសង្គមស៊ីវិល ការសិក្សា និងយុវជន។

**វិទ្យាស្ថានកម្ពុជាមាន "ការស្រេកឃ្លានក្នុងការស្រាវជ្រាវ " គ្រូបង្រៀន៖** ការផ្លាស់ប្តូរដែលយើងមើលឃើញគឺជាផ្នែកចម្រុះគ្នាក្នុងការអប់រំសម័យបច្ចុប្បន្ន។ ប្រជាជនកម្ពុជាភាគច្រើនដែលបានទៅសិក្សានៅក្រៅប្រទេសតែងតែត្រឡប់មកវិញជាមួយការអប់រំដែលមានកម្រិតខ្ពស់ ហើយមានស្ថាប័នឯកជនជាច្រើនអញ្ជើញពួកគាត់ឱ្យទៅបង្រៀនក្នុងសាលារបស់គេ។ ពួកគាត់ជាអ្នកដែលមានបំណងចង់ធ្វើការស្រាវជ្រាវ។

**អតុល្យភាពយេនឌ័រ៖** ការស្រាវជ្រាវរបស់យើងបានបង្ហាញពីអានុភាពនៃភាពមិនស្មើគ្នាទាក់ទងនឹងបញ្ហាយេនឌ័រ។ ចំនួនសិស្សស្រីដែលចុះឈ្មោះនាពេលបច្ចុប្បន្នមានតិច។

**គោលបំណងរបស់ម្ចាស់ជំនួយរារាំងការស្រាវជ្រាវ៖** គម្រោងដែលប្រើពេលខ្លី និងមានវត្ថុបំណងជាក់លាក់វាពិតជារារាំងដល់ការស្រាវជ្រាវ។លើសពីនេះទៅទៀត អ្នកពិគ្រោះយោបល់ក្នុងការស្រាវជ្រាវក៏មានគំនិតអវិជ្ជមានលើបរិស្ថាននៃការស្រាវជ្រាវក្នុងតំបន់ដែរ។ ម្ចាស់ជំនួយត្រូវតែរកវិធីដើម្បីធ្វើការបង្ហាញប្រាប់តាមរយៈការនិយាយ ឬការសរសេរដែលមានខ្លឹមសារគ្រប់គ្រាន់ទាក់ទងនឹងការផ្លាស់ប្តូរដែលសង្កត់ធ្ងន់លើលទ្ធផល ទៅជាការផ្តល់អាទិភាពដល់លទ្ធផល ហើយក៏គួរតែទទួលយកសញ្ញាបត្រក្នុងតំបន់ទាក់ទងនឹងការអភិវឌ្ឍកម្មវិធីដែរ។

**សិក្ខាសាលាផ្សព្វផ្សាយទិន្នន័យ ប៉ុន្តែមិនបានកសាងសមត្ថភាពទេ៖**សិក្ខាសាលាជាមធ្យោបាយដ៏ល្អមួយក្នុង ការទទួលបានការស្រាវជ្រាវពីភាគីពាក់ព័ន្ធនិងអ្នកបង្កើតគោលនយោបាយ។ ប៉ុន្តែចំពោះការបណ្តុះបណ្តាលនិងការកសាងសមត្ថភាព ពួកគេមិនបានធ្វើវានោះទេ។ សកម្មភាពនៃការស្រាវជ្រាវជាមួយកម្មវិធីអនុវត្តន៍ និងបទពិសោធន៍នៃលទ្ធផលដែលទាក់ទងនឹងគម្រោងស្រាវជ្រាវជាក់លាក់ គឺត្រូវការដោះស្រាយជាចាំបាច់។

**រដ្ឋាភិបាលមិនបានចែករំលែកគោលបំណងនៃការស្រាវជ្រាវដូចគ្នាជាមួយអ្នកស្រាវជ្រាវ និងនិស្សិតទេ៖** រដ្ឋាភិបាល (និងម្ចាស់ជំនួយ)ឧបត្ថម្ភដល់ការស្រាវជ្រាវដែលបានបង្ហាញនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងដល់ការស្រាវជ្រាវពាក់ព័ន្ធនឹងអាជីវកម្ម និងកសិកម្ម។ ចំនែកឯនិស្សិត និងក្រុមអ្នកស្រាវជ្រាវបានបង្ហាញការចាប់អារម្មណ៍ក្នុងការកែលម្អទិដ្ឋភាពសង្គម។ ទាំងនេះវាបានបង្ហាញពីកង្វះខាតនៃការប្តេជ្ញាចិត្តរួមមួយ ដើម្បីអភិវឌ្ឍស្តង់ដារស្រាវជ្រាវ ដែលជាកាតព្វកិច្ចរបស់ HEIs ហើយវាបានឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃការអភិវឌ្ឍការស្រាវជ្រាវរយៈពេលវែងដែរ។

**ការលើកឡើងរបស់គ្រឹះស្ថានឧត្តមសិក្សា / អង្គការសង្គមស៊ីវិលទាក់ទងនឹងកិច្ចសហការ៖**

វាជាទម្លាប់ទៅហើយដែលសង្គមស៊ីវិលអនុវត្តការស្រាវជ្រាវ ហើយសាកលវិទ្យាល័យមិនធ្វើការងារនេះ។ ប៉ុន្តែនៅកម្ពុជា ទាំងអង្គការមិនមែនរដ្ឋាភិបាលនិងអ្នកសិក្សាស្រាវជ្រាវបានទទួលយកការប្រមូលធនធានដែលមានកម្រិតទាំងនោះ ដើម្បីកសាងសមត្ថភាពក្នុងការងារស្រាវជ្រាវ។

**ការផ្តល់មូលនិធិ និងបញ្ហាសមត្ថភាពមានភាពលាយឡំគ្នា៖** ភាពខ្វះខាតថវិកាសម្រាប់សកម្មភាពស្រាវជ្រាវគឺជាប្រធានបទច្បាស់លាស់មួយក្នុងការសម្ភាសរបស់យើង។ ប៉ុន្តែគម្រោងនៃការស្រាវជ្រាវមិនត្រូវបានគេយកមកប្រតិបត្តិនោះទេ បើទោះបីជាមានថវិកាហើយក្តី។ ក្នុងរបាយការណ៍របស់យើងមានការពិភាក្សាលើកត្តាជាច្រើនទាក់ទងនឹងបាតុភូតនេះ។ វិធីសាស្រ្តថ្នាក់ក្រោមទៅថ្នាក់ខ្ពស់ បានធ្វើការវាយតម្លៃលើសមត្ថភាពនៃការស្រាវជ្រាវដែលបានផ្តល់សិទ្ធិទៅឱ្យសមាជិកក្នុងសហគមន៍ស្រាវជ្រាវ ខណៈដែលលទ្ធផលនៃកិច្ចចរចាបានកំណត់មូលដ្ឋានគ្រឹះបន្ថែមរវាងកិច្ចសហការជាមួយសមាជិករបស់ខ្លួននោះ។ ការពង្រឹងអំណាចដែលកើតចេញពីឥរិយាបថ ហាក់បីដូចជាឧបសគ្គក្នុងការស្រាវជ្រាវមួយដែលមានភាពទាក់ទងគ្នា និងងាយផ្លាស់ប្តូរនៅពេលដែលមានទស្សនៈផ្សេងៗទៀតលើកឡើងក្នុងសហគមន៍ការស្រាវជ្រាវនោះ។ មួយវិញទៀតទម្លាប់នៃការស្តីបន្ទោស និងភាពអសកម្មក្នុងការកសាងសមត្ថភាព វាអាចធ្វើឱ្យមានភាពគ្រោះថ្នាក់ដល់ប្រទេសជាតិ ស្ថាប័ន និងបុគ្គលខ្លួនឯងផ្ទាល់ដែរ។

**ការទទួលយកគោលនយោបាយត្រូវពឹងផ្អែកលើការផ្សព្វផ្សាយការស្រាវជ្រាវ**

តាមការសិក្សារបស់យើងបានបង្ហាញពីវិធីសាស្រ្តដែលមានប្រសិទ្ធភាពចំនួនបី ដើម្បីបង្កើនទំនាក់ទំនងរវាងគោលនយោបាយ និងការស្រាវជ្រាវ៖ វិធីសាស្រ្តរបស់អង្គការក្រៅរដ្ឋាភិបាល វិធីសាស្រ្តរបស់ក្រុមអ្នកជំនាញ និងវិធីសាស្រ្តរបស់ម្ចាស់ជំនួយ។ វិធីសាស្រ្តនីមួយៗមានប្រសិទ្ធភាព និងមានភាពគ្រប់គ្រាន់រៀងៗខ្លួន។

# អនុសាសន៍

អ្នកដែលត្រូវបានគេសម្ភាស និងអ្នកដែលបានចូលរួមក្នុងការស្ទង់មតិទាំងអស់ត្រូវបានគេសួរសំណួរមួយចំនួនដើម្បីជាការផ្ដល់អនុសាសន៍ក្នុងការកែលម្អការស្រាវជ្រាវនៅកម្ពុជា។ សរុបមកអនុសាសន៍ភាគច្រើនអាចត្រូវបានគេបំបែកទៅជាបីប្រភេទ៖

**សកម្មភាពរបស់រដ្ឋ៖** រដ្ឋអាចដើរតួនាទីក្នុងការបង្កើតស្តង់ដារស្រាវជ្រាវ ចំណាត់ថ្នាក់ តម្រូវការសម្រាប់ការផលិតការស្រាវជ្រាវនៅកម្រិតសាកលវិទ្យាល័យ និងបទពិសោធន៍នៃការស្រាវជ្រាវនៅសាលាបឋមសិក្សា ក៏ដូចជាមធ្យមសិក្សា។ លើសពីនេះទៀតពួកគេអាចផ្តល់នូវធនធានហិរញ្ញវត្ថុតាមរយៈការប្រកួតប្រជែងមូលនិធិថ្នាក់ជាតិ។

**សកម្មភាពរបស់សាកលវិទ្យាល័យ៖** សាកលវិទ្យាល័យអាចជំរុញការស្រាវជ្រាវតាមរយៈការផ្តល់តំណែងពេញម៉ោងសម្រាប់អ្នកជំនាញធ្វើការស្រាវជ្រាវ មូលនិធិ ហើយពួកគេអាចជួយជំរុញឱ្យមានការសហការគ្នារវាងសាកលវិទ្យាល័យ ជាមួយអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអាជីវកម្ម និងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗផងដែរ។ មួយវិញទៀត សាកលវិទ្យាល័យអាចផ្តល់ឱកាសបន្ថែមទៀតដល់អ្នកស្រាវជ្រាវដូចជា ការចូលរួមសិក្ខាសាលា វគ្គបណ្ដុះបណ្ដាលនានា ដែលអាចជួយពួកគេក្នុងការរៀបចំវិភាគការស្រាវជ្រាវ និងសមត្ថភាពភាសាអង់គ្លេស។ ពួកគេអាចបង្កើតគោលនយោបាយល្អៗ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានទាំងឡាយទាក់ទងនឹងសកម្មភាពរបស់ពួកគេផ្ទាល់។

**សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល៖** ដើម្បីកាត់បន្ថយការពឹងផ្អែកលើអ្នកពិគ្រោះយោបល់មកពីខាងក្រៅអង្គការមិនមែនរដ្ឋាភិបាលបានធ្វើការបណ្ដុះបណ្ដាលបុគ្គលិករបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលអាចបង្កើនគុណភាពនៃបណ្តាញរបស់ខ្លួន ដើម្បីសម្រេចបាននូវលទ្ធផលល្អប្រសើរក្នុងការទាញយកគោលនយោបាយ ហើយក៏មានការសម្របសម្រួលបន្ថែមទៀតជាមួយគ្រឹះស្ថានឧត្តមសិក្សា HEIs (បង្វែរការប្រកួតប្រជែងទាក់ទងនឹងធនធានមនុស្ស ទៅជាការបណ្តុះការសហការនៃធនធានមនុស្ស)។ អង្គការមិនមែនរដ្ឋាភិបាលគួរតែមានបំណងកាត់បន្ថយការជំរុញរបស់ម្ចាស់ជំនួយទាក់ទងនឹងអត្ថប្រយោជន៍នៃការស្រាវជ្រាវ ហើយធ្វើឱ្យមានភាពប្រសើរឡើងក្នុងការសហការជាមួយភ្នាក់ងាររដ្ឋាភិបាល ដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការវិភាគលើគោលនយោបាយ។ផ្អែកលើការសិក្សាស្រាវជ្រាវដែលយើងបានរកឃើញ យើងនឹងចែករំលែកនូវអនុសាសន៍ដូចខាងក្រោម៖

### *រដ្ឋជាម្ចាស់ជំនួយ និងអង្គការ*

- បង្កើតគម្រោងរយៈពេលវែងដែលពិតជាអាចកសាងសមត្ថភាពតាមរយៈភាពស៊ីសង្វាក់គ្នា និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ គម្រោងទាំងនេះត្រូវតែរួមបញ្ចូលទាំងប្រាក់ខែសម្រាប់អ្នកស្រាវជ្រាវក្នុងតំបន់ និងមុខតំណែងជាអ្នកជួយបង្ហាត់បង្ហាញ។

- ជាទូទៅ ការគាំទ្រគឺត្រូវការចាំបាច់ណាស់ ប៉ុន្តែដើម្បីធ្វើដូច្នេះបាន ម្ចាស់ជំនួយត្រូវតែកែលម្អការសម្របសម្រួលរបស់ខ្លួន។ សកម្មភាពរបស់ម្ចាស់ជំនួយអាចបំពេញទៅបាន និងអាចកសាងសមត្ថភាពស្ថាប័នទាំងនោះ ដើម្បីសម្រេចបានលទ្ធផលរយៈពេលវែង បើទោះបីជាមានគម្រោងរយៈពេលខ្លីក៏ដោយ។
- ធានាឱ្យមានការទាមទារយន្តការនៃសំណើគាំទ្រ ដែលជំរុញឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវទាន់ពេលវេលា មុនការប្រកាសឱ្យប្រើប្រាស់។ វាជាតម្រូវការសម្រាប់ការកើនឡើងជាញឹកញាប់ និងការផ្សារភ្ជាប់គុណភាពដូចជា សិក្ខាសាលាដែលនាំឱ្យមានការសិក្សាទាំងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកបង្កើតគោលនយោបាយ។
- ធានាឱ្យបាននូវការចូលដំណើរការទិនានុប្បវត្តិសិក្សានាពេលបច្ចុប្បន្ន។ យើងអាចសម្រេចវាទៅបានតាមរយៈមូលនិធិផ្ទាល់សម្រាប់ការជាវជាប្រចាំ ដែលជាផ្នែកមួយក្នុងការកសាងសមត្ថភាពរយៈពេលវែង។ ការជាវមូលដ្ឋានទិន្នន័យថ្នាក់ជាតិជាឧទាហរណ៍ដែលអាចប្រើដោយសាកលវិទ្យាល័យទាំងអស់។ វាអាចធ្វើទៅបានតាមរយៈគំនិតផ្តួចផ្តើមដែលដាក់សម្ពាធទៅលើអ្នកបោះពុម្ពផ្សាយដើម្បីផ្លាស់ប្តូរលក្ខខណ្ឌការជាវរបស់ខ្លួន ដោយអនុញ្ញាតឱ្យសាកលវិទ្យាល័យដែលមានធនធានគ្រប់គ្រាន់ "ចែករំលែក" ជាមួយសាកលវិទ្យាល័យក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ឧទាហរណ៍ ការផ្តល់ឱ្យដោយ"ឥតគិតថ្លៃ"សម្រាប់សាកលវិទ្យាល័យនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍អាចបង្ហាញនូវសមត្ថភាពក្នុងការស្រាវជ្រាវយ៉ាងខ្លាំង។
- មូលនិធិសម្រាប់ការស្រាវជ្រាវក្រោយបញ្ចប់ការសិក្សា ការលើកឡើងដោយសាកលវិទ្យាល័យក្នុងស្រុក ឬនៅអង្គការមិនមែនរដ្ឋាភិបាលនានា។ វាគឺជាការលើកទឹកចិត្តដាក់ស្តែងដល់និស្សិតដែលទទួលបានជោគជ័យ និងបានផ្តល់ជូននូវទស្សនវិស័យហិរញ្ញវត្ថុបន្ទាប់ពីបញ្ចប់ការសិក្សាដែរ។
- ផ្តល់ជូននូវថវិកាគ្រប់គ្រាន់ និងយន្តការសម្រាប់ផ្សព្វផ្សាយការស្រាវជ្រាវ ដោយប្រើប្រាស់ភាសារបស់ប្រទេសម្ចាស់ផ្ទះ។ ហើយការផ្សព្វផ្សាយ ក៏គួរតែមានភាពត្រូវគ្នាជាមួយអ្នកធ្វើគោលនយោបាយរបស់ប្រទេសម្ចាស់ផ្ទះដែរ។

### *ក្រសួងអប់រំយុវជន និងកីឡា*

- គោលនយោបាយរបស់វិទ្យាស្ថានដែលបញ្ជាក់ពីចំណាត់ថ្នាក់សាស្ត្រាចារ្យ និងកញ្ចប់ប្រាក់ខែដែលសមស្របសម្រាប់អ្នកប្រាជ្ញ ដើម្បីជំរុញការស្រាវជ្រាវ។ វាគួរតែមានការប្តេជ្ញាច្បាស់លាស់ណាមួយ ដើម្បីធ្វើការអភិវឌ្ឍគោលនយោបាយស្រាវជ្រាវ ជាមួយនឹងស្តង់ដារដ៏រឹងមាំដែលកំណត់ដោយអាជ្ញាធរកណ្តាល រួមទាំងភាពទូលំទូលាយនៃបញ្ជីគោលដៅ និងសូចនាករដើម្បីវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា។

- ការផ្តល់មូលនិធិ និងការគ្រប់គ្រងការចែកចាយរបស់ពួកគេ ក្នុងការគាំទ្រការស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាពនៅសាកលវិទ្យាល័យមួយចំនួន។ មូលនិធិដំបូងត្រូវបានគេដោះស្រាយជាពិសេសលើបញ្ហាប្រឈមចំនួនបួននាពេលបច្ចុប្បន្ន៖

១) សមត្ថភាពរបស់ស្ថាប័នក្នុងការគ្រប់គ្រងមូលនិធិស្រាវជ្រាវ

២) សមត្ថភាពរបស់អ្នកស្រាវជ្រាវក្នុងការរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវ

៣)ភាពលំបាកខ្លាំងក្នុងការទទួលបានទម្រង់មូលនិធិ

៤)ការផ្សព្វផ្សាយដែលមានប្រសិទ្ធភាពបន្ទាប់ពីរកឃើញការស្រាវជ្រាវ

បញ្ហាប្រឈមទាំងនេះអាចដោះស្រាយបានតាមរយៈការផ្តោតលើគំនិតផ្តួចផ្តើមនៃការជួយបង្ហាត់បង្ហាញ ដែលអនុញ្ញាតឱ្យក្រុមអ្នកស្រាវជ្រាវ និងស្ថាប័នមួយចំនួនធ្វើការសហការជាមួយស្ថាប័នដែលមានការអភិវឌ្ឍតិច ហើយលើកកម្ពស់កិច្ចសហការរវាងស្ថាប័នសាធារណៈ និងឯកជន។

- មានភាពខ្វះខាតពីចំណុចទាក់ទងនឹងការអភិវឌ្ឍគោលនយោបាយស្រាវជ្រាវ។ ១) ការដាក់បញ្ចូលការវាយតម្លៃខ្លួនឯងនិងការស្រាវជ្រាវចំពោះការអនុវត្តរបស់ក្រសួងគឺជាផ្នែកមួយក្នុងការអភិវឌ្ឍគោលនយោបាយស្រាវជ្រាវ។២) ការដាក់បញ្ចូលបញ្ហាសង្គម និងគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍខ្លួនឯងគឺជាផ្នែកមួយនៃគោលនយោបាយភាសា។ បញ្ហាចុងក្រោយនេះត្រូវបានរាយការណ៍ដោយសិស្ស ទាក់ទងនឹងទិដ្ឋភាពសំខាន់ៗបំផុតនៃការស្រាវជ្រាវ ប៉ុន្តែវាត្រូវបានបាត់ពីគោលនយោបាយរបស់ក្រសួង ដែលនាំឱ្យមានការយកចិត្តទុកដាក់ទៅលើតែបញ្ហាសេដ្ឋកិច្ច។
- ចំពោះការចំណាយប្រកបដោយប្រសិទ្ធភាព សម្រាប់ការកសាងសមត្ថភាពស្រាវជ្រាវ ក្រសួងអប់រំអាចមានគំនិតផ្តួចផ្តើមជាផ្លូវការ ដោយឱ្យអង្គការមិនមែនរដ្ឋាភិបាលធ្វើកម្មសិក្សាសម្រាប់និស្សិតសាកលវិទ្យាល័យដើម្បីផ្តល់ឱ្យពួកគេមានបទពិសោធន៍ជាក់ស្តែងលើការស្រាវជ្រាវ។ គំនិតផ្តួចផ្តើមនេះនឹងជួយបង្កើនទាំងសមត្ថភាពស្រាវជ្រាវ និងទាំងគុណភាពស្រាវជ្រាវនៅកម្ពុជា។

*ក្រសួងផ្សេងៗទៀត*

- ធ្វើឱ្យទិន្នន័យរបស់អ្នកអាចប្រើប្រាស់ជាសាធារណៈបាន។ ស្ថាប័នរដ្ឋាភិបាលការតស៊ូមតិរបស់អង្គការសង្គមស៊ីវិល អ្នកសិក្សា និងអ្នកស្រាវជ្រាវពាណិជ្ជកម្មបានបង្ហាញចេញនូវបញ្ហាសំខាន់ៗទាំងអស់ដែលផ្តើមចេញពីកង្វះខាតព័ត៌មានពីខាងរដ្ឋាភិបាល (ដោយសារតែភ្នាក់ងាររដ្ឋមិនមាន ឬដោយសារតែពួកគេមិនមានឆន្ទៈក្នុងការផ្តល់នូវព័ត៌មានទាំងនោះ) ព្រមទាំងភាពលំបាកក្នុងការចូលទៅយកព័ត៌មានពីស្ថាប័នអាជីវកម្មឯកជននានា។

- បោះពុម្ពផ្សាយការស្រាវជ្រាវនៅលើគេហទំព័ររបស់អ្នក។ ភាពបរាជ័យក្នុងការអភិវឌ្ឍនៃការឆ្លើយតបរួមមាន ការផ្តល់ព័ត៌មានស្តីពីសកម្មភាពរបស់ក្រសួង ឬលទ្ធផលនៃការស្រាវជ្រាវរបស់ក្រសួងតាមការស្នើសុំ គឺជាឧបសគ្គក្នុងការប្រមូលយកទិន្នន័យ និងការទទួលយកគោលនយោបាយ។ មួយវិញទៀត ដើម្បីឱ្យមានការផ្សារភ្ជាប់គ្នាជាមួយការបង្កើតគោលនយោបាយក្នុងការស្រាវជ្រាវនោះ គួរតែមានកិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងគ្រឹះស្ថានឧត្តមសិក្សា អង្គការសង្គមស៊ីវិល និងស្ថាប័នរដ្ឋ។

*គ្រឹះស្ថានឧត្តមសិក្សា*

- ការកំណត់ថវិកាសម្រាប់ការឈប់សម្រាកក្នុងការស្រាវជ្រាវរបស់មហាវិទ្យាល័យ។ ការកំណត់សកម្មភាពស្រាវជ្រាវរបស់មហាវិទ្យាល័យអាចកើតមានចាប់ពីសមត្ថភាពទាបឡើងទៅ ប៉ុន្តែវាក៏អាចកើតចេញពីឧបសគ្គផ្សេងៗ ជាពិសេសគឺការកំណត់ពេលវេលា។ លើសពីនេះទៅទៀត ការផ្តល់មូលនិធិសម្រាប់គម្រោងស្រាវជ្រាវ ក៏គួរតែឧបត្ថម្ភថវិកាដោយគិតលើពេលវេលាដែរ។
- លើកកម្ពស់សេរីភាពសិក្សាដល់សាស្ត្រាចារ្យ និងនិស្សិតដើម្បីផ្តល់អំណាចដល់ពួកគេក្នុងការត្រិះរិះពិចារណានិងធ្វើការស្រាវជ្រាវលើបញ្ហាសំខាន់ៗទាក់ទងនឹងសង្គម។ បង្កើនកិច្ចសន្ទនារវាងស្ថាប័ន ដោយឱ្យពួកគេធ្វើការវាយតម្លៃលើសមិទ្ធផលរបស់ស្ថាប័ននិងឧបសគ្គនានា។ ការបង្កើនឱកាសឱ្យគ្រូក្នុងការបញ្ចូលការរចនា និងការអនុវត្តគោលនយោបាយរបស់ស្ថាប័ន ព្រមទាំងការផ្តល់សិទ្ធិអាទិភាពក្នុងការវាយតម្លៃខ្លួនឯងទាក់ទងនឹងលទ្ធផលនៃការស្រាវជ្រាវ។
- ធ្វើឱ្យប្រាកដថាការលើកទឹកចិត្តរបស់អ្នក ដើម្បីធ្វើការស្រាវជ្រាវនឹងលេចចេញនូវផ្លែផ្កាដូចអ្វីដែលចង់បាន។ ស្ថាប័នទាំងអស់ដែលបានផ្តល់នូវការលើកទឹកចិត្តសម្រាប់ការបោះពុម្ពផ្សាយដូចជាការប្រគល់ប្រាក់ ឬការដំឡើងប្រាក់បៀវត្សរ៍ គួរតែមានផលប៉ះពាល់ទៅលើការស្រាវជ្រាវ។ តើសមាជិកមហាវិទ្យាល័យប៉ុន្មាននាក់ដែលទទួលបានអត្ថប្រយោជន៍ពីវា? តើអ្វីទៅជាលក្ខណវិនិច្ឆ័យសម្រាប់កម្មវិធីនេះ? តើកម្មវិធីនោះផ្សព្វផ្សាយយ៉ាងដូចម្តេច? និងតើមានកត្តាអ្វីខ្លះដែលរាំងស្ទះដល់ការប្រើប្រាស់កម្មវិធីនេះ?
- ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយស្រាវជ្រាវជាផ្លូវការ បានឆ្លុះបញ្ចាំងពីសមត្ថភាពរបស់ស្ថាប័នជាងការប្រាថ្នាចង់បានរបស់រដ្ឋបាល។ ការស្រាវជ្រាវទាក់ទងនឹងស្ថាប័ន និងធនធានមនុស្សគួរតែធ្វើឱ្យបានមុនឯកសារគោលនយោបាយទាំងអស់ ក្នុងគោលបំណងដើម្បីបម្រុងទុកមូលនិធិឱ្យបានត្រឹមត្រូវ។
- ចាប់ផ្តើមធ្វើការស្រាវជ្រាវទាក់ទងនឹងវគ្គសិក្សាក្នុងឆ្នាំមូលដ្ឋាន (វគ្គសិក្សាស្នូលដែលត្រូវបានប្រគល់សិទ្ធិដោយ ACC សម្រាប់និស្សិតឆ្នាំដំបូង)។ វាអាចធ្វើឱ្យសិស្សមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀនសូត្រ អនុវត្តជំនាញរបស់ពួកគេ និងបង្កើតគម្រោងស្រាវជ្រាវសម្រាប់ឆ្នាំចុង

ក្រោយ។ ការសិក្សាវគ្គស្រាវជ្រាវនៅឆ្នាំទីបី ធ្វើឱ្យនិស្សិតមិនមានបទពិសោធន៍គ្រប់គ្រាន់ដើម្បីធ្វើការងារនោះទេ។

- ការដាក់ផែនការផ្សព្វផ្សាយនៅជួរមុខគេនៃគម្រោងស្រាវជ្រាវ។ ប្រើប្រាស់គេហទំព័រដើម្បីផ្សព្វផ្សាយអំពីការស្រាវជ្រាវនៅសាកលវិទ្យាល័យ និងលើកកម្ពស់គុណភាពស្រាវជ្រាវនៅសាកលវិទ្យាល័យរបស់អ្នក។
- សិស្ស និស្សិតតែងតែចង់បានការស្រាវជ្រាវដែលមានគុណភាព ហើយវាក៏មានតម្លៃដល់សង្គមដែរ។ ប្រសិនបើសាកលវិទ្យាល័យ មានថវិកាគ្រប់គ្រាន់ដើម្បីជួលនិស្សិតថ្នាក់បណ្ឌិតPhD អន្តរជាតិមកធ្វើជាគ្រូបង្រៀន វាពិតជាមានការលើកទឹកចិត្ត (និងជួយសម្រួល) ដល់សកម្មភាពស្រាវជ្រាវរបស់ពួកគេ ហើយនិស្សិតនឹងយល់ឃើញថា សាកលវិទ្យាល័យមានកេរ្តិ៍ឈ្មោះ និងបានបង្កើនសក្តានុពលនៃការរៀនសូត្ររបស់ពួកគេដែរ។
- ការសង្កត់ធ្ងន់លើការសហការ និងការពង្រឹងភាពជាដៃគូរវាងសាកលវិទ្យាល័យរដ្ឋនិងឯកជន ព្រមទាំងស្ថាប័នអន្តរជាតិស្តីពីការកសាងសមត្ថភាពស្រាវជ្រាវ។ ស្ថាប័ននីមួយៗមានភាពខ្លាំង និងចំណុចដែលគេផ្តោតជាសំខាន់រៀងខ្លួន ដែលរួមបញ្ចូលលើជំនាញក្នុងការបង្កើនសមត្ថភាព។
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវតែមានកាតព្វកិច្ចជាចម្បងក្នុងការបណ្តុះបណ្តាលនិស្សិត និងធ្វើឱ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ពេលចូលបម្រើការងារ ក៏ដូចជាចែករំលែកទៅកាន់សង្គមជាតិ ដោយការគាំទ្រដល់ការលើកទឹកចិត្តដែលមានស្រាប់ ចំពោះយុវជនក្នុងការធ្វើការស្រាវជ្រាវដែលជាប្រយោជន៍ពិតសម្រាប់សហគមន៍។
- ភាពសកម្មក្នុងការជំរុញ ក៏ដូចជាលើកទឹកចិត្តឱ្យយុវជនធ្វើការរៀនសូត្រ មានសកម្មភាពលើការស្រាវជ្រាវ និងពង្រឹងការកសាងសមត្ថភាពភាសាអង់គ្លេស។

### *អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមអ្នកជំនាញ*

- ធ្វើឱ្យឯកសារទាំងអស់រួមទាំងគេហទំព័រ ប្រើប្រាស់ភាសាក្នុងតំបន់
- លើកកម្ពស់ទំនាក់ទំនងរវាងនិស្សិត និងក្រុមអ្នកស្រាវជ្រាវ ដើម្បីកសាងសមត្ថភាពរបស់ពួកគេ និងប្រើប្រាស់ជំនាញដែលគេមានក្នុងវិធីសាស្ត្រស្រាវជ្រាវជាផ្លូវការ។
- អភិវឌ្ឍទំនាក់ទំនងនៃការស្រាវជ្រាវ (ពិធីការ) និងស្ថាប័នបណ្តុះបណ្តាលវិធីសាស្ត្រស្រាវជ្រាវ។
- គ្រឹះស្ថានឧត្តមសិក្សាបានអញ្ជើញសិស្ស និស្សិត ដើម្បីធ្វើការពិភាក្សា ចូលរួមសិក្ខាសាលា និងធ្វើបទបង្ហាញលើមូលដ្ឋានទៀងទាត់មួយ។

- ការទទួលស្គាល់គោលនយោបាយ និងការអនុវត្តដែលសិស្សបានផ្តល់ឱ្យនូវប្រភពសំខាន់នៃធនធានមនុស្សបន្ថែមទៀតនេះ ជាមធ្យោបាយមួយដើម្បីធ្វើឱ្យប្រសើរឡើងលើការផ្សព្វផ្សាយជាសាធារណៈ និងជាគន្លឹះដែលអាចធ្វើឱ្យវប្បធម៌នៃការស្រាវជ្រាវ ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយបន្ថែមទៀត។
- ផ្តោតជាសំខាន់លើការកែលម្អទំនាក់ទំនង និងការសហការជាមួយអង្គការសង្គមស៊ីវិលផ្សេងទៀតក្នុងគោលបំណងធ្វើឱ្យមានភាពប្រសើរឡើងក្នុងការទំនាក់ទំនងនិងការសហការគ្នាក្នុងសហគមន៍។ កែលម្អយុទ្ធសាស្រ្តសម្រាប់ការផ្សព្វផ្សាយ និងកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន។

*ការសហការរបស់គ្រឹះស្ថានឧត្តមសិក្សា និងអង្គការសង្គមស៊ីវិល*

- យើងមើលឃើញពីសក្តានុពលសម្រាប់ការអភិវឌ្ឍសមត្ថភាពតាមរយៈកិច្ចសហការគ្នារវាងគ្រឹះស្ថានឧត្តមសិក្សា និងអង្គការសង្គមស៊ីវិល។ គ្រឹះស្ថានឧត្តមសិក្សាស័ក្តិសមជាទីកន្លែងដែលធ្វើការបញ្ចូលអក្សរសាស្រ្តសិក្សាដែលមានព័ត៌មានគ្រប់គ្រាន់ ហើយចូលរួមចែករំលែកទ្រឹស្តី ក៏ដូចជាវិធីសាស្រ្តផ្សេងៗរបស់អង្គការមិនមែនរដ្ឋាភិបាល។
- អង្គការសង្គមស៊ីវិលអាចផ្តល់នូវការបណ្តុះបណ្តាលពិតប្រាកដមួយ សម្រាប់សិស្ស និស្សិតទាក់ទងនឹងជំនាញស្រាវជ្រាវ ក្នុងគម្រោងដ៏សកម្មនោះ។ ប្រភេទនៃកិច្ចសហការនេះអាចធ្វើឱ្យមានភាពប្រសើរឡើងក្នុងការទាញយកគោលនយោបាយ និងបានរួមចំណែកដល់ការកសាងសមត្ថភាពយ៉ាងមានប្រសិទ្ធភាពផងដែរ។
- មានភាពជាម្ចាស់ការក្នុងតំបន់ ត្រូវចាប់ផ្តើមចេញពីការផ្លាស់ប្តូរការគ្រប់គ្រង ការផ្តល់សិទ្ធិអំណាចដល់អ្នកស្រាវជ្រាវម្នាក់ៗ និងស្ថាប័ននីមួយៗ។ វាអាចកើតឡើងតាមរយៈការកែលម្អការចរចា ដោយផ្អែកលើការយល់ដឹងចាប់ពីថ្នាក់ក្រោមឡើងទៅ បូករួមជាមួយនឹងការវាយតម្លៃលើឧបសគ្គដែលបានកំណត់ទុកក្នុងការបង្កើត និងផ្សព្វផ្សាយសកម្មភាពស្រាវជ្រាវ។

# ១.សេចក្តីផ្តើម

ប្រទេសកម្ពុជានៅតែជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ដែលមានបរិយាកាសស្រាវជ្រាវនៅទន់ខ្សោយនៅឡើយ។ មួយចំណែកគឺដោយសារតែការសម្លាប់អ្នកប្រាជ្ញ និងបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសិក្សាស្រាវជ្រាវនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ដោយរបបខ្មែរក្រហមនិងជាច្រើនឆ្នាំបន្តបន្ទាប់មកទៀតនៅក្នុងការកសាងប្រទេសឡើងវិញនៅក្នុងពេល ដែលមានអស្ថិរភាពនយោបាយនិងសង្គម។ ស្ថានភាពនេះកាន់តែមានភាពល្អក់កករបន្ថែមទៀតតាមរយៈបរិយាកាសនយោបាយក្នុងពេលបច្ចុប្បន្ន ដែលមានភាពភ័យខ្លាច និងការមិនជឿទុកចិត្តគ្នាទៅវិញទៅមក ដែលនេះជាការបន្ទុចបង្អាក់ក្នុងការចូលរួមជាសាធារណៈដោយបើកចំហនៅក្នុងដំណើរការនយោបាយ និងបានរារាំងដល់ការស្រាវជ្រាវដែលមានផលិតកម្មខ្ពស់។ ការសិក្សាស្រាវជ្រាវភាគច្រើនដែលត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាគឺបានទទួលការឧបត្ថម្ភគាំទ្រ ឬក៏ត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ស្ថាប័នស្រាវជ្រាវបរទេស ឬទីប្រឹក្សាដែលកំពុងធ្វើការជាមួយនឹងអង្គការម្ចាស់ជំនួយ ដែលទាំងអស់នោះបានកត់សម្គាល់អំពីការលំបាកនានាដែលពាក់ព័ន្ធជាមួយនឹងការប្រមូលទិន្នន័យដែលគួឱ្យទុកចិត្តបាន និងទិន្នន័យដែលមានគុណភាពខ្ពស់នៅក្នុងបរិយាកាសបែបនេះ។ មានបញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធផ្សេងៗទៀតជាច្រើនដែលរារាំងក្នុងការទទួលបានទិន្នន័យដែលមានគុណភាពខ្ពស់ និងរារាំងទប់ស្កាត់មិនឱ្យមានបរិយាកាសស្រាវជ្រាវដ៏រស់រវើកមួយ ស្តីពីការស្រាវជ្រាវទាក់ទងទៅនឹងគំនិតផ្តួចផ្តើមស្រាវជ្រាវពីម្ចាស់ជំនួយអន្តរជាតិដែលយើងនឹងពិភាក្សានៅក្នុងរបាយការណ៍មួយនេះ។ តែទោះបីជាយ៉ាងណាក៏ដោយ ឱនភាពដ៏ខ្លាំងបំផុតមួយនៅក្នុងបរិយាកាសស្រាវជ្រាវក្នុងប្រទេសកម្ពុជាគឺការខ្វះខាតអ្នកស្រាវជ្រាវក្នុងស្រុក ដែលទទួលបានការបណ្តុះបណ្តាលល្អ និងការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធសិក្សាអប់រំ ដែលនៅមានកម្រិតនៅឡើយ។ គម្រោងរបស់យើងសំដៅរួមចំណែកដល់ការកសាងសមត្ថភាពនៅ ក្នុងប្រទេសកម្ពុជាតាមរយៈការផ្តល់បន្ថែមនូវកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលផ្នែកស្រាវជ្រាវ ដែលបានចាប់ផ្តើមរួចហើយនៅវិទ្យាស្ថានសម្រាប់សហប្រតិបត្តិការនិងសន្តិភាពនៅកម្ពុជា (CICP) ដែលក្នុងនោះ និស្សិតសាកលវិទ្យាល័យនៅក្នុងប្រទេសត្រូវបានទទួលការបង្ហាត់បង្រៀន និងត្រួតពិនិត្យតាមរយៈការចូលរួមនៅក្នុងគម្រោងស្រាវជ្រាវដែលមានលក្ខណៈសកម្មនៅវិទ្យាស្ថាន និងផ្តល់នូវការបណ្តុះបណ្តាលផ្នែកវិធីសាស្ត្រស្រាវជ្រាវយុទ្ធសាស្ត្រក្នុងការវិភាគ និងការរចនាការសិក្សាស្រាវជ្រាវជាដើម។

**របាយការណ៍ខាងក្រោម៖** នេះជាការរួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងសមត្ថភាពជាមួយនឹងការស្រាវជ្រាវទៅក្នុងបរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា និងទំនាក់ទំនងរវាងការស្រាវជ្រាវ និងការចាប់យកគោលនយោបាយ។

**បញ្ហាប្រឈម**

ជាទូទៅបញ្ហាប្រឈមធំជាងគេបំផុតមួយនៅក្នុងបរិយាកាសស្រាវជ្រាវគឺការខ្វះខាតអ្នកស្រាវជ្រាវដែលបានទទួលការបណ្តុះបណ្តាលល្អរួមជាមួយ នឹងហេដ្ឋារចនាសម្ព័ន្ធអប់រំដែលមានការគាំទ្រ។ ផ្នែកមួយនៃការខ្វះខាតនេះគឺអាចមើលឃើញច្បាស់តាមរយៈការខ្វះខាតមនុស្សជំនាន់មុនដោយសារតែភាគច្រើននៃពួកគាត់ត្រូវបានគេសម្លាប់នៅក្នុងរបបខ្មែរក្រហមអស់ទៅហើយ។ គេក៏អាចមើលឃើញច្បាស់ផងដែលទាក់ទងជាមួយនឹងការប្រមូលចងក្រងឯកសារ ដែលមិនទាន់មានសភាពគ្រប់គ្រាន់នៅឡើយព្រមជាមួយនឹងការធ្វើផែនទីសម្រាប់បរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា និងរំហូរព័ត៌មានដែលនៅមានកម្រិតតិចតួចរវាងអ្នកធ្វើគោលនយោបាយ និងអ្នកសិក្សាស្រាវជ្រាវ។ មានរបៀបវារៈតាមការចង់បានរបស់ម្ចាស់ជំនួយច្រើនហួសហេតុ ព្រមទាំងគម្រោងដែលមានរយៈពេលខ្លី និងគម្រោងដែលមានវិសាលភាពស្ថិតក្នុងកម្រិតតិចតួចមួយដែលធ្វើឱ្យរាំងដល់សកម្មភាស្រាវជ្រាវ និងបន្ទាបកិត្តិយសអ្នកស្រាវជ្រាវ។ ចុងបញ្ចប់ការទទួលយកការស្រាវជ្រាវដើម្បីជះឥទ្ធិពលទៅលើគោលនយោបាយនោះនៅមានកម្រិតនៅឡើយ ហើយការរកបានព័ត៌មានដែលទាក់ទងមួយនឹងរដ្ឋាភិបាល ក៏នៅមានកម្រិតតិចតួច ហើយដែលព័ត៌មានទាំងអស់នោះអាចនឹងដើរតួនាទីក្នុងការជំរុញការស្រាវជ្រាវ។

លទ្ធផលគោលនយោបាយជាក់លាក់ ដែលកើតមកអំពីការទើបប្រទះពីសំណាក់អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធផ្សេងៗទៀតនោះនៅមិនទាន់ត្រូវបានគេកត់ត្រាឱ្យបានគ្រប់គ្រាន់នៅឡើយទេ និងស្ថិតនៅក្នុងភាពរប៉ាត់រប៉ាយនៅឡើយ។ តាមរយៈការយកចិត្តទុកដាក់ជាពិសេសក្នុងការធ្វើស្ថាប័ននីយកម្មសម្រាប់ការបណ្តុះបណ្តាល និងការធ្វើឱ្យទៅជាផ្លូវការនៃការធ្វើច្បាប់ និងគោលនយោបាយដែលមានលក្ខណៈគាំទ្រ ព្រមទាំងការកសាងនូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រមួយនោះ យើងអាចរួមចំណែកដល់ការចងក្រងប្រមូលឯកសារ និងដំណើរការធម្មជាតិនយកម្មនៃដំណើរការសម្រាប់ការចាប់យកការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយ។ អន្តរកម្មរវាងការផលិតការស្រាវជ្រាវដែលមានគុណភាពការផ្សព្វផ្សាយដែលមានប្រសិទ្ធភាពព្រមទាំងការចាប់យកសម្រាប់ការអភិវឌ្ឍស្ថាប័ន និងសង្គមស្ថិតនៅលើហេដ្ឋារចនាសម្ព័ន្ធនៃការបណ្តុះ បណ្តាលនិងគោលនយោបាយ ប៉ុន្តែត្រូវធ្វើដំណើរតាមរយៈសកម្មភាពមួយដែលមានលក្ខណៈទូលំទូលាយដែលធ្វើឡើងដោយបុគ្គលដែលមានការប្តេជ្ញាចិត្តខ្ពស់។

**វិសាលភាពនៃការស្រាវជ្រាវ**

គម្រោងនេះប្រើប្រាស់ការប្រមូលទិន្នន័យដើមដោយប្រើប្រាស់បច្ចេកទេសប្រមូលទិន្នន័យចម្បងចំនួនបី៖ ការសម្ភាសដែលមានការផ្ដោតទៅលើគោលដៅជាសំខាន់ ការពិភាក្សាក្រុមនិងការស្ទង់មតិ។ យើងប្រើប្រាស់នីតិវិធីធ្វើសំណាក និងពិធីការសម្រាប់ការសិក្សាស្រាវជ្រាវដែលត្រូវបានរចនាឡើងដើម្បីលាតត្រដាងនូវទស្សនៈអំពីរចនាសម្ព័ន្ធក្រឹត្យក្រមសកម្មភាពការរីកចម្រើន ការប្រឈម និងឱកាសដែលធ្វើឱ្យមានបរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ ការធ្វើបែបនេះផ្ដល់នូវព័ត៌មានសម្បូរបែបសម្រាប់ធ្វើការបកស្រាយនិងព័ត៌មាន ដែលមានភាពសំខាន់ផ្នែកស្ថិតិទាក់ទងនឹងបទពិសោធន៍ និងការយល់ដឹងអំពីការស្រាវជ្រាវទៅលើតួអង្គសំខាន់ៗនៅក្នុងវិស័យនេះ។ ក្នុងប្រទេសកម្ពុជាវិស័យនេះវាហួសពីស្ថាប័នសិក្សាអប់រំ ដោយសារតែវាគឺជាសកម្មភាពស្រាវជ្រាវដ៏សំខាន់ ដែលត្រូវធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ក្រសួង និងអង្គការម្ចាស់ជំនួយ។

បន្ថែមពីលើការប្រមូលទិន្នន័យ ការស្រាវជ្រាវនេះបានរួមចំណែកដល់បរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាតាមរយៈធាតុចេញដែលអាចមើលឃើញច្បាស់ចំនួនបី។ យើងបង្កើតឱ្យមានកម្មវិធីបណ្ដុះបណ្ដាល ដែលមានលក្ខណៈអនុវត្តជាក់ស្ដែង សម្រាប់អ្នកស្រាវជ្រាវថ្មីៗដែលគេអាចប្រើដោយតួអង្គសំខាន់ៗ ដូចជាសាកលវិទ្យាល័យនិងអង្គការសង្គមស៊ីវិលជាដើម។ យើងបានបង្កើតនូវទម្រង់ដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធើណិតមួយដែលផ្ដល់ ឬក៏ដែលផ្ទុកនូវការស្រាវជ្រាវដែលផលិតបាននៅក្នុងប្រទេស បញ្ជីឈ្មោះអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ ព្រមទាំងវេទិកាដែលអ្នកស្រាវជ្រាវអាចភ្ជាប់ពីគ្នាទៅវិញទៅមកទាំងនៅក្នុងឆាកជាតិ និងអន្តរជាតិ។ លើសពីនេះទៅទៀត គេហទំព័រនេះនឹងក្លាយទៅជាកន្លែងមួយដែលអ្នកស្រាវជ្រាវ អាចផ្សព្វផ្សាយ ឬក៏ស្វែងរកនូវឱកាសស្រាវជ្រាវថ្មីៗ និងទទួលបាននូវព័ត៌មានសម្រាប់ផ្ដល់មូលនិធិដល់ការសិក្សាស្រាវជ្រាវនេះប្រកបដោយបច្ចុប្បន្នភាព។ យើងនឹងប្រើប្រាស់ទម្រង់គេហទំព័រមួយនេះដើម្បីចែករំលែកនូវផ្នែកខ្លះនៃរបកគំហើញក្នុងកាស្រាវជ្រាវរបស់យើង និងបង្កើតឱ្យវាក្លាយទៅជាកន្លែងមួយសម្រាប់អ្នកដទៃទៀតអាចផ្សព្វផ្សាយនូវរបកគំហើញស្រាវជ្រាវថ្មីៗ ព្រមទាំងផ្ដល់នូវសេចក្ដីសង្ខេបគោលនយោបាយតាមរយៈកិច្ចខិតខំប្រឹងប្រែងមួយដើម្បីធ្វើឱ្យរបកគំហើញផ្នែកស្រាវជ្រាវនេះអាចមានភាពងាយស្រួលក្នុងការទទួលយកបាន។ ជាចុងក្រោយ យើងពិនិត្យសង្កេតទៅលើបរិយាកាសស្រាវជ្រាវនេះតាមរយៈច្បាប់និងគោលនយោបាយសំខាន់ៗមួយចំនួនតាមរយៈក្រឹត្យក្រមសំខាន់ៗ និងតួអង្គសំខាន់ៗក៏ដូចជាតាមរយៈប្រព័ន្ធស្ថាប័នដែលមានរចនាសម្ព័ន្ធក្នុងការបង្កើតការស្រាវជ្រាវនៅស្ថាប័នផ្សេងៗ នៅក្នុងការសិក្សារបស់យើង។ តាមរយៈការប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ និងបរិមាណវិស័យ និងឧបករណ៍ស្រាវជ្រាវដែលរួមបញ្ចូលទាំងសំណួរបើកនិងសំណួរបិទនោះ យើងអាចមានលទ្ធភាពនៅក្នុងការប្រើប្រាស់ និងគណនាអំពីបរិយាកាសស្រាវជ្រាវទាក់ទងជាមួយនឹងរចនាសម្ព័ន្ធកម្រិតម៉ាក្រូ ហើយនឹងអាចមានលទ្ធភាពនៅក្នុងការប្រមូលនូវទិន្នន័យតាមលំអានផ្សេងៗអំពីតួអង្គសំខាន់ៗ និងអំពីការផលិតការស្រាវជ្រាវ។

**តួអង្គសំខាន់ៗ**

នៅក្នុងអំឡុងពេលនៃការស្រាវជ្រាវរបស់យើង យើងផ្តោតទៅលើស្ថាប័នសំខាន់ចំនួន៦ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។

- រដ្ឋាភិបាល

- ក្រសួង

- សាកលវិទ្យាល័យ

- ក្រុមអ្នកត្រិះរិះពិចារណា

- អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល

- អង្គការម្ចាស់ជំនួយ

-(សម្រាប់ប្រវត្តិស្ថាប័ននានា សូមមើលក្នុងបញ្ជីឧបសម្ព័ន្ធទី១)

អន្តរកម្មរវាងស្ថាប័នផ្សេងៗគ្នាទាំងអស់នេះ ដែលសុទ្ធតែបានផលិតការស្រាវជ្រាវ បានផ្តល់ជាពន្លឺបំភ្លឺផ្លូវដែលមានភាពស្មុគស្មាញមួយចំនួនតាមរយៈការស្រាវជ្រាវ តាមរយៈការធ្វើអន្តរកម្មរវាងការស្រាវជ្រាវ និងគោលនយោបាយ។ ខណៈដែលការប៉ះពាល់ដោយផ្ទាល់នៃការស្រាវជ្រាវទៅលើគោលនយោលបាយមានការលំបាកក្នុងកាលកំណត់នៅក្នុងគ្រប់កាលៈទេសៈទាំងឡាយនោះ របកគំហើញរបស់យើងបានបង្ហាញថា អំណាចដ៏ខ្លាំងរបស់អង្គការម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលក្នុងការជះឥទ្ធិពលទៅលើគោលនយោយបាយ និងអប្រសិទ្ធភាពដែលមានការជាប់ពាក់ព័ន្ធទៅនឹងងគ្រឹះស្ថានឧត្តមសិក្សាទាំងឡាយនោះ ជាពិសេសនៅក្នុងការផលិតការស្រាវជ្រាវដែលមានការពាក់ព័ន្ធទៅលើគោលនយោលបាយ។ អន្តរកម្មនេះនៅតែជាចំណុចមួយដែលត្រូវការស្រាវជ្រាវបន្ថែមទៀត ប៉ុន្តែយើងបានរុករកនូវចលករទាំងឡាយនេះនៅក្នុងរបាយការណ៍ខាងក្រោម។

**គោលបំណង និងសំណួរ**

ការស្រាវជ្រាវនេះស្វែងរកការធ្វើផែនទីដែលមានលក្ខណៈទូលំទូលាយមួយអំពី បរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាតាមរយៈការពិនិត្យមើលយ៉ាងលម្អិតទៅលើក្របខ័ណ្ឌគោននយោបាយ និងតាមរយៈការចុះបញ្ជីនូវតម្រូវការរបស់អ្នកស្រាវជ្រាវជាបុគ្គលនីមួយៗ។ លើសពីនេះទៀតគម្រោងនឹងធ្វើការកត់ត្រារៀបចំ និងផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងសំណួរសំខាន់ៗមួយចំនួនរបស់យើង៖

- តើប្រភេទនៃការស្រាវជ្រាវអ្វីខ្លះដែលគេកំពុងធ្វើ តែក្នុងប្រទេសកម្ពុជា ធ្វើឡើងដោយអ្នកណា? ធ្វើក្នុងគោលបំណងអ្វី ហើយមានធនធានអ្វីខ្លះ ?

- តើមានយន្តការអ្វីខ្លះដែលការស្រាវជ្រាវទាំងអស់នេះបង្កឱ្យមានការកសាងសមត្ថភាពក្នុងការស្រាវជ្រាវ?
- តើមានឧបសគ្គចម្បងៗអ្វីខ្លះនៅក្នុងការផលិតការស្រាវជ្រាវ ដែលមានគុណភាពនៅក្នុងប្រទេសកម្ពុជា?

ក្នុងគោលបំណងដើម្បីឆ្លើយសំណួរទាំងអស់នេះ យើងពិនិត្យមើលលើទំនាក់ទំនងរវាងក្រសួង អង្គការម្ចាស់ជំនួយ អង្គការសង្គមស៊ីវិល និងស្ថាប័នឧត្តមសិក្សាសំខាន់ៗជាមួយនឹងបញ្ហាផ្ទៃក្នុងដែលស្ថាប័ននីមួយៗ កំពុងប្រឈម។

## ការសង្ខេបរបកគំហើញសំខាន់ៗ

### ការស្រាវជ្រាវជាដំណើរការ៖

វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យរបស់យើងគឺជាយានដ៏មានសារៈសំខាន់មួយ សម្រាប់វាយតម្លៃ បរិយាកាសនៃការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។ ជាមួយនឹងវិធីសាស្ត្រនេះ យើងទទួលបានការជួបជាមួយតួអង្គសំខាន់ៗនៅក្នុងស្ថាប័នស្រាវជ្រាវ ព្រមទាំងទទួលបាននូវការលាតត្រដាងដោយស្មោះត្រង់ទាក់ទងទៅនឹងភាពជោគជ័យដោយផ្ទាល់ខ្លួនរបស់ពួកគេ និងកត្តាបរាជ័យផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ សំខាន់ជាងនេះទៀត ជាមួយនឹងវិធីសាស្ត្រនេះ យើងបានក្លាយទៅជាអ្នកចូលរួមដ៏សកម្មនៅក្នុងការបង្កើតឱ្យមានបរិយាកាសស្រាវជ្រាវដល់រស់រវើកមួយ។ នៅក្នុងអំឡុងពេលធ្វើការពិភាក្សាតុមូលជាមួយសិស្សនិស្សិតដែលពីមុនមិនបានដឹងអ្វីសោះនោះ បានក្លាយទៅជាអ្នកដែលបានដឹងឮ មិនមែនត្រឹមតែអំពីបរិយាកាសស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងបានដឹងអំពីគំនិតដែលថាបរិយាកាសស្រាវជ្រាវនេះគឺជាវិធីមួយដែលអាចដឹកនាំឱ្យមាននៅថាមពលផ្ទាល់ខ្លួនសម្រាប់ពួកគេទៀតផង។

**បរិយាកាសកំពុងស្ថិតនៅក្នុងអន្តរកាល៖** តាមរយៈការពិភាក្សាយ៉ាងជិតស្និទ្ធនានាជាមួយនិស្សិត និងអ្នកស្រាវជ្រាវផ្សេងៗ យើងបានរកឃើញអំពីអ្វីដែលគេបាននិយាយ និងវិធីដែលពួកគេទទួលបាននូវការស្រាវជ្រាវដែលមានការប្រទាញប្រទង់ជាមួយ នឹងឯការប៉ាន់ប្រមាណដែលធ្វើឡើងដោយអ្នករដ្ឋបាលមួយចំនួន។ អ្នកគ្រប់គ្រងផ្នែករដ្ឋបាលមួយចំនួនបានប្រាប់យើងថា និស្សិត "ជាទូទៅមិនសូវចូលរួមក្នុងការស្រាវជ្រាវហើយពួកគេមិនសូវយល់ពីប្រយោជន៍ពីបណ្ណាល័យផងដែរ"(ZY:Dean1) ឬថាពួកគេមានការ(ភ័យខ្លាច) ចំពោះការស្រាវជ្រាវ (UBB: DR) ហើយពួកគេបានបន្ថែមទៀតថា អ្នកប្រាជ្ញជាជនជាតិកម្ពុជាខ្វះខាត "ការយល់ដឹងនៅក្នុងការផ្តល់តម្លៃដល់ការស្រាវជ្រាវ"(PUC:Dean2)។ យើងបានស្នើឡើងថាគម្លាតរវាងការយល់ឃើញ និងអាទិភាពជាក់ស្តែងដែលជាប្រធានបទកំពុងផុសឡើងមួយនៅក្នុងទិន្នន័យរបស់ពួកគេយើងបានស្នើឡើងថាបរិយាកាសនៃការស្រាវជ្រាវកំពុង ស្ថិតនៅក្នុងដំណាក់កាលអន្តរកាល។ នេះគឺជាបរិយាយកាសមួយដែលកំពុងមានសភាពរឹងមាំទៅៗ ហើយ

ខណៈដែលអ្នករដ្ឋបាលជាច្រើននៅតែមានអារម្មណ៍អំពីការខកខាន នៅក្នុងប្រទេសកម្ពុជានេះ អ្នករដ្ឋបាលទាំងអស់នោះ ដែលពិនិត្យមើលដោយយកចិត្តទុកដាក់អំពីបរិយាកាសស្រាវជ្រាវដែលកំពុងតែផុសឡើងអាច នឹងចាប់ផ្ដើមធ្វើគោលនយោបាយចេញអំពីមូលដ្ឋាននេះទៅបាន ហើយវាជាគោលនយោបាយឆ្លុះបញ្ចាំងអំពីតម្រូវការបច្ចុប្បន្នទៅលើសកម្មភាពស្រាវជ្រាវ និងគំនិតផ្ដួចផ្ដើមថ្នាក់ជាតិរបស់ពួកគេទៀតផង។

**ស្ថាប័ននៅក្នុងប្រទេសកម្ពុជាមានបុគ្គលដែល "ស្រេកឃ្លានការស្រាវជ្រាវ"** ផ្នែកមួយនៃភាពអន្តរកាលដែលយើងបានឃើញនេះគឺស្ថិតនៅក្នុងផ្នែកមួយនៃភាពអន្តរកាល ដែលយើងបានឃើញគឺស្ថិតក្នុងការប្រមូលផ្ដុំផ្សេងៗគ្នានៃអ្នកអប់រំសម័យបច្ចុប្បន្នជាច្រើន។ ប្រជាជនកម្ពុជាដែលបានទទួលការអប់រំមកពីក្រៅប្រទេសកាន់តែច្រើនកំពុងតែវិលត្រឡប់មកក្នុងប្រទេសវិញ ដោយមានសញ្ញាបត្រជាន់ខ្ពស់ៗ ហើយមានសាកលវិទ្យាល័យឯកជនកាន់តែច្រើនដែលមានថវិកា និងជួលបុគ្គលិកបង្រៀនដែលបានទទួលការអប់រំល្អអំពីបរទេសផងដែរ។ ខណៈដែលស្ថាប័នទាំងអស់នេះនៅតែខ្វះខាតហេដ្ឋារចនាសម្ព័ន្ធក្នុងការគាំទ្រចំពោះបរិយាកាសស្រាវជ្រាវនោះ បុគ្គលិកបង្រៀនរបស់ពួកគេកំពុងតែផលិតនូវការស្រាវជ្រាវផ្ទាល់ខ្លួន ហើយពួកគេក៏កំពុងតែរំពឹងទុក និងទាមទារថា ការសិក្សាស្រាវជ្រាវត្រូវតែទទួលបានការគាំទ្រ ត្រូវតែទទួលបានការផ្ដល់តម្លៃនិងមានការទទួលស្គាល់។

**អតុល្យភាពយេនឌ័រ**

ការស្រាវជ្រាវរបស់យើងបានបង្ហាញឱ្យឃើញនូវអតុល្យភាពយេនឌ័រដ៏មានឥទ្ធិពលមួយ។ អតុល្យភាពនេះគឺមិនសូវជាមានភាពខ្លាំងក្លានៅក្នុងវិស័យអង្គការមិនមែនរដ្ឋាភិបាលទេ ខណៈស្ថាប័នពីរក្នុងចំណោមស្ថាប័នចូលរួម៤ត្រូវបានគ្រប់គ្រងដោយស្ត្រី។ មានតែអ្នកស្រាវជ្រាវម្នាក់ក្នុងចំណោមអ្នកស្រាវជ្រាវនាំមុខគេ៦នាក់ ដែលយើងបានសម្ភាសគឺជានារី។ការពិភាក្សាជាក្រុមជាមួយនិស្សិត គឺមានតុល្យភាពដោយសារតែជួនកាលយើងមានស្ត្រីច្រើនជាងបុរស។ ការសម្ភាសអ្នកផ្ដល់ព័ត៌មានសំខាន់ៗគឺភាគច្រើនធ្វើឡើងជាមួយបុរស ហើយអ្នកដែលបានធ្វើការឆ្លើយតបក្នុងការស្ទាបស្ទង់មតិ ក៏បានបង្ហាញអំពីភាពលម្អៀងទៅខាងផ្នែកបុរសខ្លាំងដែរ ( សូមមើលទំព័រទី២៧) គេមិនអាចមានយេនឌ័រ នៅតែលើផ្នែកណាមួយ ហើយអតុល្យភាព យេនឌ័រ នឹងមើលមិនឃើញភ្លាមៗនោះទេ។ អតុល្យភាពយេនឌ័រនៅគ្រឹស្ថានឧត្តមសិក្សាគឺមានភាពច្បាស់ណាស់រហូតដល់យើងឃើញថា សម្រាប់ស្ថាប័នចូលរួមតែមួយគត់ដែលមានស្ត្រីជាសាកលវិទ្យាធិការជាតិនោះ យេនឌ័ររបស់គាត់បានក្លាយទៅជាកម្មបទពិភាក្សាផ្ដល់យោបល់ជាច្រើន ដល់ប្រធាននាយកដ្ឋាននីមួយៗរបស់ពួកគេ។ បញ្ហាប្រឈមទាំងអស់នេះក៏បានលេចឡើង នៅក្នុងចំណោមស្ត្រី ដែលបានចូលរួមនៅក្នុងការពិភាក្សាជាក្រុមផ្ដោតលើនិស្សិតដែរ ហើយរឿងទាំងអស់នេះក៏បានរួមបញ្ចូលនូវបញ្ហាមួយចំនួនដូចជាបញ្ហាទាក់ទងជាមួយនឹងការធ្វើដំណើរ ចរាចរណ៍ ហើយនឹងចម្ងាយជាដើមសម្រាប់ការចុះស្រាវជ្រាវ

(USEA:SRT,RUA:SRT)។ ការដែលស្ត្រីមានអារម្មណ៍ថាជួបឧបសគ្គ ឬក៏មានការលំបាកចំពោះសមត្ថភាពរបស់គេចំពោះការធ្វើដំណើរ ហើយនឹងធ្វើការស្រាវជ្រាវដោយឯករាជ្យនោះ គឺជាការឆ្លុះបញ្ចាំងអំពីភាពលម្អៀងរបស់បុរសនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា រួមជាមួយនឹងការខ្វះខាតតួនាទីគំរូ ការលើកទឹកចិត្ត និងបញ្ហាសាកលអំពីភាពលម្អៀងរបស់បុរសដែលមើលឃើញកាន់តែច្បាស់នៅក្នុងប្រទេស ដែលមានការអភិវឌ្ឍតិចតួច។

**គោលដៅរបស់ម្ចាស់ជំនួយបានរារាំងរាជរដ្ឋាភិបាល**

ការស្រាវជ្រាវភាគច្រើនបំផុតដែលត្រូវបានធ្វើឡើងក្នុងប្រទេសកម្ពុជា បច្ចុប្បន្ននេះបានទទួលការគាំទ្រពីមូលនិធិពីអង្គការម្ចាស់ជំនួយ បរិយាកាសដែលនាំមកដោយម្ចាស់ជំនួយបែបនេះមានលក្ខណៈមួយចំនួននៅក្នុងប្រទេសកម្ពុជា ហើយយើងបានរកឃើញវិធីសំខាន់ៗពីរ ដែលវារារាំងជាជាងជំរុញដល់ការស្រាវជ្រាវដ៏មានប្រសិទ្ធភាពដល់ប្រទេសកម្ពុជា។ ទី១. គម្រោងរបស់ម្ចាស់ជំនួយគឺជាគម្រោងដែលមានរយៈពេលខ្លីមិនមានគោលបំណងជាក់លាក់ និងគ្មានគោលបំណងជាក់ស្តែង។ គម្រោងបែបនេះរារាំងដល់ការស្រាវជ្រាវដែលមានលក្ខណៈស៊ើបអង្កេត ពីព្រោះការប្រមូល និងការវិភាគទិន្នន័យដើមគឺមិនមែនជារឿងងាយស្រួលនោះទេ គឺវាមិនលឿន ហើយក៏មិនថយដែរ។ ប៉ុន្តែវាគឺជាទម្រង់នៃការប្រមូលព័ត៌មានដែលគួរឱ្យជឿទុកចិត្តបានជាទីបំផុត សម្រាប់សេដ្ឋកិច្ចចំណេះដឹង ហើយជារឿយៗ វាត្រូវបានរារាំងដោយសារតែពេលវេលានៃមូលនិធិរបស់ម្ចាស់ជំនួយ។ បន្ថែមពីលើនេះ ការសិក្សាស្រាវជ្រាវរបស់យើងបានរកឃើញថា មូលនិធិរបស់ម្ចាស់ជំនួយផ្តោតទៅលើការផ្សព្វផ្សាយរបាយការណ៍របស់ម្ចាស់ជំនួយដែលមានការផ្តោតតិចតួចទៅលើការប្រាស្រ័យទាក់ទងទូលំទូលាយ។ ទី២. ឧបសគ្គដែលនាំមុខដោយម្ចាស់ជំនួយដែលស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាគឺឥទ្ធិពលរបស់អ្នកប្រឹក្សាយោបល់ទៅលើបរិយាកាសការស្រាវជ្រាវនៅក្នុងប្រទេស។ ក្រសួងនានាបានរាយការណ៍ថា ខ្លួនមិនបានទទួលការផ្តល់មូលនិធិឱ្យបានគ្រប់គ្រាន់ដើម្បីធ្វើការងារប្រមូលទិន្នន័យដើមឱ្យបានគ្រប់គ្រាន់នោះទេ ប៉ុន្តែមានត្រឹមតែមូលនិធិគ្រប់គ្រាន់សម្រាប់បង់ថ្លៃដល់អ្នកផ្តល់ប្រឹក្សាដល់អ្នកដែលមកពីក្រៅប្រទេស ហើយត្រូវចំណាយថ្លៃមែនទែន។ ភាពពឹងផ្អែកទៅលើអ្នកប្រឹក្សាយោបល់នេះបានធ្វើឱ្យថយចុះនូវការកសាងសមត្ថភាព និងបង្កើតបានជាវប្បធម៌នៃការពឹងផ្អែកមួយ ហើយផលិតបានតែការស្រាវជ្រាវដែលគុណភាពនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។

**សិក្ខាសាលាដែលចែករំលែកផ្សព្វផ្សាយទិន្នន័យប៉ុន្តែមិនបានកសាងសមត្ថភាព**

សិក្ខាសាលាគឺជាយានដល់ប្រសើរបំផុតមួយសម្រាប់ការផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវទៅដល់ភាគីពាក់ព័ន្ធនឹងធ្វើគោលនយោបាយ។ ក៏ប៉ុន្តែសម្រាប់ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសិក្ខាសាលាទាំងអស់នេះមិនបានបង្កើតឱ្យមានលទ្ធផលដូចដែលយើងប្រាថ្នាចង់បាននោះ

ទេ។ ទោះបីជសិក្ខាសាលាអាចនឹងចំណាយថវិកាតិច និងមិនសូវប្រើប្រាសកម្លាំងច្រើនក៏ដោយ ក៏សិក្ខាសាលាទាំងអស់នេះមិនបានផលិតនូវលទ្ធផលដែរ ពីព្រោះសិក្ខាសាលាទាំងអស់នេះ ខ្វះខាតដំណើរការដែលមានលក្ខណៈពិសោធន៍ការរៀនសូត្រអាចកើតឡើងបានដោយពិតប្រាកដ។ មានតែការធ្វើការស្រាវជ្រាវផ្ទាល់នេះហើយដែលធ្វើឱ្យមានការកសាងសមត្ថភាព (CDRI:FD) ។ និស្សិតបានយល់ដឹងអំពីបញ្ហាទាំងអស់នេះ ហើយបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ការចូលរួមជាក់ស្តែងនៅក្នុងស្រាវជ្រាវគឺជា "ការផ្ទេរពីទ្រឹស្តីទៅក្នុងការអនុវត្តជាក់ស្តែង" (SOU:FRI)។

**រដ្ឋាភិបាលមិនមានគោលបំណងធ្វើការស្រាវជ្រាវដូចអ្នកស្រាវជ្រាវនិងនិស្សិតទេ**

ការស្រាវជ្រាវដែលឧបត្ថម្ភដោយរាជរដ្ឋាភិបាល និងម្ចាស់ជំនួយបង្ហាញអំពីចំណង់ខ្លាំងក្នុងការស្រាវជ្រាវដែលមានពាក់ព័ន្ធទៅនឹងអាជីវកម្ម និងកសិកម្មដែលការសិក្សាទាំងនេះមានការអនុវត្តជាក់ស្តែងផ្អែកទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ អ្នកស្រាវជ្រាវនិងនិស្សិតច្រើនតែផ្តោតទៅលើទិន្នផលទៅលើការស្រាវជ្រាវផ្នែកសង្គម និងការអភិវឌ្ឍខ្លួនដែលមានភាពខ្វះខាតខ្លាំងពីការពិភាក្សាផ្នែកគោលនយោបាយ។

**កិច្ចសហការរវាងស្ថាប័នឧត្តមសិក្សានិងអង្គការសង្គមស៊ីវិលដែលស្នើឡើងដោយភាគីទាំងពីរ**

ជារឿយៗ យើងមានគម្លាតតាមលក្ខណៈប្រពៃមួយ រវាងការស្រាវជ្រាវបែបអនុវត្តដែលធ្វើឡើងដោយអង្គការសង្គមស៊ីវិល និងការសិក្សាស្រាវជ្រាវបែបអប់រំដែលចេញមកអំពីសាកលវិទ្យាល័យ។ ក៏ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាទាំងអង្គការសង្គមស៊ីវិល និងអ្នកស្រាវជ្រាវបែបសិក្សាបានបង្ហាញអំពីសេចក្តីប្រាថ្នានៅក្នុងការប្រមូលបង្រួបបង្រួមគ្នានូវធនធានមានកម្រិតរបស់ពួកគេឱ្យបានជាក់រួមគ្នាក្នុងគោលបំណង ដើម្បីកសាងសមត្ថភាពស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលមានមូលនិធិច្រើន និងមានសកម្មភាពច្រើនជាង និងមានសកម្មភាពស្រាវជ្រាវកំពុងតែធ្វើនាពេលបច្ចុប្បន្នច្រើនដែរ។ ស្ថានភាពទាំងអស់នេះអាចផ្តល់នូវបទពិសោធន៍ជាក់ស្តែងសម្រាប់និស្សិត ដែលអាចនាំយកមកអនុវត្តនូវចំណេះដឹងផ្នែកទ្រឹស្តីរបស់ពួកគេ។ លើសពីនេះទៅទៀត វាអាចនឹងផ្តល់នូវសំឡេងបន្ថែមទៀតទៅដល់អ្នកស្រាវជ្រាវសិក្សាបែបអប់រំមានការលំបាកដោយសារតែបរិយាកាសនយោបាយនៅក្នុងប្រទេសកម្ពុជា។

**បញ្ហាមូលនិធិ និងសមត្ថភាពមិនសូវមានភាពខុសគ្នាទេ**

កង្វះខាតមូលនិធិសម្រាប់ការស្រាវជ្រាវប្រធានបទដ៏ស៊ីសង្វាក់មួយ នៅក្នុងការសម្ភាសរបស់ពួកយើង។ នេះជាការពិតណាស់ដែលអ្នកស្រាវជ្រាវសិក្សាអប់រំ នៅក្នុងប្រទេសកម្ពុជាមិនមានប្រាក់ខែច្រើននៅឡើយទេ ហើយនិស្សិតនិងគ្រូបង្រៀននៅសាកលវិទ្យាល័យត្រូវតែស្វែងរកមូលនិធិគាំទ្រ ដល់ការសិក្សាស្រាវជ្រាវរបស់ពួកគេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទោះបីជានៅពេលដែលមាន

មូលនិធិក៏ដោយ ក៏គម្រោងស្រាវជ្រាវមួយចំនួនមិនត្រូវបានគេអនុវត្តដែរ។ បញ្ហាមួយគឺទាក់ទងនឹងកិច្ចការងារដ៏ច្រើននៅក្នុងការងាររបស់ពួកគេ ហើយដែលវាទាក់ទងជាមួយនឹងការផ្តល់មូលនិធិ ក៏ប៉ុន្តែវាក៏ជាបញ្ហាផ្នែករចនាសម្ព័ន្ធដ៏ស៊ីជម្រៅមួយដែលមានការពាក់ព័ន្ធជាមួយប្រាក់ខែ និងការលើកទឹកចិត្តផ្សេងៗឧទាហរណ៍ (ដូចជាភាពជាសាស្រ្តាចារ្យជាដើម) ព្រមទាំងបន្ទប់នៃការបង្រៀនវគ្គច្រើនៗ។ សូម្បីតែអ្នកដែលមានថាមពលអាចចូលរួមជាឯករាជ្យ ក៏មិនបានដឹងថាតើគេអាចរកមូលនិធិបាននៅកន្លែងណា ហើយអាចរកបានដូចនោះឡើយ។ បញ្ហាមួយទៀតថាអ្នកស្រាវជ្រាវមិនទាន់មានសមត្ថភាពនៅក្នុងការអនុវត្តគម្រោងការស្រាវជ្រាវនៅឡើយទេ ហើយកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាពដោយស្ថាប័នជាច្រើន បានផ្តល់ជាលទ្ធផលមកវិញនោះគឺការបាត់បង់បុគ្គលិកជាជាងបាត់បង់ស្ថាប័នរបស់ពួកគេ។ សមត្ថភាពនៅក្នុងប្រទេសកម្ពុជាក៏ទាមទារជំនាញផ្នែកភាសាអង់គ្លេសឱ្យបានច្បាស់លាស់ ហើយដែលនេះជាបញ្ហាប្រឈមសំខាន់មួយសម្រាប់អ្នកស្រាវជ្រាវ។

**ការចាប់យកគោលនយោបាយពឹងផ្អែកទៅលើការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ**

ការសិក្សារបស់យើងបានបង្ហាញឱ្យឃើញនូវវិធីដ៏មានប្រសិទ្ធភាពបីសម្រាប់ជំរុញអន្តរកម្មរវាងការស្រាវជ្រាវនិងគោលនយោបាយ។ ទី១គឺការ ធ្វើការស្ទួមតិ ហើយការផ្សព្វផ្សាយជាសាធារណៈអំពីភាពមិនគ្រប់គ្រាន់នៃគោលនយោបាយដោយផ្អែកទៅលើភ័ស្តុតាង ដែលប្រមូលបានពីការប្រមូលទិន្នន័យនិងពីឯកសារផ្សេងៗត្រូវបានគេធ្វើឡើងតាមរយៈការស្រាវជ្រាវទៅលើប្រភពឯកសារដើម។ នេះគឺជាវិធីរបស់អង្គការមិនមែនរដ្ឋាភិបាល។វិធីដ៏មានប្រសិទ្ធភាពទី២គឺត្រូវចងមិត្តជាមួយអ្នកធ្វើគោលនយោបាយ ហើយផ្តល់ឱ្យអ្នកធ្វើគោលនយោបាយនោះនូវការធ្វើការស្រាវជ្រាវដ៏មានប្រយោជន៍តែមិនជំទាស់នឹងគោលបំណងរបស់ពួកគេនោះទេ។នេះគឺជាវិធីសាស្រ្តរបស់ក្រុមអ្នកត្រិះរិះពិចារណា។ វិធីដែលមានប្រសិទ្ធភាពទី៣គឺការផ្តល់ឱ្យអ្នកធ្វើគោលនយោបាយទាំងអស់នោះនូវមូលនិធិមួយចំនួន និងផ្តល់ដល់ឱ្យពួកគេនូវការស្រាវជ្រាវមួយដែលមិនជំទាស់នឹងគោលបំណងរបស់ពួកគេ។ នេះគឺជាវិធីសាស្រ្តរបស់ម្ចាស់ជំនួយ។ អ្នកស្រាវជ្រាវនៅ គ្រឹះស្ថានឧត្តមសិក្សា ជាទូទៅមានចំណងខ្សោយណាស់ជាមួយអ្នកធ្វើគោលនយោបាយ។ ប្រព័ន្ធផ្សព្វផ្សាយសង្គមកំពុងតែធ្វើការកែលម្អសមត្ថភាពរបស់ឧត្តមសិក្សានៅក្នុងការធ្វើការសិក្សាស្រាវជ្រាវ ហើយអ្នកស្រាវជ្រាវមួយចំនួនកំពុងតែបង្ហាញនូវស្នាដៃរបស់ពួកគេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចំណងជាមួយអ្នកធ្វើគោលនយោបាយនៅមានកម្រិតតិចតួចស្តួចស្តើងខ្លាំងណាស់។

# ២.ក្របខ័ណ្ឌបញ្ញត្តិ និងវិធីសាស្ត្រស្រាវជ្រាវ

## គោលបំណងនៃការស្រាវជ្រាវ

គោលបំណងរួមនៃគម្រោងស្រាវជ្រាវនេះគឺដើម្បីកត់ត្រាចងក្រងជាឯកសារ និងកែលម្អបរិយាកាសស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។ គោលបំណងដ៏ទូលំទូលាយនេះអាចនឹងបញ្ជាក់ច្បាស់បន្ថែមទៀតជាគោលបំណងតូចៗចំនួន៧៖

- វាស់វែងសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រសង្គម និងធ្វើចំណាត់ថ្នាក់អង្គការដែលពាក់ព័ន្ធជាមួយនឹងការស្រាវជ្រាវ។
- ស៊ើបអង្កេត និងពិនិត្យមើលទៅលើរបៀបដែលការស្រាវជ្រាវត្រូវបានគេបកស្រាយឱ្យក្លាយទៅជាគោលនយោបាយសាធារណៈប្រកបដោយជោគជ័យ។
- ប៉ាន់ប្រមាណអំពីកម្រិតដែលអង្គការស្រាវជ្រាវទាំងឡាយមានការពាក់ព័ន្ធ និងការកសាងសមត្ថភាពរបស់អ្នកស្រាវជ្រាវ។
- ទាញយកប្រយោជន៍ពីកម្មវិធីតាមដានសិស្សដើម្បីវាយតម្លៃអំពីសក្តានុពលសម្រាប់ការចូលរួមរបស់និស្សិតជាមធ្យោបាយមួយដើម្បីបង្កើតធនធានមនុស្សនៅក្នុងការស្រាវជ្រាវ។
- ស្វែងយល់អំពីការអនុវត្តល្អៗរបស់អង្គការស្រាវជ្រាវទាំងឡាយដែលរួមចំណែកដល់គោលនយោបាយសាធារណៈនិងការអភិវឌ្ឍអ្នកស្រាវជ្រាវវ័យក្មេង។
- ទទួលនូវការយល់ដឹងអំពីបរិមាណ និងគុណភាពនៃការស្រាវជ្រាវដែលកំពុងត្រូវបានផលិតក្នុងខណៈដែលមានការបង្កើតនូវបណ្តាញមួយដើម្បីចងអ្នកស្រាវជ្រាវជាមួយគ្នា និងតភ្ជាប់របកគំហើញព្រមទាំងផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ។
- តាមរយៈការប្រើប្រាស់បណ្តាញធនធានដែលប្រើប្រាស់ដោយប្រព័ន្ធអ៊ីនធើណិតត គឺដើម្បីកំណត់រកឱ្យឃើញនូវយន្តការមួយចំនួនសម្រាប់ជំរុញ និងកែលម្អទាំងការផ្សព្វផ្សាយជាសាធារណៈពីការស្រាវជ្រាវទៅដល់ភាគីពាក់ព័ន្ធ និងក្នុងការបញ្ចូលលទ្ធផលនៃការស្រាវជ្រាវទៅក្នុងដំណើរការគោលនយោបាយ សាធារណៈ។

## ក្របខ័ណ្ឌបញ្ញត្តិ៖ សកម្មភាពដែលមានចំណងភ្ជាប់គ្នាទៅវិញទៅមកចំនួនបី

បើនិយាយជាទូលំទូលាយ គម្រោងនេះរួមមានផ្តោតទៅលើវិស័យនិងសកម្មភាពចំនួនបី៖ ការសិក្សាស្រាវជ្រាវវិភាគស៊ីជម្រៅទៅលើបរិមាណ និងគុណភាពនៃការស្រាវជ្រាវបែបវិទ្យាសាស្ត្រសង្គមដែលកំពុងតែធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ការស្រាវជ្រាវរបស់និស្សិត និងសមាសភាពនៃការតាមដានព្រមទាំងការអភិវឌ្ឍវេទិកាវិជ្ជាជីវៈសម្រាប់ការបោះពុម្ពផ្សាយឱកាសស្រាវជ្រាវ និងលទ្ធផលស្រាវជ្រាវ។

**ការសិក្សាស៊ីជម្រៅ**

ដោយសារតែការស្រាវជ្រាវពីមុននៅមានកម្រិតតិចតួចស្ដីអំពីបរិយាកាសស្រាវជ្រាវ នៅក្នុងប្រទេសកម្ពុជា គម្រោងនេះផ្ដោតជាចម្បងទៅលើការសិក្សាទិន្នន័យដើម ដែលប៉ាន់ប្រមាណទៅលើបរិយាយកាសស្រាវជ្រាវវិទ្យាសាស្ត្រសង្គមនៅក្នុងស្ថាប័នឧត្ដមសិក្សា អង្គការសង្គមស៊ីវិល អង្គការម្ចាស់ជំនួយ ក្រុមអ្នកគិតនិងស្ថាប័នវិស័យសាធារណៈ។ យើងប្រើប្រាស់ទាំងវិសាលភាពបែបបរិមាណវិស័យនិងគុណវិស័យនៅគ្រឹះស្ថានឧត្ដមសិក្សាក្នុងគោលបំណងដើម្បីស្វែងយល់អំពីទិដ្ឋភាពជាក់លាក់មួយចំនួន អំពីការផលិតការស្រាវជ្រាវ (តាមរយៈការធ្វើការស៊ុំមតិដែលគ្រប់គ្រងនៅក្នុងស្ថាប័ននៅទីក្រុងនិងនៅជនបទ) ព្រមទាំងការសម្ភាសបែបគុណវិស័យស៊ីជម្រៅ និងការពិភាក្សាតុមូលដើម្បីស្វែងយល់អំពីការលំបាកបែបរចនាសម្ព័ន្ធ និង ចំណង់ចំណូលចិត្ត និងការលើកទឹកចិត្តដល់តួអង្គដែលមានការពាក់ព័ន្ធ។ នៅក្នុងអង្គការសង្គមស៊ីវិលនិងស្ថាប័នវិស័យសាធារណៈ យើងបានធ្វើការសម្ភាសបែបគុណវិស័យស៊ីជម្រៅ។ ការសិក្សាស្រាវជ្រាវដោយទិន្នន័យដើមនេះក៏បានសួរថា តើកម្មវិធីបណ្ដុះបណ្ដាល ឬក៏កម្មវិធីតាមដាននឹងវេទិកា ដែលប្រើប្រាស់តាមប្រព័ន្ធអ៊ីធើណិតនេះអាចត្រូវបានប្រើប្រាស់ដើម្បីកសាងសមត្ថភាពស្រាវជ្រាវ និងដើម្បីកែលម្អការចាប់យកលទ្ធផលនៃការស្រាវជ្រាវចូលទៅក្នុងការធ្វើគោលនយោបាយដែរឬទេ។

**ការស្រាវជ្រាវរបស់និស្សិតនិងការបង្វឹកហាត់៖** សមាសភាពសំខាន់មួយនៃគម្រោងនេះ គឺការស្រាវជ្រាវបែបសកម្មភាពវិធីសាស្ត្រ ដោយប្រើប្រាស់ការស្រាវជ្រាវរបស់និស្សិត និងការតាមដានទាំងក្នុងការរៀបចំបង្កើតនូវសំណាក និងនៅក្នុងការប្រមូលទិន្នន័យដើមនិងទិន្នន័យបន្ទាប់បន្សំ។ យើងបានបង្កើតឱ្យមានជាវគ្គបណ្ដុះបណ្ដាលស្រាវជ្រាវបែបច្នៃប្រឌិតថ្មីមួយ ដែលមានរួមបញ្ចូលទាំងការសិក្សាបែបថ្នាក់រៀនដែលមានលក្ខណៈតានតឹងមួយ ព្រមទាំងបទពិសោធន៍ចុះប្រមូលទិន្នន័យជាក់ស្ដែង ដែលពេលបច្ចុប្បន្ននេះយើងកំពុងធ្វើឱ្យមានតាមរយៈវេទិកាតាមប្រព័ន្ធអ៊ីនធើណិតសម្រាប់ស្ថាប័នស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា ដើម្បីទទួលយកទៅប្រើប្រាស់។ វគ្គសិក្ខាសាលាដូចថ្នាក់រៀនដែលរយៈពេលពីរថ្ងៃនេះផ្ដោតទៅលើឧបករណ៍និងបច្ចេកទេសនៅក្នុងការប្រមូលទិន្នន័យផ្សេងៗគ្នា។ សិស្សទទួលបានការបណ្ដុះបណ្ដាល ហើយបានបង្ហាញទាំងការយល់ដឹងដែលមានការកើនឡើង និងការកោតសរសើរចំពោះការសិក្សាស្រាវជ្រាវ។ ពួកគេទទួលបានទាំងចំណេះដឹង និងទំនុកចិត្តនៅក្នុងវិស័យដូចខាងក្រោមនេះ៖ ពិធីការក្នុងការស្រាវជ្រាវ ការសម្ភាស ការស៊ុំមតិ ការពិភាក្សាជាក្រុមការសង្កេត ការត្រួតពិនិត្យឡើងវិញស្នាដៃដែលមានស្រាប់(ការស្វែងរកឯកសារការដកស្រង់ឯកសារ ការប្រមូលទិន្នន័យបណ្ណសារ ការគ្រប់គ្រងទិន្នន័យ និងការវិភាគទិន្នន័យ)។ កម្មវិធីបណ្ដុះបណ្ដាលនេះ បានទទួលជោគជ័យខ្លាំងមែនទែន។ លទ្ធផលបណ្ដុះបណ្ដាល ដែលគេរំពឹងទុករួមមាន ទាំងការដែលសិស្សនិស្សិតអាចសួរសំណួរសំខាន់ៗ ហើយនឹងធ្វើការសិក្សាស្រាវជ្រាវប្រកបដោយប្រសិទ្ធភាពមួយដើម្បីឆ្លើយនូវសំណួរទាំងអស់នោះ អ្នកដែលដឹងអំពីសមាសភាពផ្សេងៗគ្នានៃគម្រោងស្រាវជ្រាវ ចាប់តាំងពី

ការចាប់ផ្តើមដំបូងរហូតដល់ការផ្សព្វផ្សាយព្រមទាំងនិស្សិតដែលអាចធ្វើការស្រាវជ្រាវ និងដឹកនាំគម្រោងស្រាវជ្រាវដោយឯករាជ្យនៅក្នុងពេលអនាគត។ ក្នុងចំណោមសិស្សនិស្សិតទាំង១៦នាក់ ដែលយើងបានបណ្តុះបណ្តាល ២នាក់បានទទួលអាហារូបករណ៍ទៅសិក្សានៅបរទេស ១នាក់កំពុងធ្វើការជាជំនួយការស្រាវជ្រាវនៅក្នុងគម្រោងស្រាវជ្រាវដ៏សកម្មមួយស្តីអំពីការប្រែប្រួលអាកាសធាតុ ៣នាក់បានក្លាយទៅជាអ្នកចូលរួមជាទៀងទាត់នៅក្នុងសកម្មភាពស្រាវជ្រាវនៅ CICP ១នាក់បានចាប់ផ្តើមការស្រាវជ្រាវរបស់ខ្លួនស្តីអំពី គោលនយោបាយសាធារណៈ ហើយ៧នាក់ទៀតបានធ្វើការជាបណ្តោះអាសន្នម្តងម្កាលទៅលើ "គម្រោងស្រាវជ្រាវនេះ" ដោយសារតែពួកគេជាប់រវល់ក្នុងការបន្តការសិក្សារបស់ខ្លួន។ មាននិស្សិតតែ២នាក់តែប៉ុណ្ណោះដែលមិនបានឆ្លើយតបចំពោះឱកាសស្រាវជ្រាវ ដែលផ្តល់ឱ្យដោយគម្រោងនេះ នេះជាការបង្ហាញអំពីអាត្រាខ្ពស់នៃចំណាប់អារម្មណ៍ និងបង្ហាញអំពីសមត្ថភាពរបស់និស្សិត និងសេចក្តីប្រាថ្នាចង់ចូលរួមនៅក្នុងការស្រាវជ្រាវទាំងឡាយ។ ការអភិវឌ្ឍវេទិកាវិជ្ជាជីវៈ និងធនធានតាមប្រព័ន្ធអ៊ីនធើណិត សម្រាប់ការស្រាវជ្រាវ និងឱកាសបណ្តុះបណ្តាល និងការផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ។ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមសំខាន់ៗនៅក្នុងការកែលម្អបរិយាកាសស្រាវជ្រាវ គឺកង្វះការទទួលបានការស្រាវជ្រាវបន្ទាប់បន្សំ និងការចងបណ្តាញកិច្ចសហប្រតិបត្តិការដែលនៅមានកម្រិត ព្រមទាំងចំណេះដឹងនៃឱកាសស្រាវជ្រាវក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយ។ នេះនឹងក្លាយទៅជាគេហទំព័រដំបូងគេមួយនៅក្នុងប្រទេស ដែលខិតខំប្រឹងប្រែងប្រមូលនូវអត្ថបទស្រាវជ្រាវ ដែលអាចរកបានទាំងអស់នៅក្នុងវិទ្យាសាស្ត្រសង្គម ហើយនឹងផ្តល់នូវវេទិកាមួយសម្រាប់អ្នកប្រើប្រាស់ ដែលបានចុះឈ្មោះដើម្បីបញ្ចេញនូវមតិយោបល់របស់ពួកគេ ហើយនឹងចោទជាសំណួរនៅក្នុងវេទិកានេះ ដើម្បីបង្ហាញខ្លួនរបស់ពួកគេនៅក្នុងប្រវត្តិអ្នកស្រាវជ្រាវ ហើយនឹងដើម្បីឱ្យពួកគេបានដឹងអំពីព័ត៌មាន ស្តីអំពីការផ្តល់មូលនិធិអំពីការស្រាវជ្រាវ និងការចងបណ្តាញ ព្រមទាំងឱកាសនៅក្នុងការសហការជាមួយគ្នា ហើយគេហទំព័រនេះមានទម្រង់ដូចតទៅ:

1. Home
2. About us
   - About Us (briefly describe the objectives and research outcomes of GDN
3. Publication (only social science fields)
   - Politics
   - Economics
   - Society and Culture

- Environment
- Law
- Foreign Affairs

4. Researchers

- Researcher profiles
- Institutional profiles

5. Opportunities

- Research training / seminars
- Call for proposal
- Research positions

6. Forum ( interactive platform )

- project
- Contact

គោលបំណងមួយនៃគម្រោងនេះធ្វើឱ្យមានភាគីពាក់ព័ន្ធ (ដែលរួមបញ្ចូលទាំងអ្នកស្រាវ ជ្រាវ និងអ្នកធ្វើគោលនយោបាយ) ចូលរួមនៅក្នុងការរចនា និងការធ្វើតេស្តទៅលើគេហទំព័រនេះចាប់តាំងពីដំបូងទៅ។ ទន្ទឹមគ្នានេះដែរ យើងបានរៀបចំកិច្ចប្រជុំតុមូល និងការប្រជុំក្រៅផ្លូវការផ្សេងៗដើម្បីប្រមូលយោបល់ត្រឡប់ និងដើម្បីដឹកនាំឡើងវិញទៅលើវិធីសាស្ត្រតាមតម្រូវការជាក់ស្តែង។ គេហទំព័រនេះគឺជាដំណាក់កាលកំពុងតែស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការផលិត ហើយនឹងត្រូវធ្វើការដាក់ផ្សាយឱ្យប្រើប្រាស់មុនសប្តាហ៍ទីបីនៃខែធ្នូ ឆ្នាំ២០១៥។

**វិធីសាស្ត្រ**

ការធ្វើយុទ្ធកម្មសម្រាប់វិធីសាស្ត្រដែលមានភាពចាំបាច់បញ្ចូលគ្នា គម្រោងនេះបានបង្កើតឡើងប្រកបដោយជោគជ័យ និងបានប្រើប្រាស់ការធ្វើសំណើដ៏ល្អប្រសើរមួយ និងការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដ៏ល្អមួយ។ យុទ្ធសាស្ត្រនៅក្នុងការធ្វើសំណើត្រូវបានគេពិភាក្សាលម្អិតយ៉ាងពេញលេញនៅខាងក្រោម។ គម្រោងនេះបានប្រមូលផ្តុំនូវទិន្នន័យដើមតាមរយៈវិធីសាស្ត្របែបគុណវិស័យ (កិច្ចប្រជុំតុមូលជាមួយនិស្សិត ការសម្ភាសដែលពាក់កណ្តាលរចនាសម្ព័ន្ធជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដោយរួមបញ្ចូលទាំងមន្ត្រីនៅក្នុងក្រសួងស្ថាប័នរដ្ឋ ដែលមានការពាក់ព័ន្ធក្នុងរដ្ឋបាលសាកលវិទ្យាល័យ

បុគ្គលិកសាកលវិទ្យាល័យ និងអ្នកសម្របសម្រួលគម្រោងអង្គការសង្គមស៊ីវិល) ព្រមទាំងការស្ទង់មតិបែបបរិមាណវិស័យដែលធ្វើឡើងចំពោះអ្នកបង្រៀននៅសាកលវិទ្យាល័យ។ ការប្រើប្រាស់វិធីចម្រុះនេះមានសារៈសំខាន់សម្រាប់ការប្រមូលព័ត៌មានដោយសារតែវាអាចផ្តល់ឱ្យអ្នកឆ្លើយតបនូវឱកាសនៅក្នុងការបញ្ចេញនូវទស្សនៈ បទពិសោធន៍តាមពាក្យពេចន៍របស់ខ្លួនតាមរយៈការរៀបរាប់ស៊ីជម្រៅមួយហើយដែលមានភាពស៊ីសង្វាក់ជាមួយនឹងគោលបំណងនៃការកសាងសមត្ថភាព ក៏ដូចជាការប្រមូលនូវទិន្នន័យបែបគុណវិស័យដ៏ធំមួយដើម្បីស្វែងយល់អំពីគុណភាពនិងបរិមាណនៃការស្រាវជ្រាវបែបសិក្សាអប់រំ និងការស្រាវជ្រាវដែលមិនមានលក្ខណៈសង្ស័យ។

**វិធីសាស្រ្តបង្កើតសំណើ**

បញ្ជីស្ថាប័នដែលត្រូវបានជ្រើសរើសនិងប្រវត្តិស្ថាប័នរបស់ពួកគេអាចរកបាននៅក្នុងឧបសម្ព័ន្ធទីមួយ។ដើម្បីទទួលបានបញ្ជីនេះ ជាដំបូងយើងប្រមូលផ្តុំបញ្ជី នៅសាកលវិទ្យាល័យតាមរយៈការប្រើប្រាស់ប្រព័ន្ធ អ៊ីនធើណិត និងព័ត៌មាន Derictori ដែលអាចរកបានជាសាធារណៈ (ភាគច្រើនគឺជាប្រព័ន្ធទិន្នន័យ ដែលយើងរកបានតាមរយៈគេហទំព័រនិងបញ្ជីសាកលវិទ្យាល័យ ដែលកំពុងមានសកម្មភាពដែលត្រូវបានបោះពុម្ពផ្សាយ ដោយក្រសួងអប់រំ យុវជន និង កីឡា )។ យើងបានធ្វើចំណាត់ថ្នាក់សាកលវិទ្យាល័យ ទាក់ទងជាមួយនឹងការផលិតការស្រាវជ្រាវរបស់ពួកគេ ( ច្រើន មធ្យម ឬក៏ខ្ពស់)។ យើងក៏បានបង្កើតនូវបញ្ជីនៃក្រុមអ្នកត្រិះរិះពិចារណា ព្រមទាំងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការសិក្សាស្រាវជ្រាវភាគច្រើនគឺទទួលមកអំពីគេហទំព័ររបស់ពួកគេ។ ដោយសារតែមានចំនួនសាកលវិទ្យាល័យច្រើន ហើយអង្គការសង្គមស៊ីវិលជាច្រើន ដែលបច្ចុប្បន្ននេះកំពុងមានភាពសកម្មនៅក្នុងប្រទេសកម្ពុជា ដែលបង្ហាញនូវសកម្មភាពតិចតួច ឬគ្មានសកម្មភាពសោះ ក្នុងការអភិវឌ្ឍការស្រាវជ្រាវ បន្ទាប់មក យើងបានធ្វើការគណនាវិធីសាស្រ្តនេះ តាមរយៈការប្រមូលនូវគំនិតរបស់អ្នកសិក្សាជំនាញរយៈការពិភាក្សាតុមូល ដែលធ្វើនៅ CICP នៅថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៥ ។ បញ្ជីទាំងអស់នេះ ត្រូវបានផ្តល់ទៅឱ្យក្រុមអ្នកចូលរួមនៅកិច្ចប្រជុំតុមូល ដែលរួមមាន អ្នកសិក្សាស្រាវជ្រាវ អ្នកស្រាវជ្រាវនៅក្នុងក្រុមត្រិះរិះពិចារណា និង មន្ត្រីរដ្ឋាភិបាល ដែលត្រូវបានបញ្ជូនដំណឹងទៅក្រសួងផែនការ ។ ការពិភាក្សានេះបង្កើតបានជាគំនិតអ្នកជំនាញ ដោយផ្អែកទៅលើបញ្ជីដែលយើងបានពិនិត្យទៅលើលទ្ធផលនៃការស្រាវជ្រាវ តាមអ៊ីនធើណិត ដើម្បីកំណត់អំពីនិរន្តរភាព និងប្រយោជន៍នៃសំណើរបស់ពួកយើង និងដើម្បីធានាថាសំណើចុងក្រោយត្រូវបានឆ្លុះបញ្ចាំងដូចខាងក្រោម៖

**សម្រាប់គ្រឹះស្ថានឧត្តមសិក្សាសំណាករួមមាន៖**

- សំណាករួមមានទាំងសាកលវិទ្យាល័យឯកជននិងសាកលវិទ្យាល័យរដ្ឋដែលមានការពាក់ព័ន្ធក្នុងការស្រាវជ្រាវ។

- សាកលវិទ្យាល័យដែលជាសំណាកទាំងអស់នេះត្រូវបញ្ចូលការស្រាវជ្រាវជាផ្នែកមួយនៃដំណើរការធ្វើសារណា ឬជាសមាសធាតុដែលគេរំពឹងថាជាការងាររបស់បុគ្គលិកសាកលវិទ្យាល័យ។
- សំណាកនេះរួមបញ្ចូលទាំងសាកលវិទ្យាល័យដែលត្រូវបានវិនិច្ឆ័យផ្អែកទៅលើការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណិតជាដំបូង និងគំនិតរបស់អ្នកជំនាញថាមានកម្រិត «ខ្ពស់» ឬ «មធ្យម» ឬ «ទាប» នៅក្នុងការផលិតការស្រាវជ្រាវ ។
- គម្រោងនេះក៏រួមមាន សាកលវិទ្យាល័យនៅក្នុងរាជធានីភ្នំពេញ ហើយនៅក្នុងបណ្តាខេត្ត ដើម្បីឱ្យយើងអាចមានលទ្ធភាពនៅក្នុងការលើកឡើងអំពីភាពបែងចែងខុសគ្នារវាងទីក្រុង និងជនបទដែលកំណត់នៅមានលក្ខណៈសម្គាល់របស់កម្ពុជា។
- ជម្រើសចុងក្រោយនៃសាកលវិទ្យាល័យទាំងនោះ ( បញ្ជីសំណាកមួយដែលមានស្ថាប័នសិក្សាជាន់ខ្ពស់ឧត្តមសិក្សាចំនួន១២ ) ដែលត្រូវផ្អែកទៅលើការពិចារណាដូចខាងលើនោះ ពឹងផ្អែកទៅលើការពិចារណាអំពីអនុសាសន៍ នៃអ្នកសិក្សាស្រាវជ្រាវជាក់ស្តែងដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សាតុមូលរបស់ CICP និងផ្អែកទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណិត អំពីសកម្មភាពនៃសាកលវិទ្យាល័យទាំងអស់ដែលបានចុះបញ្ជី។

នៅក្នុងសាកលវិទ្យាល័យទាំងឡាយនោះ អ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានគេផ្តោតទៅលើដោយអាស្រ័យ ទៅលើមូលដ្ឋាននៃតួនាទីរបស់ពួកគេ ( ប្រធាន នាយកកិច្ចការសិក្សាស្រាវជ្រាវ នាយកស្រាវជ្រាវ ព្រឹទ្ធបុរសផ្នែកវិទ្យាសាស្ត្រសង្គម )។ តាមរយៈព័ត៌មានដែលបានទទួលនៅក្នុងការសម្ភាសបែបគុណវិស័យជាមួយនឹងតួអង្គសំខាន់ៗ បញ្ជីនៃមហាវិទ្យាល័យត្រូវបានកំណត់ឡើងសម្រាប់ធ្វើការសម្ភាស។

**សម្រាប់សង្គមស៊ីវិលសំណាករួមមាន៖**

- ស្ថាប័នដែលមានការចូលរួមក្នុងការស្រាវជ្រាវដោយមានការផ្សព្វផ្សាយអំពីសកម្មភាពរបស់ពួកគេជាសាធារណៈ
- ស្ថាប័នដែលមានការចូលរួមនៅក្នុងការស្រាវជ្រាវដែលពាក់ព័ន្ធជាមួយនឹងគោលនយោបាយ។
- ស្ថាប័នដែលមានបុគ្គលិកកម្ពុជាដែលមានភាពស្ទាត់ជំនាញក្នុងផ្នែកភាសាអង់គ្លេសនឹងបានទទួលការអប់រំបានល្អ។
- ស្ថាប័នដែលប្រមូលទិន្នន័យដើម ឬក៏ទិន្នន័យដែលមានប្រភពដើម បរិយាកាសអង្គការសង្គមស៊ីវិលគឺមានលក្ខណៈពិបាកនៅក្នុងការស្រាវជ្រាវ ពីព្រោះបុគ្គលិកទាំងនោះមានភាពមមាញឹកខ្លាំងមែនទែន ហើយដោយសារតែការសម្ភាសរបស់ពួកយើងត្រូវការពេលវេលារបស់ពួកគេដើម្បីសួររកមតិយោបល់។បន្ទាប់ពីទាក់ទងតាមរយៈអ៊ីម៉ែលជាមួយនឹងនាយកស្ថាប័ន ដោយ

យើងត្រូវបានណែនាំឱ្យជួបជាមួយនឹងអ្នកផ្តល់ព័ត៌មានដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។ យើងធ្វើការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗជាមួយនឹងមន្ត្រីគម្រោងមួយឬក៏ពីរនាក់នៅស្ថាប័នដែលយើងបានជ្រើសរើសនីមួយៗនោះ។

**សម្រាប់ក្រុមពិចារណាសំណាករួមមាន៖**

- វិទ្យាស្ថានដែលមានការស្រាវជ្រាវនាពេលបច្ចុប្បន្ន ( ២០១៤ ) និងមានសកម្មភាពបោះពុម្ពផ្សាយ
- កម្មវិធីស្រាវជ្រាវដែលរួមមានការតាមដានត្រួតពិនិត្យ ហើយនឹងគំនិតផ្តួចផ្តើមនៅក្នុងការបណ្តុះបណ្តាល។
- វិទ្យាស្ថានដែលផលិតការស្រាវជ្រាវដោយមានផលប៉ះពាល់ទៅលើគោលនយោបាយពាក់ព័ន្ធ អ្នកផ្តល់ព័ត៌មានសំខាន់ៗ នៃក្រុមត្រិះរិះពិចារណាត្រូវបានគេផ្តោតជាគោលដៅទៅលើតួនាទី (នាយក) ។ ដោយសារតែបុគ្គលទាំងអស់នេះមានការលំបាក ទាក់ទងជាមួយនឹងពេលវេលា យើងបានផ្ញើសំណួរទៅពួកគេតាមរយៈ Email ហើយពួកគេបានឆ្លើយតបនឹងសំណួររបស់យើងជាលាយល័ក្ខណ៍អក្សរ។

**ក្រសួងរបស់រាជរដ្ឋាភិបាលសំណាករួមមាន៖**

- ក្រសួងដែលមានការពាក់ព័ន្ធចំពោះការរចនាគម្រោងរបស់ពួកយើង
- ក្រសួងដែលធ្វើការប្រមូលទិន្នន័យប្រភពដើមផ្អែកទៅលើតួនាទី (នាយក)
- ក្រសួងដែលយើងអាចធ្វើការសិក្សាស្រាវជ្រាវជាមួយ

ការសម្ភាសត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គលបន្ទាប់ពីបានផ្ញើលិខិតសមរម្យមួយទៅដល់ក្រសួងនីមួយៗដោយគូសបញ្ជាក់អំពីគម្រោងរបស់យើង និងការផ្តល់នូវបញ្ជីសំណួរគំរូមួយចំនួន។

**សម្រាប់អង្គការម្ចាស់ជំនួយសំណាករួមមាន៖**

- ការសិក្សាស្រាវជ្រាវកំពុងធ្វើការសិក្សាស្រាវជ្រាវនិងបោះពុម្ពផ្សាយជាសាធារណៈនៃរបាយការណ៍ដែលអាចរកបាន
- កំពុងធ្វើការស្រាវជ្រាវដោយមានការជាប់ទាក់ទងនឹងគោលនយោបាយ
- កំពុងធ្វើការស្រាវជ្រាវស្តីអំពីវិទ្យាសាស្ត្រសង្គម អង្គការម្ចាស់ជំនួយមានការលំបាកនៅក្នុងការទាក់ទងសម្ភាស។ បន្ទាប់ពីការព្យាយាមទាក់ទងជាច្រើនដង យើងអាចធ្វើការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗជាមួយមន្ត្រីទម្រង់មួយមកពីអង្គការចំនួនពីរក្នុងចំណោមអង្គការចំនួនបីដែលបានជ្រើសរើសយកមកសិក្សា។




*Figure 1: Locations of Surveyed Institutions*

*Table 1: Phnom Penh Universities and Institutions:*

| Universities | CSO | Think Tank | Donor | Ministry |
|---|---|---|---|---|
| Royal University of Phnom Penh | Equitable Cambodia | Cambodia Development Research Institute | World Bank | Ministry of Education Youth and Sports |
| Zaman University of Cambodia | Cambodian Center for Human Rights | Center for Khmer Studies | Asia Development Bank | Ministry of Planning |
| Royal University of | Committee for Free and Fair Elections | Sleuk Rith Institute/ DC-Cam | | |

| | | | | |
|---|---|---|---|---|
| Law and Economics | | | | |
| Royal University of Agriculture | Cambodian League for the Promotion and Defense of Human Rights | | | |
| Paññasastra University of Cambodia | | | | |
| National University of Management | | | | |

**ទិន្នន័យ និងឧបករណ៍សម្រាប់ស្ទង់មតិ៖**

យើងបានរចនាពិធីការស្រាវជ្រាវ៤ផ្សេងៗគ្នាដើម្បីប្រមូលយកនូវប្រភេទព័ត៌មានផ្សេងៗគ្នាពីអ្នកឆ្លើយតបរបស់យើងនៅក្នុងឧបសម្ព័ន្ធទី៣។ ពិធីការទាំងនេះរួមមានការវិភាគបែបគុណវិស័យ និងបែបបរិមាណវិស័យ និង រួមបញ្ចូលទាំងសំណួរបើក និងសំណួរបិទ៖

១. ការសម្ភាសដែលផ្តល់ព័ត៌មានសំខាន់ៗ សំណួរសម្រាប់សម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗសម្រាប់រដ្ឋបាល គ្រឹះស្ថានឧត្តមសិក្សា និងរដ្ឋមន្ត្រីត្រូវបានបង្កើតឡើងជាសំណួរដែលមានលក្ខណៈទូលំទូលាយដើម្បី៖

-ទទួលបាននូវព័ត៌មានជាទិដ្ឋភាពទូទៅអំពីអង្គភាព ហើយនឹងដើម្បីផ្តត់ផ្គង់ឱ្យពួកគេនូវលំហមួយដែលពួកគេអាចពង្រីកទៅប្រតិបត្តិការរបស់ពួកគេបាន។

-យល់អំពីបញ្ហាប្រឈមដែលពួកគេជួបប្រទះនៅក្នុងការធ្វើការស្រាវជ្រាវដែលមានគុណភាព ប្រកបដោយប្រសិទ្ធភាព។

- រៀនសូត្រអំពីគំនិតរបស់ពួកគេដើម្បីធ្វើការកែលម្អ និងធ្វើការផ្លាស់ប្តូរ

២. សំណួរសម្រាប់សម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ប្រធាននាយកដ្ឋាន បុគ្គលិកបង្រៀនអង្គការមិនមែនរដ្ឋាភិបាល និងដៃគូដែលជាអង្គការផ្នែកអភិវឌ្ឍន៍ត្រូវបានរៀបចំឱ្យមានលក្ខណៈលម្អិតបន្ថែមទៀត និងរចនាឡើងដើម្បីផ្តល់នូវព័ត៌មានពិនិត្យទៅលើអ្វីដែលខាងរដ្ឋបាល និងរដ្ឋមន្ត្រីបានអះអាង ថាតើការអះអាងទាំងអស់នេះមានលក្ខណៈយ៉ាងដូចម្តេច? ក្នុងការអនុវត្តជាក់ស្តែង យើងចង់រៀនសូត្រអំពីគោលបំណងរបស់ស្ថាប័ន ដែលទាក់ទងជាមួយនឹងការអនុវត្តការស្រាវជ្រាវប្រភពមូលនិធិ និងបញ្ហាប្រឈម វិធីសាស្ត្រសម្រាប់ការស្រាវជ្រាវ គំនិតផ្តួចផ្តើមក្នុងការបណ្តុះបណ្តាល ភាពរកបាននូវធនធានការជានាគុណភាព ការបោះពុម្ពផ្សាយ ការផ្សព្វផ្សាយនិងការប្រើប្រាស់ការស្រាវជ្រាវ។ យើងបានសួរអំពីបញ្ហាប្រឈមជាទូទៅក្នុងការស្រាវជ្រាវ និងសួរអំពីអនុសាសន៍សម្រាប់ធ្វើការកែលម្អ ឬសម្រាប់ធ្វើការកែប្រែ។

៣. សិស្សនិស្សិតដែលមានការចូលរួមក្នុងកិច្ចពិភាក្សាតុមូលត្រូវបានរៀបចំឡើងដើម្បីទទួលបាននូវការយល់ឃើញអំពីជំនាន់របស់ពួកគេ និងការស្រាវជ្រាវ ហើយក៏ដើម្បីយល់អំពីគោលនយោបាយរបស់សាកលវិទ្យាល័យ ត្រូវបានយកទៅប្រើប្រាស់ក្នុងការអនុវត្តជាក់ស្តែងសម្រាប់និស្សិត។ យើងបានស្នើសុំឱ្យមានគំនិតមួយចំនួនសម្រាប់ធ្វើការកែប្រែ និងធ្វើការកែលម្អ។

៤.ការស្ទង់មតិតាមបែបបរិមាណវិស័យក៏ត្រូវបានរចនាឡើង ដើម្បីសួរប្រធាននាយកដ្ឋាននិងសាស្ត្រាចារ្យមួយចំនួនទៀត គឺឱ្យបានច្រើនជាងអ្វីដែលយើងអាចធ្វើបានជាមួយនឹងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ហើយក៏ដើម្បីបំពេញបន្ថែមនូវសមាសធាតុគុណវិស័យ ដោយមានការសង្កត់ធ្ងន់បន្ថែមទៀតទៅលើសំណួរទាំងឡាយដែលទាក់ទងនឹងចំនួន និងប្រភេទនៃការស្រាវជ្រាវដែលត្រូវបានបោះពុម្ពផ្សាយអំពីការប្រាស្រ័យទាក់ទងផ្នែកស្រាវជ្រាវ ការទទួលបាន និងការប្រើប្រាស់ការស្រាវជ្រាវ ព្រមទាំងព័ត៌មានពាក់ព័ន្ធវិទ្យាសាស្ត្រ។ ការធ្វើបែបនេះក៏បានផ្តល់នូវទីតាំងមួយសម្រាប់ឱ្យសាស្ត្រាចារ្យនិងប្រធាននាយកដ្ឋានអាចឆ្លើយនូវសំណួរដោយមិនចាំបាច់បញ្ចេញឈ្មោះ។

ការឆ្លើយតបនៅក្នុងការស្ទង់មតិទាំងអស់នេះត្រូវបានប្រមូលតាមក្រដាស កម្មវិធីរបស់កុំព្យូទ័រមួយដើម្បីវិភាគប្រើប្រាស់កម្មវិធី SPSS។ ការសម្ភាសត្រូវបានធ្វើប្រតិចារឹកដោយអ្នកធ្វើកំណត់ត្រា ហើយបន្ទាប់មកបញ្ចូលចូលទៅក្នុងកុំព្យូទ័រ រួចដាក់ចូលទៅក្នុងប្រធានបទរៀងៗខ្លួន។

## ភាពកំហិតនៃការរចនាការស្រាវជ្រាវ

យើងបានប្រឹងប្រែងធ្វើសំណាកបែបប្រូបាបប៊ីលីតេសម្រាប់សមាសភាព នៃការធ្វើការស្ទង់មតិជាមួយនឹងគ្រូបង្រៀននៅមហាវិទ្យាល័យ ប៉ុន្តែការធ្វើបែបនេះមានការលំបាកខ្លាំងពេក ។ សមាជិកដែលជាគ្រូបង្រៀននៅសមាជិកនៅក្នុងមហាវិទ្យាល័យជាច្រើន ដែលមានពេលវេលាសម្រាប់ឱ្យយើងធ្វើការសម្ភាសនោះទេ ឬពួកគេមិនអាចនឹងឱ្យយើងជួបបាន ដោយសារតែពួកគេនៅមហាវិទ្យាល័យ តែពេលបង្រៀនតែប៉ុណ្ណោះ ហើយបើមិនដូច្នេះទេគឺពួកគេធ្វើការនៅកន្លែងផ្សេងទៀត ។ ការលំបាកទាំងឡាយដែលយើងបានជួបប្រទះនៅក្នុងការជួបជាមួយនឹងគ្រូបង្រៀន នៅសាកលវិទ្យាល័យនេះគឺជាការបញ្ជាក់អំពីបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុដែលពួកគេប្រឈមមុខ ហើយដែលយើងនឹងរុករកពេញលេញនៅក្នុងជំពូកទីប្រាំ ។ ចំពោះបញ្ហាមួយនេះយើងបានផ្លាស់ប្តូរវិធីសាស្ត្ររបស់យើង ដោយប្រើប្រាស់ជាការធ្វើសំណាកបែបបាល់ព្រិលទៅវិញសម្រាប់ការធ្វើការស្ទង់មតិ និងសម្រាប់ការធ្វើសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ ។ សម្រាប់ហេតុផលមួយនេះវាមិនអាចទៅរួចទេ នៅក្នុងការកំណត់លក្ខណៈអំពីចំនួនអ្នកធ្វើការស្រាវជ្រាវឱ្យបានដូចដែលយើងចង់ជ្រើសរើសតាមបែបចៃដន្យ ហើយដែលកត្តានេះបាននាំឱ្យមានសំណាកមួយដែលមិនមានលក្ខណៈជាតំណាងឡើយ ។ បន្ថែមពីលើនេះចំនួននៃអ្នកឆ្លើយតបគឺមិនត្រូវបានចែកចាយឱ្យបានស្មើគ្នានៅឡើយក្នុងចំណោមសាកលវិទ្យាល័យទាំងអស់ ហើយការបែងចែកនេះក៏មិនបានថ្លឹងថ្លែងដោយផ្អែកទៅលើទំហំនៃសាកលវិទ្យាល័យដែរ។ នេះមានន័យថា សាកលវិទ្យាល័យដែលមានអ្នកឆ្លើយតបច្រើន មិនមែនមានន័យថាជាសាកលវិទ្យាល័យដែលធំជាងគេជានិច្ចនោះទេ ។ ការបែងចែកអ្នកឆ្លើយតបក្នុងចំណោមសាកលវិទ្យាល័យនេះគឺផ្អែកជាសាមញ្ញទៅលើកម្រិតនៃការដែលយើងអាចទទួល ឬក៏អាចរកបាននូវអ្នកឆ្លើយទាំងអស់នោះនៅសាកលវិទ្យាល័យផ្សេងៗគ្នា ។

*Table 2: Survey Data Respondents*

| University | Frequency | Percent |
|---|---|---|
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>Royal University of Phnom Penh | 28 | 15,3 |
| សាកលវិទ្យាល័យភូមិកសិកម្ម<br>Royal University of Agriculture | 15 | 8,2 |
| សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច<br>Royal University of Law and Economics | 22 | 12,0 |

| | | |
|---|---|---|
| សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា<br>Pannasastra University of Cambodia | 12 | 6,6 |
| សាកលវិទ្យាល័យហ្សាម៉ាន់<br>Zaman University | 9 | 4,9 |
| សាកលវិទ្យាល័យស្វាយរៀង<br>Svay Rieng University | 11 | 6,0 |
| សាកលវិទ្យាល័យបាត់ដំបង<br>University of Battambang | 38 | 20,8 |
| សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>National University of Management | 5 | 2,7 |
| សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍<br>University of Southeast Asia | 26 | 14,2 |
| សាកលវិទ្យាល័យមានជ័យ<br>Mean Chey University | 17 | 9,3 |
| **Total** | **183** | **100,0** |

ដោយសារតែចំនួនអ្នកឆ្លើយតបនៅសាកលវិទ្យាល័យនីមួយៗមានកម្រិតតិចតួច ហើយដោយសារតែវិធីដែលបានប្រើសម្រាប់ប្រមូលទិន្នន័យ និងលទ្ធផលនៃការវិភាគទិន្នន័យនេះមិនអាចត្រូវបានគេធ្វើការប៉ាន់ប្រមាណ ឬស្មានសម្រាប់សាកលវិទ្យាល័យទាំងអស់ ឬក៏សម្រាប់សាកលវិទ្យាល័យកម្ពុជាជាទូទៅបានឡើយ។ ក៏ប៉ុន្តែ ការវិភាគរួមគ្នាបែបគុណវិស័យ បរិមាណវិស័យពិតជាបានផ្តល់នូវការគណនាមួយអំពីលទ្ធផល ហើយបានលើកឡើងក្នុងសភាពដ៏រឹងមាំមួយអំពីប្រធានបទសំខាន់ ស្រដៀងគ្នា ដែលបង្កើតបានជាមូលដ្ឋានគ្រឹះនៃរបាយការណ៍នេះ ។ ការឆ្លើយតបនៅក្នុងកម្រងសំណួរអាចត្រូវបានគេប្រើដើម្បីពិសោធទៅលើអំពីថាតើអ្នកឆ្លើយតបទាំងអស់នោះយល់នូវសំណួរទាំងអស់នោះបានកម្រិតប៉ុណ្ណា។ តារាងទីប្រាំប្រៀបធៀបនូវសំណួរពីរ ។ សំណួរទី២៣សួរថាតើអ្នកឆ្លើយតបធ្លាប់បានចូលរួមក្នុងការស្រាវជ្រាវដែរឬទេ ។ សំណួរទី២៨ សួរអំពីចំនួនគម្រោងស្រាវជ្រាវដែលអ្នកឆ្លើយតបបានចូលរួម ។ តាមន័យតក្កវិទ្យា ប្រសិនបើអ្នកឆ្លើយតបប្រកាសថាមិនបានចូលរួមនៅក្នុងការស្រាវជ្រាវណាមួយនោះទេនោះ ចម្លើយរបស់ពួកគេសម្រាប់សំណួរទី ២៨ គឺ សូន្យ ។ ក៏ប៉ុន្តែមានមនុស្ស១០ នាក់ដែលបានចូលរួមនៅក្នុងគម្រោងស្រាវជ្រាវមួយ ឬក៏ច្រើន ប៉ុន្តែស្របពេលជាមួយគ្នានោះ គាត់បាននិយាយថាមិនបានចូលរួមនៅក្នុងការស្រាវជ្រាវនោះទេ ។ ប្រការនេះបានបង្ហ

ឱ្យមានភាពសង្ស័យដោយចៀសមិនរួច អំពីភាពត្រឹមត្រូវនៃទិន្នន័យទាំងអស់នេះ ។ មូលហេតុអំពីភាពខុសគ្នានេះមិនត្រូវបានរកឃើញនៅក្នុងលទ្ធផលនៃកម្រងសំណួរទាំងអស់នេះទេ ។ មានតែការស្រាវជ្រាវបែបគុណវិស័យប៉ុណ្ណោះ ដែលអាចផ្តល់នូវចម្លើយសម្រាប់បញ្ហានេះបាន។ ចម្លើយដែលអាចទៅរួចនោះគឺថាអ្នកឆ្លើយតបមិនបានយល់នូវសំណួរទាំងអស់នោះពេញលេញនៅឡើយទេ ។ វាអាចជាឧបសគ្គផ្នែកភាសាមួយ ពីព្រោះកម្រងសំណួរទាំងអស់នេះត្រូវបានគេសរសេរជាភាសាអង់គ្លេស ជាប្រធានបទមួយដែលបានជ្រាបចូលនៅក្នុងរបាយការណ៍របស់យើងដែរ ហើយត្រូវបានគេពិនិត្យយ៉ាងជាក់លាក់នៅក្នុងជំពូកទី៥ ។ បញ្ញត្តិនៃ "ការស្រាវជ្រាវ" ក៏អាចត្រូវបានគេយល់ត្រឹមតែក្នុងសភាពជាការប្រមូលទិន្នន័យដើមតែប៉ុណ្ណោះ ("ការប្រមូលទិន្នន័យ") ហើយអ្នកដែលចូលរួមក្នុងការវិភាគទិន្នន័យបន្ទាប់បន្សំអាចនឹងមិនគិតថា ពួកគេគឺជាអ្នកស្រាវជ្រាវទេ ។ ប្រហែលជាមូលហេតុនៃភាពខុសប្លែកគ្នានេះ គឺជាការប្របាច់បញ្ចូលនូវកត្តាផ្សេងៗគ្នាជាច្រើនដែលមានរៀបរាប់ដូចខាងលើ ។ ហេតុដូច្នេះហើយ វាសំខាន់ណាស់នៅក្នុងការចងចាំក្នុងចិត្តថា ទិន្នន័យមិនតែងតែត្រឹមត្រូវ១០០ភាគរយនោះទេ។ ក៏ប៉ុន្តែ ចំណង់នៅក្នុងកម្រិតខ្ពស់មួយរវាងសំណួរប្រហាក់ប្រហែលគ្នា ហើយនិងការគណនាជាមួយនឹងការសម្ភាសបូកផ្សំជាមួយនឹងទិន្នន័យនៅក្នុងការពិភាក្សាជាក្រុម ពិតជាបានធ្វើឱ្យការស្រង់ទិន្នន័យស្ទង់មតិនៅតែផ្តល់នូវព័ត៌មានស៊ីជម្រៅនៅក្នុងទស្សនៈទូទៅរបស់អ្នកឆ្លើយតប និងជាការបង្ហាញអំពីការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពស្រាវជ្រាវផងដែរ ។

*Table 3: Number of publications (Q28) and Involvement in research (Q23)*

| Number of research projects | Involved in research | | Total |
|---|---|---|---|
| | Yes | No | |
| 0 | 46 | 60 | 106 |
| 1 | 33 | 8 | 41 |
| 2 | 19 | 1 | 20 |

| | | | |
|---|---|---|---|
| 3 | 8 | 0 | 8 |
| 4 | 4 | 0 | 4 |
| 5 | 3 | 1 | 4 |
| Total | 113 | 70 | 183 |

ភាពលម្អៀងមួយផ្សេងទៀតនៅក្នុងការធ្វើសំណាកនេះគឺទាក់ទងជាមួយនឹងការជ្រើសរើសសំណាក បុរសច្រើនជាងស្ត្រី នៅក្នុងឧបករណ៍ស្រាវជ្រាវទាំងអស់របស់ពួកយើង ។ នៅក្នុងតារាងទី២ ជាមួយនឹងតារាងទី៣ ខាងលើយើងឃើញមានភាពលម្អៀងយេនឌ័រដ៏ខ្លាំងក្លាមួយ នៅក្នុងគ្រប់វិស័យទាំងអស់ លើកលែងតែកិច្ចប្រជុំពិភាក្សាតុមូលរបស់និស្សិត ហើយសាកលវិទ្យាល័យចំនួន៧ ក្នុងចំណោមសាកលវិទ្យាល័យចំនួន១០ គឺមិនបានផ្តល់អ្នកឆ្លើយតបជាស្ត្រីសម្រាប់ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ទេ ។ ឧបករណ៍ស្ទង់មតិរបស់ពួកយើងបានបង្កើតនូវភាពលម្អៀងស្រដៀងគ្នានេះមួយ ហើយនៅសាកលវិទ្យាល័យដែលបានចូលរួមចំនួន៣ ស្ត្រីត្រូវបានគេដកចេញទាំងស្រុងពីសំណាកស្ទង់មតិនេះ ។

*Table 4: Survey Instrument Gender division*

| | ចំនួន Frequency | ភាគរយ Percent |
|---|---|---|
| ប្រុស Male | 159 | 86,9 |
| ស្រី Female | 24 | 13,1 |
| Total | 183 | 100,0 |

ភាពលម្អៀងនេះគឺដោយសារតែបញ្ហាស្ថានភាពយេនឌ័រ នៃតួនាទីរបស់អ្នកដឹកនាំនៅក្នុងប្រទេសកម្ពុជាគឺថារដ្ឋបាលសាកលវិទ្យាល័យជាន់ខ្ពស់ភាគច្រើនគឺជាបុរស អ្នកស្រាវជ្រាវភាគច្រើនបំផុតដែលយើងបានជួបគឺជាបុរស ហើយនេះក៏ជាករណីនៃមន្ត្រីសាធារណៈជាច្រើន ដែលភាគច្រើនគាត់គឺជាបុរសដែរ។ ក៏ប៉ុន្តែ នេះមិនមែនសុទ្ធតែអ៊ីចឹងនោះទេដោយសារតែបានកត់សម្គាល់ទៅលើអ្នក

ចូលរួមដែលជានិស្សិត ហើយយើងបានគូសបញ្ជាក់អំពីករណីតួនាទីរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅក្នុងរបាយការណ៍របស់យើងដូចជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យបាត់ដំបងជាដើម។

ទិន្នន័យរបស់ពួកយើងក៏ខ្ពស់ជាងការរំពឹងទុកពីស្ថាប័នម្ចាស់ជំនួយនិងអង្គការសង្គមស៊ីវិលដែរ។ យើងសង្ឃឹមទុកថា នឹងទទួលបានការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ៤នាក់ពីស្ថាប័ននីមួយៗនៃស្ថាប័នទាំងអស់នេះ ប៉ុន្តែផ្ទុយទៅវិញយើងបានទទួលតិចជាងពាក់កណ្តាលនៃចំនួននោះទៅវិញ។ ស្ថាប័នម្ចាស់ ជំនួយមានការលំបាកជាពិសេសក្នុងការទទួលបាននូវអ្នកដែលយើងត្រូវធ្វើសម្ភាសជាមួយ ហើយម្ចាស់ជំនួយមួយនោះមិនបានមានវត្តមានសម្រាប់ការសម្ភាសដែលយើងបានរៀបចំពេលវេលាចំនួន២ដងមកហើយជាមួយអ្នកស្រាវជ្រាវយើង។ ទោះបីជាបន្ទាប់ពីបានទទួលការជួបអ្នកសម្របសម្រួលគម្រោងមួយមកពីស្ថាប័នពីរ យើងអាចទទួលបានក្នុងការបង្កើតវិធីសាស្ត្របែបបាល់ព្រិលដែលគ្មាននៅស្ថាប័នទាំងអស់នោះ។ ក៏ប៉ុន្តែទិន្នន័យដែលយើងប្រមូលបានពីប្រភពទាំងអស់នោះដែលយើងអាចចងភ្ជាប់ជាមួយពួកគេបាននោះគឺទិន្នន័យទាំងអស់នោះ គឺមានភាពសម្បូរបែបមែនទែនយើងមានអារម្មណ៍ថាយើងមានទំនុកចិត្តជាមួយការអះអាងដែលយើងបានលើកឡើង។ ការស្រាវជ្រាវបន្ថែមទៀតបានស្នើឱ្យមានការប្រើប្រាស់នូវឧបករណ៍ស្ទង់មតិតាមរយៈអ៊ីម៉ែល ដែលជាយានមួយមានភាពល្អប្រសើរក្នុងការជួបជាមួយសហគមន៍ទាំងនេះ។

ទោះបីជាមានបញ្ហាប្រឈមជាមួយឧបករណ៍ស្ទង់មតិ ការកំហិតសម្រាប់ការសម្ភាសដែលមានលក្ខណៈជាបាល់ព្រិល (Snow ball) អតុល្យភាពយេនឌ័រ និងទទួលបានអ្នកឆ្លើយតបតិចជាងដែលយើងត្រូវការក៏ដោយ ក៏យើងមានទំនុកចិត្តចំពោះទិន្នន័យដែលយើងបានប្រមូលដែរ។ បញ្ហាប្រឈមចំពោះទិន្នន័យមួយចំនួនរបស់យើងដូចជាបញ្ហាយេនឌ័រគឺជាលក្ខណៈធម្មតា ហើយបញ្ហាប្រឈមផ្សេងៗទៀតដូចជាការជ្រើសរើសតាមបែបប្រូបាប ខណៈដែលយើងទទួលបានតិចជាងអ្វីដែលយើងចង់បាននោះ ក៏វាមិនធ្វើឱ្យប៉ះពាល់ដល់របបគំហើញរបស់យើងច្រើនដែរ។ ចំណុចខ្លាំងមួយក្នុងចំណោមចំណុចខ្លាំងជាច្រើននៃវិធីសាស្ត្រចម្រុះនេះគឺថាការស្ទង់មតិរបស់យើង បង្ហាញបញ្ជាក់ឱ្យកាន់តែច្បាស់អំពីកម្លាំងនៃភាពលម្អៀងផ្នែកយេនឌ័រដែលហួសអំពីការស្រាវជ្រាវដែលយើងបានជ្រើសរើសតាមបែបលក្ខណៈរដ្ឋបាលនេះ ហើយទិន្នន័យបែបគុណវិស័យរបស់ពួកយើងក៏មិនបានចាកឆ្ងាយខ្លាំងអំពីការឆ្លើយតបដែលទទួលបានពីការស្ទង់មតិបែបគុណវិស័យដែរ។ យើងបានជួបជាមួយនឹងអ្នកឆ្លើយតបមួយចំនួនជាច្រើនមកហើយ ហើយទិន្នន័យដែលយើងបានទទួលនោះគឺមានភាពសម្បូរបែបខ្លាំងមែនទែន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មានកំហិតមួយចំនួនដែលអ្នកឆ្លើយតបអាចនឹងមិនសូវមានឆន្ទៈក្នុងការពិភាក្សាដោយស្មោះត្រង់អំពីកំហិតផ្នែករចនាសម្ព័ន្ធដើម្បីធ្វើឱ្យការស្រាវជ្រាវមួយប្រកបដោយប្រសិទ្ធភាព (ជាពិសេសប្រធានបទស្តីអំពីការតាមដានផ្នែកនយោបាយដែលយើងពិភាក្សាក្នុងផ្នែកទី៥)។

# ៣.ការស្រាវជ្រាវឯកសារដែលមានស្រាប់

ការសិក្សាស្រាវជ្រាវឯកសាដែលមានស្រាប់នេះត្រូវបានបែងចែងជាបីសំខាន់ៗ សង្គមស៊ីវិល ឧត្តមសិក្សា និងការសន្និដ្ឋាន។ ផ្នែកពីដំបូងពិភាក្សាអំពីផ្នែកតួអង្គសំខាន់ៗចំនួនពីរនៅក្នុងសហគមន៍ស្រាវជ្រាវគឺអង្គការសង្គមស៊ីវិល និងគ្រឹះស្ថានឧត្តមសិក្សាព្រមទាំងតួនាទីរបស់ពួកគេទាក់ទងជាមួយនឹងរដ្ឋាភិបាលក្នុងការផលិតការស្រាវជ្រាវនិងការផ្សព្វផ្សាយការស្រាវជ្រាវ និងការកសាងសមត្ថភាព។ ផ្នែកទី១ពិនិត្យមើលទៅលើទិដ្ឋភាពទូទៅទូលំទូលាយមួយអំពីការវិវត្តតាមប្រវត្តិសាស្ត្រ ការរួមចំណែក និងបញ្ហាប្រឈមដែលអង្គការសង្គមស៊ីវិលបានជួបប្រទះក្នុងការពង្រីកតួនាទីរបស់ពួកគេក្នុងការស្រាវជ្រាវដែលត្រូវបានគេប្រើប្រាស់នៅក្នុងការធ្វើគោលនយោបាយឱ្យមានប្រសិទ្ធភាព។ ផ្នែកនេះគឺមានលក្ខណៈទូលំទូលាយតាមគោលបំណងរបស់យើង ហើយនឹងមានភាពលម្អិតដល់អ្នកស្រាវជ្រាវចំណុចសំខាន់មួយដែលទាក់ទងជាមួយនឹងអង្គការសង្គមស៊ីវិល។ ការធ្វើបែបនេះគឺជាការស្វែងរកនូវការគាំទ្រជាចំហ ដែលមានអង្គការសង្គមស៊ីវិលកម្ពុជាបានចូលរួមចំណែកយ៉ាងច្រើនទៅដល់បរិយាកាសដែលមានការស្រាវជ្រាវ ប៉ុន្តែមានភាពប្រឈមដោយសារតែផលប៉ះពាល់តិចតួចនៅកម្រិតមូលដ្ឋាន បញ្ហាទាក់ទងនឹងការចូលរួមនៅក្នុងការធ្វើគោលនយោបាយ ដែលការពិតទៅអាចនឹងកែលម្អបានតាមរយៈការសង្កត់ធ្ងន់ទៅលើការរួមចំណែកប្រកបដោយសក្តានុពលរបស់គ្រឹះស្ថានឧត្តមសិក្សានៅក្នុងសហគមន៍ស្រាវជ្រាវ ការវិភាគលម្អិតបន្ថែមទៀតមួយគឺត្រូវបម្រុងសម្រាប់ធ្វើការសន្និដ្ឋានគឺនៅផ្នែកទី៣ ដែលតភ្ជាប់គំនិតសំខាន់ៗដែលបានតភ្ជាប់ការសិក្សាដែលមានឯកសារស្រាប់ទៅនឹងគម្រោងរបស់ CICP ។

**សង្គមស៊ីវិល**

សង្គមស៊ីវិលដែលមិនទាន់មានគឺមានភាពចាំបាច់ណាស់នៅក្នុងរង្វង់ទាំងបីនៃសហគមន៍ គឺមាន ផ្នែកសង្គមសេដ្ឋកិច្ចនយោបាយក្នុងគោលបំណង ដើម្បីឱ្យមានការចរចាប្រកបដោយជោគជ័យដើម្បីរចនាសម្ព័ន្ធអំណាច ដើម្បីជះឥទ្ធិពលទៅលើគោលនយោបាយ។ ក៏ប៉ុន្តែ នៅក្នុងប្រទេសកម្ពុជាក៏ដូចជានៅក្នុងរដ្ឋ ផ្សេងៗទៀតជាច្រើនដែរ "លំហនយោបាយ" ដែលប្រព័ន្ធសង្គមស៊ីវិលអាចប្រតិបត្តិបាន ហើយអាចប៉ះពាល់ នោះកំពុងតែមានភាពចុះខ្សោយ។ កម្មវិធីអភិវឌ្ឍន៍រូបធាតុបានរកឃើញពីថ្នាក់ដឹកនាំប្រជាធិបតេយ្យ ដែលមានភាពកាន់តែរួមទៅនៅថ្នាក់ជាតិ ដោយរួមបញ្ចូលទាំងការរឹតបន្តឹងទៅលើសិទ្ធិសំខាន់ៗ ដែលត្រូវការសម្រាប់កៀរគរប្រមែប្រមូលនិងការផ្សព្វផ្សាយដែលជាភាពដ៏សំខាន់ ដើម្បីឱ្យសហគមន៍ដ៏រឹងមាំមួយចំនួនដូចជាការបញ្ចេញយោបល់ក៏ដូចជាការបង្កើតជាសមាគមព្រមទាំងនីតិរដ្ឋដែលមានភាពខ្សោយ ព្រមទាំងអំពើពុករលួយដែលបង្កើញប្រានឱ្យមានគម្លាតដ៏ធំមួយរវាងគោលនយោបាយ និងការអភិវឌ្ឍគោលនយោបាយទាំងអស់នោះ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានរៀបរាប់អំពីលក្ខខណ្ឌទាំងអស់នេះថាជាការសណ្តោសប្រណីដែលកាន់តែមានភាពអន់ថយចំពោះ

គណបក្សនយោបាយប្រឆាំង ដែលបានជះឥទ្ធិពលទៅលើប្រតិបត្តិការរបស់សង្គមស៊ីវិល (ដោយរួមបញ្ចូលទាំងការស្រាវជ្រាវ ការផ្សព្វផ្សាយ ការចូលរួមមតិ និងការចូលរួមក្នុងការធ្វើគោលនយោបាយ) នៅលើវិស័យទាំងអស់ដែលរដ្ឋាភិបាលគិតថា មានភាពសំខាន់ខ្លាំងចំពោះពួកគេ ហើយជាពិសេសគឺទាក់ទងនឹងផ្នែកសិទ្ធិមនុស្ស។ ទោះបីជាវាសំខាន់ក្នុងការចៀសវាងនូវការកំណត់បែបវប្បធម៌ដែលបានធ្វើការសន្និដ្ឋានថា គំរូតាមបែបប្រពៃណី និងការទទួលខុសត្រូវសង្គម និងអភិបាលកិច្ចតាមបែបផ្តាច់ការមិនអាចឆ្លងផុតបាននោះក្តី ក៏លក្ខខណ្ឌទាំងអស់នេះពិតជាទាមទារឱ្យមានការចោទសួរថាតើប្រទេសកម្ពុជាកំពុងតែធ្វើដំណើរឆ្ពោះទៅរកប្រជាធិបតេយ្យ ឬក៏កំពុងធ្វើដំណើរចេញពីប្រជាធិបតេយ្យ។

រឿងរ៉ាវរបស់ផ្នែកអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាបានឈានទៅដល់ការសន្និដ្ឋានពីរ ដែលមានភាពប្រទាញប្រទង់គ្នាទាក់ទងជាមួយប្រសិទ្ធភាពនិងផលប៉ះពាល់ ម្យ៉ាងទៀតវាត្រូវបានពិភាក្សាយ៉ាងសកម្មនិងមានឥទ្ធិពល ក៏ប៉ុន្តែម្យ៉ាងវិញទៀតគេអាចចាត់ទុកថាវាមានភាពមិនសូវឯករាជ្យដោយត្រូវពឹងផ្អែកទៅលើការចង់បានរបស់ម្ចាស់ជំនួយ វាមានលក្ខណៈមជ្ឈការខ្លាំងពេក ហើយវាបានដាក់កំហិតទៅលើសមត្ថភាពដែលបានជះឥទ្ធិពលទៅលើគោលនយោបាយរដ្ឋាភិបាល។ បើយោងទៅតាមអ្នកប្រាជ្ញម្នាក់លើកឡើងថា“ម្តងហើយម្តងទៀតការពិតដែលស្ទើរតែមានលក្ខណៈជាសាកលចំនួនពីរត្រូវបានលើកឡើងអំពីប្រទេសកម្ពុជា។ ទី១ ប្រទេសនេះគឺពឹងផ្អែកទៅលើជំនួយ។ ទី២ ផ្នែកសង្គមស៊ីវិលនៅមានភាពក្មេងខ្ចីនិងមានភាពទន់ខ្សោយ”។ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ការស្រាវជ្រាវអង្គការសហប្រជាជាតិទៅលើដំណើរប្រជាធិបតេយ្យនីយកម្មនៅក្នុងប្រទេសកម្ពុជាក៏បានបង្ហាញផងដែរថា សង្គមស៊ីវិលមិនទាន់បានអភិវឌ្ឍឱ្យបានពេញលេញនៅក្នុងការធ្វើឱ្យមានឥទ្ធិពលទូលំទូលាយនៅឡើយទេចំពោះការកែលម្អភាពឆ្លើយតបនឹងការចាប់យកធ្វើគោលនយោបាយដែលមានភាពចាំបាច់សម្រាប់បរិយាកាសស្រាវជ្រាវដ៏រឹងមាំនិងប្រកបដោយនិរន្តរភាពមួយ។ ដោយហេតុនេះហើយ ការខំប្រឹងប្រែងរបស់ក្រុមស្រាវជ្រាវយើងនៅក្នុងការពង្រឹងការស្រាវជ្រាវនៅក្នុងវិស័យនេះ ដើម្បីពង្រីកកិច្ចសម្របសម្រួលជាមួយនឹងតួអង្គសំខាន់ៗផ្សេងៗទៀតនៅក្នុងសហគមន៍ស្រាវជ្រាវ (គ្រឹះស្ថានឧត្តមសិក្សា និងរដ្ឋាភិបាល) និងបង្កើតឱ្យមានការចាប់យកលទ្ធផលនៃការស្រាវជ្រាវសម្រាប់ធ្វើគោលនយោបាយឱ្យមានភាពកាន់តែរលូន និងមានប្រសិទ្ធភាពត្រូវដោះស្រាយនូវភាពដែលកើតឡើងដំណាលគ្នានៃភាពរស់រវើក និងមូលដ្ឋានគ្រឹះដ៏ទន់ខ្សោយនៃអង្គការសង្គមស៊ីវិល។ ថាមពលនៃភាពរស់រវើកនិងភាពទន់ខ្សោយមួយផ្នែកបានមកដោយសារតែការផ្លាស់ប្តូរការពឹងផ្អែកទៅលើសមត្ថភាពសង្គមស៊ីវិលដែលជាចលនាមួយដែលគណៈកម្មាធិការសហប្រតិបត្តិការកម្ពុជាបានពន្យល់រៀបរាប់ថា “និន្នាការបណ្តោះអាសន្នមួយ ប៉ុន្តែនិន្នាការដែលទទួលបានការស្វាគមន៍មួយសម្រាប់ការកាត់បន្ថយផលប្រយោជន៍នៃការពឹងផ្អែកទៅលើម្ចាស់ជំនួយ និងបង្កើតការធ្វើឱ្យមានប្រភពផ្សេងនៃថវិកា ព្រមទាំងស្វ័យភាព”។ ទោះជាយ៉ាងណាក៏ដោយ ធនាគារពិភពលោកបានឃើញ

អំពីកង្វះខាតនៃអង្គការពលរដ្ឋ និងការប្រមូលគៀរគរប្រជាជនដែលជាចំណុចខ្សោយដ៏សំខាន់មួយសម្រាប់អង្គការសង្គមស៊ីវិល ប្រជាជននាពេលបច្ចុប្បន្ន ហើយបានយល់ឃើញថា វាកើតចេញអំពីកម្រិតនៃការជឿទុកចិត្តនៃការជឿមូលធនដែលមានលទ្ធភាពទាបនៅឡើយ ។

**បញ្ញត្តិគន្លឹះ**

ទោះបីជាមានការអះអាងថាសង្គមស៊ីវិលគួរតែត្រូវបានគេពិនិត្យមើលក្នុងសភាពដែលជាអញ្ញតិមួយដែលមានភាពមិនច្បាស់លាស់ឬក៏មានភាពប្រទាញប្រទង់យ៉ាងណាក៏ដោយ ក៏មាននិយមន័យដែលគេកំពុងតប្រើប្រាស់មួយចំនួនដែលយើងអាចរកបានដែរ ដែលនេះការឆ្លុះបញ្ចាំងអំពីភាពឯកភាពគ្នានៅក្នុងសហគមន៍អភិវឌ្ឍន៍ និងសហគមន៍ស្រាវជ្រាវវិទ្យាសាស្រ្តសង្គម។ សម្រាប់គោលបំណងនៃរបាយការណ៍នេះយើងបានផ្តល់និយមន័យអង្គការសង្គមស៊ីវិលជាអង្គការដែលមិនមែនជាអង្គការរដ្ឋ មិនមែនជាអង្គការទីផ្សារដែលស្វែងរកប្រាក់ចំណេញ ហើយក៏មិនមែនជាអង្គភាពឯកជន ឬក៏អង្គភាពគ្រួសារមានប្រភេទនៃរចនាសម្ព័នផ្លូវការមួយចំនួនអនុវត្ត យ៉ាងហោចណាស់វិធានការមួយនៃការអភិបាលកិច្ចដោយខ្លួនឯង និងមានរបៀបវារៈស៊ីសង្វាក់មិនស្វែងរកប្រាក់ចំណេញដើម្បីបង្កើតនូវអំពើល្អនៅក្នុងសង្គម អង្គការ Oxfam បានផ្តល់និយមន័យបន្ថែមអំពីសង្គមស៊ីវិលថា ជាវេទិកាមួយដែលខុសប្លែកពីរដ្ឋ និងទីផ្សារដែលមនុស្សលើកកម្ពស់ផលប្រយោជន៍រួមរបស់ពួកគេ និងស្វែងរកការតម្រែតម្រង់ទិសអភិបាលកិច្ចគោលនយោបាយសម្រាប់ផ្តល់ប្រយោជន៍ទាំងអស់គ្នានៅក្នុងសង្គមដោយមិនមានការសន្យាអំពីផលចំណេញបែបជំនួញ ឬក៏បែបនយោបាយឡើយ បើយោងទៅតាមធនាគារអភិវឌ្ឍន៍អាស៊ី សង្គមស៊ីវិលគឺខុសប្លែកពីរដ្ឋាភិបាល និងវិស័យឯកជនព្រមទាំងរួមមានបុគ្គលផ្សេងៗគ្នាជាច្រើន ឬក៏ក្រុមផ្សេងៗគ្នាឬអង្គការដែលមិនស្វែងរកប្រាក់ចំណេញ។ អង្គការសង្គមស៊ីវិលប្រតិបត្តិការជុំវិញផលប្រយោជន៍រួម គោលបំណងរួមនិងគុណតម្លៃរួមជាមួយនឹងកម្រិតខុសគ្នានៃភាពជាផ្លូវការ និងក្រសោបនូវភាពខុសប្លែកគ្នាជាច្រើនគឺថាចាប់តាំងពីក្រុមសហគមន៍ដែលមិនមានការរៀបចំក្នុងសភាពមិនផ្លូវការ ហូតដល់អង្គការសហជីពការងារអន្តរជាតិធំៗ។ ដោយមានការជាប់ពាក់ព័ន្ធជាពិសេសចំពោះធនាគារអភិវឌ្ឍន៍អាស៊ី នោះសង្គមស៊ីវិលជាអង្គការមិនមែនរដ្ឋាភិបាល ជាអង្គការដែលជារបស់សហគមន៍ និងជាអង្គការប្រជាពលរដ្ឋ ជាមូលនិធិ ជាសមាគមវិជ្ជាជីវៈ ជាវិទ្យាស្ថានស្រាវជ្រា វនិងសាកលវិទ្យាល័យ សហជីពអង្គការដែលមានសមាជិកច្រើនចលនាសង្គម និងសម្ព័ន្ធព្រមទាំងបណ្តាញអង្គការសង្គមស៊ីវិលនិងអង្គការដែលមានសិទ្ធិនៅក្រោមឆត្ររបស់ពួកគេ។

## មូលដ្ឋានគ្រឹះប្រវត្តិសាស្ត្រ

ការបញ្ចូលគ្នារវាងរដ្ឋនិងសង្គមស៊ីវិលត្រូវបានគេយល់កាន់តែច្បាស់បន្ថែមទៀត បើសិនជាយុវជននៅក្នុងសង្គមស៊ីវិលត្រូវបានគេយកទៅពិចារណា។ ក្នុងន័យម្យ៉ាង ឯកសារដែលមានស្រាប់ហាក់បីដូចជាមើលទៅសង្គមស៊ីវិល ប្រទេសកម្ពុជាតាមសភាពនៃកណើនរបស់អង្គការដែលផ្តល់មូលនិធិដល់ម្ចាស់ជំនួយ និងសកម្មភាពដែលបានចាប់ផ្តើមជាមួយនឹងអាជ្ញាធរអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និងបន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ។ អង្គការមិនមែនរដ្ឋាភិបាល និងរង្វង់អង្គការសង្គមស៊ីវិល នៅក្នុងសង្គមកម្ពុជានៅមានភាពវ័យក្មេង ហើយមានអង្គការសំខាន់ៗមួយចំនួនដែលត្រូវបានបង្កើតឡើងនៅទសវត្សរ៍ឆ្នាំ១៩៩០ ហើយអង្គការទាំងអស់នោះបង្កើតបន្ទាប់ពីឆ្នាំ២០០០។ អង្គការមិនមែនរដ្ឋាភិបាលដំបូងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩១ បន្ទាប់ពីមួយទសវត្សរ៍នៃការចូលរួមដោយសង្គមស៊ីវិលអន្តរជាតិ ហើយដែលបន្តចេញមកអំពីរយៈពេលនៃជម្លោះសង្គ្រាមស៊ីវិល និងការធ្វើឱ្យបរាជ័យដល់ការពិសោធសង្គមដែលធ្វើឱ្យមានលទ្ធផលកើតចេញមកជាការផ្តាច់ប្តូរសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាទៅវិញ។ ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺនៅក្នុងទសវត្សរ៍អំឡុងឆ្នាំ១៩៨០ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិផ្តល់ភាពសំខាន់ទៅលើការផ្តល់សេវាកម្មដែលមិនមានការគាំទ្រពីស្ថាប័នរដ្ឋឬក៏ដោយសារតែការិយាធិបតេយ្យ។ រួមជាមួយនឹងអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា អ៊ុនតាក់ នៅក្នុងពេលនោះមានអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងស្រុកផ្សេងៗទៀតត្រូវបានបង្កើតឡើង។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនផ្តោតទៅលើលទ្ធិប្រជាធិបតេយ្យ (ការបោះឆ្នោត) និងសិទ្ធិមនុស្ស ប៉ុន្តែចាប់តាំងពីពេលនោះមក ភាពមានការបោះបង់ចោល ក៏បានប្តូរទៅជាអង្គការដែលមានសកម្មភាពទាក់ទងជាមួយនឹងងការអភិវឌ្ឍទៅវិញ ហើយនេះក្នុងគោលបំណងបន្តស្វែងរកឱ្យបាននូវការគាំទ្រប្រភពធនធានមកពីខាងក្រៅតាមរយៈម្ចាស់ជំនួយ។ ការស្រាវជ្រាវរបស់គណៈកម្មាធិការសហប្រតិបត្តិការកម្ពុជា CCC អំពីសមាគុសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាបង្ហាញថាប្រហែលជា៥៨%នៃសង្គមស៊ីវិល ត្រូវបានកើតឡើងក្រោយឆ្នាំ២០០០ ហើយប្រហែលជា៣៦% ត្រូវបានបង្កើតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ នៅក្នុងរយៈពេលនេះ ចំនួនអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានកើនឡើងច្រើនខ្លាំងលឿនជាងចំនួនអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ហើយវាមិនមានអ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះទេដែលការសិក្សាមួយក្នុងឆ្នាំ២០០៨ បានរកឃើញថា មានអង្គការតែ៤៥% ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ១.៥០០ប៉ុណ្ណោះមានភាពសកម្ម ខណៈដែល៩៣%នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចំនួន ៣១៦ មានភាពសកម្ម (១៦)។

ការរកកើតសង្គមស៊ីវិលមានប្រយោជន៍អំពីការកើតឡើងយ៉ាងឆាប់រហ័សនៃសមាគមក្រៅផ្លូវការ ប៉ុន្តែមិនបានគិតគូរដល់កម្រិតមូលដ្ឋាន និងសង្គមស៊ីវិលបែបប្រពៃណីនៅក្នុងប្រទេសកម្ពុជានេះទេ ការមិនបានគិតគូរទាំងអស់នេះអាចពន្យល់បានមួយផ្នែកថាហេតុអ្វីបានជាវិស័យអង្គការមិនមែន

រដ្ឋាភិបាល ដែលម្ចាស់ជំនួយបរាជ័យនៅក្នុងការធ្វើឱ្យមានផលប៉ះពាល់ធំទូលំទូលាយ ទៅលើសង្គមនីយកម្មនយោបាយ និងការប្រមូលផ្តុំបែបនយោបាយ។ ដោយមានការសិក្សារបស់គាត់ស្តីអំពីការទទួលបានព័ត៌មានលោកនីអូបានភ្ជាប់វប្បធម៌នយោបាយនាពេលបច្ចុប្បន្នទៅនឹងការយល់អំពីសមត្ថកិច្ចចំពោះការអនុវត្តបែបប្រពៃណីដែលគេធ្វើជាយូរយារណាស់មកហើយ។ គាត់បានកត់សម្គាល់ថាពាសពេញរយៈពេលវេលាអំឡុងពេលផ្សេងៗគ្នានិងមនោគមវិជ្ជាផ្សេងៗគ្នាជាច្រើននៃរបបបន្តបន្ទាប់មកនោះមានការខ្វះខាតប្រកបដោយសង្គតិភាពមួយ តម្លាភាពឬ" រដ្ឋាភិបាលបើកចំហ " នៅក្នុងនយោបាយកម្ពុជា ។ សង្គមស៊ីវិលប្រទេសកម្ពុជា ដែលស្ថិតនៅកម្រិតលើអង្គភាពគ្រួសារនោះគឺវត្តអារាមឬក៏ប្រព័ន្ធវត្តអារាម។ ប្រព័ន្ធជាប្រពៃណីនេះដែលមានកំណើតតាំងពីមុនសម័យទំនើបនោះទាំងឯករាជភាព និងការិយាធិបតេយ្យរបស់ប្រព័ន្ធនោះព្រមទាំងជម្លោះសង្គ្រាមមស៊ីវិល និងការធ្វើពិសោធសង្គមដែលបានទទួលបរាជ័យកន្លងមកហើយដែលបានបង្ហាញបញ្ជាក់ថាវាមានការរំខានដល់ដំណើរការលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រទេសកម្ពុជា។ គំរូនៃការចងជាសមាគមបែបនេះបានលើកកម្ពស់ឱ្យមានការចូលរួមស្ម័គ្រចិត្តនៅកម្រិតមូលដ្ឋាននិងកម្រិតភូមិ។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ វាគឺជាការបង្ហាញអំពីភាពទន់ខ្សោយរចនាសម្ព័ន្ធជាទូទៅនៃសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាដែលប្រព័ន្ធវត្តមានមន្ត្រីត្រូវបានគេតភ្ជាប់ឱ្យមានប្រសិទ្ធភាព តាមរយៈយុទ្ធនាការកិច្ចសហប្រតិបត្តិការសម្រាប់កម្មវិធីអភិវឌ្ឍន៍សកម្មភាពរដ្ឋាភិបាលដែលមានលក្ខណៈវិមជ្ឈការ ឬវិស័យអង្គការមិនមែនរដ្ឋាភិបាលទេ។ ចំណុចសំខាន់គឺចំណងដ៏ទន់ខ្សោយបន្តិចបន្តួចតែប៉ុណ្ណោះដែលត្រូវបានអភិវឌ្ឍបង្កើតឡើងរវាងម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល ដែលទទួលបានការគាំទ្រក្រោយសម័យអ៊ុនតាក់ និងទម្រង់បែបប្រពៃណីឬមូលដ្ឋាន។ នៅកម្រិតមូលដ្ឋានវា ក៏មានចំនួនអង្គការសហគមន៍ក្នុងចំនួនច្រើនមួយដែរហើយដែលអង្គការទាំងអស់នេះជារឿយៗគឺភ្ជាប់ទៅនឹងសកម្មភាព និងទាក់ទងជាមួយនឹងការអភិវឌ្ឍហើយនិងគម្រោងអភិវឌ្ឍន៍។ អង្គការសហគមន៍អាចពឹងផ្អែកលើទីតាំងភូមិសាស្រ្ត (ភូមិ) ផ្អែកតាមផលប្រយោជន៍ (កន្លែងដែលមានសកម្មភាពសេដ្ឋកិច្ច) ឬផ្អែកទៅលើទីតាំងជាក់លាក់ណាមួយ (តម្រូវការជាពិសេសឬក៏ក្រុមដែលងាយរងគ្រោះ)។ ខណៈនៃការបង្កើត និងគោលបំណង របស់អង្គការមូលដ្ឋានត្រូវកើតចេញមកពីខាងក្នុងដោយខ្លួនឯងនោះ ពួកគេបែរជាមានភាពផ្អែកទៅលើសម្ភារៈពីខាងក្រៅនិងការគាំទ្រផ្នែកហិរញ្ញវត្ថុពីខាងក្រៅទៅវិញ ។ លោក Dosh បានរៀបរាប់អំពីសង្គមស៊ីវិលកម្ពុជាបែបប្រពៃណីគេត្រូវរួបរួមគ្នាដោយបណ្តាញ ឬក៏ចំណងនៃភាពចាក់ស្រេះនៃសហគមន៍នៅតាមវត្ត ប៉ុន្តែដោយផ្អែកទៅលើអភិបាលកិច្ចមួយ ឬក៏រចនាសម្ព័ន្ធអាជ្ញាធរមួយដែលឆ្លុះបញ្ចាំងអំពីបណ្តាញអភិបាលកិច្ចដែលមានភ្ជាប់មកជាមួយ។ លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ត្រូវបានជំរុញចេញមកអំពីនៃលក្ខខណ្ឌក្រោយសង្គ្រាមតាមរយៈសហគមន៍អន្តរជាតិ។ អង្គការសហប្រជាជាតិបានក្លាយទៅជាកម្លាំងដ៏មានឥទ្ធិពលគ្របដណ្តប់ដ៏ធំមួយ នៅក្នុងកិច្ចប្រឹងប្រែងនៃដំណើរការប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៣។ ប្រការនេះបាននាំឱ្យឃើញថាភាព

ផ្សេងៗគ្នានៅក្នុងប្រទេសពីលទ្ធិប្រជាធិបតេយ្យ និងដំណើរការដែលបានចំណាយពេលអស់រយៈពេលជាង២០ឆ្នាំ សម្រាប់ប្រជាជនកម្ពុជាឱ្យបានយល់ដឹងថាប្រជាធិបតេយ្យមិនមែនកម្រិតត្រឹមតែការបោះឆ្នោត ការទៅបោះឆ្នោត ការជាប់ឈ្មោះបោះឆ្នោត និងការគូសទៅលើសន្លឹកឆ្នោតតែប៉ុណ្ណោះនោះទេ។ ទម្រង់កូនកាត់នៃលទ្ធិប្រជាធិបតេយ្យ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ត្រូវបានជះឥទ្ធិពលដោយកត្តាក្នុងស្រុកនិងកត្តាបែបប្រពៃណីរួមជាមួយនឹងកត្តាសហគមន៍អន្តរជាតិ។ ការយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យនៅពេលបច្ចុប្បន្ននេះគឺសិទ្ធិនៅក្រោមលក្ខខណ្ឌមួយចំនួនតាមរយៈបទពិសោធន៍អំពីទម្រង់នៃការគ្រប់គ្រងបែបប្រពៃណី និងអតីតកាល។ ទំនាក់ទំនងប្រពៃណី និងមូលដ្ឋានដែលបង្កើតបានជាសាវតារដែលលទ្ធិប្រជាធិបតេយ្យសេរីត្រូវបានបង្កើតឡើងនោះគឺមានលក្ខណៈជាទំនាក់ទំនងរវាង ( មេ និងកូនចៅ )។ លោក Chandler បានកំណត់និយមន័យនៃទំនាក់ទំនងទាំងនេះថាមានលក្ខណៈជាអន្តរបុគ្គល ជាការចរចាជាងការឆ្លើយតបមួយដែលមានទម្រង់ជា“ ការផ្លាស់ប្តូរបណ្តាញគ្រប់គ្រងការជ្រើសរើស និងការដាក់បញ្ហាការជួយជ្រោមជ្រែងឬក៏ផ្សេងៗទៀត”។ ផលប៉ះពាល់ជាប្រចាំថ្ងៃទៅលើបុគ្គលមានភាពខុសប្លែកពីទំនាក់ដែលបានបែងចែងចេញពីទំនាក់ទំនងមេ និងកូនចៅចេញមកពីទម្រង់អរូបិយ ហើយមានភាពដាច់ឆ្ងាយពីអាជ្ញាធរដូចជារាជាធិបតេយ្យ រាជានិយម។ អ្នកប្រាជ្ញផ្សេងទៀតបានលើកសំអាងថា ប្រព័ន្ធចៅហ្វាយនាយនិងកូនចៅបានក្លាយទៅជាក្រឹត្យក្រមនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាដែលជាការគាំទ្រដល់រចនាសម្ព័ន្ធនយោបាយតាមបែបប្រពៃណី។ ហេតុដូចនេះហើយ គណនេយ្យភាពដែលត្រូវបានគេអនុវត្ត ឬដែលត្រូវបានគេពឹងនោះទៅលើបុគ្គលជាជាងទៅលើគណបក្សនយោបាយ ហេតុនេះហើយបានជាការបោះឆ្នោតនៅក្នុងឆ្នាំ ១៩៩៣ និងឆ្នាំ ១៩៩៨ ត្រូវបានគេបកស្រាយក្នុងន័យជាការប្រកួតប្រជែងមួយដើម្បីធានាថា អ្នកដឹកនាំអាចផ្តល់នូវរង្វាន់ទាំងអស់នេះសម្រាប់អ្នកដែលស្មោះត្រង់ ហើយនៅក្នុងនេះ វាប្រៀបដូចជាករណីនៅក្នុងបណ្តាញមួយ ដែលហៅថាខ្សែរតាមបែបប្រពៃណី។ ចំណងខ្សែជាចំណងដែលចងបុគ្គលនឹងគ្រួសារ ហើយអាចនឹងពង្រីកទៅដល់នយោបាយដោយរួមបញ្ចូលទាំងគ្រួសារមួយនិងគ្រួសារផ្សេងទៀត ដែលមានការតភ្ជាប់ទៅបុគ្គលតាមរយៈទំនាក់ទំនងចៅហ្វាយនាយ និងកូនចៅដែលមានរយៈពេលយូរអង្វែង ទំនាក់ទំនងចៅហ្វាយនាយនិងកូនចៅគឺមានលក្ខណៈបែបជាឋានានុក្រម និង “ ចំណងច្រើនចាក់ស្រែះ” ដោយសារតែវាប៉ះទង្គិចដល់សេដ្ឋកិច្ចសង្គមនិងនយោបាយ។ ចៅហ្វាយនាយផ្តល់នូវការការពារនិងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ខណៈដែលផ្តល់អាទិភាពទៅដល់កូនចៅដើម្បីឱ្យទទួលបាននូវតួនាទីនិងសមភាពអ្វីមួយ។ កូនចៅមានកាតព្វកិច្ចស្មោះត្រង់ និងផ្តល់ការគាំទ្រនៅក្នុងប្រទេសកម្ពុជា ខ្សែឬក៏បណ្តាញខ្សែរយៈមានភាពជាន់លើគ្នា ឬក៏ត្រូវបានច្របាច់បញ្ចូលទៅក្នុងបណ្តាញជាច្រើនដែលបន្តកើតមានរបស់រដ្ឋ ប្រការនេះត្រូវបានផ្តល់នូវឥទ្ធិពលទៅលើភាពជាតំណាង និងការផ្តល់អំណោយ។ ការផ្តល់អំណោយបានឆ្លុះបញ្ចាំងគំរូបែបបទប្រពៃណីបែបអាជ្ញាធរសមត្ថកិច្ចតាមរយៈផ្លូវពីរ៖ ទី១ តាមរយៈការផ្ទៀងផ្ទាត់អំពីការកៀរគរធនធានតាមរយៈវិធីទីមួយបានបង្កើតឱ្យមានគំនិតមួយអំពីអំណាច

ស្មារតីពីកំណើត និងមិនអាចផ្លាញ់បានដែលត្រូវបានគេបង្ហាញតំណាងថា ជាការតោងទៅបុគ្គលជាពិសេសណាម្នាក់ដូចជាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាវិធីមួយសម្រាប់លើកសរសើរគណបក្សប្រជាជនកម្ពុជាធៀបទៅនឹងស្ថានភាពមួយនៃអ្នកកាន់កាប់អំណាចបែបធម្មជាតិ ហើយអ្នកការពារដែលមិនបានទទួលនូវផលប្រយោជន៍នៃអំពើល្អសម្រាប់ប្រទេសជាតិ។ ការកៀរគរធនធានតាមបែបទី២កើតឡើងតាមរយៈសីលធម៌ទាក់ទងនឹងការជួយគ្នាទៅវិញទៅមក ជាវិធីមួយសម្រាប់ប្រមូលសន្លឹកឆ្នោតក្នុងចំណោមប្រជាជន និងការប្រមូលនូវអំណាចរបស់បក្សតាមរយៈចំណងបុគ្គល សម្រាប់ការការពារ និងទទួលបានការពេញចិត្តអ្វីមួយដែលជាកាគាំទ្រ និងទទួលបានផលប្រយោជន៍អំពីអំណាចបង្ខំមួយចំនួននៃរដ្ឋសម័យទំនើប ព្រមទាំងជាការការពារ ហើយគាំទ្រទៅដល់ប្រការនោះតាមរយៈការត្រៀមបម្រុងទុកនូវអារម្មណ៍នាការភ័យខ្លាចមួយ ដែលហាក់បីដូចជានៅស្រស់ៗ ។

**ការធ្វើការបែងចែកតាមប្រភេទ និងការរួមវិភាគទាន៖**

អង្គការមិនមែនរដ្ឋាភិបាលបានរួមចំណែកយ៉ាងសំខាន់ទៅដល់ស្ថិរភាព និងសុខុមាលភាពសង្គមតាមរយៈធ្វើការងារសង្គមស៊ីវិលរបស់ពួកគេយ៉ាងសកម្ម និងប្រកបដោយភាពស៊ីសង្វាក់ឬការបំពេញមុខងារជាអ្នកតាមដាននិងជាអ្នកសហប្រតិបត្តិការដ៏សំខាន់មួយជាមួយនឹងរដ្ឋ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានធ្វើការបែងចែកអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ជាអង្គការជាតិនិងអន្តរជាតិ។ អង្គការអន្តរជាតិត្រូវបានគេបែងចែកទៅជា៥ប្រភេទ ទាក់ទងជាមួយនឹងសកម្មភាព ឬមុខងាររបស់ពួកគេ ហេដ្ឋារចនាសម្ព័ន្ធនិងជាអង្គការដោយផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធ និងការកសាងឡើងវិញដែលជាអង្គការមានសមត្ថភាពនៅក្នុងការផ្តល់សេវានៅក្នុងទ្រង់ទ្រាយធំមួយជាមួយ នឹងការគាំទ្រមូលនិធិទ្វេភាគី ឬក៏ពហុភាគីពីម្ចាស់ ជំនួយអង្គការដែលធ្វើការជាដៃគូជាមួយនឹងរដ្ឋាភិបាលជាតិដើម្បីផ្តល់ការអភិវឌ្ឍផ្នែកសេវាកម្ម ការអភិវឌ្ឍសហគមន៍តាមរយៈអង្គការធំៗដែលផ្តោតទៅ លើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅថ្នាក់មូលដ្ឋាន អង្គការដែលមានជំនាញឯកទេស និងវិជ្ជាជីវៈនៅមូលដ្ឋានព្រមទាំងអង្គការមហាជនដែលកើតចេញមកអំពីការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងសកម្មភាព ឬអង្គការដែលទាក់ទងជាមួយ នឹងការស្រាវជ្រាវនិងការចងភ្ជាប់ការស្រាវជ្រាវទៅនឹងបញ្ហានៃការតស៊ូមតិ។ ទាក់ទងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកប្រាំប្រភេទដែល៖ សេរីភាព (សិទ្ធិនិងប្រជាធិបតេយ្យ អង្គការដែលធ្វើដំណើរការលទ្ធិប្រជាធិបតេយ្យ អង្គការផ្នែកអភិវឌ្ឍន៍ដែលមានវិស័យជាច្រើនដែលពួកគេចាប់អារម្មណ៍ អង្គការដែលមានការគាំទ្រចំពោះការអភិវឌ្ឍធនធានមនុស្ស អង្គការមហាជននិងអង្គការស្រាវជ្រាវ ឬធ្វើការវិភាគដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងបញ្ហាធ្វើការតស៊ូមតិ)។

អង្គការសង្គមស៊ីវិលទាំងអស់នេះមានភាពខុសប្លែកគ្នាទាំងទំហំអង្គការ និងវិសាលភាពសកម្មភាព។ រហូតមកទល់ ឆ្នាំ២០០១ អង្គការមហាជនមានទឹកប្រាក់ប្រចាំឆ្នាំជាមធ្យម ២០.០០០

ដុល្លារ ដែលទឹកប្រាក់នេះសម្រាប់អង្គការមិនមែនរដ្ឋាភិបាលតូចៗនិងមធ្យមមានថវិកាប្រចាំឆ្នាំជាមធ្យម ១៥០.០០០ ដុល្លារអាមេរិក និងអង្គការអន្តរជាតិធំៗមានថវិកាប្រចាំឆ្នាំជាមធ្យម៣៩០.០០០ ដុល្លារអាមេរិក។ ប្រភពអំពីមូលនិធិរបស់អង្គការសង្គមស៊ីវិលត្រូវបានគេបែងចែកជាបួនប្រភេទ ប្រាក់កម្ចីសុទ្ធសាធផ្តល់ជាអំណោយ សកម្មភាពពាណិជ្ជកម្ម ការផ្តល់មូលនិធិ និងការគាំទ្ររដ្ឋាភិបាលនិងផ្សេងៗទៀត។ ទិន្នន័យបានបង្ហាញថាប្រាក់កម្ចីឥតសំណងនិងការផ្តល់ជាអំណោយ មានចំនួនច្រើនជាងប្រភេទផ្សេងៗទៀតនៃថវិកាទាំងអស់។ ប៉ុន្តែទោះបីជាយ៉ាណាក៏ដោយ វាមិនបានអនុញ្ញាត សម្រាប់ការបញ្ជាក់ឱ្យបានច្បាស់ថាតើមួយណាក្នុងចំណោមពីរនិងជាអ្នកផ្តល់ធនធានសំខាន់ជាង។ ជាងនេះទៅទៀត មូលនិធិរបស់រាជរដ្ឋាភិបាលបានគាំទ្រទៅដល់អង្គការនៅក្នុងកម្រិតមួយតិចតួចតែប៉ុណ្ណោះ ដែលមានឥទ្ធិពលក្នុងការផ្តល់មូលនិធិដែលធ្លាក់ពីលើចុះមកក្រោមដែលបង្កឡើងដោយសារតែអង្គការដែលបានទទួលមូលនិធិទាំងអស់នោះ បន្តផ្តល់ឱ្យអង្គការសង្គមស៊ីវិលផ្សេងៗទៀត។ នៅក្នុងការស្ទង់មតិរបស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការកម្ពុជាមាន អង្គការសង្គមស៊ីវិលពីរភាគបីដែលបានបញ្ជាក់ថាពួកគេពិតជាអាចផ្តល់មូលនិធិទៅដល់អង្គការសង្គមស៊ីវិល ហើយជួនកាលបានផ្តល់ទៅដល់អង្គការមហាជន ប៉ុន្តែភាគច្រើនទៅដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬក៏សមាគម។ អង្គការគណៈកម្មាធិការសហប្រតិបត្តិការកម្ពុជាបានធ្វើការប៉ាន់ប្រមាណថា មានថវិកាជាតិប្រចាំឆ្នាំសរុបសម្រាប់វិស័យអង្គការសង្គមស៊ីវិល និងក្នុងទឹកប្រាក់ ៥៥០.,០០០.០០០ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១១។ ការប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃមូលនិធិទាំងអស់នេះ ទៅលើមូលដ្ឋានរួមមានអង្គការមហាជន និងសមាគមនៅតាមមូលដ្ឋាននោះ អង្គការគណៈកម្មាធិការសហប្រតិបត្តិការកម្ពុជាបានធ្វើការសន្និដ្ឋានថា ទឹកប្រាក់ប្រហែលជាង ៤៤.០០០.០០០ដុល្លារសហរដ្ឋអាមេរិក នៃថវិកាទាំងអស់នេះគាំទ្រដោយសហគមន៍ស៊ីវិលតាមមូលដ្ឋាន។ ការប៉ាន់ប្រមាណអំពីទឹកប្រាក់៥៥០.០០០.០០០ដុល្លារសហរដ្ឋអាមេរិកសម្រាប់វិស័យអង្គការសង្គមស៊ីវិលមានន័យថា វាបានចូលរួមចំណែកយ៉ាងសំខាន់ចំពោះធនធានទាំងឡាយសម្រាប់សុខុមាលភាព និងការអភិវឌ្ឍផ្នែកសង្គមនិងសេដ្ឋកិច្ច។ សម្រាប់ថវិកាឆ្នាំ២០១២ របស់រដ្ឋាភិបាលកម្ពុជាបានចែងកំណត់អំពីថវិកាសរុបមួយដែលមានជាទឹកប្រាក់ចំនួន២.៦៧៨.០០០.០០០ ដុល្លារសហរដ្ឋអាមេរិក ដែលរួមជាមួយទឹកប្រាក់ ៥៩៤.០០០.០០០ដុល្លារសហរដ្ឋអាមេរិក សម្រាប់វិស័យសង្គមកិច្ច និងទឹកប្រាក់ចំនួន ១៣២.០០០.០០០ ដុល្លារអាមេរិកសម្រាប់វិស័យសេដ្ឋកិច្ច។ គណៈកម្មាធិការសហប្រតិបត្តិការកម្ពុជាបានប្រើប្រាស់ការប៉ាន់ប្រមាណ បែបធម្មតាមួយនៅក្នុង ការគិតគណនាអំពីចំនួននៃអ្នកទទួលផលប្រយោជន៍ពីសកម្មភាពរបស់អង្គការសង្គមស៊ីវិលក្នុងមួយឆ្នាំ គឺស្ថិតនៅក្នុងទឹកប្រាក់ ១.០៣៥.០០០ ដុល្លារសហរដ្ឋអាមេរិកនៅទូទាំងអង្គការសង្គមស៊ីវិល និងនៅគ្រប់វិស័យប្រតិបត្តិការ។

លោក Dosrch ក៏បានពិនិត្យមើលទៅលើការផ្តល់ថវិការបស់សង្គមស៊ីវិលតាមរយៈជំនួយអន្តរជាតិ ប៉ុន្តែគាត់បានធ្វើសេចក្តីសន្និដ្ឋានផ្សេងទៅវិញអំពីចំណុចខ្លាំងនិងសមត្ថភាពដែលចេញមក

អំពីខាងក្នុងទាំងមូលរបស់អង្គការសង្គមស៊ីវិល។ គាត់បានបង្ហាញថាប្រទេសកម្ពុជាគឺជាអ្នកទទួលជំនួយដ៏ធំមួយពីជំនួយអភិវឌ្ឍន៍ជាផ្លូវការ(ODA) នៅចន្លោះឆ្នាំ២០០៣ដល់ឆ្នាំ២០០៨ ប្រទេសកម្ពុជាបានទទួលប្រហែលជាង៦០០លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំតាមរយៈ ODA ហើយចំនួនមានការកើនឡើងដោយសារតែមានការគាំទ្របន្ថែមទៀតពីម្ចាស់ជំនួយថ្មីៗដូចជាប្រទេសចិន និងប្រទេសកូរ៉េខាងត្បូងជាដើម។ នៅក្នុងឆ្នាំ២០១០ ប្រាក់ជំនួយសរុបបានកើនឡើងរហូតដល់ ១.០៧៥.០០០.000 លានដុល្លារសហរដ្ឋអាមេរិកហើយនៅក្នុងឆ្នាំ២០១១ បានកើនឡើងដល់ ១.២៣៥.000.000 ដុល្លារអាមេរិក។ ម្ចាស់ជំនួយធំៗចំនួន៤ដែលផ្តល់ទឹកប្រាក់ច្រើនជាង១០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំមានប្រទេសចិន សហគមន៍អឺរ៉ុប ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសជប៉ុន។ ជំនួយទាំងអស់នេះសរុបទៅបានរួមចំណែកដល់៥៥%នៃ ODA សរុបដល់ប្រទេសកម្ពុជា។ ODA មានចំនួនស្មើនឹង ៩,៤%នៃ GDP ដែលមានន័យថាស្មើនឹង ៧៨ដុល្លារសហរដ្ឋអាមេរិកសម្រាប់មួយនាក់ ដែលតួលេខនេះធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជាប្រទេសដែលពឹងផ្អែកទៅលើចំណូលច្រើនបំផុត ទីពីរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ បើយោងទៅតាម លោក Dorsch មានអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.000ដែលបានចុះបញ្ជីជាមួយ ប៉ុន្តែមានតែ ៣៥0 ទៅ៤00 ប៉ុណ្ណោះដែលគេចាត់ទុកជាប្រតិបត្តិការ។ អង្គការសង្គមស៊ីវិលគឺមានការពឹងផ្អែកខ្លាំងក្លាទៅលើជំនួយបរទេសនិងការគាំទ្រពីខាងក្រៅ ហើយវាបានបង្ឱ្យមាន (ករណីភាពទៅខាងលើមួយ) ដែលពិបាកទៅក្នុងការផ្លាស់ប្តូរទាក់ទងទៅនឹងម្ចាស់ជំនួយ។ លោក Dorsch បានចង្អុលបង្ហាញថា តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យមានឥទ្ធិពលដោយឯករាជ្យទៅលើការបែងចែកលុយជំនួយ ODA នេះមានកម្រិតតិចតួចណាស់ដោយសារថាមានតែមួយភាគដប់ ODA ប៉ុណ្ណោះត្រូវបានបែងចែកដោយអង្គការមិនមែនរដ្ឋាភិបាល។ តែទោះជាយ៉ាងណា អង្គការសង្គមស៊ីវិល គឺជាដៃគូដែលម្ចាស់ជំនួយអន្តរជាតិជាច្រើនចង់បាន ហើយដែលមានបំណងចង់អភិវឌ្ឍផ្នែកអង្គការសង្គមស៊ីវិលនេះឱ្យទៅជាគ្រឹះមួយរបស់សង្គមស៊ីវិលទៅតាមលក្ខណៈដែលអំពើពុករលួយដ៏ខ្លាំងក្លាបានធ្វើឱ្យកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋក្លាយទៅជាភាពដែលអង្គការម្ចាស់ជំនួយមិនចង់បាន។

អង្គការ Oxfam បានធ្វើផែនទីអំពីការចូលរួមរវាងសង្គមស៊ីវិលនិងរដ្ឋាភិបាលក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩៩៥ និងការចូលរួមរបស់គណៈកម្មការដើម្បីកិច្ចសហការនៅប្រទេសកម្ពុជា និងវេទិកាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ជាមួយនឹងគណៈកម្មការអន្តរជាតិស្តីអំពីការកសាងសង្គមកម្ពុជាឡើងវិញ(ICORC)។ ពួកគេក៏បានចូលរួមនៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ចាប់តាំងពីឆ្នាំ២០០២មកផងដែរ ហើយវេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា (CDCF)ចាប់តាំងពីឆ្នាំ២០០៧។ ទាក់ទងជាមួយនឹងរចនាសម្ព័ន្ធការចូលរួមរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល នៅមានកម្រិតខ្ពស់បំផុតមួយបានកើតឡើងនៅក្នុង CDCF។ នៅក្នុងវេទិកានេះ ភាគីផ្សេងៗគ្នាបានពិភាក្សាអំពីការរីកចម្រើន និងកំណត់គោលដៅព្រមទាំងសូចនាករដើម្បីតាមដានការរីកចម្រើន។ រដ្ឋាភិបាលកម្ពុជា

កំពុងតែស្វែងរកធ្វើកំណែទម្រង់យន្តការ ដើម្បីធ្វើឱ្យការដាក់បញ្ចូលគ្នាចូលវិស័យឯកជនមានប្រសិទ្ធភាព។ ក្នុងឆ្នាំ២០០៤ គណៈកម្មការសម្របសម្រួលជំនួយរបស់រដ្ឋាភិបាល ( CDCC) ត្រូវបានបង្កើតឡើង។

នៅពីក្រោម CDCF មានក្រុមការងារបច្ចេកទេសចម្រុះដៃគូរវាងរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ (JTWGs)។ នៅពេលចាប់ផ្តើមក្នុងឆ្នាំ២០០៤ ក្រុមទាំងនោះបានដើរតួនាទីជា (យន្តការសម្របសម្រួលបច្ចេកទេស) ចម្បងមួយដើម្បី បង្រួបបង្រួមម្ចាស់ជំនួយរដ្ឋាភិបាលនិងសង្គមស៊ីវិល។ មនុស្សទាំងអស់នេះមានប្រធានម្នាក់មកពីក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល ម្ចាស់ជំនួយដែលធ្វើការសម្របសម្រួល និងរួមមានតំណាងរបស់អង្គការសង្គមស៊ីវិលដែលត្រូវបានបញ្ចូលឱ្យធ្វើជាអ្នកសង្កេតការណ៍ចាប់តាំងពីឆ្នាំ២០០៧មក ហើយនិងជាអ្នកចូលរួមចាប់តាំងពីឆ្នាំ២០១០មក។ មានក្រុមការងារបច្ចេកទេសចម្រុះចំនួន១៩ ទាក់ទងជាមួយនឹងវិស័យចំនួន១២។ ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងក្រុមការងារបច្ចេកទេសនេះគឺត្រូវបានសម្របសម្រួលដោយ CCC និងវេទិកាអង្គការមិនមែនរដ្ឋាភិបាល។ អង្គការធំទាំងពីនេះ ក៏បានតំណាងឱ្យអង្គការសង្គមស៊ីវិលទាំងមូលនៅក្នុងវេទិកាសំខាន់ចំនួនពីរគឺ CDCF និង GDCC ក៏ដូចជាបានដើរតួនាទីជាយន្តការដើម្បីបញ្ចូលធាតុចូល ពីអង្គការសង្គមស៊ីវិលសម្រាប់ការធ្វើផែន ការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ។ ក្នុងនាមជាអង្គការមេទាំងពីនេះ ទាំង CCC និង NGO Forum បានរៀបចំវេទិកាបញ្ហាដែលទាក់ទងជាមួយនឹងការអភិវឌ្ឍដើម្បីទទួលនូវមតិយោបល់ត្រឡប់ធាតុចូលពីអង្គការសង្គមស៊ីវិលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិហើយដែលក្រោយមកបានគេបញ្ចូលទៅក្នុងសេចក្តីព្រាងនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ដូចដែលបានកើតឡើងនៅក្នុងពេលបច្ចុប្បន្ននេះនៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៤ ដល់២០១៨។ តំណាងអង្គការសង្គមស៊ីវិលត្រូវបានធ្វើការប៉ាន់ប្រមាណថា ២៧%នៃអនុសាសន៍របស់ពួកគេត្រូវបានទទួលយកដោយរដ្ឋាភិបាល នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិចុងក្រោយ។

មានលំហដែលត្រូវបានគេអញ្ជើញ មួយចំនួនដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលដែលធ្វើឱ្យការចូលរួម និងការពាក់ព័ន្ធរបស់សង្គមស៊ីវិលមានភាពស្របច្បាប់នៅក្នុងដំណើរការធ្វើគោលនយោបាយ។ ក៏ប៉ុន្តែ លទ្ធភាពសមត្ថភាពក្នុងការចូលរួម ត្រូវបានដាក់កំហិតដោយការសម្រេចចិត្តរបស់រដ្ឋាភិបាលជាក្រុមការងារបច្ចេកទេសចម្រុះ និងកិច្ចប្រជុំរវាង JTWG និង GDCC អស់រយៈពេលជិត២ឆ្នាំ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៣។ តួអង្គសង្គមស៊ីវិលក៏បានបញ្ជាក់អំពីភាពសង្ស័យរបស់ខ្លួនទាក់ទងជាមួយនឹងផលប៉ះពាល់ទៅនឹងផលប្រយោជន៍ជាចុងក្រោយអំពីការចូលរួមនេះដោយពួកគេបាបញ្ជាក់ច្បាស់ថាផលប៉ះពាល់សើៗ ទៅលើការសម្រេចចិត្តរបស់អ្នកធ្វើគោលនយោបាយបានកាត់បន្ថយនៅគុណភាពនៃការចូលរួមពាក់ព័ន្ធនេះ។ ចំនួនអ្នកចូលរួមដែលជាអង្គការស៊ីវិល និងគុណភាពនៃការចូលរួមរបស់ពួកគេនៅក្នុងលំហដែលត្រូវបានគេអញ្ជើញនេះ គឺមានកម្រិតតិចតួចមែនទែន។

តាមពិតទៅសម្រាប់សមត្ថភាពរបស់សង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា នៅក្នុងការចូលរួម និងការចូលរួមធ្វើការតស៊ូមតិមានការកើនឡើង។ មានការកើនឡើងផងដែរនូវការគាបសង្កត់ ឬក៏ជាការបង្ក្រាបនូវការឆ្លើយតបមួយ និងការដាក់ការរឹតត្បិតទៅលើផ្នែកមួយចំនួនដែលរដ្ឋបានប្រើប្រាស់នូវប្រព័ន្ធតុលាការកាន់តែច្រើនឡើងនៅក្នុងការអនុវត្តគោលនយោបាយនឹងដើម្បីបន្តសម្រេចនូវគោលបំណងគោលនយោបាយរបស់ពួកគេ។ ជាលទ្ធផលតួអង្គសង្គមស៊ីវិលបានលើកឡើងផងដែរនូវលំហបញ្ចេញមតិ និងការចូលរួមនៅក្នុងប្រទេសកម្ពុជាថាមានការថយចុះ លោកMarshall និងវគ្គផ្សេងទៀតបានរកឃើញថាអង្គការសង្គមស៊ីវិលជាច្រើន (៥៧% មានអារម្មណ៍ថាពួកគេមានទំនាក់ទំនងការងារដ៏រឹងមាំមួយជាមួយនឹងរដ្ឋាភិបាល។ ក៏ប៉ុន្តែស្របពេលជាមួយគ្នានោះដែរ អ្នកឆ្លើយតបដែលជាអង្គការសង្គមស៊ីវិលប្រហែលជាពាក់ កណ្តាលដែលត្រូវបានធ្វើការស្ទង់មតិនេះ បានលើកឡើងអំពីបញ្ហាប្រឈមក្នុងសកម្មភាពកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋដោយសារការកង្វះភាពជឿជាក់ និងការប្រាស្រ័យទាក់ទងមិនល្អ ការធ្វើច្បាប់ដែលមានលក្ខណៈរឹតបន្តឹង និងសមត្ថភាពឬធន្ធៈមិនគ្រប់គ្រាន់។ ប្រការទាំងអស់នេះកាន់តែមានភាពខ្លាំងក្លាថែមទៀតតាមរយៈការធ្វើច្បាប់នាពេលថ្មីៗ នេះដែលបានដាក់កំហិតទៅលើលំហ និងសំឡេងរបស់អង្គការសង្គមស៊ីវិលដូចជាច្បាប់ស្តីអំពីសមាគមអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីអំពីព្រឹត្តកម្មតាមប្រព័ន្ធអ៊ីនធើណិត ច្បាប់ស្តីអំពីឋានៈចៅក្រមនិងច្បាប់កម្មសិទ្ធិបញ្ញាអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ ច្បាប់ស្តីអំពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីអំពីការគ្រប់គ្រងការប្រើប្រាស់កសិកម្ម និងច្បាប់ស្តីអំពីសហជីព។

ថ្វីត្បិតតែមានសក្តានុពល ដែលទទួលរងដោយសារតែការដឹកនាំរបស់ម្ចាស់ជំនួយក៏ដោយ ក៏អង្គកាសង្គមស៊ីវិលបានអភិវឌ្ឍនូវបណ្តាញដ៏ទូលំទូលាយក្នុងចំណោមអង្គការដែលបានដើរតួនាទីជាមូលដ្ឋានសម្រាប់ចែករំលែកព័ត៌មានទាក់ទងជាមួយនឹងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយនិងការស្រាវជ្រាវដែលមានពាក់ព័ន្ធផ្សេងៗ។ ចំណុចនេះបានក្លាយទៅជាកម្លាំងចលករដ៏សំខាន់មួយសម្រាប់កសាងសមត្ថភាពនៅថ្នាក់ជាតិ ហេតុដូច្នេះហើយ ប្រព័ន្ធប្រាស្រ័យទាក់ទងនិងបណ្តាញសម្របសម្រួលដ៏ទូលំទូលាយនិងមានភាពស្មុគស្មាញមួយនោះបានឱ្យអង្គការសង្គមស៊ីវិលក្លាយទៅជាសម្ព័ន្ធ ដែលមានចំនួនច្រើនជាង ៦០%។ អង្គការមេធំៗពីសម្រាប់អង្គការសង្គមស៊ីវិលគឺ CCC និង NGO Forum ។ បណ្តាញផ្សេងទៀតបានប្រតិបត្តិការក្នុងការគាំទ្រទៅដល់វិស័យអង្គការមិនមែនរដ្ឋាភិបាល ដូចជាអង្គការស្តារកម្ពុជា ឬបណ្តាញទៅតាមប្រធានបទផ្សេងៗដូចជាបណ្តាញភាពជាដៃគូ ក្នុងវិស័យអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាល (NEP) និងMEDiCAM ។ CCC បានធ្វើការផ្លាស់ប្តូរព័ត៌មានរវាងអង្គកាមិនមែនរដ្ឋាភិបាលជាសមាជិកបានរក្សានូវមជ្ឈមណ្ឌលធនធានមួយដែលបានបោះដំហរ ដោយសាធារណជននិងផ្តល់ជំនួយទៅដល់អង្គការសង្គមស៊ីវិលទាក់ទងជាមួយនឹងការចូលរួមពាក់ព័ន្ធពីរដ្ឋាភិបាល ឬការអនុវត្តល្អបំផុតផ្ទៃក្នុង។ វេទិកា អង្គការមិនមែនរដ្ឋាភិបាល រួមមានអង្គការជាង៦០ហើយប្រតិបត្តិការដោយផ្តោត

ទៅលើការតស៊ូមតិ អង្គការសង្គមស៊ីវិលប្រហែលជា៣/៤ ដែលត្រូវបានធ្វើការស្ទង់មតិដោយ CCC បានបង្ហាញដោយសមាជិកភាពរបស់ពួកគេនៅក្នុងអង្គការសង្គមស៊ីវិលមេមួយនេះ។

បើយោងទៅតាម លោកMarshall និងអ្នកផ្សេងទៀត នោះ៨០%នៃអង្គការសង្គមស៊ីវិល ជាសមាជិករបស់អង្គការបែបនេះ។ អង្គការមេដែលសំខាន់បំផុត នៅក្នុងប្រទេសកម្ពុជា ដោយយោងទៅតាមទិន្នន័យដែលផ្តល់ឱ្យអ្នកសម្ភាសក្នុងការស្ទង់មតិនេះគឺបើរៀបតាមលំដាប់នៃភាពសំខាន់នោះគឺមាន CCC វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) MEDiCAM និងបណ្តាញភាពជាដៃគូក្នុងវិស័យអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាល (NEP)។ បើយោងទៅតាម CCC អង្គការមិនមែនរដ្ឋាភិបាលបាន ផ្តល់នូវសំឡេងចម្រុះគ្នាផ្សេងៗគ្នា ទាក់ទងជាមួយនឹងបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ ហើយជាចុងក្រោយក៏បានបង្ហាញនូវផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនទៅលើសមត្ថភាពនៅ ក្នុងការធ្វើការស្រាវជ្រាវនិងចូលរួមជាមួយនឹងរដ្ឋាភិបាលដើម្បីឱ្យការស្រាវជ្រាវទាំងអស់នោះបានចូលទៅក្នុងគោលនយោបាយ។ បញ្ហាប្រឈមទាំងនេះរួមមាន៖ ថវិកាមិនគ្រប់គ្រាន់សម្រាប់គម្រោងរយៈពេលវែង និងនិរន្តរភាពនៃវត្តមានរបស់អង្គការ កង្វះការសម្របសម្រួលក្នុងចំណោមម្ចាស់ជំនួយទាក់ទងជាមួយនឹងការ ធ្វើរបាយការណ៍គម្រោងអសមត្ថភាពនៅក្នុងការទទួលព័ត៌មានពីស្ថាប័នរដ្ឋាភិបាល ការលំបាកនៅក្នុងការធ្វើឱ្យមានភាពជាម្ចាស់នៅមូលដ្ឋាននិងនៅសហគមន៍សម្រាប់គម្រោងទាំងឡាយ កង្វះការសម្របសម្រួលរវាងអង្គការសង្គមស៊ីវិលសមត្ថភាពនៅទន់ខ្សោយផ្នែកអភិបាលកិច្ច និងការផាត់ចេញការពិភាក្សាស្តីពីការអភិវឌ្ឍ គ្របដណ្តប់ដោយតួអង្គដទៃទៀត។

## សង្គមស៊ីវិលកំពុងផ្លាស់ប្តូររបស់

និន្នាការនៅក្នុងសកម្មភាព និងសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក៏ដូចជាកម្លាំងចលករនៃទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយ ព្រមទាំងរវាងអង្គការសង្គមស៊ីវិលនិងរដ្ឋបានគាំទ្រទៅដល់ការបង្កើតឱ្យមានការប្រែប្រួលសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាតាមរយៈការងារនៃអង្គការដែលមានឈ្មោះថា ACTALLIANCE នោះអង្គការ CCC បានលើកសំអាងថាមានការកើនឡើងយ៉ាងឆាប់រហ័សមួយអំពីទំហំវិសាលភាព និងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលនៅក្នុងរយៈប៉ុន្មានទសវត្សរ៍ថ្មីៗនេះនៅកម្រិតសាកល។ ធនាគារពិភពលោកបានធ្វើការប៉ាន់ប្រមាណអំពីការចំណាយថវិកាប្រចាំឆ្នាំដែលមានរហូតទៅដល់ ១,៣ ទ្រីលានដុល្លារ ហើយនឹងបានផ្តល់ការងារទៅដល់មនុស្សជាង៤០លាននាក់នៅក្នុងអង្គការសង្គមស៊ីវិលមិនរកប្រាក់ចំណូលនេះនៅក្នុងសាកលលោក ។ អង្គការសង្គមស៊ីវិល កម្ពុជាបានបង្ហាញអំពីការអភិវឌ្ឍសមត្ថភាពមួយរបស់អង្គការមួយដោយផ្អែកទៅលើសភាពនៃការឆ្លងប្រទេសដែលកំពុងតែកើតឡើង ដែលប្រការនេះធ្វើឱ្យមានភាពមិនសូវពឹងផ្អែកទៅលើចំណងជាក់លាក់មួយចំនួនរវាងអង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយឬទៅលើការឈោងចាប់ជា

លក្ខណៈអន្តរជាតិចំពោះអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិធំៗមួយចំនួន។ នេះគឺជាភ័ស្តុតាងអំពីតួនាទី ដែលមានលក្ខណៈ បែបចូលរួមដែលតួអង្គសង្គមស៊ីវិលបានដើរតួនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងសមភាគីរបស់ពួកគេ ទាំងថ្នាក់តំបន់ និងថ្នាក់សាកល។ សង្គមស៊ីវិលនៅកម្ពុជាគឺជាអ្នកចូលរួមនៅក្នុងដំណើរការនៃការ បង្កើតវេទិកាអង្គការ Open Forum វេទិកាបើកចំហសម្រាប់ប្រសិទ្ធភាពអង្គការសង្គមស៊ីវិល។ សង្គមស៊ីវិលកម្ពុជាបានចូលរួមនៅក្នុងកិច្ចប្រជុំ និងការសម្រេចចិត្ត នៃមហាសន្និបាតអង្គការសង្គមស៊ីវិល សាកលលើកទីមួយដែលធ្វើឱ្យមានលទ្ធផលកើតចេញជាការរៀបចំបង្កើតឱ្យមានគោលការណ៍ Istanbul ហើយបន្ទាប់មកបានធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតជាសាកលលើទី២ ដែលបង្កើតបានជាការព្រមព្រៀងរបស់អង្គការសង្គមស៊ីវិលស្តីអំពីក្របខ័ណ្ឌអន្តរជាតិសម្រាប់ប្រសិទ្ធភាពនៃការអភិវឌ្ឍអង្គការសង្គមស៊ីវិលនៅខេត្តសៀមរាប។ តំណាងអង្គការសង្គមស៊ីវិលនៅកម្ពុជា ក្រោយមកក៏បានចូលរួមនៅក្នុងដំណើរការដែលបានបង្កើតឱ្យមានជាឯកសារលទ្ធផល Busan នៅក្នុងពាក្យពេចន៍នៃដំណើរការនេះចាប់តាំងពីឆ្នាំ ២០០៨ មក អង្គការ CCC បានស្វែងរកឱ្យមានការកែលម្អទៅលើការពិភាក្សា និងការអនុវត្តដែលមានការពាក់ព័ន្ធ ជាមួយនឹងប្រសិទ្ធភាពជំនួយតាមរយៈការរៀបចំសិក្ខាសាលា និងកិច្ចពិគ្រោះយោបល់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នេះជាការឆ្លុះបញ្ចាំងដោយសង្គមស៊ីវិលនៅកម្រិតជាតិ និងអន្តរជាតិចំពោះបញ្ហាអំពីការពឹងពាក់ និងឧបសគ្គនៅក្នុងការធ្វើឱ្យសង្គមស៊ីវិលអាចរស់ដោយខ្លួនឯងបាននៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍ ប្រទេសដែលមិនមានលទ្ធិប្រជាធិបតេយ្យ។

នៅថ្នាក់តំបន់ អង្គការCCCគឺជាអ្នកចូលរួមនាំមុខមួយក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់តំបន់អាស៊ី សម្រាប់កម្មវិធីក្រោយឆ្នាំ២០១៥ ដែលស្វែងរកនូវការប្តេជ្ញាចិត្តបន្ថែមទៀតចំពោះការសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅក្នុងតំបន់។ កម្មវិធីក្រោយឆ្នាំ២០១៥ នេះរួមមានអង្គការសង្គមស៊ីវិលច្រើនជាង ១.០០០ មកពីរដ្ឋចំនួន ១៣០។ អង្គការ CCC ក៏បានតំណាងឱ្យអង្គការសង្គមស៊ីវិលកម្ពុជានៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់ស្តីអំពីរបៀបវារៈក្រោយឆ្នាំ២០១៥ ដែលបានធ្វើឡើងនៅក្នុងប្រទេសឥណ្ឌូណេស៊ីក្នុងឆ្នាំ២០១៤។ វេទិកានិងសិក្ខាសាលាថ្នាក់ជាតិមួយក៏ត្រូវបានរៀបចំឡើងដោយ អង្គការ CCC និងអង្គការសហប្រជាជាតិក្នុង ឆ្នាំ២០១៤ ដែលបានបង្កើតឱ្យមានកិច្ចព្រមព្រៀងមួយទៅលើប្រធានបទសំខាន់ៗចំនួន៥សម្រាប់ យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥។ យុទ្ធសាស្ត្រទាំងនោះរួមមានៈការដាក់បញ្ចូលក្នុងសង្គមការអភិវឌ្ឍសេដ្ឋកិច្ច ការការពារបរិស្ថានអភិបាលកិច្ចល្អនិងសិទ្ធិមនុស្ស Oxfam អាចធ្វើការសន្និដ្ឋានបានថា ការចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការទាំងអស់នេះបានធ្វើឱ្យសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាកាន់តែមានភាពយល់ដឹង និងមានភាពសកម្មនៅក្នុងការអភិវឌ្ឍជាសង្គមស៊ីវិល ជាលក្ខណៈសាកល ហើយបានបង្កើតនូវការយល់ដឹងដែលមានការរីកចម្រើនមួយអំពីវិធានការដែលត្រូវការចាត់ឡើងដើម្បីពង្រឹងសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ ចំណុចនេះរួមបញ្ចូលមិនមែនត្រឹមតែរដ្ឋាភិបាលដែលកំពុងតែផ្តល់នូវបរិយាកាសអំណោយផលមួយសម្រាប់សង្គមស៊ីវិលបែបនេះ

ប៉ុណ្ណោះទេ ប៉ុន្តែក៏វាមានបញ្ហាលម្ចាស់ជំនួយផងដែរ។ តម្រូវការដ៏សំខាន់មួយរបស់សង្គមស៊ីវិលមួយគឺត្រូវធ្វើការតស៊ូមតិឱ្យមានការផ្លាស់ប្តូរតាមរបៀបមួយដែលម្ចាស់ជំនួយបានផ្តល់មូលនិធិហើយ ដោយទាមទារឱ្យមានការធ្វើរបាយការណ៍ ការធ្វើការតស៊ូមតិដែលចៀសឱ្យផុតពីការធ្វើការតស៊ូមតិដោយផ្អែកទៅលើគម្រោង ឱ្យទៅជាការផ្តល់មូលនិធិដោយផ្អែកទៅលើកម្មវិធីវិញ។

តែទោះជាយ៉ាងណាក៏ ដោយភាពតានតឹងរវាងសង្គមស៊ីវិល និងរដ្ឋាភិបាលនៅតែបង្កកើតមានពាសពេញតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។ ប្រការនេះត្រូវបានបង្ហាញតាមរយៈឧទាហរណ៍វេទិកានៃពលរដ្ឋអាស៊ាននៅក្នុង២០១២។ អង្គការសង្គមស៊ីវិល ថ្នាក់តំបន់បានបដិសេធមិនព្រមទទួលយកសេចក្តីប្រកាសស្តីអំពីសិទ្ធិមនុស្សអាស៊ានដោយសារតែមូលហេតុថាវាមានលក្ខណៈទាបជាងស្តង់ដារអន្តរជាតិដែលមានស្រាប់រួចមកហើយ។ ក្នុងអំឡុងពេលរៀបចំវេទិកាពលរដ្ឋអាស៊ាន ការកៀរគរអង្គការសង្គមស៊ីវិលត្រូវបានដាក់កំហិតយ៉ាងសកម្មដោយឥទ្ធិពលរដ្ឋាភិបាល ដែលបង្កឱ្យមានការបិទទីតាំងការប្រមូលផ្តុំជាច្រើន។ ចុងបញ្ចប់ ស្របពេលជាមួយគ្នាដែលអង្គការសង្គមស៊ីវិលនៅមូលដ្ឋាននៃវេទិកាពលរដ្ឋអាស៊ានបានរៀបចំមហាសន្និបាតប្រជាជនមូលដ្ឋានក្នុងអាស៊ាន ដែលបង្ហាញថាសង្គមស៊ីវិលមានភាពសកម្ម និងមិនត្រូវបានគេរឹតត្បិតក្នុងកម្រិតណាមួយនៅថ្នាក់មូលដ្ឋាន ក៏ប៉ុន្តែវាក៏បង្ហាញអំពីការបែងចែកនូវភាពតានតឹងមួយចំនួនដែលបានកើតឡើងរវាងអង្គការនៅតាមមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងជាផ្លូវការនោះ។

ការសិក្សាប្រៀបធៀបមួយចំនួនស្តីអំពីតួនាទីអង្គការសង្គមស៊ីវិល ក្នុងតំបន់អាស៊ីអាគ្នេយ៍បានរកឃើញថាពួកគេបានបំពេញមុខងាររបស់ខ្លួនដោយរាប់ចាប់តាំងពីការផ្តល់សេវាមូលដ្ឋានរហូតដល់ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស រហូតដល់ការផ្តល់ជំនួយមនុស្សធម៌ និងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងរហូតដល់ការតស៊ូមតិ។ អង្គការសង្គមស៊ីវិលជាទូទៅត្រូវបានគេទទួលស្គាល់ថាជាសមាសធាតុដ៏សំខាន់សម្រាប់ការកែលម្អសង្គមដោយរដ្ឋចាប់ពីការចេញជាការផ្តល់សេវាជាមូលដ្ឋាន រហូតដល់ការកែតម្រូវផ្នែករចនាសម្ព័ន្ធដោយរួមបញ្ចូលទាំងការអភិវឌ្ឍអភិបាលកិច្ចល្អនិងប្រជាធិបតេយ្យនីយកម្ម ហើយក៏ជាស្នូលដ៏សំខាន់មួយចំពោះអភិបាលកិច្ចជាទូទៅតាមរយៈសកម្មភាពដែលមានចាប់តាំងពីការផ្តល់សេវាជាមូលដ្ឋាន ការផ្តល់ជំនួយមនុស្សធម៌ ការកសាងសមត្ថភាពនិងការតស៊ូមតិ Chong, Elies et al. និងអ្នកផ្សេងទៀតបានពន្យល់បន្ថែមអំពីទំនាក់ទំនងផ្សេងៗគ្នារវាងសង្គមស៊ីវិល និងរដ្ឋាភិបាលដែលមានការខុសប្លែកគ្នាទាក់ទងជាមួយនឹងភាពតានតឹងរបស់អង្គការសង្គមស៊ីវិល នៅក្នុងការជម្នះទៅលើគោល នយោបាយ និងសំណើជាច្រើនរហូតដល់ទាក់ទងកិច្ចសហប្រតិបត្តិការដែលអង្គការសង្គមស៊ីវិល ត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលថាចាំបាច់ការអភិវឌ្ឍប្រកបដោយជោគជ័យ។ គំរូរបស់ពួកគេបានបង្ហាញនូវវិសាលភាពចំនួន៣ ចំពោះការចូលរួមពាក់ព័ន្ធជាមួយនឹងសង្គមស៊ីវិលនិងរដ្ឋាភិបាល។ ទី១ “ ការយល់ដឹងដោយស្ងៀមស្ងាត់” និងផល

ប្រយោជន៍ទៅវិញទៅមកនៅក្នុងវិស័យសេវាមូលដ្ឋាន ទី២ មានទំនាក់ទំនង “ ដែលត្រូវបានសម្របសម្រួល ” នៅក្នុងន័យមួយដែលថាស្វ័យភាពរបស់អង្គការស៊ីវិលគឺត្រូវបានកំណត់ដោយក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែរបានចែងដោយរដ្ឋ។ ទី៣ មានភាពតានតឹងឬក៏ទំនាស់នៅពេលដែលអង្គការសង្គមស៊ីវិលបានចូលរួមយ៉ាងសកម្មនៅក្នុងកាតស៊ូមតិសម្រាប់ក្រុមដែលមិនទទួលការយកចិត្តទុកដាក់។ ភាពតានតឹងរវាងសង្គមស៊ីវិលហើយនឹងរដ្ឋ នៅក្នុងប្រទេសកម្ពុជាមានកើតឡើងនៅក្នុងវិស័យផ្សេងៗគ្នា។ ភាគច្រើនក្នុងវិស័យដែលមានការពាក់ព័ន្ធជាមួយនឹងការកែលម្អសមត្ថភាពស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គម និងទិន្នន័យដែលគេត្រូវការ ។ វិស័យទាំងអស់នេះរួមមានដូចជាសេដ្ឋកិច្ចប្រជាធិបតេយ្យ អភិបាលកិច្ចសិទ្ធិធនធានដីធ្លី និងធនធានធម្មជាតិ ព្រមទាំងការដោះស្រាយវិសមភាពដែលកើតចេញមកអំពីកំណើត។ សង្គមស៊ីវិលត្រូវប្រឈមនឹងការងារលំបាកៗទាំងក្នុងការជូនដំណឹង ឬក្នុងការជូនយោបល់អំពីគោលនយោបាយ និងក្នុងការជម្នះគោលនយោបាយរបស់រដ្ឋាភិបាល ។

ពាក់ព័ន្ធជាមួយនឹងនិន្នាការថ្នាក់តំបន់អំពីការសកម្មភាពសមត្ថភាពរបស់អង្គការសង្គមស៊ីវិល Chong, Elies et al. និងអ្នកផ្សេងទៀតបានបង្ហាញពីសមាសភាពដែលមានការកើតឡើងសម្រាប់ការចូលរួមពាក់ព័ន្ធផ្នែកគោលនយោបាយនៅក្នុងវិស័យដូចជាកសិកម្ម ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន និរន្តរភាពនៃការអភិវឌ្ឍ និងសិទ្ធិមនុស្ស។ សំណួរគន្លឹះដែលបានកើតឡើងគឺថាតើធ្វើដូចម្តេចដើម្បីចាត់ចែងការហូរចូលប្រកបដោយថាមភាពនៅក្នុងសង្គមស៊ីវិល និងរដ្ឋឱ្យបានល្អបំផុត?។ នៅក្នុងបរិបទនៃក្រឹត្យក្រមដែលមានការវិវត្តដោយមានការទទួលស្គាល់និងការបញ្ចូលសង្គមស៊ីវិលដូចដែលមានភស្តុតាងបញ្ជាក់ដោយសេចក្តីប្រកាសពីក្រុងប៉ារីស របៀបវារៈសម្រាប់សកម្មភាព Accra គោលការណ៍ប្រសិទ្ធភាពសម្រាប់អភិវឌ្ឍសង្គមស៊ីវិលនៅទីក្រុង Istanbul និងភាពជាដៃគូ Busan នោះវាបានក្លាយទៅជាភាពចាំបាច់ដែលមានការកើតឡើងជាច្រើនក្នុងការអនុវត្ត និងក្នុងការធ្វើឱ្យមានការទទួលស្គាល់មានភាពជាធម្មតាដោយរដ្ឋ។ នៅពេលដែលសង្គមស៊ីវិលមានការកើនឡើងសមត្ថភាពរបស់ការចូលរួមពាក់ព័ន្ធជាមួយនឹងរដ្ឋកាន់តែក្លាយទៅជាមានសភាពស្មុគស្មាញឡើង។

អង្គការ CCC បានរៀបរាប់អំពីការរួមចំណែករបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាថាមានចាប់តាំងពីការផ្តល់សិទ្ធិសង្គម និងសិទ្ធិសេដ្ឋកិច្ចដើម្បីជានា និងគាំទ្រអភិបាលកិច្ចតាមរយៈសិទ្ធិករណីភាពនិងការចូលរួមដែលរួមចំណែកដល់ការផ្លាស់ប្តូរជាបន្តបន្ទាប់។ បើយោងតាមគណៈកម្មការជំនួយអភិវឌ្ឍន៍ OECD នោះអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់នូវផលប្រយោជន៍បែបប្រៀបធៀបក្នុងការធ្វើការដោយផ្ទាល់ច្រើនជាមួយ នឹងអ្នកទទួលផលដែលជាក្រុមគោលដៅបានផ្តល់នូវសមត្ថភាពឆ្លើយតបលឿន និងបានផ្តល់នូវការកៀរគរថវិកាក្នុងអង្គការសង្គមស៊ីវិលព្រមទាំងការលើកកម្ពស់ការយល់ដឹងសម្រាប់បញ្ហាទាំងឡាយដែលជាអាទិភាព។ ធនាគារពិភព

លោកបានលើកឡើងថាការចូលរួមរបស់ពាក់ព័ន្ធរបស់សង្គមស៊ីវិលគួរតែកើតចេញមកអំពីចំណុចខ្លាំងទាំងឡាយដូចជាទំនាក់ទំនងនៅមូលដ្ឋាន បទពិសោធន៍ពីការធ្វើការនៅតាមមូលដ្ឋាន ភាពច្នៃប្រឌិត និងលទ្ធភាពបន្សាំ ការតម្រង់ទិសពីដំណើរការសម្រាប់ការអភិវឌ្ឍវិធីសាស្ត្របែបចូលរួម ការផ្តោតទៅលើគោលការណ៍រយៈពេលវែង ឬគោលការណ៍និរន្តរភាព ព្រមទាំងប្រសិទ្ធផលនៃលទ្ធផល។

អង្គការមិនមែនរដ្ឋាភិបាលបានរួមចំណែកជាច្រើនចំពោះអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិបានដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការផ្តល់ ឬគាំទ្រដល់សេវាសង្គមជាមូលដ្ឋាន ហើយជារឿយៗនៅក្នុងតំបន់ដាច់ស្រយាល និងសហគមនដាច់ស្រយាល ហើយមានវត្តមាននៅគ្រប់ខេត្តទាំងអស់នៅក្នុងវិស័យចម្បងៗ នៅក្នុងប្រទេសកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលក៏បាននាំមកយកនូវគម្រោងធ្លាស់និងវិធីសាស្ត្រធ្លាស់មួយចំនួនសម្រាប់ការអភិវឌ្ឍ ដោយសង្កត់ធ្ងន់ទៅលើការចូលរួមសមធម៌ ការយល់ដឹងអំពី យេនឌ័រ និងនិរន្តរភាពបរិស្ថាន។ វាជាការសំខាន់ណាស់នៅក្នុងការពិចារណាថា នៅក្នុងវិស័យមួយចំនួនធនធានដែលផ្តល់ដល់ វិស័យអង្គការសង្គមស៊ីវិលមានចំនួនច្រើនជាងធនធានដែលផ្តល់ឱ្យរដ្ឋាភិបាលដូចជាការអភិវឌ្ឍសហគមន៍និង យេនឌ័រ ជាដើម អង្គការ CCC បានលើកឡើងថាត្រូវការការស្រាវជ្រាវស៊ីជម្រៅបន្ថែមទៀតដែរ ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីកម្រិតនៃការទទួលយកបានរវាងកម្មវិធីរបស់រដ្ឋាភិបាល និងគោលបំណងអាទិភាពនៃសកម្មភាពរបស់អង្គការសង្គមស៊ីវិល និងដើម្បីកែលម្អយុទ្ធសាស្ត្រឆ្ពោះទៅរកការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ បញ្ហានេះវាកើតចេញមកអំពីការផ្តល់នូវភាពផ្តាច់មុខនៃការធ្វើកម្មវិធីដោយអង្គការសង្គមស៊ីវិលដែលកើតចេញមកអំពីការបែងចែកការងារ បែងចែកអង្គការមិនមែនរដ្ឋាភិបាលពីសង្គមស៊ីវិលជាទូទៅ។ ចំណងដ៏ទន់ខ្សោយចំពោះសង្គមស៊ីវិលលើការងារមូលដ្ឋានវប្បធម៌បែបប្រពៃណីនៃការមិនចូលរួមពីនយោបាយដែលមានលក្ខណៈចូលរួម និងសកម្មភាពសង្គមព្រមទាំងការគោរពចំពោះអាជ្ញាធរ ក៏ដូចជាកម្រិតនៃការពឹងផ្អែកដ៏ច្រើនទៅលើម្ចាស់ជំនួយ ព្រមទាំងការផ្តោតទៅលើសកម្មភាពផ្សេងៗគ្នានៅក្នុងវិស័យអង្គការមិនមែនរដ្ឋាភិបាល រចនាសម្ព័ន្ធក្នុងការដាក់កំហិតសម្រាប់ការកសាងសមត្ថភាព និងការចាប់យកការស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាលសម្រាប់ធ្វើគោលនយោបាយ។ ជាងនេះទៅទៀត ការទទួលព័ត៌មានដែលមានកម្រិត តិចតួចព្រមទាំងផលប៉ះពាល់នៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ព្រមទាំងមូលដ្ឋានធនសង្គមដទៃទៀតបានធ្វើឲ្យមានការរឹតបន្តឹង ពីថ្នាក់លើចុះមកថ្នាក់ក្រោម និងពីថ្នាក់ក្រោមឡើងទៅថ្នាក់លើស្តីពីការពង្រឹងបន្ថែម និងការចូលរួមពាក់ព័ន្ធបន្ថែមសម្រាប់ការចាប់យកនូវការស្រាវជ្រាវនិងការផ្សព្វផ្សាយការស្រាវជ្រាវ។ លក្ខណៈទាំងអស់នេះគឺជាការរៀបរាប់ជាទូទៅ អំពីសង្គមស៊ីវិលដែលស្ថិតនៅក្នុងការផ្លាស់ប្តូរ ហើយត្រូវបានរៀបរាប់ក្នុងការស្រាវជ្រាវឯកសារដែលមានស្រាប់។

របស់សំខាន់សម្រាប់អង្គការសង្គមស៊ីវិលតាមរយៈទស្សនៈនៃម្ចាស់ជំនួយគឺត្រូវបានបង្ហាញដោយ សហគមន៍អឺរ៉ុបថាជាចលនាមួយដែលចេញពីសង្គមស៊ីវិលក្នុងនាមជាដៃគូដ៏សំខាន់ក្នុងការអនុវត្តកម្មវិធី អភិវឌ្ឍន៍ទៅដល់អង្គការសង្គមស៊ីវិលដែលធ្វើកិច្ចសហប្រតិបត្តិការរដ្ឋ និងការដកការទទួលខុសត្រូវជាបន្ត បន្ទាប់ទៅឱ្យរដ្ឋ។ ចុងក្រោយ អង្គការសង្គមស៊ីវិលភាគច្រើនមានការពាក់ព័ន្ធជាមួយនឹងផលប្រយោជន៍និងតម្រូវការរបស់ក្រុមគោលដៅជាអាទិភាព។ សកម្មរបស់អង្គការសង្គមស៊ីវិលបានកើនឡើងដល់ការយល់ដឹងជាសាធារណៈ និងការចូលរួមជាសាធារណៈទៅលើបញ្ហាផ្សេងៗដោយបង្កើតឱ្យមានការរំពឹងទុកផ្នែកសង្គម និងទាមទារឱ្យមានអភិបាលកិច្ចល្អដែលត្រូវបានគេយល់ជាទូទៅថាជាដំណើរការនៃការធ្វើការសម្រេចចិត្តជាសាធារណៈ ដែលបង្កើតជាលទ្ធផលត្រូវបានឆ្លុះបញ្ចាំងដល់ការសម្រេចចិត្តគោលនយោបាយ និងនៅក្នុងការអនុវត្តគោនយោបាយ។ ដើម្បីសម្រេចបានគោលបំណងនេះអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលអាច និងត្រូវតែផ្តល់ជំនាញនិងព័ត៌មានត្រឹមត្រូវ ការតភ្ជាប់នៅតាមមូលដ្ឋាននិងបទពិសោធន៍ដែលផ្អែកទៅលើការដឹងរបៀបធ្វើការធ្វើសម្រេចចិត្តនិងអនុសាសន៍។ ប្រការនេះអាចយល់ដឹងការចូលរួមរបស់ពលរដ្ឋជាការបើកច្រកសម្រាប់បញ្ចូលសំឡេងដែលមិនត្រូវបានគេយកចិត្តទុកដាក់ និងការតាមដានអនុវត្តគោលនយោបាយព្រមទាំងការផ្តល់យោបល់ ត្រឡប់ទៅឱ្យអាជ្ញាធរ។ ការចូលរួមពាក់ព័ន្ធជាមួយអ្នកធ្វើគោលនយោបាយនិងការចាប់យកគោលនយោបាយឱ្យមានប្រសិទ្ធភាពអាចធ្វើតាមច្រកនៃការសម្របសម្រួលជាផ្លូវការ ឬតាមរយៈការកៀរគរផ្នែកសង្គមដោយផ្អែកទៅលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការធ្វើការតស៊ូមតិ ឬក៏ទាំងពីរ។

និន្នាការសំខាន់មួយដែលគាំទ្រដោយការវិភាគការស្រាវជ្រាវឱ្យមានសក្តានុពលសម្រាប់ការកាត់បន្ថយភាពពឹងផ្អែកដែលកើតចេញមកអំពីការផ្លាស់ប្តូរពីការផ្តល់ជំនួយ និងសកម្មភាពដែលជំរុញដោយកម្ចីឥតសំណង ទៅជាប្រតិបត្តិការដែលផ្តល់មូលនិធិតាមបែបពាណិជ្ជកម្ម។ មានភស្តុតាងនៃការរំពឹងទុកមួយដោយអ្នកឆ្លើយតបមួយចំនួនច្រើនគួរសមអំពីកាផ្លាស់ប្តូរឱ្យទៅជាប្រភពចំណូលបែបពាណិជ្ជកម្មនៅក្នុងរយៈពេល៥ឆ្នាំខាងមុខទៀត។ វិស័យដែលសង្គមស៊ីវិលបានអភិវឌ្ឍប្រកបដោយជោគជ័យគឺការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពដែលមាននិរន្តរភាពក៏ដូចជាប្រភពចំណូល។ តែទោះជាយ៉ាងណា ក៏វាមិនទាន់ច្បាស់ថា តើប្រការនេះអាចនឹងត្រូវរឹតបន្តឹងចំពោះវិស័យមួយចំនួននៃអង្គការសង្គមស៊ីវិល ឧទាហរណ៍ដូចជាទេសចរណ៍ និងអង្គការបណ្តុះបណ្តាលផ្នែកទេសចរណ៍និងបដិសណ្ឋារកិច្ចដែរឬយ៉ាងណានោះ។ អ្វីដែលជាបញ្ហាបន្ថែមទៀតនោះគឺអវត្តមាននៃការទទួលស្គាល់ដ៏ច្បាស់លាស់មួយអំពីការគាំទ្រពីសង្គមស៊ីវិលខ្លួនឯងនៅក្នុងទម្រង់ជាការផ្តល់អំណោយបែបសប្បុរសធម៌ និងអវត្តមាននៃការរំពឹងទុកពីការកើនឡើងនៃការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋ។ បើយោងទៅតាមអង្គការ CCC ខណៈដែលសកម្មភាពរបស់អង្គការសង្គមស៊ីវិលមួយចំនួនធំ និងធនធានមួយចំនួនធំត្រូវបានគេប្រើសម្រាប់ការផ្តល់សេវាកម្មសម្រាប់វិស័យនៃសកម្មភាពរបស់អង្គការសង្គមស៊ីវិល ដែលមាន

ការពាក់ព័ន្ធនោះ សកម្មភាពជាច្រើនបានផ្ដោតទៅលើការកសាងសមត្ថភាព និងការពង្រឹងតាមបែបប្រព័ន្ធ និងការពង្រឹងតាមបែបស្ថាប័ន។ ការរួមចំណែករបស់អង្គការសង្គមស៊ីវិលបានផ្ដល់សេវាកម្មគួរតែត្រូវបានគេចាត់ទុកថាបានសូចនាករនៃនិន្នាការជារួមសម្រាប់អង្គការសង្គមស៊ីវិលដែលចេញពីភាពជាដៃគូនៅក្នុងការអនុវត្ត គម្រោងផ្នែកការផ្ដល់សេវាទៅជាការដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងផ្នែកអភិបាលកិច្ចបែប ប្រជាធិបតេយ្យ។ ប្រការដែលគួរឱ្យកត់សម្គាល់អ្នកស្រាវជ្រាវបានរកឃើញអំពីការកែលម្អជាច្រើនទាក់ទងជាមួយនឹងការតាមដានទៅលើជំនួយដោយម្ចាស់ជំនួយ ប៉ុន្តែការយកចិត្តទុកដាក់មិនទាន់បានធ្វើឡើងគ្រប់គ្រាន់នៅឡើយទេចំពោះភាពជាម្ចាស់នៅតាមមូលដ្ឋាន និងគណនេយ្យភាពបែបប្រជាធិបតេយ្យ។ អង្គការ CCC បានទទួលស្គាល់ថា ការផ្ដោតការយកចិត្តទុកដាក់របស់អង្គការសង្គមស៊ីវិលទៅលើការគាំទ្រ និងការផ្លាស់ប្ដូរ សង្គមដែលកំពុងតែមានការអភិវឌ្ឍតាមរយៈការកសាងសមត្ថភាពស្ថាប័ននឹងប្រព័ន្ធក៏ដូចជាតាមគោល នយោបាយសាធារណៈ និងការអនុវត្តគោលនយោបាយសាធារណៈដូចជាការគាំទ្រផ្ដល់គណនេយ្យភាពសង្គម ឬក៏ផ្នែកតម្រូវការឱ្យមានការអភិវឌ្ឍល្អនៅក្នុងតួនាទីមួយ ដែលត្រូវបានទទួលស្គាល់ក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិផ្ទាល់របស់រដ្ឋាភិបាលយុទ្ធសាស្ត្រចតុកោណបានបង្ហាញថា ដំណើរការនៃការអនុវត្តនេះអាចនឹងកំពុងតែប្រព្រឹត្តទៅ ប៉ុន្តែវាអាចនឹងត្រូវការចោទសួរបន្ថែមទៀតនៅក្នុងការស្រាវជ្រាវនៅក្នុងពេលអនាគតមុនពេលដែលធ្វើការទាញសេចក្ដីសន្និដ្ឋានរឹងមាំណាមួយ " ។

ការវាយតម្លៃរបស់ធនាគារពិភពលោកទៅលើសង្គមស៊ីវិលបានរកឃើញថាសង្គមស៊ីវិលដែលជាលទ្ធផលនៃផលប៉ះពាល់ដោយសារព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ គឺភាគច្រើន កើតចេញមក អំពីការគាំទ្រហើយ នឹងធនធានរបស់ម្ចាស់ជំនួយអន្តរជាតិ ហើយថាវានៅតែមានការពឹងផ្អែក ខ្លាំងទៅលើម្ចាស់ជំនួយ ដោយសារតែមូលដ្ឋានគ្រឹះនៅតាមមូលដ្ឋាននៅមានកម្រិតនៅឡើយ។ ប៉ុន្តែធនាគារពិភពលោកក៏បានសន្និដ្ឋានដែរថាសង្គមស៊ីវិល កម្ពុជាមានភាពចម្រុះនិងមានដំណើរការល្អខណៈដែលអង្គការមិនមែនរដ្ឋាភិបាលបែបវិជ្ជាជីវៈ មានទស្សនវិស័យដូចគ្នាជាមួយនឹងសហជីពបណ្ដាញអង្គការមហាជន និងចលនាមហាជន។ ការផ្លាស់ប្ដូរនេះគឺមួយផ្នែកដោយសាតែកិច្ចខិតខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការយល់ដឹងពីសិទ្ធិ និងគណនេយ្យភាពបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ ធនាគារពិភពលោកបានរកឃើញថាការផ្លាស់ប្ដូរមានសភាពយឺត ហើយការកៀរគរពិតប្រាកដ ដែលមានចំណងភ្ជាប់ទៅនឹងតួអង្គនៅក្នុងវិស័យផ្សេងៗនោះ គឺមានភាពច្បាស់លាស់នៅក្រោយការបោះឆ្នោតនៅឆ្នាំ២០១៣តែប៉ុណ្ណោះ។

អង្គការ Oxfam បានរៀបរាប់ដំណើរការនៃការផ្លាស់ប្ដូរនេះទាក់ទងជាមួយនឹងបញ្ហាប្រឈមដែលកើតឡើងមិនចេះចប់សម្រាប់សង្គមស៊ីវិល។ ការផ្លាស់ប្ដូរទៅសម្រេចឱ្យបានសង្គមស៊ីវិលដែលមាន សមត្ថភាព និងមានស្វ័យតគឺយើងមើលឃើញថា មានភាពប្រាកដនៅក្នុងទាក់ទងជាមួយនឹងការ

សហប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល ដែលនៅតែទទួលរងការលំបាកដោយសារតែកង្វះខាតនៃភាពស៊ីសង្វាក់ជាទូទៅមួយនៅក្នុងវិស័យនេះ។ បុព្វហេតុសំខាន់ៗនៃការខ្វះខាតកិច្ចសហប្រតិបត្តិការនេះគឺរួមមានគោលនយោបាយរបស់ម្ចាស់ជំនួយ និងប្រព័ន្ធផ្តល់មូលនិធិ ការប្រកួតប្រជែងរវាងអង្គការសង្គមស៊ីវិលដើម្បីដណ្តើមយកធនធានទាំងអស់នោះព្រមទាំងបុគ្គលិកលក្ខណៈ កិត្តិយសជាសាធារណៈរបស់អង្គការសង្គមស៊ីវិល (នយោបាយសង្គមស៊ីវិល)។ បញ្ហាសម្រាប់ការគាំទ្រគ្នាទៅវិញទៅមក និងការកៀរគរធនធានទៅវិញទៅមកក្នុងចំណោមអង្គការសង្គមស៊ីវិលនេះកើតចេញមកពីរបៀបវារៈដែលដឹកនាំដោយម្ចាស់ជំនួយសម្រាប់ធ្វើឱ្យកម្មវិធី និងការផ្តល់មូលនិធិរយៈពេលខ្លី(តាមរយៈគម្រោងជាជាងការផ្តល់ជាកម្មវិធីទាំងមូល) ការកាត់បន្ថយធនធានជាទូទៅដែលអាចរកបានដោយម្ចាស់ជំនួយ និងការខ្វះខាតសមត្ថភាពនៅក្នុងការឆ្លើយតប និងគំនិតផ្តួចផ្តើមថ្មីៗ។ អង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញវាជាការចាំបាច់ណាស់ម្ចាស់ជំនួយត្រូវការសហការគ្នាទៅលើស្តង់ដារ ហើយប្រាស័យទាក់ទងគ្នាទៅលើគម្រោងនានា ដើម្បីចៀសវាងនូវការបង្កើនភាពប្រកួតប្រជែងក្នុងចំណោមអង្គការសង្គមស៊ីវិល ហើយថាម្ចាស់ជំនួយគួរតែផ្លាស់ប្តូរពីការផ្តល់មូលនិធិដល់គម្រោងទៅជាការផ្តល់មូលនិធិសម្រាប់កម្មវិធីរយៈពេលវែងវិញ។ អង្គការ CCC បានស្វែងរកភ្នាក់ងារនៅក្នុងការរៀបចំបង្កើតជាមួយ និងកិច្ចពិគ្រោះយោបល់ជាមួយនឹងតួអង្គសង្គមស៊ីវិលផ្សេងគ្នាដើម្បីបង្កើតនូវចក្ខុវិស័យរបស់អង្គការសង្គមស៊ីវិលជាយុទ្ធសាស្រ្តរួមគ្នាមួយដែលអាចនឹងកែលម្អដល់ការសម្របសម្រួលក្នុង ចំណោមវិស័យនានាដើម្បីឱ្យមានសុខដុមរមនាកម្មសម្រាប់កិច្ចខិតខំប្រឹងប្រែងផ្នែកគោលនយោបាយរបស់ពួកគេ។

កត្តាប្រែប្រួលផ្សេងៗទៀតដែលមានការជះឥទ្ធិពលទៅដល់បរិយាកាសរបស់អង្គការសង្គមស៊ីវិល រួមមាន បម្លាស់ទីលំនៅតាមជនបទនិងការធ្វើនគរូបនីយកម្ម បច្ចេកវិទ្យា (ទូរស័ព្ទ អ៊ីនធើណិត និងបណ្តាញសង្គម) ការកើនឡើងនៃសមត្ថភាពនៅក្នុងការបង្កើតចលនាសង្គម ការកើនឡើងនូវឆន្ទៈរបស់សាធារណជនសម្រាប់ការបញ្ចេញមតិ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ... 

ក៏ដោយ។ ហើយការកើនឡើងទាំងចំនួនអង្គការ មហាជននិងការយល់ដឹងអំពីសារៈសំខាន់នៃការសម្របសម្រួលរវាងអង្គការទាំងឡាយ។ ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានរកឃើញទាំងការវិវត្តនៃវិស័យសង្គមស៊ីវិលការផ្តល់សេវាជាសាធារណៈ ដែលកំពុងតែបន្តមានក្នុងសភាពជាបញ្ហាមិនល្អដែលកើតចេញមកអំពីបញ្ហាដែលកើតឡើងជាប្រចាំហើយកំពុងតែមានការវិវត្តទៅមុខ។ ម្យ៉ាងវិញទៀត វិស័យអង្គការមិនមែនរដ្ឋាភិ បាលមានការវិវត្ត ហើយនៅក្នុងនោះវាក៏បានវិវត្តទៅរកភាពវិជ្ជាមានបានផ្លាស់ប្តូរមួយចំណែកក្លាយទៅជាការអភិវឌ្ឍ និងការធ្វើប្រជាធិបតេយ្យនីយកម្មក្នុងរយៈពេលវែងជាជាងការដែលផ្តល់ជំនួយផ្នែកមនុស្សធម៌ និងការផ្ទេរតំបន់មួយចំនួនសម្រាប់ផ្តល់សេវាកម្មសាធារណៈទៅឱ្យរដ្ឋាភិបាលតាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការ ហើយម្យ៉ាងវិញទៀត អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបន្តធ្វើការដោយផ្ទាល់ទៅលើរយៈពេលខ្លីដែលប្រើប្រាស់វិធីសាស្រ្តកម្មវិធីដែលមានភាពសមស្របជាមួយនឹងការផ្តល់ជំនួយមនុស្សធម៌ដូចដែលអង្គការច្រើនបានបន្តចូលរួមនៅក្នុងក្រារផ្តល់សេវាដែល

មានលក្ខណៈប្រហាក់ប្រហែល និងការបញ្ជូនបុគ្គលិករដ្ឋាភិបាលឱ្យទៅធ្វើការនៅក្នុងគម្រោងជាបណ្តោះអាសន្ន។

ទាក់ទងជាមួយនឹងការរីកចម្រើន ធនាគារអេភិវឌ្ឍន៍អាស៊ីបានរៀបរាប់អំពី វិស័យអង្គការមិនមែន រដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាថា មានភាពរឹងមាំក្នុងផ្នែកតស៊ូមតិ។ ជាងនេះទៅទៀត មានទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ដែលបង្កើតឡើងយ៉ាងល្អរវាងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុកតាមរយៈការផ្តល់មូលនិធិក្នុងការកសាងសមត្ថភាព។ ដូចដែលបានកត់សម្គាល់រួចមកហើយថា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានចាប់យកវិធីសាស្ត្ររយៈពេលវែងសម្រាប់ការអភិវឌ្ឍ ហើយការធ្វើបែបនេះទាមទារឱ្យមាននិរន្តរភាពដែលពួកគេអាចបន្តការងាររបស់ពួកគេដោយខ្លួនឯងបានកាន់តែខ្លាំងបន្ថែមទៀតរួមជាមួយ នឹងការផ្តល់ហិរញ្ញប្បទានធ្វើឱ្យពួកគេបន្តធ្វើដំណើរការដោយខ្លួនឯងបានរួមជាមួយនឹងការថយចុះនៃភាពពឹងផ្អែកទៅលើជំនួយខាងក្រៅ។ ជាចុងក្រោយ មានអង្គការដែលត្រូវបានបង្កើតឡើងយ៉ាងល្អ និងមានសមត្ថភាព ហើយការស្រាវជ្រាវដែលអាចធ្វើគម្រោងល្អៗ និងអាចផលិតនូវលទ្ធផលដែលមានគុណភាពស័ក្តិសមសម្រាប់ការទទួលយកធ្វើគោលនយោបាយ។

តែទោះជាយ៉ាងណាក៏ដោយ មានឧបសគ្គគួរឱ្យកត់សម្គាល់មួយចំនួនដែលកំពុងតែប្រឈមដែលកំពុងរៀបចំអភិវឌ្ឍឱ្យមានយុទ្ធការ សម្រាប់ធ្វើឱ្យមានការផ្លាស់ប្តូរមួយរវាងការស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកធ្វើគោលនយោបាយ។ ទី១ មូលនិធិសង្គមស៊ីវិលនៅតាមមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាមានភាពទន់ខ្សោយនៅឡើយ ហើយអង្គការមិនមែនរដ្ឋាភិបាលដែលមានវិជ្ជាជីវៈគឺកើតចេញមកអំពីធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលមកពីខាងក្រៅខ្លាំងជាជាងចេញមកអំពីដំណើរការប្រជាធិបតេយ្យនីយកម្មដែលកើតចេញមកអំពីខាងក្នុង។ វប្បធម៌នៃការគាំទ្រសកម្មភាពអ្នកស្ម័គ្រចិត្តមិនមានអ្នកវត្តមានច្រើនទេ រួមនឹងអ្នកគាំទ្រជនថ្នាក់កណ្តាលសម្រាប់កម្មវិធីបរិច្ចាគដែលមានការរៀបចំត្រឹមត្រូវ។ ទី២ ទោះបីជានៅក្នុងវិស័យជាច្រើនដែលអង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលបន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋាភិបាលក៏ដោយ ក៏ក្នុងវិស័យមួយចំនួនអង្គការមិនមែនរដ្ឋាភិបាលត្រូវបានគេរកឃើញថាមានភាពរិះគន់ខ្លាំងក្លាពេក ខណៈដែលអ្នកវិភាគបានបង្ហាញពីនិន្នាការជាទូទៅមួយចំពោះការថយចុះក្នុងការសន្តោសប្រណីពីរដ្ឋ។ ចុងបញ្ចប់បន្ទាប់ពីមានការដាក់បញ្ចូលគ្នាអំពីបញ្ហាប្រឈមទាំងពីរខាងលើនេះ ការពិភាក្សាផ្នែកគោលយោបាយ និងការចាប់យកសម្រាប់ធ្វើគោលនយោបាយនៅតែមានភាពពិបាកពិពណ៌នា"។ កិច្ចសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ ជាទូទៅរវាងរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលគឺមានភាពទន់ខ្សោយ ហើយពឹងផ្អែកទៅលើវិស័យជាក់លាក់មួយចំនួន"។

បើយោងទៅតាមកាលវិភាគរបស់អង្គការ Oxfam "ការផ្លាស់ប្តូរសំខាន់ដែលគេសង្កេតឃើញមាននោះ គឺការពង្រឹងភាពជាពលរដ្ឋដ៏សកម្មនៅកម្រិតមូលដ្ឋានតាមរយៈការលើកកម្ពស់ការយល់ដឹង និងការអប់រំ ការកៀរគរការតភ្ជាប់សម្រាប់សកម្មភាពពីសមូហភាព និងការគាំទ្រយុទ្ធសាស្ត្រធ្វើការតស៊ូមតិ"។ នេះបង្ហាញថា មានការផ្លាស់ប្តូរជាមូលដ្ឋានមួយចំពោះការយល់ឃើញទៅលើខ្លួនឯងសម្រាប់ពលរដ្ឋកម្ពុជាជាច្រើនទាក់ទងនឹងទំនាក់ទំនងជាមួយរដ្ឋ និងសមត្ថភាពរបស់អ្នកស្រាវជ្រាវ និងលទ្ធភាពរបស់ពួកគេក្នុងការជះឥទ្ធិពលទៅលើរដ្ឋាភិបាល" ស្របពេលជាមួយគ្នាដែលរបាយការណ៍នោះបានធ្វើការសន្និដ្ឋានថា សង្គមស៊ីវិលដែលមានភាពរឹងមាំជាងមុននេះមិនបានជះឥទ្ធិពលដោយផ្ទាល់ទៅលើគោលនយោបាយទេ ហើយនៅតែត្រូវបានរដ្ឋាភិបាលបកស្រាយថា ជាការប្រឈម ហើយជាការរិះគន់ដែលគ្មានសុពលភាព ហេតុដូច្នេះហើយរដ្ឋបានឆ្លើយតបទៅវិញជាមួយនឹងការប្រានចោល ឬក៏ការបំភិតបំភ័យ និងអំពើហិង្សា។ នៅក្នុងករណីមួយចំនួន គេត្រូវការច្បាប់នៅក្នុងករណីមួយចំនួនទៀតច្បាប់មិនត្រូវបានគេអនុវត្តប្រកបដោយយុត្តិធម៌ និងដោយមានប្រសិទ្ធភាពទេ។ ជាងនេះទៅទៀត សេចក្តីសម្រេចចិត្តនៃថ្នាក់មូលដ្ឋានត្រូវបានគ្របដណ្តប់ដោយការសម្រេចចិត្តនៃថ្នាក់ជាតិដែលនេះជាការដាក់កំហិតទៅលើវិមជ្ឈការធ្វើវិមជ្ឈការនិងការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទាំងការខ្វះខាតច្បាប់ និងការខ្វះខាតការអនុវត្តច្បាប់ដែលមានស្រាប់នេះគឺកើតចេញមកភាគច្រើនពីការខ្វះខាតឆន្ទៈនយោបាយ និងអវត្តមាននៃប្រព័ន្ធតុលាការឯករាជ្យដែលប្រតិបត្តិការទៅលើគោលការណ៍នីតិរដ្ឋ តម្លាភាព និងការបញ្ចេញព័ត៌មានពេញលេញ។

បើយោងតាមរបាយការណ៍របស់អង្គការ Oxfam Novib ប្រទេសកម្ពុជាឥឡូវនេះគឺកំពុងតែស្ថិតក្នុងដំណាក់កាល "ត្រូវតែផ្លាស់ប្តូរ" ដែលវាមានសក្តានុពលនៅក្នុងការធ្វើប្រជាធិបតេយ្យនីយកម្មបន្ថែមទៀតឬការផ្លាស់ប្តូរត្រឡប់ទៅរកភាពផ្តាច់ការ។ វិធីសាស្ត្រដែលមានពីរស្រទាប់ត្រូវការមានជាចាំបាច់ដើម្បីធ្វើឱ្យមានតុល្យភាពឆ្ពោះទៅរកការធ្វើប្រជាធិបតេយ្យនីយកម្ម គឺការបង្កើនជាតុចូលពីអង្គការសង្គម ស៊ីវិលទៅក្នុងគោលនយោបាយនិងការពង្រីកសហាគមន៍ ឬការកៀរគរដោយផ្អែកទៅលើមូលដ្ឋាននៃការអនុវត្តល្អបំផុត និងការកសាងសមត្ថភាព។ ការធ្វើបែបនេះនិងការតភ្ជាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលដែលមានលក្ខណៈពីលើចុះក្រោមនិងពីក្រោមឡើងទៅលើ។

ការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងសង្គមស៊ីវិលគឺការកើនឡើងនៃការកសាងសមត្ថភាពនៅកម្រិតមូលដ្ឋាន និងកម្រិតអង្គការមហាជនបន្ថែមទៅលើការផ្តល់សេវាកម្មសម្រាប់អ្នកទទួលផលទាក់ទងជាមួយនឹងការអនុវត្តគម្រោងដែលគាំទ្រដោយម្ចាស់ជំនួយ។ គន្លឹះសំខាន់ៗចំពោះចំណុចនេះគឺការកើនឡើងចំណេះដឹងនិងការកែលម្អការទទួលបានព័ត៌មាន ហើយវាទាមទារឱ្យមានការបំបាត់ចោលនិងជម្រុះចោលនូវវប្បធម៌ភ័យខ្លាច និងការសម្ងាត់ដោយផ្អែកទៅលើមូលដ្ឋាននៃបទពិសោធន៍ និងការចូលរួមពិតប្រាកដដ៏មានវិសាលភាពសហាគមន៍ដ៏ទូលំទូលាយមួយតាមរយៈការដោះស្រាយបញ្ហាជារួម

ការប្រមូលព័ត៌មានជារួម និងការវិភាគដែលកើតចេញមកអំពីប្រការទាំងអស់នោះ។ សមាសធាតុជាសម្ភារៈនិងជាហេដ្ឋារចនាសម្ព័ន្ធសំខាន់សម្រាប់ដំណើរការនេះគឺបណ្តាញឬសម្ព័ន្ធ។ វិធីសាស្ត្រនេះបានផ្តល់នូវលទ្ធផលជាជោគជ័យមួយចំនួន ប៉ុន្តែបញ្ហានៅតែកើតមានក្នុងការធ្វើការជាមួយនឹង អាជ្ញាធររដ្ឋាភិបាលដែលបញ្ហានេះកើតចេញមកអំពីរចនាសម្ព័ន្ធនៃការសម្រេចចិត្តដែលពឹងផ្អែកលើបញ្ញាជាជាងនីតិរដ្ឋ និងការខ្វះខាតនូវប្រព័ន្ធយុត្តិធម៌ឯករាជ្យមួយ ដែលជាការដាក់កំហិតទៅលើការប្រើប្រាស់ទៅលើការទាញយកផលប្រយោជន៍ពីច្បាប់នៅក្នុងរដ្ឋសង្គមស៊ីវិល។នៅក្នុងលក្ខខណ្ឌទាំងនេះ សម្ព័ន្ធឬក៏បណ្តាញបានបង្កឱ្យមានកិច្ចសហប្រតិបត្តិការប្រកបដោយភាពច្នៃប្រឌិតជាច្រើន ដែលត្រូវតែបន្តបណ្តុះបណ្តាលតទៅទៀត។ ប្រការទាំងអស់នេះគឺជាការកៀរគរក្នុងចំណោមវិស័យផ្សេងៗ ដើម្បីឱ្យក្រុមទាំងឡាយគាំទ្រដល់ការទាមទារសិទ្ធិដោយផ្អែកទៅលើអត្តសញ្ញាណរបស់ក្រុមផ្សេងៗទៀត ការផ្តល់ជំនាញបច្ចេកទេសនិងការគាំទ្រផ្នែកភ័ស្តុភារដល់សហគមន៍ ដើម្បីកៀរគរការចងសម្ពន្ធមិត្តតាមរយៈការគាំទ្រដល់តួអង្គនៅក្នុងវិស័យឯកជន ការបង្កើនការចូលរួមពាក់ព័ន្ធជាមួយនឹងយុវជននិងការកែលម្អការផ្សព្វផ្សាយនិងកិច្ចសហប្រតិបត្តិការជាមួយនឹងសាកលវិទ្យាល័យ។

ទោះបីជាមានការបង្ហាញរួចហើយអំពីការរួមចំណែកប្រកបដោយភាពស៊ីសង្វាក់មួយចំពោះការកសាងសមត្ថភាពតាមរយៈបណ្តាញសង្គមស៊ីវិលក៏ដោយ ក៏កម្រិតនៃការផ្ទេរចំណេះដឹងនិងការយល់ដឹង ជាទូទៅចំពោះសារធារណជនជាទូទៅនៅមានកម្រិតទាបនៅឡើយ។ ទោះបីជាមានការពង្រីកបណ្តាញ និងធនធានមានការកែលម្អការកសាងសមត្ថភាពក៏ដោយ ក៏គេនៅតែត្រូវការវិធីសាស្ត្រថ្មីៗដែលត្រូវមានការ ចូលរួមនៅក្នុងទម្រង់ដូចជាមូលធន និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ គឺទាំងនៅកម្រិតក្រុមឬ កម្រិតអង្គការ ព្រមទាំងនៅក្នុងរង្វង់សាធារណជនយ៉ាងទូលំទូលាយមួយ។ បណ្តាញអង្គការមិនមែន រដ្ឋាភិបាលត្រូវឬទាញយកប្រយោជន៍ចេញពីបណ្តាញនេះ ប៉ុន្តែការយល់ដឹងជាការកសាងសមត្ថភាពត្រូវតែធ្វើឱ្យបានហួសពីការដែលគ្រាន់តែយល់ដឹងជាមូលដ្ឋានអំពីប្រសិទ្ធភាពអង្គការ។

សូចនាករមួយផ្សេងទៀតនៃរបត់នេះត្រូវបានរកឃើញនូវកម្រិតអភិបាលកិច្ចខ្លួនឯងក្នុងនាមជាអភិបាលកិច្ចល្អ ឬក៏ការអនុវត្តល្អបំផុតសម្រាប់ប្រតិបត្តិការអង្គការសង្គមស៊ីវិលផ្ទៃក្នុងដែលមានភាពចាំបាច់សម្រាប់ការបង្កើតឱ្យមានការកសាងសមត្ថភាព ដែលកើតចេញពីខាងក្នុងជាទូទៅមួយ គម្រោងអភិបាលកិច្ចល្អរបស់អង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាល (GPP) របស់អង្គការ CCC ជាប្រព័ន្ធស្ម័គ្រចិត្តមួយក្នុងការផ្តល់វិញ្ញាបនបត្រដល់អង្គការមិនមែនរដ្ឋាភិបាល ដែលជាដំណើរការដំបូងមួយនៅក្នុងប្រទេសកម្ពុជាសម្រាប់បង្កើតនូវស្តង់ដារជាអប្បបរមាសម្រាប់ការអនុវត្តល្អសម្រាប់អង្គការសង្គមស៊ីវិល។ គម្រោង GPP ក៏ផ្តល់សមត្ថភាពសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីឱ្យពួកគេបំពេញតាមតម្រូវការនៅក្នុងការទទួលវិញ្ញាបនបត្រនេះ ព្រមទាំងការផ្សព្វផ្សាយជាសាធារណៈនូវឯកសារពាក់ព័ន្ធរបស់

ពួកគេដែលមាននៅតាមគេហទំព័រ។ អង្គការ Oxfam ដែលបានសិក្សាទៅលើការរួមចំណែករបស់អង្គការសង្គមស៊ីវិល ទៅលើគោលនយោបាយបានរកឃើញថា គម្រោង GPP មិនទាន់មានឥទ្ធិពលជាដុំកំភួនក្នុងចំណោមតួអង្គសង្គមស៊ីវិលនៅឡើយទេ។ គម្រោងនេះបានរកឃើញថា ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ៣០០ និងអង្គការក្នុងស្រុក៣.០០០ មានតែ៤០% ទៅ៥០% ប៉ុណ្ណោះដែលបានបំពេញការងារត្រឹមត្រូវតាមដំណើរការនូវការផ្តល់វិញ្ញាបនបត្រនេះ។ អង្គការសង្គមស៊ីវិលបានបង្ហាញថាវិញ្ញាណបនបត្រនេះគឺមានប្រយោជន៍ក្នុងការទាក់ទាញមូលនិធិម្ចាស់ជំនួយ ក៏ប៉ុន្តែមិនមែនសម្រាប់ការកែលម្អពាក់ព័ន្ធជាមួយនឹងការចូលរួមអ្នកធ្វើគោលនយោបាយនោះទេ។ លើសពីនេះទៅទៀត អង្គការសង្គមស៊ីវិល បានបង្ហាញថាដំណើរការនេះបានបង្ហាញការគាំទ្រទៅដល់គណនេយ្យភាពម្ចាស់ជំនួយគឺជាអត្តិភាពមួយទៅលើគណនេយ្យភាពមួយធ្វើឱ្យសហគមន៍ និងអ្នកទទួលផលប្រយោជន៍បានទទួលនូវផលទាំងអស់នោះ។ ជាងនេះទៅទៀត ទោះបីជាមានការពាក់ព័ន្ធសម្រាប់អង្គការមិនមែនរដ្ឋាភិបាលធំៗក៏ដោយ ក៏ដំណើរការនៃការទទួលបានវិញ្ញាបនបត្រនេះអាចនឹងមានលក្ខណៈតឹងតែងជ្រុលសម្រាប់អង្គការមហាជនតូចៗ ឬក៏មិនសូវផ្លូវការ អង្គការមួយចំនួនបានបង្ហាញថាពួកគេត្រូវការធនធានជាច្រើនទៀតដើម្បីបំពេញតាមតម្រូវការដើម្បីទទួលបានវិញ្ញាបនបត្រនេះដែលបានលើកឡើងអំពីធនធានទាំងនោះត្រូវបានគេប្រើដើម្បីបំពេញតម្រូវការជាផ្លូវការ ជាជាងសម្រាប់ទទួលបានជាលទ្ធផលដែលមានប្រយោជន៍រឹងមាំសម្រាប់អ្នកទទួលផលប្រយោជន៍របស់គម្រោង។

បើយោងតាមការស្ទង់មតិស្រាវជ្រាវថ្មីៗទៅលើប្រធានបទនេះរបស់អង្គការ CCC លទ្ធផលជាទូទៅមានភាពចម្រុះទាក់ទងជាមួយនឹងទាំងការយល់ដឹង និងការអនុវត្តគោលនយោបាយដោយស្វយ័តនៅកម្រិតស្ថាប័ននីមួយៗ។ នេះមានន័យថា មួយផ្នែកវាបានឆ្លុះបញ្ចាំងទៅលើភាពទន់ខ្សោយនៃគំរូដែលធ្វើការពីលើចុះមកក្រោមដល់ការអភិវឌ្ឍបណ្តាញដែលត្រូវបានគេយល់យ៉ាងច្បាស់នៅក្នុងការត្រួតពិនិត្យទៅលើឯកសារដែលមានស្រាប់ស្តីអំពីការរួមចំណែកនៃអង្គការសង្គមស៊ីវិល និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការចូលរួមពាក់ព័ន្ធជាមួយនឹងអ្នកធ្វើគោលនយោបាយ។

នៅលើជ្រុងម្ខាងអង្គការសង្គមស៊ីវិលត្រូវតែវិវត្ត និងកែប្រែឱ្យបានប្រសើរឡើង។ នៅលើជ្រុងម្ខាងទៀតអង្គការសង្គមស៊ីវិលដែលមានសុខភាពល្អត្រូវការបរិយាកាសអំណោយផលមួយ។ ទាក់ទងជាមួយនឹងការកែលម្អសង្គមស៊ីវិល គេត្រូវតែធ្វើឱ្យមានការរីកចម្រើនទាំងលទ្ធផល និងគណនេយ្យភាព។ គោលការណ៍ Istanbul បានដាក់បញ្ចូលទៅលើការផ្តោតដោយយកចិត្តទុកដាក់ទៅលើការពង្រឹង និងការចូលរួមភាពជាម្ចាស់តាមបែបប្រជាធិបតេយ្យទៅលើប្រតិបត្តិការដែលមានតម្លាភាព និងគណនេយ្យភាពទៅលើការចែករំលែកចំណេះដឹង និងការរៀនសូត្រ ព្រមទាំងទៅលើនិរន្តរភាពនៃការផ្លាស់ប្តូរសង្គមដែលមានលក្ខណៈអវិជ្ជមាននិងជាបន្តបន្ទាប់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទាំង

អង្គការសង្គមស៊ីវិល ម្ចាស់ជំនួយគួរតែសង្កត់ធ្ងន់ទៅលើឥទ្ធិពលទៅលើផលគុណដែលមានជាសក្តានុពលនៃការកសាងសមត្ថភាពទាំងការចងបណ្តាញ ព្រមទាំងការទាមទារឱ្យមានការវាយតម្លៃកម្មវិធីមួយក្នុងសភាពជាបណ្តុំនៃផលប៉ះពាល់ដែលមានកម្រិត ប្រការនេះកើតចេញមកអំពីការទទួលស្គាល់គោលការណ៍ស្វ័យភាព និងការចូលរួមដោយផ្អែកទៅលើមាតិកាក្នុងការកំណត់អំពី "សង្គមស៊ីវិល" ។ កិច្ចខិតខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើឱ្យមានការឆ្លើយតបទៅប្រជាជនមូលដ្ឋាន និងធ្វើឱ្យពួកគាត់មានការចូលរួមទាក់ទងជាមួយនឹងបញ្ហាដែលកើនមានជាក់ស្តែង មានគោលបំណងក្នុងការបង្កើតឱ្យមាននិរន្តរភាព ក្នុងការចូលរួមពាក់ព័ន្ធឱ្យលើសពីវិសាលភាពដែលមានកម្រិត និងភ្នាក់ងារគាំទ្រដល់ម្ចាស់ជំនួយអង្គការមិនមែនរដ្ឋាភិបាល ស្របពេលជាមួយគ្នានេះដែរ វិធានការដែលមានសង្គតិភាពត្រូវតែចាប់យកដើម្បីចៀសវាងការពង្រឹងអំពើពុករលួយ ឬគំរូដែលមានស្រាប់នៃការសម្រេចចិត្តដែលមានការផ្តាច់ការ។

ផលប៉ះពាល់ និងការចូលរួមបន្ថែមទៀតរបស់សង្គមស៊ីវិលមិនត្រូវពឹងផ្អែក តែត្រូវសម្លឹងមួយផ្អែកទៅលើការដោះស្រាយភាពខ្វះខាតនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីបង្កើតឱ្យមានធន្ទនយោបាយ និងដើម្បីដោះស្រាយទៅលើភាពខ្វះខាតផ្អែកហេដ្ឋារចនាសម្ព័ន្ធទាក់ទងទៅនឹងការតំណាងបែបប្រជាធិបតេយ្យនិងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ សូមកត់សម្គាល់ថាការកសាងសមត្ថភាពក្នុងការស្រាវជ្រាវគឺមានលក្ខណៈសំខាន់ណាស់ចំពោះកិច្ចប្រឹងប្រែង ព្រមទាំងផ្តល់នូវការគាំទ្រផ្អែកផ្លូវចិត្តចំពោះការអភិវឌ្ឍពីថ្នាក់ក្រោមឡើងទៅថ្នាក់លើនៃការអភិវឌ្ឍសមតាមស្ថានភាព និងការចូលរួមពាក់ព័ន្ធឱ្យបានលើសពីការឈោងចាប់របស់កម្មវិធីម្ចាស់ជំនួយជាក់លាក់មួយចំនួន។ នៅត្រង់ចំណុចនេះវាមានការពាក់ព័ន្ធចំពោះការគិតអំពីប្រព័ន្ធឧត្តមសិក្សាក្នុងប្រទេសកម្ពុជា និងសក្តានុពលនៅក្នុងការធ្វើឱ្យមានភាពរឹងមាំទៅដល់គ្រឹះស្ថានឧត្តមសិក្សា ដែលជាកត្តាដ៏សំខាន់មួយសម្រាប់ការកែលម្អការកសាងសមត្ថភាព និងកិច្ចខិតខំប្រឹងប្រែងឱ្យមានការចាប់យកធ្វើគោលនយោបាយដោយសង្គមស៊ីវិល។

## ឧត្តមសិក្សា

សហគមន៍ស្រាវជ្រាវថ្នាក់ឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា បានបន្តដើបខ្លួនចេញមកអំពីផលប៉ះពាល់ដែលធ្វើឱ្យបាត់បង់នូវសមត្ថភាពដោយសារតែសង្គ្រាមស៊ីវិល សហគមន៍ស្រាវជ្រាវមានកម្រិតទាបដោយសារតែការខ្វះខាតការទទួលស្គាល់នៅមូលធនមនុស្សសម្រាប់គោលដៅជាតិ និងគោលដៅបម្រើសាធារណៈ កម្រិតធំមួយនៃអន្តរកម្មដែលបានកើតឡើងពាសពេញតួអង្គស្រាវជ្រាវសំខាន់ៗ និងបណ្តាញដ៏ស្មុគស្មាញ និងសម្រាប់ចែកចាយនូវព័ត៌មានអំពីការចូលរួមពាក់ព័ន្ធ ប៉ុន្តែវាមិនទាន់បានកែលម្អឱ្យបានជាចំណាត់ណាមួយអំពីគុណភាពជាទូទៅនៃរបត់សហគមន៍ស្រាវជ្រាវ ឬដើម្បីឱ្យបានត្រូវតាមតម្រូវការនៃការស្វែងរកការងារធ្វើនៅឡើយទេ។ នៅក្នុងផ្អែកទី១ តាមការពិនិត្យឯកសារដែល

មានស្រាប់នេះ យើងបានរកឃើញ ហើយយើងបានស្ទះស្វែងនូវការប៉ាន់ប្រមាណទូលំទូលាយមួយអំពីរចនាសម្ព័ន្ធនៃការចូលរួមចំណែកវិធីនៃការចូលរួមពាក់ព័ន្ធបញ្ហាប្រឈមមិនចេះដាច់ ដែលអង្គការសង្គមស៊ីវិលបានជួបប្រទះ។ នៅក្នុងផ្នែកនេះ យើងងាកទៅផ្តោតលើភាពជាក់លាក់ទៅលើប្រព័ន្ធអប់រំឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា និងមូលដ្ឋានស្ថាប័ន និងបទបញ្ញត្តិសម្រាប់ការកសាងសមត្ថភាពតាមរយៈគ្រឹះស្ថានឧត្តមសិក្សា។

## ប្រវត្តិនៃការអភិវឌ្ឍឧត្តមសិក្សាក្នុងប្រទេសកម្ពុជា

រឿងរ៉ាវពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍប្រព័ន្ធអប់រំច្រើនចាប់ផ្តើមជាមួយនឹងការស្តារឡើងវិញនូវសន្តិភាពនៅដើមទសវត្សរ៍ឆ្នាំ១៩៩០និងការធ្វើឱ្យមានស្ថិរភាពនយោបាយដែលជាចុងក្រោយនៅឆ្នាំ ១៩៩៧ ការបំផ្លាញប្រព័ន្ធអប់រំក៏ដូចជាសមត្ថភាពស្រាវជ្រាវណាមួយបានកើតឡើងនៅពេលដែលមានការជម្រុះចោលនូវវណ្ណៈមធ្យមគម្រប់ខួបដោយរាប់បញ្ចូលទាំងអ្នកដែលមានការអប់រំខ្ពស់ផងដែរ។ ការបំផ្លាញទាំងស្រុងនូវប្រព័ន្ធអប់រំ ដោយក្នុងនោះមានទាំងធនធានមនុស្សរបស់ប្រទេស ការជម្រុះចោលនូវការរីកចម្រើននៃការអភិវឌ្ឍប្រព័ន្ធអប់រំទំនើបមួយ ដែលមានការសម្របសម្រួលជាមួយនឹងយុទ្ធនាការអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព Rany,Bzain និងJamil បានធ្វើការសន្និដ្ឋានថា៖ ″សរុបសេចក្តីមក ភាពបរាជ័យនៃមនោគមវិជ្ជាកម្មុយនីស្តជ្រុលនិយមរបស់កម្ពុជាប្រជាធិតេយ្យ និងគោលនយោបាយអប់រំរបស់ពួកគេបាននាំឱ្យប្រទេសកម្ពុជាវិលត្រឡប់ទៅឆ្នាំ០ (សូន្យ) ដោយសារតែការបំផ្លាញប្រព័ន្ធការអប់រំទាំងមូល″ ។

ការស្នើគោលនយោបាយប្រព័ន្ធអប់រំមួយបានចេញមកតាមរយៈការគាំទ្ររបស់សូវៀតបានបង្ហាញនៅក្នុងមហាវិទ្យាល័យវេជ្ជសាស្ត្រនិងឱសថសាស្ត្រ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧៩។ វាជាការលំបាកនៅក្នុងការប៉ាន់ប្រមាណអំពីការីកចម្រើនក្នុងការស្រាវជ្រាវទាំងនៅក្នុងផ្នែកវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រធម្មជាតិនៅក្នុងអំឡុងពេលនេះ។ ការផ្តោតត្រូវបានផ្តល់ឱ្យដោយក្របខ័ណ្ឌស្ថាប័នដែលត្រូវបានបង្កើតឡើងនោះ ហាក់ដូចជាមានការផ្តោតច្រើនទៅលើវិស័យបច្ចេកទេសជាមួយនឹងការអនុវត្តនៅក្នុងសង្គមដែលបានបង្ហាញតាមរយៈសាកលវិទ្យាល័យដែលត្រូវបានបង្កើតឡើងនោះ នៅលើជ្រុងម្ខាងនោះយើងឃើញថាការរីកចម្រើនផ្នែកបច្ចេកទេស និងការអភិវឌ្ឍបច្ចេកទេសអភិវឌ្ឍសមត្ថភាពផ្នែកបច្ចេកទេសហាក់ដូចជាមានកម្រិតទាបខ្លាំង ដោយសារតែការប៉ាន់ប្រមាណដ៏ទន់ខ្សោយមួយដែលសហគមន៍ស្រាវជ្រាវនិងសមត្ថភាពសេវាស៊ីវិលបានទទួលនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងបន្ទាប់ពីនោះមកទៀត។ នៅលើជ្រុងម្ខាងទៀត ក៏យើងសង្កេតឃើញថាដោយសារតែបើតាមសមត្ថភាពធនធានមនុស្សដែលត្រូវបានបង្កើតឡើងដោយគោលនយោបាយខ្មែរក្រហម មិនមានឃើញការចម្រើននៅក្នុងវិស័យអប់រំ ការកសាងសមត្ថភាពស្រាវជ្រាវ ឬក៏ការធ្វើគោលនយោបាយដោយផ្អែកទៅលើភ័ស្តុតាងដែលត្រូវបានគេពិចារណាថាជាសមិទ្ធផល ដែលគួរឱ្យកត់

សម្គាល់មួយនោះទេ។ ជាមួយនឹងកំណើនសេដ្ឋកិច្ចការពង្រីកគ្រឹះស្ថានឧត្តមសិក្សាបានកើតឡើងនៅក្នុងអត្រាមានលំនឹងមួយ ដែលរួមជាមួយនឹងការចុះឈ្មោះចូលរៀនដែលអនុញ្ញាតឱ្យយើងរំពឹងថាមាននិន្នាការជាក់លាក់មួយចំនួនក្នុងការបន្តជាមួយនឹងកំណើនសេដ្ឋកិច្ចនោះ។ ក៏ប៉ុន្តែបញ្ហាសំខាន់ៗមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ តាមរយៈកំណើនដែលមានពីមុនមក ហើយភាពមិនល្អប្រសើរនៃការសម្របសម្រួលរវាងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធព្រមទាំងភាពខុសគ្នារវាងទីក្រុង និងតំបន់ដែលនៅតាមខេត្ត។

ការស្រាវជ្រាវថ្មីៗនេះបានបង្ហាញអំពីនិន្នាការនៃទំនោរដែលគ្រឹះស្ថានឧត្តមសិក្សាមានការកើនឡើងពីឆ្នាំ១៩៨០ ដល់ឆ្នាំ២០០១៤ តាមទិន្នន័យនេះចំនួនគ្រឹះស្ថានឧត្តមសិក្សាត្រូវបានគេវាស់វែង៖

| ឆ្នាំ<br>Year | ចំនួនឧត្តមសិក្សាថ្នាក់រដ្ឋ<br>Number public HEIs | ចំនួនឧត្តមសិក្សាថ្នាក់ឯកជន<br>Number private HEIs |
|---|---|---|
| 1980 | 2 Public ថ្នាក់រដ្ឋ | 0 Private ថ្នាក់ឯកជន |
| 1990 | 8 Public ថ្នាក់រដ្ឋ | 0 Private ថ្នាក់ឯកជន |
| 1997 | 8 Public ថ្នាក់រដ្ឋ | 1 Private ថ្នាក់ឯកជន |
| 2000 | 8 Public ថ្នាក់រដ្ឋ | 6 Private ថ្នាក់ឯកជន |
| 2005 | 13 Public ថ្នាក់រដ្ឋ | 32 Private ថ្នាក់ឯកជន |
| 2011 | 38 Public ថ្នាក់រដ្ឋ | 59 Private ថ្នាក់ឯកជន |
| 2014 | 39 Public ថ្នាក់រដ្ឋ | 66 Private ថ្នាក់ឯកជន |

ការផ្លាស់ប្តូរដ៏សំខាន់មួយបានកើតឡើងនៅក្នុងឆ្នាំ១៩៩៧ នៅពេលដែលស្ថានប័នឯកជនត្រូវបានគេអនុញ្ញាត ហើយប្រព័ន្ធបែបបង់ថ្លៃសិក្សាត្រូវបានគេអនុញ្ញាត ឱ្យសាកលវិទ្យាល័យរដ្ឋមានមហាវិទ្យាល័យផ្នែកជំនួញគ្រប់គ្រង មហាវិទ្យាល័យច្បាប់ និងសេដ្ឋកិច្ចដែលបានអនុម័តចាប់យកគោលនយោបាយនេះតាំងពីដើមដំបូងទៅ។ នេះអាចចាត់ទុកថាជាឯករាជភាពដែលបានកើតឡើងជាបន្តបន្ទាប់នៅពេលដែលស្ថាប័នទាំងអស់នេះត្រូវបានផ្ទេរទៅជាសាកលវិទ្យាល័យជាតិគ្រប់គ្រងដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ហើយសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ

សេដ្ឋកិច្ច ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៣ ប្រការនេះបានចេញដំណើរជាការរីកចម្រើនដោយឆាប់រហ័សមួយនៃឧត្តមសិក្សា ដោយមានការពង្រីកនៃចំនួនស្ថាប័នឯកជនជាច្រើនលើសពស្ថាប័នសាធារណៈ។ ទិដ្ឋភាពស្ថាប័នបានផ្លាស់ប្តូរពីគ្រឹះស្ថានឧត្តមសិក្សាចំនួន៩ក្នុងឆ្នាំ១៩៩៧ ដែលមានសាកលវិទ្យាល័យឯកជនមួយបានកើនឡើងទៅចំនួនគ្រឹះស្ថានឧត្តមសិក្សា៤៥ ក្នុងឆ្នាំ២០០៥ និងមានសាកលវិទ្យាល័យឯកជនចំនួន៣២និងបានកើនទៅដល់១០៥ ក្នុងឆ្នាំ២០១៤ ដែលមានសាកលវិទ្យាល័យឯកជន៦៦ ប្រភពមួយផ្សេងទៀតបានលើកឡើងថា ក្នុងឆ្នាំ២០១១ មានឧត្តមសិក្សាចំនួន៩៧ដោយមានឯកជនចំនួន៥៩ចំណុច ដែលគួរឱ្យកត់សម្គាល់គឺថាភាគរយនៃគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ដែលជាឧត្តមសិក្សាឯកជនបានថយចុះ ពី៧១.១% ក្នុងឆ្នាំ២០០៥ ទៅ៦២.៨% នៅក្នុងឆ្នាំ២០១៤ នេះមានន័យថាសម្រាប់ទសវត្សរ៍ចុងក្រោយនេះកំណើន គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនបានកើតឡើងនៅក្នុងអត្រាមួយស្រដៀងគ្នា។

ការផ្លាស់ប្តូរនៅក្នុងឧត្តមសិក្សានៅក្នុងពីរទសវត្សរ៍ចុងក្រោយនេះអាចត្រូវបានគេពិនិត្យមើលទាក់ទងជាមួយនឹងការកសាងឡើងវិញ និងការកសាងជាតិតាមរយៈកំណើនមួយដែលមានស្ថិរភាពនិងសមត្ថភាពរបស់រដ្ឋដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវបានធ្វើការអប់រំក្នុងទ្រង់ទ្រាយធំ។ ការទទួលបានការអប់រំក្នុងទ្រង់ទ្រាយធំនេះត្រូវបានបង្ហាញតាមរយៈការផ្លាស់ប្តូរនៃអត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតឧត្តមសិក្សាគឺពី១% នៅដើមសតវត្សរ៍ដើមឆ្នាំ១៩៩០ ទៅប្រហែល១៦% ក្នុងឆ្នាំ២០១៤។ ការចុះឈ្មោះចូលរៀនសរុបស្ថិតនៅកម្រិតសិស្សសរុប ១០.០០០នាក់ ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧ ក៏ប៉ុន្តែចំនួននេះបានកើនឡើងរហូតទៅដល់ ៣០.០០០នាក់ត្រឹមឆ្នាំ២០០៥។ នៅក្នុងចន្លោះឆ្នាំ២០០៥ និងឆ្នាំ២០១២ ការចុះឈ្មោះសរុបបានកើនឡើងយ៉ាងឆាប់រហ័សដោយក្នុងនោះមានការចុះឈ្មោះសិស្សសរុប ២៥៥.៧៩១នាក់ នៅគ្រឹះស្ថានឧត្តមសិក្សាសម្រាប់ឆ្នាំសិក្សា២០១២២០១៣។ ចំនួនសិស្សដែលបានចុះឈ្មោះចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សារដ្ឋគឺមាន ១០៥.៤៥៥នាក (ស្ត្រី៤០.៣៤៨នាក់)។ ដូចនេះសិស្សដែលនៅសល់ចំនួន ១៥០.៣៣៦នាក់ បានចុះឈ្មោះនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាឯកជន ប៉ុន្តែក្នុងចំនួននោះមានតែ ១.០៦៣នាក់ តែប៉ុណ្ណោះដែលបន្តការសិក្សារហូតដល់ថ្នាក់បណ្ឌិត ចំណុចសំខាន់ជាពិសេសសម្រាប់ការជះឥទ្ធិពលជាក់លាក់ណាមួយទៅលើគ្រឹះស្ថានឧត្តមសិក្សា គឺនៅមានកម្រិតទាបនៅឡើយ ទាក់ទងជាមួយធនធានមនុស្សជាទូទៅនៅក្នុងប្រព័ន្ធ មធ្យមសិក្សាសាធារណៈ។ ភាគរយនៃគ្រូនៅបឋមសិក្សា និងមធ្យមសិក្សាដែលមិនមានសញ្ញាបត្រនៅក្នុងឆ្នាំ២០១៣ ២០១៤នោះគឺមានកម្រិត ៤៨,១៨%។ ភាគរយនៃគ្រូអនុវិទ្យាល័យដែលគ្មាន សញ្ញាបត្រវិទ្យាល័យគឺមានកម្រិត២១,១៥% គ្រឹះនៃការស្រាវជ្រាវត្រូវតែកើតឡើងនៅក្នុងការដោះស្រាយទៅលើបញ្ហាប្រឈមទូទាំង ប្រទេស ដើម្បីផ្តល់នូវជំនាញស្រាវជ្រាវវិធីសាស្ត្រស្រាវជ្រាវព្រមទាំងគុណតម្លៃនៃការប្រើប្រាស់ ការស្រាវជ្រាវនេះទៅដល់កម្រិតសិក្សាថ្នាក់ទាបដើម្បីឱ្យការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ អាចចាប់ផ្តើមតាំងពីវ័យដំបូងទៅ។

តែទោះជាយ៉ាងណាក៏ដោយ សម្រាប់ការផ្ទេរការបង្រៀនទាំងអស់នេះនិងដើម្បីឱ្យមាន ការអភិវឌ្ឍជំនាញប្រាស្រ័យទាក់ទង គ្រូទាំងឡាយត្រូវតែមានការយល់ដឹងជាសារវតារដែលរឹងមាំមួយចំនួនទៅលើសម្ភារៈដែលមានកម្រិតខ្ពស់។ ថ្មីៗនេះ រឿងនេះមិនទាន់បានកើតឡើងនៅឡើយទេនៅក្នុងវិស័យអប់រំសាធារណៈប្រទេសកម្ពុជា។

រដ្ឋាភិបាលកម្ពុជាបានផ្តល់នូវស្ថិតិដែលទាក់ទងជាមួយ និងសិស្សនៅស្ថាប័នកម្រិតឧត្តមសិក្សាតាមរយៈអគ្គនាយកដ្ឋានឧត្តមសិក្សា។ ព័ត៌មានទាំងនេះបង្ហាញអំពីអតុល្យភាព យេនឌ័រ ដ៏ខ្លាំងក្លាមួយនៅគ្រប់កម្រិតទាំងអស់នេះតាមរយៈនៃការពិនិត្យមើលបន្តិចទៅលើភាពខុសគ្នារវាងចំនួននៃការចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់ការសិក្សាជាក់ស្តែង និងកម្រិតទាបបំផុតនៃនិស្សិតថ្នាក់បណ្ឌិត។ ទិន្នន័យនេះត្រូវបានគេសង្ខេបនៅក្នុងតារាងដូចខាងក្រោម។

| កម្រិត | ចំនួននិស្សិតក្នុងឆ្នាំ ២០១២-២០១៣ | | | ចំនួននិស្សិតបញ្ចប់ការសិក្សាក្នុងឆ្នាំ ២០១១-២០១២ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | % និស្សិតស្រី | សរុប | ស្រី | % និស្សិតស្រី |
| *បរិញ្ញាបត្ររង* | ២៣.៦៧៨ | ៧.៩៤៤ | ៣៣,៥៥% | ១០.៣៩៥ | ៣.៨៨៧ | ៣៧,៣៩% |
| *បរិញ្ញាបត្រ* | ២១៦.០៥៣ | ៨៦.២៣៥ | ៣៩,៩១% | ៣៤.៩៧៨ | ១៤.៤៣២ | ៤១,២៦% |
| *អនុបណ្ឌិត* | ១៤.៩៩៧ | ២.៨៨៤ | ១៩,២៣% | ១.២៩៦ | ៣៦៧ | ២៨,៣២% |
| *បណ្ឌិត* | ១.០៦៣ | ៥៧ | ៥,៣៦% | ៣៤ | ១ | ២,៩៤% |
| *សរុប* | ២៥៥.៧៩១ | ៩៧.១២០ | ៣៧,៩៧% | ៤៦.៧០៣ | ១៨.៦៨៧ | ៤០,០១% |

តារាងទី១ ចំនួននិស្សិតចុះឈ្មោះក្នុងឆ្នាំ ២០១២-២០១៣ និងចំនួននិស្សិតបញ្ចប់ការសិក្សាក្នុងឆ្នាំ ២០១១-២០១២ (ប្រភព៖ ស្ថិតិពីនាយកដ្ឋានឧត្តមសិក្សា ២០១៤)

## និន្នាការ និងសមាសធាតុស្ថាប័ននាពេលបច្ចុប្បន្ន

និន្នាការពីរអាចមានសក្ដានុពលក្នុងការជះឥទ្ធិពលខ្លាំងទៅលើទិន្នភាពនេះ។ ទាំងនេះរួមមានការផ្ទេរក្រេឌីតឬការផ្លាស់ប្ដូរប្រព័ន្ធមួយដែលត្រូវបានគេដាក់ឱ្យអនុវត្តហើយ ហើយការកើតឡើងជាបន្ទាប់ៗនៅក្នុងការរៀនតាមប្រព័ន្ធអ៊ីនធើណិត។ ការផ្លាស់ប្ដូរទាំងពីនេះធ្វើឱ្យវិធីអប់រំឆ្ពោះទៅកាន់ការទទួលបានសញ្ញាបត្រកម្រិតឧត្តមសិក្សាកាន់តែមានភាពបត់បែននឹងអាចឱ្យសិស្សងាយរកបាន ដែលវាបានប្រឈមជាមួយនឹងពេលវេលាដ៏សំខាន់ និងមានការលំបាកខាងផ្នែកធនធានដែលកើតចេញមកអំពីភាពចាំបាច់ត្រូវរកការងារធ្វើ ប៉ុន្តែ ឥទ្ធិពលទាំងនេះមិនទាន់ត្រូវបានគេធ្វើការចងក្រងទុកជាឯកសារនៅក្នុងវិស័យឧត្តមសិក្សា ធនធានមនុស្សសម្រាប់អង្គការសង្គមស៊ីវិល ឬក៏កម្រិតនៃការកសាងសមត្ថភាពស្រាវជ្រាវទូទៅនៅឡើយនោះទេ។ ប្រព័ន្ធនៃការផ្ទេរក្រេឌីតដែលកំពុងតែអនុវត្តគឺកើតចេញមកពីសេចក្ដីសម្រេចស្ដីអំពីប្រព័ន្ធនៃការផ្ទេរក្រេឌីតនៅក្នុងឆ្នាំ២០០៤។

ការប្រើប្រាស់បច្ចេកវិទ្យាសិក្សាតាមប្រព័ន្ធអ៊ីនធើណិតសម្រាប់ការទទួលបានសញ្ញាបត្រថ្នាក់ឧត្តមសិក្សានេះគឺនៅមានកម្រិតតិចតួចនៅឡើយនៅក្នុងប្រទេសកម្ពុជា រហូតមកដល់ពេលបច្ចុប្បន្ននេះ ប៉ុន្តែការស្រាវជ្រាវថ្មីៗនេះបានបង្ហាញនូវសក្ដានុពលសម្រាប់ឱ្យមានការណែនាំប្រកបឱ្យមានការជោគជ័យមួយ លើសពីនេះទៅទៀត កត្តាសេដ្ឋកិច្ចដែលនៅពីក្រោយជោគជ័យវិធីសាស្ត្រនេះនៅក្នុងប្រទេសផ្សេងៗទៀតគឺកំពុងមានវត្តមាននៅក្នុងតាមលក្ខខណ្ឌរបស់ប្រទេសកម្ពុជា ដូចជាការប្រកួតប្រជែងខ្ពស់ក្នុងចំណោមអ្នកផ្ដល់ការអប់រំដើម្បីទទួលបានចំណែកទីផ្សារនៅក្នុងលក្ខខណ្ឌ ដែលថ្លៃសិក្សាមានកម្រិតទាបរួចហើយ ប្រៀបធៀបទៅនឹងកម្រិតថ្លៃសិក្សាជាមធ្យមនៅក្នុងរដ្ឋផ្សេងៗទៀត។

ការប្រើប្រាស់បច្ចេកវិទ្យាថ្មីដែលសម្របទៅតាមការវិវត្តនោះ អាចប្រឈមជាមួយនឹងបញ្ហាជាច្រើនហើយបញ្ហាប្រឈមមួយចំនួនមានការពាក់ព័ន្ធជាពិសេសទៅនឹងការបង្កើតវប្បធម៌នៃការស្រាវជ្រាវដូចជាបច្ចេកទេសស្រាវជ្រាវ វិធីសាស្ត្របែបបរិមាណវិស័យ និងការវិភាគបែបបរិមាណវិស័យជំនឿក្នុងការប្រើប្រាស់ស្រាវជ្រាវ និងការបង្កើតផលស្ម័យគុណសម្រាប់ការកសាងសមត្ថភាពលើសពីកម្មវិធីបណ្ដុះបណ្ដាលនិងសិក្ខាសាលាជាក់លាក់មួយចំនួន ឯកសារដែលមានស្រាប់ដែលត្រូវបានពិនិត្យឡើងវិញនេះ មិនមានការចែងអំពីគោលនយោបាយ ឬក៏សកម្មភាពជាក់លាក់នៅកម្រិតក្រសួងដើម្បីប្រើប្រាស់ទាញយកប្រយោជន៍ពីការរៀនតាមប្រព័ន្ធអ៊ីនធើណិតនោះទេ។ មានការកត់ត្រាច្រើនទាក់ទងជាមួយនឹងនិន្នាការជាទូទៅក្នុងការប្រើប្រាស់អ៊ីនធើណិត និងទទួលបានអ៊ីនធើណិតប្រើប្រាស់។ វាជាការសំខាន់ណាស់ដែលត្រូវបានគេប្រើប្រាស់ការសិក្សានេះដើម្បីបង្កើតឱកាស និងដើម្បីចូលរួមពាក់ព័ន្ធក្នុងកិច្ចសហប្រតិបត្តិការដែលបង្កើតនូវការអភិវឌ្ឍជំនាញតាមរយៈការផ្ទេរជំនាញការរៀនតាមប្រព័ន្ធអ៊ីនធើណិតអាចផ្ដល់នូវឱកាសមួយចំនួនឧទាហរណ៍ដូចជាការអនុញ្ញាតឱ្យមាន

កាលវិភាគសិក្សាឱ្យកាន់តែមានលក្ខណៈបត់បែនសម្រាប់និស្សិតដែលធ្វើការផង ហើយក៏ដូចជាការបង្កើននូវសមត្ថភាពរៀបចំរបស់សិស្សតាមរយៈការគ្រប់គ្រងហើយនឹងតាមរយៈការបង្ហាញនូវវគ្គសិក្សា និងវេទិកានិស្សិតសម្រាប់ការពិភាក្សាជាបន្តបន្ទាប់ដើម្បីបង្កើនឱកាសរបស់សិស្សក្នុងការចូលរួម និងការផ្តល់មតិយោបល់ត្រឡប់ ចំណុចអវិជ្ជមានគឺថាអាចមានហានិភ័យនៅក្នុងការដែលសិស្សត្រូវឃ្លាតចេញពីបទពិសោធន៍សង្គមដ៏មានសារៈសំខាន់ដែលការសិក្សា គឺជាដំណើរការមួយនៃការបង្កើនព័ត៌មាន ការបង្កើនធ្វើបានព័ត៌មានផង ហើយវាក៏ជាការដោះស្រាយបញ្ហារួមគ្នាផងនិង ជាការអភិវឌ្ឍប្រកបដោយភាពសកម្មចំពោះ"ខ្លួនឯង"តាមរយៈសក្តានុពលបុគ្គលផ្ទាល់ខ្លួនមនុស្សម្នាក់ៗសម្រាប់ធ្វើឱ្យមានការរីកចម្រើនក៏ដូចជាការទទួលខុសត្រូវសហគមន៍មួយ។ កត្តាខាងក្រៅដែលមានភាពកាន់តែសំខាន់និងអាចវាស់វែងបាននោះគឺការពង្រឹងសិទ្ធិអំណាច ដែលកំពុងតែមាននិន្នាការឆ្ពោះទៅរកការសម្រេចចិត្តដែលមានលក្ខណៈមជ្ឈការ និងការគ្រប់គ្រងទៅលើការធ្វើគោលនយោបាយ។ ដោយសារតែទីផ្សារការងារស្វែងរកសមត្ថភាពបច្ចេកទេសដែលមានការកែលម្អ និងការអភិវឌ្ឍសមត្ថភាព ត្រូវបានគេចាត់ទុកជា "ការបណ្តុះបណ្តាលវិជ្ជាជីវៈ" តាមបច្ចេកវិទ្យានៃការរៀនតាមប្រព័ន្ធអ៊ីនធើណិតដែលជួយក្នុងការអភិវឌ្ឍកង្វះខាតសមត្ថភាពនៃបច្ចេកទេសដែល "ត្រូវការ" ដោយផ្អែកផ្គត់ផ្គង់នៅក្នុងសេដ្ឋកិច្ច ។

ព័ត៌មានដែលទាក់ទងជាមួយសមាជិកនៃធនធានមនុស្សនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាអាចរកបាននៅក្នុងស្ថិតិទាក់ទងជាមួយនឹងគ្រូបង្រៀន។ សន្និបាតក្រសួងអប់រំយុវជន និងកីឡាបានរកឃើញថានៅក្នុងឆ្នាំ២០១៤ មានគ្រូចំនួន ១០.៨៤២នាក់ នៅគ្រឹះស្ថានឧត្តមសិក្សារួមបញ្ចូលទាំងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន និងគ្រូថ្នាក់ជាតិ និងគ្រូនៅកម្រិតជាតិ និងគ្រូថ្នាក់ក្រោមជាតិ។ ចំណុចសំខាន់ៗរួមមានភាគរយគ្រូដែលមានសញ្ញាបត្របណ្ឌិតមានចំនួនទាប។ គ្រូភាគច្រើនយ៉ាងហោចណាស់មានសញ្ញាបត្រអនុបណ្ឌិត ប៉ុន្តែប្រហែល ១ភាគ៣ នៃគ្រូកម្រិតបរិញ្ញាបត្រទាំងអស់មានសញ្ញាបត្រត្រឹមតែបញ្ញាបត្រតែប៉ុណ្ណោះ។ មានការគណនាមិនទាន់ត្រឹមត្រូវមួយអំពីរបៀបបែងចែកគ្រូរវាងគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិង ឯកជន ឬរវាងគ្រឹះស្ថានឧត្តមសិក្សានៅតាមតំបន់ទីក្រុងនិងជនបទ ស្ថាប័នសាធារណៈមានគ្រូមួយចំនួនជាគ្រូជាប់កិច្ចសន្យា និងគ្រូមួយចំនួនទៀតដែលជាមន្ត្រីរាជការនៅក្នុងរដ្ឋាភិបាល ខណៈដែលគ្រូនៅឧត្តមសិក្សាឯកជនដែលសិទ្ធិជាបុគ្គលិកកិច្ចសន្យាទាំងអស់។ ព័ត៌មានទាំងនេះមិនបានពិចារណាទៅលើភាពខុសប្លែកគ្នានៅក្នុងស្ថាប័នរដ្ឋទេ។ ស្ថិតិទាំងអស់នេះបានផ្តល់ព័ត៌មានអំពីភាពប្រទាញប្រទង់នៅក្នុងស្ថាប័នរដ្ឋ និងស្ថាប័នសាធារណៈ ឬក៏ផ្តល់ព័ត៌មានអំពីតុល្យភាពយេនឌ័រនៅក្នុងក្រុមថ្នាក់ជាតិនិងមិនមែនថ្នាក់ជាតិនោះទេ។

ការធ្វើផែនទីអំពីរចនាសម្ព័ន្ធអភិបាលកិច្ចដែលមានការជាប់ពាក់ព័ន្ធ និងការពង្រឹងសហគមន៍ស្រាវជ្រាវត្រូវពិចារណាទៅលើទិដ្ឋភាពច្បាប់ និងទិដ្ឋភាពស្ថាប័ននៃវិស័យអប់រំឧត្តមសិក្សាក្នុងប្រទេស

កម្ពុជា។ ការចាប់ផ្តើមជាមួយនឹងច្បាប់ ជាតិនិងច្បាប់អន្តរជាតិពាក់ព័ន្ធមួយចំនួនត្រូវតែធ្វើឡើង ដោយសារតែមានលក្ខណៈតម្រូវសម្រាប់បង្កើតបរិយាកាសស្រាវជ្រាវដែលមានសុខភាពល្អមួយ ដោយរួមបញ្ចូលទាំងការសង្កេតបែបត្រិះរិះពិចារណា និងការបោះពុម្ពផ្សាយនូវលទ្ធផលទាំងអស់នោះ។ មាត្រាទី៦៥បានចែងថារដ្ឋមានកាតព្វកិច្ចក្នុងការការពារ និងលើកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិតទាំងអស់។ មាត្រាទី៦៦នៃរដ្ឋធម្មនុញ្ញបានចែងថាប្រព័ន្ធអប់រំត្រូវធានានូវគោលការណ៍សេរីភាពក្នុងការអប់រំ លើសពីនេះទៅទៀតមាត្រា១៨ និងមាត្រា២៨ នៃច្បាប់ស្តីអំពីការអប់រំបានចែងថាការអប់រំត្រូវលើកកម្ពស់ការស្រាវជ្រាវបែបវិទ្យាសាស្ត្របច្ចេកទេសវប្បធម៌សង្គម ដើម្បីសម្រេចឱ្យទទួលបាននូវសមត្ថភាពចំណេះដឹងជំនាញសីលធម៌គំនិតច្នៃប្រឌិតបង្កើតថ្មី និងស្មារតីសហគ្រិនភាពឆ្ពោះទៅការអភិវឌ្ឍប្រទេស។ លើសពីនេះទៀត មាត្រា៣៥នៃច្បាប់ស្តីពីការអប់រំបានផ្តល់ឱ្យសិស្សនូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិដោយសេរីចំពោះទស្សនៈសិក្សារបស់ពួកគេ និងសិទ្ធិក្នុងការទទួលបានសេរីភាពក្នុងការរៀនសូត្រ ។ សេរីភាពនៃការសិក្សាស្រាវជ្រាវក៏ត្រូវបានការពារផងដែរតាមច្បាប់អន្តរជាតិ។មាត្រាទី២៦ នៃសេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស ការពារសិទ្ធិក្នុងការទទួលបានសេរីភាពផ្នែកសិក្សាស្រាវជ្រាវ និង អប់រំស្របពេលដែលមាត្រាទី១៣ នៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌បានចែងអំពីសិទ្ធិក្នុងការទទួលបានការអប់រំផងដែរ។ គណៈកម្មការសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ដែលឃ្លាំមើលទៅលើការអនុវត្តអនុសញ្ញានេះនៅក្នុងសេចក្តីអធិប្បាយទូទៅលេខ១៣បានចែងថា សិទ្ធិទទួលបានការអប់រំអាចត្រូវបានគេទទួលបាន លុះត្រាតែអមមកជាមួយសេរីភាពក្នុងការសិក្សាស្រាវជ្រាវរបស់បុគ្គលិកនិងរបស់និស្សិតផង។

តាមរយៈការផ្តល់សមត្ថកិច្ច និងអាណត្តិដោយរដ្ឋធម្មនុញ្ញឱ្យកម្ពុជានោះ អង្គាធរពាក់ព័ន្ធខ្ពស់បំផុតសម្រាប់វិស័យអប់រំ និងការស្រាវជ្រាវគឺរដ្ឋសភាតាមរយៈគណៈកម្មការរបស់រដ្ឋសភាពទី៧គឺគណៈកម្មការស្តីអំពីការអប់រំ យុវជន ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍។ ការទទួលខុសត្រូវរបស់គណៈកម្មការនេះរួមមានការធ្វើសំណើ ឬក៏ការផ្លាស់ប្តូរក្នុងច្បាប់ស្តីពីការអប់រំ ការស្នើសុំបញ្ជាក់ឱ្យច្បាស់ ឬក៏ព័ត៌មានបន្ថែមស្តីអំពីសេចក្តីព្រាងច្បាប់អប់រំ និងការគ្រប់គ្រងព័ត៌មានឱ្យបានត្រឹមត្រូវគ្រប់គ្រាន់ និងមានបច្ចុប្បន្នភាពគ្រប់គ្រាន់ទាក់ទងជាមួយនឹងវិស័យអប់រំ។ គណៈកម្មការនេះមិនមែនជាស្ថាប័នដែលមានសមត្ថកិច្ចទៅលើការគ្រប់គ្រងការអប់រំឧត្តមសិក្សាដោយខ្លួនឯងទេ។ ជាងនេះទៅទៀត ទោះបីជាវាមានសមត្ថកិច្ចផ្នែកច្បាប់នៅក្នុងការផ្តួចផ្តើមឱ្យមានការធ្វើច្បាប់ពាក់ព័ន្ធក៏ដោយ ក៏ក្នុងការអភិវឌ្ឍខ្លួនឯង តួនាទីមានកម្រិតតិចតួចណាស់ក្នុងការពិភាក្សា និងការអនុម័តនូវសេចក្តីព្រាងច្បាប់ដែលបានស្នើឡើងដូចដែលបានបង្ហាញនៅក្នុងករណីនៃច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧។ ប្រការនេះបានឆ្លុះបញ្ចាំងនូវភាពទន់ខ្សោយជាទូទៅនៃនីតិប្បញ្ញត្តិនៅក្នុងដំណើរការ

អភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជាដែលមិនមែនជាប្រភពសំខាន់នៃការតាក់តែង ហើយក៏មិនមែនជាអ្នកអនុវត្តច្បាប់នោះដែរ។

## ៤.ស្រាវជ្រាវតម្រិតម៉ាក្រូលើបរិស្ថានវិទ្យាសាស្ត្រសង្គម

ក្នុងផ្នែកនេះយើងដាក់ចេញនូវគោលនយោបាយស្រាវជ្រាវរបស់ស្ថាប័នមួយចំនួនទៅក្នុងការសិក្សារបស់យើង ហើយនឹងធ្វើការពិភាក្សាគ្នាអំពីកម្មវិធីស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សា។ យើងសួរសំណួរទាក់ទងនឹងវិសាលភាពរបស់គោលនយោបាយនៃការស្រាវជ្រាវ ដែលជំរុញឱ្យមានការអនុវត្តការស្រាវជ្រាវដោយការសម្លឹងមើលទៅលើវត្តមាន ឬអវត្តមាននៃការអនុវត្តការស្រាវជ្រាវក្នុងស្ថាប័ននិងគោលនយោបាយរបស់ពួកគេ។យើងនឹងចាប់ផ្តើមធ្វើការពិភាក្សាអំពីគោលនយោបាយជាផ្លូវការ ដែលយើងបានជួបប្រទះ។ យើងកត់សម្គាល់ឃើញថា មិនសូវមានគោលនយោបាយជាផ្លូវការប៉ុន្មានទេ ដោយសារតែហេតុផលនេះហើយបានជាយើងសម្រេចចិត្តដាក់បង្ហាញនូវផ្នែកនេះ ជាជាងយកទៅរៀបរាប់នៅក្នុងឧបសម្ព័ន្ធ។ យើងក៏បានពិភាក្សាផងដែរអំពីគំនិតផ្តួចផ្តើមដែលគួរឱ្យកត់សម្គាល់បំផុតនៅកម្រិតម៉ាក្រូមូលនិធិរបស់ធនាគារពិភពលោកលើគុណភាពកម្រិតខ្ពស់នៃការអប់រំ ក៏ដូចជាគម្រោងក្នុងការកែលម្អសមត្ថភាព (HEQCIP)។ វាជាការផ្តួចផ្តើមដ៏ធំមួយដែលគេបានផ្តល់មូលនិធិសម្រាប់អភិវឌ្ឍការស្រាវជ្រាវ និងការគាំទ្រដល់គម្រោងស្រាវជ្រាវបុគ្គល។

**ទិដ្ឋភាពទូទៅរបស់គោលនយោបាយស្រាវជ្រាវជាផ្លូវការ និងការតភ្ជាប់ជាមួយការអនុវត្ត**

បច្ចុប្បន្ននេះក្រសួងអប់រំមិនទាន់មានគោលនយោបាយលើការស្រាវជ្រាវនៅឡើយទេ ប៉ុន្តែពួកគេកំពុងធ្វើសេចក្តីព្រាងលើឯកសារនេះ។ ក្រសួងមានគោលនយោបាយដែលកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ជូនដល់អនុបណ្ឌិត និងបណ្ឌិត ហើយសាកលវិទ្យាល័យទាំងនោះនឹងអនុវត្តទៅតាមបទដ្ឋានផ្សេងៗ។ លក្ខណៈពិសេសមួយក្នុងគោលនយោបាយដែលគួរឱ្យកត់សម្គាល់នោះគឺអវត្តមាននៃការបញ្ចេញមតិរបស់ក្រសួង ឬអ្នកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា លើការវាយតម្លៃការអនុវត្តផ្ទាល់របស់ខ្លួន សកម្មភាពនៃការស្រាវជ្រាវ និងការទំនាក់ទំនងជាមួយទីភ្នាក់ងារផ្សេងៗ។ យើងបកស្រាយលើចំណុចចំនួនពីរ ដែលទាក់ទងជាមួយនឹងតម្រូវការរបស់អ្នកគ្រប់គ្រងក្នុងការសរសេរ សកម្មភាពរបស់ខ្លួនចូលទៅក្នុងគោលនយោបាយ និងការលើកឡើងនូវបញ្ហា បូករួមជាមួយនឹងការប្រើប្រាស់វិធីសាស្ត្រពីថ្នាក់ខ្ពស់ទៅដល់ថ្នាក់ក្រោម ដើម្បីធ្វើការផ្លាស់ប្តូរការលើកទឹកចិត្ត និងគំនិតផ្តួចផ្តើម។ យើងរកឃើញថា គោលនយោបាយមិនបានជំរុញឱ្យមានការអនុវត្តនោះទេ។ ពុំមានអង្គការសង្គមស៊ីវិលណាមួយដែលយើងបានសម្ភាស មានគោលនយោបាយនៃការស្រាវជ្រាវជាផ្លូវការនោះទេ ប៉ុន្តែពួកគេបានផលិតការស្រាវជ្រាវជាច្រើន ដែលបានបង្ហាញថាគោលនយោបាយកម្រិតម៉ាក្រូនេះគឺពិតជាមានសារៈសំខាន់ណាស់។ ឬមួយក៏វាជាការគ្រប់គ្រាន់ ដូចដែលយើងបានបង្ហាញក្នុងករណីរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលនៅតែទទួលរងភាពបរាជ័យក្នុងការអនុវត្តគោលនយោបាយនៅផ្នែកខ្លះ

បើទោះបីជាពួកគេមានគោលការណ៍ណែនាំស្រាវជ្រាវជាច្រើនក៏ដោយ(RUPP:D2)។ បញ្ហាដែលកើតមានឡើងក្នុងការអនុវត្តនេះ បានគូសបញ្ជាក់ពីគម្លាតរវាងគោលនយោបាយលម្អិតជាមួយភាពច្បាស់លាស់ក្នុងការអនុម័តចក្ខុវិស័យ និងភាពខ្វះខាតក្នុងការទទួលខុសត្រូវ (PUC:Dean1; PUC:VP)។ គោលនយោបាយអាចជាប់គាំងបាន ប៉ុន្តែការអនុវត្តដែលទន់ខ្សោយ មិនបានបង្ហាញសញ្ញាឱ្យយើងឃើញថាវាអន់នោះទេ។ សាកលវិទ្យាល័យមួយចំនួន បានទទួលយកគោលនយោបាយរបស់ខ្លួនដើម្បីឱ្យមានការអនុវត្តមួយដែលល្អប្រសើរជាងមុន។ ឧទាហរណ៍គោលនយោបាយរបស់សាកលវិទ្យាល័យបាត់ដំបងតម្រូវឱ្យធ្វើការស្រាវជ្រាវ សម្រាប់និស្សិតបញ្ចប់ការសិក្សាទាំងអស់ ដើម្បីឱ្យមានការផ្លាស់ប្តូរដោយអនុញ្ញាតឱ្យមានការជ្រើសរើសក្នុងការប្រឡងដែលអាចសម្រួលដល់និស្សិត និងសាស្ត្រាចារ្យដែរ (ចំណាំ៖ នេះការសម្រេចចិត្តដែលលើកឡើងដោយលោកស្រីសាកលវិទ្យាធិការ)។ សូម្បីតែនៅក្នុងស្ថាប័ន ដែលមិនមានគោលនយោបាយនៃការស្រាវជ្រាវជាផ្លូវការសម្រាប់សិស្សនិស្សិតនោះ ក៏យើងបានរកឃើញថា និស្សិតមានការចាប់អារម្មណ៍ និងចូលរួមក្នុងការស្រាវជ្រាវ ដែលបានបង្ហាញឱ្យឃើញថាគោលនយោបាយមិនបានជំរុញលើការស្រាវជ្រាវនោះទេ។

**គោលនយោបាយតាមវិស័យរាជរដ្ឋាភិបាល**
**ក្រសួងអប់រំ យុវជន និងកីឡា**

ក្រសួងអប់រំ យុវជន និងកីឡាមិនទាន់មានច្បាប់កំណត់ជាក់លាក់ណាមួយទាក់ទងនឹងការងារស្រាវជ្រាវទេ។ ក៏ប៉ុន្តែ មានការអនុម័តទៅលើផែនការមេសម្រាប់គោលនយោបាយស្រាវជ្រាវ ទៅលើព្រះរាជក្រឹត្យស្តីពីឋានៈសាស្ត្រាចារ្យ និងទៅលើការរៀបចំចក្ខុវិស័យសម្រាប់ឧត្តមសិក្សាឆ្នាំ២០៣០[1]។ បណ្ឌិតពីររូបមកពីស្ថាប័នផ្សេង ក៏ត្រូវបានចូលរួមក្នុងធ្វើសេចក្តីព្រាងច្បាប់នេះផងដែរ (PUC:VP) ។ ជាដំបូងការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាត្រូវបានគេផ្តល់អាទិភាពមុនគេក្នុងការអនុវត្តគ្រឹះស្ថានឧត្តមសិក្សានេះ ប៉ុន្តែក្នុងផែនការយុទ្ធសាស្ត្រនៃការអប់រំ ESP ២០១៤-២០១៨បានផ្តល់អាទិភាពថ្មីមួយទៀតទៅវិស័យតូចៗនៃការអប់រំកម្រិតខ្ពស់នេះ ដែលស្ថិតលើបន្ទាត់នៃការអភិវឌ្ឍធនធានមនុស្ស ហើយវាក៏ជាយុទ្ធសាស្ត្រមួយ ក្នុងចំណោមសសរស្តម្ភទាំងបួននៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងដំណាក់កាលទី៣នេះ។ ការប្រមើលមើលទិដ្ឋភាពរួមនៃយុទ្ធសាស្ត្រចតុកោណ គឺត្រូវបានបង្ហាញដូចខាងក្រោម។ គោលបំណងចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាគឺ ការអភិវឌ្ឍប្រាក់ចំណូលរបស់ប្រជាជន ដោយពង្រឹងគុណភាពលើវិស័យអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងការបង្កើតថ្មី។[2]

---

[1] ក្រសួងអប់រំយុវជន និងកីឡា "ផែនការយុទ្ធសាស្ត្រនៃការអប់រំ២០១៤-២០១៨, គោលនយោបាយចក្ខុវិស័យសម្រាប់ឧត្តមសិក្សាឆ្នាំ២០៣០" (ភ្នំពេញ ក្រសួងអប់រំយុវជន និងកីឡា ២០១៤)

[2] យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៣, សម្តេចតេជោ ហ៊ុន សែន, ២០១៣ ទំព័រទី៧




ជាតុផ្សំផ្សេងៗដែលពាក់ព័ន្ធនឹងការស្នើសុំឱ្យមានការធ្វើផែនការមេសម្រាប់គោលនយោបាយស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់សម្រាប់ការងារស្រាវជ្រាវ និងការផ្តល់យោបល់របស់យើង។ នៅត្រង់ចំណុចនេះ យើងនឹងបង្ហាញប្រាប់អ្នកចំពោះតែការស្រាវជ្រាវណាដែលទាក់ទងគ្នាប៉ុណ្ណោះ ដើម្បីងាយស្រួលក្នុងការចង្អុលបង្ហាញប្រាប់អ្នកនូវផ្នែកបន្ទាប់នៃរបាយការណ៍នេះ។

គោលបំណងចម្បងទីមួយរបស់ក្រសួងគឺពង្រឹងគុណភាពនៃការរៀនសូត្រ ការបង្រៀន និងប្រព័ន្ធនៃការស្រាវជ្រាវដើម្បីឱ្យសិស្សមានចំណេះដឹង ក៏ដូចជាជំនាញដែលជាតម្រូវការរបស់ទីផ្សារការងារ និងជាការអភិវឌ្ឍរបស់ប្រទេសជាតិផងដែរ ដើម្បីឈានទៅដល់គោលដៅដូចបានរៀបរាប់ខាងលើ យុទ្ធសាស្ត្រសំខាន់ៗ ៤ប្រភេទត្រូវបានគេរៀបចំឡើង៖

- ដើម្បីជួយលើកកម្ពស់ឱ្យមានការចូលរួម និងរៀបចំឱ្យមានការផ្លាស់ប្តូរ ដែលសហការជាមួយសាកលវិទ្យាល័យបរទេស ក្នុងគោលបំណងជួយបង្កើនសមត្ថភាពបុគ្គលិក ការសិក្សារៀនសូត្រ ការបង្រៀន និងការងារស្រាវជ្រាវផ្សេងៗ។
- ដើម្បីធានាឱ្យបានថា បុគ្គលិកដែលបម្រើការក្នុងវិស័យអប់រំ សិស្សនិស្សិត និងជាពិសេសអ្នកដែលបានរៀនចប់ បានចូលរួមចែករំលែកចំណេះដឹងដើម្បីឱ្យកិច្ចការស្រាវជ្រាវនេះមានភាពប្រសើរឡើង និង អភិវឌ្ឍប្រពៃណីវប្បធម៌នៅក្នុងប្រទេសកម្ពុជា ដើម្បីឱ្យមានការអភិវឌ្ឍទៅតាមសេចក្តីត្រូវការរបស់ប្រទេសជាតិ។
- ដើម្បីជួយលើកទឹកចិត្តឱ្យសមាជិកក្នុងគ្រឹះស្ថានឧត្តមសិក្សា និងសមាជិកក្នុងមហាវិទ្យាល័យគ្រប់រូបពង្រឹងការស្រាវជ្រាវរបស់ខ្លួនបន្ថែម ហើយផ្តល់សេវាកម្មប្រឹក្សាមួយដែលអាចមានភាពរឹងមាំ និងមានផលចំណេញសម្រាប់វប្បធម៌របស់កម្ពុជា ជាមួយនឹងការកំណត់ឱ្យបាននូវជំនាញដែលប្រទេសជាតិត្រូវការ និង ការអភិវឌ្ឍជាចម្បង។
- ដើម្បីធ្វើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់បុគ្គលិក និងផែនការអភិវឌ្ឍន៍ការងារដែលជំរុញឱ្យមានការរៀនសូត្រ ការបង្រៀន ការស្រាវជ្រាវ និងការគ្រប់គ្រងយ៉ាងទូលំទូលាយ។

រចនាសម្ព័ន្ធនៃគម្រោងដែលបានធ្វើឡើងនេះ គឺក្នុងគោលបំណងជួយសម្រួលដល់កិច្ចចាប់ផ្តើមការងារស្រាវជ្រាវដែលដឹកនាំដោយគ្រឹះស្ថានឧត្តមសិក្សា។ គេក៏រំពឹងទុកទៀតដែលថា វាពិតជាជួយសម្រួលដល់សកម្មភាពទាំងឡាយណាដែលទាក់ទងនឹងការងារស្រាវជ្រាវនេះ ដូចជា៖ " ក. ធ្វើឱ្យគុណភាពនៃការបង្រៀន និងការរៀនសូត្រមានភាពរីកចម្រើន ខ. សង្កត់ធ្ងន់ទៅលើមុខវិជ្ជាសំខាន់ៗ គ. ដោះស្រាយលើបញ្ហាផ្សេងៗដែលទាក់ទងនឹងការអភិវឌ្ឍនេះ ឃ. ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច "។ ការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ ក៏ត្រូវបានចង្អុលបង្ហាញដោយផ្ទាល់ពីគ្រឹះស្ថានឧត្តមសិក្សា ដែលសង្កត់ធ្ងន់ទៅលើ " គន្លឹះនៃការធ្វើអន្តរាគមន៍របៀបថ្មីមួយ " ហើយបន្ថែមជាមួយនឹង " ការប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលប្រកបដោយប្រសិទ្ធភាព "។ ការបង្កើតថ្មីនេះរួមមាន៖ "ការពង្រឹងប្រព័ន្ធស្វ័យភាពរបស់គ្រឹះស្ថានឧត្តមសិក្សា គណនេយ្យភាព និងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាថា ធនធានដែលផ្តល់ឱ្យក្នុងកម្មវិធីអប់រំឧត្តមសិក្សានេះគឺ សម្រាប់ពង្រឹងគុណភាពការស្រាវជ្រាវ សមត្ថភាពនៃការច្នៃប្រឌិត និងរាល់សកម្មភាពទាំងឡាយណាដែលមានឥទ្ធិពលទៅលើសមត្ថភាពនិស្សិត ដែលបញ្ចប់ការសិក្សាដោយផ្ទាល់ ដើម្បីចូលរួមក្នុងទីផ្សារការងារ ហើយវាក៏ជាការបង្កើតធនធានហិរញ្ញវត្ថុសម្រាប់គ្រឹះស្ថានឧត្តមសិក្សាដែលបានមកពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា។ ការរកឃើញនូវសកម្មភាពស្រាវជ្រាវនិងការច្នៃប្រឌិតនេះប្រាកដជារួមចំណែកលើកស្ទួយដល់កំណើនសេដ្ឋកិច្ច។ ការកសាងសមត្ថភាពរបស់ឧត្តមសិក្សា ដើម្បីគ្រប់គ្រងធនធានហិរញ្ញវត្ថុដែលបានមកពីប្រាក់ចំណូលសាធារណៈពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល "។

គោលបំណងយុទ្ធសាស្ត្រ និងរចនាសម្ព័ន្ធសំខាន់ៗដែលបានរៀបរាប់ឡើងខាងលើនេះ គឺគេមិនទាន់បានធ្វើការពិភាក្សាពីតួនាទីរបស់ក្រសួងនៅឡើយទេ។ មន្ត្រីមកពីនាយកដ្ឋានឧត្តមសិក្សារបស់ក្រសួងអប់រំមួយរូបបាននិយាយថា នាយកដ្ឋានរបស់លោកជំរុញឱ្យការស្រាវជ្រាវដើរតួនាទីត្រឹមតែជាអ្នកសម្របសម្រួលខាងផ្នែកហិរញ្ញវត្ថុ ជាជាងការអនុវត្តការស្រាវជ្រាវដោយខ្លួនឯងផ្ទាល់ដោយបូករួមទាំង " ការបញ្ចេញលទ្ធផលនៃការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងគោលនយោបាយ " ( MoEYS1 ) ។ ការស្រាវជ្រាវរបស់យើងបានបង្ហាញថា ពួកគេទទួលយកតួនាទីនេះ ហើយក៏មានការឆ្លើយតបជាច្រើនដែលបានរាយការណ៍ថា ថវិការបស់ពួកគេបានមកពីក្រសួងអប់រំយុវជន និង កីឡា (PUC:PR; UBB:PR; RUPP:DR; MCU:DR; SVU:PR)។ ទោះជាយ៉ាងណាក៏ដោយ គោលបំណង និងគោលដៅរបស់ពួកគេ គឺចង់ឱ្យគ្រឹះស្ថានឧត្តមសិក្សាមានការទទួលខុសត្រូវ សម្រាប់ការអនុវត្តនេះ ហើយបើនិយាយពីតួនាទីរបស់ក្រសួងអប់រំវិញ គឺមិនទាន់មានភាពច្បាស់លាស់នោះទេ។ គួរឱ្យកត់សម្គាល់ផងដែលថា ការបាត់បង់នូវគោលនយោបាយគឺជាការអនុវត្តរបស់ក្រសួងមិនបានគ្រប់ជ្រុងជ្រោយ ឬក៏ជាការវាយតម្លៃដោយខ្លួនឯងទៅលើគោលនយោបាយនោះដោយប្រការណាមួយ។ លើសពីនេះទៅទៀត ការផ្តល់អនុសាសន៍ទាក់ទងនឹងថវិកានេះគឺផ្តោតសំខាន់ទៅលើការបង្កើននៃការចូលរួមចុះកិច្ចសន្យា ការប្រឹក្សាយោបល់ និងកិច្ចផ្តួចផ្តើមក្នុងការស្រាវជ្រាវ ដែលភាគច្រើនគម្រោងនៃការស្រាវជ្រាវរបស់មូលនិធិ GDN ក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន បានលើកឡើងថា វាជាការរាំងដែលអាចប៉ះពាល់ដល់ដំណើរការនៃការស្រាវជ្រាវនេះ។ លើសពីនេះទៅទៀត គោលដៅនៃការស្រាវជ្រាវនេះគឺត្រូវធ្វើយ៉ាងណាដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ប៉ុន្តែមិនមានការស៊ើបអង្កេតណាមួយធ្វើឡើងដើម្បីសម្រេចបានគោលដៅ ឬអាចដោះស្រាយបញ្ហាសង្គមណាមួយដែលត្រូវគ្នាជាមួយការផ្តួចផ្តើមទាំងពីរនេះទេ។

**ក្រសួងផែនការ**

ក្រសួងផែនការ គឺមិនមានគោលនយោបាយនៃការស្រាវជ្រាវជាផ្លូវការណាមួយនោះទេ ប៉ុន្តែក្រសួងបានបើកវគ្គបណ្តុះបណ្តាលដែលទាក់ទងនឹងការធ្វើផែនការនិងការធ្វើស្ថិតិជាមួយក្រសួងចំនួន ១០នៅខេត្តបាត់ដំបង និងខេត្តសៀមរាប ក្នុងរយៈពេល ៣ថ្ងៃជាប់គ្នា លើប្រធានបទចំនួន១២ រួមមាន (ការធ្វើផែនការ ការធ្វើស្ថិតិ ការប្រើប្រាស់ស្ថិតិ ការវាយតម្លៃលើទិន្នន័យ សូចនាករ វិធីប្រើប្រាស់ទិន្នន័យដោយប្រើកម្មវិធី SPSS វិធីប្រើប្រាស់ទិន្នន័យដែលបានមកពីជំណាក់កាលដំបូង ហើយធ្វើការវិភាគ (MoP1)។ ការឆ្លើយតបរបស់ក្រសួងផែនការ បានបង្ហាញឱ្យដឹងថា ភាពទន់ខ្សោយនៃគោលនយោបាយនេះ វាកើតមានតាមរយៈការយល់ច្រឡំ និងការខ្វែងគំនិតគ្នាអំពីគោលនយោបាយនិងសកម្មភាពស្រាវជ្រាវក្នុងចំណោមមន្ត្រីមកពីស្ថាប័នដូចគ្នាមួយ។ មន្ត្រីម្នាក់បានរាយការណ៍ថា មិនចាំបាច់មានការបណ្តុះបណ្តាលទៅលើសកម្មភាពនៃការស្រាវជ្រាវនោះទេ ហើយពួកគេក៏មិនត្រូវការអ្នកដែលរៀនចប់ថ្នាក់បណ្ឌិត ដែលមានជំនាញខាងការស្រាវជ្រាវនេះដែរ (នេះគឺសំដៅទៅលើការជួល

អ្នកពិគ្រោះយោបល់មកពីខាងក្រៅមកធ្វើការ)។ លោកបានកត់សម្គាល់ឃើញថា ក្រសួងបានគាំទ្រឱ្យមានការកសាងសមត្ថភាពក្នុងការងារនេះពោលគឺ " ការផ្តល់ឱកាសសម្រាប់ការស្រាវជ្រាវ " (MoP1)។ មន្ត្រីមួយរូបផ្សេងទៀតបានឱ្យដឹងដែរថា ការបណ្តុះបណ្តាលគឺ " ជាសមាសភាគនៃដំណើរការចុះទៅកន្លែងស្រាវជ្រាវដោយផ្ទាល់ " (ភាគច្រើនការប្រមូលទិន្នន័យជាលក្ខណៈបរិមាណ) (MoP2)។ វគ្គបណ្តុះបណ្តាលនេះត្រូវចំណាយពេលប្រហែលមួយសប្តាហ៍និងត្រូវបានបន្តដោយ "ការធ្វើតេស្តជាមុន "ហើយបន្ទាប់មកទៀត អ្នកដែលបានទទួលការបណ្តុះបណ្តាលនេះ នឹងបន្តទៅពង្រឹងលើជំនាញនេះដល់អ្នកស្រាវជ្រាវផ្សេងទៀតនៅតាមបណ្តាខេត្តផ្សេងៗ។ ក្រសួងផែនការជាប្រធាននៃគម្រោងនេះ ប៉ុន្តែគេមិនមែនជាអ្នកផ្តល់មូលនិធិនោះទេ។ MoP មានអ្នកជំនាញមកពីខាងក្រៅរបស់ខ្លួន ដែលគេជួលមកក្នុងន័យជាអ្នកពិគ្រោះយោបល់(MoP1)។ មានបញ្ហាប្រឈម ឬឧបសគ្គមួយចំនួននៅក្រសួងផែនការ ដែលកើតចេញមកពីការដាក់បញ្ចូលគ្នារវាងកម្រិតនៃការបណ្តុះបណ្តាល និងការដឹកនាំឱ្យត្រួតពិនិត្យមើលការស្រាវជ្រាវជាមួយអ្នកជំនាញក្នុងស្ថាប័ននេះ។ ទាំងនេះហើយបានធ្វើឱ្យក្រសួងនេះមិនមានថវិកាផ្ទាល់ខ្លួនក្នុងការធ្វើការងារស្រាវជ្រាវនេះ ហើយវាក៏ជាការអភិវឌ្ឍដ៏គ្រោះថ្នាក់មួយ និងមិនទំនងលេចចេញជារូបរាងដែរ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានដាក់ចេញក្របខ័ណ្ឌច្បាប់របស់ខ្លួននៅក្នុង"ផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៩-២០១៣"[3] ដែលត្រូវបានកែសម្រួលឡើងវិញសម្រាប់ឆ្នាំ ២០១៤-២០១៨[4] ។ សេចក្តីថ្លែងការណ៍ស្តីពីទស្សនវិស័យរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ "ដើម្បីឱ្យក្លាយទៅជាសាកលវិទ្យាល័យមួយដែលនាំមុខគេនៅក្នុងប្រទេសកម្ពុជា គឺត្រូវផ្តោតលើគុណភាពជាចម្បង មានការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍប្រទេសជាតិ និងចែករំលែកទៅនឹងសាកលលោក"។

**ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យនេះ គេត្រូវអនុវត្តតាមបេសកកម្មទាំង៥យ៉ាង៖**

1. ដើម្បីបង្កើត និងអប់រំនិស្សិតក្រោយបញ្ចប់ការសិក្សាឱ្យប្រកបទៅដោយគុណភាពដែលមានចំណេះដឹង ជំនាញ និងមានសមត្ថភាពគ្រប់គ្រាន់។
2. ដើម្បីធ្វើការស្រាវជ្រាវ និងប្រមូលផ្តុំចំណេះដឹងដែលមាន យកមកអភិវឌ្ឍទៅលើការសិក្សា និងអភិវឌ្ឍប្រទេសជាតិ។

---

[3]ផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ ២០០៩-២០១៤ (ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៨)

[4]ផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ ២០១៤-២០១៨ (ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៤)

3. ដើម្បីបង្កើនចំណេះដឹង និងផ្ទេរចំណេះដឹងទាក់ទងនឹងបច្ចេកវិទ្យា ហើយចូលរួមអភិវឌ្ឍប្រទេសជាតិតាមរយៈចំណេះដឹងដែលខ្លួនមាន
4. ដើម្បីផ្តល់សេវាកម្មដល់វិស័យសាធារណៈ និងវិស័យឯកជនសម្រាប់ការអភិវឌ្ឍសហគមន៍
5. ដើម្បីលើកកម្ពស់ការថែរក្សា ការផ្លាស់ប្តូរ និងការអភិវឌ្ឍប្រពៃណីវប្បធម៌ជាតិ

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានដាក់ចេញក្របខ័ណ្ឌច្បាប់របស់ខ្លួននៅក្នុង "ផែនការយុទ្ធសាស្រ្តឆ្នាំ ២០០៩-២០១៣"[5] ដែលត្រូវបានកែសម្រួលឡើងវិញសម្រាប់ឆ្នាំ ២០១៤-២០១៨[6] ។ សេចក្តីថ្លែងការណ៍ស្តីពីទស្សនវិស័យរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ "ដើម្បីឱ្យក្លាយទៅជាសាកលវិទ្យាល័យមួយដែលនាំមុខគេនៅក្នុងប្រទេសកម្ពុជា គឺត្រូវផ្តោតលើគុណភាពជាចម្បង មានការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍប្រទេសជាតិ និងចែករំលែកទៅនឹងសាកលលោក"។

**ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យនេះ គេត្រូវអនុវត្តតាមបេសកកម្មទាំង៥យ៉ាង៖**

6. ដើម្បីបង្កើត និងអប់រំនិស្សិតក្រោយបញ្ចប់ការសិក្សាឱ្យប្រកបទៅដោយគុណភាពដែលមានចំណេះដឹង ជំនាញ និងមានសមត្ថភាពគ្រប់គ្រាន់
7. ដើម្បីធ្វើការស្រាវជ្រាវ និងប្រមូលផ្តុំចំណេះដឹងដែលមាន យកមកអភិវឌ្ឍទៅលើការសិក្សា និងអភិវឌ្ឍប្រទេសជាតិ
8. ដើម្បីបង្កើនចំណេះដឹង និងផ្ទេរចំណេះដឹងទាក់ទងនឹងបច្ចេកវិទ្យា ហើយចូលរួមអភិវឌ្ឍប្រទេសជាតិតាមរយៈចំណេះដឹងដែលខ្លួនមាន
9. ដើម្បីផ្តល់សេវាកម្មដល់វិស័យសាធារណៈ និងវិស័យឯកជនសម្រាប់ការអភិវឌ្ឍសហគមន៍
10. ដើម្បីលើកកម្ពស់ការថែរក្សា ការផ្លាស់ប្តូរ និងការអភិវឌ្ឍប្រពៃណីវប្បធម៌ជាតិ

**ជាមួយនឹងគោលដៅ**

1. ដើម្បីសម្រេចឱ្យបាននូវស្តង់ដារួមមួយទាំងថ្នាក់ជាតិ និងថ្នាក់តំបន់
2. គ្រប់ផ្នែកនីមួយៗត្រូវធ្វើការអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់អនុបណ្ឌិត បណ្ឌិតរៀងៗខ្លួន

---

[5]ផែនការយុទ្ធសាស្រ្តរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ ២០០៩-២០១៤ (ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៨)

[6]ផែនការយុទ្ធសាស្រ្តរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ ២០១៤-២០១៨ (ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៤)

3. គ្រប់ផ្នែកទាំងអស់ត្រូវធ្វើការអភិវឌ្ឍសកម្មភាពស្រាវជ្រាវរបស់ខ្លួន និងអភិវឌ្ឍកម្មវិធីនៃការផ្តល់សេវាកម្មដល់សហគមន៍
4. ដើម្បីធ្វើឱ្យមានភាពរីកចម្រើន និងការចែករំលែកព័ត៌មានឱ្យគ្នាទៅវិញទៅមក គេធ្វើឡើងតាមរយៈប្រព័ន្ធទំនាក់ទំនងនៃបច្ចេកវិទ្យា ដែលមាននៅទូទាំងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដូច្នេះអ្នកពាក់ព័ន្ធទាំងអស់ អាចចូលរួមដំណើរការនៃការផ្លាស់ប្តូរព័ត៌មានឱ្យគ្នាបាន។
5. គ្រប់ផ្នែកទាំងអស់នឹងត្រូវបង្កើតឱ្យមានការវាស់ស្ទង់នូវគុណភាពរបស់ខ្លួន ឬយន្តការនៃការវាយតម្លៃផ្សេងៗ

ក្របខ័ណ្ឌច្បាប់សម្រាប់ឆ្នាំ ២០១៤-២០១៨ បានលើកឡើងថា "មានបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរ នៅក្នុងការអភិវឌ្ឍសមត្ថភាព ដែលតម្រូវឱ្យមានការធ្វើកំណែទម្រង់ទៅលើលក្ខខណ្ឌនៃការដឹកនាំការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុដោយបូករួមទាំងបុគ្គលិក និងទីកន្លែងធ្វើការ"។ ការកែលម្អគោលដៅសម្រាប់ "ការអភិវឌ្ឍសមត្ថភាព" និង "ការធ្វើកំណែទម្រង់លើគ្រប់វិស័យ" ត្រូវបានគេបញ្ចូលនូវគោលដៅចម្បងចំនួន១០ ដើម្បីដោះស្រាយបញ្ហានេះ។

១. បញ្ចូលបន្ថែមបុគ្គលិកផ្នែកបង្រៀន និងបុគ្គលិករដ្ឋបាលកម្រិតកណ្តាល ដែលយ៉ាងហោចណាស់មានកម្រិតអប់រំត្រឹមថ្នាក់អនុបណ្ឌិតជាមួយនឹងសមត្ថភាពភាសាអង់គ្លេស និងICT

២. អាចមានសមត្ថភាពសម្រាប់ការងារស្រាវជ្រាវ និងការបោះពុម្ពផ្សាយផ្សេងៗ

៣. ការបង្កើនកម្មវិធីសម្រាប់ថ្នាក់បញ្ចប់ការសិក្សា និងលើកកម្ពស់សិទ្ធិសេរីភាពនៃការសិក្សា

៤. បង្កើនចំនួននិស្សិតគ្រប់ជាតិសាសន៍ ឱ្យចូលរួមគ្រប់វគ្គសិក្សាទាំងអស់

៥. បង្កើនការផ្លាស់ប្តូរបទពិសោធន៍នៃការសិក្សារបស់និស្សិត និងសាស្ត្រាចារ្យជាមួយនឹងបណ្តាសាកល

វិទ្យាល័យនៅអាស៊ាននៅ (AUN) និងសាកលវិទ្យាល័យដែលជាដៃគូផ្សេងទៀត

៦. លើកកម្ពស់សុចរិតភាព ការទទួលខុសត្រូវនិងភាពជាម្ចាស់ការលើខ្លួនឯងរបស់និស្សិត សាស្ត្រាចារ្យ និងបុគ្គលិក

៧. ធានាឱ្យបានថានឹងមានការបង្រៀនមួយ ដែលមានគុណភាពបូករួមជាមួយបរិស្ថានជុំវិញនៃការរៀនសូត្រល្អផងដែរ

៨. ផ្តល់នូវការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងការប្រើប្រាស់អ៊ីនធើណិតដោយឥតគិតថ្លៃសម្រាប់និស្សិត និងបុគ្គលិកទាំងអស់

៩. កែប្រែឱ្យក្លាយទៅជាមជ្ឈមណ្ឌលធនធានកណ្តាលមួយ សម្រាប់ការសិក្សារៀនសូត្រការស្រាវជ្រាវ និងការផ្តល់សេវាកម្មដល់សហគមន៍

១០. ការធានាឱ្យបាននូវគុណភាព និងយន្តការនៃការវាយតម្លៃនៅគ្រប់ផ្នែក និងគ្រប់កម្មវិធីសិក្សាទាំងអស់[7]

គួរឱ្យកត់សម្គាល់ម្តងទៀតដែលថា គោលដៅទាំងនេះមិនបានបម្រើដល់រចនាសម្ព័ន្ធ និងការបង្កើនសេរីភាពនៃការស្រាវជ្រាវនោះទេ ហើយការផ្តល់ឱ្យប្រើប្រាស់សេវាកម្មអ៊ីនធើណិតនេះ ក៏មិនបានប្រឈមមុខនឹងបរិយាកាសនយោបាយបច្ចុប្បន្ន និងច្បាប់ថ្មីដែលទាក់ទងនឹងការប្រើប្រាស់អ៊ីនធើណិតនេះទេ។[8] លើសពីនេះទៅទៀត ការបន្ថែមបុគ្គលិក ក៏មិនទាន់មានភាពច្បាស់លាស់ដែរ ពេលគឺទាក់ទងទៅនឹងចំនួនសរុបទាំងអស់នៃគ្រូបង្រៀន ឬក៏មានការជ្រើសរើសបណ្ឌិតបន្ថែម។ ដើម្បីពង្រឹងគុណភាពឱ្យមានភាពប្រសើរឡើង ត្រូវសង្កត់ធ្ងន់ទៅលើការដឹកនាំ និងការគ្រប់គ្រង ប៉ុន្តែនៅមិនទាន់មានផែនការច្បាស់លាស់ណាមួយសម្រាប់ការវាយតម្លៃលើការគ្រប់គ្រងរបស់ខ្លួនឯងនៅឡើយទេ។ ការផ្តោតសំខាន់ទៅលើការបង្កើនចំនួនបុគ្គលិករដ្ឋបាល គឺជាការមិនយកចិត្តទុកដាក់ទៅលើការស៊ើបអង្កេតយ៉ាងជិតដល់ លើការអនុវត្តនាពេលបច្ចុប្បន្ន ហើយក៏ជាកង្វះខាតមួយនៃការដឹកនាំដែលមានស្រាប់ផងដែរ។ [9]ការគាំទ្រឱ្យមានមុខតំណែងនេះ វាមានសារៈសំខាន់ណាស់ ក្នុងការផ្ទេរនូវធនធានទាំងឡាយដើម្បីបញ្ឈប់ឱ្យមានការិយាធិបតេយ្យ ជាពិសេសភាពមន្ទិលសង្ស័យកើតមានឡើង នៅពេលដែលទិន្នន័យរបស់យើងបានបង្ហាញថា បញ្ហាកើតមានឡើងនៅពេលដែលគ្រូបង្រៀន និងអ្នកស្រាវជ្រាវធ្វើការងារច្រើនហួសហេតុជាងអ្នកគ្រប់គ្រង។

ផែនការយុទ្ធសាស្រ្តសម្រាប់ការផ្តល់ថវិការបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺនៅមានភាពមិនច្បាស់លាស់ ដែលមានការស្រាយបំភ្លឺពីក្រសួងអប់រំ យុវជន និងកីឡាទាក់ទងនឹងគម្រោងខាងលើ និងការរួមបញ្ចូលគ្នាជាមួយនឹងធាតុផ្សំសំខាន់ៗចំនួនបីនោះ ដែលតម្រូវឱ្យមានការវិនិយោគជាហិរញ្ញវត្ថុលក្ខណៈទ្រង់ទ្រាយធំ សម្រាប់ដំណើរការនេះរួមមាន ការកសាងបរិវេណកីឡា ដើម្បីការអប់រំកាយរបស់និស្សិត និងបុគ្គលិកទទួលបានថវិកាសម្រាប់ការសាងសង់អគារស្ទែម (STEM) មួយរបស់មហាវិទ្យាល័យវិទ្យាសាស្រ្ត ព្រមទាំងការប្រមូលមូលនិធិដើម្បី សាងសង់អគាររួមគ្នាមួយរវាងមហាវិទ្យាល័យអប់រំ និងមជ្ឈមណ្ឌលខេមរសិក្សា។ តើត្រូវធ្វើ ឬមិនត្រូវធ្វើក្នុងការ ជួយសម្រួលការងារ នៃការស្រាវជ្រាវនេះឱ្យមានភាពប្រសើរឡើង បើការអប់រំ និងសមត្ថភាពនៃការអភិវឌ្ឍនៅតែត្រូវបានគេមើលឃើញនោះ ហើយការស្រាវជ្រាវនេះត្រូវបានគេស្រាយបំភ្លឺ តាមរយៈផលប៉ះពាល់នៃការជួយសម្រួលកិច្ច

---

[7]Ibid pp 3-4.

[8]សម្ព័ន្ធប្រជាជនកម្ពុជា ដើម្បីគាំទ្រ និងការពារសិទ្ធិមនុស្ស(LICADO)

[9]Ibid pp 4.

ការអភិវឌ្ឍផ្សេងៗ បើធៀបជាមួយនឹងការអភិវឌ្ឍសមត្ថភាពរបស់មនុស្សក្នុងការទទួលបានគុណភាព នៃការអប់រំ និងការស្រាវជ្រាវមួយ។ ភាពជោគជ័យដ៏ អស្ចារ្យបំផុត នៃគម្រោងដែលចាយថវិកាដ៏ធំនេះ គឺជាការសហការគ្នាជាមួយមជ្ឈមណ្ឌលខេមរសិក្សា ហើយការផ្តល់ថវិកានេះបានធ្វើឱ្យស្ថាប័ននេះ ទទួលបានជោគជ័យក្នុងដំណើរការនៃការស្រាវជ្រាវ ជាមួយនឹងការផ្សព្វផ្សាយមួយ ទៅកាន់ប្រទេស ដទៃទៀតផងដែរ។

សាស្ត្រាចារ្យនៅមហាវិទ្យាល័យភូមិន្ទភ្នំពេញមួយចំនួនបានផ្តល់យោបល់ថា គោលនយោបាយ ដ៏ទូលំទូលាយរបស់ស្ថាប័ននេះមិនត្រូវគេយកមកប្រតិបត្តិទេ "បើយោងតាមសាកលវិទ្យាធិការរបស់ យើង សាកលវិទ្យាល័យនេះបានបម្រុងទុកនូវថវិកាសម្រាប់ការងារស្រាវជ្រាវនេះហើយ ប៉ុន្តែគោល នយោបាយនៃការស្រាវជ្រាវ និងគណៈកម្មាធិការរបស់គ្រឹះស្ថាននេះមិនទាន់ធ្វើរួចរាល់នៅឡើយទេ" (RUPP:SR)។ ទាំងនាយក និងនាយករងនៃផ្នែកស្រាវជ្រាវនេះ មិនទាន់ប្រាកដថាថវិកានៃការ ស្រាវជ្រាវនេះបានមកពីប្រភពណានោះទេ ហើយក៏បានបញ្ជាក់ដែរថា យន្តការដើម្បីធានាឱ្យបានការ ស្រាវជ្រាវមួយដែលមានគុណភាពគឺត្រូវមានការរួមបញ្ចូលគ្នាក្នុងគោលនយោបាយនោះ (RUPP: DR)។ បើទោះជាមានការដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យឆ្នាំ ២០១៤-២០១៨ ជា "សកម្មភាព" តួលេខ 10។

សរុបមកប្រសិទ្ធភាពនៃគោលនយោបាយដ៏ធំទូលាយរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងការងារស្រាវជ្រាវនេះ គឺមិនទាន់មានភាពប្រាកដប្រជានៅឡើយទេ។ សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ ហាក់ដូចជាបានសម្រេចនូវភាពជោគជ័យរបស់ខ្លួនបានមួយកម្រិតជាមួយនឹងវិធីសាស្ត្រតាម បែបរិមជ្ឈការនេះ ប៉ុន្តែការគាំទ្រឱ្យមានការបោះពុម្ព និងការផ្សព្វផ្សាយនូវគោលនយោបាយនេះ ក៏ត្រូវ ទាមទារឱ្យមានការកែប្រែឡើងវិញដែរ ដើម្បីធ្វើការផ្សារភ្ជាប់ជាមួយនឹងវិន័យ និងការសិក្សាដ៏ជាក់លាក់ មួយ។

## សាកលវិទ្យាល័យជាតិគ្រប់គ្រង

សាកលវិទ្យាល័យជាតិគ្រប់គ្រង មានមជ្ឈមណ្ឌលមួយសម្រាប់ការស្រាវជ្រាវ និងការបោះពុម្ព ផ្សាយ ជាមួយនឹងគោលដៅទាំងនេះ៖

- ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវ ស្តីពីសេដ្ឋកិច្ច និងច្បាប់ក្នុងតំបន់អាស៊ាន
- ដើម្បីបង្កើតបណ្តាញអន្តរជាតិ ដែលពាក់ព័ន្ធនឹងការសិក្សានៅតាមស្ថាប័ននីមួយៗ (សាកលវិទ្យាល័យ) ហើយមានការចូលរួមទាំងសេដ្ឋកិច្ច និងគម្រោងស្រាវជ្រាវផ្នែកច្បាប់។

### សកម្មភាពសិក្សាសំខាន់ៗរួមមាន៖

- ប្រមូលផ្តុំ និងចែកចាយព័ត៌មានផ្សេងៗដែលទាក់ទងនឹងសេដ្ឋកិច្ច និងច្បាប់

- រៀបចំ និងសម្របសម្រួលការសិក្សាស្រាវជ្រាវស្តីពីសេដ្ឋកិច្ច និងច្បាប់
- បង្កើតដៃគូស្រាវជ្រាវជាលក្ខណៈអន្តរជាតិនៅតាមវិទ្យាស្ថានសិក្សារដ្ឋាភិបាលកន្លែងធ្វើអាជីវកម្ម និងអង្គការមិនមែនរដ្ឋាភិបាល។
- ធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈតាមរយៈការធ្វើសិក្ខាសាលា

នៅក្នុងជំពូកទី៦នៃរបាយការណ៍នេះបានរៀបរាប់ពីអ្វីដែលត្រូវធ្វើក្នុងសកម្មភាពនៃការស្រាវជ្រាវ សមត្ថភាពនៃការស្វែងរកមូលនិធិ និងការលើកទឹកចិត្តផ្សេងៗក្នុងការធ្វើការងារនេះ។ ទោះបីជាលទ្ធផលនៃការស្រាវជ្រាវនៅមានកម្រិតទាបក៏ដោយ ក៏មានការលើកឡើងថាសាកលវិទ្យាល័យជាតិគ្រប់គ្រង បានជួបប្រសព្វជាមួយនឹងសកម្មភាពដែលពួកគេចង់បាន ប៉ុន្តែការស្រាវជ្រាវដែលមិនទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់នេះ ត្រូវបានគេដាក់បញ្ចូលក្នុងការអនុវត្តរបស់មហាវិទ្យាល័យផ្សេងៗនៃសាកលវិទ្យាល័យនេះ មុនពេលដែលគេសរសេរវាទុកក្នុងគោលនយោបាយរបស់សាលាទៅទៀត។

### សាកលវិទ្យាល័យបាត់ដំបង

សាកលវិទ្យាល័យបាត់ដំបងមាននាយកដ្ឋានស្រាវជ្រាវ និងបានបង្កើតការិយាល័យដែលទាក់ទងនឹងការងាររបស់និស្សិតផងដែរ (UBB:SR)។ សាកលវិទ្យាល័យមិនមានការបែងចែក និងសរសេរបទប្បញ្ញត្តិជាផ្លូវការណាមួយដែលទាក់ទងទៅនឹងគោលនយោបាយនៃការស្រាវជ្រាវ ឬតម្រូវការណាមួយនោះទេ ពោលគឺផ្តោតសំខាន់លើតម្រូវការនៃការកសាងសមត្ថភាពសម្រាប់ការស្រាវជ្រាវរបស់និស្សិត និងសាស្ត្រាចារ្យ ដោយបូករួមទាំងការធ្វើឱ្យទៅជាស្តង់ដារអន្តរជាតិមួយ ដែលត្រូវបានរួមបញ្ចូលទៅក្នុងគោលនយោបាយរួមរបស់សាកលវិទ្យាល័យ ហើយក៏មានគោលនយោបាយសម្រាប់សាស្ត្រាចារ្យ ដែលគេដាក់បញ្ចូលទៅក្នុងការងារស្រាវជ្រាវ ទាក់ទងនឹងជាតុផ្សំនៃគរុកោសល្យផងដែរ។ វគ្គសិក្សានៃការស្រាវជ្រាវទាំងនេះរួមមាន វិធីសាស្ត្រផ្សេងៗនៃការស្រាវជ្រាវទៅលើទីផ្សារ និងវគ្គសិក្សាផ្សេងទៀតទៅតាមភាពខុសគ្នារបស់មហាវិទ្យាល័យនីមួយៗ។

មិនមានតម្រូវការណាមួយពីសាស្ត្រាចារ្យក្នុងការបោះពុម្ពផ្សាយការងារស្រាវជ្រាវទាំងនោះទេ ប៉ុន្តែវាជាតម្រូវការសម្រាប់សិស្សនិស្សិតដែលរៀនលើមុខវិជ្ជាមួយចំនួនដូចជា ព័ត៌មានវិទ្យាវិទ្យាសាស្ត្រកុំព្យូទ័រ កសិកម្ម និងវិទ្យាសាស្ត្រសត្វ។ សម្រាប់មុខវិជ្ជាទាំងនេះ តម្រូវឱ្យមានការស្រាវជ្រាវទៅលើគម្រោងនៃការសរសេរនិក្ខេបបទរបស់ពួកគេ ដើម្បីបញ្ចប់ការសិក្សាដោយជោគជ័យ។ ចំពោះមុខវិជ្ជាដទៃទៀត និងជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រសង្គម សាកលវិទ្យាល័យតម្រូវឱ្យធ្វើការស្រាវជ្រាវសម្រាប់ថ្នាក់មិនទាន់បញ្ចប់បរិញ្ញាបត្រ ដែលការងារនេះវាហួសពីសមត្ថភាពរបស់សិស្ស និងសាស្ត្រាចារ្យដែលសិក្សា ឬបង្រៀនក្នុងជំនាញទាំងនោះ។ សាកលវិទ្យាល័យបានព្យាយាមជម្នះឧបសគ្គទាំងនេះ ដោយ

ការដាក់ឱ្យអនុវត្តនូវគោលនយោបាយដែលជំរុញឱ្យមានការអេភិវឌ្ឍប្រទេសជាតិ និងការរួមបញ្ចូលគ្នាដើម្បីអភិវឌ្ឍរចនាសម្ព័ន្ធតាមលក្ខណៈអន្តរជាតិ (នៅក្នុងជំពូកទី ៦)។

ទោះបីជាសាកលវិទ្យាល័យនេះមិនទាន់មានបទប្បញ្ញត្តិណាមួយទាក់ទងនឹងការស្រាវជ្រាវនេះក៏ដោយ ប៉ុន្តែពួកគេមានឆន្ទៈខ្ពស់ក្នុងការលើកកម្ពស់ និងអនុវត្តសកម្មភាពស្រាវជ្រាវនេះ ទាំងក្នុងវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្ររូបនិយម។ គម្រោងរបស់សាកលវិទ្យាល័យបាត់ដំបង បានបង្ហាញពីសារៈសំខាន់នៃសញ្ញាបត្រ ដែលតម្រូវឱ្យមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ហើយពួកគេក៏បានជំរុញឱ្យមានទំនាក់ទំនងជាមួយដៃគូអន្តរជាតិជាច្រើន ដែលនាំឱ្យមានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ ធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផងដែរ។

## សាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជា

សាកលវិទ្យាល័យបញ្ញាសាស្ត្រ មានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍របស់ខ្លួន (ដឹកនាំដោយមនុស្សពីរនាក់ ដោយម្នាក់ជាសាស្ត្រាចារ្យដែលបានជួល 50% និងម្នាក់ទៀតដើម្បីមកអភិវឌ្ឍការស្រាវជ្រាវ 50%)។ ពួកគេមិនមានគោលការណ៍ណែនាំស្តីពីការធ្វើការងារស្រាវជ្រាវនោះទេ បើទោះបីជាពួកគេកត់សម្គាល់ឃើញថា "យើងមានគោលដៅនៃស្រាវជ្រាវរបស់យើង ប៉ុន្តែមិនមែនជាគោលនយោបាយទេ" (PUC:DR)។ គណៈគ្រប់គ្រងរបស់សាលា និងក្រសួងអប់រំកំពុងសហការគ្នាសរសេរគោលនយោបាយនេះឡើង ហើយយើងក៏សង្ឃឹមថា វានឹងលេចចេញជារូបរាងក្នុងពេលឆាប់ៗនេះផងដែរ។ ប៉ុន្តែក្រសួងអប់រំមាន "សំណុំបែបបទដែលបានរៀបរាប់យ៉ាងលម្អិតដ៏វែងមួយសម្រាប់ធ្វើការបំពេញបន្ថែម" ដែលជាមូលហេតុអាចនាំឱ្យមានភាពយឺតយ៉ាវនៃដំណើរការមួយនេះ(PUC:DR)។ គេកត់សម្គាល់ឃើញថា សាកលវិទ្យាល័យបញ្ញាសាស្ត្រត្រូវការ"គោលនយោបាយស្រាវជ្រាវមួយ ដែលរួមបញ្ចូលទាំងយុទ្ធសាស្ត្រក្នុងការដោះស្រាយជាមួយនឹងធនធានដែលមានកំណត់"។

## សាកលវិទ្យាល័យហ្សាម៉ាន់

សាកលវិទ្យាល័យហ្សាម៉ាន់ មិនមានគោលនយោបាយស្រាវជ្រាវជាផ្លូវការសម្រាប់ខ្លួនឯងទេ ប៉ុន្តែសាកលវិទ្យាល័យនេះមានមជ្ឈមណ្ឌលសម្រាប់គាំទ្រការស្រាវជ្រាវ ដែលរៀបចំឡើងក្នុងគោលបំណង បង្កើតទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងអង្គការមិនមែនរដ្ឋាភិបាល ហើយរវាងរដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិបរទេសផ្សេងៗ។គោលបំណងនេះគឺដើម្បី "នាំយកសាស្ត្រាចារ្យ និងអ្នកជំនាញមកពីខាងក្រៅ មកធ្វើការផ្តួចផ្តើមក្នុងការស្រាវជ្រាវ និងស្វែងរកថវិកា" (ZU:DH2)។ ហ្សាម៉ាន់ កំពុងធ្វើការយ៉ាងសកម្មដើម្បីអភិវឌ្ឍបណ្តាញនេះជាមួយនឹងសមាជិកដែលមកពីប្រទេសផ្សេងៗដែលជាឱកាសក្នុងការកសាងសមត្ថភាពឱ្យប្រសើរឡើង និងការផ្សព្វផ្សាយ វិសាលភាពរបស់ខ្លួនផងដែរ។ មូលហេតុនេះបានបង្កើនលទ្ធភាពនៃការផលិត ការស្រាវជ្រាវឱ្យមានភាពកើនឡើង តាមរយៈការសម្របសម្រួលនៃបណ្តាញដែលមានស្រាប់ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនៃការធ្វើមជ្ឈការនេះ វាមិនបានធ្វើឱ្យ

គម្រោងនេះមានភាពខុសប្លែកគ្នាច្រើននោះទេ។ តើគួរធ្វើគោលនយោបាយអ្វី ដើម្បីធានាឱ្យបានថា សាកលវិទ្យាល័យហ្សាម៉ាន់មានអ្នកស្រាវជ្រាវដែលប្រកបដោយសមត្ថភាព និងមានរចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីគ្រប់គ្រងគម្រោងដែលនឹងខិតជិតចូលមកដល់នេះ។

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មិនមានគោលនយោបាយនៃការស្រាវជ្រាវណាមួយច្បាស់លាស់ទេ ប៉ុន្តែចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ សាកលវិទ្យាល័យនេះនឹងអនុវត្តយុទ្ធសាស្ត្រថ្មីមួយ ដែលទាក់ទងទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ យុទ្ធសាស្ត្រនោះគឺ "សាកលវិទ្យាល័យនេះនឹងក្លាយទៅជាសាកលវិទ្យាល័យមួយដែលឈានមុខគេនៅក្នុងកិច្ចការស្រាវជ្រាវនេះ"។ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះបានព្យាយាមបង្កើតទំនាក់ទំនងជាមួយដៃគូបរទេសដែលអាច "ផ្តល់ទាំងជំនាញទន់និងរឹងដល់គេ ដូច្នេះគ្រប់មុខវិជ្ជាទាំងអស់នៅក្នុងសាកលវិទ្យាល័យនេះនឹងមានភាពប្រសើរឡើងជាមិនខាន" (RULE: Dean1)។ និស្សិតម្នាក់បានប្រាប់ឱ្យដឹងថា"សាកលវិទ្យាល័យមានគោលនយោបាយសម្រាប់ការស្រាវជ្រាវដែរ ប៉ុន្តែវាមិនអាចបំពេញតម្រូវការបច្ចុប្បន្នរបស់សាកលវិទ្យាល័យនេះនោះទេ" (RULE:SRT)។ ព្រឹទ្ធបុរសម្នាក់បានលើកឡើងថា "សាកលវិទ្យាល័យនេះកម្រធ្វើការសិក្សាស្រាវជ្រាវណាស់។ ថ្នាក់លើនៃសាកលវិទ្យាល័យនេះតែងតែលើកទឹកចិត្តដល់សាស្ត្រាចារ្យក្នុងការស្វែងរកមូលនិធិ សម្រាប់ធ្វើការស្រាវជ្រាវ។ ប៉ុន្តែទោះជាយ៉ាងណា វាមិនបានចេញជាលទ្ធផលអ្វីនោះទេ" (RULE:D1)។ គោលនយោបាយនៃការស្រាវជ្រាវរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអាចនឹងចូលរួមក្នុងការលើកទឹកចិត្តយ៉ាងពិតប្រាកដដល់សាស្ត្រាចារ្យ ដើម្បីធ្វើការស្រាវជ្រាវនេះ។

## សាកលវិទ្យាល័យភូមិន្ទកសិកម្ម

បេសកកម្មរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្មគឺមានដូចជា ការស្រាវជ្រាវ ការអប់រំ និងការពង្រីកខ្លួនបន្ថែមទៀត ប៉ុន្តែបើយោងតាមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យនេះ បានលើកឡើងថា មិនមានគោលការណ៍ណែនាំជាផ្លូវការ សម្រាប់ការស្រាវជ្រាវ ហើយសាកលវិទ្យាល័យក៏មិនមានថវិកាសម្រាប់គម្រោងនេះផងដែរ (RUA:PR)។ សាកលវិទ្យាល័យនេះបានចូលរួមនៅក្នុងគម្រោងនៃការស្រាវជ្រាវផ្សេងៗគ្នាជាច្រើន ដែលនាំឱ្យមហាវិទ្យាល័យនីមួយៗទទួលបានថវិកាជំនួយពីអង្គការអន្តរជាតិ សម្រាប់ពង្រីកបន្ថែមការស្រាវជ្រាវលើវិស័យកសិកម្ម។ ការស្រាវជ្រាវនេះមានការជំរុញបន្ថែមពីសំណាក់សាស្ត្រាចារ្យគ្រប់ជាន់ថ្នាក់ (ជំនួយការសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ) សម្រាប់អ្នកដែលមានឋានៈខ្ពស់ ក៏ទទួលបានកម្រៃពីការបង្រៀនខ្ពស់ដែរ ហើយតម្រូវឱ្យមានពេលវេលាបន្ថែមទៀតក្នុងការធ្វើការស្រាវជ្រាវ (RUA:PR)។ ទោះយ៉ាងណាក៏ដោយ សាកលវិទ្យាធិការនៃ

សាកលវិទ្យាល័យនេះបានកត់សម្គាល់ឃើញថា (កត្តាដែលបង្កឱ្យមានភាពរាំងស្ទះដល់ការស្រាវជ្រាវ) គឺក្រសួងអប់រំមិនទាន់អនុញ្ញាតឱ្យសាស្ត្រាចារ្យទាំងអស់ធ្វើការងារនេះនោះទេ (RUA:PR)។ ព្រឹទ្ធបុរសម្នាក់ បានបន្ថែមថាពួកគេមានបុគ្គលិកធ្វើការពេញម៉ោងចំនួន១៤នាក់ និងធ្វើការក្រៅម៉ោងចំនួន ១២នាក់ (RUA:Dean2)។

## សាកលវិទ្យាល័យមានជ័យ

សាកលវិទ្យាល័យមានជ័យ មិនមានគោលនយោបាយនៃការស្រាវជ្រាវជាផ្លូវការទេ ប៉ុន្តែពួកគេព្យាយាមផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការធ្វើគម្រោងស្រាវជ្រាវរួមគ្នា (MCU:VP)។ ពួកគេក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ ក្នុងការអភិវឌ្ឍសមត្ថភាពនៃការស្រាវជ្រាវរបស់ពួកគេផងដែរ (MCU:D1)

## សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ

សាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ ជាសាកលវិទ្យាល័យមួយដែលមានទីតាំងក្នុងខេត្តសៀមរាប បានធ្វើសេចក្តីថ្លែងការណ៍លម្អិតមួយ ស្តីពីគោលនយោបាយ និងនីតិវិធីនៃការស្រាវជ្រាវ (ដែលបានបង្កើតឡើងនៅឆ្នាំ ២០១១)។ សាកលវិទ្យាល័យនេះមានបំណងចង់ក្លាយទៅជាមជ្ឈមណ្ឌលស្រាវជ្រាវមួយ ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបោះពុម្ពផ្សាយ និងចែករំលែកលទ្ធផលនៃការស្រាវជ្រាវនោះទៅកាន់សង្គមជាតិ (USEA:VP)។ សាកលវិទ្យាល័យនេះក៏បានសហការជាមួយដៃគូជាតិ អន្តរជាតិ និងស្ថានទូតសហរដ្ឋអាមេរិកដើម្បីធ្វើការកែលម្អគុណភាពនៃការអប់រំនិងការស្រាវជ្រាវរបស់ខ្លួនផងដែរ។ គោលបំណងរបស់មហាវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ គឺដើម្បីជួយឱ្យនិស្សិតរៀននូវជំនាញដែល "ត្រូវនឹងទីផ្សារនិងឱកាសការងារនាពេលបច្ចុប្បន្ន"។ ឧទាហរណ៍ថា "តើវិស័យទេសចរណ៍គឺជាអ្វី?" និង "តើពួកគេត្រូវធ្វើដូចម្តេចដើម្បីជាក់ពាក្យចូលបម្រើការក្នុងវិស័យទេសចរណ៍នេះ?"(USEA:D1)។ សាកលវិទ្យាល័យក៏តម្រូវឱ្យសិស្សនិស្សិតទាំងអស់ ធ្វើការប្រកួតប្រជែងគ្នាក្នុងការប្រឡង និងសរសេរនិក្ខេបបទមួយមុនពេលដែលពួកគេបញ្ចប់ការសិក្សា។ ព្រឹទ្ធបុរសម្នាក់ បានគូសបញ្ជាក់បន្ថែមពីកិច្ចសហប្រតិបត្តិការជាមួយ "ដៃគូជាច្រើនដើម្បីបង្កើនជំនាញនៃការស្រាវជ្រាវនិងទស្សនវិស័យរបស់ពួកយើង ពោលគឺឱ្យស្របគ្នាជាមួយនឹងអ្វីដែលរដ្ឋាភិបាលបច្ចុប្បន្នកំពុងធ្វើ"(USEA:D2)។

នៅទីនេះ យើងកត់សម្គាល់ឃើញថា ការធ្វើអាជីវកម្ម និងវិស័យសេដ្ឋកិច្ច ត្រូវធ្វើការការផ្តោតសំខាន់ទៅលើការស្រាវជ្រាវ រួមជាមួយនឹងការយកចិត្តទុកដាក់លើបេត់នយោបាយផងដែរ ដែលនៅក្នុងរបាយការណ៍នេះបានបង្ហាញថា វាគឺជាកត្តាដ៏សំខាន់មួយក្នុងការរាំងស្ទះចំពោះកិច្ចការស្រាវជ្រាវនៃផ្នែកវិទ្យាសាស្ត្រសង្គមនេះ។

**សាកលវិទ្យាល័យស្វាយរៀង**

សាកលវិទ្យាល័យស្វាយរៀងមិនមានគោលនយោបាយនៃការស្រាវជ្រាវជាផ្លូវការនោះទេ ប៉ុន្តែពួកគេមានបេសកកម្មមួយ "ដើម្បីក្លាយទៅជាមជ្ឈមណ្ឌលដែលមានគុណភាពគ្រប់គ្រាន់ទាំងការអប់រំ និងការស្រាវជ្រាវ" បេសកកម្មនោះគឺ"ដើម្បីផ្តល់ចំណេះដឹង និងបង្រៀនឱ្យនិស្សិតមានសីលធម៌ត្រឹមត្រូវដែលអាចឱ្យពួកគេចូលរួមធ្វើការចែករំលែកចំណុចវិជ្ជមានទាំងនោះ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា" ក្នុងគោលបំណង "ដើម្បីផ្តល់ការអប់រំ និងឱកាសនៃការស្រាវជ្រាវសម្រាប់ថ្នាក់ខេត្ត ហើយជាពិសេសសម្រាប់អ្នកដែលមានការលំបាកក្នុងការទទួលយកការអប់រំថ្នាក់ឧត្តមសិក្សានេះ" (SRU:Deans)។ សាកលវិទ្យាល័យនេះ ក៏អនុវត្តនូវយុទ្ធសាស្ត្រ ដើម្បីកែលម្អគម្រោងនៃការស្រាវជ្រាវរបស់ក្រសួងអប់រំផងដែរ "ប៉ុន្តែសាស្ត្រាចារ្យមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការស្រាវជ្រាវនោះទេ" (SRU:Deans)។

**ម្ចាស់ជំនួយ**

**ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB)

ធនាគារអភិវឌ្ឍន៍អាស៊ីមិនមានគោលនយោបាយសម្រាប់ធ្វើការស្រាវជ្រាវនោះទេ ប៉ុន្តែពួកគេមានគោលនយោបាយសម្រាប់ជួលអ្នកប្រឹក្សាយោបល់ឱ្យចូលរួមក្នុងការងារនេះ។ ក្នុងករណីភាគច្រើន "ការស្រាវជ្រាវដែលទទួលបានជោគជ័យ តែងតែមានការចូលរួមពីអ្នកប្រឹក្សាដែលមានសមត្ថភាព" (អ្នកប្រឹក្សាយោបល់អន្តរជាតិ និងថ្នាក់ជាតិ)។ បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ីភាគច្រើន "គ្រប់គ្រងគម្រោងនេះ ដោយការកំណត់លក្ខខណ្ឌនៃសេចក្តីបញ្ជាក់មួយសម្រាប់ការជ្រើសរើសអ្នកពិគ្រោះយោបល់"។ ពួកគេតាមដានទៅលើភាពរីកចម្រើននៃគម្រោងនេះ និងអាចចូលរួមផ្តល់អនុសាសន៍ផ្សេងៗក្នុងអំឡុងពេលអនុវត្តផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើត និងបានធ្វើការកែប្រែគោលការណ៍ណែនាំ ស្តីពីការប្រើប្រាស់ការពិគ្រោះយោបល់ និងមានភាពច្បាស់លាស់អំពីនីតិវិធីនៃការជ្រើសរើសអ្នកពិគ្រោះយោបល់។ "នៅពេលដែលអ្នកពិគ្រោះយោបល់ត្រូវបានគេជ្រើសរើស យើងបានបញ្ជាក់ពីលក្ខខណ្ឌលម្អិត និងបានបង្ហាញពីវិធីសាស្ត្រផ្សេងៗទាក់ទងនឹងគម្រោងរបាយការណ៍នៃការស្រាវជ្រាវនេះ ទៅកាន់ពួកគេ"។

**ធនាគារពិភពលោក** (WB)

ធនាគារពិភពលោកមិនមានគោលនយោបាយ និងសកម្មភាពសម្រាប់ការស្រាវជ្រាវផ្ទាល់ខ្លួននោះទេ ប៉ុន្តែពួកគេផ្តោតសំខាន់ទៅលើតួនាទីរបស់ពួកគេ ក្នុងការអភិវឌ្ឍការស្រាវជ្រាវក្នុងប្រទេសកម្ពុជា និងផ្តល់ព័ត៌លម្អិតផ្សេងៗទាក់ទងទៅនឹងគម្រោង HEQCIP របស់ធនាគារពិភពលោក និងក្រសួងអប់រំ៖

ប្រព័ន្ធអប់រំឧត្តមសិក្សាបច្ចុប្បន្ន មានការរីកលូតលាស់យ៉ាងឆាប់រហ័ស ប៉ុន្តែនៅមានលក្ខណៈតូចប្រចាំតំបន់ និងមានការព្រួយបារម្ភច្រើនអំពីគុណភាព ដំណើរការ ប្រសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។ ដើម្បីជួយគាំទ្រដល់ចំណុចទាំងនេះធនាគារពិភពលោក បានចុះកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយផ្តល់ទឹកប្រាក់ចំនួន ២៣លានដុល្លារអាមេរិក (៥០% ជាជំនួយឥតសំណង និង៥០% ជាឥណទាន) ដើម្បីផ្តល់ថវិកា៥ឆ្នាំ សម្រាប់គម្រោងកែលម្អគុណភាព និងសមត្ថភាពថ្នាក់ឧត្តមសិក្សា (HEQCIP) ឆ្នាំ ២០១១-២០១៥។

**គោលបំណងរបស់គម្រោង HEQCIP គឺដើម្បីកែលម្អ៖**

ក) គុណភាពនៃការបង្រៀន ការគ្រប់គ្រង និងគម្រោងគាំទ្រការស្រាវជ្រាវ

ខ) សាកល្បងកំណត់ទិសដៅនៃផលវិបាករបស់និស្សិតដើម្បីឱ្យទទួលបានផលល្អ និងរារាំងមិនឱ្យមានបញ្ហាផ្សេងៗ

ការស្រាវជ្រាវរបស់យើងបានបង្ហាញថា នេះគឺជាការចាប់ផ្តើមនៃគំនិតវិជ្ជមានមួយ ប៉ុន្តែមានការិយាល័យធិបតេយ្យជាច្រើន ហើយរបៀបវារៈដឹកនាំរបស់ម្ចាស់ជំនួយនិងសមត្ថភាពនៃការស្រាវជ្រាវក៏មិនទាន់គ្រប់គ្រាន់ផងដែរ។ ស្រទាប់នៃការិយាធិបតេយ្យបានធ្វើឱ្យស្វ័យភាពនៃអ្នកស្រាវជ្រាវគម្រោងនេះមានការថយចុះ ហើយការរំពឹងទុកក្នុងការទទួលជំនួយនោះក៏ហួសពីសមត្ថភាពរបស់ស្ថាប័ន និងសមត្ថភាពនៃការស្រាវជ្រាវដែរ (MCU:Dean5)។ វាក៏អាចទៅរួចផងដែរ ដែលការស្រាវជ្រាវក្នុងពេលបច្ចុប្បន្ននេះ គេប្រហែលជាឱ្យតម្លៃទៅលើបរិមាណ ជាងគុណភាព និងជាហេតុផលដែលគួរតែត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀត។ បញ្ហានៃការផ្តួចផ្តើមធ្វើការស្រាវជ្រាវមួយទៀតនោះ គឺមិនមានថវិកាគ្រប់គ្រាន់សម្រាប់តបស្នងអ្នកស្រាវជ្រាវ ប៉ុន្តែមានកញ្ចប់ថវិកាសម្រាប់អ្នកប្រឹក្សាយោបល់។ ទាំងនេះគឺជាឧបសគ្គយ៉ាងធ្ងន់ធ្ងរ សម្រាប់អ្នកដែលចូលរួមធ្វើការស្រាវជ្រាវ និងការដាក់តម្លៃខ្ពស់ក្នុងការចែករំលែកយោបល់ (ប្រហែលជាមិនដឹងខ្លួន)។ ក៏មានការយល់ឃើញពីសាកលវិទ្យាល័យឯកជនមួយចំនួនអំពីវិសមភាពនៃថវិកា និងគម្រោងនៃការស្រាវជ្រាវផងដែរ (USEA:F3)។

**អង្គការក្រៅរដ្ឋាភិបាល / អង្គការសង្គមស៊ីវិល**

**អង្គការសមធម៌កម្ពុជា** (EC)

អង្គការសមធម៌កម្ពុជាមិនមានគោលនយោបាយនៃការស្រាវជ្រាវជាផ្លូវការទេ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេមានគម្រោងនៃការសិក្សាស្រាវជ្រាវជាច្រើនដែលបានចូលរួម ហើយគម្រោងទាំងនោះភាគច្រើនពាក់ព័ន្ធទៅនឹងសកម្មភាពរបស់ខ្លួនក្នុងការធ្វើការងារនេះ ប៉ុន្តែពួកគេមិនបានបញ្ជាក់ពីបេសកកម្មចម្បងរបស់ខ្លួនទេ (EC:DM)។ គោលដៅយុទ្ធសាស្ត្រនៃអង្គការនេះគឺ៖

- លើកកម្ពស់ឱ្យមានការយល់ដឹងជាសាកល និងជំរុញឱ្យមានការសាមគ្គីគ្នាជាអន្តរជាតិដើម្បីដោះស្រាយបញ្ហាក្រីក្រដែលកំពុងប្រឈមមុខ និងសហគមន៍មួយចំនួនដែលងាយរងគ្រោះនៅកម្ពុជា ។
- សហគមន៍ក្រីក្រ និងសហគមន៍មួយចំនួនដែលងាយរងគ្រោះត្រូវបានគេជំរុញទឹកចិត្តឱ្យមានការរៀបចំ និងការគាំទ្រយ៉ាងមានប្រសិទ្ធភាពបំផុត ក្នុងការយកឈ្នះលើបញ្ហារួមរបស់ពួកគេ និងឈានទៅធ្វើអ្វីដែលពួកគេចង់បានយ៉ាងពេញលេញ។
- ប្រជាជនកម្ពុជា ត្រូវបានគេជូនដំណឹង ក៏ដូចជាគាំទ្រយ៉ាងសកម្មដើម្បីការពារសិទ្ធិ និងការតស៊ូមតិរបស់ពួកគេសម្រាប់ការអភិវឌ្ឍប្រកបដោយសមភាពនិងមានការទទួលខុសត្រូវ។
- រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន បានព្យាយាមកែលម្អឱ្យមានការគោរពច្បាប់ទាក់ទងនឹង ធនធានដីធ្លី លំនៅស្ថាន និងធនធានធម្មជាតិ។

ដើម្បីបំពេញតាមគោលបំណងទាំងនេះ ក្រុមការងាររបស់ECត្រូវបានគេជំរុញឱ្យចូលរួមក្នុងការស្រាវជ្រាវជាច្រើន និងប្រមូលយកទិន្នន័យនៃគំនិតផ្តួចផ្តើមទាំងនោះ។ យើងនឹងធ្វើការពិភាក្សាលើបញ្ហាទាំងនេះបន្ថែមទៀត នៅក្នុងផ្នែកក្រោយៗនៃរបាយការណ៍របស់យើង។

**អង្គការលីកាដូ** ( LICADHO )

អង្គការលីកាដូធ្វើការស៊ើបអង្កេតលើបញ្ហាដីធ្លីដោយរួមបញ្ចូលទាំងការរៀបចំលើផែនទី បញ្ហាជម្លោះ និងការរក្សាទិន្នន័យថ្នាក់ជាតិមួយដែលបានមកការវិភាគស្ថិតិរបស់ពួកគេទៅលើជម្លោះដីធ្លីទាំងនោះ។ បេសកកម្មរបស់ពួកគេរួមមាន៖

អង្គការលីកាដូគឺជាអង្គការសិទ្ធិមនុស្សកម្ពុជា។ ចាប់តាំងពីការកកើតឡើងនៅឆ្នាំ ១៩៩២ អង្គការលីកាដូបានដើរជួរមុខគេ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារសិទ្ធិប្រជាជនស៊ីវិល អ្នកនយោបាយ អ្នកសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ការគោរពរបស់រដ្ឋាភិបាលនិងស្ថាប័នផ្សេងៗទៅកាន់ពួកគេ។ តាមរយៈការកសាងសមិទ្ធផលពីអតីតកាលរបស់ខ្លួននេះហើយ ទើបអង្គការលីកាដូនៅតែបន្តធ្វើជាអ្នកតស៊ូមតិសម្រាប់ប្រជាជនកម្ពុជា និងឃ្លាំមើលរដ្ឋាភិបាល តាមកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យសំខាន់របស់ខ្លួននៅរាជធានីភ្នំពេញ និងការិយាល័យចំនួន១៣នៅតាមបណ្តាខេត្តផ្សេងៗផងដែរ។

នៅក្នុងសេចក្តីថ្លែងការណ៍នៃបេសកកម្មនោះ ពួកគេបានដើរតួនាទីជាអ្នកតស៊ូមតិ និងជាអ្នកត្រួតពិនិត្យ។ គោលបំណងទាំងពីរនេះគឺនាំឱ្យមានការអនុវត្តការស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព។ ពួកគេមិនមានយុទ្ធសាស្ត្រនៃការស្រាវជ្រាវណាមួយជាក់លាក់នោះទេ ប៉ុន្តែពួកគេមាន វិធីសាស្ត្រផ្សេងៗ វិធីសាស្ត្រនៃការប្រមូលទិន្នន័យទិន្នន័យតែមួយគត់នៅក្នុងកុំព្យូទ័រ ដែលមានរយៈពេលយូរឆ្នាំមកហើយ ២០០៨។ ហើយត្រូវបានគេរក្សាទុកនៅក្នុងកុំព្យូទ័រ និងប្រើវាជាឧបករណ៍សម្រាប់វិភាគ

ស្ថិតិ”(LICHADO)។ ការតស៊ូមតិភាគច្រើនដែលយើងធ្វើ គឺជាសេចក្តីថ្លែងការណ៍និងអត្ថបទសង្ខេប" មិនមែនកើតឡើងដោយការនឹកឃើញនោះទេ ប៉ុន្តែវាជារបស់ពិសេសមួយ ដូចជាសេរីភាពលើប្រព័ន្ធអ៊ីនធើណិត”។ គំរូនៃការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់ពួកគេត្រូវពឹងផ្អែកលើការហ្វឹកហ្វឺន ស្តាប់តាមការឱ្យយោបល់ពីអ្នកណែនាំ ឬការចែករំលែកពីមិត្តភក្តិឱ្យគ្នាទៅវិញទៅមក ជាជាងគោលនយោបាយដែលបានសរសេរទុកលើក្រដាស។

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**(CCHR)

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានគោលនយោបាយរបស់ខ្លួនទាក់ទងនឹងបញ្ហាជាច្រើនដូចជា ហិរញ្ញវត្ថុ ការងារ យេនឌ័រ បរិស្ថាន និងបញ្ហាផ្សេងៗទៀត ក៏ប៉ុន្តែពួកគេមិនមានគោលនយោបាយស្រាវជ្រាវនោះទេ។ បេសកកម្មរបស់ស្ថាប័ននេះគឺ៖ "មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺជាអង្គការតស៊ូមតិមួយដែលជួយសម្រួលដល់អ្នកចូលរួមតាំងពីថ្នាក់មូលដ្ឋាន ដើម្បីពង្រឹងអំណាចសហគមន៍តាមរយៈការអប់រំអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ និងសិទ្ធិអ្នកនយោបាយ។អង្គការនេះក៏បានជួយសម្រួល ក្នុងការកសាងទំនាក់ទំនងរវាងសង្គមស៊ីវិលនៅប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិដើម្បីបង្កើនការអភិវឌ្ឍនៃការតស៊ូមតិ និងសិទ្ធិមនុស្សនៅកម្ពុជា”។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានមើលឃើញថា ការស្រាវជ្រាវគឺជាផ្នែកដ៏សំខាន់មួយក្នុងការសម្រេចបាននូវបេសកកម្មរបស់ខ្លួន បើទោះជាពួកគេមិនបានសរសេរគោលនយោបាយនៃការស្រាវជ្រាវក៏ដោយ ប៉ុន្តែពួកគេមានគំរូនៃសៀវភៅណែនាំទាក់ទងនឹងការសរសេររបាយការណ៍ និងការសង្ខេបដែលមានការកំណត់ទម្រង់មួយជាក់លាក់ផងដែរ។ ពួកគេក៏មានឯកសារស្រាវជ្រាវមួយចំនួនដែលរៀបរៀងឡើងក្នុងសិក្ខាសាលាឆ្នាំ២០១៣ ហើយនឹងធ្វើការសរសេរគម្រោង វិធីសាស្ត្រសរសេរសេចក្តីថ្លែងការណ៍ និងសង្ខេបគោលនយោបាយរៀងរាល់ពីរខែម្តងផងដែរ។ បុគ្គលិកមជ្ឈមណ្ឌលបានលើកឡើងថា នៅពេលដែលចុះទៅធ្វើការងារផ្ទាល់ គឺតម្រូវឱ្យមានការពិនិត្យលើប្រសិទ្ធភាពនៃការសម្ភាស និងធ្វើការពិភាក្សាជាមួយសមាជិកដែលចុះទៅផ្ទាល់លើវិធីសាស្ត្រផ្សេងៗ (CCHR:SR)។ ការបណ្តុះបណ្តាលនៃការងារស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើការណែនាំគ្នាទៅវិញទៅមក ពោលគឺមិនមែនជាការរៀបចំជាឯកសារផ្សេងៗនោះទេ។

**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI)

បេសកកម្មរបស់ CDRI គឺដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព និងសុខុមាលភាពរបស់ប្រជាជនរបស់ខ្លួនតាមរយៈការបង្កើតគោលនយោបាយស្រាវជ្រាវ ដែលមានគុណភាពខ្ពស់ ការផ្សព្វផ្សាយចំណេះដឹង និងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។ខណៈដែលពួកគេមិនមានគោលនយោបាយស្រាវជ្រាវជាក់លាក់នោះ៖ បេសកកម្មរបស់ពួកគេបានចង្អុលបង្ហាញយ៉ាងច្បាស់ ពីសកម្មភាពនៃការងារការស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាពរបស់ក្រុមអ្នកស្រាវជ្រាវវ័យក្មេង

នៅប្រទេសកម្ពុជា។ អតីតប្រធាន CDRI បានផ្តល់យោបល់ផ្តោតសំខាន់ទៅលើ"អភិបាលកិច្ច ជាពិសេសការធ្វើកំណែទម្រង់តាមរបៀបរិមជ្ឈការ និងវិសហមជ្ឈការ រួមជាមួយនឹងបញ្ហាដែលកំពុងកើតមាន ដូចជាកំណើននៃការអប់រំនិងការផ្លាស់ប្តូរអាកាសធាតុជាដើម"។

CDRI បានទទួលការគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC) តាមរយៈការផ្តួចផ្តើមធ្វើវេទិកាអភិវឌ្ឍន៍ការស្រាវជ្រាវ (DRF) នៅក្នុងប្រទេសកម្ពុជា ដែលមានការជំរុញពីមូលដ្ឋាន និងដៃគូនៃស្ថាប័នស្រាវជ្រាវដែលឈានមុខគេ CDRI សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងសមាគមសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ វេទិកានេះ "ផ្តល់នូវឱកាសឱ្យអ្នកបង្កើត និងអ្នកស្រាវជ្រាវវ័យក្មេង ធ្វើការចែករំលែកចំណេះដឹង និងរៀនពីគ្នាទៅវិញទៅមក ដើម្បីការកសាងសមត្ថភាពនៃការស្រាវជ្រាវរបស់ពួកគេ"។ CDRI ក៏មានការព្រួយបារម្ភផងដែររវាងគំនិតផ្តួចផ្តើមក្នុងតំបន់ជាមួយនឹង IDRC និងមូលនិធិ Rockefeller" យើងបានពង្រឹងកិច្ចសហការក្នុងតំបន់របស់យើង អភិវឌ្ឍបណ្តាញនៃការវិភាគដើម្បីបង្កើតភាពជាដៃគូរបស់ មហាអនុតំបន់ទន្លេមេគង្គ(GMS-wide)។ មួយវិញទៀតយើងខិតខំធ្វើការងារនេះ គឺដើម្បីផ្តល់សារៈសំខាន់នៃការធ្វើសមាហរណកម្មក្នុងតំបន់ និងកិច្ចសហប្រតិបត្តិការរបស់ប្រទេសកម្ពុជានាពេលអនាគត ឱ្យក្លាយទៅជា "តំបន់មួយ"។ CDRI ជាស្ថាប័នមួយដែលដើរតួនាទីយ៉ាងសកម្មសម្រាប់បណ្តាញស្រាវជ្រាវក្នុងតំបន់តាមរយៈដៃគូនៃការអភិវឌ្ឍគោលនយោបាយនិងវេទិកានានា" (CDRI:FD)។

**មជ្ឈមណ្ឌលខេមរសិក្សា** (CKS)

មជ្ឈមណ្ឌលខេមរសិក្សាគាំទ្រការស្រាវជ្រាវការបង្រៀន និងការផ្តល់សេវាសាធារណៈក្នុងវិស័យវិទ្យាសាស្ត្រសង្គម សិល្បៈនិងមនុស្សសាស្ត្រនៅប្រទេសកម្ពុជា ព្រមទាំងប្រទេសក្នុងតំបន់ទន្លេមេគង្គ។ មជ្ឈមណ្ឌលខេមរសិក្សាគឺជាស្ថាប័នស្រាវជ្រាវមួយ ដែលគាំទ្រដល់ការងារស្រាវជ្រាវ ប៉ុន្តែមិនធ្វើការស្រាវជ្រាវនោះទេ។ ហេតុដូច្នេះ មជ្ឈមណ្ឌលខេមរសិក្សាជំរុញឱ្យមានការស្រាវជ្រាវ និងការផ្លាស់ប្តូរការស្រាវជ្រាវជាលក្ខណៈអន្តរជាតិ ហើយកម្មវិធីនេះបានជួយបង្កើនការយល់ដឹងដល់ប្រទេសកម្ពុជា និងប្រទេសក្នុងតំបន់។ មជ្ឈមណ្ឌលនេះព្យាយាមពង្រឹងវប្បធម៌របស់ប្រទេសកម្ពុជា និងរចនាសម្ព័ន្ធអប់រំ ហើយក៏បានបញ្ចូលបណ្ឌិតកម្ពុជាមួយចំនួនឱ្យទៅចូលរួមក្នុងកម្មវិធីនៃការផ្លាស់ប្តូរថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ (CKS:PR)។ ទាំងអស់នេះក៏ជាគោលបំណងមួយក្នុងការលើកកម្ពស់សង្គមស៊ីវិលឱ្យមានភាពរឹងមាំផងដែរ។ ការវាយតម្លៃបន្ថែមទៀតគឺចាំបាច់ត្រូវធ្វើការវាស់ស្ទង់ទៅលើភាពជោគជ័យនៃការលើកកម្ពស់ភាពយល់ដឹងរបស់អ្នកជំនាញ នៃការស្រាវជ្រាវជាសាធារណៈនិងសកម្មភាពរបស់ស្ថាប័ននីមួយៗ ដែលធ្វើការផ្សារភ្ជាប់គ្នាទៅនឹងទំនាក់ទំនងរបស់បណ្ឌិតនៅកម្រិតជាតិនិងកម្រិតអន្តរជាតិ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា** (DC-Cam)

មជ្ឈមណ្ឌលឯកសារកម្ពុជាមានមោទនភាពក្នុងនាមជាស្ថាប័នដំបូងគេបង្អស់ក្នុងតំបន់ ដែលបានឧទ្ទិសដល់ការរកឃើញការពិតនៅពីក្រោយអំពើឃោរឃៅជាច្រើនក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងចង់អប់រំ បណ្ដុះបណ្ដាលសិស្ស និស្សិត និងអ្នកដឹកនាំវ័យក្មេង ដែលប្រកបទៅដោយមនុស្សធម៌ យុត្តិធម៌ និងសមធម៌ ជាមួយនឹងការស្រឡាញ់សន្តិភាព និងបុគ្គលដែលមានកម្លាំងចិត្តជំរុញឱ្យមានការផ្លាស់ប្ដូរនៅក្នុងប្រទេសកម្ពុជា ទាំងក្នុងតំបន់ និងនៅជុំវិញពិភពលោក ដើម្បីយកចំណេះដឹងជំនាញវិជ្ជាជីវៈរបស់ពួកគេធ្វើការសិក្សាស្រាវជ្រាវពីប្រទេសកម្ពុជាទាំងអតីតកាលបច្ចុប្បន្ន និងនាពេលអនាគត។

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើតាមគោលដៅដូចខាងក្រោមនេះ៖

- ដើម្បីក្លាយជាអ្នកដឹកនាំក្នុងការស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- បណ្ដុះគំនិតឱ្យមានវប្បធម៌នៃការស្រាវជ្រាវសម្រាប់បញ្ញវន្តនៃប្រទេសកម្ពុជានាពេលខាងមុខ
- ដើម្បីធ្វើការស្វែងរកមធ្យោបាយក្នុងការកសាងសន្តិភាពយុត្តិធម៌ លើកកម្ពស់ការផ្សះផ្សាជាតិ នឹងក្លាយទៅជាស្ថាប័នបណ្ដុះបណ្ដាលដែលមានវប្បធម៌អហិង្សា ដើម្បីកសាងសង្គមកម្ពុជាប្រកបទៅដោយមនុស្សធម៌ មានយុត្តិធម៌ក្នុងសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព។

ដើម្បីធ្វើការអភិរក្សប្រវត្តិសាស្ត្រនិងរំឭកដល់អ្នកដែលបានស្លាប់ ឬរស់រានមានជីវិតពីអំពើសម្លាប់យ៉ាងរង្គាលខ្មែរក្រហមនៅកម្ពុជា ក៏ដូចជាអំពើឃោរឃៅនៅបណ្ដាលប្រទេសផ្សេងៗទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ (DCCAM:D)។

## ករណីសិក្សា៖ ខុមហ្វ្រែល - វិធីសាស្ត្រនៃស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងទិន្នន័យ

យើងជ្រើសរើសអង្គការនេះ មកធ្វើជាករណីសិក្សាដោយសារតែ អង្គការនេះមានការយកចិត្តទុកដាក់ និងចំណាយពេលជាច្រើនក្នុងការបណ្តុះបណ្តាលនៅគ្រប់កម្រិត មុនពេលពួកគេចាប់ផ្តើមធ្វើការស្រាវជ្រាវនេះ។ វាក៏ជារឿងគួរឱ្យកត់សម្គាល់មួយផងដែរ ដោយសារតែជំហានដែលពួកគេធ្វើដើម្បីទទួលបានភាពត្រឹមត្រូវ និងសុពលភាពនៃការរកឃើញនោះ វាបង្ហាញលទ្ធផលមុនពេលដែលពួកគេធ្វើការបោះពុម្ពផ្សាយទៅទៀត។ ការស្រាវជ្រាវទៅលើគណៈកម្មាធិការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានផ្តោតសំខាន់លើការស្ទង់មតិជាស្ថិតិនៅក្នុងចំណុចចំនួនបួន៖ សវនកម្មទៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត (ហើយយកទៅប្រៀបធៀបជាមួយនឹងបញ្ជីឈ្មោះបោះឆ្នោតថ្នាក់ជាតិនៃប្រទេសកម្ពុជា អ្នកចូលរួមបោះឆ្នោត និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ) - ការប្រព្រឹត្តទៅនៃការបោះឆ្នោត ការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន និងវិមជ្ឈការ (អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ) ការបោះឆ្នោតស្របគ្នាជាមួយនឹងចំនួនដែលបានរាប់ និងការចូលរួមបោះឆ្នោតពីសំណាក់ជនពិការ (Com:B)។

នាយកខុមហ្វ្រែលបានឱ្យដឹងថា ពួកគេផ្តោតសំខាន់ទៅលើ យុទ្ធសាស្ត្រនៃការស្រាវជ្រាវ ដែលរួមមានការសរសេរទៅការអនុវត្តលក្ខខណ្ឌផ្សេងៗ គោលបំណង វិធីសាស្ត្រ កាលវិភាគ ក្រមសីលធម៌ ការបណ្តុះបណ្តាល និង "ការបញ្ជាក់ពីអ្នកសម្ភាសដើម្បីធានាថាពួកគេមានសមត្ថភាពអាចធ្វើការស្រាវជ្រាវនេះបាន"(Com:A)។ ជាដំបូងក្រុមអ្នកស្រាវជ្រាវរបស់ខុមហ្វ្រែល បានធ្វើការអភិវឌ្ឍវិធីសាស្ត្ររបស់ពួកគេ និងរៀបចំជាកម្រងសំណួរ ហើយបន្ទាប់មកធ្វើការហ្វឹកហ្វឺនអ្នកប្រមូលទិន្នន័យរបស់ពួកគេ។ បន្ទាប់មកទៀត ក្រុមអ្នកស្រាវជ្រាវ បានចុះទៅប្រមូលទិន្នន័យដោយផ្ទាល់នៅតាមតំបន់ផ្សេងៗ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃការស្រាវជ្រាវ ហើយក៏ត្រូវសុំការការអនុញ្ញាតមុនពេលសម្ភាសផងដែរ។ ខុមហ្វ្រែលមានបណ្តាញបង្គោលក្នុងតំបន់ (តំណែងស្ម័គ្រចិត្ត) នៅខេត្ត ស្រុក និងឃុំ ដែលត្រូវបានគេនាំយកមកកាន់រាជធានីភ្នំពេញ ដើម្បីបណ្តុះបណ្តាលក្នុងវិធីសាស្ត្រនៃការស្ទង់មតិ។ ក្នុងក្រុមស្រាវជ្រាវនីមួយៗ អ្នកដឹកនាំក្រុមដើរតួនាទីជាអ្នកត្រួតពិនិត្យមើលលើការប្រមូលទិន្នន័យដើម្បីធានាឱ្យបានថា ទិន្នន័យដែលទទួលបានគឺត្រឹមត្រូវនិងច្បាស់លាស់ (Com:B)។ នៅថ្នាក់ខេត្តលេខាធិការដ្ឋានខុមហ្វ្រែលបានធ្វើការកែសម្រួលទិន្នន័យទាំងនោះ មុនពេលបញ្ជូនទៅកាន់ការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ នៅថ្នាក់ជាតិ អ្នកស្រាវជ្រាវ ឬអ្នកគ្រប់គ្រងកម្មវិធីបានពិនិត្យលើទិន្នន័យនេះជាថ្មីម្តងទៀត។ មុនពេលចេញជារបាយការណ៍ខុមហ្វ្រែលពេលខ្លះ បានធ្វើកិច្ចសន្យាជាមួយអង្គការដៃគូដទៃទៀតដើម្បីពិនិត្យមើល និងវិភាគលើកិច្ចការទាំងនោះ (Com:A)។ ពួកគេទទួលបានមូលនិធិពីម្ចាស់ជំនួយស្នូលអន្តរជាតិ (Norwegian People Aid (NPA), OXFAM, Forum sheet, National Democratic Institutute (NDI), ស្ថានទូតចក្រភពអង់គ្លេស) និងមូលនិធិទំហំតូចពីម្ចាស់ជំនួយក្នុងស្រុក។

**កម្មវិធីស្រាវជ្រាវសម្រាប់ថ្នាក់មិនទាន់បញ្ចប់និងថ្នាក់បញ្ចប់នៃគ្រឹះស្ថានឧត្តមសិក្សា** (HEI)

ការស្រាវជ្រាវរបស់យើងបានរកឃើញថា និស្សិតនៅសាកលវិទ្យាល័យមួយចំនួនត្រូវបានជំរុញឱ្យចូលរួមនៅក្នុងការងារស្រាវជ្រាវ និងជាច្រើនអ្នកទៀតបានចាប់យកវគ្គសិក្សាពីវិធីសាស្ត្រនៃស្រាវជ្រាវ (ជាធម្មតានៅកម្រិតបរិញ្ញាបត្រថ្នាក់ និងថ្នាក់ឆ្នាំទី៤)។ ភាគច្រើននៃការសិក្សាថ្នាក់អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រមួយចំនួនគឺតម្រូវឱ្យមានការសរសេរនិក្ខេបបទស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សារបស់ពួកគេ បើទោះបីជាមានការប្រែប្រួលក៏ដោយ ហើយសាកលវិទ្យាល័យមួយចំនួនទៀតបានផ្តល់នូវជម្រើសក្នុងការប្រឡងវគ្គផ្តាច់ព្រ័ត្រសម្រាប់ពួកគេ។ ឧទាហរណ៍ បច្ចុប្បន្ននេះសាកលវិទ្យាល័យជាតិគ្រប់គ្រងមានថ្នាក់បណ្ឌិតជាន់ខ្ពស់ ដែលមានអ្នកស្រាវជ្រាវថ្នាក់បណ្ឌិតនេះចំនួន ២០នាក់ (NUM:PR)។ និស្សិតដែលបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យជាតិគ្រប់គ្រងបានរៀបរាប់ពីតម្រូវការរបស់ថ្នាក់បណ្ឌិត គឺត្រូវបញ្ចប់គ្រប់វគ្គទាំងអស់ (រួមទាំងវគ្គសិក្សានៃការស្រាវជ្រាវ) និងការធ្វើការស្រាវជ្រាវ (ដោយផ្អែកលើគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងអ្នកគ្រប់គ្រងនិងសហអ្នកគ្រប់គ្រងពីរូបទៀត)។ អ្នកគ្រប់គ្រងត្រូវមានការយល់ដឹងពីប្រធានបទនៃការស្រាវជ្រាវនោះ (NUM:SRT)។ សិស្សនិស្សិតជាច្រើនបាននិយាយថា មានអ្នកគ្រប់គ្រងមួយចំនួនមានជំនាញនិងធ្វើការងារនេះប្រកបដោយគុណភាពខ្ពស់ (NUM:SRT)។ ដំណើរការនៃការធ្វើនិក្ខេបបទនេះ គឺតម្រូវឱ្យមានការស្រាវជ្រាវការវិភាគការពិនិត្យឡើងវិញពីសំណាក់អ្នកពិនិត្យ (Peer Review) និងការការពារ។ គម្រោងនៃនិក្ខេបបទត្រូវបានវាយតម្លៃដោយគណៈកម្មាធិការ មុនពេលចុះទៅធ្វើការងារស្រាវជ្រាវនោះផ្ទាល់។ ក្នុងអំឡុងពេលចុះធ្វើការស្រាវជ្រាវផ្ទាល់ គឺតម្រូវឱ្យមានការត្រួតពិនិត្យ ដែលរួមបញ្ចូលទាំងការពិនិត្យមើលភាពរីកចម្រើននៃការវាយតម្លៃពិនិត្យលើបទដ្ឋាននានា និងពិនិត្យឡើងវិញទៅលើទិន្នន័យដែលទទួលបាន។ ប្រសិនបើមានការយល់ព្រមទៅលើនិក្ខេបបទ នោះនឹងឈានទៅដល់ការការពារដើម្បីបញ្ចប់។នេះគឺជាការឆ្លើយតបរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រងទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ និងមានការអនុម័តពីក្រសួងដើម្បីទទួលបានសញ្ញាបត្រជាបណ្ឌិតជាន់ខ្ពស់។ ត្រូវការចំនួន ៥៤ក្រេឌីតដើម្បីបញ្ចប់បណ្ឌិតជាន់ខ្ពស់នេះបាន។ កម្មវិធីបណ្ឌិតនេះត្រូវបានរចនាឡើងដើម្បីបំពេញតាមស្តង់ដារអន្តរជាតិនៃ AUN (បណ្តាញសាកលវិទ្យាល័យអាស៊ាន)។ ទាំងអស់នេះបានបង្កើនឱ្យមានការប្រកួតប្រជែងរបស់សាកលវិទ្យាល័យនានា និងបង្កើនបណ្តាញទំនាក់ទំនងទាំងក្នុងតំបន់ និងធាកអន្តរជាតិ (NUM:SRT)។ ប្រសិនបើសិស្សមិនជាប់នោះ ពួកគេត្រូវតម្រូវឱ្យធ្វើឡើងវិញ ឬអាចផ្លាស់ប្តូរប្រធានបទ។ ការកំណត់ពេលវេលាសម្រាប់ការសិក្សាថ្នាក់បណ្ឌិតនោះគឺមានរយៈពេល ៦ឆ្នាំសម្រាប់និស្សិតពេញម៉ោងនិង ៨ឆ្នាំសម្រាប់និស្សិតក្រៅម៉ោង (NUM:SRT)។

សាកលវិទ្យាល័យនៃតំបន់អាស៊ីអាគ្នេយ៍ (USEA) ផ្តល់ឱ្យអ្នកដែលបញ្ចប់ការសិក្សា ឬអ្នកមិនទាន់បញ្ចប់បរិញ្ញាបត្រធ្វើការសិក្សាលើវគ្គវិធីសាស្ត្រនៃការស្រាវជ្រាវ និងវិជ្ជាជីវៈដែលផ្តោតសំខាន់ទៅ

លើការសរសេរ (USEA:F4) ហើយសិស្សទាំងអស់នៃUSEA ត្រូវតែសរសេរ (ជាក្រុម) និក្ខេបបទមួយមុនពេលពួកគេអាចបញ្ចប់ការសិក្សា (USEA:VPR)។ និស្សិតទាំងអស់បានរំពឹងថា ពួកគេនឹងបង្ហាញស្នាដៃរបស់ខ្លួនបន្ទាប់ពីបញ្ចប់ការចុះទៅធ្វើការស្រាវជ្រាវដោយផ្ទាល់ ក្នុងការចូលរួមសិក្ខាសាលានានាដើម្បីជួយពួកគេ "ធ្វើឱ្យនិក្ខេបបទរបស់ពួកគេមានភាពល្អប្រសើរជាងមុនដូចជាមានភាពសមហេតុផលច្រើន និងលក្ខណៈវិទ្យាសាស្ត្រពិត" (USEA:F1)។ គណៈកម្មាធិការផ្ទៃក្នុងរបស់សាកលវិទ្យាល័យដែលមានសមាជិកចំនួន ៤-៥នាក់មានតួនាទីត្រួតពិនិត្យឯកសារស្រាវជ្រាវរបស់និស្សិតមុនពេលពួកគេបញ្ចប់ការសិក្សា(USEA:DR)។ សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវបានជ្រើសរើសដើម្បីឱ្យប្រតិបត្តិតាមបទដ្ឋានដែលបានកំណត់ដោយក្រសួងអប់រំ។ ពួកគេមានកញ្ចប់ថវិកាចំនួន២.៤០០$ សម្រាប់ការធ្វើសកម្មភាពស្រាវជ្រាវដែលដឹកនាំដោយសាស្ត្រាចារ្យ និងនិស្សិត ហើយក៏បានអញ្ជើញសិស្សនិស្សិតផ្សេងទៀតឱ្យចូលរួមក្នុងសិក្ខាសាលានោះ ដើម្បីជ្រើសរើសសិស្សនិស្សិតឱ្យជួយក្នុងការងារស្រាវជ្រាវនោះផងដែរ។ USEA បានចេញផ្សាយសៀវភៅចំនួន ៤៩៨ក្បាល។ និស្សិតនៅសាកលវិទ្យាល័យ USEA បានយល់ឃើញពីតម្លៃនៃការស្រាវជ្រាវ បូករួមជាមួយការធ្វើលំហាត់ និងកិច្ចការសាលាផ្សេងៗដែលតម្រូវឱ្យសិស្សនិស្សិតទាំងអស់ធ្វើការស្រាវជ្រាវ (តាមរយៈការអានសៀវភៅ និងការស្វែងរកព័ត៌មានផ្សេងតាមអ៊ីនធើណិត) ក្នុងគោលបំណងដើម្បីបង្កើនចំណេះដឹងលើកទឹកចិត្ត និងស្វែងរកការពិតនៅពេលពួកគេធ្វើការងារសាលា និងធ្វើលំហាត់ទាំងនោះ(USEA:SRT)។

នៅសាកលវិទ្យាល័យមានជ័យ (MCU) និស្សិតឆ្នាំទី៤ និស្សិតក្នុងមុខវិជ្ជាមួយចំនួនបានរៀនវគ្គជំនាញនៃការស្រាវជ្រាវ (MCU:Dean4) និងការសរសេរនិក្ខេបបទមួយដោយផ្អែកទៅលើការស្រាវជ្រាវជាបឋម (MCU:SRT)។ និស្សិតដែលរៀនមុខវិជ្ជាមួយចំនួនដូចជា IT គឺមិនតម្រូវឱ្យសរសេរនិក្ខេបបទចេញនោះទេ ពោលពួកគេត្រូវផ្តោតសំខាន់ទៅលើការងារជាក្រុម ដែលផ្តល់ឱកាសឱ្យពួកគេកាន់តែច្រើនក្នុងការសិក្សា និងចូលរួមក្នុងសកម្មភាពស្រាវជ្រាវផ្សេងៗ។ សិស្សនិស្សិតក៏បានបញ្ជាក់បន្ថែមដែរថា សាកលវិទ្យាល័យបានផ្តល់ការគាំទ្រក្នុងកិច្ចសហការជាមួយស្ថាប័នដទៃផងដែរ ដោយឱ្យពួកគេធ្វើការជាមួយដៃគូមកពីខាងក្រៅសម្រាប់ការស្រាវជ្រាវ ដែលមានដូចជាអង្គការ World Vision សាកលវិទ្យាល័យអាល្លឺម៉ង់(ការស្រាវជ្រាវលើបណ្តាញជានារ៉ាប់រង) និងក្រុមហ៊ុនមួយដែលគេហៅថា River Orchid Inside (ការស្រាវជ្រាវលើទីផ្សារ) (MCU:SRT)។ ទោះជាយ៉ាងណា ក៏ពួកគេមានការត្អូញត្អែរចំពោះភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល និងមិនមានទំនាក់ទំនងគ្រប់គ្រាន់ជាមួយប្រជាជនក្នុងតំបន់ (MCU:SRT)។

សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) បានផ្តល់ការសិក្សាកម្រិតខ្ពស់សម្រាប់ថ្នាក់បរិញ្ញាបត្រដើម្បីធ្វើការលើគម្រោងដែលទាក់ទងនឹងការផ្តល់ថវិកាពីម្ចាស់ជំនួយសម្រាប់ពង្រីកខ្លួនបន្ថែមទៀតលើការស្រាវជ្រាវផ្នែកកសិកម្ម។ និស្សិតដែលសិក្សាថ្នាក់បរិញ្ញាបត្រកម្រិតខ្ពស់ ត្រូវតែ

សរសេរនិក្ខេបបទដើម្បីបញ្ចប់ការសិក្សា (RUA:PR) ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ជំនួយការសាស្ត្រាចារ្យ ក្នុងកិច្ចការការស្រាវជ្រាវនោះ។ ឧទាហរណ៍នៅក្នុងការពិភាក្សាគុម្ពមាននិស្សិតចំនួន៨នាក់ ដែលពួកគេទាំង ៨នាក់នោះបានចូលរួមក្នុងគម្រោងស្រាវជ្រាវ ដោយចុះទៅធ្វើការងារផ្ទាល់នៅតាមតំបន់នៃខេត្តនីមួយៗ (RUA:SRT)។ សិស្សនិស្សិតបានរាយការណ៍ពីអ្វីដែលពួកគេទទួលបានដូចជា ការបណ្តុះបណ្តាលផ្នែកវិភាគទិន្នន័យការងារចុះទៅមូលដ្ឋានផ្ទាល់ និងការសរសេររបាយការណ៍ផងដែរ (RUA:SRT)។ទោះយ៉ាងណាក៏ដោយ សិស្សនិស្សិតបានកត់សម្គាល់ឃើញថាពួកគេមិនសូវយល់ពីគោលការណ៍ណែនាំរបស់សាកលវិទ្យាល័យ ដែលទាក់ទងនឹងការលួចចម្លង និងបទដ្ឋាននៃឯកសារយោងផ្សេងៗទេ ហើយក៏បានបន្ថែមទៀតថា ពួកគេត្រូវតែចូលរួមក្នុងដំណើរការនៃការសរសេរទិនានុប្បវត្តិ និងស្វែងរកប្រភពដោយខ្លួនឯង (RUA:SRT)។

និស្សិតថ្នាក់បរិញ្ញាបត្រភាគច្រើននៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ធ្វើរបាយការណ៍ស្រាវជ្រាវ និងនិស្សិតថ្នាក់អនុបណ្ឌិតធ្វើនិក្ខេបបទស្រាវជ្រាវ (RULE;F2)។ និស្សិតភាគច្រើនធ្វើការស្រាវជ្រាវប្រកបដោយគុណភាព (ប្រហែល ២០% ធ្វើការស្រាវជ្រាវគិតលើបរិមាណ)។ និស្សិតបានឱ្យដឹងថា សាកលវិទ្យាល័យនេះផ្តល់នូវអាទិភាពដល់សិស្សនិស្សិតដែលពូកែៗ ដោយឱ្យពួកគេមានឱកាសដើម្បីធ្វើការស្រាវជ្រាវសម្រាប់បញ្ចប់ការសិក្សា (RULE:SRT)។ វគ្គសិក្សាស្រាវជ្រាវនោះមានឈ្មោះថា "វិធីសាស្ត្រនៃការស្រាវជ្រាវ"នៅក្នុងឆ្នាំទី៣ និងទី៤ (RULE;SRT)។

នៅសាកលវិទ្យាល័យស្វាយរៀង (SRU) និស្សិតក្នុងមហាវិទ្យាល័យកសិកម្មតម្រូវឱ្យធ្វើការស្រាវជ្រាវដើម្បីសរសេរគម្រោងថ្នាក់បញ្ចប់នៃការសិក្សារបស់ខ្លួន (SRU:F1,F2,F3)។ សមាជិកនៃមហាវិទ្យាល័យទាំងអស់បានប្រាប់ថា មហាវិទ្យាល័យភាគច្រើន លើកលែងតែមហាវិទ្យាល័យកសិកម្មមិនដែលបាននាំនិស្សិតចុះធ្វើការសិក្សានៅមូលដ្ឋានផ្ទាល់នោះទេ ហើយនិស្សិតនៅក្នុងមហាវិទ្យាល័យគ្រប់គ្រង និងរដ្ឋបាលសាធារណៈ បានធ្វើការស្រាវជ្រាវតិចណាស់ ព្រោះពួកគេជ្រើសរើសយកការប្រឡងវគ្គផ្តាច់ព្រ័ត្រជាជាងការសរសេរនិក្ខេបបទ។ នៅមហាវិទ្យាល័យកសិកម្ម សាស្ត្រាចារ្យមានក្រុមស្រាវជ្រាវមួយសម្រាប់និស្សិតធ្វើការពិសោធ។ ពួកគេមិនមានថ្នាក់ស្រាវជ្រាវជាក់លាក់ណាមួយសម្រាប់ឱ្យសិស្សទាំងអស់សិក្សានោះទេ ប៉ុន្តែមហាវិទ្យាល័យខ្លះមានវគ្គសិក្សាសម្រាប់ការស្រាវជ្រាវនៅក្នុងនោះផងដែរ (SRU:SRT)។ និស្សិតបានរាយការណ៍ថា សាកលវិទ្យាល័យមានទីប្រឹក្សាសម្រាប់ណែនាំនិស្សិតក្នុងការសរសេរគម្រោងសម្រាប់ថ្នាក់បញ្ចប់ និងការសរសេរនិក្ខេបបទ ហើយព្រមទាំងការផ្តល់នូវធនធានមួយចំនួន ដូចជាបណ្ណាល័យ និងប្រព័ន្ធ Wi-Fi ផងដែរ (SRU:SRT)។ មួយវិញទៀត និស្សិតក៏ត្រូវបានបញ្ជូនឱ្យធ្វើទស្សនកិច្ចសិក្សាក្នុងក្រុមហ៊ុនសាធារណៈ និងឯកជនមួយចំនួន ប៉ុន្តែមិនអាចជួយពួកគេក្នុងការស្វែងរកចម្លើយណាមួយដែលគេចង់បាននោះទេ (SRU:SRT)។ និស្សិតម្នាក់បាន

ប្រាប់យើងថា "មិនមានសិស្សណាម្នាក់ត្រូវបានចូលរួមនៅក្នុងសកម្មភាពនៃស្រាវជ្រាវនោះទេ" (SRU:SRT)។ ទោះយ៉ាងណាក៏ដោយ សាកលវិទ្យាល័យនេះមានការិយាល័យស្រាវជ្រាវមួយផ្ទាល់ខ្លួន ដែលនិស្សិតមួយចំនួនបានកត់សម្គាល់ឃើញថា គម្រោងផ្សេងៗនៃការស្រាវជ្រាវដែលពួកគេចូលរួមនោះ ត្រូវតែមានភាពជាក់លាក់ (បង្ហាញថា និស្សិតដែលធ្វើឱ្យគម្រោងនៃស្រាវជ្រាវកើតឡើងនោះ មានតែនៅក្នុងនាយកដ្ឋាន ឬក្នុងមហាវិទ្យាល័យជាក់លាក់ណាមួយប៉ុណ្ណោះ ជាក់ស្តែងដូចជាក្នុងវិស័យកសិកម្ម)។ ការផ្លាស់ប្តូររបស់និស្សិតនេះបានបង្ហាញពីដំណើរការនៃការផលិតការស្រាវជ្រាវ និងជាពិសេសបង្ហាញពីវិធីសាស្រ្តជាក់លាក់របស់យើងក្នុងការប្រមូលយកទិន្នន័យដែលមានគុណភាព ភាពបើកចំហនៃការសន្ទនាគ្នា កសាងការយល់ដឹង និងវប្បធម៌នៃការស្រាវជ្រាវតាមរយៈការប្រមូលទិន្នន័យទាំងនោះ។

នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងវិទ្យាស្ថានភាសាបរទេសសិស្សនិស្សិតថ្នាក់បរិញ្ញាបត្រទាំងអស់រៀនវគ្គស្រាវជ្រាវនៅក្នុងឆ្នាំទីបី។ ចាប់ពីឆ្នាំទី២ ទៅសាកលវិទ្យាល័យតម្រូវឱ្យនិស្សិតបង្កើតគម្រោងស្រាវជ្រាវរួមគ្នាមួយជារៀងរាល់ឆ្នាំរហូតដល់ពេលបញ្ចប់ការសិក្សា(គម្រោងស្រាវជ្រាវរួមគ្នាសរុបចំនួនបី)។ និស្សិតកិត្តិយសទាំងអស់នឹងធ្វើគម្រោងស្រាវជ្រាវឯករាជ្យមួយនៅឆ្នាំទី៤ (RUPPIFL:SRT)។ និស្សិតម្នាក់បានកត់សម្គាល់ឃើញថា ការឆាប់ចាប់ផ្តើមចូលរួមអនុវត្តការស្រាវជ្រាវនៅថ្នាក់បរិញ្ញាបត្រនេះគឺជាផលប្រយោជន៍មួយក្នុងការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖ "ខ្ញុំបានសិក្សានៅក្នុងសាកលវិទ្យាល័យមួយផ្សេងទៀត ហើយពួកគេបានចាប់ផ្តើមបណ្តុះបណ្តាលឱ្យធ្វើការស្រាវជ្រាវនៅក្នុងឆ្នាំទី៣ ខ្ញុំគិតថា វាដូចជាយឺតពេកហើយសម្រាប់ខ្ញុំ ក្នុងការយល់ដឹង និងអនុវត្តការស្រាវជ្រាវនេះខ្លួនឯង។ ឥឡូវនេះ យើងចាប់ផ្តើមធ្វើវាលឿនជាមុន ហើយខ្ញុំក៏បានរៀននិងអានបន្ថែមបានច្រើនដែរ" (RUPPIFL:SRT)។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានបង្កើតកម្មវិធីប្រកួតប្រជែងសម្រាប់និស្សិតឆ្នាំទី៣ទៅលើការស្រាវជ្រាវជារៀងរាល់ឆ្នាំ ហើយកម្មវិធីនេះបានរៀបចំឡើងដោយវិទ្យាស្ថានអភិវឌ្ឍន៍កម្ពុជា (CDI) នៃសាកលវិទ្យាល័យនេះ។ ជាដំបូង និស្សិតទាំងអស់ត្រូវយកកិច្ចការរបស់គេទៅឱ្យអ្នករៀបចំកម្មវិធី បន្ទាប់អ្នករៀបចំកម្មវិធីធ្វើការជ្រើសរើសយកឯកសារដែលល្អជាងគេចំនួនបីមកធ្វើការបោះពុម្ពផ្សាយ និងឡើងធ្វើបទបង្ហាញ(RUPPIFL:SRT)។

**គុណភាពឧត្តមសិក្សា និងសមត្ថភាពកែលម្អគម្រោង** (HEQCIP)

គុណភាពឧត្តមសិក្សានិងសមត្ថភាពកែលម្អគម្រោង បានផ្តល់ថវិកាដោយធនាគារពិភពលោករួមជាមួយនឹងក្រសួងហិរញ្ញវត្ថុ ដែលវាគឺជាសមាសភាគមួយក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យចំនួន២២ (សាធារណៈនិងឯកជន) ហើយនឹងយកថវិកាទាំងនោះ ទៅធ្វើការសិក្សាស្រាវជ្រាវលើគម្រោងចំនួន៤៥ខុសៗគ្នា។ អ្នកតំណាងរបស់ធនាគារពិភពលោកបានបញ្ជាក់ថា៖ "ក្រសួងអប់រំបានទាមទារឱ្យមានគម្រោងស្រាវជ្រាវសម្រាប់គ្រឹះស្ថានឧត្តម

សិក្សានេះ ព្រោះមិនទាន់មានការគាំទ្រណាមួយសម្រាប់ថ្នាក់ឧត្តមសិក្សានោះទេ។ រដ្ឋាភិបាលបារាំងបានគាំទ្រដល់សាកលវិទ្យាល័យជាច្រើនរួមមានសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យច្បាប់ សាកលវិទ្យាល័យRUA និងសាកលវិទ្យាល័យមួយចំនួនទៀតផងដែរ ប៉ុន្តែមិនមានការគាំទ្រជាទូទៅដើម្បីអភិវឌ្ឍស្ថាប័នសម្រាប់ឧត្តមសិក្សានោះទេ។

ដំណាក់កាលដំបូងនៃគម្រោងនេះគឺចាប់ពីឆ្នាំ២០១០-២០១៤ ដែលគេបានធ្វើការដឹកនាំដើម្បីកែលម្អវិស័យអប់រំបឋមសិក្សា និងមធ្យមសិក្សា។ រដ្ឋមន្ត្រីក្រសួងអប់រំបានប្រកាន់នូវគោលនយោបាយដែលផ្តល់អាទិភាពក្នុងការពង្រឹងវិស័យអប់រំក្នុងកម្រិតបឋមសិក្សា។ ផ្នែកមួយនៃគម្រោងនេះត្រូវបានបញ្ចប់និងគម្រោងរបស់គ្រឹះស្ថានឧត្តមសិក្សាបន្តធ្វើវាសម្រាប់ឆ្នាំ២០១៤-២០១៥។ ថវិកាត្រូវបានប្រើសម្រាប់អភិវឌ្ឍឱ្យទៅជាស្តង់ដារ និងសម្រាប់ធ្វើកិច្ចការនេះក្នុងដំណាក់កាលចំនួនពីរ។ ដំណាក់កាលដំបូងគឺដើម្បីផ្តល់ឧបករណ៍សម្រាប់ការស្រាវជ្រាវ ឬគ្រឿងបរិក្ខារផ្សេងៗ និងការបណ្តុះបណ្តាលអ្នកស្រាវជ្រាវ ហើយជំហានទីពីរនោះ គឺដើម្បីផ្តល់ទុនដល់គម្រោងស្រាវជ្រាវដែលបានបង្កើតឡើងដោយក្រុមអ្នកស្រាវជ្រាវ មានចំនួន៣0 លើ៤0នៃគម្រោងដែលបានបញ្ចប់ហើយនោះ (WB1)។ ថវិកាភាគច្រើនរបស់ធនាគារពិភពលោក ត្រូវបានគេយកទៅបង្កើតឱ្យទៅជាស្តង់ដាររួមមួយដែលមានការទទួលស្គាល់ "សម្រាប់ធនាគារពិភពលោកប្រព័ន្ធទទួលស្គាល់គុណភាពគឺជាកត្តាសំខាន់ណាស់សម្រាប់ការវាស់ស្ទង់ភាពជោគជ័យនៃកម្មវិធីនេះ ដូច្នេះយើងកំពុងតែបង្កើតវាឡើង" (WB1)។

នេះគឺជាអ្វីដែលបង្ហាញថា សកម្មភាពផ្សេងៗនៃគោលនយោបាយដើម្បីកែលម្អគុណភាពអប់រំត្រូវបានដឹកនាំឱ្យទៅឆ្ងាយពីកម្រិតនៃការអប់រំថ្នាក់ជាតិ ហើយនៅក្នុងកម្រិតអន្តរជាតិ ម្ចាស់ជំនួយបានកំណត់ឱ្យ ប្រើប្រាស់វិធីសាស្ត្រផ្សេងៗ និងគិតទៅលើលទ្ធផលជាអាទិភាព។ ដំណើរការរបស់ម្ចាស់ជំនួយនេះបានជំរុញឱ្យមានភាពទប់ស្កាត់នូវគ្រោះថ្នាក់ផ្សេងៗក្នុងការអភិវឌ្ឍការស្រាវជ្រាវនៅក្នុងសហគមន៍ ហើយការលើកទឹកចិត្តសម្រាប់ផលិតការស្រាវជ្រាវនេះ ដែលមិនត្រូវបានកំណត់ដោយអ្នកស្រាវជ្រាវ ឬស្ថាប័ននេះណាមួយនោះទេ។ ការផ្តោតសំខាន់ទៅលើការអប់រំកម្រិតបឋមនេះមានន័យថា លទ្ធផលមួយចំនួនត្រូវបានគេយកទៅវាស់វែងតែនៅក្នុងរយៈពេលវែងប៉ុណ្ណោះ។បញ្ហាប្រឈមនោះ គឺវាអាចនឹងនាំឱ្យមានភាពយឺតពេលសម្រាប់សិស្សនិស្សិតក្នុងកម្រិតឧត្តមសិក្សា។ ផលវិបាកនោះគឺការពង្រឹងការអប់រំកម្រិតបឋមសិក្សាត្រូវការកសាងមូលដ្ឋានគ្រឹះនៅទូទាំងប្រទេស ប៉ុន្តែវាមិនបានបំពេញតម្រូវការទីផ្សារការងារក្នុងការអភិវឌ្ឍជំនាញនៃការស្រាវជ្រាវថ្នាក់ជាតិ និងសមត្ថភាពនៃការវិភាគនោះទេ។ ភាពទន់ខ្សោយជាក់ស្តែងមួយនៃក្របខ័ណ្ឌគោលនយោបាយនេះគឺការផ្តោតសំខាន់ទៅលើលទ្ធផល (ស្តង់ដារឱ្យមានការទទួលស្គាល់) ជាជាងលទ្ធផល (ការវាស់ទំហំលើគុណភាពដែលសម្រេចបាន)។ ទាំងនេះគឺជាការផ្តោតសំខាន់ទៅលើភាពកម្សោយនៃការអភិវឌ្ឍឧបករណ៍សម្រាប់ធ្វើ

ការវាស់វែងទៅលើការផ្ទេរជំនាញពិត និងវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាព ក្នុងការធ្វើសកម្មភាពបន្ថែមទៀត ។

នៅក្នុងគម្រោងនេះ គោលបំណងចម្បងរបស់ធនាគារពិភពលោក គឺចង់ធ្វើការផ្សារភ្ជាប់ទំនាក់ទំនងជាមួយសាកលវិទ្យាល័យទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការបង្កើតឱ្យមានភាពងាយស្រួលក្នុងការផ្តល់ព័ត៌មានរវាងក្រសួង និងសាកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជាទាំងអស់នោះ គឺជារឿងមួយដែលពិបាកបំផុតសម្រាប់គម្រោងនេះ យោងតាមការលើកឡើងរបស់អ្នកតំណាងធនាគារពិភពលោក (WB1)។ ដើម្បីទទួលបាននូវព័ត៌មានរួមគ្នា ការគាំទ្រជាទូទៅលើវិស័យនេះគឺជាកត្តាចាំបាច់ ហើយដើម្បីធ្វើដូច្នេះបាន គឺយើងត្រូវធ្វើឱ្យកិច្ចសហការគ្នារវាងម្ចាស់ជំនួយនិងក្រសួងមានភាពប្រសើរឡើង។

បើតាមការសិក្សារបស់យើងបានបង្ហាញថា "មានភាពខ្វះខាតក្នុងការលើកទឹកចិត្តចំពោះក្រុមអ្នកស្រាវជ្រាវដែលធ្វើការលើគម្រោងនៃមូលនិធិរបស់ធនាគារពិភពលោកនេះ។ ពួកគេមិនតម្រូវឱ្យសាស្ត្រាចារ្យនៃសាកលវិទ្យាល័យទាំងនោះធ្វើការស្រាវជ្រាវអ្វីនោះទេ "(គ្រឹះស្ថានឧត្តមសិក្សា) (MoEYS1)។ ជំនួយការអ្នកគ្រប់គ្រងរបស់ធនាគារពិភពលោកបានផ្តល់ភាពខុសគ្នានៅលើនេះចំណុចនេះថា របៀបធ្វើពិធីការនៃមូលនិធិសម្រាប់ការផ្គត់ផ្គង់ដែលរៀបចំឡើងដោយក្រសួងអប់រំ គឺមានសភាពស្មុគស្មាញខ្លាំង និងមានដាក់បន្ទុកធ្ងន់ទៅលើអ្នកស្រាវជ្រាវទាំងអស់ផងដែរ។ គាត់បានបន្ថែមទៀតថា ក្រុមអ្នកស្រាវជ្រាវជាច្រើនបាននិយាយថា៖ "ប្រសិនបើខ្ញុំត្រូវធ្វើវា ដើម្បីទទួលបានប្រាក់នោះខ្ញុំមិនធ្វើវានោះទេ" (WB1) គាត់ក៏បានបញ្ជាក់បន្ថែមទៀតថា ថ្មីៗនេះនាយករដ្ឋមន្ត្រីបានដាក់កម្រិតឱ្យមានការបើកប្រាក់ដើម្បីជាការលើកទឹកចិត្ត ដល់អ្នកស្រាវជ្រាវទាំងឡាយ និងអ្នកដែលមិនបានទទួលប្រាក់បៀវត្សរ៍ ហើយយកវាទៅរៀបចំក្នុងដំណើរការនៃការធ្វើឯកសារដ៏ស្មុគស្មាញនោះ។ ការចូលរួមរបស់ស្ថាប័នមួយដែលទាក់ទងជាមួយនឹងប្រភេទគម្រោងនៃការស្រាវជ្រាវដែលពួកគេធ្វើ និងគុណភាពនៃលទ្ធផលរបស់ពួកគេ គឺហួសពីវិសាលភាពនៃសមត្ថភាពរបស់ក្រុមនេះ ប៉ុន្តែក៏បានផ្តល់នូវភាពងាយស្រួលក្នុងការតាមដានគម្រោង និងជួយឱ្យយើងធ្វើការប្រៀបធៀបនូវព័ត៌មានផ្សេងៗ ដើម្បីឱ្យធនាគារពិភពលោកបង្កើតគម្រោងនេះបាន។

# ៥.កត្តាដែលលើកកម្ពស់ ឬរារាំងការងារស្រាវជ្រាវ

ការងារស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា ហាក់បីដូចជាបង្ហាញសញ្ញានៃការផ្លាស់ប្តូរច្រើន ប៉ុន្តែនៅតែមានបញ្ហាប្រឈមមួយចំនួនដើម្បីឱ្យយើងជម្នះវាឱ្យបាន។ ដើម្បីឱ្យកាន់តែច្បាស់នៅត្រង់ចំណុចនេះ យើងនឹងរៀបរាប់ម្តងទៀត ដោយផ្តោតសំខាន់ទៅលើកត្តាមួយចំនួនដែលរារាំងការងារស្រាវជ្រាវនេះ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាសំខាន់ៗមួយចំនួនត្រូវបានគេដោះស្រាយ ហើយក៏កំពុងតែបោះជំហានទៅមុខបន្តទៀតដើម្បីលើកកម្ពស់ការងារនេះ ក្នុងលក្ខខណ្ឌនៃការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កើតគោលនយោបាយឱ្យស្ថាប័ននីមួយៗ ស្វែងរកថវិកា កិច្ចសហការជាអន្តរជាតិ និងការកសាងសមត្ថភាព (ជាពិសេសក្នុងចំណោមសិស្ស និស្សិត)។ បញ្ហាទាំងអស់នេះ យើងនឹងរៀបរាប់នៅផ្នែកបន្តបន្ទាប់នៃរបាយការណ៍របស់យើង។ ចំពោះផ្នែកនេះ យើងនឹងធ្វើការពិភាក្សាអំពីការផ្តល់មូលនិធិ និងការកសាងសមត្ថភាព។ កត្តាទាំងនេះវាអាចកើតចេញជាឱកាសផង និងឧបសគ្គផងសម្រាប់ការងារស្រាវជ្រាវនេះ ពោលគឺវាអាស្រ័យទៅលើវិធីដែលពួកគេយកមកប្រើ។

វាជារឿងគួរឱ្យកត់សម្គាល់មួយដែលកត្តាទាំងអស់នៃការរារាំងការងារស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាក៏ត្រូវបានគេដាក់បញ្ចូលនៅក្នុងគម្រោងផ្សេងៗនៃការងារស្រាវជ្រាវ ក្រោមការផ្តល់មូលនិធិរបស់ GDN ដើម្បីធ្វើការស៊ើបអង្កេតបន្ថែមទៀតនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន។ ទាំងអស់នេះបង្ហាញថា កម្រិតនៃរចនាសម្ព័ន្ធ គឺវាហួសពីសមត្ថភាពរបស់ប្រទេសមួយក្នុងការដោះស្រាយបញ្ហា ហើយមានកត្តាសំខាន់ពីរ ដែលយើងស្នើឱ្យធ្វើការដោះស្រាយទាក់ទងនឹងការស្រាវជ្រាវជាអន្តរជាតិ និងសហគមន៍ម្ចាស់ជំនួយ។

១) កំណត់ដំណើរការនៃមូលដ្ឋានទិន្នន័យ (Databases) និងការសិក្សាលើទិនានុប្បវត្តិ

២) ថវិកាមូលនិធិ ដែលប្រទេសនីមួយៗប្រើប្រាស់ដើម្បីពិគ្រោះយោបល់ជាអន្តរជាតិ ក្នុងការបង្កើតឱ្យមានការស្រាវជ្រាវ និងផ្តួចផ្តើមការស្រាវជ្រាវរយៈពេលខ្លីរបស់ម្ចាស់ជំនួយ មុនពេលដែលគេត្រូវការ និងតាមលក្ខខណ្ឌនៃប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន។ តាមពិតគម្រោងដែលយើងបានចូលរួមធ្វើ ក៏ជាគំនិតនៃការផ្តួចផ្តើមរយៈពេលខ្លីមួយ ដែលធ្វើឱ្យមានភាពលំបាកក្នុងការអនុវត្តវិធីសាស្ត្រនៃការស្រាវជ្រាវ ហើយយើងក៏ត្រូវកសាងសមត្ថភាពអ្នកស្រាវជ្រាវនៅប្រទេសកម្ពុជាដែរ។

**តើការស្រាវជ្រាវត្រូវបានគេឱ្យតម្លៃ ឬអត់នៅប្រទេសកម្ពុជា?**

ក្រៅពីកត្តារាំងមួយចំនួនដែលយើងបានរៀបរាប់ នៅមានកត្តារាំងដ៏ខ្លាំងក្លាមួយទៀតដែលយើងរកឃើញនៅអំឡុងពេលសម្ភាសនោះគឺ ជំនឿរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់មួយចំនួន ដែលយល់

ឃើញថាការស្រាវជ្រាវមិនត្រូវបានគេឱ្យតម្លៃទេនៅកម្ពុជា។ បើតាមការស្រាវជ្រាវរបស់យើង យើងបានច្រានចោលទស្សនៈបែបនេះទាំងស្រុង ប៉ុន្តែអ្នកគ្រប់គ្រងនៅតែបន្តនិយាយថា វាជាការពិតនៅកម្ពុជា។ ភាពខុសគ្នារវាងជំនឿ និងការអនុវត្តជាពិសេសជំនឿដែលលើកឡើងដោយអ្នកគ្រប់គ្រងវ័យចំណាស់មួយចំនួន និងការអនុវត្តដោយក្រុមអ្នកស្រាវជ្រាវវ័យក្មេងនោះ គឺជាលក្ខណៈពិសេសដែលគេកំណត់ដើម្បីឆ្លងកាត់កាលៈទេសៈណាមួយប៉ុណ្ណោះ។

និន្នាការមួយត្រូវបានអ្នកចូលរួមទាំងខាងរដ្ឋាភិបាលនិងរដ្ឋបាលរបស់សាកលវិទ្យាល័យ លើកឡើងថា យើងមិនធ្វើការស្រាវជ្រាវដោយសារតែការរកឃើញ និងការវិភាគរបស់យើងមិនសូវមានមនុស្សឱ្យតម្លៃ។ បញ្ហាទាំងនេះក៏ជាសម្ពាធមួយសម្រាប់សាកលវិទ្យាល័យ ព្រោះពួកគេត្រូវបន្ថែមម៉ោងបង្រៀន មិនមានប្រាក់ខែគ្រប់គ្រាន់សម្រាប់សាស្ត្រាចារ្យ ភាពរសើបនៃនយោបាយ ដែនកំណត់របស់អ្នកផ្តល់មូលនិធិ និងកង្វះខាតអ្នកជំរុញធ្វើការស្រាវជ្រាវ។ អ្នកចូលរួមក្នុងការស្រាវជ្រាវ ទាំងភាគីរដ្ឋាភិបាលនិងសាកលវិទ្យាល័យបានសន្និដ្ឋានថា អ្វីដែលគេបានដឹងមានដូចជា កង្វះខាតនៃការឱ្យតម្លៃសម្រាប់ការស្រាវជ្រាវ សមត្ថភាពនៃអ្នកស្រាវជ្រាវម្នាក់ៗនៅមានកម្រិត កត្តាដែលនាំឱ្យការស្រាវជ្រាវចេញជាលទ្ធផលល្អ និងអាកប្បកិរិយារបស់អ្នកស្រាវជ្រាវ។ ក្រុមមន្ត្រីរដ្ឋាភិបាលបាននិយាយពីភាពខ្វះខាតថវិកាសម្រាប់ការស្រាវជ្រាវ ប៉ុន្តែបញ្ហាពិតប្រាកដនោះគឺស្ថិតនៅត្រង់កម្រិតសមត្ថភាពរបស់បុគ្គលម្នាក់ៗនៃស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាល័យខ្លួនឯង មិនបង្កើតឱ្យមានវប្បធម៌នៃការស្រាវជ្រាវនេះឡើងទៅវិញទេ នៅក្នុងសាកលវិទ្យាល័យ។ មន្ត្រីម្នាក់បានលើកឡើងថា សាកលវិទ្យាល័យត្រូវតែសម្រេចចិត្ត"ថាតើពួកគេចង់ក្លាយជាសាកលវិទ្យាល័យមួយដែលមានការស្រាវជ្រាវយ៉ាងល្អិតល្អន់ ឬក៏គ្រាន់តែជាសាកលវិទ្យាល័យដែលមានតែរូបភាព" (MoEYS1)។ អ្នកគ្រប់គ្រងក្នុងសាកលវិទ្យាល័យមួយចំនួនបានផ្សារភ្ជាប់កង្វះខាតខាងផ្នែកហិរញ្ញវត្ថុ និងកង្វះខាតនៃការលើកទឹកចិត្ត ទៅនឹងភាពខ្វះខាតនៃការឱ្យតម្លៃលើការងារស្រាវជ្រាវ ក៏ដូចជាឥរិយាបថរបស់អ្នកស្រាវជ្រាវទាំងឡាយ "ផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ"(PUC:DR)។ អ្នកគ្រប់គ្រងក្នុងសាកលវិទ្យាល័យខ្លះបានសម្តែងការខកចិត្តនៅពេលដែលសាស្ត្រាចារ្យបង្រៀន "ដើម្បីតែប្រាក់" ហើយរំពឹងថា នឹងបានប្រាក់ត្រឡប់មកវិញសម្រាប់ការចូលរួមក្នុងសន្និសីទនានា (PUC:DR) ខណៈដែលអ្នកផ្សេងទៀតចាត់ទុកការស្រាវជ្រាវ "ជាសេវាសង្គម" និងខ្លះទៀតយល់ថាការស្រាវជ្រាវ "មិនមែនជាអាជីពនោះទេ" (Z:Dean1)។

នៅសាកលវិទ្យាល័យហ្សាម៉ាន់ ព្រឹទ្ធបុរសម្នាក់បាននិយាយថា សិស្សមិនឱ្យតម្លៃលើការងារស្រាវជ្រាវនោះទេ ពួកគេមិនផ្តោតសំខាន់ទៅលើការស្រាវជ្រាវ និងមិនបានចាប់អារម្មណ៍លើកម្មវិធីស្រាវជ្រាវណាមួយក្នុងសាកលវិទ្យាល័យ នៅពេលពួកគេមកចុះឈ្មោះចូលរៀននោះទេ។ ដូច្នេះក្នុងវិស័យឯកជន "ការជំរុញឱ្យធ្វើអាជីវកម្ម" សាកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា "មិនមានការចំណាយប្រាក់ច្រើនសម្រាប់វិស័យនេះនៅឡើយទេ ព្រោះនិស្សិតមិនមានចំណេះដឹងទាក់ទងនឹង

ការងារស្រាវជ្រាវនោះ” តាមការលើកឡើងរបស់ព្រឹទ្ធបុរស (Z:Dean1)។ ស្រដៀងគ្នានេះដែរ នៅឯសាកលវិទ្យាល័យបញ្ញាសាស្ត្រ អ្នកគ្រប់គ្រងបានត្អូញត្អែរថាសាកលវិទ្យាល័យទទួលបានកិច្ចប្រជុំប្រចាំខែដើម្បីពិភាក្សាលើការងារស្រាវជ្រាវ ប៉ុន្តែមហាវិទ្យាល័យនីមួយៗ “មិនខ្វល់អំពីការស្រាវជ្រាវ” នោះទេ (PUC:DR)។ ព្រឹទ្ធបុរសម្នាក់ដែលបញ្ចប់ការសិក្សានៅក្រៅប្រទេសបានលើកឡើងថា អ្នកដែលទទួលបានការបណ្តុះបណ្តាលនៅក្រៅប្រទេសភាគច្រើន “ឱ្យតម្លៃលើការងារស្រាវជ្រាវណាស់” ប៉ុន្តែនៅកម្ពុជា ការងារនេះមិនសូវបានគេឱ្យតម្លៃទៅវិញ “យើងបានសរសេរទាក់ទងនឹងវប្បធម៌របស់យើងផ្ទាល់ និងតំបន់ផ្សេងៗទៀត ជាពិសេសនៅប្រទេសបារាំង និងបណ្តាបស្ចិមប្រទេសមួយចំនួន” (PUC:DR)។ គាត់ជឿថា អ្នកស្រាវជ្រាវទាំងអស់ត្រូវតែធ្វើការប្រកួតប្រជែងដើម្បី “ឱ្យពួកគេមានការអភិវឌ្ឍខ្លួន មិនមែនចេះតែទទួលយកបាននោះទេ”។ ប្រការដែលយើងគួរទប់ស្កាត់ក្នុងអំឡុងពេលសម្ភាសនោះគឺ “គួរចាត់ទុកការស្រាវជ្រាវជាកាតព្វកិច្ច បើមិនដូច្នេះទេនឹងមិនមានការលើកទឹកចិត្ត ក៏ដូចជាចំណាយពេលវេលាក្នុងការបង្រៀនទាក់ទងនឹងការងារស្រាវជ្រាវនោះឡើយ” (RUPP-IFL:DH)។ គោលនយោបាយទាក់ទងនឹងកាតព្វកិច្ចនៃការស្រាវជ្រាវ (រួមបញ្ចូលទាំងការស្នើឱ្យមានការបោះពុម្ព) ជាមួយនឹងគំនិតស្រាវជ្រាវដែលមិនត្រូវបានគេឱ្យតម្លៃនេះបានបង្ហាញថា មិនមានការយកចិត្តទុកដាក់ទៅលើវចនាសម្ព័ន្ធនៃការងារនេះទេ។

ក្មេងៗជំនាន់ក្រោយបានឆ្លើយតបត្រឡប់ទៅវិញជុំវិញបញ្ហាដែលមិនឱ្យយតម្លៃលើការងារស្រាវជ្រាវនេះ។ ឧទាហរណ៍ អ្នកស្រាវជ្រាវវ័យក្មេងម្នាក់បាននិយាយថា “មិនមានការឱ្យតម្លៃចំពោះការងារស្រាវជ្រាវ” នេះប្រហែលជាពួកគេមិនដឹងទេថា ប្រសិនបើគ្មានការស្រាវជ្រាវទេ ប្រទេសជាតិក៏មិនមានការអភិវឌ្ឍអ្វីដែរ (USEA:F3)។ ហេតុផលនេះបានបង្ហាញថា ពួកគេមានការចាប់អារម្មណ៍ចំពោះការងារស្រាវជ្រាវនេះ ហើយកត្តាដែលនាំឱ្យពួកគេពេញចិត្តនេះ ក៏មិនមែនមកពីអ្នកបង្កើតគោលនយោបាយ និងអ្នកគ្រប់គ្រងទាំងនោះដែរ។ លើសពីនេះទៅទៀត មានការបង្ហាញថា “អ្នកជំនាន់មុនៗមិនចង់ទៅសិក្សាបន្ថែមទៀតទេ” (RUA:Dean4) ហើយមានតែ “អ្នកស្ម័គ្រចិត្តវ័យក្មេង និងមហាវិទ្យាល័យមួយចំនួនប៉ុណ្ណោះដែលចាប់អារម្មណ៍ចំពោះការបណ្តុះបណ្តាលនៅក្រៅប្រទេសបន្ថែមទៀតនោះ” (RUA:Dean1)។

មាននិន្នាការសំខាន់ៗមួយចំនួន ដែលបានបង្ហាញពីការពិតជាក់ស្តែងនៃការឱ្យតម្លៃទៅលើការងារស្រាវជ្រាវនោះ។ វាផ្ទុយទៅនឹងការអះអាងរបស់អ្នកគ្រប់គ្រងដែលនិយាយថា មិនមានអ្នកចាប់អារម្មណ៍ក្នុងការងារស្រាវជ្រាវនោះទេ ហើយនិស្សិតនៅក្នុងសាកលវិទ្យាល័យរបស់យើងបានកត់សម្គាល់ឃើញថា ការចាប់ផ្តើមសិក្សាវគ្គស្រាវជ្រាវនៅថ្នាក់មូលដ្ឋាន (ឆ្នាំទី១) គឺជារឿងល្អប្រសើរជាងការសិក្សានៅឆ្នាំទីបី ព្រោះអាចឱ្យពួកគេមានពេលវេលាបន្ថែមដើម្បីអភិវឌ្ឍជំនាញសំខាន់ៗរបស់គេ។ លើសពីនេះទៅទៀត សិស្សនិស្សិតបានត្រៀមខ្លួនក្នុងការធ្វើការងារនេះ (Secondary source) និង

ធ្វើការស្រាវជ្រាវដែលទាក់ទងនឹងការងារអាជីវកម្មដើម្បីជំរុញឱ្យមានការចូលរួមពីសង្គមស៊ីវិលនៅកម្ពុជាក្នុងការដោះស្រាយបញ្ហាសង្គមនានា ហើយកិច្ចការស្រាវជ្រាវទៀតសោតក៏ត្រូវធ្វើទៅតាមការទាមទាររបស់សាលាដើម្បីបញ្ចប់ការសិក្សារបស់ពួកគេផងដែរ។ នៅក្នុងការពិភាក្សារបស់យើង សិស្សនិស្សិតដែលសាលាមិនតម្រូវឱ្យធ្វើការស្រាវជ្រាវនោះ បានបង្ហាញនូវគោលបំណងរបស់គេក្នុងការចង់ធ្វើការងារនេះទៅវិញ។ ជាក់ស្តែង ក្នុងការស្រាវជ្រាវរបស់បុគ្គលម្នាក់ៗដូចជានៅសាកលវិទ្យាល័យច្បាប់ សិស្សដែលរៀនពូកែត្រូវបាន "ទទួលរង្វាន់" ហើយអាចធ្វើការប្រមូលទិន្នន័យសំខាន់ៗក្នុងការងារស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សារបស់ពួកគេបាន។ ចំណែកឯនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានតែនិស្សិតដែលទទួលបានពិន្ទុខ្ពស់ៗប៉ុណ្ណោះ ដែលអាចចូលរួមក្នុងការងារស្រាវជ្រាវ ហើយក៏មានការប្រកួតប្រជែងលើការស្រាវជ្រាវរបស់និស្សិតទាំងនោះផងដែរ។ RUA ជាកន្លែងដែលជួយបង្ហាត់បង្ហាញនិស្សិត និងសាស្ត្រាចារ្យ ហើយក៏នាំពួកគេឱ្យចូលរួមក្នុងគម្រោងនៃការស្រាវជ្រាវរបស់ម្ចាស់ជំនួយផងដែរ។

លើសពីនេះទៅទៀត ការរារាំង ឬការប្រឆាំងនានា វាអាចជាសម្ពាធដល់ក្រុមដែលធ្វើការងារស្រាវជ្រាវ ហើយក៏អាចប៉ះពាល់ទៅលើនយោបាយរបស់រដ្ឋាភិបាល ដែលគាំទ្រឱ្យមានការប្រមូលយកទិន្នន័យ ឬព័ត៌មានផ្សេងៗ និងការផ្សព្វផ្សាយដែលទាក់ទងនឹងបញ្ហាសង្គមផងដែរ។ ឧទាហរណ៍ អង្គការសមធម៌កម្ពុជា បានបង្ហាញបទពិសោធន៍របស់ខ្លួនថា ភ្នាក់ងាររដ្ឋាភិបាលភាគច្រើនយល់ស្រប និងលើកកម្ពស់ឱ្យមានការវិនិយោគពីក្រុមហ៊ុនចិន ឬវៀតណាមច្រើនជាងជ្រើសយកការអភិវឌ្ឍនៅក្នុងសង្គមកម្ពុជា (EC:DM)។ រដ្ឋាភិបាលក៏បានបង្ហាញពីភាពតានតឹងរបស់ខ្លួនជាមួយសាកលវិទ្យាល័យរដ្ឋ និងឯកជនទាំងឡាយផងដែរ។ អ្នកគ្រប់គ្រងជាន់ខ្ពស់មួយរូបនៅ USEA បាននិយាយថា "រដ្ឋាភិបាលមិនបានផ្តល់ ឱ្យមានភាពស្មើគ្នារវាងសាកលវិទ្យាល័យឯកជន និងសាកលវិទ្យាល័យរដ្ឋមួយចំនួននោះទេ (USEA:PR)។ ឧទាហរណ៍ រដ្ឋាភិបាលទទួលបានប្រាក់២៣លានដុល្លារអាមេរិក ពីធនាគារពិភពលោកសម្រាប់ធ្វើការលើគម្រោងផ្សេងៗគ្នា។ ប្រាក់ទាំងនេះត្រូវបានគេបែងចែកជាបួនសមាសភាគ និងប្រមាណចំនួន ៧លានដុល្លារអាមេរិកសម្រាប់គម្រោងស្រាវជ្រាវ។ រដ្ឋាភិបាលបានចាត់ឱ្យមានគម្រោងស្រាវជ្រាវតូចមួយ (ប្រហែល $៥0.000) សម្រាប់សាកលវិទ្យាល័យឯកជន និងបង្កើតឱ្យមានគម្រោងនៃការស្រាវជ្រាវលក្ខណៈធំសម្រាប់សាកលវិទ្យាល័យរដ្ឋ (ប្រហែល $ ២00.000) ។ "នេះពិតជាបានបង្ហាញថា រដ្ឋាភិបាលពេញចិត្តសាកលវិទ្យាល័យរដ្ឋច្រើនជាងសាកលវិទ្យាល័យឯកជន ហើយវានឹងនាំឱ្យមានបញ្ហានៅពេលអនាគតផងដែរ" (USEA:PR)។ អ្នកគ្រប់គ្រងរូបនោះបានបញ្ជាក់ទៀតថា មហាវិទ្យាល័យនានា ក្នុងសាកលវិទ្យាល័យរបស់រដ្ឋ "មិនមានឆន្ទៈ" ដើម្បីធ្វើការងារនេះទេ ព្រោះពួកគេទទួលបានប្រាក់ខែតិច និងទទួលបន្ទុកការងារខ្ពស់។ ការស្រាវជ្រាវរបស់យើងបានបង្ហាញថា បញ្ហាប្រឈមគឺវាមិនមែនស្ថិតនៅលើថវិកា និងឆន្ទៈនោះទេ គឺវាស្ថិតនៅលើភាពមិនច្បាស់លាស់រវាងសមត្ថភាពរបស់ក្រុមអ្នកស្រាវជ្រាវនៅ USEA ថាតើពួកគេអាចបង្កើតការស្រាវជ្រាវមួយដែលមាន

គុណភាព (ការវាយតម្លៃអំពីលទ្ធផលរបស់ពួកគេគឺ HEQCIP ពិតជាមានសារៈសំខាន់ក្នុងការវាស់ស្ទង់សមត្ថភាព)បានឬក៏អត់។

**ការផ្តល់មូលនិធិ**

សមត្ថភាពនៃការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុមិនគ្រប់គ្រាន់គឺជាបញ្ហាប្រឈមដ៏ពិតប្រាកដមួយ ដែលប៉ះពាល់ដល់ការស្រាវជ្រាវនៅប្រទេសកម្ពុជា។ អំឡុងពេលដែលអ្នកស្រាវជ្រាវគ្រប់ទីកន្លែងទាំងអស់កំពុងមានបញ្ហាប្រឈមទាក់ទងនឹងផ្នែកហិរញ្ញវត្ថុនេះ មានការគូសបញ្ជាក់ថ្មីមួយទៀតឱ្យឃើញថា ការបង្កើនតែចំនួនថវិកាមួយមុខ ក៏មិនអាចដោះស្រាយបញ្ហាបានទាំងស្រុងនោះដែរ។ នៅក្នុងចំណុចនេះ យើងនឹងធ្វើការគូសបញ្ជាក់ទៅលើការផ្លាស់ប្តូរវិជ្ជមានមួយចំនួនទាក់ទងនឹងការផ្តល់មូលនិធិនៃការស្រាវជ្រាវប្រាក់ខែរួមជាមួយនឹងការលើកទឹកចិត្តផ្សេងៗ បន្ទាប់មកយើងនឹងធ្វើការពិភាក្សាលើផលវិបាកនានាក្នុងការធ្វើការងារនេះ។

**មូលនិធិនៃការស្រាវជ្រាវដែលអាចរកបាន**

ថវិកាដែលអាចរកបាននឹងមានការកើនឡើងតាមរយៈចំណូលផ្សេងៗ។ ជម្រើសក្នុងការផ្តល់ថវិកាត្រូវបានបើកចំហទាំងសម្រាប់អ្នកស្រាវជ្រាវដែលមកពីសាកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិល។

កាលពីឆ្នាំមុន CKS បានធ្វើការស្នើទៅកាន់អ្នកស្រាវជ្រាវនៅប្រទេសបារាំង និងអាមេរិកឱ្យមានការបើកចំហចំពោះអ្នកស្រាវជ្រាវរបស់កម្ពុជា ក៏ដូចជាបណ្ឌិត (PhD) ដើម្បីអនុវត្តការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ បើទោះបីជាមានការផ្លាស់ប្តូរញឹកញាប់នៅតាមសាកលវិទ្យាល័យនានាក៏ដោយ ក៏អ្នកស្រាវជ្រាវដែលទទួលបានជោគជ័យទាំងនោះបានមូលនិធិដែលមានប្រភពមកពីកម្ពុជា និង បណ្តាដៃគូអន្តរជាតិដែរ (រូបភាពទី ២)។

*រូបភាពទី ២៖ ប្រភពមូលនិធិសម្រាប់គម្រោងស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សា*



រូបភាពទី២ បង្ហាញថាសាកលវិទ្យាល័យជាតិគ្រប់គ្រង បានបង្កើតការស្រាវជ្រាវច្រើនជាងគេ (ក្នុងចំណោមមហាវិទ្យាល័យដែលយើងបានសម្ភាសទាំងអស់ ពួកគេសុទ្ធតែទទួលបានថវិកាសម្រាប់ការស្រាវជ្រាវ)។ បច្ចុប្បន្ន សាកលវិទ្យាល័យជាតិគ្រប់គ្រងកំពុងផ្តោតសំខាន់ទៅលើការផ្លាស់ប្តូរពីការបង្រៀនទៅជាការស្រាវជ្រាវវិញ ដោយទទួលបានថវិកាពីធនាគារពិភពលោក (ជំនួយឥតសំណង) សាកលវិទ្យាល័យនានារបស់ប្រទេសបារាំង និងពីសាកលវិទ្យាល័យជាតិគ្រប់គ្រងខ្លួនឯងផ្ទាល់ (ជំនួយឥតសំណងរាប់ចាប់ពី USD ១.000 - USD ១០.000ឡើងទៅ) (NUM:DG)។ នាយកផ្នែកស្រាវជ្រាវនៅសាកលវិទ្យាល័យ USEA បាននិយាយថា នៅពេលថ្មីៗនេះ សាកលវិទ្យាល័យយើងបានសម្រេចជោគជ័យក្នុងការប្រមូលមូលនិធិដែលបានមកពីប្រភពចំនួនពីរ៖ សាកលវិទ្យាល័យម៉ាឡាយ៉ា ដើម្បីធ្វើការប្រមូលទិន្នន័យបន្តទៀត (USD ២0.000) និងបានមកពីធនាគារពិភពលោកដើម្បីអនុវត្តគម្រោងស្រាវជ្រាវមួយស្តីពី "កម្មវិធីនៃការអភិវឌ្ឍវិស័យទេសចរណ៍ និងគ្រប់គ្រងបដិសណ្ឋារកិច្ច" (ពីខែមិថុនា ឆ្នាំ២០១៣ ដល់ខែមិថុនា ឆ្នាំ២០១៥ចំនួន USD ៥0.000) (USEA:UPR)។ នៅវិទ្យាស្ថានភាសាបរទេស IFL ដេប៉ាតឺម៉ង់សិក្សាអន្តរជាតិ ទើបតែទទួលបានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុសម្រាប់ការស្រាវជ្រាវពីវិទ្យាស្ថានអភិវឌ្ឍន៍កម្ពុជា (USD ២0.000) គម្រោងរបស់អង្គការ SIDA ស្តីពីការប្រែប្រួលអាកាសធាតុ (USD១០0.000) និងមូលនិធិពីវិទ្យាស្ថានចិនមួយដើម្បីបង្កើតមជ្ឈមណ្ឌល Maritime Silk Road Security (USD១០0.000 ជារៀងរាល់ឆ្នាំសម្រាប់រយៈពេលប្រាំឆ្នាំ)។ ការគាំទ្រចំពោះការងារស្រាវជ្រាវនៅសាកលវិទ្យាល័យហ្សាម៉ាន់គឺមានលក្ខណៈក្មេងខ្ចីនៅឡើយ ប៉ុន្តែមានការកើនឡើងជារៀងរាល់ឆ្នាំ ហើយនៅឆ្នាំនេះពួកគេបានផ្តល់ថវិកាឱ្យសាស្ត្រាចារ្យ និងនិស្សិតដើម្បីធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី ក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍ឱ្យគ្នាទៅវិញទៅមកទាក់ទងនឹងគម្រោងនៃការស្រាវជ្រាវ (Z:DM2)។ ចំណែកឯនៅ RUA បានទទួលគម្រោងជំនួយពីសហគមន៍អន្តរជាតិដើម្បីធ្វើការស្រាវជ្រាវ ហើយនឹងចូលរួមក្នុងដំណើរការនានារបស់ម្ចាស់ជំនួយ (អង្គការ Oxfam ធនាគារពិភពលោកជាដើម) គម្រោងស្រាវជ្រាវដែលទាក់ទងទៅនឹងការពង្រីក និងពង្រឹងវិស័យកសិកម្ម (RUA:PR)។ អង្គការសមធម៌កម្ពុជា បានរាយការណ៍ថា មានម្ចាស់ជំនួយជាច្រើនគាំទ្រលើការតស៊ូមតិដែលផ្អែកលើភ័ស្តុតាងជាមូលដ្ឋាន និងមានភាពឯករាជ្យក្នុងការជ្រើសរើសធនធានថវិកាសម្រាប់ការងារស្រាវជ្រាវ។ អង្គការលីកាដូក៏បានរាយការណ៍ផងដែរថា ស្ថាបនិកជាច្រើនក៏ដូចជាក្នុងពេលដែលធ្វើការស្រាវជ្រាវ "តែងតែមិនមានថវិកាគ្រប់គ្រាន់ សម្រាប់ធ្វើរឿងដែលចាំបាច់" (LICADHO) វាគ្រប់គ្រាន់សម្រាប់តែធ្វើការងារឱ្យរួចរាល់ និងបង្ហាញតែលទ្ធផលណាដែលអាចទាក់ទាញម្ចាស់ជំនួយឱ្យបន្តការជួយតែប៉ុណ្ណោះ។

### កង្វះនៃការផ្តល់មូលនិធិនៅតែជាបញ្ហាប្រឈមចម្បងសម្រាប់អ្នកស្រាវជ្រាវភាគច្រើន

មន្ត្រីមកពីនាយកដ្ឋានឧត្តមសិក្សាមួយរូបបានលើកឡើងស្រដៀងគ្នាជាមួយមនុស្សមួយចំនួនថា "ការស្រាវជ្រាវមិនមែនជាអាជីពការងារពិតប្រាកដដែលអាចគាំទ្រការរស់នៅរបស់អ្នកស្រាវជ្រាវបាន

ទាំងស្រុងនោះទេ"។ ទោះបីជាការផ្តល់ថវិកាមានភាពវិជ្ជមានដូចដែលបានរៀបរាប់ខាងលើក្តី ក៏ការស្វែងរក និងការគ្រប់គ្រងការស្រាវជ្រាវថវិកាទាំងនោះនៅតែជាឧបសគ្គយ៉ាងសំខាន់ដដែល។ មានការស្ទង់មតិមួយដែលវាយតម្លៃទៅលើលទ្ធភាពរបស់សាកលវិទ្យាល័យ (ថវិកា) និងសមត្ថភាពក្នុងការកៀរគរមូលនិធិខាងក្រៅ។ នៅលើមាត្រដ្ឋានមួយដែលចាប់ផ្តើមពី"ការពេញចិត្តកម្រិតទាបខ្លាំង" លើលទ្ធភាពក្នុងការផ្តល់

មូលនិធិ និង "ការពេញចិត្តកម្រិតខ្លាំង" ដែល ៤១%នៃអ្នកឆ្លើយសំណួរទាំងអស់បានផ្តល់ពិន្ទុទាបបំផុត (រូបភាពទី៣) ខណៈដែលកម្រិតនៃការពេញចិត្តជាមធ្យមគឺទាប ២.១។

*រូបភាពទី ៣ ការពេញចិត្តជាមួយនឹងលទ្ធភាពនៃការផ្តល់មូលនិធិស្រាវជ្រាវរបស់សាកលវិទ្យាល័យ*




ឧទាហរណ៍នៅ UBB សិស្សត្រូវតែចេញថវិកាផ្ទាល់ខ្លួនសម្រាប់គម្រោងផ្តួចផ្តើមនៃការស្រាវជ្រាវ កត្តានេះហើយដែលវាអាចមានផលប៉ះពាល់ទៅលើការជ្រើសរើសប្រធានបទ និងទំហំនៃការងារនោះ។ នៅ RUA បញ្ហាភាគច្រើនគឺស្ថិតនៅលើតម្លៃនៃការស្រាវជ្រាវ ព្រោះមានតម្លៃថ្លៃខ្លាំង។ ការស្រាវជ្រាវលើផ្នែកកសិកម្មមាន "តម្លៃរាប់លានដុល្លារ" ហើយពួកគេក៏មិនបានទទួលមូលនិធិណាមួយពីរដ្ឋាភិបាល ឬសាកលវិទ្យាល័យខ្លួនឯងនោះទេ(RUA:Dean2)។ ក្នុងកម្រិតថ្នាក់ជាតិ ក្រសួងអប់រំបានបង្ហាញបញ្ហាប្រឈមចម្បងជាផ្លូវការថាកង្វះមូលនិធិក្នុងការស្រាវជ្រាវ វាមានផលលំបាកសម្រាប់អ្នកស្រាវជ្រាវម្នាក់ៗ ក្នុងការចូលរួមដំណើរការនេះ (MoEYS1)។ បច្ចុប្បន្ននេះតាមរយៈ HEQCIP គឺយើងមានមូលនិធិ ប៉ុន្តែមិនទាន់មានការកែសម្រួលណាមួយដែលតម្រូវឱ្យយើងចូលទៅជាកម្មវិធីមូលនិធិអចិន្ត្រៃយ៍របស់ក្រសួងហិរញ្ញវត្ថុនៅឡើយទេ (WB1)។ មានមតិជាច្រើនលើកឡើងជុំវិញបញ្ហានៃការខ្វះថវិកាសម្រាប់ការស្រាវជ្រាវនេះ ជាពិសេសសាកលវិទ្យាល័យឯកជនមួយចំនួន ដែលមិនបាន

ទទួលមូលនិធិពីរដ្ឋាភិបាល នឹងពឹងផ្អែកលើការបង់ប្រាក់របស់និស្សិតទាំងស្រុងនោះ (Z:DH2; USEA:F1)។

ប៉ុន្តែ មានការឆ្លើយតបមួយចំនួនបានបង្ហាញថា បង្កើនការផ្តល់ថវិកាតែមួយមុខមិនអាចមានប្រសិទ្ធភាពទាំងស្រុងនោះទេ ពោលគឺត្រូវមានការចូលរួមកែលម្អសមត្ថភាពរបស់ស្ថាប័ន ការគ្រប់គ្រងមូលនិធិ និងសមត្ថភាពរបស់អ្នកស្រាវជ្រាវសម្រាប់ប្រតិបត្តិការក្នុងគម្រោងផ្សេងៗទើបការងារនេះមានភាពប្រសើរឡើង។ ព្រឹទ្ធបុរសម្នាក់នៅសាកលវិទ្យាល័យបញ្ញាសាស្ត្របាននិយាយថា "យើងត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុធនធ្ន:ក្នុងការស្រាវជ្រាវ និងការយល់ដឹងពីរបៀបធ្វើ" (PUC:Dean2)។ នៅ USEA មានការលើកឡើងថា "នៅពេលដែលយើងមានប្រាក់ យើងមិនដឹងពីរបៀប និងដំណើរការនៃការធ្វើការងារនេះ។ ប៉ុន្តែទោះជាយ៉ាងណា យើងអាចរៀនសូត្រពីដំណើរការទាំងនោះបាន ដូច្នេះវានឹងមានភាពងាយស្រួលនៅពេលដែលយើងមានប្រាក់គ្រប់គ្រាន់ដើម្បីគាំទ្រដល់កិច្ចការស្រាវជ្រាវ" (USEA:DR)។ ការគ្រប់គ្រងមូលនិធិ និងការគ្រប់គ្រងគម្រោងស្រាវជ្រាវ តម្រូវឱ្យមានការប្រកួតប្រជែងច្រើន រីឯដំណើរការវិញក៏មានភាពស្មុគស្មាញខ្លាំងដែរ។ អង្គការអាដហុក (Adhoc) ទំនងដូចជាចង់ផ្តល់មូលនិធិឱ្យសាកលវិទ្យាល័យហ្សាម៉ាន់ "នៅក្នុងលក្ខខណ្ឌនៃការផ្តល់មូលនិធិនេះនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ វាអាស្រ័យទៅលើសំណើ។ ដូច្នេះប្រសិនបើនរណាម្នាក់ចង់ធ្វើការស្រាវជ្រាវ ពួកគេត្រូវសរសេរសំណើទៅកាន់រដ្ឋបាល ហើយប្រសិនបើសំណើនោះសមហេតុសមផល ពួកគេប្រាកដជាយល់ព្រមដាក់ជាមិនខាន"(Z:F)។ ប្រធាននៃអ្នកសិក្សាផ្នែកអន្តរជាតិនៅវិទ្យាស្ថានភាសាបរទេសបានបញ្ជាក់ថា "មិនមានមូលនិធិគ្រប់គ្រាន់នោះទេ។ ថវិកាសម្រាប់ការស្រាវជ្រាវគឺពឹងផ្អែកលើជំនួយឥតសំណងពីស្ថាប័នខាងក្រៅ ដូចនេះតម្រូវឱ្យពួកគេមានបណ្តាញរឹងមាំ និងជំនាញច្បាស់លាស់ក្នុងការសរសេរសំណើដើម្បីទទួលបានជំនួយទាំងនោះ"(RUPP-IFL:DH)។

លើសពីនេះទៀត សូម្បីតែពេលដែលស្ថាប័នមួយចំនួនមានលទ្ធភាពក្នុងការផ្តល់មូលនិធិឱ្យនោះ ក៏អ្នកស្រាវជ្រាវ និងសាកលវិទ្យាល័យមួយចំនួនមិនដឹងថាតើត្រូវយកពីកន្លែងណា និងរបៀបស្វែងរកមូលនិធិពីស្ថាប័នទាំងនោះដែរ។ ពួកគេមានចំណេះដឹងតិចតួចក្នុងការសរសេរសំណើទាំងនោះ ហើយការទំនាក់ទំនងរវាងរដ្ឋាភិបាល និងក្រសួងអប់រំក៏មានការលំបាក (UBB:FR2)។ នៅសាកលវិទ្យាល័យហ្សាម៉ាន់មិនមានគោលនយោបាយច្បាស់លាស់ ឬមានតម្លាភាពគ្រប់គ្រាន់ ដែលអាចឱ្យបុគ្គលិកទទួលបានមូលនិធិពីស្ថាប័នខាងក្រៅនោះទេ (Z:DH1)។ កន្លងមក នៅ UBB ក៏ធ្លាប់ទទួលបានការបណ្តុះបណ្តាលក្នុងការសរសេរសំណើនោះដែរ ប៉ុន្តែពួកគេក៏ត្រូវការការបណ្តុះបណ្តាលបន្ថែមទៀតសម្រាប់ក្រុមការងារបច្ចុប្បន្ននេះ។ វាបង្ហាញឱ្យយើងឃើញក្រុមខ្លះ (Z:DH2) បានដឹងពីរបៀបធ្វើគម្រោងដើម្បីទទួលបានថវិកាពីស្ថាប័នផ្សេងៗ ប៉ុន្តែក្រុមខ្លះទៀតក៏មិនដឹង ដែលជាហេតុធ្វើឱ្យពួកគេមិនទទួលបានថវិកា។ អ្វីដែលយើងឃើញនៅចំណុចនេះ គឺតម្រូវឱ្យពួកគេពង្រឹងសមត្ថភាពក្នុងការ

សរសេរសំណើ និងធ្វើការស្រាវជ្រាវរកបន្ថែមទៀតទៅលើស្ថាប័នណាដែលមានលទ្ធភាពអាចផ្តល់មូលនិធិឱ្យពួកគេបាន។ គេហទំព័ររបស់យើងនឹងផ្តល់ជូនព័ត៌មានមួយចំនួនទាក់ទងនឹងឱកាសនៃការទទួលបានមូលនិធិពីស្ថាប័នផ្សេងៗ ហើយក៏អាចប្រើប្រាស់គេហទំព័រនេះដើម្បីធ្វើការទំនាក់ទំនងគ្នាដែរ។

បញ្ហាបន្ថែមទៀតនោះគឺទាក់ទងជាមួយនឹងម្ចាស់ជំនួយ ការប្រឹក្សាយោបល់ និងកិច្ចផ្តួចផ្តើមការស្រាវជ្រាវដែលក្រសួងផែនការមិនមានថវិកាដើម្បីធ្វើសកម្មភាពជំរឿន (ពួកគេទាំងអស់មានម្ចាស់ជំនួយក្នុងការផ្តល់មូលនិធិ)។ ការធ្វើជំរឿននៅឆ្នាំ២០១៨ មិនមានការផ្តល់មូលនិធិពីម្ចាស់ជំនួយណាមួយទេ ហើយ រដ្ឋាភិបាលបច្ចុប្បន្នកំពុងតែស្វែងរកការគាំទ្រនេះ (ត្រូវការថវិកាប្រហែល ៨លានដុល្លារដើម្បីធ្វើការជំរឿន)។ ពួកគេក៏ខ្វះថវិកាដើម្បីធ្វើការផ្សព្វផ្សាយ និងការស្រាវជ្រាវលើកិច្ចការរបស់ពួកគេដែរ (MoP1)។ ផលប៉ះពាល់នេះអាចជះឥទ្ធិពលទៅលើអារម្មណ៍របស់ក្រុមអ្នកស្រាវជ្រាវ ហើយទិន្នន័យស្ថិតិដែលបានមកពីរដ្ឋាភិបាលក៏មានការពិបាកក្នុងការដាក់ឱ្យដំណើរការមិនមានភាពទាន់សម័យ និងមិនមានគុណភាព។ ទោះជាយ៉ាងណា ក្រសួងផែនការបានរាយការណ៍ថា ពួកគេមានប្រាក់សំណាងគ្រប់គ្រាន់ដើម្បីឱ្យទៅក្រុមអ្នកស្រាវជ្រាវ "យោងតាមតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង" (MoP2)។ ទំហំនៃប្រាក់សំណាងនេះត្រូវបានប្រើដើម្បីធ្វើការស៊ើបអង្កេតបន្ថែមនៅលើការពិគ្រោះយោបល់ ដោយត្រូវដឹងពីរបៀបដែលក្រសួងគ្រប់គ្រងប្រាក់សំណាងទៅកាន់អ្នកស្រាវជ្រាវទាំងនោះ ប៉ុន្តែមិនមែនប្រើប្រាស់សម្រាប់ការធ្វើជំរឿន និងសកម្មភាពនៃការធ្វើជំរឿនដែលពឹងផ្អែកលើការគាំទ្រពីខាងក្រៅ (ពិគ្រោះយោបល់អន្តរជាតិ) នោះទេ។ ទាំងនេះបានបង្ហាញថា ការស្រាវជ្រាវគឺជាអាជីពដែលទទួលបានផលចំណេញនៅកម្ពុជា (មានទីផ្សារសម្រាប់អ្នកពិគ្រោះយោបល់) ហើយក៏មានការផ្លាស់ប្តូរការគិតមួយចំនួន(មិនទទួលផលចំណេញ) នៅពេលដែលអ្នកពិគ្រោះយោបល់នៃការស្រាវជ្រាវខ្លះទទួលបានប្រាក់កម្រៃសមរម្យ ក៏ដូចជាបានជំរុញឱ្យមានការបណ្តុះ បណ្តាលនិស្សិត ដើម្បីចូលរួមក្នុងទីផ្សារការងារដែរ។

**ប្រាក់បៀវត្សរ៍ និងការលើកកម្ពស់**

ទីនេះគឺជាកន្លែងមួយសម្រាប់ធ្វើការអភិវឌ្ឍ និងការពិនិត្យពិច័យរបស់អ្នកធ្វើគោលនយោបាយរួមគ្នាជាមួយអ្នកគ្រប់គ្រង។ នៅក្នុងប្រាក់ចំណូលនៃសេដ្ឋកិច្ចរបស់យើង ការបើកប្រាក់ខែគឺជាផលចំណេញតូចបំផុតនៃមូលធនរបស់យើង ហើយការចាយវាយក៏មានលក្ខណៈត្បិតត្បៀតដែរ។ យើងមិនឃើញមានប្រាក់ឧបត្ថម្ភសម្រាប់ប្រាក់ខែមូលដ្ឋាន នៃគោលនយោបាយការស្រាវជ្រាវដែលបានដាក់ចេញដោយក្រសួង ឬអ្នកគ្រប់គ្រងណាមួយនោះទេ។ នេះគឺជារឿងដែលគួរឱ្យព្រួយបារម្ភមួយ ព្រោះមានការយកចិត្តទុកដាក់តិចបំផុតក្នុងការផ្តល់ប្រាក់ឈ្នួល ខណៈដែលប្រទេសកម្ពុជាកំពុងមានការផ្លាស់ប្តូរបន្តិចបន្តួចនេះ។

សាកលវិទ្យាល័យមួយចំនួនកំពុងចាប់ផ្តើមលើកកម្ពស់វិស័យសិក្សា ដោយជំរុញឱ្យមានការបង់ប្រាក់បន្ថែមដើម្បីទទួលបានការអប់រំកម្រិតខ្ពស់(UBB:DR)។ នៅសាកលវិទ្យាល័យបាត់ដំបង និងសាកលវិទ្យាល័យហ្សាម៉ាន់ ប្រាក់ខែដែលសាស្ត្រាចារ្យទទួលបានពីការបង្រៀនគឺត្រូវផ្អែកទៅលើកម្រិតនៃការអប់រំ និងបទពិសោធន៍នៃការស្រាវជ្រាវរបស់ពួកគេ (Z:Dean1; UBB:DR)។ សាកលវិទ្យាល័យហ្សាម៉ាន់ ក៏សង្ឃឹមផងដែរថា ពួកគេនឹងបង្កើតកម្មវិធីមួយដើម្បី "ធ្វើឱ្យមានការរួមសហការគ្នារវាងសាស្ត្រាចារ្យ និងបណ្ឌិត" ដោយផ្អែកលើស្នាដៃនៃការស្រាវជ្រាវរបស់ពួកគេ (Z:Dean1)។ សាកលវិទ្យាល័យបញ្ញាសាស្ត្រគ្រោងនឹងអនុវត្តប្រព័ន្ធមួយដែលមានសិទ្ធិគ្រប់គ្រាន់ (Tenureship system) ដោយផ្អែកលើការបង្រៀន (៥០%)ការស្រាវជ្រាវ (៣០%)និងសកម្មភាពក្រៅកម្មវិធីសិក្សា (២០%)។ ក្នុងពេលនេះសាកលវិទ្យាល័យ "បានខិតខំធ្វើការដើម្បីផ្តល់ការគាំទ្រផ្នែកស្មារតី" ចំពោះមហាវិទ្យាល័យណាដែលទទួលបានកិច្ចសន្យាឱ្យធ្វើការស្រាវជ្រាវ ទាំងលក្ខណៈបុគ្គល និងទាំងការសហការជាមួយនឹងរដ្ឋាភិបាល។ ខណៈដែលគម្រោងទាំងនេះបានបង្ហាញសញ្ញាវិជ្ជមាននាពេលអនាគតនោះ ក៏មានការពិតមួយចំនួនកើតមានឡើងនាពេលបច្ចុប្បន្ន "ដែលនាំឱ្យមានអត្ថប្រយោជន៍រយៈពេលយូរដូចជា ការផ្សព្វផ្សាយ ការដំឡើងប្រាក់ខែ និងការទំនាក់ទំនងក្នុងសង្គមដើម្បីក្លាយទៅជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យមួយ ដែលទាមទារឱ្យមានភាពលំបាក" (NUM:DR)។ វាជាការលំបាកសម្រាប់សាលារៀននៅតាមបណ្តាខេត្តក្នុងការស្វែងរក ក៏ដូចជាការរក្សាទុកក្រុមអ្នកស្រាវជ្រាវដែលមានសមត្ថភាពគ្រប់គ្រាន់ (UBB:DR) ព្រោះប្រាក់ខែរបស់ពួកគេនៅមានកម្រិតទាបខ្លាំងណាស់។ ចំណែកឯនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ថវិកាសម្រាប់ការស្រាវជ្រាវមិនមានភាពគ្រប់គ្រាន់ក្នុងការធានាឱ្យអ្នកស្រាវជ្រាវរស់នៅបានដោយសមរម្យនោះទេ (RULE; Dean1:DH)។

## ការលើកទឹកចិត្តអ្នកស្រាវជ្រាវ

ដើម្បីជំរុញបន្ថែមលើការងារស្រាវជ្រាវរបស់ខ្លួន សាកលវិទ្យាល័យមួយចំនួនបានបង្កើនប្រាក់ឈ្នួលសម្រាប់អ្នកស្រាវជ្រាវទាំងអស់ លើការបង្កើតអត្ថបទផ្សេងៗ និងការបោះពុម្ពជាសៀវភៅ។ ឧទាហរណ៍ សាស្ត្រាចារ្យនៅUBBត្រូវបានគេផ្តល់ប្រាក់បៀវត្សរ៍ខ្ពស់ជាងមុន ប្រសិនបើពួកគាត់បង្ហាញឯកសារនានាដែលបានបោះពុម្ពផ្សាយ។ សាស្ត្រាចារ្យទាំងអស់នឹងទទួលបានពី USD ១-២ បន្ថែមទៀតក្នុងមួយម៉ោងសម្រាប់ការបោះពុម្ពផ្សាយជាបន្តបន្ទាប់របស់ពួកគាត់ (UBB:DR)។ RUA បានផ្តល់ងារជាសាស្ត្រាចារ្យពេញសិទ្ធិ សម្រាប់គ្រូបង្រៀនណាដែលសម្រេចបានការស្រាវជ្រាវ និងផ្តល់ប្រាក់ឈ្នួលខ្ពស់ ក៏ដូចជាផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីបន្តធ្វើការងារនេះទៀត (RUA:Dean4)។

រង្វាន់ផ្សេងៗក៏ត្រូវបានគេផ្តល់ឱ្យសម្រាប់ការងារបោះពុម្ពផ្សាយដែរ។ នៅហ្សាម៉ាន់ សាកលវិទ្យាល័យបានចំណាយទាំងអស់លើការបោះពុម្ពផ្សាយ និងផ្តល់ការលើកទឹកចិត្តចំពោះការសរសេរលទ្ធផលនៃការស្រាវជ្រាវនីមួយៗ ហើយនៅឆ្នាំក្រោយសាកលវិទ្យាល័យនេះមានផែនការផ្តល់ថវិកាឱ្យ

មហាវិទ្យាល័យនីមួយៗចំនួន USD ៣០០ រាល់ការបោះពុម្ពផ្សាយសៀវភៅមួយលើកៗ។ សាកលវិទ្យាល័យជាតិគ្រប់គ្រងជំនួយខ្នាតតូចមួយសម្រាប់ការងារស្រាវជ្រាវពេញមួយឆ្នាំ ដែលមានចំនួនសរុបប្រហែល USD ១០០.០០០ និងការលើកទឹកចិត្តចំនួន USD ៨០០ ចំពោះការបោះពុម្ពផ្សាយអត្ថបទមួយ (NUM:Dean4; NUM:FR1)។ ថវិកាសម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រត្រូវបានគេប្រើសម្រាប់ការបោះពុម្ពផ្សាយ ប៉ុន្តែចំនួនទឹកប្រាក់ដែលបានបែងចែកនោះគឺមិនមានភាពច្បាស់លាស់នោះទេ។ សាស្ត្រាចារ្យម្នាក់អាចទទួលបានប្រាក់រហូតដល់ទៅ USD១.៥០០ ក្នុងការលើកទឹកចិត្តគាត់ដើម្បីបោះពុម្ពសៀវភៅ ឬអត្ថបទផ្សេងៗ (RULE:Dean1; DH)។ សាកលវិទ្យាល័យមួយចំនួនទៀតក៏បានផ្តល់នូវមូលនិធិសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការធ្វើដំណើរទៅកាន់កិច្ចប្រជុំផ្សេងៗដែរ។ ធនាគារពិភពលោកក៏បានឧបត្ថម្ភថវិកាមួយចំនួនឱ្យសាកលវិទ្យាល័យជាតិគ្រប់គ្រងសម្រាប់ការបណ្តុះបណ្តាលអ្នកស្រាវជ្រាវឱ្យយល់ដឹងពីវិធីសាស្ត្រនៃការធ្វើការងារនេះ និងការចុះទៅសហគមន៍ផ្ទាល់ដែរ (NUM:DH; NUM:F1)។ ដោយឡែក សាកលវិទ្យាល័យហ្សាម៉ាន់ បានគាំទ្រឱ្យសាស្ត្រាចារ្យរបស់ខ្លួនចូលរួមក្នុងសន្និសីទនានា ដោយសាលាផ្តល់ជូននូវរាល់ការចំណាយផ្សេងៗ និងការចំណាយលើសំបុត្រយន្តហោះ (Z:DH2)។

ការលើកទឹកចិត្តទាំងអស់នេះពិតជាមានសារៈសំខាន់ ហើយក៏ជាការបោះជំហានទៅមុខមួយដើម្បីកសាង និងជំរុញកិច្ចការស្រាវជ្រាវឱ្យមានភាពរស់រវើក។ ទោះជាយ៉ាងណាក៏ដោយ យើងបានសម្ភាសជាមួយនឹងសាស្ត្រាចារ្យមួយចំនួន ហើយលទ្ធផលបានបង្ហាញថា ការយល់ដឹងរបស់ពួកគាត់នៅមានកម្រិត ជាពិសេសក្នុងចំណោមសាស្ត្រាចារ្យជាច្រើនដែលមានឱកាសទទួលបានកញ្ចប់ថវិកាសម្រាប់ធ្វើការស្រាវជ្រាវ (NUM:DG)។ យើងសូមផ្តល់យោបល់យ៉ាងមុតមាំមួយថា ការស្រាវជ្រាវរបស់ស្ថាប័ននីមួយៗនៅពេលអនាគត គួរតែធ្វើឡើងដើម្បីឱ្យអ្នកស្រាវជ្រាវទាំងនោះទទួលបានការដំឡើងប្រាក់បៀវត្សរ៍ និងប្រាក់បន្ថែមសម្រាប់ការបោះពុម្ពផ្សាយរបស់ពួកគេ។ ដំណើរការនេះគួរតែធ្វើឡើងដើម្បីបង្កើតភាពងាយស្រួលក្នុងការបំពេញទម្រង់បែបបទនានាទាក់ទងនឹងការផ្តល់មូលនិធិ និងការផ្សព្វផ្សាយទៅកាន់ស្ថាប័នដែលផ្តល់មូលនិធិសម្រាប់ការបោះពុម្ព ក៏ដូចជាការអភិវឌ្ឍសមត្ថភាពដើម្បីសម្រេចចេញនូវលទ្ធផលដែលចង់បាន។

លើសពីនេះទៅទៀត ការលើកទឹកចិត្តក្នុងការស្រាវជ្រាវមានភាពតានតឹងច្រើន ដែលពេលខ្លះវាប្រៀបដូចជាការរុំក្រណាត់បិទដំបៅលើឆ្អឹងដែលបាក់ ដែលវានឹងសះដោយខ្លួនឯង (like a Band-Aid on a compound fracture if enacted by itself.)។ នៅករណីក្នុងប្រទេសកម្ពុជា គឺតម្រូវឱ្យយើងធ្វើការងារមួយចំនួន ប៉ុន្តែការលើកទឹកចិត្តគួរតែត្រូវធ្វើឡើងក្នុងការកែសម្រួលនៃរចនាសម្ព័ន្ធ ដូចជាការបន្ថែមប្រាក់ខែ និងមិនរំពឹងថាមានអ្វីផ្សេងជំនួសវិធីនេះឡើយ។ ឧទាហរណ៍ ដូចជានៅសាកលវិទ្យាល័យហ្សាម៉ាន់ គេបានបញ្ជាក់យ៉ាងច្បាស់នូវវិធីសាស្ត្រក្នុងការរួមបញ្ចូលគ្នាទាំងការលើកទឹកចិត្ត

ផ្នែកហិរញ្ញវត្ថុ និងបរិបទវិជ្ជមាននៃការស្រាវជ្រាវដែលប្រៀបដូចជាអាទិភាពរបស់ស្ថាប័នមួយ។ ព្រឹទ្ធបុរសមួយរូបបានរាយការណ៍ថា "ស្ថាប័ននេះនឹងស្វែងរកការបង្កើតបរិយាកាសល្អៗសម្រាប់ធ្វើការស្រាវជ្រាវ ដោយផ្តល់នូវពេលវេលាគ្រប់គ្រាន់សម្រាប់មហាវិទ្យាល័យនីមួយៗ ក៏ដូចជាសិស្សនិស្សិតដើម្បីធ្វើការស្រាវជ្រាវ ព្រមទាំងផ្តល់ជូននូវសម្ភារៈបរិក្ខារដូចជាម៉ាស៊ីនត្រជាក់ ការតភ្ជាប់អ៊ីនធើណិត និងការជាវអត្ថបទតាមបណ្តាអ៊ីនធើណិតមួយចំនួនដែរ"។

## ភាពលេចធ្លោនៃការស្រាវជ្រាវជាភាសាអង់គ្លេស

បើតាមការលើកឡើងរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្រ សាកលវិទ្យាល័យមានជ័យ សាកលវិទ្យាល័យបាត់ដំបង និងសាកលវិទ្យាល័យហ្សាម៉ាន់ បានរាយការណ៍ថា ការធ្វើការងារស្រាវជ្រាវជាភាសាអង់គ្លេសគឺពិតជាមានភាពលំបាក។ មានបញ្ហាជាច្រើនចំពោះការប្រើប្រាស់ភាសាអង់គ្លេសដ៏ច្រើនលើសលប់នេះ ពោលគឺវាហួសពីបញ្ហាប្រឈមរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាសំខាន់ៗទាំងនោះត្រូវបានអ្នកឆ្លើយតបរបស់ប្រទេសកម្ពុជាលើកឡើងថាតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត (RUA:Dean1)។ ជាទូទៅ អ្នកស្រាវជ្រាវដែលមានវ័យចំណាស់ត្រូវបានគេជំរុញបន្ថែមទៅលើសមត្ថភាពនៃភាសាអង់គ្លេសរបស់ពួកគេ ជាក់ស្តែងដូចជាស្ថាប័ននៅតាមជនបទមួយចំនួន ដែលសាស្ត្រាចារ្យមិនមានសមត្ថភាពក្នុងការយល់ដឹងពីភាសាអង់គ្លេសបានជ្រៅជ្រះនោះទេ (SRU:F1,F2,F3)។ សាស្ត្រាចារ្យមួយរូបរបស់សាកលវិទ្យាល័យហ្សាម៉ាន់បានកត់សម្គាល់ឃើញថា នៅពេលដែលនរណាម្នាក់ធ្វើការស្រាវជ្រាវជាភាសាអង់គ្លេស ប្រភេទជាក់លាក់នៃព័ត៌មានទាំងនោះគឺវាងាយស្រួលយល់ ដូចជាសៀវភៅដែលរិះគន់រដ្ឋាភិបាលជាដើម។ ចំពោះការឆ្លើយតបរបស់យើង យើងបានចោទជាសំណួរថា "តើមានអ្វីកើតឡើងចំពោះអ្នកដែលធ្វើការស្រាវជ្រាវជាភាសាខ្មែរ?" (Z:F)។ មួយវិញទៀត យើងក៏អាចសួរសំណួរដែលទាក់ទងនឹងវិសាលភាពនៃវប្បធម៌ ក៏ដូចជាធាតុផ្សំផ្សេងៗនៃប្រវត្តិសាស្ត្រដែលទាក់ទងជាមួយនឹងចំណេះដឹងរបស់ប្រជាជនកម្ពុជា ការឱ្យតម្លៃរឿងរ៉ាវសាសនា និងដំណើរការនៃនយោបាយ ដែលមានការបកស្រាយខុស ឬមិនឱ្យតម្លៃចំពោះការស្រាវជ្រាវជាភាសាអង់គ្លេស។

មិនមានបញ្ហាទាក់ទងជាមួយនឹងគុណភាពនៃការស្រាវជ្រាវរបស់ពួកគេនោះទេ ចំពោះអ្នកស្រាវជ្រាវដែលមិនអាចអាន ឬសរសេរភាសាអង់គ្លេសក្នុងកម្រិតខ្ពស់បាន ពួកគេតែងតែជួបប្រទះជាមួយនឹងបញ្ហាលំបាកមួយចំនួនដូចជា ក្នុងពេលដែលពួកគេពិគ្រោះយោបល់ទាក់ទងនឹងការងារបោះពុម្ពផ្សាយតាមរយៈ(online) (DCCAM:D) ពេលបោះពុម្ព (NUM:ST) និងសមត្ថភាពរបស់ខ្លួនដើម្បីទទួលបានប្រភពថវិកានោះ។ សាកលវិទ្យាល័យមួយចំនួន ជាក់ស្តែងដូចជា USEA "វគ្គសិក្សាភាគច្រើនត្រូវបានបង្រៀនជាភាសាខ្មែរ ប៉ុន្តែការស្រាវជ្រាវភាគច្រើនគឺតម្រូវឱ្យធ្វើជាភាសាអង់គ្លេសដោយសារតែទទួលបានថវិកាមកពីម្ចាស់ជំនួយបរទេស។ យើងមិនអាចសរសេរសំណើ និងអត្ថបទនៃ

ការស្រាវជ្រាវជាភាសាខ្មែរបានទេ" (USEA:VPR)។ ទោះបីជាចំនួននៃវគ្គបណ្តុះបណ្តាលអ្នកស្រាវជ្រាវនៅកម្ពុជាមានភាពកើនឡើងក៏ដោយ ក៏ភាពចាំបាច់ក្នុងការសរសេរជាភាសាអង់គ្លេសត្រូវបានគេកាត់បន្ថយ យើងបានសម្ភាសអ្នកដែលបានចូលរួមក្នុង CCHR ដែលបានកត់សម្គាល់ឃើញថា នៅពេលធ្វើការប្រៀបធៀបរវាងសមាជិកអ្នកស្រាវជ្រាវក្នុងស្រុកនៃក្រុមរបស់នាងជាមួយនឹងក្រុមប្រឹក្សានៃអ្នកស្រាវជ្រាវអន្តរជាតិឃើញថា "វាជាការលំបាកណាស់ក្នុងការនិយាយថា តើនរណាជាអ្នកដឹកនាំក្រុមនៅក្នុងអង្គការនេះ? ជាទូទៅ តែងតែមានបញ្ហាក្នុងការសរសេរ"(CCHR:SR)។

តាមរយៈការសង្កេតរបស់យើង និស្សិតម្នាក់បានប្រាប់យើងថា "បញ្ហាប្រឈមនោះគឺមកពីការស្រាវជ្រាវតម្រូវឱ្យយើងអានជាភាសាអង់គ្លេស ដូច្នេះវាជាមូលហេតុដែលនាំឱ្យយើងមានការខ្វះខាតក្រុមអ្នកស្រាវជ្រាវក្នុងប្រទេសកម្ពុជា"។ ប្រជាជនកម្ពុជាភាគច្រើនមិនអាចចាប់យកការអប់រំជាភាសាអង់គ្លេសបានទេ ហើយភាពលំបាកនៃការផ្តល់ការអប់រំជាភាសាអង់គ្លេសក៏មានទំហំធំ ដែលធ្វើឱ្យពួកគេពិបាកក្នុងការដោះស្រាយបញ្ហាទាំងនេះ។ ចំណុចដែលសំខាន់អំពីបញ្ហានេះ គឺវាស្ថិតនៅក្នុងដំណើរនៃការស្វែងរកមួយដើម្បីឱ្យក្លាយទៅជា "ទីផ្សារមួយដែលឋិតថេរ (market viable)" ភាពសម្បូរបែបនៃប្រវត្តិសាស្ត្រខ្មែរ និងភាពចាក់ឫសជ្រៅនៃប្រព័ន្ធសង្គមដែលអាចកាត់ផ្តាច់លទ្ធភាពនៃភាពជោគជ័យក្នុងការធ្វើពាណិជ្ជកម្ម។

## សមត្ថភាពក្នុងការបង្កើតការស្រាវជ្រាវ

ទន្ទឹមនឹងបញ្ហាដែលទាក់ទងជាមួយនឹងដែនកំណត់របស់ហិរញ្ញវត្ថុ និងកង្វះខាតនៃការលើកទឹកចិត្តអ្នកស្រាវជ្រាវ ដែលយើងបានរៀបរាប់ខាងលើ យើងក៏បានផ្សារភ្ជាប់ភាពខ្វះខាតនៃការបណ្តុះបណ្តាល និងជំនាញក្នុងការស្រាវជ្រាវជាបឋម និងជាមធ្យម ដែលត្រូវបានរាយការណ៍យ៉ាងទូលំទូលាយដោយអ្នកឆ្លើយតបរបស់យើង។ នៅក្នុងផ្នែកនេះយើងបង្ហាញពីបញ្ហានានាដែលទាក់ទងនឹងភាពខ្វះខាតនៃការបណ្តុះបណ្តាល ក៏ដូចជាការអភិវឌ្ឍជំនាញ និងការផ្តួចផ្តើមនាពេលបច្ចុប្បន្នដើម្បី"កសាងសមត្ថភាព"។

## បញ្ហាប្រឈមនៃការកែប្រែសមត្ថភាពក្នុងបរិស្ថានការងារស្រាវជ្រាវ

បើយោងតាមមតិឆ្លើយតបដែលយើងប្រមូលបាននៅពេលសម្ភាសជាមួយបុគ្គលិកធនាគារពិភពលោក គឺនៅមានបញ្ហាច្រើនទាក់ទងនឹងការងាររដ្ឋបាលរបស់កម្ពុជាពីមួយជំនាន់ទៅមួយជំនាន់ នៅពេលដែលយើងធ្វើការប្រៀបធៀបពីបទពិសោធន៍ដែលយើងធ្លាប់ធ្វើការជាមួយមន្ត្រីកម្ពុជា និងពេលធ្វើការជាមួយរដ្ឋាភិបាលផ្សេងទៀត។ "ប្រជាជនកម្ពុជាមានវ័យក្មេង។ នៅប្រទេសផ្សេងទៀត រដ្ឋមន្ត្រីកំពូលៗគឺស្ថិតនៅក្នុងវ័យ ៥០ឆ្នាំនិង ៦០ឆ្នាំ។ នៅក្នុងប្រទេសកម្ពុជា រដ្ឋមន្ត្រីកំពូលៗស្ថិតក្នុងវ័យពី ៣០ឆ្នាំនិង ៤០ឆ្នាំ។ នេះក៏ជាបញ្ហាប្រឈមមួយសម្រាប់ការដឹកនាំរបស់កម្ពុជា ខណៈមានមន្ត្រីក្មេងៗដែលមានបទពិសោធន៍តិច" (WB1)។ នៅក្នុងសេចក្តីថ្លែងការណ៍នៃក្រុមអ្នកស្រាវជ្រាវរបស់

យើង បានសិក្សាអំពីក្រុមអ្នកស្រាវជ្រាវវ័យចំណាស់ ដែលធ្វើការដោយគ្មានប្រសិទ្ធភាព ក៏អាចជាផ្នែកមួយនៃរឿងនេះដែរ។ មនុស្សចាស់ៗជាច្រើនដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមិនបានទទួលការអប់រំ និងជាញឹកញាប់ត្រូវបានគេតែងតាំងដោយគិតទៅលើសមត្ថភាពរបស់ពួកគាត់ ជាជាងជម្រើសផ្សេងទៀត។ ការទន្ទឹងរង់ចាំស្ថិតិជាផ្លូវការទាក់ទងនឹងបញ្ហាប្រជាសាស្ត្រលក្ខណសម្បត្តិដែលរួមបញ្ចូលទាំងមន្ត្រីខ្លួនឯង ថាតើបានចូលរួមឬក៏អត់ ក្នុងការស្រាវជ្រាវ ជុំវិញសកម្មភាពនៅក្នុងតំបន់ដែលក្រសួងនីមួយៗទទួលបន្ទុក និងមានការសន្និដ្ឋានមួយចំនួនត្រូវបានគេដកចេញ ប៉ុន្តែក៏តម្រូវឱ្យមានការស៊ើបអង្កេតបន្ថែមទៀតដែរ។

បញ្ហាស្ថិតនៅលើការបណ្តុះបណ្តាលមិនគ្រប់គ្រាន់នៅកម្រិតមូលដ្ឋានក្នុងកិច្ចការស្រាវជ្រាវ និងការកំណត់សមត្ថភាពក្នុងជំនាញនៃការសរសេរដែលជំរុញឱ្យយើងអនុវត្ត និងបង្កើតការស្រាវជ្រាវនេះឡើង។ ការវាយតម្លៃនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់តាមរយៈការសិក្សារបស់យើង។ អ្នកគ្រប់គ្រងជាច្រើនបានត្អូញត្អែរថា "ពួកគេមិនត្រូវបានបង្រៀនពីរបៀបធ្វើការស្រាវជ្រាវនោះទេ" (PUA:DA) ហើយក្រុមអ្នកស្រាវជ្រាវ "មិនមានគោលដៅច្បាស់លាស់ដើម្បីកំណត់ព្រំដែននៃគម្រោងស្រាវជ្រាវរបស់ពួកគេដែរ" (PUC:VP)។ ចំពោះ "បណ្ណាល័យក៏មិនសូវមានការប្រើប្រាស់" និងមាន "ការភ័យខ្លាចចំពោះស្ថិតិផ្សេងៗ" (PUC:DA)។ សាស្ត្រាចារ្យមួយចំនួន "ទើបតែបញ្ចប់ការសិក្សា និងមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើការស្រាវជ្រាវ" (RUPP-IFL: DH)។ សាស្ត្រាចារ្យមួយចំនួនបាននិយាយថា ពួកគេមិនមានសមត្ថភាពក្នុងការធ្វើការងារស្រាវជ្រាវនោះទេ ព្រោះពួកគេមិនដឹងពីរបៀបវិភាគទិន្នន័យ មិនដឹងពីរបៀបសរសេរសំណើ ឬយុទ្ធសាស្ត្រនៃការស្រាវជ្រាវ (SRU:F1,F2,F3)។ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រងបានរៀបរាប់ពីទុក្ខលំបាករបស់ស្ថាប័នគាត់ថា "NUM មិនមានបញ្ហាជាមួយថវិកាសម្រាប់មហាវិទ្យាល័យដើម្បីធ្វើការស្រាវជ្រាវទេ ប៉ុន្តែយើងពុំមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីធ្វើការស្រាវជ្រាវ" (NUM:PR)។

និស្សិតនៅ SRU ក៏បានត្អូញត្អែរដែរថា "សាកលវិទ្យាល័យយើងមិនមានសាស្ត្រាចារ្យដែលមានចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងការស្រាវជ្រាវនោះទេ" (SRU:PR)។ "ធនធានមនុស្សគឺជា [ឧបសគ្គ] ដ៏សំខាន់បំផុត"។ យើងឱ្យតម្លៃចំពោះការស្រាវជ្រាវ និងមានថវិកាគ្រប់គ្រាន់ដើម្បីធ្វើវា ប៉ុន្តែយើងមិនមានមនុស្សដែលមានជំនាញពិតប្រាកដ យើងក៏មិនអាចធ្វើវាដោយងាយស្រួលដែរ (USEA:F3)។ ភាពរឹងទទឹងចំពោះការកសាងសមត្ថភាព ត្រូវបានរកឃើញក្នុងចំណោមសិស្ស និស្សិត និងសាស្ត្រាចារ្យនៅ UBB។ ទាំងនិស្សិត និងសាស្ត្រាចារ្យ មិនចង់ "មានការអភិវឌ្ឍខ្លួន" ដូចជាមិនចង់រៀនអ្វីដែលថ្មី ដែលផ្ទុយពីអ្វីដែលពួកគេបានរៀន និងមិនចង់បង្កើនចំណេះដឹងរបស់ខ្លួននោះទេ។ សូម្បីតែការបង្រៀនទាក់ទង់នឹងវិធីសាស្ត្រ ស្ថិតិក៏មានភាពហួសសម័យដែរ។ នាយកបានកត់សម្គាល់ឃើញថា វាជាការទទួលខុសត្រូវរបស់គាត់ក្នុងការផ្លាស់ប្តូរលក្ខខណ្ឌទាំងនេះ(UBB:PR)។

## ការបន្លំ និងលួចចម្លងជាបញ្ហាដែលប៉ះពាល់ក្នុងការអភិវឌ្ឍសមត្ថភាព

ការលួចចម្លងរបស់និស្សិត គឺវាមានប្រវត្តិជាយូរណាស់មកហើយសម្រាប់ប្រទេសកម្ពុជា ហើយមួយវិញទៀត យើងក៏ធ្លាប់បានជួបប្រទះបញ្ហានេះនៅក្នុងករណីស៊ើបអង្កេតរបស់យើងដែរ។ យើងចង់ឱ្យមានការផ្លាស់ប្តូរចំពោះទស្សនៈបែបនេះសម្រាប់សាកលវិទ្យាល័យទាំងនោះ។ នាយកផ្នែកស្រាវជ្រាវរបស់សាកលវិទ្យាល័យបញ្ញាសាស្ត្របានធ្វើការប៉ាន់ប្រមាណថា ៣០%នៃសិស្ស និស្សិតបានធ្វើការលួចចម្លង។ ចំពោះ NUM ក៏បានរាយការណ៍ពីដែនកំណត់សំខាន់ៗទាក់ទងនឹងការអភិវឌ្ឍសមត្ថភាពរបស់និស្សិតដែរ ព្រមទទួលយកការលួចចម្លងរបស់សិស្ស និស្សិត និងមហាវិទ្យាល័យនីមួយៗ (NUM:PR)។ នៅក្នុងកិច្ចពិភាក្សាតុមូលរបស់និស្សិត RUA បានស្នើថា ពួកគេគួរតែមានសិទ្ធិក្នុងការបង្កើតទិន្នន្យប្បវត្តិ និងប្រើប្រាស់ឯកសារយោងណាដែលល្អៗ ប៉ុន្តែពួកគេបានកត់សម្គាល់ថា ច្បាប់ដែលទាក់ទងនឹងឯកសារយោង "មិនមានភាពច្បាស់លាស់" ហើយគោលការណ៍ណែនាំនៃការលួចចម្លងក៏ "មិនតឹងរ៉ឹង" ដែរ (RUA:SRT)។ មហាវិទ្យាល័យរបស់សាកលវិទ្យាល័យមួយចំនួនយល់ឃើញថា អ្នកស្រាវជ្រាវ "ធ្វើការលួចបន្លំ" យកគំនិតអ្នកដទៃមកធ្វើជារបស់ខ្លួន។ សាស្ត្រាចារ្យម្នាក់របស់ USEA បានផ្តល់យោបល់ថា "ការស្រាវជ្រាវនោះនឹងទទួលបានការឱ្យតម្លៃ ដែលមានកម្រិតទាប ព្រោះពួកគេមិនគោរពប្រភពដើម និងកម្មសិទ្ធិបញ្ញា" នោះទេ (USEA:F3)។ ជាទូទៅត្រូវបានគេគិតថាដោយសារតែកង្វះការយល់ដឹងទាក់ទងនឹងការរៀបចំឯកសារយោង និងការស្រាវជ្រាវកេងឯកសារផ្សេងៗ (USEA:F1;F3)។

នាយក DC-Cam បានលើកឡើងថា កត្តាដែលនាំឱ្យមានការលួចចម្លងរបស់ក្រុមអ្នកស្រាវជ្រាវក្នុងស្រុកគឺដោយសារតែពួកគេមិនដឹងពីរបៀបនៃការដកស្រង់ប្រយោគ និងការប្រើប្រាស់ឯកសារយោងទាំងនោះ។ "សាលារបស់ពួកគេមិនបានបណ្តុះបណ្តាលឱ្យមានភាពច្បាស់លាស់លើបញ្ហានេះ។ វាគឺជាឧបសគ្គដ៏ធំសម្រាប់ខ្ញុំដើម្បីដឹកនាំពួកគេឱ្យដឹងពីរបៀបនៃការប្រើប្រាស់ និងការដាក់ឯកសារយោងនេះឱ្យបានត្រឹមត្រូវ"។ "វិធីសាស្ត្រដែលពួកគេប្រើគឺត្រូវការកែតម្រូវឡើងវិញ"។ បញ្ហាដែលកើតឡើងមកពីការបណ្តុះបណ្តាលមិនគ្រប់គ្រាន់នេះបានបញ្ជាក់ឱ្យឃើញថា "សៀវភៅដែលសរសេរជាភាសាខ្មែរជាច្រើន មិនគោរពតាមស្តង់ដារ (តម្រូវឱ្យដាក់ឯកសារយោងត្រឹមត្រូវ) និងប្រើប្រាស់វិធីសាស្ត្រដែលមានកម្រិតទាប" (DCCAM:D)។ បើយោងតាមឧទាហរណ៍ដែលយើងបានលើកឡើង វាគឺជាការអភិវឌ្ឍសមត្ថភាពមួយដើម្បីធានាឱ្យបាន ការប្រើប្រាស់វិធីសម្រង់ពាក្យសម្តី ឬឃ្លារបស់នរណាម្នាក់យកមកប្រើឱ្យបានត្រឹមត្រូវ ហើយយើងក៏ទទូចសុំឱ្យមហាវិទ្យាល័យប្រើប្រាស់វិធីនេះផងដែរ។ នេះគឺជាបញ្ហារបស់ពិភពលោកក្នុងការកំណត់យកស្តង់ដាររួមមួយដែលនឹងកើតមានឡើងនាពេលខាងមុខ ហើយក៏ជារឿងសំខាន់មួយក្នុងការសង្កេតឃើញថា របាយការណ៍របស់ប្រទេសកម្ពុជាគឺមិនដូចគ្នានឹងរបាយការណ៍មុនៗនោះទេ។ ចេតនានៃសកម្មភាពក្នុងការលួចចម្លងដែលមានដូចជា

ការទិញចម្លើយ ឬជួលនរណាម្នាក់ឱ្យសរសេរនិក្ខេបបទ គឺមិនត្រូវបានគេលើកឡើងក្នុងឧទាហរណ៍ទាំងនេះទេ។

**ការអភិវឌ្ឍសមត្ថភាពរបស់អង្គការសង្គមស៊ីវិល** (CSOs)

បញ្ហាប្រឈមរបស់អង្គការសង្គមស៊ីវិលបានបង្ហាញថា ភាពជាដៃគូនៃការសិក្សាអាចជាលទ្ធផលដែលពួកគេទទួលបាន។ ថ្មីៗនេះ ការស្រាវជ្រាវរបស់អ្នកជំនាញកម្រិតខ្ពស់បំផុត មិនត្រូវបានគេរក្សាទុកនៅសាកលវិទ្យាល័យនោះទេ គឺគេប្រមូលផ្តុំទុកនៅវិទ្យាស្ថានអ្នកស្រាវជ្រាវ អង្គការសង្គមស៊ីវិល ឬអង្គការក្រៅ រដ្ឋាភិបាល។ មន្ត្រីរដ្ឋាភិបាលម្នាក់បានលើកឡើងថា សាកលវិទ្យាល័យគួរតែធ្វើការទាក់ទាញអ្នកជំនាញដែលមានចំណេះដឹងលើបញ្ហានេះ និងកែប្រែខ្លួនឱ្យក្លាយទៅជាស្ថាប័នស្រាវជ្រាវ (MoEYS1)។ អ្នកផ្សេងទៀតក៏បានកត់សម្គាល់ដែរថា ក្រុមអ្នកស្រាវជ្រាវគួរតែធ្វើការស្រាវជ្រាវសម្រាប់អង្គការមិនមែនរដ្ឋាភិបាល។ វាអាចជាឧបសគ្គមួយក្នុងការយកកម្មសិទ្ធិរបស់នរណាម្នាក់មកអនុវត្តលើទ្រឹស្តីនៃការស្រាវជ្រាវ ប៉ុន្តែវាក៏អាចជាឱកាស និងការប្រមូលផ្តុំគំនិតដែលការស្រាវជ្រាវ "គួរតែមានការសម្រេចចិត្តមួយច្បាស់លាស់ ចាប់ពីពេលដែលប្រើប្រាស់ធនធានផ្សេងៗនោះ និងបន្តធ្វើវាដើម្បីទទួលបានគោលបំណងតែមួយគត់ គឺចំណេះដឹង" (PUC:VP)។ ភាពជាដៃគូជាមួយអង្គការមិនមែន
រដ្ឋាភិបាល គឺជាអ្វីដែលគេគ្រប់គ្នាចង់បាន ព្រោះពួកគេមានឱកាសទទួលបានថវិកាឧបត្ថម្ភក្នុងការបណ្តុះបណ្តាលទាក់ទងនឹងការប្រមូលទិន្នន័យ ដែលបច្ចុប្បន្ននេះក្នុងកម្មវិធីរបស់គ្រឹះស្ថានឧត្តមសិក្សាកំពុងតែមានការខ្វះខាត (EC:PM)។

លើសពីនេះទៀត អង្គការក្រៅរដ្ឋាភិបាលដូចជាអង្គការសមធម៌កម្ពុជា បានកម្រិតលើការបណ្តុះបណ្តាលអ្នកស្រាវជ្រាវ ហើយពួកគេក៏មិនបានប្រាប់ពីវិធីសាស្ត្រនៃការស្រាវជ្រាវទៅដល់បុគ្គលិកដែលភាគច្រើនមានតែក្នុងកម្រិតសាកលវិទ្យាល័យប៉ុណ្ណោះ។ "យើងមិនធ្វើគម្រោងស្រាវជ្រាវទេ ប៉ុន្តែនៅក្នុងគម្រោងរបស់យើង គឺមានការធ្វើការស្រាវជ្រាវ។ ជាញឹកញាប់យើងតែងតែធ្វើវាជាមួយអ្នកពិគ្រោះយោបល់មកពីខាងក្រៅ ដែលជាបុគ្គលធ្លាប់ទទួលបានការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវយ៉ាងច្បាស់លាស់"។ សមត្ថភាពរបស់បុគ្គលិកក្នុងស្រុកនៅមានកម្រិតទាប ហើយវាក៏ជាបញ្ហាប្រឈមមួយរបស់អង្គការសង្គមស៊ីវិលដែលតម្រូវឱ្យបន្តធ្វើការស្រាវជ្រាវ ដើម្បីការគាំទ្រចំពោះការតស៊ូមតិ។ វិធីសាស្ត្រក្នុងការដាក់បញ្ចូលការស្រាវជ្រាវដែលទាក់ទងនឹងការសិក្សា គួរតែមានការពង្រឹងសកម្មភាពរបស់ EC។ នៅ CCHR ពួកគេកំពុងកសាងសមត្ថភាពរបស់ប្រជាពលរដ្ឋ ធ្វើយ៉ាងណាឱ្យពួកគេយល់ដឹងពីសិទ្ធិរបស់ខ្លួន ដើម្បីរាយការណ៍ពីសកម្មភាពការរំលោភបំពាន ធ្វើការស្វែងយល់ពីកន្លែងណាដែលពួកគេអាចពឹងពាក់បាន និងរបៀបទទួលយកទិន្នន័យតាមរយៈ "គេហទំព័រសិទ្ធិមនុស្សកម្ពុជា (www.sithi.org) ដែលមានផ្ទុកព័ត៌មានទាក់ទងនឹងច្បាប់ ក៏ដូចជារបាយការណ៍អំពីបញ្ហានៃរំលោភ

បំពានផ្សេងៗផងដែរ" (CCHR:SR)។ CCHR បានចូលរួមចែករំលែកព័ត៌មានទាក់ទងនឹងបញ្ហាសំខាន់ៗ ហើយក៏បានផ្តល់ឯកសារយោងផ្សេងៗឱ្យទៅក្រុមអ្នកស្រាវជ្រាវ និងអង្គការដែលកំពុងធ្វើ ឬចង់ធ្វើការស្រាវជ្រាវនៅកម្ពុជា (CCHR:PR)។ ការបង្ហាញពីការវិវឌ្ឍខ្លួនរបស់បណ្តាញសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈនេះ បានធ្វើឱ្យលទ្ធផលនៃការស្រាវជ្រាវមានភាពប្រសើរឡើង ហើយចំពោះសកម្មភាពដែលកំពុងបន្ត ក៏មានភាពរីកចម្រើនដែរ។ ការប្រើប្រាស់វិធីសាស្ត្រដ៏ទូលំទូលាយនេះ វាពិតជាបានជួយដោះស្រាយបញ្ហាប្រឈមជាច្រើនក្នុងគ្រឹះស្ថានឧត្តមសិក្សា។

**គំនិតផ្តួចផ្តើមថ្មីរបស់មជ្ឈដ្ឋានខាងក្រៅ និងក្នុងស្រុកដើម្បីអភិវឌ្ឍសមត្ថភាព**

យើងកត់សម្គាល់ឃើញថា មានការផ្លាស់ប្តូរច្រើនទាក់ទងនឹងបញ្ហាកង្វះសមត្ថភាពនេះ ហើយក៏មានការយកចិត្តទុកខ្លាំងផងដែរសម្រាប់ជម្នះរាល់ឧបសគ្គដែលនឹងកើតឡើងនៅឆ្នាំខាងមុខ។ អ្នកតំណាងឱ្យ DC-Cam មានអារម្មណ៍ថា បរិស្ថាននៃការស្រាវជ្រាវនៅកម្ពុជា មានសង្ឃឹមជោគជ័យជាងមុនច្រើន ដោយសារតែពួកគេមានឱកាសក្នុងការកសាងសមត្ថភាព។ យើងមានក្រុមអ្នកស្រាវជ្រាវវ័យក្មេងៗ ដែលទទួលបានអាហារូបករណ៍ និងជំនួយសម្រាប់ការសិក្សានៅបរទេស "ពួកគេត្រឡប់មកវិញជាមួយនឹងបទពិសោធន៍ល្អៗទាក់ទងការស្រាវជ្រាវ ហើយបានក្លាយទៅជាអ្នកណែនាំ ឬគ្រូបង្រៀនដែលបង្រៀន ក៏ដូចជាលើកកម្ពស់ការងារស្រាវជ្រាវនៅក្នុងបណ្តាញរបស់ពួកគេ"។ ការកើនឡើងនៃវិទ្យាស្ថានអ្នកស្រាវជ្រាវបែបនេះ "អាចជួយឱ្យមានការស្វែងយល់បន្ថែមទៀតសម្រាប់បញ្ហានៃការស្រាវជ្រាវនៅកម្ពុជា ហើយក៏ជំរុញឱ្យមានការបង្កើតការស្រាវជ្រាវដើម្បីអភិវឌ្ឍគោលនយោបាយ ព្រមទាំងជំរុញឱ្យមានឥទ្ធិពលលើអ្នកបង្កើតគោលនយោបាយដែរ" (DCCAM:D)។

សាកលវិទ្យាល័យជាច្រើន ក៏ត្រូវបានគេជំរុញឱ្យធ្វើការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនិងសមត្ថភាពរបស់ស្ថាប័នខ្លួនផងដែរ។ ពួកគេរួមបញ្ចូលវគ្គបណ្តុះបណ្តាលលើវិធីសាស្ត្រ និងវគ្គបណ្តុះបណ្តាលលើការស្រាវជ្រាវ ដែលបង្រៀនដោយគ្រូជាតិនិងអន្តរជាតិ (RUPPIFL: DH,UBB,USEA)។ ហើយពេលខ្លះពួកគេក៏បានកំណត់កាលវិភាគនៅក្រៅម៉ោងសិក្សា(RULE) "ជាការបណ្តុះបណ្តាលក្រៅផ្លូវការ" ដោយអ្នកជំនាញ "មានបទពិសោធន៍លើការស្រាវជ្រាវយ៉ាងត្រឹមត្រូវ" និងមានវគ្គបណ្តុះបណ្តាលជាលក្ខណៈអន្តរជាតិ ដែលបញ្ជូនអ្នកស្រាវជ្រាវទៅធ្វើការបណ្តុះបណ្តាលនៅក្រៅស្រុក (RUPPIFL: DH, RUA: Dean, UBB)។ លើសពីនេះទៅទៀត សកម្មភាពនៃការស្រាវជ្រាវរបស់ USEA គឺមានភាពរីកចម្រើនច្រើនដោយសារតែមានការគាំទ្រពីធនាគារពិភពលោក ព្រមទាំងបានបង្កើតសិក្ខាសាលា ៣-៥ ថ្ងៃ ទាក់ទងនឹងរបៀបសរសេរសំណើ ការវិភាគទិន្នន័យ ការធ្វើគម្រោងថវិកា ផែនការសកម្មភាព ការធ្វើលទ្ធកម្ម និងដំណើរការដទៃទៀតនៃការស្រាវជ្រាវ ដែលដកចេញនូវបញ្ហាមួយចំនួនដូចជា យេនឌ័រ សុខភាព និងបរិស្ថាន។ គំនិតផ្តួចផ្តើមមួយដែលយើងគួរតែសង្កេតមើលនោះ គឺ មហាវិទ្យាល័យថ្មីមួយសម្រាប់អភិវឌ្ឍការសិក្សា និង Coordination Research Unit នៅសាកល

វិទ្យាល័យភូមិន្ទភ្នំពេញ។ ភាពជាសហគ្រិនរបស់មជ្ឈមណ្ឌលស្រាវជ្រាវបាន ផ្តល់នូវសេវារដ្ឋបាលនិងយកថវិកាជំនួយសម្រាប់ការស្រាវជ្រាវទៅទ្រទ្រង់ដល់គ្រឹះស្ថានរបស់ខ្លួន (RUPP:FR)។

និស្សិតភាគច្រើនផ្តោតសំខាន់លើការអភិវឌ្ឍខ្លួន ហើយរបាយការណ៍នៃការស្រាវជ្រាវរបស់ពួកគេដែលធ្វើនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តែងតែមានការចូលរួមយ៉ាងសកម្មពីអ្នកណែនាំ (ឱ្យសរសេរនិក្ខេបបទផ្សេងៗ) ហើយពួកគេក៏មានឱកាសក្នុងការប្រមូលយកទិន្នន័យពីអង្គការក្រៅរដ្ឋាភិបាលទៀតផង (RUPP:SRT)។ សមាជិកម្នាក់របស់មហាវិទ្យាល័យមួយនៅហ្សាម៉ាន់បានប្រាប់ឱ្យដឹងថា លោកបានព្យាយាមជួយសិស្សឱ្យធ្វើការស្រាវជ្រាវតាមរយៈការបង្ហាត់បង្ហាញដោយខ្លួនឯងផ្ទាល់ បើទោះបីជាមិនមានមូលនិធិសម្រាប់ធ្វើវាក៏ដោយ។ CKS បានព្យាយាមដោះស្រាយបញ្ហាទាក់ទងនឹងសមត្ថភាពរបស់សិស្ស ដោយ "អនុញ្ញាតឱ្យនិស្សិតមិនទាន់បានបញ្ចប់ការសិក្សាមកពីបីប្រទេសរួមមានកម្ពុជា៥នាក់ អាមេរិក៥នាក់ បារាំង៥នាក់ ចូលរៀនក្នុងពេលជំណាលគ្នានៅប្រទេសកម្ពុជា រយៈពេល៦សប្តាហ៍នៅរដូវក្តៅនេះ។ គោលបំណងចម្បងនោះគឺ ដើម្បីបង្កើនចំណេះដឹងផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម ហើយព្រមទាំងផ្តល់ជូននូវឧបករណ៍ផ្សេងៗដើម្បីឱ្យពួកគេធ្វើការស្រាវជ្រាវជាលើកដំបូងដែរ" (CKS:PR)។

នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និស្សិតមានទស្សនៈចំពោះការគាំទ្រឱ្យធ្វើការស្រាវជ្រាវ ដោយពួកគេបានកត់សម្គាល់ឃើញថា សាលាមានទាំងបណ្ណាល័យ និងបណ្ណាល័យអេឡិចត្រូនិក ហើយព្រមទាំងមានការិយាល័យដើម្បីជួយសិស្សឱ្យរកមើលស្ថាប័ន ថវិកា និងតម្រូវការផ្សេងៗ ដែលចាំបាច់ចំពោះការស្រាវជ្រាវ។ សាស្ត្រាចារ្យក៏បានលើកទឹកចិត្តសិស្ស និស្សិតឱ្យចុះទៅសហគមន៍ផ្ទាល់ (RULE:SRT) ចំណែកឯសាលាក៏បានលើកទឹកចិត្តឱ្យសិស្សនិស្សិតចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬក្នុងអង្គប្រជុំផ្សេងៗផងដែរ (RUPP:SRT)។ នៅសាកលវិទ្យាល័យហ្សាម៉ាន់ និស្សិតរៀនវគ្គស្ថិតិ វគ្គវិធីសាស្ត្រនៃការស្រាវជ្រាវ និងវគ្គទស្សនៈវិជ្ជាលើការស្រាវជ្រាវ។ ពួកគេក៏ត្រូវបានគេលើកទឹកចិត្តឱ្យសរសេរនិក្ខេបបទមួយសម្រាប់បញ្ចប់ការសិក្សា និងចូលរួមក្នុងសិក្ខាសាលាដែលនិយាយពីវិធីសាស្ត្រនៃការធ្វើនិក្ខេបបទដែរ (Z:DH2)។ តាមរបាយការណ៍របស់និស្សិត ពួកគេចំណាយពេល ១០ម៉ោង ឬច្រើនជាងនេះក្នុងការធ្វើការងារស្រាវជ្រាវ។ មានរឿងចម្លែកមួយលើកឡើងដែរថា និស្សិតមួយចំនួនមិនបានដឹងថាសាកលវិទ្យាល័យមានមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវនោះទេ (Z:SRT)។ នៅ UBBបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ។ មានតែនិស្សិតប្រហែល ១០ ទៅ២០% ប៉ុណ្ណោះដែលបានចូលរៀន ដោយសារតែប្រាក់ខែរបស់គ្រូមិនបានខ្ពស់ ទើបធ្វើឱ្យលទ្ធផលនៃការអប់រំរបស់សាកលវិទ្យាល័យនៅមានកម្រិត (UBB:DR)។ វាគួរតែមានបច្ចេកទេស ឬនីតិវិធីផ្សេងទៀតដើម្បីឱ្យការស្រាវជ្រាវមានភាពរីកចម្រើន។

ខណៈដែលការកសាងសមត្ថភាព គឺជាកូនសោមួយដ៏សំខាន់ក្នុងការកែលម្អបរិស្ថាននៃការស្រាវជ្រាវ ប៉ុន្តែការកសាងសមត្ថភាពនេះ មិនមានភាពស្មើគ្នាទេ។ អតីតនាយកនៃក្រុមអ្នកជំនាញ CDRI បានបង្ហាញថា សិក្ខាសាលាទាក់ទងនឹង "ការកសាងសមត្ថភាព" មានស្ទើរតែរៀងរាល់ថ្ងៃនៅក្នុងរាជធានីភ្នំពេញ "ជាលក្ខណៈនៃការបណ្តុះបណ្តាលរយៈពេលខ្លី ឬដើម្បីជាស់តឿនការយល់ដឹង ដែលអ្នកខ្លះឱ្យតម្លៃ និងខ្លះទៀតក៏មិនឱ្យតម្លៃ ពោលគឺនៅមានភាពស្ទាក់ស្ទើរ និងមិនមានមូលនិធិសម្រាប់ការងារនេះទេ។ ទិន្នន័យបានមកពីការស្ទង់មតិរបស់យើង (សូមមើលតារាងទី៥ និង៦) បង្ហាញថា ភាគច្រើននៃមហាវិទ្យាល័យដែលបានស្ទង់មតិ (៧០%)ធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៃការស្រាវជ្រាវរយៈពេលខ្លី ហើយមនុស្សជាច្រើនក៏បានចូលរួមក្នុងវគ្គសិក្សាស្រាវជ្រាវកម្រិតសាកលវិទ្យាល័យផងដែរ (វគ្គសិក្សានៃការស្រាវជ្រាវបានធ្វើឡើងបីលើក ហើយពួកគេចូលរួមពីរលើក)។

*តារាងទី៥៖ តើអ្នកធ្លាប់ចូលរួមក្នុងវគ្គសិក្សាខ្លីៗទាក់ទងនឹងការស្រាងជ្រាវដែរឬទេ?*

| | ភាពញឹកញាប់ | ភាគរយ |
|---|---|---|
| Yes | ១២៨ | ៦៩.៩ |
| No | ៥៥ | ៣០.១ |
| សរុប | ១៨៣ | ១០០.០ |

*តារាងទី ៦៖ តើអ្នកធ្លាប់បានចូលរួមក្នុងវគ្គសិក្សាទាក់ទងនឹងការស្រាវជ្រាវក្នុងកម្រិតសាកលវិទ្យាល័យបានប៉ុន្មានលើក?*

| | ភាពញឹកញាប់ | ភាគរយ | ចំនួនកើនឡើងនៃភាគរយ |
|---|---|---|---|
| ០ | ៥២ | ២៨.៤ | ២៨.៤ |
| ១ | ៣៦ | ១៩.៧ | ៤៨.១ |
| ២ | ៥៩ | ៣២.២ | ៨០.៣ |
| ៣ | ១៨ | ៩.៨ | ៩០.២ |
| ៤ | ៨ | ៤.៤ | ៩៤.៥ |

| | | | |
|---|---|---|---|
| ៥ | ៥ | ២.៧ | ៩៧.៣ |
| ៦ | ៣ | ១.៦ | ៩៨.៩ |
| ១០ | ២ | ១.១ | ១០០ |
| **សរុប** | ១៨៣ | ១០០.0 | |

តារាងទាំងនេះបានបង្ហាញនូវការប្តេជ្ញាចិត្តដើម្បីកែលម្អជំនាញនៃការស្រាវជ្រាវ។ តាមពិត ៩២% (n =១៨៣) នៃអ្នកឆ្លើយសំណួរបាននិយាយថា ពួកគេគ្រោងនឹងចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៃការស្រាវជ្រាវនាពេលអនាគត។ ទោះយ៉ាងណាក៏ដោយ វិធីសាស្ត្រក្នុងការកសាងសមត្ថភាពនេះ មិនបង្ហាញលទ្ធផលថា បានបង្កើតអ្នកស្រាវជ្រាវនោះទេ។អ្នកដែលឆ្លើយតបនឹងសំណួររបស់យើងប្រហែលជា ៦២% បាននិយាយថា ពួកគេបានចូលរួមក្នុងគម្រោងនៃការស្រាវជ្រាវយ៉ាងហោចមួយលើក និងមានតែ ៤២% ប៉ុណ្ណោះដែលមិនធ្លាប់បានបោះពុម្ពផ្សាយការស្រាវជ្រាវរបស់ពួកគេ (សូមមើលជំពូកទី ៨)។អតីតនាយករបស់ CDRI បានបង្ហាញពីភាពខុសគ្នារវាងការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងការកំណត់លទ្ធផលនៃការស្រាវជ្រាវ ថា យើងចាំបាច់ត្រូវការវិធីសាស្ត្រថ្មីក្នុងការកសាងសមត្ថភាព ដោយរួមបញ្ចូលទាំងការធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធអប់រំ លក្ខណសម្បត្តិរបស់អ្នកជំនាញ និងជំនាញក្រោយបញ្ចប់ការសិក្សា។ ការអភិវឌ្ឍអ្នកជំនាញ និងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ ត្រូវបានអ្នកជំនាញផ្តល់ដំបូន្មាន និងចែករំលែកជំនាញដែលគេមាន ហើយព្រមទាំងការសហការក្នុងរយៈពេលវែងចំពោះស្ថាប័នណាដែលធ្វើការស្រាវជ្រាវទាំងអស់ (ស្ថាប័នខ្លាំង និងខ្សោយ) ជាពិសេសនៅក្នុងបណ្តាប្រទេសនៃតំបន់របស់យើង (អាស៊ាន ចិន កូរ៉េ ខាងត្បូង និងជប៉ុន)។ លោកក៏បានអះអាងបន្តទៀតថា ការពឹងផ្អែកហួសហេតុលើអ្នកពិគ្រោះយោបល់អន្តរជាតិដែលមានតម្លៃថ្លៃ និងទីប្រឹក្សាបច្ចេកទេសនោះ គឺជាការវិនិយោគដែលមានរយៈពេលខ្លី ក្នុងការកសាងសមត្ថភាពរបស់អ្នកស្រាវជ្រាវក្នុងតំបន់ មានន័យថា សមត្ថភាពនៃការយកជំនួយមានសភាពខ្លាំងជាង សមត្ថភាពនៃការអភិវឌ្ឍខ្លួន ហើយស្ថិតនៅក្រោមចំណុះរបស់នរណាម្នាក់ (CDRI:FD)។

**ទំហំការងារ**

ទំហំការងារដែលមានបន្ទុកធ្ងន់ ត្រូវបានគេចាត់ទុកថាជាកត្តាមួយដ៏សំខាន់ក្នុងការដាក់កម្រិតលើការស្រាវជ្រាវទាំងក្នុងមហាវិទ្យាល័យ និងការគ្រប់គ្រងរបស់គ្រឹះស្ថានឧត្តមសិក្សា ។ ដើម្បីធ្វើឱ្យការស្រាវជ្រាវនេះមានសកម្មភាពបន្ត សាស្ត្រាចារ្យបានខិតខំធ្វើការងារជាច្រើន ក៏ដូចជាមានភាពមមាញឹកដើម្បីសម្រេចការងារនេះផងដែរ (PUC:DA; នាយកស្រាវជ្រាវសាកលវិទ្យាល័យបញ្ញាសាស្ត្រ

UBB:DR)។ ប្រមាណជា ៨០% នៃសាស្ត្រាចារ្យនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ ទទួលយកការបង្រៀន គ្រាន់តែជាការងារបន្ទាប់ បន្សំប៉ុណ្ណោះ គេមិនធ្វើការពេញម៉ោងទេ មានន័យថា ពួកគាត់ទទួលបានប្រាក់ខែលើតែវគ្គណាដែលគេបាន បង្រៀន។ មួយវិញទៀត ពួកគាត់ម្នាក់ៗមានការងារដែលត្រូវធ្វើពីរ ឬច្រើនជាងនេះ ដូចជាធ្វើការនៅក្នុងស្ថាប័នរដ្ឋាភិបាល (PUC:DA)(ដែលមិនទទួលបានមូលនិធិសម្រាប់ធ្វើការស្រាវជ្រាវនោះទេ) និងបង្រៀនក្នុងវគ្គផ្សេងៗនៅមហាវិទ្យាល័យដែលជាបន្ទុកការងារដ៏ធ្ងន់។ ឧទាហរណ៍ដូចជានាយកនៃការស្រាវជ្រាវរបស់សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ក្នុងខេត្តសៀមរាបបច្ចុប្បន្ន កំពុងបង្រៀនថ្នាក់បរិញ្ញាបត្រចំនួន៧វគ្គ។ សកម្មភាពនៃការស្រាវជ្រាវគឺ "វាគ្រាន់តែជាការសាកល្បងមួយ ប៉ុន្តែវាមិនមានប្រសិទ្ធភាពនោះទេ ព្រោះនៅពេលដែលអ្នកមិនមានការគាំទ្រ អ្នកគ្រាន់តែចំណាយពេលប្រាំថ្ងៃ ក្នុងមួយឆ្នាំពីរ ឬបីដងដើម្បីធ្វើវាប៉ុណ្ណោះ" (PUC:DA)។ នេះគឺជាសមត្ថភាពមួយ "ភាពផ្ទាល់ខ្លួនរបស់អ្នក" (PUC:DL) នៅពេលដែលខ្វះខាតការគាំទ្រផ្នែកហិរញ្ញវត្ថុធនធានផ្សេងៗពីរដ្ឋាភិបាលនិងសាកលវិទ្យាល័យ។

និស្សិតក៏ប្រឈមមុខជាមួយនឹងបញ្ហាទំហំការងារនេះដែរ។ និស្សិតថ្នាក់បណ្ឌិត (PhD) នៅ NUM បានរាយការណ៍ថា ពួកគេធ្វើជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យផ្សេងទៀត។ និស្សិតឆ្នាំទីបីនិងទីបួនភាគច្រើនធ្វើការនៅសាកលវិទ្យាល័យខាងក្រៅ ដែលជាមូលហេតុធ្វើឱ្យពួកគេមានភាពលំបាកក្នុងការរៀបចំពេលវេលាជួបជាមួយសមាជិកក្រុមនិងគ្រូដើម្បីពិភាក្សាពីគោលដៅនៃការស្រាវជ្រាវរបស់គេ(USEA:SRT)។ និស្សិតមិនមានពេលវេលាគ្រប់គ្រាន់ ដោយសារតែពួកគេភាគច្រើនត្រូវធ្វើការដើម្បីបានប្រាក់ទ្រទ្រង់ដល់ការសិក្សា និងតម្រូវការនៃគ្រួសាររបស់ខ្លួន (SRU:SRT)។ និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញជាប់រវល់ជាមួយការងារពេញម៉ោង ដូច្នេះកង្វះខាតនៃពេលវេលាក្នុងការសរសេរនិក្ខេបបទ គឺតម្រូវឱ្យមានអ្នកប្រឹក្សាដើម្បីជួយណែនាំក្នុងគម្រោងនៃការស្រាវជ្រាវរបស់ពួកគេ។ និស្សិតថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងបាននិយាយថា សាស្ត្រាចារ្យរបស់ពួកគេរវល់ច្រើនហើយ "ការលើកទឹកចិត្តក៏មានកម្រិតទាប" ក្នុងការគាំទ្រនិស្សិតថ្នាក់បណ្ឌិតនេះ។ សាស្ត្រាចារ្យមួយចំនួន "ផ្តោតសំខាន់លើការងារអាជីវកម្មរបស់ខ្លួន មិនសូវយកចិត្តទុកដាក់ក្នុងការបង្រៀននោះទេ។ ពួកគាត់តែងតែបន្ថែមម៉ោងរៀនជារៀងរាល់ថ្ងៃសៅរ៍និងថ្ងៃអាទិត្យ" (SRU:SRT)។ បន្ទុកការងារធ្ងន់ធ្ងររបស់សាស្ត្រាចារ្យ គឺធ្វើឱ្យនិស្សិតនៅMCU មានអារម្មណ៍ថា "ត្រូវតែមានពេលកំណត់ណាមួយដើម្បីជួបជាមួយសាស្ត្រាចារ្យរបស់គេ ក្នុងការបង្ហាត់បង្ហាញឱ្យធ្វើការស្រាវជ្រាវនោះ" (MCU: SRT)។ បញ្ហាទាក់ទងនឹងការគាំទ្រទៅលើនិស្សិតនេះ ត្រូវបានគេជួបប្រជុំគ្នានៅក្នុងស្ថាប័នមួយចំនួន ដោយពួកគេព្យាយាមស្វះស្វែងរកអ្នកជំនាញពីបរទេស និងចូលរួមក្នុងសិក្ខាសាលា ឬអញ្ជើញអ្នកជំនាញទាំងនោះឱ្យមកបង្រៀនផ្ទាល់ពេញមួយឆមាសតែម្តង (NUM:SRT)។ យើងបានផ្តល់អនុសាសន៍ឱ្យមានការផ្លាស់ប្តូរការណែនាំ រវាងស្ថាប័ន និងស្ថាប័ន ដើម្បីកសាងសមត្ថភាព (UBB:PR)។

នៅសាកលវិទ្យាល័យហ្សាម៉ាន់ ពួកគេជួលសាស្ត្រាចារ្យពេញម៉ោងមកបង្រៀន មិនមែនមកបង្រៀនគ្រាន់តែជាការបន្ទាប់បន្សំនោះទេ (នៅក្នុងដេប៉ាតឺម៉ង់វិទ្យាសាស្ត្រនយោបាយ មានសាស្ត្រាចារ្យ ៤នាក់ធ្វើការពេញម៉ោង និង ៦នាក់ធ្វើការក្រៅម៉ោង)។ និស្សិតទទួលបានផលប្រយោជន៍ពីសាស្ត្រាចារ្យដែលធ្វើការពេញម៉ោង ព្រោះពួកគាត់ "នៅសាលាដើម្បីធ្វើការពិភាក្សាជាមួយនិស្សិតរៀងរាល់ម៉ោងធ្វើការ" ហើយ "ពួកគាត់ក៏មិនជំរុញឱ្យនិស្សិតទាំងអស់រៀនពីសាកលវិទ្យាល័យក្នុងពេលតែមួយដែរ" (Z:Dean1)។ មហាវិទ្យាល័យមួយនៅហ្សាម៉ាន់ បង្រៀនពី ៩ ទៅ ១២ម៉ោងក្នុងមួយសប្តាហ៍ ដូច្នេះមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការស្រាវជ្រាវថ្នាក់បណ្ឌិតរបស់ពួកគេ (Z:F; Z:D)។ ថ្នាក់ដែលមានទំហំតូច និងមានបន្ទុកការងារទាប បានធ្វើឱ្យនិស្សិតទទួលបានការបណ្តុះបណ្តាលដែលមានលក្ខណៈល្អប្រសើរជាងមុន ហើយមហាវិទ្យាល័យក៏មានពេលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវដែរ (Z:D)។ ហ្សាម៉ាន់ផ្តល់ថវិកាតិចតួចសម្រាប់ការស្រាវជ្រាវ ក៏ប៉ុន្តែបានចំណាយថវិកាចំពោះបុគ្គលណាដែលចូលរួមក្នុងអង្គសិក្ខាសាលា ដើម្បីទទួលបានអត្ថប្រយោជន៍ដល់ការស្រាវជ្រាវរបស់ពួកគេ។ លើសពីនេះទៅទៀត ប្រសិនបើបុគ្គលិកចង់បានការប្រមូលទិន្នន័យពីខាងក្រៅ ពួកគេត្រូវមានសំណើច្បាស់លាស់មួយ ហើយក៏មិនមានឧបសគ្គអ្វីដែរក្នុងការទទួលបានកញ្ចប់ថវិកានោះ (Z:DH1)។ កញ្ចប់ថវិកាដែលទទួលបានពេលគេចេញទៅធ្វើការស្រាវជ្រាវនោះ មិនមែនជាប្រាក់បន្ថែមសម្រាប់ការស្រាវជ្រាវនោះទេ។ នៅក្នុងគម្រោងនៃការស្រាវជ្រាវទាំងមូល មានអ្នកឆ្លើយតបតែម្នាក់គត់បានរាយការណ៍ពីបន្ទុកនៃការបង្រៀនដែលល្អ ជាមួយនឹងពេលវេលាបន្ថែមសម្រាប់ការស្រាវជ្រាវ គឺសមាជិករបស់មហាវិទ្យាល័យ RUA (RUA:Dean3)។ តាមគំរូរបស់សាកលវិទ្យាល័យហ្សាម៉ាន់ ដែលទាក់ទងនឹងការផ្តល់ជូននូវការងារពេញម៉ោង មិនមានម៉ោងបង្រៀនត្រូវបានគេបង្កើតកាន់តែច្រើនឡើងៗនោះ បានភ្ជាប់ទំនាក់ទំនងជាមួយនឹងអត្ថប្រយោជន៍នៃការស្រាវជ្រាវដើម្បីធានាឱ្យមហាវិទ្យាល័យទាំងនោះបន្តជំរុញ និងធ្វើការងារបោះពុម្ពនៃការស្រាវជ្រាវបន្ថែមទៀតទេ។

**ភាររក្សាទុក**

ការកសាងសមត្ថភាព វាពិតជាមានសារៈសំខាន់ និងត្រូវបានគេកត់សម្គាល់ឃើញថាមានបញ្ហាប្រឈមជាច្រើនផងដែរ។ ក្នុងពេលជាមួយគ្នានេះដែរ ទោះបីជាដល់ចំណុចចុងក្រោយនៃគោលនយោបាយដែល "ទទួលរងសម្ពាធ" ដោយគ្មានការលើកទឹកចិត្តពីស្ថាប័នណាមួយក្នុងការបណ្តុះបណ្តាលភាពរយៈពេលវែង។ ក្នុងករណី សាកលវិទ្យាល័យបញ្ជូនសាស្ត្រាចារ្យទៅទទួលយកការបណ្តុះបណ្តាល និងទៅកសាងសមត្ថភាពនៅក្រៅប្រទេស ប៉ុន្តែពួកគេកម្រនឹងត្រឡប់មកវិញជាមួយនឹងជំនាញថ្មីៗណាស់ ពោលគឺពួកគេតែងតែជំនួសមកវិញនូវការទាមទារប្រាក់ខែដែលមានតម្លៃខ្ពស់ និងធ្វើការនៅក្នុងទីក្រុង (UBB:DR)។ ការរាយការណ៍ពីគ្រឹះស្ថានឧត្តមសិក្សាផ្សេងទៀតបានលើកឡើងថា ការទទួលរងសម្ពាធពីការអភិវឌ្ឍសមត្ថភាពនេះ គឺបាននាំឱ្យពួកគេបានចំណូលទៅវិញ។ "សាកលវិទ្យាល័យ [ហ្សាម៉ាន់] មិនចង់ធ្វើការវិនិយោគ[អភិវឌ្ឍសមត្ថភាព] សមាជិកនៃមហាវិទ្យាល័យរយៈពេល

ខ្លីដូច្នេះ[យើងវិនិយោគចំពោះ] តែសមាជិកណាដែលយើងជឿថា អាចនៅជាមួយយើងរយៈពេលវែង ប៉ុន្តែយើងមានភាពលំបាកក្នុងកំណត់ និងទទួលស្គាល់” (Z:Dean1)។ ទោះបីជាមានការលំបាកក្នុងការរស់ស្ទង់ក៏ដោយ ក៏ការយល់ឃើញពីបញ្ហាអាចត្រូវបានបញ្ឈប់ការគ្រប់គ្រងជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាដែលព្យាយាមស្វែងរកគោលនយោបាយនៃការអភិវឌ្ឍសមត្ថភាព និងបង្កឱ្យមានទិដ្ឋភាពនៃការប្រកួតប្រជែងជាមួយអង្គការសង្គមស៊ីវិល ដែលតែងតែផ្តល់ជូននូវប្រាក់ខែខ្ពស់សម្រាប់ក្រុមអ្នកស្រាវជ្រាវដែលមានបទពិសោធន៍នោះ។

សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក៏បញ្ហានេះកើតឡើងដែរ ទោះបីជាទទួលបានចំណូលខ្ពស់ពិតមែន។ បុគ្គលិកទទួលបានជំនាញដែលអាចជួយពួកគេដាក់ពាក្យសុំអាហារូបករណ៍សម្រាប់សាលាផ្សេងៗ ឬទទួលបានប្រាក់ខែខ្ពស់សម្រាប់អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត។ប្រធានកម្មវិធីនៅអង្គការសមធម៌កម្ពុជាបាននិយាយថា “ពេលខ្លះក្នុងអំឡុងពេលនៃកិច្ចប្រជុំសម្របសម្រួលនីមួយៗ តែងតែមានសមាជិកថ្មី និងសមាជិកចាស់ ដូច្នេះមុនពេលចាប់ផ្តើមកិច្ចប្រជុំ ឬធ្វើគម្រោង យើងត្រូវតែធ្វើការសង្ខេបប្រាប់ពួកគេអំពីគម្រោងនោះ” (EC:PM)។ បញ្ហាប្រឈមចម្បងមួយផ្សេងទៀត កើតចេញមកពីឫសគល់ដំបូងនោះ គឺសមត្ថភាពបុគ្គលិកនៅមានកម្រិតទាប។នៅពេលដែលមនុស្សម្នាក់មានជំនាញ ហើយពួកគេត្រូវធ្វើការផ្លាស់ប្តូរខ្លួន ដោយការចាកចេញពីស្ថាប័នដើម្បីទទួលបានជំនាញដែលគេត្រូវការ ពោលគឺពួកគេគួរតែជួលអ្នកពិគ្រោះយោបល់មកពីស្ថាប័នខាងក្រៅ ជាមួយនឹងជំនាញនៃការស្រាវជ្រាវដែលមានគុណភាព (EC:PM)។ ការប្រើប្រាស់អ្នកពិគ្រោះយោបល់មកពីខាងក្រៅ គឺពិតជាសំខាន់ ប៉ុន្តែភាពមិនគ្រប់គ្រាន់ទេគឺស្ថិតនៅលើទិដ្ឋភាពនៃការចងក្រងឯកសារស្រាវជ្រាវក្នុងប្រទេសកម្ពុជាដែលនឹងត្រូវបានពិភាក្សានៅចំណុចខាងក្រោម។

### បញ្ហាប្រឈមក្នុងការធានាឱ្យបាននូវគុណភាពនៃការស្រាវជ្រាវ

គុណភាពនៃការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា គឺទទួលរងនូវផលប៉ះពាល់ពីកត្តាជាច្រើនរួមមានមូលដ្ឋាននៃការធ្វើទិនានុប្បវត្តិ និងការធ្វើការស្រាវជ្រាវផ្សេងៗ។ មួយវិញទៀត វាក៏អាចទទួលរងផលប៉ះពាល់ពីភាពប្រែប្រួលនៃរបត់នយោបាយដែលរារាំងនូវអ្វីដែលយើងចង់ធ្វើក្នុងការស្រាវជ្រាវ និងអ្វីដែលយើងនិយាយទៅកាន់អ្នកស្រាវជ្រាវទាំងនោះ។ បញ្ហាទាំងនេះនឹងត្រូវបានរកឃើញនៅចំណុចខាងក្រោម។ ហើយក៏ មានបញ្ហាដទៃទៀតដែលត្រូវតែមានការដោះស្រាយដូចជា ការដឹកនាំធ្វើការស្រាវជ្រាវដោយម្ចាស់ជំនួញផ្ទាល់ ការកំណត់មូលនិធិក្នុងការផលិតការស្រាវជ្រាវ បញ្ហាលួចចម្លង ការកំណត់វគ្គបណ្តុះបណ្តាល និងការអភិវឌ្ឍ ជំនាញ។

### គុណភាពទិន្នន័យ និងគោលការណ៍ណែនាំនៃក្រមសីលធម៌

តាមរយៈការសិក្សារបស់យើងបានបង្ហាញថា ការយកចិត្តទុកដាក់របស់ស្ថាប័នទាក់ទងនឹងគុណភាពនាពេលបច្ចុប្បន្ននេះគឺនៅមានភាពទន់ខ្សោយ ជាពិសេសក្នុងកម្រិតគ្រឹះស្ថានឧត្តមសិក្សា

តួយ៉ាងដូចជានៅក្រសួងផែនការមានការយកចិត្តទុកដាក់ ចំពោះបញ្ហា ប៉ុន្តែដំណោះស្រាយនៅមានដែនកំណត់។ ចំណែកឯនៅអង្គការសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាលវិញគឺមានគោលការណ៍ណែនាំក្នុងការទាញយកទិន្នន័យដើម្បីឱ្យមានគុណភាព ប៉ុន្តែមិនបានសរសេរចេញជាគោលនយោបាយនោះទេ។ មានភាពយល់ច្រឡំមួយចំនួនអំពីគុណភាពនៃស្តង់ដារ ដូចជានៅ IFL បានបង្ហាញថា "ដើម្បីធានាឱ្យបាននូវការស្រាវជ្រាវដែលមានគុណភាព នោះយើងត្រូវតែគោរពតាមលក្ខណវិនិច្ឆ័យឱ្យបានខ្ជាប់ខ្ជួន"(RUPPIFL:F2)។ ប្រធានដេប៉ាតឺម៉ង់ម្នាក់បាននិយាយថា ពួកយើងមិនទាន់មានគោលការណ៍ណែនាំត្រឹមត្រូវនៅឡើយទេប៉ុន្តែ "ក្រុមអ្នកស្រាវជ្រាវភាគច្រើនមានជំនាញ" (RUPPIFL:DH)។ សាកលវិទ្យាល័យមួយចំនួនបាននិយាយថាពួកគេ ការអនុវត្តតាមគោលការណ៍ណែនាំនៃការស្រាវជ្រាវរបស់ក្រសួងអប់រំ (MCU:VP)។ នៅក្រសួងផែនការមានបញ្ហាមួយចំនួនទាក់ទងនឹងភាពទុកចិត្តក្នុងជំនាញនៃការប្រមូលយកទិន្នន័យនៅពេលចុះទៅកន្លែងការងារផ្ទាល់ និងការប្រមូលយកទិន្នន័យ។ Swedish International Development Cooperation Agency (SIDA) មានជំនាញក្នុងការបោសសម្អាត និងពិនិត្យមើលទិន្នន័យ ហើយពួកគេមកជួយយើងដើម្បីកែលម្អគុណភាពទិន្នន័យដែលយើងមាន (MoP2)។ ខណៈដែលក្រសួងមិន "ស្តីបន្ទោស" ទៅលើអ្នកប្រមូលទិន្នន័យ និងអ្នកដែលផ្តល់ដំណោះស្រាយដើម្បីបង្កើនសមត្ថភាពរបស់ពួកគេតាមរយៈការធ្វើការពេញម៉ោងនោះ ពួកគេក៏ប្រហែលជាមិនត្រូវការជួលជំនួយការដែលមានតម្លៃថ្លៃមកពីស្ថាប័នខាងក្រៅដែរ។

អង្គការសង្គមស៊ីវិលដែលយើងបានជួបសម្ភាស ពួកគេមិនបានសរសេរគោលនយោបាយដើម្បីពង្រឹងគុណភាព ក៏ដូចជាមិនមានបទដ្ឋានវិជ្ជាជីវៈនៃទិន្នន័យរបស់ពួកគេត្រឹមត្រូវនោះទេ ប៉ុន្តែពួកគេបានកែលម្អការស្រាវជ្រាវនោះតាមយន្តការនៃការត្រួតពិនិត្យ ដែលគេប្រើប្រាស់សម្រាប់ការស្រាវជ្រាវក្នុងការតស៊ូមតិ។ អង្គការសមធម៌កម្ពុជា បានធ្វើការអភិវឌ្ឍ កំណត់លក្ខណៈគោលបំណង លទ្ធផលដែលគេរំពឹងទុក វិធីសាស្ត្រ និងកង្វល់នានាទាក់ទងនឹងក្រមសីលធម៌ សម្រាប់គម្រោងនៃការស្រាវជ្រាវរបស់ពួកគេ។ បន្ទាប់ពីធ្វើការវិភាគទិន្នន័យរបស់ខ្លួនតាមរយៈកម្មវិធី SPSS" ពួកយើងបានសរសេររបាយការណ៍មួយ និងសួរអ្នកពាក់ព័ន្ធដើម្បីពិនិត្យមើល និងផ្ទៀងផ្ទាត់ព័ត៌មានទាំងនោះម្តងទៀតជាមួយនឹងសហគមន៍។ យើងអាចកែទិន្នន័យទាំងនោះបានមុនពេលបញ្ចប់វា។ បន្ទាប់មកយើងនឹងបោះពុម្ពផ្សាយរបាយការណ៍នោះតែម្តង" (EC:PM)។ អង្គការមិនមែនរដ្ឋាភិបាលអង្គការលីកាដូ មានយន្តការក្នុងការត្រួតពិនិត្យគុណភាពមួយចំនួន ដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវនៃទិន្នន័យដែលពួកគេប្រមូលបាននៅថ្នាក់ភូមិ ជុំវិញបញ្ហាទំនាស់ដីធ្លី។ គុណភាពក្នុងការប្រមូលយកទិន្នន័យលើប្រធានបទនេះមានភាពលំបាក ព្រោះផែនទីនៅក្នុងថ្នាក់ជាតិ "មិនទាន់មានភាពត្រឹមត្រូវទាំងស្រុងនៅឡើយ" ។ ដើម្បីធានាឱ្យបានភាពត្រឹមត្រូវលើបញ្ហានេះ "ពួកគេចុះទៅដល់ភូមិដែលមានបញ្ហាតែម្តង ដើម្បីប្រមូលយកទិន្នន័យ" (LICADHO)។ ពួកគេប្រើប្រាស់អ្នកពិគ្រោះយោបល់ឯកជនដើម្បីសរសេររបាយការណ៍ និងមានក្រុមសម្រាប់ "ឃ្លាំមើល" ក្នុងផ្នែកនីមួយៗទាក់ទងនឹងការប្រមូលទិន្នន័យលើបញ្ហា

ជម្លោះដែលបានបែងចែកជាបីកម្រិត (អ្នកឃ្លាំមើល អ្នកឃ្លាំមើលជាន់ខ្ពស់ និងអ្នកគ្រប់គ្រង)។ ជារៀងរាល់ខែ ពួកគេបានដាក់បញ្ចូលឯកសារករណីផ្សេងៗ ដើម្បីឱ្យអ្នកគ្រប់គ្រងធ្វើការត្រួតពិនិត្យ (LICADHO)។ ស្រដៀងគ្នាជាមួយនឹងអង្គការលីកាដូដែរ ខុមហ្វ្រែល (COMFREL) ក៏មានបណ្ដាញនៅក្នុងមូលដ្ឋាន (តំណែងជាអ្នកស្ម័គ្រចិត្ត) នៅក្នុងថ្នាក់ខេត្ត ស្រុក និងឃុំ។ អ្នកប្រមូលយកទិន្នន័យក្នុងថ្នាក់តំបន់ទាំងនោះត្រូវបានគេបញ្ជូនមកភ្នំពេញ ដើម្បីបណ្ដុះបណ្ដាលវិធីសាស្ត្រលើការស្ទង់មតិ (Com:A)។ ក្រុមអ្នកស្រាវជ្រាវនីមួយៗមានប្រធានក្រុមរបស់ខ្លួន ដែលមានតួនាទីក្នុងការគ្រប់គ្រងទិន្នន័យដើម្បីធានាឱ្យបានថាត្រឹមត្រូវនិងច្បាស់លាស់។ នៅថ្នាក់ខេត្ត លេខាធិការដ្ឋានខុមហ្វ្រែលបានធ្វើការកែសម្រួលទិន្នន័យមុនពេលផ្ញើមកកាន់ការិយាល័យកណ្ដាលនៅភ្នំពេញដែលត្រួតពិនិត្យដោយអ្នកគ្រប់គ្រងការស្រាវជ្រាវ ឬអ្នកគ្រប់គ្រងកម្មវិធី (Com:B)។ ពេលខ្លះមុនពេលចេញរបាយការណ៍ ខុមហ្វ្រែលបានចុះកិច្ចសន្យាជាមួយនឹងដៃគូពិនិត្យមើលមកពីស្ថាប័នខាងក្រៅ ដើម្បីធ្វើការវិភាគទិន្នន័យ (Com:A)។

ឧទាហរណ៍ដែលទាក់ទងជាមួយនឹងគុណភាព និងបទដ្ឋានវិជ្ជាជីវៈទាំងនេះ មិនត្រូវបានគេសរសេរឬកំណត់ជាស្តង់ដារអ្វីនោះទេ ប៉ុន្តែត្រូវបានគេជំរុញឱ្យប្រើទិន្នន័យទាំងនោះ (មានអានុភាពខ្លាំង)។ ខណៈដែលយើងសរសេរគោលនយោបាយ ដែលអាចធានាបាននូវស្តង់ដារមួយដែលមានគុណភាពនោះ គោលនយោបាយគួរតែចាប់ផ្តើមចេញពីសកម្មភាព និងគួរតែបំពេញតម្រូវការនៃការខិតខំប្រឹងប្រែងជាក់ស្តែង។ អ្វីភាគច្រើនដែលយើងបានឃើញនៅក្នុងគ្រឹះស្ថានឧត្តមសិក្សារបស់ប្រទេសកម្ពុជា គឺការព្យាយាមក្នុងការបង្កើតគោលនយោបាយដើម្បីឱ្យជួបប្រសព្វជាមួយការអនុវត្ត ប៉ុន្តែមិនត្រូវបានគេអនុវត្តនោះទេ (ភាពលំបាកក្នុងការអនុវត្តគោលនយោបាយទាំងនេះគឺជាប្រធានបទសំខាន់នៃការរកឃើញរបស់យើង)។

**ភាពរសើបផ្នែកនយោបាយ**

នៅកម្ពុជាត្រូវបានគេហាមឃាត់ មិនឱ្យធ្វើការស្រាវជ្រាវលើប្រធានបទដែលទាក់ទងនឹងចំណុច រសើបនៃនយោបាយ (DCCAM:D) ហើយបូករួមជាមួយនឹងភាពភ័យខ្លាចនៃការដាក់ទោស និងការជាប់ពិរុទ្ធផងដែរ។ វាគឺជាឧបសគ្គមួយដ៏ធំដែលមាននៅក្នុងឋានានុក្រម ឬចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យក្នុងការធ្វើការស្រាវជ្រាវ និងការទំនាក់ទំនងផ្សេងៗ។ បញ្ហាអាចនឹងមិនត្រូវបានដោះស្រាយ ព្រោះពួកគេមិនអាចចាប់ផ្តើមក្នុងការទាក់ទងបានទេ វាដូចនឹងអ្វីដែលយើងបានរកឃើញក្នុងអំឡុងពេលនៃការស្រាវជ្រាវសម្រាប់គម្រោងនេះ ជាក់ស្តែងដូចជា ពេលមហាវិទ្យាល័យបាននិយាយថាមានបញ្ហាប្រឈមពេលធ្វើការស្រាវជ្រាវកម្រិតថ្នាក់សាកលវិទ្យាល័យ ប៉ុន្តែពួកគេមិនបានប្រាប់យើងថាបញ្ហានោះជាអ្វីទេ (UBB:F2)។ ជាការកត់សម្គាល់របស់យើងក្នុងការពិនិត្យលើអក្សរសិល្ប៍នៃរបាយការណ៍នេះបានបង្ហាញថា មានប្រធានបទជាច្រើនរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ត្រូវ

បានគេពារាំងមិនឱ្យធ្វើ។ ព្រឹទ្ធបុរសម្នាក់បានកត់សម្គាល់ឃើញថា សម្ពាធនយោបាយគឺត្រូវពឹងផ្អែកលើវិន័យ "សាកលវិទ្យាល័យមិនមានសម្ពាធអ្វីទៅលើរដ្ឋាភិបាលនោះទេ។ វាប្រហែលជាមានសម្ពាធចំពោះអ្នកស្រាវជ្រាវ ដែលធ្វើការស្រាវជ្រាវលើប្រធានបទទាក់ទងនឹងច្បាប់ ប៉ុន្តែចំពោះប្រធានបទទាក់ទងនឹងសេដ្ឋកិច្ចវិញមិនមានជាបញ្ហាចោទឡើងនោះទេ" (RULE:Dean1;DH)។ និស្សិតរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្របាននិយាយថា "និស្សិតមួយចំនួនបានសរសេរសំណើសុំការអនុញ្ញាតពីសាកលវិទ្យាល័យដើម្បីធ្វើការស្រាវជ្រាវ ប៉ុន្តែសាកលវិទ្យាល័យមិនយល់ស្រប" (RULE: SRT)។ ភាពប្រែប្រួលនៃការស្នេចម្លើយដ៏សំខាន់ និងការវាយតម្លៃនេះមានលក្ខណៈលេងសើចច្រើន ដូចជាក្នុងករណីដែលរៀបរាប់ដោយអ្នកតំណាងមកពីអង្គការលីកាដូបាននិយាយថា ស្ថាប័នដែលធ្វើការទាក់ទងនឹងការអភិរក្ស មិនចូលរួមក្នុងការស្រាវជ្រាវ ឬពិភាក្សាលើបញ្ហានៃការបំផ្លាញព្រៃឈើទេ ដោយសារតែមានភាពប្រែប្រួលនៃរបត់នយោបាយ។ ELC មានផលប៉ះពាល់ទៅលើសិទ្ធិនិងផលប៉ះពាល់ព្រៃឈើផងដែរ (ការកាប់ឈើខុសច្បាប់ និងនៅលើតំបន់ការពារ)" ប៉ុន្តែដោយសារតែកម្មវិធីអភិរក្សត្រូវពឹងផ្អែកលើទំនាក់ទំនាក់ដែលរឹងមាំជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាល ធ្វើឱ្យពួកគេបដិសេធមិនទទួលយកសារៈប្រយោជន៍នេះ។ កម្មវិធីទាំងនេះគឺទាក់ទងនឹង "ជីវចម្រុះ និងព្រៃឈើ" ហើយពេលដែលអ្នកបដិសេធមិនដោះស្រាយបញ្ហាកាប់បំផ្លាញព្រៃឈើនោះ (ធ្វើតែបញ្ហាទាក់ទងនឹងជីវចម្រុះ) គឺវាអាចជារឿងមួយគួរឱ្យចង់សើច (LICADHO)។

ការចុះទៅប្រមូលយកទិន្នន័យ អាចមានភាពលំបាកទាក់ទងនឹងបញ្ហានយោបាយ "អាជ្ញាធរសួរសំណួរជាច្រើន ហើយយើងក៏មានបញ្ហានៅពេលឆ្លើយតបវិញដែរ" (CCHR:SR; Com:A)។ មួយវិញទៀត "បុគ្គលិកដែលសម្ភាសក៏មិនចង់សួរសំណួរទាក់ទងនឹងបញ្ហាទាំងនោះដូចគ្នា"។ ក្រុមអ្នកសិក្សាស្រាវជ្រាវបានឱ្យដឹងថា ការចុះទៅធ្វើការងារដល់មូលដ្ឋានផ្ទាល់ ពិតជាមានភាពលំបាក "ពិបាកក្នុងការស្វែងរកទិន្នន័យ ហើយក៏មិនទទួលបានចម្លើយដែលស្មោះត្រង់ពីអ្នកដែលយើងសួរនោះដែរ ពោលគឺពួកគេមិនប្រាប់រឿងពិតមកយើង ពួកគេនិយាយតែពីអ្វីដែលសង្គមត្រូវការប៉ុណ្ណោះ" (PUC:LD; also noted by Com:B; RUPPIFL:SRT)។ រឿងមួយដែលគួរឱ្យចាប់អារម្មណ៍នោះគឺ ទីភ្នាក់ងាររដ្ឋាភិបាលក៏មានបញ្ហាក្នុងការប្រមូលយកទិន្នន័យពីប្រជាជនក្នុងតំបន់ដែរ ដូចដែលអ្នកនាំពាក្យរបស់ក្រសួងផែនការបានកត់សម្គាល់ថា "ប្រជាជនក្នុងតំបន់មួយចំនួនគិតថាក្រុមអ្នកស្រាវជ្រាវគឺជាអ្នកដែលលួចបន្លំពួកគេ"។ នៅពេលដែលយើងចុះទៅប្រមូលទិន្នន័យជាពិសេសអំឡុងពេលនៃយុទ្ធនាការបោះឆ្នោតវាពិតជាមានការលំបាកខ្លាំង" (MoP2)។ លើសពីនេះទៅទៀត ក្រុមអ្នកស្រាវជ្រាវមកពីអង្គការ CCHR បានស្វែងរកទិន្នន័យស្តីពីវិវាទដីធ្លីពីក្រសួងផែនការ ប៉ុន្តែក្រសួងនេះមិនមានទិន្នន័យឱ្យទៅពួកគេទេ។ ក្រុមអ្នកស្រាវជ្រាវបាននិយាយថា "ក្រសួង ឬអង្គការមួយចំនួនបានព្យាយាមលាក់បាំងព័ត៌មានចំពោះក្រុមអ្នកស្រាវជ្រាវ" (USEA:F1I SRU:F1,F2,F3)។ សាស្ត្រាចារ្យមួយរូបបានលើកឡើងថា ការវាយតម្លៃគុណភាពរបស់ទិន្នន័យនៃរបាយការណ៍ស្រាវជ្រាវគួរតែ "ពិនិត្យមើលថាតើប្រធានបទទាំងនោះ វា

ប៉ះពាល់ដល់ចំណុចរសើបនៃនយោបាយឬអត់។ ការត្រួតពិនិត្យនេះគឺដើម្បីឱ្យប្រាកដថាព័ត៌មានទាំងនោះវាត្រឹមត្រូវ" (USEA:F4) ទាំងអស់នេះបានបង្ហាញថា ការស្រាវជ្រាវលើបញ្ហានយោបាយ វាពិតជាធ្វើឱ្យអ្នកស្រាវជ្រាវមានភាពភ័យខ្លាច។

សញ្ញាណទាំងនេះធ្វើឱ្យយើងយល់ថា ការស្រាវជ្រាវលើបញ្ហាទាក់ទងនឹងនយោបាយគឺមិនគួរឱ្យយើងទុកចិត្តបានទេ ដោយសារតែសមត្ថភាពរបស់អ្នកស្រាវជ្រាវ ក្នុងការដោះស្រាយបញ្ហាលើភាពចម្រូងចម្រាស និងប្រធានបទទាំងនោះ គឺជាធាតុសំខាន់មួយក្នុងការផ្លាស់ប្ដូរបរិស្ថាននៃការស្រាវជ្រាវនៅកម្ពុជា។ យើងបាននិយាយជាមួយក្រុមអ្នកសិក្សាស្រាវជ្រាវមួយចំនួន ដែលពួកគេបានលើកឡើងថា ការស្រាវជ្រាវលើប្រធានបទទាំងនោះគួរតែជាការអនុវត្តរបស់អង្គការសង្គមស៊ីវិល CSOs។ អ្នកតំណាងឱ្យសាលាហ្សាម៉ាន់បាននិយាយថា "ពួកយើងមិនចាំបាច់ធ្វើការស្រាវជ្រាវលើបញ្ហាដែលទាក់ទងនឹងអំពើពុករលួយ ឬបញ្ហានយោបាយផ្សេងទៀតនោះទេ ព្រោះអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានធ្វើវារួចរាល់ហើយ"។ ក្រុមអ្នកស្រាវជ្រាវនៅពីសាកលវិទ្យាល័យភាគច្រើនផ្ដោតសំខាន់លើបញ្ហាផ្សេងទៀតដូចជា ការទំនាក់ទំនងអន្តរជាតិ ហិរញ្ញវត្ថុ។ល។ (Z:D)។ អ្នកតំណាងដដែលបានលើកឡើងទៀតថា បរិស្ថាននៃការស្រាវជ្រាវគឺវាអំណោយផលល្អ ដោយសារតែមានវត្តមានរបស់អង្គការក្រៅរដ្ឋាភិបាល ហើយរដ្ឋាភិបាលទទួលយកការរិះគន់ "វាជាបរិយាកាសល្អមួយ សម្រាប់អ្នកស្រាវជ្រាវដើម្បីធ្វើការស្រាវជ្រាវក្នុងប្រទេសកម្ពុជា។ កម្ពុជាគឺជាប្រទេសមួយដែលមានអង្គការមិនមែនរដ្ឋាភិបាលច្រើនជាង១.០០០កំពុងប្រតិបត្តិការ និងធ្វើការនៅទីនេះ។ ខ្ញុំក៏បានឃើញដែរថា មានមតិរិះគន់រដ្ឋាភិបាលជាច្រើន ដែលគេធ្វើការបោះពុម្ពផ្សាយនាពេលបច្ចុប្បន្ននេះ" (Z:D)។

គំនិតនៃការបែងចែកកម្លាំងពលកម្មរវាងការស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិល និងការស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សាបានបង្ហាញភាពចាប់អារម្មណ៍បន្ថែមទៀតរវាងការសហការនៃដៃគូទាំងពីរនេះ។ ប៉ុន្តែសង្គមស៊ីវិលមិនទាន់មានភាពច្បាស់លាស់អំពីការបន្តសមត្ថភាពក្នុងការឃ្លាំមើលរបស់ខ្លួននៅឡើយទេ។ ច្បាប់ថ្មីដែលរឹតបន្តឹងអង្គការសង្គមស៊ីវិលក្នុងវិស័យជាច្រើន ដើម្បីកម្រិតសមត្ថភាពរបស់ពួកគេក្នុងការចាប់ផ្ដើមធ្វើលើប្រធានបទទាំងនេះ។ អ្នកតំណាងអង្គការលីកាដូបានថ្លែងថា "បុគ្គលិកអង្គការលីកាដូបីនាក់ជាប់ពន្ធនាគារខណៈដែលកំពុងបំពេញការងាររបស់ខ្លួន ហើយក៏មានការចាប់ឃុំខ្លួនក្រុមអង្គការមាតាធម្មជាតិ (Mother Nature group) ដែលបានធ្វើបាតុកម្មដោយសន្តិវិធីប្រឆាំងនឹងអាជ្ញាធរ"។ អារម្មណ៍ភ័យខ្លាចជាកត្តាដែលនាំឱ្យពួកគាត់មិនហ៊ាននិយាយស្ដី ឬអនុវត្តសកម្មភាពផ្សេងៗ។ មួយវិញទៀត ច្បាប់ថ្មីនេះក៏បាន "កាត់បន្ថយឱកាសសម្រាប់ការធ្វើសកម្មភាព និងការនិយាយស្ដីផងដែរ" (LICADHO)។ ការកំណត់ព្រំដែននៃការបញ្ចេញសកម្មភាព ឬមតិយោបល់ គឺជាបញ្ហាដែលកើតឡើងរួចមកហើយនៅក្នុងបរិស្ថាននៃការស្រាវជ្រាវរបស់កម្ពុជា។ អ្នកតំណាងអង្គការសង្គមស៊ីវិលមួយចំនួនសម្ដែងការមិនពេញចិត្ត ចំពោះគុណភាពនៃការស្រាវជ្រាវរបស់

សាកលវិទ្យាល័យ "ការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាមិនមានភាពអព្យាក្រឹត វាមិនមែនជាការសិក្សា ឬគោលដៅពិតប្រាកដនោះទេ ប៉ុន្តែអាចមានភាពលម្អៀងមួយចំនួន ដែលជាព័ត៌មានប៉ះពាល់ដល់រដ្ឋាភិបាល។ "សាកលវិទ្យាល័យមួយចំនួនតែងតែមានទំនាក់ទំនងជាមួយគណបក្សនយោបាយ និងរដ្ឋាភិបាល ដែលធ្វើឱ្យពួកគេមានភាពលំបាកក្នុងការរាយការណ៍នូវអ្វីដែលត្រឹមត្រូវ (CCHR:SR)។

វាមានការគំរាមកំហែងខាងនយោបាយ "មនុស្សជាច្រើនបានរកឃើញចម្លើយ និងជឿជាក់លើការស្រាវជ្រាវរបស់ពួកគេ ប៉ុន្តែពួកគេមិនអាចចែករំលែក ឬធ្វើការបោះពុម្ពផ្សាយអំពីអ្វីដែលគេបានរកឃើញនោះទេ ព្រោះពួកគេមានភាពភ័យខ្លាច និងមានបញ្ហាប្រឈមមួយចំនួន។ ប៉ុន្តែវាក៏អាចជាសំណាងមួយរបស់ពួកគេផងដែរ ព្រោះមនុស្សដែលមានឋានៈខ្ពស់មួយចំនួនមានការផ្លាស់ប្តូរច្រើន គឺពួកគេគ្រាន់តែច្រានចោលរាល់ការស្រាវជ្រាវណាដែលមានលទ្ធផលប្រឆាំងពួកគេប៉ុណ្ណោះ ពោលគឺមិនដាក់ទោសទណ្ឌដូចមុនទៀតទេ។ បើតាមគំនិតរបស់ខ្ញុំ ពួកគេគួរតែធ្វើការប្រកួតប្រជែងលើការងារស្រាវជ្រាវ ជាជាងការបដិសេធមិនធ្វើការស្រាវជ្រាវដោយគ្មានហេតុផលនោះ(USEA:F3)។

"វាអាស្រ័យលើសាកលវិទ្យាល័យ ឬសាស្ត្រាចារ្យ ថាតើពួកគេរងសម្ពាធពីរដ្ឋាភិបាលក្នុងការធ្វើការស្រាវជ្រាវឬក៏អត់។ ប្រសិនបើរដ្ឋាភិបាលមិនចង់ឱ្យអ្នកស្រាវជ្រាវដឹងពីអ្វីមួយនោះ អ្នកស្រាវជ្រាវក៏មិនមានឱកាសដឹងពីវាដែរ។ បញ្ហាដែលទាក់ទងនឹងការទទួលរងសម្ពាធពីរដ្ឋាភិបាលនេះ វាមិនមែនជាបញ្ហាលំបាកនោះទេ ហើយវានឹងត្រូវបានគេដោះស្រាយក្នុងពេលឆាប់ៗនេះ។ ឥឡូវនេះ រដ្ឋាភិបាលបានបើកចំហច្រើនសម្រាប់ការងារស្រាវជ្រាវ ប៉ុន្តែក្រុមអ្នកស្រាវជ្រាវត្រូវតែមានភាពច្បាស់លាស់ និងស្មោះត្រង់" (SRU:Deans)។

ព្រឹទ្ធបុរសម្នាក់នៅសាកលវិទ្យាល័យហ្សាម៉ាន់ បានបង្ហាញអារម្មណ៍ថា ការកំណត់ព្រំដែននៃការបញ្ចេញសកម្មភាព ឬមតិយោបល់ គឺជាបញ្ហាដែលកើតឡើងនាពេលអតីតកាល "ប្រសិនបើយើងចង់និយាយអំពីបញ្ហានយោបាយនោះ យើងត្រូវតែរក្សាវាទុកក្នុងសាកលវិទ្យាល័យ" (Z:D)។ ប៉ុន្តែឥឡូវនេះមានភាពប្រសើរឡើងហើយ ព្រោះអ្នកស្រាវជ្រាវភាគច្រើនតែងតែលេចមុខនៅក្នុងកម្មវិធីវិទ្យុ និងទូរទស្សន៍ ហើយ "រដ្ឋាភិបាលក៏បានជំរុញបន្ថែមទៀតដើម្បីឱ្យមានការរិះគន់ជាសាធារណៈ"។ វាពិតជាសំខាន់ណាស់ ព្រោះអ្នកដែលនិយាយនៅទីសាធារណៈគួរតែមានការស្រាវជ្រាវដ៏រឹងមាំមួយ ដើម្បីទទួលបានការជឿជាក់។ វាគឺជាភាពជឿជាក់នៃការស្រាវជ្រាវ ព្រោះនៅពេលដែលអ្នកនិយាយជាសាធារណៈ វាពិតជាអាចជំរុញឱ្យអង្គការសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាលមានភាពជឿជាក់លើការប្រមូលយកទិន្នន័យ និងជំរុញឱ្យពួកគេធ្វើការស្រាវជ្រាវនៅក្នុងកន្លែងដំបូង។ យើងមិនមានអនុសាសន៍ច្រើនទេ សម្រាប់បញ្ហាដែលទាក់ទងនឹងភាពប្រែប្រួលនៃនយោបាយ ព្រោះវាអាចប្រឈមនឹងបញ្ហាច្រើន។ យើងអាចនិយាយបានថា ភាពរឹងមាំ ភាពជឿជាក់នៃការស្រាវជ្រាវ និងភាពភ័យខ្លាច

ក្នុងការផ្សព្វផ្សាយទិន្នន័យគឺជាកូនសោដ៏សំខាន់ ដើម្បីបញ្ឈប់បញ្ហាដែលទាក់ទងនឹងការកម្រិតដែនកំណត់នៃការបញ្ចេញមតិ ឬសកម្មភាព និងភាពស្មុគស្មាញផ្សេងៗផងដែរ។

**ការធ្វើទិនានុប្បវត្តិទិន្នន័យស្ថិតិនៅបណ្ណាល័យ និងធនធានគេហទំព័រ**

ជាទូទៅ ការឆ្លើយតបចាប់ផ្តើមចេញពីការកំណត់នៃការប្រើប្រាស់ភាសា ការកំណត់ព្រំដែននៃការប្រើប្រាស់ទិន្នន័យ និងកង្វះខាតនៃការផ្តល់មូលនិធិសម្រាប់ធ្វើទិនានុប្បវត្តិជាប្រចាំ។ ភាពលំបាកនៃការស្រាវជ្រាវជាភាសាអង់គ្លេស (មានរៀបរាប់ខាងលើ) ត្រូវបានភ្ជាប់ជាមួយនឹងបញ្ហានៃសមត្ថភាព និងអនុត្តរភាព (ឥទ្ធិពលនៃការប្រើប្រាស់ភាសាអង់គ្លេស និងលទ្ធភាពក្នុងការបញ្ឈប់ឱកាសនៃការស្រាវជ្រាវសម្រាប់អ្នកដែលមិនអាចទំនាក់ទំនងជាភាសាអង់គ្លេសបាន ក៏ដូចជាការកំណត់នូវការយល់ដឹងដែលមានឫសគល់ក្នុងវប្បធម៌ និងភាសារបស់ប្រទេសកម្ពុជា)។ យើងនឹងធ្វើការរៀបរាប់ឡើងវិញចំពោះស្ថាប័នដែលបានសហការ និងមិនបានសហការជាមួយនឹងការឆ្លើយតបរបស់យើង។

សាកលវិទ្យាល័យមួយចំនួនដែលបានជាវមូលដ្ឋានទិន្នន័យនៃការស្រាវជ្រាវតាមរយៈបណ្តាញអ៊ីនធើណិត (online) មានដូចជា សាកលវិទ្យាល័យហ្សាម៉ាន់ សាកលវិទ្យាល័យបញ្ញាសាស្ត្រ សាកលវិទ្យាល័យភូមិន្ទភ្នំពេញជាវពី (JSTOR) និង MCU ជាវ Science Direct (MCU:SRT)។ សាកលវិទ្យាល័យមួយចំនួនទៀតដូចជា USEA និង UBB មិនបានចំណាយលើការជាវមូលដ្ឋានទិន្នន័យនៃការស្រាវជ្រាវនោះទេ ប៉ុន្តែនិស្សិតប្រាប់ថា "ពួកគេអាចស្វែងរកព័ត៌បានលើបណ្តាញអ៊ីនធើណិតនៅបន្ទប់កុំព្យូទ័រដែលអាចប្រើ Wi-Fi និងអានសៀវភៅក្នុងបណ្ណាល័យបាន"(USEA:SRTRULE:SRT)។ និស្សិតនៅវិទ្យាស្ថានភាសាបរទេសកត់សម្គាល់ឃើញថា ពួកគេធ្វើការស្រាវជ្រាវតាមរយៈគេហទំព័រដូចជា Google ScholarGooglebooks YouTube Bookzz.org Bookfi.org(RUPPIFL: SRT)។ និស្សិតនៅសាកលវិទ្យាល័យមួយចំនួនទៀតក៏បានត្អូញត្អែរដែរថា ធនធានដែលមាននៅក្នុងបណ្ណាល័យមិនទាន់គ្រប់គ្រាន់ទេ ដូចជាខ្វះសៀវភៅ(RUPP; RULE; UBB; SRU) អ៊ីនធើណិតដំណើរការយឺត មិនមានកុំព្យូទ័រដើម្បីស្កេនកូដរបស់សៀវភៅ និងមិនមានបុគ្គលិកគ្រប់គ្រាន់ដើម្បីជួយដល់និស្សិត (SRU:SRT)។

និស្សិតថ្នាក់បណ្ឌិត PhD របស់សាកលវិទ្យាល័យជាតិគ្រប់គ្រងបានបង្ហាញពីភាពលំបាកក្នុងការស្វែងរកទិន្នន័យមានដូចជា ការចំណាយធនធានពីខាងក្រៅដើម្បីបានទិន្នន័យដែលមានគុណភាព ភាពលំបាកក្នុងការទទួលបានទិន្នន័យទាក់ទងនឹងការរឹតបន្តឹង ក៏ដូចជាឧបសគ្គក្នុងការប្រមូលទិន្នន័យដោយសារតែបញ្ហានយោបាយ និងកាលៈទេសៈសង្គមនៅកម្ពុជា។ ពួកគេមិនមានបណ្ណាល័យអេឡិចត្រូនិក (E-library) ឬមិនអាចចូលទៅដល់មូលដ្ឋានទិន្នន័យ ដែលជាមូលហេតុធ្វើឱ្យគេមានការលំបាកក្នុងការស្វែងរកឯកសារអន្តរជាតិផ្សេងៗ។ ហើយគេក៏បានបន្ថែមទៀតថា ភាគច្រើននៃការស្រាវជ្រាវរបស់ពួកគេ គឺបានមកពីធនធានបន្ទាប់បន្សំប៉ុណ្ណោះ (secondary source)

(NUM:SRT)។ ក្រុមហ៊ុនឯកជនមួយចំនួន គឺមានភាពអាថ៌កំបាំង និងព្យាយាមលាក់ទិន្នន័យ ហើយពួកគេទទួលបានកិច្ចសហប្រតិបត្តិការតិចតួចណាស់ជាមួយរដ្ឋាភិបាលនៅក្នុងការប្រមូលយកទិន្នន័យ (ទិន្នន័យនៅលើធនធានមនុស្ស និងហិរញ្ញវត្ថុដែលយើងមិនអាចរកឃើញ) (NUM: FR2)។

បញ្ហាប្រឈមលើការស្រាវជ្រាវដែលយើងបានជួបប្រទះទាំងអស់មានដូចជា បញ្ហាដែលទាក់ទងនឹងការចូលទៅធ្វើដំណើរការ និងធនធាននៅក្នុងបណ្ណាល័យហាក់ដូចជាមានភាពងាយស្រួលក្នុងការដោះស្រាយ។ ការបើកចំហឱ្យចូលធ្វើការសិក្សាស្រាវជ្រាវ ការកែលម្អព័ត៌មានឱ្យបានទៀងទាត់ និងការថែទាំកុំព្យូទ័រ ពិតជាអាចដោះស្រាយនូវរាល់បញ្ហាទាំងនេះបាន ហើយក៏ជាអ្វីដែលសហគមន៍ម្ចាស់ជំនួយត្រូវតែធ្វើវាឱ្យបានទៀងទាត់ដែរ។

# ៦.ចំណុចសំខាន់ និងលក្ខណៈនៃការស្រាវជ្រាវ

នៅផ្នែកនេះ យើងនឹងគូសបញ្ជាក់ពីចំណុចសំខាន់នៃការស្រាវជ្រាវរបស់ស្ថាប័នផ្សេងៗគ្នារួមមានដូចជាប្រធានបទដែលគេរើសយកមកសិក្សាវិធីសាស្ត្រ និងប្រភពនៃការផ្តល់មូលនិធិ។យើងមើលឃើញថា ប្រធានបទនៃការស្រាវជ្រាវនីមួយៗមានភាពប្លែកៗគ្នា ដូចជាប្រធានបទខ្លះផ្តោតសំខាន់លើការងារកសិកម្ម និងការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទ ហើយខ្លះទៀតផ្តោតលើការធ្វើអាជីវកម្មសហគ្រាសទំនាក់ទំនងនយោបាយក្នុងតំបន់ និងការស្រាវជ្រាវដើម្បីកែលម្អលើវគ្គសិក្សាផ្សេងៗ ក៏ដូចជាជួយជំរុញឱ្យអត្រានៃភាពមានការងារធ្វើរបស់និស្សិតមានភាពកើនឡើងដែរ។ រឿងដែលសំខាន់ក្នុងការស្រាវជ្រាវ គឺវាស្ថិតនៅលើការជួលអ្នកប្រឹក្សាយោបល់មកពីមជ្ឈដ្ឋានអន្តរជាតិ (កិច្ចសន្យាមានរយៈពេលខ្លី) ជាមូលហេតុដែលនាំឱ្យការស្រាវជ្រាវមានឧបសគ្គ ប៉ុន្តែយើងក៏ទទួលបានផលប្រយោជន៍ត្រឡប់មកវិញដែរ នោះគឺការកសាងសមត្ថភាពរបស់ក្រុមអ្នកស្រាវជ្រាវនៅប្រទេសកម្ពុជា។ បន្ទាប់មកយើងបានវាយតម្លៃទៅលើទំនាក់ទំនងនៃកិច្ចសហការ និងការផ្តល់យោបល់ឱ្យគ្នាទៅវិញទៅមករបស់ក្រុមអ្នកស្រាវជ្រាវនៅកម្ពុជា។ វាគឺជាការកសាងសមត្ថភាព និងការប្រកួតប្រជែងក្នុងចំណោមសាកលវិទ្យាល័យរបស់ប្រទេសកម្ពុជាដែលបានបង្កើតឡើងដោយអង្គការសង្គមស៊ីវិល។

### ប្រភេទនៃការស្រាវជ្រាវដែលបានធ្វើរួចរាល់នៅស្ថាប័នមួយចំនួន

ក្រសួងផែនការ (MoP) ប្រើប្រាស់ទិន្នន័យដើម្បីធ្វើសេចក្តីព្រាងផែនការថ្នាក់ជាតិ និងបង្កើតគោលនយោបាយយុទ្ធសាស្ត្រ។ ឧទាហរណ៍ដូចជានៅឆ្នាំ ២០១១-២០១២ MoP បានធ្វើគម្រោងស្រាវជ្រាវមួយក្រោមប្រធានបទនៃការធ្វើចំណាកស្រុក។ ក្រសួងបានប្រមូលទិន្នន័យផ្សេងៗរួមមានចលនានៃការផ្លាស់ប្តូរពីជនបទមកទីក្រុង អត្រានៃការធ្វើចំណាកស្រុក ហេតុផលនៃការធ្វើចំណាកស្រុក ការប្រៀបធៀបជីវភាពរស់នៅមុននិងក្រោយពេលចំណាកស្រុករបស់អ្នកដែលចំណាកស្រុក និងអ្នកមិនចំណាកស្រុក។ លើសពីនេះទៅទៀត ពួកគេក៏វិភាគទៅលើបញ្ហាប្រឈមផ្សេងៗ និងភាពប្រែប្រួលក្នុងតំបន់បន្ទាប់ពីការធ្វើចំណាកស្រុករបស់ពួកគេ (ដូចជាផលប៉ះពាល់អវិជ្ជមានលើមនុស្សចាស់នៅតាមតំបន់ជនបទ)ជាដើម។ ការស្រាវជ្រាវនេះត្រូវបានគេដាក់បញ្ចូលទៅក្នុងសំណើនៃគោលនយោបាយនិងតាមដានការស្រាវជ្រាវសម្រាប់គម្រោងឆ្នាំ ២០១៦(MoP1)។ MoP ក៏បានធ្វើការស្រាវជ្រាវលើភាពក្រីក្ររបស់កុមារក្នុងឆ្នាំ២០១០ ២០១១ ២០១២ និងឆ្នាំ២០១៤ ដែរ។ ចំណុចសំខាន់ៗចំនួនពីរត្រូវបានគេយកចិត្តទុកដាក់ក្នុងការងារស្រាវជ្រាវ។ ទីមួយ បើទោះបីជាមាន ឬមិនមានគោលនយោបាយសម្រាប់ដឹកនាំការស្រាវជ្រាវក៏ដោយ ក៏ការស្រាវជ្រាវនៅតែមានប្រសិទ្ធភាពដែរ រួមបញ្ចូលទាំងភាពជាក់លាក់នៃច្បាប់ ឬសេចក្តីថ្លែងការណ៍នៃគោលនយោបាយជាដើម។ ប្រសិនបើដូច្នេះមែន កត្តាផ្សេងៗដើម្បីទទួលបានប្រសិទ្ធភាពអាចនឹងត្រូវបានគេរកឃើញ។ ទីពីរ យើងត្រូវការចាំបាច់នូវព័ត៌មានបន្ថែមទៀតដែលទាក់ទងនឹងការចូលរួម ក៏ដូចជាភាពលម្អិតនៃសកម្មភាព

ក្នុងការស្រាវជ្រាវ រួមមានរបៀបនៃការរៀនសូត្ររបស់កុមារក្រីក្រ និងការបកស្រាយលទ្ធផលទាំងនោះរបស់ក្រសួង។

សាកលវិទ្យាល័យមួយចំនួនត្រូវបានដាក់បញ្ចូលក្នុងការស្រាវជ្រាវរបស់យើង ដែលជំរុញឱ្យមានការស្រាវជ្រាវលើប្រធានបទខុសៗគ្នា ទោះបីជាវិធីសាស្ត្រ និងប្រភពមូលនិធិនៅមានកម្រិតក៏ដោយ។ យើងនឹងធ្វើការពិភាក្សាលើចំណុចនីមួយៗនៅក្នុងផ្នែកនេះ។សាកលវិទ្យាល័យជាច្រើនមានដូចជា ហ្សាម៉ាន់ IFL និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ បានចូលរួមធ្វើការទំនាក់ទំនងនយោបាយក្នុងតំបន់។ ការងារស្រាវជ្រាវរបស់សាកលវិទ្យាល័យហ្សាម៉ាន់ ទាំងគុណភាព (qualitative) និងបរិមាណ (quantitative) គឺធ្វើឡើងដោយផ្តោតសំខាន់ទៅលើការងារទំនាក់ទំនងក្នុងតំបន់ និងគោលនយោបាយសាធារណៈរបស់កម្ពុជា ដែលមានសមាសភាពរឹងមាំក្នុងការបង្ហាត់បង្ហាញ (Z: DH2)។ ចំពោះ UBB យកចិត្តទុកដាក់លើការស្រាវជ្រាវ និងសកម្មភាពរបស់និស្សិតដែលអាចជួយបង្កើនសមត្ថភាពរបស់ពួកគេ ដើម្បីធានាឱ្យបានថាពួកគេទទួលបានឱកាសម្រាប់ចំណាយលើការរស់នៅ។ ជាចុងក្រោយ UBB បានសហការជាមួយសាកលវិទ្យាល័យនៅប្រទេសថៃ និងប្រទេសកូរ៉េ ហើយបានបញ្ជូននិស្សិតទៅសិក្សាក្នុងកម្មវិធីដែលមានការអនុវត្តជាក់ស្តែងដូចជា ការវេចខ្ចប់ម្ហូបអាហារ ការបន្សុទ្ធទឹកក្នុងដប និងសកម្មភាពថ្មីៗមួយចំនួនដូចជា៖

- មជ្ឈមណ្ឌលសិល្បៈ (An art gallery center) សម្រាប់និស្សិតគូររូប និងលក់គំនូររបស់ពួកគេទៅឱ្យអ្នកដទៃដើម្បីទទួលបានផលចំណេញផ្ទាល់ខ្លួន។
- មន្ទីរពិសោធន៍វិទ្យាសាស្ត្រសត្វ និងតំបន់សម្រាប់សាកវប្បកម្មខ្នាតតូចដលផល ការដាំដុះព្រៃឈើ
- ដី (២០ ហិកតា) សម្រាប់ការពិសោធធ្វើការងារកសិកម្ម និងចិញ្ចឹមសត្វ
- វគ្គបណ្តុះបណ្តាលអាជីវកម្មលើបណ្តាញអ៊ីនធើណិត ដែលគាំទ្រដោយប្រទេសអូស្ត្រាលី ហើយក៏បានអនុញ្ញាតឱ្យសិស្ស និស្សិតមកពីមហាវិទ្យាល័យផ្សេងគ្នាៗចូលរៀន (អាជីវកម្ម) ដោយពួកគេសង្ឃឹមថាសកម្មភាពនេះនឹងអាចផ្តល់ផលចំណេញដល់និស្សិត។

នៅវិទ្យាស្ថានភាសាបរទេស ពួកគេផ្តោតសំខាន់ទៅលើទំនាក់ទំនងអន្តរជាតិ ការធ្វើសមាហរណកម្មអាស៊ាន គោលនយោបាយបរទេសសេដ្ឋកិច្ចអន្តរជាតិ និងភូមិសាស្ត្រនយោបាយ (RUPP-IFL: DH)។ ចំណុចសំខាន់នៃការសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺផ្តោតទៅលើមូលធនសង្គម ការអភិវឌ្ឍសង្គម ការផ្លាស់ប្តូរអាកាសធាតុ ការគ្រប់គ្រងប្រព័ន្ធជាវាសាស្ត្រ យុទ្ធសាស្ត្រក្នុងការចិញ្ចឹមជីវិត និងការពង្រីកវិស័យកសិកម្ម។ ពួកគេបានប្រើវិធីសាស្ត្រជាច្រើនឧទាហរណ៍ដូចជា ការពិភាក្សាជាក្រុម គន្លឹះសំខាន់ៗរបស់អ្នកជំនាញ និងមានរចនាសម្ព័ន្ធនៃកម្រងសំណួរ (RUPP: DH)។ ចំពោះមហាវិទ្យាល័យនៅសាកលវិទ្យាល័យភូមិន្ទ ត្រូវបានគេជំរុញឱ្យធ្វើការ

ស្រាវជ្រាវក្រោមប្រធានបទនៃការធ្វើសមាហរណកម្មអាស៊ានធនធានមនុស្ស (RULE:F2) ធនាគារហិរញ្ញវត្ថុ (RULE:F1;DH) ក៏ដូចជារដ្ឋបាលសាធារណៈ (RULE: Dean1) ផងដែរ។ ទោះបីជាការស្រាវជ្រាវរបស់និស្សិតធ្វើឡើងផ្តោតទៅលើគុណភាពក៏ដោយ ក៏ការស្រាវជ្រាវរបស់សាស្ត្រាចារ្យបែរជាត្រូវបានគេជំរុញឱ្យធ្វើដោយគិតទៅលើចំនួនឬបរិមាណទៅវិញ។ សាកលវិទ្យាល័យនេះមានការចូលរួមតិចតួចណាស់ក្នុងការស្រាវជ្រាវ (RULE:Dean1;F1) ទោះបីជាទទួលបានភាពជោគជ័យក្នុងការសរសេរសំណើពីនាយកសេដ្ឋកិច្ច និងទទួលបានគម្រោងមូលនិធិពី HEQEPក៏ដោយ។

ក្រុមអ្នកស្រាវជ្រាវផ្សេងទៀតដូចជា នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសាកលវិទ្យាល័យស្វាយរៀងផ្តោតលើការស្រាវជ្រាវដើម្បីធានាគុណភាពផ្ទៃកខាងក្នុង (ការកែលម្អកម្រិតដែលផ្តល់ឱ្យអតិថិជន និងស្វែងយល់ពីតម្រូវការធនធានមនុស្សរបស់ក្រុមហ៊ុន)។ សាកលវិទ្យាល័យជាតិគ្រប់គ្រងក៏បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនៃការគ្រប់គ្រង ភាពជាអ្នកដឹកនាំ ការអប់រំ (NUM: FR2) សហគ្រិនភាព (NUM:DR) សេដ្ឋកិច្ចអាជីវកម្ម (NUM:FR1;DG) វិស័យទេសចរណ៍ និងបរិស្ថានដែរ (NUM: Dean1)។ ការស្រាវជ្រាវគឺមានទាំងបរិមាណនិងគុណភាព ដែលរួមបញ្ចូលទាំងការប្រើប្រាស់កម្មវិធី SPSS (NUM: FR2)។ អត្ថបទភាគច្រើនរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រងផ្តោតសំខាន់លើបរិមាណនៃការស្រាវជ្រាវ ហើយអត្ថបទទាំងប្រាំបីស្ថិតក្នុងកម្រិត I ដែលមានតែមួយប៉ុណ្ណោះផ្តោតសំខាន់លើគុណភាព (NUM: fr1)។ និស្សិតរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រងបានចូលរួមធ្វើការស្រាវជ្រាវលើប្រធានបទចម្រុះៗគ្នារួមមាន៖ "ការស្រាវជ្រាវលើផ្នែកទីផ្សារ តើធ្វើដូចម្តេចដើម្បីគ្រប់គ្រងឥណទានក្នុងស្ថាប័ននីមួយៗបាន?" "ហេតុអ្វីបានជាសិស្សនិស្សិតនៅសាកលវិទ្យាល័យស្វាយរៀងមិនមានការងារធ្វើ ប៉ុន្តែពួកគេប្រើទូរស័ព្ទទំនើបៗដូចជាទូរស័ព្ទ iPhone" "តើធ្វើដូចម្តេចដើម្បីឱ្យអាជីវកម្មរបស់យើងមានភាពប្រសើរឡើង ទាក់ទាញអតិថិជន និងផលិតផលដែលមានគុណភាព" និង "កំណើនដំណាំនៅក្នុងសហគមន៍" (SRU:SRT)។

សាកលវិទ្យាល័យស្វាយរៀងមានគម្រោងនៃកិច្ចសហប្រតិបត្តិការមួយចំនួនដូចជា គម្រោងស្តីពី "ការបង្កើនចំនួនសិស្ស"។ សាកលវិទ្យាល័យនេះបានទទួលគម្រោងតែមួយគត់ពីធនាគារពិភពលោក ហើយបានបញ្ចប់វានៅចុងខែមិថុនាឆ្នាំ ២០១៥ (SRU:Deans)។ ការស្រាវជ្រាវភាគច្រើនត្រូវបានបង្កើតឡើងដោយមហាវិទ្យាល័យកសិកម្មស្តីពីកំណែទម្រង់រដ្ឋបាលសាធារណៈ កសិកម្ម ភាពកើនឡើងនៃបសុសត្វ (ចិញ្ចឹមសត្វ) និងSMEs (SRU:F1,F2,F3)។ ក្រុមអ្នកស្រាវជ្រាវរបស់ SRU បានកត់សម្គាល់ឃើញថា ពួកគេធ្វើការស្រាវជ្រាវទាំងគុណភាព និងបរិមាណ ដោយរួមបញ្ចូលទាំងការពិសោធលើបរិមាណ (ភាពកើនឡើងការចិញ្ចឹមមាន់) និងគុណភាពនៃការស្រាវជ្រាវដោយប្រើប្រាស់កម្រងសំណួរ (SRU:F1, F2, F3)។

ចំពោះ USEA និង MCU ធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតសំខាន់លើវិស័យទេសចរណ៍។ ការស្រាវជ្រាវនៅ MCU រួមបញ្ចូលការអភិវឌ្ឍលើវិស័យទេសចរណ៍ (MCU:VP) ការធ្វើអាជីវកម្ម (MCU:Dean4) ការប្រែប្រួលអាកាសធាតុ (MCU:Dean2) ការធ្វើចំណាកស្រុក និងការយល់ឃើញរបស់យុវជនទៅលើព្រះសង្ឃជាដើម (MCUDean3)។ មហាវិទ្យាល័យជាច្រើនយល់ឃើញថា ការស្រាវជ្រាវនេះមិនបានបង្ហាញលទ្ធផលនៃការស្រាវជ្រាវ (MCU:Dean4; MCU:DFY; MCU:Dean3) និងមិនបានផ្តល់ជូននូវការលើកទឹកចិត្ត ឬការបណ្តុះបណ្តាលដល់ក្រុមអ្នកស្រាវជ្រាវនោះទេ (MCU:DFY)។

ចំណែកឯនាយកស្រាវជ្រាវរបស់ USEA បាននិយាយថា សាកលវិទ្យាល័យនេះជោគជ័យក្នុងការទទួលបានមូលនិធិពីប្រភពចំនួនពីរក្នុងពេលថ្មីៗនេះ៖ ពីសាកលវិទ្យាល័យម៉ាឡាយ៉ាដើម្បីប្រមូលទិន្នន័យលើការបង្កើតថាមពលឡើងវិញ (USD២០.០០០) និងពីធនាគារពិភពលោកដើម្បីអនុវត្តលើគម្រោងនៃការស្រាវជ្រាវមួយស្តីពី "ការអភិវឌ្ឍកម្មវិធីសិក្សាលើវិស័យទេសចរណ៍ និងការគ្រប់គ្រងបដិសណ្ឋារកិច្ច" (ខែមិថុនា ឆ្នាំ២០១៣ ដល់ខែមិថុនា ឆ្នាំ២០១៥ USD៥០.០០០) ហើយក៏បានបង្កើតការស្រាវជ្រាវ និងសិក្ខាសាលាចំនួនបីលើគម្រោងនេះដែរ។ វាពាក់ព័ន្ធនឹងការស្រាវជ្រាវជាបឋមក្នុងតំបន់ទេសចរណ៍សំខាន់ទាំងបី សៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ដោយមានការស្ទង់មតិទៅលើប្រជាជនចំនួន ៤៨០នាក់ ទាក់ទងនឹងឱកាសការងារក្នុងវិស័យទេសចរណ៍។ អ្នកដែលបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួនបីជំនាន់របស់ USEA បានចូលរួមស្ទង់មតិទាក់ទងនឹងបញ្ហានៃការស្វែងរកការងាររបស់ពួកគេក្នុងវិស័យទេសចរណ៍បន្ទាប់ពីពួកគេបញ្ចប់ការសិក្សា (USEA:VPR)។ USEA ក៏បានសហការជាមួយស្ថានទូតអាមេរិក ដែលជារៀងរាល់ឆ្នាំស្ថានទូតអាមេរិកបានផ្តល់ថវិកាចំនួន USD១.៣០០ ចំពោះបណ្ណាល័យអាមេរិកនៅ USEA ព្រមទាំងមានគម្រោងផ្សេងៗ ដូចជាការប្រកួតប្រជែងភាសាអង់គ្លេស បណ្តុះបណ្តាលបុគ្គលិក (USEA: VPR)។ល។

យើងមើលឃើញថា ការផ្តល់ថវិកាពីម្ចាស់ជំនួយក្នុងការកសាងសមត្ថភាពនៃការស្រាវជ្រាវពិតជាមានប្រយោជន៍ខ្លាំងណាស់សម្រាប់ការលើកទឹកចិត្តដល់ការរៀបចំ ក៏ដូចជាបង្កើតឱកាសដើម្បីចុះទៅសហគមន៍ និងការផ្សព្វផ្សាយ។ ជំនួយដ៏ច្រើនរបស់ WB បានជួយបំពេញសេចក្តីត្រូវការក្នុងការអប់រំរបស់USEA ហើយ "បានធ្វើឱ្យនិស្សិតយល់ថា តើគួរធ្វើអ្វីដើម្បីបំពេញតាមតម្រូវការទីផ្សារបច្ចុប្បន្ន"។ ឧទាហរណ៍ "តើអ្វីទៅជាវិស័យទេសចរណ៍?" និងតើពួកគេត្រូវធ្វើដូចម្តេចដើម្បីចូលបម្រើការងារក្នុងវិស័យនេះបាន?" (USEA:Dean1)។

មហាវិទ្យាល័យ RUA បានចូលរួមធ្វើការស្រាវជ្រាវដោយផ្តោតសំខាន់លើវិស័យកសិកម្ម ក្រោមប្រធានបទខុសៗគ្នាមានដូចជា៖ គ្រឿងម៉ាស៊ីនកសិកម្ម ការគ្រប់គ្រងទឹក ប្រព័ន្ធជារាសាស្ត្រ ការកិនស្រូវ (RUA:Dean4) ផលិតផលសាកវប្បកម្ម (RUA;Dean2) គុណភាពរបស់ទឹក (RUA:Dean3)

ការប្រែប្រួលអាកាសធាតុ រួមនឹងអភិបាលកិច្ច យេនឌ័រជាមួយនឹងការផ្តល់សិទ្ធិអំណាចឱ្យស្ត្រី និងការកសាងសមត្ថភាព (RUA;Dean1)។ ថវិកាបានមកពីអង្គការអភិវឌ្ឍន៍អន្តរជាតិជាច្រើនមានដូចជា USAID IDRCO xfam America People In Need ការស្រាវជ្រាវ និងសេវាកម្មសម្រាប់ការអភិវឌ្ឍ។ ថវិកាក៏មានប្រភពចេញមកពីសាកលវិទ្យាល័យផងដែរ ពោលគឺចំនួន ៧០.០០០ដុល្លារអាមេរិក សម្រាប់មហាវិទ្យាល័យកសិកម្មដើម្បីធ្វើការស្រាវជ្រាវលើការផលិត "ផ្សិត" ពី Suet ហើយថវិកាចំនួន ១៦០ .០០០ដុល្លារអាមេរិក ដែលបានមកពី អង្គការ SIDA ដើម្បីធ្វើការនៅប្រទេសឡាវ វៀតណាម និងកម្ពុជាលើគម្រោងនៃការស្រាវជ្រាវទាក់ទងនឹងការកសាងសមត្ថភាពរបស់សាស្ត្រាចារ្យ (RUA: Dean4)។ ជាទូទៅការស្រាវជ្រាវរបស់ RUA មានភាពទូលំទូលាយច្រើន ប៉ុន្តែវាអាស្រ័យទៅលើការផ្សារភ្ជាប់ទំនាក់ទំនងរបស់មហាវិទ្យាល័យនីមួយៗជាមួយនឹងម្ចាស់ជំនួយអន្តរជាតិ ជាជាងយុទ្ធសាស្ត្រនៃការសម្របសម្រួល និងការលើកទឹកចិត្តរបស់សាកលវិទ្យាល័យ (RUA: Dean4; RUA: Dean1)។

យើងមើលឃើញពីភាពខុសប្លែកគ្នានៃក្រុមអ្នកស្រាវជ្រាវរបស់សាកលវិទ្យាល័យទាំងអស់ជាមួយនឹងការផ្តោតសំខាន់លើវិស័យកសិកម្មការចិញ្ចឹមជីវិតនៅជនបទ ការធ្វើអាជីវកម្មសហគ្រាស ទំនាក់ទំនងនយោបាយក្នុងតំបន់ និងរដ្ឋបាលសាធារណៈ។ សាកលវិទ្យាល័យចំនួនបីបានធ្វើការស្រាវជ្រាវដើម្បីបង្កើន អត្រានៃការរកការងារធ្វើរបស់ពួកគេ និងជាការទាក់ទាញនិស្សិតឱ្យចូលរៀនផងដែរ។ យើងកត់សម្គាល់ឃើញទិដ្ឋភាពមួយ គឺការកំណត់វិធីសាស្ត្រក្នុងការស្រាវជ្រាវ។ ការស្រាវជ្រាវដែលប្រើកម្រងសំណួរ គឺជាវិធីសាស្ត្រដ៏ពេញនិយមមួយសម្រាប់សាកលវិទ្យាល័យទាំងអស់។ វិធីសាស្ត្រនេះត្រូវបានគេប្រើជាចម្បងក្នុងការស្រាវជ្រាវជាលក្ខណៈបរិមាណ (quantitative research) ប៉ុន្តែនៅក្នុងបទសម្ភាសន៍ជាច្រើន ក្រុមអ្នកស្រាវជ្រាវបានប្រើប្រាស់ការស្ទង់មតិ ដើម្បីទទួលបានការស្រាវជ្រាវជាលក្ខណៈគុណភាព (qualitative method)។ ក្រុមអ្នកស្រាវជ្រាវរបស់ប្រទេសកម្ពុជាបានប្រឈមមុខជាមួយនឹងវិធីសាស្ត្រនៃការប្រកួតប្រជែងនេះតាមរយៈឧទាហរណ៍នេះ។

**ចំណាប់អារម្មណ៍ក្នុងការស្រាវជ្រាវ**

ទោះបីជាអ្នកដែលឆ្លើយតបនឹងការស្ទង់មតិរបស់យើងសុទ្ធតែជាសាស្ត្រាចារ្យក៏ដោយ ក៏មិនមែនគ្រប់គ្នាមានពិសោធន៍ជាមួយការងារស្រាវជ្រាវនេះដែរ។ ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ១៨៣ នាក់ មាន១១២នាក់ (៦១,៧%) និយាយថា ពួកគេបានចូលរួមនៅក្នុងគម្រោងស្រាវជ្រាវ (តារាងទី ៧)។ នៅពេលដែលយើងធ្វើការប្រៀបធៀបរវាងអ្នកដែលធ្លាប់បានចូលរួមធ្វើការស្រាវជ្រាវ ជាមួយនឹងអ្នកដែលមានគម្រោងចូលរួមនៅពេលអនាគតនោះ (តារាងទី ៧) យើងទទួលបានលទ្ធផលគួរឱ្យចាប់អារម្មណ៍មួយចំនួន។ មនុស្សចំនួន១១២នាក់បានធ្វើការស្រាវជ្រាវ ហើយ៩៨នាក់បានប្រាប់ថា ពួកគេចង់ធ្វើការស្រាវជ្រាវនាពេលអនាគត និងចំនួន១៤នាក់បាននិយាយថា ពួកគេមិនចង់ធ្វើការស្រាវជ្រាវជាថ្មីម្តងទៀតទេ។ មានតែមនុស្សចំនួន៩នាក់ប៉ុណ្ណោះដែលមិនធ្លាប់បានធ្វើការស្រាវជ្រាវ ហើយក៏មិន

ចង់ធ្វើវានាពេលអនាគតដែរ។ មានន័យថា សរុបមក អ្នកឆ្លើយសំណួរចំនួន១៥៩នាក់ (៨៧%) មានការចាប់អារម្មណ៍ក្នុងការងារស្រាវជ្រាវ។

*តារាងទី ៧៖ ការចូលរួមក្នុងការស្រាវជ្រាវពេលកន្លងមក និងបំណងប្រាថ្នានៃការចូលរួមការស្រាវជ្រាវនាពេលអនាគត*

| | | តើអ្នកធ្លាប់បានចូលរួមក្នុងការស្រាវជ្រាវដែរឬទេ? | | |
|---|---|---|---|---|
| | | *Yes* | *No* | *សរុប* |
| តើអ្នកចង់ធ្វើការស្រាវជ្រាវនាពេលអនាគតដែរឬទេ? | *Yes* | 98 | 61 | 159 |
| | *No* | 14 | 9 | 23 |
| | *សរុប* | 112 | 70 | 182 |

ដើម្បីវាស់ស្ទង់ទៅលើសកម្មភាពរបស់អ្នកស្រាវជ្រាវទាំងអស់ អ្នកឆ្លើយតបត្រូវបានគេសួរថា តើបច្ចុប្បន្ននេះ អ្នកចូលរួមក្នុងគម្រោងនៃការស្រាវជ្រាវចំនួនប៉ុន្មាន (រូបទី ៤)? (៥៨%) ក្នុងចំណោមអ្នកឆ្លើយតបចំនួន១០៦នាក់ មិនមានគម្រោងស្រាវជ្រាវនោះទេ ខណៈដែលអ្នកនៅសល់ចំនួន ៧៧នាក់ (៤២%) កំពុងចូលរួមក្នុងសកម្មភាពស្រាវជ្រាវនាពេលបច្ចុប្បន្ន។ ពួកគេភាគច្រើនមានគម្រោងនៃការស្រាវជ្រាវមួយ។

*រូបភាពទី ៤៖ តើបច្ចុប្បន្ននេះអ្នកបានចូលរួមក្នុងគម្រោងនៃការស្រាវជ្រាវចំនួនប៉ុន្មាន?*



តារាងនេះបង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំងរវាងការចាប់អារម្មណ៍ក្នុងការធ្វើការងារស្រាវជ្រាវ (៨៧% នៃអ្នកឆ្លើយតប) និងអ្នកដែលកំពុងធ្វើការស្រាវជ្រាវបច្ចុប្បន្ន ដែលមានតែចំនួន (៤២%) កំពុងធ្វើការស្រាវជ្រាវ ហើយមានអ្នកឆ្លើយតបតិចតួចណាស់ដែលបានធ្វើការស្រាវជ្រាវលើសពីមួយគម្រោង។

## ការស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

ការស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិលដោយផ្ដោតសំខាន់លើបញ្ហាសិទ្ធិមនុស្ស អភិបាលកិច្ច និងការវិភាគផ្នែកច្បាប់ទាក់ទងនឹងរបាយការណ៍នៃការតស៊ូមតិ ក៏ដូចជាការស្រាវជ្រាវដើម្បីបណ្ដុះបណ្ដាលសហគមន៍។ ចំពោះ CCHR ធ្វើការស្រាវជ្រាវ ចេញផ្សាយរបាយការណ៍ដែលទាក់ទងនឹងការការពារសិទ្ធិមនុស្ស សិទ្ធិនយោបាយ បញ្ហាដីធ្លី សិទ្ធិទទួលបានសេរីភាពក្នុងការប្រជុំ និងការចូលរួមផ្សេងៗ។ Equitable Cambodia បានបែងចែកជាបី៖ ការឃ្លាំមើលការអភិវឌ្ឍ (Development Watch) ពង្រឹងអំណាចសហគមន៍ រួមទាំងការការយល់ដឹងច្បាប់ CELA និងការរៀបចំសហគមន៍។ សកម្មភាពនៃផ្នែកនីមួយៗក្នុងការងារស្រាវជ្រាវពិតជាសំខាន់។ អង្គការមិនមែនរដ្ឋាភិបាលក៏បានចូលរួមធ្វើការស្រាវជ្រាវលើបញ្ហាច្បាប់ ដើម្បីបណ្ដុះបណ្ដាលសហគមន៍ដែលរងផលប៉ះពាល់ដោយបញ្ហាដីធ្លី និងអភិវឌ្ឍផលប៉ះពាល់ផ្សេងៗដែរ។ "ច្បាប់គឺមានភាពស្មុគស្មាញ និងតម្រូវឱ្យយើងធ្វើការស្រាវជ្រាវ ក៏ដូចជាធ្វើការវិភាគបន្ថែម ដូច្នេះចាំបាច់ត្រូវតែមានការបណ្ដុះបណ្ដាលដែលមានប្រសិទ្ធភាព ដូចជាការធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញ និងអត្ថបទច្បាប់មួយចំនួនឱ្យបានច្រើនដង" (EC:PM)។ គម្រោងស្រាវជ្រាវថ្មីៗរបស់ EC បូករួមជាមួយនឹងការស៊ើបអង្កេតនៅខេត្តកោះកុងទាក់ទងបញ្ហាជម្លោះដីធ្លី និងការជិះជាន់ពលកម្មលើកុមារ ការចរចារជាមួយចម្ការកៅស៊ូរបស់ក្រុមហ៊ុនវៀតណាមនៅខេត្តរតនគិរីផងដែរ (EC:PM)។ សកម្មភាពទាំងនេះធ្វើឱ្យមានការយល់ដឹងលើគោលនយោបាយ ហើយបានដាក់សម្ពាធទៅលើក្រុមហ៊ុន និងវិនិយោគិនដែលមានបំណងក្នុងការបណ្ដាក់ទុនដើម្បីអភិវឌ្ឍនៅប្រទេសកម្ពុជា។ ការអភិវឌ្ឍនៅក្នុងចំណុចនេះបានចង្អុលបង្ហាញថា "បន្ទាត់ផ្ដេក (horizontal)" ក្នុងការទទួលយកលទ្ធផលពីតួអង្គដែលមិនមែនជារដ្ឋាភិបាលពិតជាសំខាន់ ប៉ុន្តែការមើលរំលងលើសេចក្ដីថ្លែងការណ៍ដែលទាក់ទងនឹង "បញ្ឈរ (vertical)" ដែលតម្រូវឱ្យមានការចូលរួមជំរុញជាមួយក្រុមអ្នកបង្កើតគោលនយោបាយនោះ។ ការស្រាវជ្រាវរបស់ខុមហ្រ្វែលផ្ដោតសំខាន់ទៅលើការស្ទង់មតិជាស្ថិតិលើបួនចំណុច៖ ការធ្វើសវនកម្មលើបញ្ជីឈ្មោះបោះឆ្នោត (ហើយធ្វើការប្រៀបធៀបជាមួយបញ្ជីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកម្ពុជា គ.ជ.ប) ការចូលរួម ក៏ដូចជាការធ្វើអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ (ដំណើរការចូលរួម) ការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ការធ្វើវិមជ្ឈការ (អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ) ភាពស្របគ្នានៃការរាប់សន្លឹកឆ្នោត និងការចូលរួមរបស់ជនពិការ (Com:B)។

ពួកគេទទួលបានមូលនិធិស្នូលពីម្ចាស់ជំនួយអន្តរជាតិ (NGA OXFAM ស្ថានទូតចក្រភពអង់គ្លេស Forum sheet NDI) និងទទួលបានថវិកាទ្រង់ទ្រាយតូចពីម្ចាស់ជំនួយក្នុងស្រុកដែរ។

## ការពិគ្រោះយោបល់រយៈពេលខ្លីសម្រាប់ការស្រាវជ្រាវ

ខណៈដែលការស្រាវជ្រាវរបស់យើងបានផ្តោតជាចម្បងលើលក្ខណសម្បត្តិនៃក្រុមអ្នកស្រាវជ្រាវនៅកម្ពុជានោះ អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជនមួយចំនួន បានជួលក្រុមអ្នកប្រឹក្សាយោបល់រយៈពេលខ្លីដើម្បីធ្វើការស្រាវជ្រាវ ហើយពួកគេភាគច្រើនជាអ្នកស្រាវជ្រាវអន្តរជាតិ។ ឧទាហរណ៍ដូចជា អ្នកនាំពាក្យរបស់ADBបានប្រាប់យើងថា ជាទូទៅបុគ្គលិករបស់ ADB មិនធ្វើការស្រាវជ្រាវដោយខ្លួនឯងផ្ទាល់នោះទេ ពួកគេជួល(និងគ្រប់គ្រង)អ្នកពិគ្រោះយោបល់ជាតិ និងអន្តរជាតិ (ADB)៖ "នៅក្នុងលក្ខខណ្ឌជាតិ យើងជ្រើសរើសអ្នកពិគ្រោះយោបល់ទាំងថ្នាក់ជាតិ និងអន្តរជាតិ។ មានករណីជាច្រើន ហើយយើងបានដាក់បញ្ចូលជំនាញនៅក្នុងករណីចំនួនពីរ ដែលអ្នកពិគ្រោះយោបល់ថ្នាក់ជាតិបានដឹងអំពីបរិបទសង្គម ប៉ុន្តែអ្នកពិគ្រោះយោបល់អន្តរជាតិទាមទារឱ្យមានជំនាញបច្ចេកទេស"។ អ្នកឆ្លើយតបរបស់ ADB បានកត់សម្គាល់ឃើញថា នៅក្នុងការសម្ភាសដែលពួកគេមិនបានបណ្តុះបណ្តាលអ្នកស្រាវជ្រាវនោះ ពួកគេបានជួលអ្នកស្រាវជ្រាវដែលមានការបណ្តុះបណ្តាលល្អ និងមានជំនាញគ្រប់គ្រាន់ចំពោះការស្រាវជ្រាវ។ អង្គការមិនមែនរដ្ឋាភិបាលលីកាដូបានជួលអ្នកពិគ្រោះយោបល់មកពីខាងក្រៅដែលភាគច្រើនជាអតីតអ្នកកាសែតមកពីអង់គ្លេសឬជាបុគ្គលិកមកពីអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ឬក៏អតីតបុគ្គលិកអង្គការលីកាដូ (LICADHO)។ ស្រដៀងគ្នានេះដែរ CCHR និង EC បានជួលអ្នកពិគ្រោះយោបល់អន្តរជាតិ ដែលធ្វើការក្នុងកិច្ចសន្យាផ្សេងៗគ្នាទាក់ទងនឹងការស្រាវជ្រាវផ្នែកច្បាប់ ការធ្វើសំណើ និងការរៀបចំរបាយការណ៍ (CCHR:SR;EC:DM)។

ការពិគ្រោះយោបល់ជាលក្ខណៈអន្តរជាតិ គឺជានិន្នាការដ៏ទូលំទូលាយមួយសម្រាប់ការស្រាវជ្រាវក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដើម្បី"ជំរុញម្ចាស់ជំនួយ"។ មួយវិញទៀត ការស្រាវជ្រាវធ្វើឡើងដើម្បីទាក់ទាញចំណាប់អារម្មណ៍ម្ចាស់ជំនួយអន្តរជាតិ ជាងអ្វីដែលជាការពាក់ព័ន្ធជាមួយបរិបទមូលដ្ឋាន។ បញ្ហានេះមិនមែនកើតមានឡើងតែនៅក្នុងប្រទេសកម្ពុជានោះទេ គឺវាកើតឡើងយ៉ាងច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ តាមរយៈការស្រាវជ្រាវរបស់យើងបានបង្ហាញថា របៀបវារៈរបស់ម្ចាស់ជំនួយមានឥទ្ធិពលលើប្រភេទនៃការស្រាវជ្រាវដែលអាចឱ្យយើងធ្វើការអនុវត្ត និងផ្សព្វផ្សាយបាន។ ឧទាហរណ៍ដូចជាអ្នកឆ្លើយតបរបស់ ADB គឺមានភាពច្បាស់លាស់ណាស់ដែលថា ពួកគេមិនធ្វើការបោះពុម្ពផ្សាយលទ្ធផលនោះទេ ប្រសិនបើRGC មិនអនុម័តនោះ។ បើតាមសេចក្តីរាយការណ៍របស់ម្ចាស់ជំនួយបានតម្រូវឱ្យគម្រោងរបស់ពួកគេគឺត្រូវតែមាន "ភាពជោគជ័យ" វាអាចមានផលប៉ះពាល់ដល់គុណភាពនៃការស្រាវជ្រាវ ដូចជាអ្នកស្រាវជ្រាវត្រូវបានគេជំរុញឱ្យផ្តោតសំខាន់ទៅលើភាពជោគជ័យតែមួយមុខ ហើយក៏មិនចាប់អារម្មណ៍លើទិដ្ឋភាពផ្សេងទៀតក្នុងកម្មវិធីរបស់ម្ចាស់ជំនួយដែរ។

វាជារឿងដែលមិនអាចធ្វើទៅបាន នៅពេលដែលម្ចាស់ជំនួយកំណត់ពេលវេលាយ៉ាងតឹងរ៉ឹង ហើយចង់បានការស្រាវជ្រាវមួយដែលមានគុណភាពនោះ។ កិច្ចពិភាក្សាជាមួយអ្នកស្រាវជ្រាវម្នាក់ ដែលបានបដិសេធពីម្ចាស់ជំនួយក្នុងការប្រឹក្សាយោបល់បានបង្ហាញពីបញ្ហានេះ។ លោកបានរាយការណ៍ថា គាត់ធ្វើការនៅតំបន់ពាយព្យនៃប្រទេសកម្ពុជា ជាកន្លែងដែលមានចលនារបស់ប្រជាជនជនជាតិដើមយ៉ាងធំសម្បើម។ គាត់ត្រូវបានបង្រៀនដោយធនាគារអភិវឌ្ឍន៍អាស៊ី ADB រយៈពេលបីខែដើម្បីកំណត់លើតម្រូវការរបស់សហគមន៍ទាំងនោះ ក្នុងគោលបំណងដើម្បីបង្កើតគោលនយោបាយអភិវឌ្ឍន៍ឱ្យបានប្រសើរជាងមុន។ គាត់ក៏បានបញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើពួកគេចង់ធ្វើការវិភាគឱ្យបានល្អនោះ ការសិក្សានេះគួរតែមានរយៈពេលច្រើនជាងបីខែ ដែលគិតទៅលើចម្ងាយផ្លូវជាក់ស្តែង និងភាពរួញរារបស់សហគមន៍ជនជាតិដើមភាគតិច។ បន្ទាប់មក ធនាគារអភិវឌ្ឍន៍អាស៊ីបានរកឃើញអ្នកស្រាវជ្រាវមួយផ្សេងទៀតដើម្បីធ្វើការងារនេះ ហើយអ្នកស្រាវជ្រាវនោះក៏បានចេញផ្សាយរបាយការណ៍ ដែលបានជូនដំណឹងទៅសហគមន៍ជនជាតិដើមភាគតិចរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទាក់ទងនឹងគោលនយោបាយនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ដែរ។

ផ្នែកខ្លះៗនៃបញ្ហាក្នុងការដឹកនាំរបៀបវារៈការស្រាវជ្រាវដោយម្ចាស់ជំនួយនេះ ត្រូវបានអង្គការធំៗមួយចំនួនកំពុងដោះស្រាយ មានដូចជាធនាគារពិភពលោក ដែលបានផ្តល់មូលនិធិក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញសម្រាប់ក្រុមអ្នកស្រាវជ្រាវនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយដើម្បីឱ្យការស្រាវជ្រាវដែលមានប្រសិទ្ធភាព យើងបានស្នើឱ្យធ្វើការផ្លាស់ប្តូរប្រកបដោយចីរភាពបន្ថែមទៀត ដោយផ្តោតទៅលើការអភិវឌ្ឍសមត្ថភាពរយៈពេលវែង និងលក្ខខណ្ឌសម្រាប់ការស្រាវជ្រាវក្នុងតំបន់របស់ម្ចាស់ជំនួយ ដូចនឹងស្ថាប័នស្រាវជ្រាវក្នុងស្រុកដែលចាប់ផ្តើមពីការធ្វើផែនការ ការផ្តល់មូលនិធិតាមរយៈការអនុវត្ត និងទំនាក់ទំនងនៃការស្រាវជ្រាវ។ វាជាការយល់ឃើញរួមរបស់អង្គការសង្គមស៊ីវិលទាំងនោះ ដែលតម្រូវឱ្យពួកគេត្រូវការអ្នកពិគ្រោះយោបល់អន្តរជាតិ។ ហេតុអ្វីបានជាដំណើរការនេះមិនបាននាំឱ្យមានការផ្លាស់ប្តូរជំនាញថ្នាក់ជាតិ ក៏ដូចជានាំឱ្យការអនុវត្តនូវព័ត៌មានទាំងឡាយដែលតម្រូវឱ្យមានការស៊ើបអង្កេតពីធាតុផ្សំនៃដំណើរការ និងជាឧបសគ្គសម្រាប់ការអភិវឌ្ឍសមត្ថភាពក្រុមអ្នកស្រាវជ្រាវថ្នាក់ជាតិទៅវិញ។ យើងត្រូវធ្វើដូចម្តេចដើម្បីឱ្យអ្នកពិគ្រោះយោបល់អន្តរជាតិប្រើប្រាស់វិធីវិជ្ជមានក្នុងការណែនាំនៅកម្ពុជា។ មានទម្រង់ពីរដែលជួយអ្នកពិគ្រោះយោបល់អន្តរជាតិពាក់ព័ន្ធនឹងភាសា និងជំនាញនៃការសរសេរ ក៏ដូចជាជំនាញនៃវិធីសាស្ត្រក្នុងការស្រាវជ្រាវដែលមានដូចជាការវិភាគទៅលើបរិមាណនិងគុណភាពជាដើម។

**បំណងប្រាថ្នារបស់ក្រុមអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ**

ការជួលក្រុមអ្នកស្រាវជ្រាវអន្តរជាតិអាចនាំមកនូវផលប្រយោជន៍ (នៅក្នុងលក្ខខណ្ឌនៃជំនាញវិធីសាស្ត្រ និងសក្តានុពលក្នុងការជួយបង្ហាត់បង្ហាញដល់ក្រុមអ្នកស្រាវជ្រាវកម្ពុជា) ប៉ុន្តែមានអ្នក

ផ្តល់ចម្លើយជាច្រើនក្នុងការស្រាវជ្រាវរបស់យើងយល់ឃើញថា មានការកំណត់ភាពប្រឈមរបស់ក្រុមអ្នកស្រាវជ្រាវ អន្តរជាតិ និងអត្ថប្រយោជន៍របស់ក្រុមអ្នកស្រាវជ្រាវជាតិ ក៏ដូចជាអន្តរជាតិដែរ។ DC-Cam តែងតែធ្វើការជាមួយក្រុមអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ហើយពួកគេបានកត់សម្គាល់ឃើញថា ក្រុមអ្នកស្រាវជ្រាវអន្តរជាតិប្រឈមនឹងឧបសគ្គជាច្រើនក្នុងការបង្កើតការស្រាវជ្រាវមួយដែលមានគុណភាពនៅកម្ពុជា។ ពួកគេបានរួមបញ្ចូលទាំងគំនិត "នៃកង្វះការយល់ដឹងភាសាខ្មែរ និងវប្បធម៌ខ្មែរ" ព្រមទាំងរារាំងការអភិវឌ្ឍគុណភាពនៃការស្រាវជ្រាវរបស់មជ្ឈដ្ឋានខាងក្រៅ។ មួយវិញទៀត "ពួកគេមានការលំបាកក្នុងការស្វែងរកមនុស្សដើម្បីសម្ភាស" និងមានបញ្ហាជាមួយម្ហូបអាហារនៅក្នុងប្រទេសកម្ពុជា" ដែលពិតជាអាចធ្វើឱ្យមានភាពងាយស្រួលតាមរយៈកិច្ចសហការក្នុងតំបន់។ លើសពីនេះទៀត អ្នកស្រាវជ្រាវក្នុងស្រុកតែងតែ "កំណត់ថវិកា" ដែលអាចធ្វើឱ្យមានភាពប្រសើរឡើងតាមរយៈការសហការជាអន្តរជាតិ (DCCAM:D)។

ធនាគារអភិវឌ្ឍន៍អាស៊ីបានកត់សម្គាល់ថា បញ្ហារបស់អ្នកពិគ្រោះយោបល់ក្នុងតំបន់ និងអន្តរជាតិ (ស្រដៀងគ្នាជាមួយនឹង DC-Cam): "យើងត្រូវការអ្នកប្រឹក្សាយោបល់ ដែលដឹងពីបរិបទសង្គមកម្ពុជា និងអាចធ្វើការបានយ៉ាងរលូនជាមួយក្រសួងទាំងនោះបាន។ នៅក្នុងករណីរបស់ខ្ញុំទាក់ទងនឹងវិស័យកសិកម្ម យើងមានអ្នកពិគ្រោះយោបល់ល្អៗ និងបានសហការគ្នាជាមួយក្រសួងយ៉ាងរលូន ហើយទីបំផុតយើងទទួលបានលទ្ធផលល្អ។ ពេលខ្លះអ្នកប្រឹក្សាយោបល់អន្តរជាតិមិនបានយល់ពីបរិបទរបស់កម្ពុជាទេ ប៉ុន្តែពួកគេសរសេររបាយការណ៍បានយ៉ាងល្អ។ ជាចុងក្រោយ របាយការណ៍នេះមិនអាចប្រើប្រាស់បានទេ ព្រោះពួកគេគិតថានឹងមិនមាននរណាប្រើរបាយការណ៍របស់ពួកគេទេ។ ដូច្នេះ ការកម្រិតភាពអតិបរមាជាមួយក្រសួងគឺពិតជាមានសារៈសំខាន់ណាស់"(ADB)។ ចំណុចចុងក្រោយគឺ ភាពលំបាកដែលយើងជួបប្រទះជាមួយនឹងចំណុចរសើបនៃបញ្ហានយោបាយ ព្រមទាំងតម្រូវការក្នុងការកម្ចាត់ឧបសគ្គទាំងឡាយទាក់ទងនឹងបញ្ហាវប្បធម៌ និងបញ្ហាពិបាកក្នុងការធ្វើឱ្យវាមានដំណើរការលើសកម្មភាពផ្សេងៗ។ បើតាមបទពិសោធន៍នៃក្រុមស្រាវជ្រាវរបស់យើងបានបង្ហាញពីភាពងាយស្រួលក្នុងពេលធ្វើការជាមួយក្រសួងរដ្ឋាភិបាល និងក្រុមមន្ត្រីគ្រឹះស្ថានឧត្តមសិក្សា ដោយប្រើប្រាស់ការទំនាក់ទំនងក្នុងតំបន់។ ទាំងអស់នេះតម្រូវឱ្យយើងមានទំនាក់ទំនងល្អ (ពិធីការ) ហើយវាក៏អាចជាឧបសគ្គមួយសម្រាប់ក្រុមអ្នកស្រាវជ្រាវដែលមិនមានចំណេះដឹងដែរ។

### ការសហការ ការដឹកនាំ ការស្រាវជ្រាវ និងវត្តមាននៃក្រុមអ្នកស្រាវជ្រាវ

ការសហការ ការដឹកនាំធ្វើការស្រាវជ្រាវ និងការបង្កើតក្រុមអ្នកស្រាវជ្រាវ គឺនៅមានកម្រិតនៅឡើយសម្រាប់ការប្រកួតប្រជែងក្នុងការងារស្រាវជ្រាវនៅកម្ពុជា។ ការសហការជាលក្ខណៈអន្តរជាតិមានច្រើន ហើយនឹងមានភាពលម្អិត ប៉ុន្តែចំពោះការសហការរវាងស្ថាប័នក្នុងស្រុកគឺនៅមានតិចតួចនៅឡើយ។ មានការសហការគ្នាច្រើនរវាងអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល ដោយសារតែ

ពួកគេធ្វើការលើប្រធានបទ "ចំណុចក្តៅរបស់សង្គម" ដូចគ្នា។ មានការពិភាក្សាជាច្រើនដែលនិយាយអំពីការខ្វះកិច្ចសហប្រតិបត្តិការ ការប្រមូលនិន្នន័យ និងការជំរុញពីអតិថិជន ប៉ុន្តែផលប៉ះពាល់ទាំងនេះវាជាផ្នែកដាច់ដោយឡែកមួយរបស់អង្គការសង្គមស៊ីវិល ដែលតម្រូវឱ្យធ្វើកិច្ចសហការបន្ថែមទៀតនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដូចគ្នានេះដែរ គ្រឹះស្ថានឧត្តមសិក្សាជាកន្លែងដែលពួកគេធ្វើកិច្ចសហការក្នុងការប្រកួតប្រជែងលើទីផ្សារ និងភាពឯការបស់របាយការណ៍អ្នកស្រាវជ្រាវ ក៏ដូចជាឧបសគ្គនៃពេលវេលាដែរ។ វាបង្ហាញឱ្យឃើញថា មិនមានភាពគ្រប់គ្រាន់ចំពោះការប្រើប្រាស់អ្នកស្រាវជ្រាវក្នុងតំបន់ ហើយក្រុមអ្នកស្រាវជ្រាវទាំងនោះសង្ឃឹមថា ការខិតខំរបស់ពួកគេក្នុងការផ្សព្វផ្សាយ និងធនធានគេហទំព័ររបស់ពួកគេ នឹងអាចជួយបណ្តុះបណ្តាលនូវការអនុវត្តដែលមានរួចជាស្រេចហើយនោះ។

មានការអភិវឌ្ឍមួយចំនួនដើម្បីឆ្ពោះទៅរកការកសាងបណ្តាញរបស់ក្រុមអ្នកស្រាវជ្រាវ ដូចជាក្រុមអ្នកស្រាវជ្រាវ និងកិច្ចសហការក្នុងការណែនាំរវាងស្ថាប័នគ្រឹះស្ថានឧត្តមសិក្សា HEI។ ការកសាងសមត្ថភាពនៅផ្នែកមុន (ជំពូកទី៥) យើងមើលឃើញថាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានផ្តល់សិក្ខាសាលាដល់ស្ថាប័ននៅតាមបណ្តាលខេត្ត ហើយចំពោះសាកលវិទ្យាល័យបញ្ញាសាស្រ្តក៏បានបណ្តុះបណ្តាលដល់ក្រុមមន្ត្រី រដ្ឋាភិបាលទាក់ទងនឹងវិធីសាស្រ្តនៃការស្រាវជ្រាវដែរ។ លើសពីនេះទៅទៀត នាយកនៃនាយកដ្ឋានស្រាវជ្រាវនៅ UBB ក៏ត្រូវបានគេអញ្ជើញឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលការស្រាវជ្រាវនៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យដែរ (UBB:DR)។ ចំពោះសាកលវិទ្យាល័យជាតិគ្រប់គ្រងមានក្រុមសហការគ្នាលើការស្រាវជ្រាវទាក់ទងនឹងទីផ្សារភាគហ៊ុន (NUM:FR1) ហើយសាកលវិទ្យាល័យស្វាយរៀងបានរាយការណ៍ថា ថវិកាមូលនិធិរបស់ធនាគារពិភពលោកបានលើកកម្ពស់ការស្រាវជ្រាវផ្នែកកសិកម្ម និងជំរុញឱ្យមានកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ RUA និងសាកលវិទ្យាល័យព្រៃវែង (SRU:Deans)។

រង្វាស់មួយដែលត្រូវបានគេប្រើប្រាស់ដើម្បីវាស់វិសាលភាពនៃការបោះពុម្ពគឺ ការបោះពុម្ពការស្រាវជ្រាវរបស់សហនិពន្ធរបស់អ្នកនិពន្ធក្នុងតំបន់ជាមួយនឹងអ្នកនិពន្ធអន្តរជាតិ។ លទ្ធផលនៃការស្ទង់មតិរបស់យើងបានបង្ហាញថាភាគច្រើននៃក្រុមអ្នកស្រាវជ្រាវនៅកម្ពុជា បានបោះពុម្ពផ្សាយការស្រាវជ្រាវរបស់ខ្លួន (តារាងទី៨)។ មានតែ ១៣,៧% ប៉ុណ្ណោះ បានធ្វើការបោះពុម្ពផ្សាយការស្រាវជ្រាវជាមួយអ្នកស្រាវជ្រាវកម្ពុជា និងចំនួនតិចតួចបំផុត ៣,៨% បានបោះពុម្ពផ្សាយការស្រាវជ្រាវជាមួយសហអ្នកនិពន្ធអន្តរជាតិ (ចំណាំថាអ្នកឆ្លើយតបអាចជ្រើសយកចម្លើយបានច្រើនក្នុងចំណោមសំណួរនីមួយៗ)។

*តារាងទី៨៖ វិសាលភាពនៃសហអ្នកនិពន្ធក្នុងចំណោមក្រុមអ្នកស្រាវជ្រាវនៅកម្ពុជា*

| **អ្នកនិពន្ធ** | **ចំនួនអ្នកឆ្លើយតប** | **ភាគរយ** |
|---|---|---|
| អ្នកនិពន្ធ | ១០២ | ៥៥,៧ % |
| សហអ្នកនិពន្ធជាមួយជនជាតិខ្មែរ | ២៥ | ១៣,៧ % |
| សហអ្នកនិពន្ធជាមួយជនជាតិបរទេស | ៧ | ៣,៨ % |

អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិលមិនបានចែករំលែកព័ត៌មានទេ(CCHR: SR;EC:PM)។ ដោយសារតែពួកគេតែងតែធ្វើការក្នុងតំបន់ និងសហគមន៍ដូចគ្នា (អង្គការជាច្រើនបានឆ្លើយតបទៅនឹងបញ្ហាដ៏ធ្ងន់ធ្ងរនេះ) ដែលបង្ខំឱ្យពួកគេស្វែងរកវិធីដើម្បីសហការគ្នា "វាពិតជាលំបាកខ្លាំងណាស់"(EC:PM)។ បុគ្គលិករាយការណ៍អំពីបទពិសោធន៍ដែលទាក់ទងនឹងភាពតានតឹង និងភាពមិនស៊ីសង្វាក់គ្នានៃការសហការរបស់អង្គការសង្គមស៊ីវិល។ ឧទាហរណ៍ នៅពេលដែលធ្វើការជាមួយអង្គការ HRTF (Human Rights Task Force) លើបញ្ហាពង្រីកដីព្រលានយន្តហោះ អង្គការមិនមែនរដ្ឋាភិ បាលនីមួយៗមានបេសកកម្មរៀងៗខ្លួន។ EC បានប្រើប្រាស់ការសម្រុះសម្រួលជាយន្តការដើម្បីឱ្យមានឥទ្ធិពលលើការសន្ទនាជាមួយនឹងក្រុមហ៊ុនព្រលានយន្តហោះ ព្រមទាំងភាគីពាក់ព័ន្ធសាធារណៈនានា។ នៅក្នុងដំណើរការនៃការសម្រុះសម្រួលនេះ សហគមន៍មិនអាចធ្វើការតវ៉ា និងធ្វើបាតុកម្មជាសាធារណៈបានទេ។ ប៉ុន្តែអង្គការ HRTF បានគាំទ្រវិធីរបស់គេ និងបានឱ្យសហគមន៍ធ្វើបាតុកម្មជាសាធារណៈក្នុងអំឡុងពេលធ្វើការសម្រុះសម្រួលនោះ។ ដូច្នេះអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ មានយុទ្ធសាស្ត្រផ្សេងៗគ្នាដើម្បីធ្វើការកៀរគរអ្នកពាក់ព័ន្ធ ក៏ដូចជាជំរុញឱ្យចេញគោលនយោបាយដែលជាលទ្ធផលប្រឆាំងអ្នកផ្សេងទៀត។ វាគឺជាការស៊ើបអង្កេតដែលបានបង្ហាញចេញនូវលទ្ធផលវិជ្ជមានមួយ ដើម្បីកំណត់ការសម្របសម្រួល និង ការចែករំលែកព័ត៌មានដែលនាំឱ្យមានការអភិវឌ្ឍចំពោះស្ថាប័នខុសៗគ្នា។

វប្បធម៌ និងសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា បានធ្វើឱ្យសាស្ត្រាចារ្យមួយចំនួនមានគំនិតអវិជ្ជមាន ហើយមានការលំបាកខ្លាំងក្នុងការគិតវិជ្ជមាន និងការជឿទុកចិត្តគ្នា។ សាកលវិទ្យាធិការUBB ដែលមានជំនាញផ្នែកសង្គមវិទ្យា និងប្រវត្តិសាស្ត្របានយល់ឃើញពី ប្រវត្តិសាស្ត្រ វប្បធម៌ ស្ថានភាពគ្រួសារ និងចំណង់ចំណូលចិត្តរបស់មហាវិទ្យាល័យនៅUBBថាវាជាបញ្ហាដ៏ធំមួយ (UBB:PR)។ សាកលវិទ្យាល័យផ្សេងទៀតក៏បានរាយការណ៍ពីភាពខ្វះខាតនៃកិច្ចសហប្រតិបត្តិការ (MCU:VR) និងពេលវេលា "សាស្ត្រាចារ្យខ្លះរស់នៅឆ្ងាយ ដែលអាចឱ្យពួកគេមានការលំបាកខ្លាំងក្នុងការធ្វើដំណើរ

ជាក្រុម។ សាស្ត្រាចារ្យមួយចំនួនចង់ធ្វើការអភិវឌ្ឍចំណេះដឹងខ្លួនឯងបន្ថែម ប៉ុន្តែក៏មានមួយចំនួនទៀតមិនចង់ដែរ" (SRU:Deans)។

វាគឺជាការលំបាកណាស់ក្នុងការផ្តល់អនុសាសន៍ចំពោះស្ថានភាពនេះ ពេលគឺតម្រូវឱ្យយើងប្រើប្រាស់ពេលវេលាដើម្បីធ្វើការផ្លាស់ប្តូរ។ អនុសាសន៍ទាំងនោះត្រូវបានគេដាក់ចេញរួចមកហើយ ក្នុងលក្ខខណ្ឌនៃការវាយតម្លៃខ្លួនឯង និងកិច្ចសហការដែលឆ្លងកាត់ស្ថាប័នផ្សេងៗគ្នា ដើម្បីឆ្ពោះទៅរកកិច្ចសហការមួយដែលនាំឱ្យមានភាពល្អប្រសើរជាងមុន។

**កិច្ចសហប្រតិបត្តិការអន្តរជាតិ**

នៅក្នុងកិច្ចសហការអន្តរជាតិគឺមានលក្ខណៈរស់រវើកជាងកិច្ចសហការក្នុងតំបន់ បើទោះបីជាវាស្ថិតក្នុងដំណាក់កាលនៃការអភិវឌ្ឍក៏ដោយ។ ជាការយល់ឃើញទូទៅ ហើយក៏ជាការពិតមួយទាក់ទងនឹងសមត្ថភាពនៃកិច្ចសហការក្នុងតំបន់ដែលនៅមានកម្រិតទាបនោះ។ មានសាកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិលជាច្រើនបានបង្កើតទំនាក់ទំនងអន្តរជាតិ ដើម្បីធ្វើការបង្កើនសមត្ថភាពនិងសកម្មភាពរបស់ខ្លួនផ្ទាល់។ វាជារឿងដែលគួរឱ្យចាប់អារម្មណ៍មួយ ដែលស្ថាប័នរដ្ឋ (ក្រសួង) មានកិច្ចសហប្រតិបត្តិការតិចតួចណាស់ជាមួយរដ្ឋាភិបាល (ក្រៅពីស្ថាប័នយោធា) ប៉ុន្តែកិច្ចសហការជាលក្ខណៈអន្តរជាតិតែងតែកើតមានឡើងរវាងក្រសួង និងម្ចាស់ជំនួយអន្តរជាតិទៅវិញ។ គួរតែមានការស៊ើបអង្កេតមួយចំនួនបន្ថែមទៀតលើបញ្ហាទាំងនេះ។ យើងបានរកឃើញថា សកម្មភាពក្នុងការចូលរួមរបស់ស្ថាប័នអន្តរជាតិក្នុងប្រទេសកម្ពុជាមួយចំនួនដូចជា៖ កិច្ចសហប្រតិបត្តិការរវាងស្ថាប័ន និងអ្នកស្រាវជ្រាវដើម្បីកសាងសមត្ថភាពកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិ ជាមួយស្ថាប័នអន្តរជាតិដើម្បីធ្វើការចែករំលែក ការប្រមូលយកទិន្នន័យ និងការផ្សព្វផ្សាយ។

សាកលវិទ្យាល័យហ្សាម៉ាន់មានមជ្ឈមណ្ឌលសម្រាប់គាំទ្រការស្រាវជ្រាវ ដែលគោលបំណងក្នុងការបង្កើតនេះគឺដើម្បីនាំយកមូលនិធិពីស្ថាប័នខាងក្រៅឱ្យសាស្ត្រាចារ្យ ក៏ដូចជាអ្នកជំនាញរបស់ខ្លួន (អង្គការមិនមែនរដ្ឋាភិបាល ឬភ្នាក់ងារអន្តរជាតិ) សម្រាប់ធ្វើគម្រោងនៃការអភិវឌ្ឍនៅកម្ពុជា (Z:DH2; Z:DH1)។ ហ្សាម៉ាន់ក៏បានស្នើឱ្យមានតំណែងសាស្ត្រាចារ្យកិត្តិយស សម្រាប់អ្នកប្រាជ្ញអន្តរជាតិដែលបានផ្តល់ជូននូវការិយាល័យក៏ដូចជាកន្លែងធ្វើការងារ និងតែងតែផ្តល់ជូនថ្នាក់សម្រាប់ពួកគាត់បង្រៀនផងដែរ (Z:F)។ នាយកនៃសាកលវិទ្យាល័យហ្សាម៉ាន់បានឱ្យដឹងថា ពួកគេកំពុងតែធ្វើការលើកទឹកចិត្តដល់អតីតនិស្សិតរបស់គេ ឱ្យទៅសិក្សាបន្តនៅបរទេសដើម្បីធ្វើការងារពេញម៉ោងនៅមហាវិទ្យាល័យ "ជាមួយក្រុមអ្នកស្រាវជ្រាវជំនាន់ថ្មី ហើយការងារស្រាវជ្រាវនឹងមានភាពប្រសើរឡើងក្នុងរយៈពេល ៣ទៅ៤ឆ្នាំទៀត (Z:D)។

សាកលវិទ្យាល័យជាច្រើន បានបង្កើតឱកាសសម្រាប់មហាវិទ្យាល័យរបស់ខ្លួនទៅសិក្សានៅបរទេស។ ឧទាហរណ៍ដូចជា RUA បានបញ្ជូនសមាជិកមហាវិទ្យាល័យ ទៅក្រៅប្រទេសដើម្បីសិក្សា

ថ្នាក់អនុបណ្ឌិត បណ្ឌិត និងចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីជាមួយដៃគូអន្តរជាតិ Development Research Centre (IDRC) (RUA:Dean4)។ UBB ក៏បានជំរុញឱ្យមានកម្មវិធីសិក្សាអន្តរជាតិសម្រាប់សាស្ត្រាចារ្យ និងនិស្សិតមកពីប្រទេសអេស្ប៉ាញ អ៊ីតាលី កូរ៉េ អូស្ត្រាលី ថៃ និងវៀតណាម (UBB:DR) ដែលមានការចូលរួមពីសាស្ត្រាចារ្យអន្តរជាតិមួយចំនួន (UBB:PR; this is also reported at RUPP) ក៏ដូចជាមានកម្មវិធីផ្លាស់ប្តូរការសិក្សាគ្នា ជាមួយនឹងសាកលវិទ្យាល័យបរទេសផ្សេងទៀតដែរ។

អង្គការមិនមែនរដ្ឋាភិបាលក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយស្ថាប័នអន្តរជាតិផងដែរ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានធ្វើការតស៊ូមតិទាំងថ្នាក់ជាតិនិងអន្តរជាតិ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានផ្តល់ទិន្នន័យសម្រាប់យន្តការរបស់អង្គការសហប្រជាជាតិ 'International Convention for Civil Political Rights' ពិនិត្យឡើងវិញនៅខែមីនាឆ្នាំ២០១៤ (CCHR:SR)។ អង្គការលីកាដូ និង EC បានរាយការណ៍ស្តីពីអន្តរកម្មអន្តរជាតិ (ពិភាក្សានៅចំណុចមុន) ហើយនាយក DC-Cam បានកត់សម្គាល់ពីភាពកើនឡើង "នូវរំហូរជាសាកលនៃកិច្ចផ្តួចផ្តើមធ្វើការស្រាវជ្រាវ តាមរយៈបណ្តាញជាមួយនឹងបុគ្គលដែលធ្វើការស្រាវជ្រាវនៅកម្ពុជា" ហើយវាពិតជាមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះការរំពឹងទុកនៃកិច្ចការស្រាវជ្រាវនៅកម្ពុជា (DCCAM:D)។ ការសហការនេះអាចបង្កើនទំនាក់ទំនងនៃការបង្ហាត់បង្ហាញ ហើយក៏ជាឧបករណ៍មួយដែលជួយឱ្យមានការអភិវឌ្ឍទាំងក្រុមស្រាវជ្រាវជាតិ និងអន្តរជាតិផងដែរ។ យើងសង្ឃឹមថាវេទិកាដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងក្រុមអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិរបស់យើងនេះ នឹងធ្វើការជំរុញឱ្យមានកិច្ចសហការទាំងនេះបន្ថែម។

### ករណីសិក្សា៖ ការបណ្តុះបណ្តាលបរិស្ថានស្រាវជ្រាវ - រឿងរ៉ាវទាក់ទងនឹងអ្នកស្រាវជ្រាវពីរនាក់

ករណីសិក្សាទាំងពីរនេះបានបង្កើតឱ្យមានពន្លឺក្នុងការវាយតម្លៃចំនួនពីរខុសៗគ្នាទៅលើអ្នកចែករំលែកការស្រាវជ្រាវទៅកាន់សហគមន៍៖ សាស្ត្រាចារ្យរៀនចប់ថ្នាក់ PhD ដែលមិនធ្វើការស្រាវជ្រាវ និងអ្នករៀនថ្នាក់ PhD ដែលមានបំណងចង់ធ្វើការស្រាវជ្រាវ។ យើងមើលឃើញពីបញ្ហាប្រឈមរបស់ស្ថាប័នទាំងនោះតាមការបង្ហាញរបស់ក្រុមអ្នកស្រាវជ្រាវទាំងពីរ ប៉ុន្តែសកម្មភាពរបស់បុគ្គលនីមួយៗបានបង្ហាញពីវិធីដែលពួកគេមានឥទ្ធិពលទៅលើសកម្មភាពនៃបរិស្ថានស្រាវជ្រាវនោះទៅវិញ។

នាយកថ្នាក់សិក្សាមូលដ្ឋាននៅ UBB ផ្តល់នូវករណីសិក្សាដែលទាក់ទង នឹងក្រុមអ្នកស្រាវជ្រាវក្នុងប្រទេសកម្ពុជា។ លោកទទួលបានការបណ្តុះបណ្តាលនៅកម្ពុជាថ្នាក់ MA និងមួយទៀតថ្នាក់PhD។ សម្រាប់ការស្រាវជ្រាវថ្នាក់ PhD គាត់ធ្វើការសិក្សាលើទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ ហើយប្រើវាជា "ឯកសារដើម្បីជួយគាំទ្រ" ដល់ការបង្កើតគោលនយោបាយរបស់ក្រសួងអប់រំ។ មិនមាន

ការបោះពុម្ពផ្សាយនៅបណ្ណាល័យរបស់រាជបណ្ឌិត្យសភាកម្ពុជា ហើយអ្នកនិពន្ធក៏មិនមានគម្រោងក្នុងការបោះពុម្ព ក៏ដូចជាធ្វើការស្រាវជ្រាវបន្ថែមទៀតដែរ។ ទោះបីជាគាត់មិនបានចូលរួមធ្វើការងារស្រាវជ្រាវក្នុងសាកលវិទ្យាល័យក៏ដោយ ក៏គាត់និយាយថា "ការស្រាវជ្រាវនៅសាកលវិទ្យាល័យនេះមិនមានដំណើរការល្អទេ។ ដោយសារតែគុណភាពរបស់បុគ្គលិកនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងសាធារណជនមិនឱ្យតម្លៃចំពោះការស្រាវជ្រាវរបស់គេ"។ គាត់គិតថា សាកលវិទ្យាល័យមិនមានគោលនយោបាយច្បាស់លាស់ និងមិនមានថវិកាសម្រាប់ធ្វើការស្រាវជ្រាវ ដែលធ្វើឱ្យក្រុមអ្នកស្រាវជ្រាវមិនបានទទួលការបណ្តុះបណ្តាល ក៏ដូចជាមិនបានចូលរួមក្នុងមជ្ឈមណ្ឌលស្រាវជ្រាវដែរ។ មតិទាំងនេះគឺវាទាក់ទងទៅនឹងបរិស្ថាននៃការស្រាវជ្រាវក្នុងសាកលវិទ្យាល័យ ដែលមានការជំទាស់លើគំនិតវិជ្ជមានជាច្រើនក្នុងសាកលវិទ្យាល័យនេះ។

លោក ហេង សុខ គឺជាអ្នកប្រាជ្ញវ័យក្មេងនៅសាកលវិទ្យាល័យហ្សាម៉ាន់ ដែលបានទទួលការអប់រំនៅសហរដ្ឋអាមេរិករយៈពេលប្រាំមួយឆ្នាំ (សញ្ញាបត្រអនុបណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Chapman បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណិតវិទ្យាពីសាកលវិទ្យាល័យ Chapman) ហើយគាត់ក៏បានសិក្សានៅប្រទេសកាណាដារយៈពេលពីរឆ្នាំ និងបច្ចុប្បន្ននេះគាត់គឺជាបេក្ខជនថ្នាក់បណ្ឌិត PhD នៅសាកលវិទ្យាល័យ Canada's Simon Fraser ដែរ។ គាត់បានចាប់ផ្តើមធ្វើការនៅសាកលវិទ្យាល័យហ្សាម៉ាន់ តាំងពីខែមករា ឆ្នាំ ២០១៥ ហើយបច្ចុប្បន្ននេះគាត់គឺជាសាស្ត្រាចារ្យ និងជាប្រធានដេប៉ាតឺម៉ង់ធនាគារ និងហិរញ្ញវត្ថុនៅហ្សាម៉ាន់។ ក្រៅពីធ្វើការងារនៅហ្សាម៉ាន់ គាត់ធ្លាប់ធ្វើជាព្រឹទ្ធបុរសរងនៅសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ក្នុងមហាវិទ្យាល័យហិរញ្ញវត្ថុ។ ក្នុងករណីរបស់គាត់ លោក ហេង បាននិយាយថា សាកលវិទ្យាល័យបានកាត់ផ្តាច់ការធ្វើការងារស្រាវជ្រាវរបស់គាត់។ គាត់មិនមានភាពច្បាស់លាស់ក្នុងការទទួលយកមូលនិធិសម្រាប់ការស្រាវជ្រាវ ហើយភាគច្រើននៃសកម្មភាពក្នុងការស្រាវជ្រាវរបស់គាត់គឺត្រូវទាក់ទងជាមួយនឹងសាកលវិទ្យាល័យរបស់គាត់នៅបរទេសច្រើនជាងសាកលវិទ្យាល័យហ្សាម៉ាន់។ ថ្មីៗនេះគាត់បានបញ្ចប់ការសិក្សាថ្នាក់ PhD ហើយសង្ឃឹមថា នឹងធ្វើការបោះពុម្ពផ្សាយការស្រាវជ្រាវទាក់ទងនឹងគណិតវិទ្យា។ បើទោះបីជាមិនមានថវិកាសម្រាប់ការស្រាវជ្រាវក៏ដោយ ក៏គាត់បានលើកទឹកចិត្តឱ្យសិស្សរបស់គាត់ធ្វើការស្រាវជ្រាវដើម្បីទទួលបានការអប់រំដែលមានកម្រិតខ្ពស់ដែរ។ គាត់មានសិស្សមួយចំនួនដែលធ្វើការលើការយល់ដឹងទាក់ទងនឹងការសម្រេចចិត្តរបស់មនុស្ស ពេលដែលពួកគេជ្រើសរើសសាកលវិទ្យាល័យ ដូច្នេះគាត់អាចទទួលបានទិន្នន័យដើម្បីជួយជំរុញយុទ្ធសាស្ត្រទីផ្សាររបស់សាកលវិទ្យាល័យហ្សាម៉ាន់ដែរ។

វត្តមានរបស់លោក ហេង តំណាងឱ្យភាពកើនឡើងនៃក្រុមអ្នកប្រាជ្ញវ័យក្មេងរបស់កម្ពុជា ដែលបានទៅសិក្សានៅបរទេស និងត្រឡប់មកវិញក្រោយបញ្ចប់ការសិក្សា ហើយទទួលបានមុខតំណែងជាសាស្ត្រាចារ្យនៅកម្ពុជា។ ក្រុមអ្នកស្រាវជ្រាវទាំងនេះមានថាមពល មានការចាប់អារម្មណ៍ និងមានបទ

ពិសោធន៍ក្នុងការងារស្រាវជ្រាវ បូករួមជាមួយនឹងជំនាញដែលពួកគេមានអាចប្រើប្រាស់ដើម្បីធ្វើការអភិវឌ្ឍនិស្សិត ឱ្យធ្វើការស្រាវជ្រាវបាន។ ប៉ុន្តែពួកគេក៏នៅមានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹង "ការកាត់ផ្តាច់" ក៏ដូចជាកង្វះខាតមូលនិធិ និងការគាំទ្រដែរ។

# ៧.ការយល់ដឹងពីសារៈប្រយោជន៍នៃការស្រាវជ្រាវ

**ទស្សនៈរបស់និស្សិតនៅលើការស្រាវជ្រាវ**

«ការធ្វើអ្វីមួយដោយគ្មានការស្រាវជ្រាវគឺពុំមានប្រសិទ្ធភាព មុននឹងធ្វើការអនុវត្តអ្វីមួយ យើងត្រូវធ្វើការសិក្សាស្រាវជ្រាវជាមុនសិន » ( NUM : SRT )

**ការយល់ឃើញរបស់និស្សិតជាច្រើន**

លើការស្រាវជ្រាវគឺវាមានសារៈសំខាន់ដើម្បីឈានទៅរកការជឿទុកចិត្ត។ ក្នុងបរិបទសង្គមពោរពេញទៅដោយភាពផ្លាស់ប្តូរបរិបទប្រព័ន្ធនយោបាយយ៉ាងឆាប់រហ័ស ដែលនាំមកនូវភាពទន់ខ្សោយផ្នែកគុណភាពដោយមានលក្ខណៈទ្រង់ទ្រាយធំ បានផ្តោតទៅលើតែលក្ខណៈទ្រង់ទ្រាយមិនគ្រប់គ្រាន់តាមបែបការស្រាវជ្រាវដើម្បីឱ្យមានគុណភាព។ ការធ្វើកិច្ចពិភាក្សាតុមូលជាមួយក្រុមនិស្សិតបានបង្ហាញឱ្យឃើញថា ការស្រាវជ្រាវគឺជាអត្ថប្រយោជន៍ដើម្បីឱ្យពួកគេយល់ដឹងកាន់តែច្បាស់នូវសីលធម៌នៃការសួរសំណួរ មិនតែប៉ុណ្ណោះ ការស្រាវជ្រាវអាចបង្កើននូវបណ្តាញទំនាក់ទំនងបានច្រើនទូទាំងពិភពលោក។ និស្សិតទាំងនោះយល់ឃើញថា ការស្រាវជ្រាវបានផ្តល់ឱ្យពួកគាត់ «រៀនស្គាល់ពីខ្លួនឯងអំឡុងពេលធ្វើការសិក្សាស្រាវជ្រាវ» (MCU : SRT) ហើយថែមទាំង« អភិវឌ្ឍចំណេះដឹង និងយល់អំពីភាពខ្លាំង និងភាពខ្សោយរបស់ខ្លួនទៀតផង» (PUC: STRT) ជាពិសេសជាងនេះទៅទៀត « ការស្រាវជ្រាវផ្តល់នូវព័ត៌មានជាក់ស្តែង សម្រាប់ការអភិវឌ្ឍសង្គម» (PUC: SRT)។

មិនតែប៉ុណ្ណោះ គំនិតនៃការស្រាវជ្រាវនេះជួយចែករំលែកក្នុងការអភិវឌ្ឍសង្គម ហើយក៏មាននិស្សិតនៃសាកលវិទ្យាល័យ UBB និង USEA បានបង្ហាញឱ្យកាន់តែច្បាស់ថា ការស្រាវជ្រាវបង្ហាញនូវបញ្ហានានា ហើយក៏ជាការជំរុញឱ្យសីលធម៌សង្គម និងផ្តល់នូវដំណោះស្រាយមួយដោយតថភាពជាក់ស្តែង៖

- ការស្រាវជ្រាវគឺជាការស្វែងរកបញ្ហា និងដំណោះស្រាយនៅក្នុងសង្គម" ស្វែងរកអ្វីជាបញ្ហាប្រឈមមុខ នៅក្នុងសង្គម (UBB: SRT)។
- ការស្រាវជ្រាវគឺជាការស្វែងរកនូវការស៊ើបអង្កេតយ៉ាងមុតមាំ
- ការស្រាវជ្រាវគឺធ្វើឱ្យនិស្សិតទាំងឡាយមានភាពតស៊ូ ដើម្បីបង្កើននូវចំណេះដឹង ក៏ដូចជាបង្កើននូវការត្រិះរិះពិចារណាដ៏ស៊ីជម្រៅ មិនតែប៉ុណ្ណោះការស្រាវជ្រាវក៏អាចជួយឱ្យនិស្សិតមានចំណេះដឹងទូលំទូលាយផងដែរ (RULE: SRT) ។

គំនិតទាំងអស់នេះបានលើកឡើងដោយកង្វះខាតនៃគោលការណ៍ច្បាប់ក្នុងការស្រាវជ្រាវ និងមតិទូទៅជុំវិញគំនិតនៃការអភិវឌ្ឍគឺថា ព័ត៌មានពុំមានលក្ខណៈការពិតជាក់ស្តែងដែលគោលការណ៍ច្បាប់បច្ចុប្បន្នគឺពុំបានផ្តោតទៅលើព័ត៌មានជាក់ស្តែងនៅឡើយ។ ដូច្នេះហើយ និស្សិតជាច្រើនបានសម្តែងនូវទុក្ខកង្វល់នៃការអនុវត្តក្នុងការស្រាវជ្រាវ ដូចជាការប្រឈមមុខ នឹងអាកាសធាតុ ការយល់

ដឹងអំពីដី និងជម្រើសថាមពលអគ្គិសនីថ្មីៗ ដោយឃើញផលវិបាកក្នុងការអនុវត្តជាក់ស្តែងនេះ និស្សិតទាំងឡាយយល់ថា ការស្រាវជ្រាវអាចជួយពួកគេយល់អំពីទ្រឹស្តី ដើម្បីធ្វើការអនុវត្តផ្ទាល់។ និស្សិតនៃ RUA មួយចំនួនចូលរួមអនុវត្តគម្រោងការស្រាវជ្រាវច្រើន ហើយយល់ឃើញថា ការស្រាវជ្រាវបានផ្តល់នូវការអនុវត្តដោយផ្ទាល់ដើម្បីស្វែងរកលទ្ធផលល្អមួយ«ការស្រាវជ្រាវយើងអាចកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន ហើយអាចផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត» (RUA:SRT)។ DR. Strange ជាអតីតប្រធាន CDRI បានធ្វើសិក្ខាសាលាមួយទៅលើការអភិវឌ្ឍសមត្ថភាព បទបង្ហាញនេះធ្វើឱ្យយើងខ្ញុំជាអ្នកស្រាវជ្រាវយល់កាន់តែស៊ីជម្រៅទៅនឹងសារៈសំខាន់នៃការស្រាវជ្រាវនេះ។ ពួកគេជួយបណ្តុះបណ្តាលនិស្សិតដើម្បីចូលរួមគម្រោងស្រាវជ្រាវជាច្រើន ប៉ុន្តែពួកគេពុំបានផ្តល់នូវលទ្ធផលល្អទេ ពីព្រោះពួកគេពុំមានបទពិសោធន៍នៃការស្រាវជ្រាវគ្រប់គ្រាន់។ ទាំងនេះហើយគឺថាការស្រាវជ្រាវដែលតម្រូវឱ្យមានការបណ្តុះបណ្តាលសមត្ថភាពជាមុនសិន។

**ការយល់ឃើញក្នុងបណ្តាស្ថាប័នពាក់ព័ន្ធ**

«ការស្រាវជ្រាវគឺមានសារៈសំខាន់ ពីព្រោះគ្មានការស្រាវជ្រាវ គ្មានការអភិវឌ្ឍ » USE: UFR អ្នកបង្កើតច្បាប់និយាយថា « ចំនួន ឬគុណភាពទិន្នន័យសម្រាប់ធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវនៅមានភាពខ្វះខាត » យើងត្រូវការទិន្នន័យសម្រាប់ធ្វើផែនការនេះ។ (MOP1) ទាំងនេះជាបញ្ហាថាតើទិន្នន័យប្រភេទមួយណាជាអាទិភាពចម្បង? តើក្រសួងត្រូវការអ្វីដើម្បីធ្វើការទំនាក់ទំនងទៅលើស្ថាប័នស្រាវជ្រាវផ្សេងៗ ហើយតើក្រសួងធ្វើការកែលម្អ និងសម្របសម្រួលដោយរបៀបណាដើម្បីអភិវឌ្ឍសមត្ថភាពនៃការស្រាវជ្រាវ និងសេចក្តីត្រូវការរបស់ស្ថាប័នស្រាវជ្រាវដើម្បីផ្សារភ្ជាប់ទៅនឹងអ្នកបង្កើតច្បាប់។

ក្នុងបណ្តាសាកលវិទ្យាល័យនានា ក្នុងបុគ្គលិករដ្ឋ សាស្ត្រាចារ្យ ពួកគេយល់ឃើញថា ការស្រាវជ្រាវគឺត្រូវបានទទួលស្គាល់ថា វាជាផ្នែកមួយដ៏សំខាន់នៃការបង្រៀន ក៏ដូចជាការផ្សព្វផ្សាយសម្រាប់ការសិក្សា។ ការស្រាវជ្រាវបានក្លាយទៅជាស្ពានដ៏សំខាន់ក្នុងការផ្លាស់ប្តូរនូវបញ្ហាសង្គមនៅក្នុងទីផ្សារឧត្តមសិក្សាក៏ដូចជា ជួយឱ្យវិស័យអប់រំប្រកបដោយកិត្យានុភាព។ បញ្ញវន្តមួយចំនួនបានលើកឡើងពីសារៈសំខាន់នៃថ្នាក់បណ្ឌិត ដើម្បីបង្កើននូវអត្តិភាពសំខាន់នៃអ្នកស្រាវជ្រាវ ហើយស្ថាប័នបុគ្គលិករដ្ឋបាលផ្សារភ្ជាប់ការស្រាវជ្រាវទៅនឹងការបង្រៀនឱ្យមានគុណភាព ដោយមានគំនិតថា "ការស្រាវជ្រាវល្អអាចបង្កើននូវកម្រិតគុណភាពនៃការបង្រៀន"។ ជាទូទៅ ការស្រាវជ្រាវអាចធ្វើឱ្យរាជរដ្ឋាភិបាលមានមុខមាត់ល្អ ក៏ដូចជាធ្វើឱ្យស្ថាប័នល្អប្រសើរដែរ មិនតែប៉ុណ្ណោះក៏អាចធ្វើឱ្យមុខមាត់ប្រទេសជាតិយើងមានកិត្តិយស » (PUC: Dean 2). សរុបសេចក្តីមក សាស្ត្រចារ្យទាំងអស់ទទួលស្គាល់ និងយល់ព្រមថា ការផ្សារភ្ជាប់ការស្រាវជ្រាវក្នុងការបង្រៀនអាចបង្កើននូវចំណេះដឹង និងបទពិសោធន៍។

**សូចនាករ៥ ការលើកទឹកចិត្តក្នុងការស្រាវជ្រាវ៖**

តម្រូវការសាកលវិទ្យាល័យ

ជួយបង្កើតជំនាញ

បទពិសោធន៍

បង្កើនចំណេះដឹង

ខណៈនេះដែរ ការសហការជាមួយអ្នកស្រាវជ្រាវក្រៅប្រទេសគឺជាចំណុចវិជ្ជមានមួយដើម្បីស្វែងរកផ្លូវបង្កើនសមត្ថភាពអ្នកស្រាវជ្រាវក្នុងតំបន់ ហើយអ្នកចូលរួមបាននិយាយអំពីភាពអាម៉ាស់ដែលខ្លួនធ្លាប់មាន៖

ពេលខ្ញុំបានសិក្សាថ្នាក់អនុបណ្ឌិតក្នុងឆ្នាំ ២០០១ គំនិតនៃការធ្វើការស្រាវជ្រាវគឺជាគំនិតមួយថ្មីសន្លាងសម្រាប់ខ្ញុំ។ វាជាវិធីសាស្ត្រថ្មី... ខ្ញុំពុំយល់ច្បាស់អ្វីទៅហៅថាវិធីសាស្ត្រស្រាវជ្រាវ គ្រាន់តែដឹងថា ការចងក្រងពីឯកសារផ្សេងៗគ្នាដើម្បីដាក់ចូលជាឯកសារតែមួយ ឬក៏យកទិន្នន័យចេញពីសៀវភៅនេះ សៀវភៅនោះ ហើយដាក់ចូលគ្នាបែបដូចនេះគឺហៅថាការស្រាវជ្រាវសម្រាប់ខ្ញុំ។ អ្នកស្រាវជ្រាវបរទេសខ្លះបានមកបង្រៀននៅក្នុងប្រទេសកម្ពុជា បានស្តីបន្ទោសនិស្សិតទាំងឡាយថា គេពុំយល់នូវអ្វីដែលគេចង់សរសេរទេ? (CCH: SR)

សម្រាប់អ្នកចូលរួម CSO និយាយថា ការស្រាវជ្រាវគឺជាការងារបណ្តុះបណ្តាលដោយផ្ទាល់ ហើយ ការស្រាវជ្រាវ គឺដូចជាការស្រាវជ្រាវជាន់ខ្ពស់ ប៉ុន្តែការស្រាវជ្រាវគឺត្រូវការអនុវត្តច្រើន (CCHR: SR) នេះហើយជាសារៈប្រយោជន៍នៃការពន្លឿន និងផ្សព្វផ្សាយនូវលទ្ធផលដូចដែលអ្នកចូលរូម LICADHO បានឱ្យសេចក្តីណែនាំថា៖ ការស្រាវជ្រាវជាន់ខ្ពស់មានលក្ខណៈបត់បែនច្រើន ពីព្រោះវាមានលក្ខណៈពុំសូវពាក់ព័ន្ធនឹងភាពជាក់ស្តែង» (LICADHO)។ ក៏ប៉ុន្តែការស្រាវជ្រាវCSO បានយល់ឃើញថា ការស្រាវជ្រាវជាន់ខ្ពស់មានទ្រង់ទ្រាយកំហិតពេក ពីព្រោះជួនកាលទិន្ន័យដែលបង្ហាញនូវការលំបាកដោយសារតែការសិក្សានេះពុំសូវបានកែលម្អ ឱ្យបានទូលំទូលាយសម្រាប់ស្ថានភាពប្រទេសទាំងមូល ហើយវាជាទិន្ន័យឯកោតែប៉ុណ្ណោះ។ ចំណែកឯការស្រាវជ្រាវជាន់ខ្ពស់វិញគឺបានដាក់កំណត់ច្បាស់លាស់នូវវិធីសាស្ត្រនៃការស្រាវជ្រាវ និងតួយ៉ាងនៃការស្រាវជ្រាវ (ចំនួនមនុស្សនៃការសិក្សាស្រាវជ្រាវ) ការជ្រើសរើសរកទីតាំងជាដើម។

សាស្ត្រាចារ្យដែលបានចូលរួមបានបង្ហាញពីការមិនសប្បាយចិត្ត អំពីការស្រាវជ្រាវដែលពុំមានគុណភាពត្រឹមត្រូវ ពីព្រោះការកំណត់នូវការផ្សព្វផ្សាយ ការស្រាវជ្រាវអាចបង្ហាញពីបញ្ហាសំខាន់ៗជា

ច្រើន ប៉ុន្តែប្រសិនជាអ្នកស្រាវជ្រាវទាំងឡាយពុំមានចំណាប់អារម្មណ៍ក្នុងការបោះពុម្ពផ្សាយ ហើយទុកការស្រាវជ្រាវដែលខ្លួនបានធ្វើជាសម្ងាត់នោះ ការស្រាវជ្រាវពុំមានតម្លៃអ្វីបន្តិចសោះឡើយ។

សាស្ត្រាចារ្យជាច្រើនបានធ្វើការស្រាវជ្រាវ ពីព្រោះពួកគាតចង់ដឹងពីប្រភពបញ្ហា ដូចជាអាហារដែលមានជាតិគីមី ប៉ុន្តែទោះជាមនុស្សជាច្រើនយល់ដឹងនូវបញ្ហាទាំងអស់នេះហើយក៏ដោយ តែពួកគេមិនអាចដោះស្រាយបញ្ហានោះបានទេ។ សាស្ត្រាចារ្យជាច្រើនលះបង់គ្រប់យ៉ាងសម្រាប់ការស្រាវជ្រាវ ប៉ុន្តែពួកគាត់មិនទទួលបានអ្វីទាំងអស់ ដូច្នេះហើយអ្នកស្រាវជ្រាវភាគច្រើនគិតថា ការស្រាវជ្រាវគ្រាន់តែជាការងារសម្រាប់រកប្រាក់ចំណូល ពួកគាត់មិនយល់ពីតម្លៃនៃការស្រាវជ្រាវនៅឡើយទេ។ មូលហេតុគឺក្រោយទទួលលទ្ធផល គឺពួកគេរក្សាភាពស្ងប់ស្ងាត់ដោយពុំនិយាយអ្វីទាំងអស់។

**សេចក្តីសន្និដ្ឋាន**

ការបកស្រាយបំភ្លឺដោយនិស្សិតជាច្រើនក៏ដូចជាសាស្ត្រាចារ្យនៅគ្រប់សាកលវិទ្យាល័យបានបង្ហាញនៅក្នុងការសិក្សាស្រាវជ្រាវថា "ការស្រាវជ្រាវតម្រូវដាក់ឱ្យមាននៅក្នុងថ្នាក់ជាតិ ហើយសាស្ត្រាចារ្យ និងមន្ត្រីរដ្ឋបាលខ្លះទៀតបាននិយាយថា ការស្រាវជ្រាវជាសេវាកម្មសង្គម ហើយមនុស្សត្រូវការគិត និងត្រូវតែឱ្យស្គាល់ថាការសិក្សាស្រាវជ្រាវគឺជាសេវាសង្គមមួយដែលមិនសម្រាប់តែជាអាជីពក្នុងការរកចរិកាតែប៉ុណ្ណោះទេ។ (2:Dean1)

គោលបំណងនៃការស្រាវជ្រាវនេះគឺត្រូវបានយល់ស្របគ្នារឿងសេវាសាធារណៈក៏ដូចជា អង្គការមិនមែនរដ្ឋាភិបាលថា ការស្រាវជ្រាវគឺជាវិធីសាស្ត្រសំខាន់សម្រាប់បណ្តុះបណ្តាលទៅលើនិស្សិតដើម្បីឱ្យឈានទៅរកការអភិវឌ្ឍសង្គម។ យ៉ាងណាក៏ដោយ យន្តការនៃមូលនិធិវាមានលក្ខណៈស្មុគស្មាញសម្រាប់ $CSO_s$ ដើម្បីធ្វើសកម្មភាពផ្សេងៗ ហើយវាជាផលលំបាកក្នុងការចាត់ចំណាត់ថ្នាក់ក្នុងភាពជាសប្បុរសធម៌។ ចរិកាការស្រាវជ្រាវមានសារៈសំខាន់ដោយពុំផ្អែកទៅលើចរិកាវដ្ឋនៃស្ថាប័នរដ្ឋាភិបាលដែលពួកគេត្រូវទទួលខុសត្រូវសម្រេចនូវនីតិច្បាប់ និងរចនាសម្ព័ន្ធកញ្ចប់ចរិកា ដើម្បីលើកស្ទួយវិស័យការស្រាវជ្រាវ។ ប៉ុន្តែនេះគឺជាផ្នែកមួយនៃកិច្ចសន្ទនា ដែលរួមបញ្ចូលនូវសេចក្តីប្រឹងប្រែង និងជំនាញនៃ HEI ជាមួយនឹង $CSO_s$។

## ៨. ការផ្សព្វផ្សាយ និងនីតិច្បាប់នៃការភ្ជាប់ទំនាក់ទំនងទៅការសិក្សាស្រាវជ្រាវសង្គម

ការភ្ជាប់ទំនាក់ទំនងរវាងនីតិច្បាប់និងការសិក្សាស្រាវជ្រាវសង្គមនៅក្នុងប្រទេសកម្ពុជា ពុំទាន់មានលក្ខណៈពេញលេញនៅឡើយ។ ការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំសូមផ្តល់នូវយោបល់ ពីរចំណុចចម្បងដែលជានីតិច្បាប់មួយដែលមានប្រសិទ្ធភាព។ ទីមួយគឺការសិក្សាស្រាវជ្រាវតម្រូវឱ្យមានកញ្ចប់ថវិកា។ អ្នកផ្តល់ជំនួយអង្គការមិនមែនរដ្ឋាភិបាល (Think Tanks) គឺជាស្ថាប័នដែលអាចរកថវិកាសម្រាប់ការស្រាវជ្រាវមានប្រសិទ្ធភាពជាងសាកលវិទ្យាល័យនានាហើយការស្រាវជ្រាវរបស់ពួកគេគឺមានលក្ខណៈជះឥទ្ធិពលយ៉ាងខ្លាំងទៅលើនីតិច្បាប់ក្នុងការស្រាវជ្រាវ។ លើកលែងតែការស្រាវជ្រាវបញ្ចូលគ្នារវាង RUPP និង RUA ទេដែលទទួលកញ្ចប់ថវិកាពីក្រសួងនិងអ្នកផ្តល់ជំនួយ ប៉ុន្តែការស្រាវជ្រាវនេះត្រូវចៀសវាងការប៉ះពាល់នូវបញ្ហាសិទ្ធិមនុស្ស។ ទីពីរការផ្សព្វផ្សាយពីការស្រាវជ្រាវនៃការស្រាវជ្រាវពិតជាត្រូវការថវិកាកំណត់ឱ្យ ក៏ប៉ុន្តែមតិសាធារណៈយល់ថានីតិច្បាប់នៃការស្រាវជ្រាវអាចធ្វើឱ្យមានឥទ្ធិពលក្នុងការផ្លាស់ប្តូរស្ថាប័ននីមួយៗ ប្រសិនបើការស្រាវជ្រាវនេះអាចផ្សព្វផ្សាយបានឈានដល់សាធារណជន។

ការរកផ្លូវផ្សព្វផ្សាយការស្រាវជ្រាវឱ្យមានប្រសិទ្ធភាពគឺជាផលវិបាកមួយក្នុងសង្គមដោយហេតុថា ការយល់ដឹងនូវមានកម្រិតព្រោះភាសាអង់គ្លេសមានលក្ខណៈទន់ខ្សោយនៅឡើយ (RUPPIFL=SRT) ផលវិបាកវាមិនមែនមានតែការខ្វះចំណេះដឹង និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនោះទេ ចំណុចសំខាន់គឺការស្រាវជ្រាវខ្លះវាធ្វើឱ្យប៉ះពាល់ដល់បញ្ហាសង្គម និងនយោបាយ បើទោះបីជាអ្នកស្រាវជ្រាវមានចិត្តចង់បោះពុម្ពផ្សាយក៏ដោយ។ ក៏ប៉ុន្តែសាកលវិទ្យាល័យនានា ក្រុមអ្នកផ្តល់ជំនួយ Think Tanks ក៏ទទួលស្គាល់នូវផលវិបាកទាំងនេះដែរ។ នៅពេលដែលសង្គមស៊ីវិលនិងអង្គការនានាមានទំនោរជំរុញយ៉ាងសកម្មក្នុងការប្រឆាំងផលវិបាកខាងលើនេះ។ ការស្រាវជ្រាវរបស់រាជរដ្ឋាភិបាលពិតជាមានប្រសិទ្ធភាពសំខាន់ក្នុងការធ្វើនីតិច្បាប់ និងអាចផ្តល់នូវទិន្នន័យមួយយ៉ាងជាក់លាក់ដើម្បីឱ្យរាជរដ្ឋាភិបាលយកមកត្រិះរិះពិចារណានិងផ្សព្វផ្សាយ។ ផ្ទុយទៅវិញ បរិយាកាសអ្នកស្រាវជ្រាវនៅប្រទេសកម្ពុជាគឺជាសិទ្ធិនៅក្នុងអន្តរកាល ព្រោះថានីតិច្បាប់ក្នុងការស្រាវជ្រាវនៅមានការខ្វះខាតនៅឡើយ។ យើងខ្ញុំជាអ្នកស្រាវជ្រាវបានធ្វើកិច្ចពិភាក្សាទៅលើការអនុវត្តក្នុងការស្រាវជ្រាវរវាងបណ្តាស្ថាប័ននានា ហើយនៅក្នុងចំណុចនេះគឺយើងផ្តោតចម្បងទៅលើការអនុវត្តនូវការផ្សព្វផ្សាយនិងបន្តទៅការពិភាក្សាយ៉ាងសកម្មទៅអ្នកបង្កើតនីតិច្បាប់ក្នុងការសិក្សាស្រាវជ្រាវ។

**គេហទំព័រ** Online

អ្នកផ្សព្វផ្សាយដែលមានប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជា ក្នុងការស្រាវជ្រាវគឺគេហទំព័រ online ដែលត្រូវបានចុះផ្សាយនូវការស្រាវជ្រាវថ្មីជាប្រចាំ។ តាមការស្រាវជ្រាវរបស់យើងខ្ញុំ Think

Tanks អ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលមានគេហទំព័រ online ដែលមានគេហទំព័រទាំងនោះផ្សព្វផ្សាយនូវសកម្មភាពបច្ចុប្បន្នមានរក្សានូវរបាយការណ៍នានា និងអត្ថបទផ្សេងៗដែលពួកគេបានធ្វើការសិក្សាស្រាវជ្រាវ។ ឯកសារទាំងនោះអាចយកមកប្រើប្រាស់ជាប្រយោជន៍ក្នុងស្ថាប័ននានាក៏ដូចជាអាចយកមកតម្កល់ទុក និងចែកចាយតាមបណ្តាក្រសួងនានាក៏ដូចជានៅតាមបណ្តាខេត្តគ្រប់ជាន់ថ្នាក់ក៏ដូចជានៅក្នុងសាកលវិទ្យាល័យផ្សេងៗ មានគេហទំព័រ ៣ គឺ (CCHR, SR, និង LICADHO) មានពីរភាសាដែលអាចយកមកប្រើប្រាស់បានគឺមានអត្ថបទជាភាសាខ្មែរ និងភាសាអង់គ្លេស។ ទោះបីជា EC ពុំមានបកប្រែជាភាសាខ្មែរក៏ដោយភាគច្រើននៃគេហទំព័ររបស់ EC ប្រើប្រាស់ជាភាសាអង់គ្លេសក្នុងរបាយការណ៍ផ្សេងៗ ក៏ប៉ុន្តែក៏មានរបាយការណ៍មួយចំនួនជាភាសាខ្មែរដែរ។

CKS មានគេហទំព័របកប្រែហើយដែលអ្នកប្រើប្រាស់គេហទំព័រ CKS អាចជ្រើសរើសឬចូលមើលអត្ថបទជាភាសាខ្មែរទៅលើចំណុចសំខាន់នៃការសិក្សាសង្គម។ ក៏ប៉ុន្តែពុំមានការបកប្រែជាភាសាខ្មែរនៅលើគេហទំព័រ DC-Cam ទេ(ទោះបីជា DC-Cam បានបង្កើននូវការបណ្តុះបណ្តាលបង្រួមចូលគ្នាជាមួយនឹងវេទិកាផ្សព្វផ្សាយសង្គម និងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក online នៅចុងឆ្នាំ ២០១៣ក៏ដោយ LICADHO បានចាប់ផ្តើម "ការបញ្ច្រាបជីវិត" គឺក្នុងគោលបំណងបំផុសនូវការថែរក្សា "ឱ្យប្រព័ន្ធផ្សព្វផ្សាយលើគេហទំព័រ" ក្នុងរយៈពេល ២៤ ម៉ោងនៅក្នុងគេហទំព័រថ្មីៗដែលយកចេញពីអត្ថបទផ្សេងៗ រូបភាព និងវីដេអូផ្សេងៗ។ មនុស្សជាច្រើនអាចចូលមើលបានប្រសិនបើពួកគាត់ចង់ដឹងព័ត៌មានថ្មីៗកើតឡើងនៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស។ ក្រសួងផ្សេងៗមិនចាំបាច់ត្រូវការយកព័ត៌មានផ្ទាល់ទេគឺ LICADHO អាចបង្កើតជាព័ត៌មានយ៉ាងរហ័សដែលពួកគេចង់ដឹង។ (LICADHO)។

សាកលវិទ្យាល័យនានាគឺមានដំណើរការនៅខ្សោយនៅឡើយ គេហទំព័ររបស់ក្រសួង និងសាកលវិទ្យាល័យមានកង្វះខាតព័ត៌មានថ្មីៗ។ ដូច្នេះគេហទំព័រខាងលើនេះពុំមានប្រជាប្រិយភាពទេ។ គួរឱ្យកត់សម្គាល់នៃសាកលវិទ្យាល័យពីរគឺ RUPP & RUA ក៏ប៉ុន្តែព័ត៌មានទាំងនោះអាចបង្ហោះក្នុងគេហទំព័របានវាអាស្រ័យទៅលើប្រធានដេប៉ាតឺម៉ង់នីមួយៗ។ គេហទំព័រនៃសាកលវិទ្យាល័យទាំងនោះ និងក្រសួងនានាគឺត្រូវបានផ្សព្វផ្សាយដោយរបៀបបុរាណពេក នៅក្នុងបរិយាកាសនៃការធ្វើការស្រាវជ្រាវនៅប្រទេសកម្ពុជា។ មួយផ្នែកនៃគេហទំព័រអាចមានព័ត៌មានដែលអ្នកស្រាវជ្រាវអាចចូលមើល ឬអានបានដោយក្នុងគោលបំណងពង្រឹងនូវសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវ។ យ៉ាងណាមិញគេហទំព័រ **Facebook**គឺជា **Website** ដែលអាចផ្ទុកព័ត៌មានបាននៅក្នុងគម្រោងផ្សេងៗរបស់សាកលវិទ្យាល័យ (RUA: Dean1)។

**ការបោះពុម្ពផ្សាយ**

ក្រសួងផែនការបានចេញការបោះពុម្ពផ្សាយនូវលទ្ធផលនៃការស្រាវជ្រាវរបស់ពួកគេ នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ព្រមទាំងអញ្ជើញភ្ញៀវចូលរួមស្តាប់ ការធ្វើបទបង្ហាញស្តីពីកិច្ចការស្រាវជ្រាវទៅដល់

"ដៃគូដែលពាក់ព័ន្ធនឹងម្ចាស់ជំនួយ" នៅថ្នាក់ជាតិ។ ទោះជាយ៉ាងណាក៏ដោយ មន្ត្រីជាច្រើនដែលយើងបានធ្វើបទសម្ភាសន៍ជាមួយ មានអារម្មណ៍ថា ប្រសិទ្ធភាពនៃការផ្សព្វផ្សាយគឺកំពុងមានការខ្វះខាត អាចមកពីខ្វះនូវមូលនិធិគាំទ្រ (MoP1) ឬមកពីយន្តការសម្រាប់ការផ្តល់ព័ត៌មានមិនមានប្រសិទ្ធភាព ទៅតាមសំណើសុំផ្សេងៗ ដែលត្រូវបានរាយការណ៍ដោយក្រុមអ្នកស្រាវជ្រាវផងដែរ (មើលជំពូកទី៥) ។ ការផ្សព្វផ្សាយទិន្នន័យក្នុងគេហទំព័រ គួរតែជាអាទិភាពខ្ពស់សម្រាប់ក្រសួងផែនការ។ ក្រសួងអប់រំ យុវជន និងកីឡា មិនត្រូវបានចូលរួមនៅក្នុងការស្រាវជ្រាវណាមួយនោះទេក្នុងពេលថ្មីៗនេះ បើទោះជាការផ្តល់អនុសាសន៍របស់យើងចង់ឱ្យមានការវាយតម្លៃខ្លួនឯង និង ការស្រាវជ្រាវកម្មវិធីប្រកបដោយប្រសិទ្ធភាពគឺជាផ្នែកដ៏សំខាន់មួយសម្រាប់ពួកគាត់ដើម្បីកសាងសមត្ថភាពក្តី។

វាមានចំនួនតិច ប៉ុន្តែក៏មានការកើនឡើងនូវតួលេខនៃប្រជាជនកម្ពុជាដែលបានធ្វើការបោះពុម្ពផ្សាយការសិក្សារបស់ពួកគដែរ (រូបបង្ហាញ៦)។ នៅក្នុងការស្ទាបស្ទង់មតិរបស់យើង ២២%នៃអ្នកដែលបានឆ្លើយសំណួរបានឆ្លើយថា ពួកគេបានចុះផ្សាយការស្រាវជ្រាវរបស់ខ្លួននៅក្នុងហាង យ៉ាងហោចណាស់ក៏បានមួយដែរ។

*រូបភាពទី៦៖ ចំនួននៃការបោះពុម្ពដែលបានរៀបចំដោយមហាវិទ្យាល័យ (រួមមានសៀវភៅ អត្ថបទ និងរបាយការណ៍)*




ទម្រង់ទូទៅនៃការបោះពុម្ពផ្សាយឯកសារស្រាវជ្រាវនៅក្នុងការស្ទាបស្ទង់មតិរបស់មហាវិទ្យាល័យយើង គឺធ្វើឡើងតាមរយៈកាសែត បន្ទាប់មកគឺបោះពុម្ពជាសៀវភៅ និងមានចំនួនអ្នកឆ្លើយតិចតួចប៉ុណ្ណោះដែលបានឆ្លើយថា គេបានបោះពុម្ពលទ្ធផលស្រាវជ្រាវរបស់គេនៅត្រឹមតែក្នុងរបាយការណ៍ (តារាង៩)។

**តារាងទី៩៖ ប្រភេទនៃមធ្យោបាយបោះពុម្ពដែលអ្នកស្រាវជ្រាវបានបោះពុម្ពផ្សាយ**

| ប្រភេទនៃការបោះពុម្ព | ចំនួននៃអ្នកឆ្លើយសំណួរ | ភាគរយ |
|---|---|---|
| ទិនានុប្បវត្តិ(កាសែត) | ៦៦ | ៣៦.១% |
| សៀវភៅ | ៣៣ | ១៨.១% |
| របាយការណ៍ | ១៩ | ១០.៤% |
| ផ្សេងៗ | ១១ | ៦.0% |

មានការកត់សម្គាល់ថា ភាគច្រើននៃការបោះពុម្ពតាមរយៈកាសែត គឺនៅកាសែតដែលមិនមានលំដាប់ថ្នាក់ល្បី ហើយអ្នកខ្លះក៏ត្រូវបានបោះពុម្ពដោយសាកលវិទ្យាល័យរបស់ពួកគាត់ផ្ទាល់។ ក្រុមអ្នកស្រាវជ្រាវមកពីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង សាកលវិទ្យាល័យ ហ្សាម៉ាន់ (Zaman) សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ទាំងអស់គ្នាបានរាយការណ៍ថា បានបោះពុម្ពផ្សាយតាមរយៈកាសែត។ នៅមជ្ឈមណ្ឌលសិក្សាដើម្បីការអភិវឌ្ឍនៃមហាវិទ្យាល័យរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ពួកគេផលិតបរិមាណសៀវភៅឈានដល់កម្រិតខ្ពស់មួយ ព្រមទាំងអត្ថបទនិពន្ធជាច្រើន (៣០អត្ថបទ តាំងពីឆ្នាំ២០១០) និងរបាយការណ៍សកម្មភាពស្រាវជ្រាវ (២០របាយការណ៍ ចាប់តាំងពីឆ្នាំ២០១០)។ របាយការណ៍ខ្លះក៏មានការចូលរួមពីសិស្សនិស្សិត ទាំងនៅក្នុងពេលកិច្ចប្រជុំធ្វើបទបង្ហាញ និងទាំងកិច្ចខំប្រឹងប្រែងលើការបោះពុម្ពផ្សាយ (RUA:Dean1; Z:DH2)។ នៅករណីរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ លទ្ធផលស្រាវជ្រាវ និងការផ្សព្វផ្សាយសកម្មភាពមានការកើនឡើងនៅត្រឹមកម្រិតដេប៉ាតឺម៉ង់នីមួយៗ (RUPP:FR) ប៉ុន្តែការប៉ះពាល់ដល់គោលនយោបាយ គឺយើងពិបាកក្នុងការវាយតម្លៃ។

ភាគច្រើននៃអ្នកឆ្លើយសំណួរ អ្នកដែលបានធ្វើការបោះពុម្ពនូវអត្ថបទក្នុងកាសែត គឺមានអត្ថបទតែមួយគត់ដែលបានធ្វើការបោះពុម្ព និងមានតែ៣នាក់ប៉ុណ្ណោះដែលឆ្លើយថា បានធ្វើការបោះពុម្ពលើសពី៣អត្ថបទ (តារាងទី ១០)។ នេះចង្អុលបង្ហាញពីកម្រិតដ៏តិចតួចបំផុតនៃការបោះពុម្ពផ្សាយ។

តារាងទី ១០៖ ចំនួននៃការបោះពុម្ពផ្សាយJournal ដោយមហាវិទ្យាល័យ

| | ចំនួន នៃ ការបោះពុម្ពផ្សាយ Journal | |
|---|---|---|

| ចំនួននៃអ្នកឆ្លើយ សំណួរ | ០ | ១ | ២ | ៣ | ៤ | ៦ | សរុប |
|---|---|---|---|---|---|---|---|
| | ១១៧ | ២៥ | ២១ | ១៧ | ១ | ២ | ១៨៣ |

**ការបោះពុម្ពផ្សាយរក្សាទុកនៅផ្ទះ**

និស្សិតនិងមហាវិទ្យាល័យស្រាវជ្រាវ គឺបានរក្សាទុកនៅតាមផ្ទះសម្រាប់ស្ថាប័នភាគច្រើន (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យបាត់ដំបង សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ សាកលវិទ្យាល័យហ្សាម៉ាន់)។ សាកលវិទ្យាល័យបាត់ដំបងបានបង្កើតជា ឌីវីឌី នៃការសិក្សាស្រាវជ្រាវផ្នែកកសិកម្មរបស់ពួកគេ ដើម្បីផ្សព្វផ្សាយដល់កសិករក្នុងតំបន់ (UBB:DR) និង SRU បានផ្តល់៥០០ ច្បាប់ថតចម្លងជាភាសាអង់គ្លេស ធនាគារពិភពលោកបានផ្តល់មូលនិធិដល់របាយការណ៍ស្រាវជ្រាវចំពោះកសិករ និស្សិត និងអ្នកដទៃទៀត ព្រមទាំងអ្នកដែលមិនចេះអានភាសាអង់គ្លេសជាច្រើនទៀត (SRU:F1, F2, F3). ការសិក្សារបស់យើងបានបង្ហាញថា ការផ្សព្វផ្សាយរបស់សាកលវិទ្យាល័យ គឺមិនត្រឹមតែ មិនមានប្រសិទ្ធភាព និងនៅខ្សោយប៉ុណ្ណោះទេ ជារឿយៗវាត្រូវបានកំណត់នូវលក្ខខណ្ឌយ៉ាងតឹងរ៉ឹងទៀតផង។ ឧទាហរណ៍ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច តម្រូវឱ្យគ្រូបង្រៀនរក្សាទុក៥០ច្បាប់ នៃការងារបោះពុម្ពផ្សាយរបស់ពួកគេ នៅបណ្ណាល័យសាកលវិទ្យាល័យ មុននឹងពួកគេអាចចែកចាយ ឬលក់កន្លែងណាក៏ដោយ (RULE:Dean1)។ ជាងនេះទៅទៀត តម្រូវឱ្យសុំសិទ្ធិអនុញ្ញាតពីក្រសួងព័ត៌មានដើម្បីធ្វើការបោះពុម្ពទិនានុប្បវត្តិ (Journal) "ប្រសិនបើយើងប្រើពាក្យថា ទិនានុប្បវត្តិ (Journal) វាគឺជាបញ្ហារសើបខ្លាំងណាស់។ ពាក្យថា ទិនានុប្បវត្តិ (Journal) នៅសហរដ្ឋអាមេរិក វាជារឿងធម្មតា ក៏ប៉ុន្តែនៅប្រទេសកម្ពុជា យើងមិនត្រូវបានអនុញ្ញាតឡើយ... ផ្កាកុលាបគឺវានៅតែជាផ្កាកុលាប ថ្វីបើប្រើឈ្មោះផ្សេងក៏ដោយ ប៉ុន្តែនៅទីនេះ អ្នកមិនអាចហៅវាថាទិនានុប្បវត្តិបានទេ... អនុញ្ញាត" (PUC:Dean1)។

ការកំហិតទាំងនេះគឺវាមិនមានលក្ខណៈជាសាកលទេ ហើយ សាកលវិទ្យាល័យ ហ្សាម៉ាន់បច្ចុប្បន្នគឺកំពុងធ្វើការរួមគ្នា ជាមួយសាកលវិទ្យាល័យប្រទេស New Zealand ក្នុងការបោះពុម្ពទិនានុប្បវត្តិ (Z:F) និងសាកលវិទ្យាល័យជាតិគ្រប់គ្រង ក៏បានផលិតចេញបោះពុម្ពផ្សាយអត្ថបទមួយផងដែរលើប្រធានបទ កត្តាជោគជ័យ ក្នុងវិស័យសហគ្រាសខ្នាតតូចនិងមធ្យមរបស់កម្ពុជា ក្នុងកិច្ចសហការជាមួយ សាកលវិទ្យាល័យ Enthrop។ សាកលវិទ្យាល័យជាតិគ្រប់គ្រង បានបោះពុម្ពការស្រាវជ្រាវជាស៊េរីមួយដោយមានការឧបត្ថម្ភពីធនាគារពិភពលោក ដែលអាចរកបានពីគេហទំព័ររបស់ពួកគេ ការសរសេរនិពន្ធរបស់សិស្ស គឺត្រូវបានលើកទឹកចិត្ត ប៉ុន្តែមិនទាន់ត្រូវបានបោះពុម្ពនៅឡើយទេ

(NUM:DG)។ សាកលវិទ្យាល័យបាត់ដំបង ធ្វើការបោះពុម្ពទស្សនាវដ្ដីមួយឈ្មោះថា "The Bridge magazine" ដើម្បីបង្ហាញនិស្សិត និងមហាវិទ្យាល័យស្រាវជ្រាវ ប៉ុន្តែទាំងនេះវាបានបន្សល់ទុកនៅតែក្នុងផ្ទះ និងមិនអាចរកបាននៅគេហទំព័ររបស់ពួកគេនៅឡើយទេ បើទោះជាគោលការណ៍ថ្មីជាច្រើនបានបង្ហាញពីភាពប្រសើរឡើងនៃការប្រើប្រាស់គេហទំព័រសម្រាប់ការបោះពុម្ពផ្សាយការស្រាវជ្រាវក៏ដោយ (UBB:PR)។

ក្រុមអ្នកបង្កើតច្បាប់ បានឆ្លើយចង្អុលបង្ហាញថា មានការយល់ដឹងតិចតួចណាស់អំពីទិនានុប្បវត្តិ (Journal) ឬស្រាវជ្រាវជាស៊េរី ដែលបានបោះពុម្ពកាលពីពេលថ្មីៗនេះ។ ក្រុមអ្នកស្រាវជ្រាវទាំងពីរ ទាំងនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង និងទាំងសាកលវិទ្យាល័យហ្សាម៉ាន់ បានយល់ឃើញថាមាន "ការយកចិត្តទុកដាក់លើការបោះពុម្ពផ្សាយ ឬការបង្កើតការស្រាវជ្រាវ សម្រាប់សាធារណៈទូទៅតិចតួចណាស់" (NUM:FR2) ដែលវា "អាស្រ័យលើអ្នកសិក្សាស្រាវជ្រាវ ក្នុងការធ្វើឱ្យ [ការស្រាវជ្រាវ] ទទួលបានការបោះពុម្ពផ្សាយនៅក្រៅស្រុក" (Z:DH2)។ អារម្មណ៍មួយនេះ ត្រឡប់ជំនួសមកវិញនៅវិទ្យាស្ថានកសិកម្ម (RUA) ដែលការស្រាវជ្រាវ ភាគច្រើនទទួលបានមូលនិធិគាំទ្រដោយម្ចាស់ជំនួយពីប្រទេសអភិវឌ្ឍន៍ដែលមានការចាប់អារម្មណ៍ ទៅលើការគាំពារកសិករខ្នាតតូច។ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម មានការផ្សព្វផ្សាយ បញ្ជាក់ហួសលើសពីរបាយការណ៍ម្ចាស់ជំនួយ និង កសិករដែលពួកគាត់បានផ្ដល់សេវាឱ្យនោះបន្តិច (RUA:Dean4) គឺ "ក្នុងនាមជាម្ចាស់ជំនួយមិនលម្អៀងក្នុងការដាក់ចំនួនថវិកាចូលក្នុងការបោះពុម្ពផ្សាយលើលពីការនិយាយជាមួយអ្នកស្ដាប់ពីខាងដើម" (RUA:Dean2)។

ជារួម គោលនយោបាយតម្រូវឱ្យមានការសរសេរបោះពុម្ពផ្សាយ ព្រមទាំងការផ្សព្វផ្សាយនូវលទ្ធផល ហើយការសិក្សារបស់យើងបង្ហាញថា នេះនៅតែជាបញ្ហាប្រឈមសម្រាប់ស្ថាប័នអប់រំជាន់ខ្ពស់ (HEI)។

**សិក្ខាសាលា/សន្និសីទ**

សិក្ខាសាលា និងសន្និសីទមួយចំនួនវិញ គឺធ្វើរបាយការណ៍ឡើងខុសឆ្ងាយពីរបៀបនៃការធ្វើរបាយការណ៍របស់លទ្ធផលស្រាវជ្រាវសម្រាប់ការផ្សព្វផ្សាយ។ ការសិក្សារបស់យើងមិនអាចនិយាយទៅដល់ប្រសិទ្ធភាពនៃវិធីសាស្ត្រនេះបានយ៉ាងណានោះទេ ប៉ុន្តែវាបានបង្ហាញពីធម្មជាតិអន្តរកាលនៃឧបករណ៍ទំនាក់ទំនងទាំងនេះ។

នៅមានគម្រោងផែនការដែលជំរុញនាំឱ្យមានសិក្ខាសាលាមួយចំនួនទៀត ឧទាហរណ៍គម្រោងរបស់សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ (USEA) ថ្មីៗនេះ ស្ដីអំពីការអភិវឌ្ឍនូវកម្មវិធី បានគាំទ្រដោយមូលនិធិធនាគារពិភពលោកនឹងត្រូវបានពិភាក្សាផ្លាស់ប្ដូរយោបល់គ្នាតាមរយៈ"សិក្ខាសាលាផ្សព្វផ្សាយរយៈពេញមួយថ្ងៃ" ដែលបានអញ្ជើញនិស្សិត ក្រសួងទេសចរណ៍ សាកលវិទ្យាល័យទាំង

ប្រាំពីរក្នុងខេត្តសៀមរាប និងដៃគូសាកលវិទ្យាល័យជាតិ និងអន្តរជាតិជាច្រើនទៀតផងដែរ (USEA:DR)។ បន្ថែមជាងនេះទៀត ការស្រាវជ្រាវផ្នែកកសិកម្ម នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបាននិយាយពីខាងលើ ជាញឹកញាប់គេដាក់បញ្ចូលនូវអ្វីដែលជាតម្រូវការដាក់លាក់របស់ម្ចាស់ជំនួយ សម្រាប់សិក្ខាសាលាដើម្បីផ្សព្វផ្សាយនូវព័ត៌មានទៅកាន់ម្ចាស់ភាគីដែលពាក់ព័ន្ធ និងកសិករនៅផ្នែកចុងបញ្ចប់នៃគម្រោង (RUA:Dean1)។

ក្រៅពីនេះក៏មានបើកសិក្ខាសាលា និងមានព្រឹត្តិការណ៍ផ្សព្វផ្សាយមួយចំនួនតាមកាលវិភាគទៀងទាត់ជាច្រើនទៀតដែលគួរឱ្យកត់សម្គាល់។ការការពារនិក្ខេបបទជាសាធារណៈមួយចំនួន ត្រូវបានប្រារព្ធឡើងនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM:SRT) និង សាកលវិទ្យាល័យបានប្រារព្ធធ្វើកិច្ចពិភាក្សាស្តីពីការស្រាវជ្រាវ ឬគោលនយោបាយយ៉ាងទៀងទាត់ (NUM:FR2) និងមានសិក្ខាសិលាប្រចាំសប្តាហ៍មួយរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្មផងដែរ ដែលធ្វើនៅវិទ្យាស្ថាន ប៉ាស្ទ័រ (RUA:Dean1)។ មជ្ឈមណ្ឌលសិក្សាភាសាខ្មែរ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសមួយ "សិក្ខាសាលាសម្រាប់អ្នកស្រាវជ្រាវកម្ពុជា "ដែលអាចផ្តល់ជាវេទិកាមួយដល់អ្នកមានចំណេះដឹងខ្ពស់ខ្មែរបានចែករំលែកនូវលទ្ធផលរកឃើញពីការសិក្សាស្រាវជ្រាវរបស់ពួកគេ និងបង្កើនជំនាញការស្រាវជ្រាវនៃការគិតប្រកបដោយភាពម៉ត់ចត់ ការវិភាគនិងក្បួនវិធីសាស្ត្រ តាមរយៈការរំឭកឡើងវិញនូវទម្រង់មួយៗក្នុងវគ្គសិក្ខាសាលា (CKS:PR)។ វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានផ្តល់វគ្គសិក្ខាសាលាយ៉ាងសកម្ម និងធ្វើសន្និសីទនៃក្រុមអ្នកជំនាញផងដែរ នៅក្នុងឆ្នាំ២០១៥ នេះ មានព្រឹត្តិការណ៍បើកជាសាធារណៈចំនួន៦រួចមកហើយ ដែលបានអញ្ជើញវាគ្មិនជាតិនិងអន្តរជាតិជាច្រើន។

ទោះជាយ៉ាងណាក៏ដោយ នៅមានករណីផ្សេងៗទៀតដូចជាការប្រើប្រាស់នៃការបើកសិក្ខាសាលានិងសន្និសីទជាដើម វាផ្តល់ផលវិជ្ជមានតិចតួចណាស់នៅក្នុងរយៈពេលនៃការកសាងនូវសមត្ថភាព ឬការផ្សព្វផ្សាយស្រាវជ្រាវ។ ឧទាហរណ៍ និស្សិតថ្នាក់អនុបណ្ឌិតមួយចំនួនរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺត្រូវបានផ្តល់ជូនមួយក្រេឌីត (One Credit) សម្រាប់ការចូលរួមវត្តមាននៅក្នុងកិច្ចប្រជុំមួយ (RULE:DH) ជាមួយនឹងលក្ខខណ្ឌតម្រូវការតិចតួចប៉ុណ្ណោះ។ ជាងនេះទៅទៀត និស្សិតនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង អាចបង្ហាញការងាររបស់ពួកគេនៅក្នុងសិក្ខាសាលា ដែលត្រូវធ្វើឡើងម្នាក់ម្តងជាប្រចាំខែ ឥឡូវកើតមានឡើងនៅពេលណាដែលមានតម្រូវការតែប៉ុណ្ណោះ។អ្នកចូលរួមមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានរាយការណ៍ផងដែរថាមានការថយចុះក្នុងការបើកវគ្គសិក្ខាសាលារបស់សាកលវិទ្យាល័យឱ្យបានទូលំទូលាយ វគ្គបណ្តុះបណ្តាល និងសកម្មភាពកិច្ចប្រជុំដាងដប់ឆ្នាំកន្លងទៅហើយ លោកបានកត់សម្គាល់ផងដែរថាសកម្មភាពគឺមានច្រើនដែលដេប៉ាតឺម៉ង់បានជំរុញសព្វថ្ងៃនេះ (RUPP:DR; RUPP:DDR)។ បើមិនមានបំណងសិក្សាស្វែងយល់ទៅក្នុងសិក្ខាសាលាទាំងនេះទេ យើងក៏មិនអាចកំណត់ប្រសិទ្ធភាពរបស់ពួកគេ

បានឡើយ ប៉ុន្តែយុទ្ធសាស្ត្រការធ្វើវិមជ្ឈការរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានកត់សម្គាល់ឃើញថា នៅក្នុងផ្នែកគោលការណ៍ថ្នាក់ម៉ាក្រូនៃរបាយការណ៍នេះ គឺមានតម្លៃស័ក្តិសមសម្រាប់ការស្រាវជ្រាវបន្តទៀត។

ទោះយ៉ាងណាក៏ដោយ យើងបានធ្វើការប្រមូលព័ត៌មានពីការប៉ះទង្គិចគ្នាលើបញ្ហាវិសាលភាព និងគុណភាពនៃសិក្ខាសាលាផងដែរ ដូចជានៅលើការផ្សព្វផ្សាយរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៃសកម្មភាពស្រាវជ្រាវទូទៅ។ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ការអនុវត្តលើការផ្សព្វផ្សាយគឺមានលក្ខណៈមិនច្បាស់លាស់។ "តាមការយល់ឃើញរបស់ខ្ញុំ" មានប្រធាននាយកម្នាក់បានប្រាប់យើងថា "ពួកគេបើកវគ្គសិក្ខាសាលានិងសន្និសីទជាច្រើនដងរួចមកហើយ" ប៉ុន្តែគាត់សង្កត់បញ្ជាក់ថា "ខ្ញុំមិនមានរបាយការណ៍ណាមួយទៅលើពីរបៀបដែលពួកគេបានធ្វើការបោះពុម្ពនោះទេ" (RUPP:DR)។ នេះត្រូវបានឆ្លើយបន្ទរដោយនាយករងដែលគាត់បាននិយាយថា "ក្រេឌីតបានមកពីលទ្ធផលនៃការស្រាវជ្រាវ ឬវិភាគទាននៃមហាវិទ្យាល័យនៅក្នុងការបង្កើតជាលទ្ធផលស្រាវជ្រាវ គឺមិនទាន់មានការលើកទឹកចិត្ត និងទទួលស្គាល់ជាផ្លូវការនៅឡើយទេ"(RUPP:DDR)។ ខណៈដែលប្រធាននាយកមានភាពមិនច្បាស់លាស់អំពី ការស្រាវជ្រាវនឹងត្រូវផ្សព្វផ្សាយយ៉ាងណានោះ ប្រធានការិយាល័យផ្នែកទំនាក់ទំនងបាននិយាយយ៉ាងច្បាស់ថា ការស្រាវជ្រាវត្រូវបានប្រើសម្រាប់"គោលការណ៍អន្តរាគមន៍ និងទិសដៅសម្រាប់ការសិក្សា គោលការណ៍សង្ខេប ទិនានុប្បវត្តិយោងជារួម និងការងារលើរបាយការណ៍" (RUPP:DH)។ ការធ្វើវិមជ្ឈការរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងការយល់ឃើញខ្វែងគំនិតគ្នាក្នុងចំណោមអ្នកគ្រប់គ្រង គឺពិតជាស័ក្តិសមសម្រាប់ការតាមដានមួយ។

**ការផ្សព្វផ្សាយស្រាវជ្រាវជាអន្តរជាតិ**

រាល់អ្នកឆ្លើយសំណួររបស់យើងទាំងអស់ ក្រៅតែពីក្រសួងរដ្ឋាភិបាល បានគាំទ្រសមត្ថភាពការស្រាវជ្រាវកម្រិតវិទ្យាស្ថាន និងប្រសិទ្ធភាពនយោបាយ តាមរយៈការឆ្លងកាត់ប្រតិបត្តិការរវាងប្រទេសជាច្រើន។ អន្តរជាតូបនីយកម្ម ហាក់ដូចជាមានភាពទូលំទូលាយបានច្រើននៅអង្គការសង្គមស៊ីវិលនិងក្រុមអ្នកជំនាញ ប៉ុន្តែសម្រាប់សាកលវិទ្យាល័យគឺកំពុងតែបង្កើតទំនាក់ទំនងជាមួយអន្តរជាតិយ៉ាងជិតស្និទ្ធ។ លទ្ធផលបឋមរបស់យើង ឆ្លុះបញ្ចាំងពីមធ្យោបាយផ្សេងៗជាច្រើន ដែលប្រភេទនៃអង្គការនីមួយៗបណ្តុះនូវឥទ្ធិពលក្នុងសហគមន៍អន្តរជាតិរហូតដល់ទីចុងបញ្ចប់។ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលសកម្មភាពរបស់ពួកគេនៅឆាកអន្តរជាតិ គឺអំពីការចែករំលែកនូវព័ត៌មាន និងការចាក់ផ្សាយបញ្ញាតស្ម័គ្រទៅកាន់ទស្សនិកជនឱ្យកាន់តែទូលំទូលាយ។ ក្រុមអ្នកជំនាញ និងសាកលវិទ្យាល័យ ទាំងពីរក្រុមប្រើនូវអន្តរជាតូបនីយកម្មដើម្បីកសាងសមត្ថភាពអ្នកស្រាវជ្រាវ និងពង្រីកទំហំនៃការស្រាវជ្រាវតាមរយៈការធ្វើដំណើរ។ ក្រុមអ្នកជំនាញក៏ប្រើបណ្តាញទំនាក់ទំនងអន្តរជាតិ ដើម្បីកាន់តែស៊ីជម្រៅនិងមានសិទ្ធិគ្រប់គ្រាន់សម្រាប់ធ្វើសន្និសីទ និងការបង្រៀនរបស់ពួកគេជាបន្តបន្ទាប់

(CDRI, CKS) ។ សាកលវិទ្យាល័យមានការកែច្នៃនូវគំនិតថ្មីនិងបង្កើតបណ្ដាញទំនាក់ទំនងអន្តរជាតិដ៏ល្អសម្រាប់ជួយដល់ការឈានទៅកាន់បច្ចេកវិទ្យាទំនើប (UBB, Zaman, RUPP, USEA) ។ សាកលវិទ្យាល័យនិងភ្នាក់ងាររដ្ឋាភិបាលមានការចូលរួមជាមួយនឹងការស្រាវជ្រាវអន្តរជាតិនៅមានកម្រិតនៅឡើយ ក្នុងរយៈពេលនៃការបោះពុម្ពផ្សាយស្រាវជ្រាវជាអន្តរជាតិ និងជាវិភាគទានដល់កាសែតអន្តរជាតិ ប៉ុន្តែទំនាក់ទំនងមានការលូតលាស់ ជាមួយអ្នកស្រាវជ្រាវអន្តរជាតិម្នាក់ៗ និងវិទ្យាស្ថានមួយចំនួនទៀតផងដែរ។ ខាងក្រោមនេះគឺជាឧទាហរណ៍សំខាន់ៗមួយចំនួនដែលជាលទ្ធផលបានមកពីការស្រាវជ្រាវរបស់យើង។

សាកលវិទ្យាល័យបាត់ដំបងបានបញ្ជូនគ្រូប្រមាណជា២០នាក់ទៅបរទេស ទៅកាន់ប្រទេសដូចជា ប្រទេសអេស្ប៉ាញ អ៊ីតាលី អាល្លឺម៉ង់ ថៃ និងប្រទេសវៀតណាម ដើម្បីកសាងសមត្ថភាពស្រាវជ្រាវ របស់ពួកគេ (UBB : DR) និងថ្មីៗនេះ និស្សិតថ្នាក់ទំនាក់ទំនងអន្តរជាតិចំនួន៧ នាក់មកពីសាកលវិទ្យាល័យ បាត់ដំបងបានចូលរួមសន្និសីទអន្តរជាតិនៅប្រទេសសិង្ហបុរីផងដែរ។ សាកលវិទ្យាល័យ បាត់ដំបង និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាដៃគូជាមួយសាកលវិទ្យាល័យ ប្រទេសជប៉ុន ដើម្បីបង្កើតមូលដ្ឋានការលើកទឹកចិត្ត ការសិក្សាស្តីពី អាស៊ាន ដែលសិស្សកំពូលទាំង២០នាក់ទទួលបានថវិកា ១៥០ដុល្លារនាពេលបញ្ចប់ (UBB : PR)។ សាកលវិទ្យាល័យ ហ្សាម៉ាន់ បានរៀបចំសន្និសីទនិស្សិតមួយនៅក្នុងប្រទេសកម្ពុជា ហើយនៅក្នុងឆ្នាំនេះ បានបើកសន្និសីទ នៅតាមតំបន់ នៃអ្នកចូលរួម ជាលើកដំបូង ដើម្បីបង្កើនអ្នកចូលរួមអន្តរជាតិនៅឆ្នាំបន្ទាប់ទៀត (Z:D)។ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏បានផ្តល់ឱកាសជាច្រើនផងដែរ សម្រាប់ការបណ្តុះបណ្តាលនៅក្រៅប្រទេស និងមានអ្នក ស្រាវជ្រាវអន្តរជាតិមកទស្សនកិច្ចបានទៀងទាត់នៅសាកលវិទ្យាល័យ (RUA : Dean 2, RUA : Dean4)។

សហគមន៍អឺរ៉ុប (EC) និង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ធ្វើសេចក្តីរាយការណ៍ក្នុងសិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិព្រមទាំងកិច្ចពិភាក្សាមួយចំនួនទៀតក្នុងគោលបំណងដើម្បីចែករំលែកនូវលទ្ធផលដែលបានរកឃើញជាក់ស្តែង និងផ្តល់ទិន្នន័យសម្រាប់អង្គការអន្តរជាតិមួយចំនួន ដើម្បីជំរុញធ្វើឱ្យការងារទាំងនេះអាចអនុវត្តបាន ចំពោះការបង្កើតគោលនយោបាយ (EC : DM : CCHR : SR)។ EC ត្រូវបានចូលរួមនៅក្នុងការតស៊ូមតិជាច្រើនករណី ដែលមានគោលដៅបង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័នផ្តល់ប្រាក់កម្ចី។ ដោយមានទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ អន្តរជាតិ និងអង្គការតស៊ូមតិមួយចំនួន ពួកគេបានបញ្ចេះឱ្យមានយុទ្ធនាការដែលចូលរួមក្នុងប្រទេស កំណើតរបស់ខ្លួន ដើម្បីបកអាក្រាតការរំលោភបំពានទៅលើសិទ្ធិមនុស្ស។ អង្គការលីកាដូបានចេញសេចក្តីថ្លែងការណ៍ តាមរយៈប្រព័ន្ធផ្សព្វផ្សាយផងដែរ ដោយមានទាំងរបាយការណ៍សរសេរ ផលិតជាខ្សែវីដេអូ រូបភាពដែលគួរឱ្យតក់ស្លុត កម្មវិធីតាមវិទ្យុ និងរបាយការណ៍ជាសំឡេងសម្រាប់

ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ។ ក្រៅពីការផ្សព្វផ្សាយជាអន្តរជាតិ ពួកគេក៏មានវត្តមាននៅក្នុងនយោបាយអន្តរជាតិផងដែរ "*ប្រធានាធិបតីរបស់យើង គឺអាចប្រហែលជាធ្វើដំណើរទេសនកិច្ចនៅបរទេស ដូច្នេះមានគោលនយោបាយសង្ខេប ដែលមិនទាន់បានបញ្ចប់នៅក្នុងគេហទំព័ររបស់យើង។ ទាំងនេះទៅកាន់ប្រទេស ប៉េរូ ឬប្រេស៊ីល ក្រុងហ្សឺណែវ និងវ៉ាស៊ីនតោនឌីស៊ី វត្តមានរបស់យើងនៅក្នុងបរិយាកាសការធ្វើនយោបាយសាកលលោក ជួយជំរុញរបៀបវារៈដែលយើងមាន [ក្នុងប្រទេសកម្ពុជា]*"។

មជ្ឈមណ្ឌលសម្រាប់សិក្សាភាសាខ្មែរ បានផ្តល់នូវជំនួយដល់ការធ្វើដំណើរដល់សិស្សនិស្សិតកម្ពុជា និងបញ្ញវន្តនៅក្នុងសាកលវិទ្យាល័យ និងមានកម្មវិធីថ្នាក់តំបន់ថ្មីមួយទៀតដែលផ្តោតលើ "ការលាតត្រដាងជម្លោះនៅក្នុងតំបន់អាស៊ាន"។ កម្មវិធីនេះបានប្រមូលអ្នកពាក់កណ្តាលជំនាញអាជីព ពីប្រទេសកម្ពុជា ភូមា ឡាវ ថៃ និងវៀតណាម ដើម្បីបង្កើនចំណេះដឹងនៃការស្រាវជ្រាវជម្លោះ ការគ្រប់គ្រង និងការបង្ការរបស់ពួកគេ។ "គោលដៅសំខាន់នោះគឺដើម្បីបង្កើតបណ្តាញនៃអ្នកជំនាញទូទាំងប្រាំប្រទេសអាចធ្វើការជាមួយគ្នាបាន និងស្វែងរកឱកាសដើម្បីធ្វើការបោះពុម្ពការស្រាវជ្រាវរបស់ខ្លួនលើប្រធានបទជម្លោះក្នុងទំនាក់ទំនងបញ្ហាព្រំដែន នយោបាយ បរិស្ថាន និងបញ្ហាសេដ្ឋកិច្ចរបស់សហគមន៍អាស៊ាន (សហគមន៍សេដ្ឋកិច្ចតំបន់អាស៊ាន) និងអំពើហិង្សា" (CKS:PR)។ ការផ្តួចផ្តើមចុងក្រោយនេះមានសក្តានុពលចំពោះផលនយោបាយ និងអាចត្រូវបានពង្រីកដើម្បីរាប់បញ្ចូលទាំងជំនាញវិជ្ជាជីវៈរបស់រដ្ឋាភិបាលផងដែរ។

## សក្តានុពលនៃការស្រូបយកគោលនយោបាយនៅក្នុងប្រទេសកម្ពុជា

អន្តរកម្មរវាងអ្នកបង្កើតគោលនយោបាយ និងអ្នកសិក្សាស្រាវជ្រាវក្នុងប្រទេសកម្ពុជា គឺមិនជាកត្តាចាំបាច់ក្នុងការផ្លាស់ប្តូរនោះទេ ប៉ុន្តែវាឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដែលជារចនាសម្ព័ន្ធស៊ីជម្រៅ និងទូលំទូលាយ។ មួយចំនួននៃការងារទាំងនេះអាចត្រូវបានដោះស្រាយនៅក្នុងស្រុក ដូចជាសមត្ថភាពរបស់អ្នកស្រាវជ្រាវ និងផលិតភាពនៃការស្រាវជ្រាវដ៏រឹងមាំពាក់ព័ន្ធនឹងក្តីព្រួយបារម្ភខាងផ្នែកនយោបាយ ដោយមិនគិតពីភាពប្រែប្រួលគោលជំហររបស់ខ្លួន។ បញ្ហាប្រឈមផ្សេងទៀត គឺមិនមែនជាបញ្ហានៅក្នុងតំបន់និងមិនឆ្លុះបញ្ចាំងពីបញ្ហាប្រព័ន្ធនយោបាយ នឹងសេដ្ឋកិច្ចសាកលលោក នាពេលបច្ចុប្បន្នដ៏គួរឱ្យពេញចិត្តនោះទេ។ នៅជុំវិញពិភពលោក ជាញឹកញាប់ក្រុមមន្ត្រី និងក្រុមអ្នកបង្កើតគោលនយោបាយសាធារណៈដែលបានជាប់ឆ្នោត មានភាពខ្វះខាតនូវសមត្ថភាពក្នុងការអាន និងយល់ដឹងពីលទ្ធផលរកឃើញនៃការស្រាវជ្រាវ។ រីឯការិយាល័យសាធារណៈផងដែរ ជារឿយៗធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយពឹងផ្អែកទៅលើទំនាក់ទំនង និងផលចំណេញផ្ទាល់ខ្លួន ជាជាងការស្រាវជ្រាវដែលសមហេតុផល។

ស្របតាមព្រំដែនបន្ទាត់នេះ រដ្ឋាភិបាលមួយបានប្រកាសជាផ្លូវការថា "គោលនយោបាយរបស់រដ្ឋាភិបាលគឺមិនត្រូវបានកើតចេញតាមរយៈការស្រាវជ្រាវទេ" (MoEYS:2)។ នេះត្រូវបានលើកឡើង

បន្ទរ ដោយអ្នកស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់យោបល់ថានៅក្នុងប្រទេសកម្ពុជា "*ការស្រាវជ្រាវមួយចំនួនមិនមានអព្យាក្រឹតភាព លទ្ធផលនៃការរកឃើញមិនត្រូវបានរាយការណ៍ប្រកបដោយតម្លាភាព ឬក៏មិនត្រូវបានរាយការណ៍ទាំងអស់នោះទេ... ទាំងនេះអាចជាប់ពាក់ព័ន្ធមកពីសម្ពាធខាងផ្នែកនយោបាយ។ ឧទាហរណ៍ ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាគឺមានកម្រិតខ្ពស់ ប៉ុន្តែអ្នកស្រាវជ្រាវណាដែលរកឃើញលទ្ធផលទាំងនេះ ប្រហែលមិនហ៊ានធ្វើការបោះពុម្ពនូវលទ្ធផលទាំងនោះទេ។ មានតែអង្គការសិទ្ធិមនុស្ស ឬអង្គការសង្គមស៊ីវិលតែមួយគត់ ដែលហ៊ាននិយាយឥតសំចៃមាត់លើបញ្ហាទាំងអស់នេះ និង និយាយចំៗ ដែលអាចជាការផ្តល់នូវអនុសាសន៍មួយផងដែរ*" (CCHR:SR)។ លទ្ធផលរកឃើញនៃពិរុទ្ធភាពនេះ ត្រូវបានរាយការណ៍ផងដែរ ដោយម្ចាស់ជំនួយដ៏ធំដែលបានថ្លែងថាដោយសារមានភាពចម្រូងចម្រាសលើបញ្ហាដីធ្លីជាច្រើន ទើបរបាយការណ៍មួយចំនួនត្រូវបានពិនិត្យឡើងវិញ និងបន្ទាប់មក ទាំងមិនអនុម័តពីក្រសួងឱ្យមានការបោះពុម្ព ទាំងមិនមានការគាំទ្រពីក្រសួងដែលអាចបោះពុម្ពបានទេ ថែមទាំង "ពួកគេនឹងមិនយល់ព្រមអនុញ្ញាតឱ្យយើងបង្ហាញនូវទិន្នន័យទៀតផង" (ADB:PD)។

ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះគឺមិនមានជាការមិនយកចិត្តទុកដាក់ពិភាក្សាគ្នាដោយចេតនាទាំងស្រុងនោះទេ ឬក៏ជាការសង្កត់ធ្ងន់លើការស្រាវជ្រាវមួយដែលសមហេតុផលនោះដែរ និងមានអ្នកស្រាវជ្រាវម្នាក់បានផ្តល់ជាយោបល់ថា កង្វះខាតនៃការស្រូបយកនៃការស្រាវជ្រាវដោយអ្នកបង្កើតគោលនយោបាយ ត្រូវបានគេមើលឃើញថា វាក្លាយជាកំហុសទាំងខ្វះការគាំទ្រពីរដ្ឋាភិបាល និង "ដោយសារតែការស្រាវជ្រាវមានភាពមិនច្បាស់លាស់ និងមិនអាចជឿទុកចិត្តបាន" (PCU : VP)។ មានការផ្តល់យោបល់បន្ថែមទៀតនោះគឺ"ខ្វះការចូលរួមគោលនយោបាយ ជាមួយការស្រាវជ្រាវគឺជាបាតុភូតទូទៅមួយនៅលើសាកលលោក មួយផ្នែកទៀត ដោយសារតែការខ្វះខាតវិជ្ជាជីវៈ លើផ្នែកនៃអ្នកស្រាវជ្រាវ និងពីព្រោះអ្នកបង្កើតគោលនយោបាយមានអារម្មណ៍កាត់ផ្តាច់ចេញពីសាកលវិទ្យាល័យ និងមិនមានអារម្មណ៍ថា របៀបនៃការស្រាវជ្រាវគឺអាចជាក្រេឌីត" (Z:DH2)។ មន្ត្រីស្ថាប័នអប់រំជាន់ខ្ពស់ម្នាក់បានកត់សម្គាល់ថា កត្តាដែលធ្វើវិភាគទានដ៏ចម្បងមួយក្នុងក្របខ័ណ្ឌរបស់នាយកដ្ឋានរដ្ឋាភិបាលគឺខ្វះខាតនូវសមត្ថភាព។ នេះគឺជាការអសមត្ថភាពក្នុងផ្នែក សម្របសម្រួល គ្រប់គ្រង ឬគាំទ្រដល់ការស្រាវជ្រាវ ដូចមន្ត្រីមួយចំនួនដែលមិនមានបទពិសោធន៍ក្នុងការចូលរួមជាមួយសកម្មភាពស្រាវជ្រាវ" (MoEYS2)។

យ៉ាងណាក៏ដោយ ការថ្លែងទាំងនេះ គឺមិនមែនជាការដាក់ទម្ងន់ដ៏ធ្ងន់នោះទេ ហើយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានធ្វើសេចក្តីរាយការណ៍ថា "ពួកគេបានផ្តល់សំណុំរឿងសិក្សាមួយចំនួនទៅឱ្យសមាជិកនៃរដ្ឋសភា អំពីបញ្ហាទំនាស់ដីធ្លី។ ក្រុមអ្នកនយោបាយស្នើឱ្យយើងបង្ហាញសំណុំរឿងជាក់លាក់នៃទីតាំងដី។ នេះគឺជាអ្វីដែលថ្មីនឹងអាចជាលទ្ធផលនៃឥទ្ធិពលរបស់គណបក្សប្រឆាំង

ក្នុងអភិបាលកិច្ច" (CCHR:SR) ។ នាពេលថ្មីៗនេះ ឥទ្ធិពលនេះបានស្ថិតនៅក្រោមការគំរាមកំហែង និងប្រហែលជាមិនអាចផ្តល់សេចក្តីសង្ឃឹមសម្រាប់ការបើកផ្លូវទៅដល់អ្នកបង្កើតគោលនយោបាយ ប៉ុន្តែវាបានបង្ហាញពីគំនិតថា រឿងមួយនេះនឹងអាចកើតមានឡើងនៅលើប្រធានបទគោលនយោបាយដ៏សើបដ៏មានឥទ្ធិពល។ មន្ត្រីក្រសួងផែនការម្នាក់បាននិយាយថា អ្នកបង្កើតគោលនយោបាយរបស់ក្រសួងផែនការចង់ធ្វើការស្រាវជ្រាវបន្ថែមទៀត ទៅលើគោលនយោបាយមូលដ្ឋាន (MoP2) គំនិតយោបល់នេះក៏មានការគាំទ្រពីមហាវិទ្យាល័យ ហ្សាម៉ាន់ផងដែរ (Z:DH2)។ ក្រសួងផែនការបានប្រើលទ្ធផលនៃការស្រាវជ្រាវដើម្បីអភិវឌ្ឍគោលនយោបាយ ដើម្បីទប់ស្កាត់រំហូរនៃការចំណាកស្រុក នៅតាមជនបទនិងទីក្រុង គោលនយោបាយដើម្បីផ្តល់ការងារធ្វើដល់ប្រជាជនក្នុងតំបន់ និងគោលនយោបាយដើម្បីការពារ និងធ្វើឱ្យមានភាពប្រសើរឡើងនូវកម្រិតជីវភាពសម្រាប់អ្នកចំណាកស្រុក (MoP1)។

អ្វីដែលសំខាន់ លទ្ធផលរកឃើញរបស់យើងបង្ហាញថា សម្រាប់អ្នកស្រាវជ្រាវសិក្សា ការស្រូបយកគោលនយោបាយគឺមិនមែនជាកង្វល់ជាចម្បងទេ។អ្នកមួយចំនួនមានយោបល់ថា គោលដៅទស្សនិកជនរបស់ពួកគេគឺ សហគមន៍នៃក្រុមមិត្តភក្តិរបស់ពួកគេ ហើយគោលបំណងនៃការស្រាវជ្រាវរបស់ពួកគេគឺធ្វើឱ្យមានសុពលភាពជំនាញអាជីព និងបំពេញតម្រូវការនៃការសិក្សារបស់គេផ្ទាល់។ សមាជិកមហាវិទ្យាល័យម្នាក់នៃសាកលវិទ្យាល័យហ្សាម៉ាន់ បានទទួលសារភាពថាសកម្មភាពការស្រាវជ្រាវរបស់គាត់នាពេលថ្មីៗនេះគឺ "មិនត្រូវបានសូម្បីតែទាក់ទងដោយប្រយោលទៅនឹងការស្រូបយកគោលនយោបាយ" ប៉ុន្តែវាបានជំរុញដល់និក្ខេបបទបណ្ឌិតរបស់គាត់ និងអភិវឌ្ឍគំនិតផ្តួចផ្តើមផ្នែកទីផ្សារសម្រាប់សាកលវិទ្យាល័យ (Z:F) មានការនិយាយលើកឡើងផ្សេងទៀតថា"គោលដៅទស្សនិកជនរបស់ខ្ញុំនោះគឺមានច្រើននៅតាមសាកលវិទ្យាល័យ។ ការស្រាវជ្រាវគួរតែមានការបើកចំហជាសាធារណៈ ដូច្នេះពួកគេអាចមានឥទ្ធិពលទៅលើគោលនយោបាយរបស់រដ្ឋាភិបាល" (Z:DH2)។

ការទាញយកគោលនយោបាយពីការស្រាវជ្រាវអាចយកមក តាមរយៈការផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងជាសាធារណៈនៃការស្រាវជ្រាវការពិតដ៏សំខាន់ ដែលអាចបង្ខំឱ្យក្រុមអ្នកបង្កើតគោលនយោបាយទទួលស្គាល់ពួកគេ និងមានការចាត់វិធានការមួយចំនួន ដូចជាការងារនៃអង្គការមិនមែនរដ្ឋាភិបាលបានចង្អុលបង្ហាញ។ ជាឱកាសមួយផងដែរ នៅពេលដែលការស្រាវជ្រាវគឺត្រូវបានស្វែងរកឥទ្ធិពលដើម្បីផ្តល់យោបល់មកគោលនយោបាយ ឬធ្វើឱ្យមានឥទ្ធិពលលើការអនុវត្ត ហើយករណីខ្លះយើងបានរកឃើញកន្លែងស្រាវជ្រាវដែលអាចពាក់ព័ន្ធនឹងគោលនយោបាយត្រូវបានធ្វើឡើង និងត្រូវបានចែករំលែកដោយមិនមានការស្នើសុំពីអ្នកបង្កើតគោលនយោបាយ។ ឧទាហរណ៍ អ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យ ហ្សាម៉ាន់ បានធ្វើការសិក្សាមួយស្តីពីសុវត្ថិភាពចរាចរណ៍។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនមានជំនឿអំពីការស្រូបយកលើគោលនយោបាយនៃលទ្ធផលរកបាននៃការស្រាវជ្រាវ

របស់ពួកគេ "ដោយបញ្ចេញនូវលទ្ធផល (ដែលចាំបាច់ ត្រូវមានប្រភពធនធានបន្ថែមកាន់តែច្រើន និងការអនុវត្តច្បាប់ ដើម្បីកាត់បន្ថយការគ្រោះថ្នាក់ចរាចរណ៍) យើងសង្ឃឹមថា ភ្នាក់ងារនឹងមានព័ត៌មានដែលអាចទាញរកបាន... ដើម្បីធ្វើការពិចារណា និងប្រៀបធៀបនៅពេលដែលពួកគេធ្វើសេចក្តីសម្រេចចិត្ត" (Z:DH2)។

វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានបង្ហាញពីវិធីសាស្ត្រដែលជាកេរមរតក នៃផលប៉ះពាល់គោលនយោបាយ ដោយមិនជំទាស់ដោយផ្ទាល់នឹងគណបក្សគ្រប់គ្រងអំណាច និងរក្សាបាននូវទំនាក់ទំនងជិតស្និទ្ធជាមួយនឹងអ្នកបង្កើតគោលនយោបាយសំខាន់ៗ។ "មិត្តភាព"នេះតម្រូវមិនឱ្យមានការចូលរួមយ៉ាងជាក់លាក់នឹងបញ្ហាសិទ្ធិមនុស្ស (CDRI:MTR)។អតីតនាយក បានស្នើសុំថា វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាត្រូវ "គ្រប់គ្រងតុល្យភាពនៃឯករាជភាពនិងការចូលរួម"និង "ជាតួអង្គសម្តែងក្នុងន័យស្ថាបនា ក្នុងការពិគ្រោះពិភាក្សាគោលនយោបាយ ក្នុងបរិយាកាសនយោបាយដ៏ស្មុគស្មាញ" (ចម្លែក)។ អ្នកត្រួតពិនិត្យរយៈពេលពាក់កណ្តាលធមាសរបស់វិទ្យាស្ថានបានលើកឡើងថា ជំហររបស់វិទ្យាស្ថានរបស់ពួកគេ ការចូលរួមជាមួយអង្គការសង្គមស៊ីវិលមួយចំនួននៅមានកម្រិត និងបានអំពាវនាវផងដែរ ឱ្យមាននូវការចូលរួមជាសំណួរក្នុងវត្ថុវិស័យរបស់អង្គការ និងដើម្បីគុណភាពនៃការស្រាវជ្រាវរបស់ពួកគេ (មើល MTR)។

នៅកម្រិតក្រសួង ធនាគារពិភពលោកកំពុងព្យាយាមលើកទឹកចិត្តវប្បធម៌ការស្រាវជ្រាវរបស់កម្ពុជា និងលើកស្ទួយជំរុញសមត្ថភាពក្រសួងអប់រំយុវជននិងកីឡា ដើម្បីគ្រប់គ្រងពានរង្វាន់ តាមរយៈជំនួយមូលនិធិរបស់គម្រោងបង្កើនគុណភាពអប់រំជាន់ខ្ពស់ (HEQIP) ទោះបីជាយ៉ាងណាក៏ដោយ វាអាចសម្គាល់បានថាលទ្ធផលនៃគម្រោងនេះ គឺមិនត្រូវដឹកនាំឱ្យបានច្បាស់លាស់នៅក្នុងគោលនយោបាយ។ លទ្ធផលតម្រូវឱ្យទទួលបានរួមមានលទ្ធផលមួយបញ្ជាក់ដោយគ្រឹះស្ថានឧត្តមសិក្សាសម្រាប់ម្ចាស់ជំនួយបោះពុម្ពចំនួន ៤៥ច្បាប់សម្រាប់ក្រសួងអប់រំ យុវជន និងកីឡាដែលបានគាំទ្រគម្រោងស្រាវជ្រាវ ប្រារព្ធធ្វើពិធីមួយផ្តល់ពានរង្វាន់ដល់អ្នកស្រាវជ្រាវទាំងនេះ និងការបោះពុម្ពសិក្សា។ ទោះបីជាយ៉ាងណា ធនាគារពិភពលោក មានបំណងឱ្យក្រសួងអប់រំ យុវជន និងកីឡា ប្រើប្រាស់ជំនាញគ្រប់គ្រងរដ្ឋបាលដែលទទួលបានថ្មីរបស់ពួកគេដើម្បីផ្តល់ជំនួយស្រាវជ្រាវបន្ថែម ជាមួយនឹងការផ្តល់ប្រាក់ប្រចាំឆ្នាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ "កញ្ចប់ថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ឆ្នាំនេះគឺកំពុងត្រូវបានប្រើដោយក្រសួងអប់រំយុវជននិងកីឡា ដើម្បីត្រួតពិនិត្យឡើងវិញកម្មវិធីសិក្សាឱ្យបានទូលំទូលាយ ដែលមិនធ្លាប់បានធ្វើពីមុនដោយប្រជាជនកម្ពុជា មានតែភាគីអ្នកខាងក្រៅតែមួយគត់ (WB1)។

**ករណីសិក្សានៃការស្រាវជ្រាវដើម្បីអន្តរកម្មគោលនយោបាយ និងផលប៉ះពាល់លើការបង្កើតគោលនយោបាយ**

ជារួមបណ្ដាញទំនាក់ទំនងនឹងការស្រាវជ្រាវគោលនយោបាយគឺមានភាពទន់ខ្សោយ។ ទោះជាយ៉ាងណា ករណីរឿងដែលយើងបានគូសបញ្ជាក់ គឺវាជាការសំខាន់ ពីព្រោះពួកគេបញ្ជាក់យ៉ាងច្បាស់ថា ផលប៉ះពាល់គោលនយោបាយមិនមែនមកពីការស្រាវជ្រាវរបស់ខ្លួនវាផ្ទាល់នោះទេ ប៉ុន្តែមកពីការផ្សព្វផ្សាយរបស់វាផ្ទាល់។

អង្គការយុត្តិធម៌ដើម្បីកម្ពុជាបានផ្ដល់ករណីសិក្សាមួយនៃផលប៉ះពាល់នៃការស្រាវជ្រាវទៅលើការបង្កើតគោលនយោបាយ។ សហភាពអឺរ៉ុបបានប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវនេះ លើក្រុមហ៊ុន Vietnam Rubber Group (VRG) ដើម្បីដាក់ពាក្យប្ដឹងប្រឆាំងក្រុមហ៊ុន VRG នៅក្នុងប្រទេសកម្ពុជា និង នៅប្រទេសវៀតណាម។ សហភាពអឺរ៉ុប បានបង្កើតក្រុមស្រាវជ្រាវមួយអភិវឌ្ឍឱ្យដល់កំពូល វត្ថុបំណង លទ្ធផលដែលគួររំពឹងទុក និងវិធីសាស្ត្រ និងក្រមសីលធម៌នៃការស្រាវជ្រាវ អនុវត្តវិធីសាស្ត្រស្រាវជ្រាវដោយតាមរបៀប គុណភាព និងបរិមាណ និងការវិភាគធ្វើឡើងដោយប្រើកម្មវិធី SPSS បន្ទាប់មក ធ្វើសេចក្ដីព្រាងរបាយការណ៍ និងធ្វើបទបង្ហាញវាទៅភាគីពាក់ព័ន្ធនានា (បញ្ចូលទាំងអ្នកចូលរួមស្រាវជ្រាវតាមសហគមន៍) សម្រាប់ការពិនិត្យឡើងវិញ។ របាយការណ៍ចុងក្រោយ ត្រូវបានដាក់ជូនសម្រាប់ការវិភាគផ្នែកច្បាប់ និងបន្ទាប់មកដំណើរការប្ដឹងទៅប្រព័ន្ធតុលាការ (ក្នុងសំណុំរឿងប្រឆាំងក្រុមហ៊ុន VRG)។ អង្គការធ្វើការងារជាមួយនឹងមេធាវីដែលមានបទពិសោធន៍ក្នុងវិស័យស្រាវជ្រាវ ក្នុងការបញ្ជូនដាក់បញ្ចូលទៅក្នុងនីតិវិធីច្បាប់យ៉ាងមានប្រសិទ្ធភាព។ លទ្ធផលដ៏យូរអង្វែង ត្រូវបានដាក់សម្ពាធទៅលើក្រុមហ៊ុនឱ្យចូលមកតុចរចា និងការផ្ដល់សំណងយ៉ាងពេញទំហឹងដល់សហគមន៍។ ទាំងនេះបានក្លាយជាឧបករណ៍ក្នុងការកាត់បន្ថយការរំលោភបំពាន និងបញ្ហាទាក់ទងនឹងដីសម្បទានសេដ្ឋកិច្ច។

អង្គការខុមហ្វ្រែល បានធ្វើការស្រាវជ្រាវទៅលើស្ថិតិការបោះឆ្នោត វាជាប្រធានបទនយោបាយមួយដ៏រសើប។ ដើម្បីធ្វើការផ្សព្វផ្សាយការស្រាវជ្រាវរបស់គេ ពួកគេបានបើកសិក្ខាសាលាជាច្រើនដើម្បីជម្រាបដល់សាធារណជនភាគីដែលពាក់ព័ន្ធ និងម្ចាស់ជំនួយ ព្រមទាំងបោះពុម្ពរបាយការណ៍ដើម្បីចែកជូនដល់សាធារណជនទៀតតាមរយៈគេហទំព័ររបស់ខ្លួនផងដែរ។ ពួកគេក៏បានបង្កើតកម្មវិធីតាមវិទ្យុដើម្បីឃោសនាការស្រាវជ្រាវរបស់គេ និងបានអញ្ជើញអ្នកជំនាញដើម្បីផ្ដល់ជាយោបល់លើរបាយការណ៍ ហើយ "យើងនឹងអនុញ្ញាតឱ្យប្រជាពលរដ្ឋទូរស័ព្ទមក និងផ្ដល់ជាយោបល់ត្រឡប់មកវិញ" (Cam:B)។ ពួកគេ បានធ្វើ ការផ្ដល់អនុសាសន៍ជាច្រើនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (NEC) និងក្រុមម្ចាស់ជំនួយ (Cam:B) ។ ពួកគេកត់សម្គាល់ឃើញថា ពួកគេចាំបាច់ត្រូវគិតដល់ទំនាក់ទំនងសហប្រតិបត្តិការជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (NEC) គឺជា "ការចូលរួមនៃដំណើរការដ៏យូរអង្វែង" (Cam:B) ។ ពួកគេធ្លាប់ទទួលបានជោគជ័យមួយចំនួនរួចមក

ហើយ ពួកគេបានស្នើសុំឱ្យដាក់បញ្ជី ឈ្មោះអ្នកបោះឆ្នោតតាមប្រព័ន្ធអ៊ីនធើណិត ហើយបច្ចុប្បន្នគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានអនុវត្តតាមនូវអនុសាសន៍នេះ (Cam:A)។

អង្គការលីកាដូ ធ្វើការចូលរួមជាមួយប្រជាពលរដ្ឋសាធារណៈ អ្នកបង្កើតគោលនយោបាយ និងតួអង្គអន្តរជាតិ តាមមធ្យោបាយផ្សេងៗ។ មានករណីសិក្សាមួយ បានឈរជាបញ្ហាដែលមានទំនាក់ទំនងនឹងគោលនយោបាយយ៉ាងពិតប្រាកដ។ អង្គការលីកាដូបានបោះពុម្ពរបាយការណ៍ជាច្រើន ហើយបានរិះគន់យ៉ាងខ្លាំងចំពោះការអនុវត្តលើការអភិវឌ្ឍរបស់កម្ពុជា ច្បាប់ភូមិបាល និងការរំលោភបំពានសិទ្ធិមនុស្សនៅទូទាំងប្រទេសកម្ពុជា។ សម្ពាធនេះបានក្លាយជាឧបករណ៍មួយក្នុងការចេញផ្អាកបណ្តោះអាសន្ននូវដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋាភិបាល (ELC)។ "យើងបានចេញពាក្យបណ្តឹងរបស់យើងនៃការកើនឡើងបញ្ហាទំនាស់ដីធ្លី ចំណែកឯរដ្ឋាភិបាលបានព្យាយាមបង្ខូចនូវបញ្ជីឈ្មោះនោះ និងពួកគេមិនអាចទទួលយកបានទេ ពួកគេមិនអាចនិយាយថា យើងមានសិទ្ធិធ្វើអ្វីមួយជាសាធារណៈ... ប៉ុន្តែការងារដែលយើងបានធ្វើ ដីសម្បទានសេដ្ឋកិច្ចដែលនាំឱ្យមានការផ្អាកបណ្តោះអាសន្នលើដីសម្បទានសេដ្ឋកិច្ចកាលពីឆ្នាំ២០១២ នេះគឺជាផ្នែកមួយនៃការដាក់សម្ពាធដែលពួកគេបានប្រឈមមុខ"។ អង្គការលីកាដូមិនកំណត់ទិសដៅចំពោះអ្នកបង្កើតគោលនយោបាយដោយផ្ទាល់ទេ ប៉ុន្តែព្យាយាមធ្វើឱ្យមានឥទ្ធិពលលើពួកគេតាមរយៈការដាក់សម្ពាធដែលការងាររបស់ពួកគេបង្កើតឡើងក្នុងទីវាលសាធារណៈ និងឆាកអន្តរជាតិ។

ធនាគារពិភពលោកបានផ្លាស់ប្តូរគោលនយោបាយដោយផ្ទាល់ បន្ទាប់ពីបានធ្វើការស្ទាបស្ទង់មតិនៅកម្រិតគ្រួសារ ដែលបានរកឃើញថា ៩០%នៃនិស្សិតសាកលវិទ្យាល័យនាពេលបច្ចុប្បន្ន គឺមកពីសង្គមគ្រួសារដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ធនាគារពិភពលោកបានផ្តល់ជាអនុសាសន៍ថា អាហារូបករណ៍នាពេលបច្ចុប្បន្នបានផ្តល់ជូនដោយក្រសួងអប់រំ យុវជន និងកីឡាតាមរយៈសាកលវិទ្យាល័យមួយចំនួន គួរតែបូករួមបញ្ចូលប្រាក់ឧបត្ថម្ភសម្រាប់ការរស់នៅ ក៏ដូចជាការលើកលែងថ្លៃឈ្នួលសាលាផងដែរ។ ក្រសួងគឺនៅតែបន្តគម្រោងសាកល្បងនេះ ដើម្បីមើលពីរបៀបប្រព័ន្ធអាហារូបករណ៍ដែលបានកែសម្រួល មានផលប៉ះពាល់យ៉ាងណាទៅលើការអនុវត្តការសិក្សាអប់រំ និងទិន្នផលនៃទីផ្សារពលកម្ម ក្នុងចំណោមសិស្ស និស្សិតដែលមានប្រាក់ចំណូលទាប។ ដំណាក់កាលបន្ទាប់ ពួកគេនឹងវាយតម្លៃឥទ្ធិពលផលប៉ះពាល់នៃការអប់រំកម្រិតខ្ពស់សម្រាប់សិស្សនៅតាមជនបទ ដើម្បីមើលថាតើឥទ្ធិពលនេះមានយ៉ាងណាទៅលើពលរដ្ឋក្នុងភូមិ និងក្រុមគ្រួសារ (WB1)។

ករណីសិក្សាទាំងនេះបានគូសបញ្ជាក់ផ្លូវដ៏មានអានុភាពពីការស្រូបយកគោលនយោបាយមួយជាការប្រឆាំងជំទាស់ និងមួយទៀតជាកេមរតក (patrimonial)។ ធនាគារពិភពលោក និងម្ចាស់ជំនួយធំៗក្នុងប្រទេសកម្ពុជាអាចមានផលប៉ះពាល់ដោយផ្ទាល់តាមរយៈការផ្សព្វផ្សាយ (patrimonial)នេះនៃគោលបំណងការប្រើប្រាស់ផ្នែកហិរញ្ញវត្ថុ ដែលពួកគេផ្តល់ទៅឱ្យក្រសួង

រដ្ឋាភិបាល និងរដ្ឋមន្ត្រី។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានជ្រៀតចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម ថ្នាក់ជាតិ និងអន្តរជាតិ ដោយប្រើប្រាស់លទ្ធផលស្រាវជ្រាវរបស់ពួកគេ ដើម្បីដាក់សម្ពាធគាបសង្កត់ទៅលើក្រុមអ្នកបង្កើតគោលនយោបាយ និងស្ថាប័នមួយចំនួន។

**សេចក្តីបញ្ចប់**

ការផ្សព្វផ្សាយគឺជាធាតុផ្សំដ៏សំខាន់នៃការសិក្សាស្រាវជ្រាវដើម្បីស្រូបយកគោលនយោបាយដ៏មានប្រសិទ្ធភាព។ នេះជាការគូសបញ្ជាក់មួយផ្សេងទៀតមួយក្នុងចំណោមអនុសាសន៍សំខាន់ៗនៃរបាយការណ៍នេះ។ ការសិក្សាស្រាវជ្រាវមិនគួរត្រូវបានបិទទ្វារលើការចំណាយក្នុងបណ្ណសារមួយលើកៗទេ។ មិនត្រឹមតែពួកគេមិនទាន់អាចប្រើប្រាស់ក្រុមអ្នកស្រាវជ្រាវក្នុងការអភិវឌ្ឍប្រទេសបានប៉ុណ្ណោះទេ ថែមទាំងពួកគេមិនអាចប្រើប្រាស់ក្រុមអ្នកបង្កើតគោលនយោបាយផងដែរ។ លទ្ធផលរកឃើញដែលបានដាក់ចេញក្នុងផ្នែកនេះបានផ្តល់យោបល់ថា អ្នកបង្កើតគោលនយោបាយ ជួនកាលស្រាវជ្រាវតាមចិត្តចង់ដើម្បីជូនដំណឹងដល់ការសម្រេចចិត្តរបស់គេ ប៉ុន្តែវាមិនមែនតែងតែអាចរកបានដោយស្រួលនោះទេ។ ប្រទេសកម្ពុជាបង្ហាញទំនាក់ទំនងយ៉ាងរឹងមាំរវាងស្ថាប័នស្រាវជ្រាវ និង តួអង្គអន្តរជាតិ ជាពិសេសការរីកលូតលាស់ និងរឹងមាំនៅកម្រិតថ្នាក់សាកលវិទ្យាល័យ។ ទំនាក់ទំនងដ៏ទូលំទូលាយនេះ នឹងអាចជួយឱ្យមានឥទ្ធិពលនយោបាយប្រទេសកម្ពុជា ដូចជាអ្នកសិក្សាស្រាវជ្រាវមួយចំនួនដែលជាមន្ត្រីរដ្ឋាភិបាល និងធ្វើឱ្យមានទំនាក់ទំនងឆ្លងព្រំដែនប្រជាជាតិផងដែរ។

គម្រោងនេះគឺមានលក្ខណៈជាប្រព័ន្ធដំបូងគេ ដែលព្យាយាមតភ្ជាប់តួអង្គបី មានដូចជារដ្ឋាភិបាល សង្គមស៊ីវិល និងគ្រឹះស្ថានឧត្តមសិក្សា ក្នុងសហគមន៍ស្រាវជ្រាវតាមរយៈវេទិកាអន្តរកម្មដែលផ្តោតទៅលើការកសាងសមត្ថភាព។ ពីព្រោះតែបញ្ហានេះហើយ គម្រោងនេះមានអានុភាពដើម្បីបង្កើតនូវគម្រោងថ្មីៗមួយចំនួនទៀត នឹងសហការគ្នាឧបត្ថម្ភគាំទ្រ ព្រមទាំងជំរុញឱ្យមានការស្រាវជ្រាវដែលផុសចេញពីផ្ទៃក្នុង។ សំឡេងនីមួយៗនៃតួអង្គទាំងបីគឺត្រូវបានគេយកមកពិចារណា និងអនុញ្ញាតឱ្យពួកគេបង្កើនការយល់ដឹងឱ្យគ្នាទៅវិញទៅមក។គម្រោងនេះស្វែងរកដើម្បីបង្ហាញពីភាពប្រឈម និងការកសាងដ៏មានសក្តានុពលឱ្យកាន់តែមានភាពប្រសើរឡើងលើសមត្ថភាពស្រាវជ្រាវក្នុងសង្គមវិទ្យាសាស្ត្រ ខណៈដែលការផ្តល់សិទ្ធិអំណាចដល់តួអង្គទាំងអស់ ដែលបានចូលរួមពាក់ព័ន្ធ។ យើងបានផ្តល់អនុសាសន៍ សូមបង្កើនការគាំទ្រពីរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយឱ្យមានភាពប្រសើរឡើង និងបង្កើតការផ្លាស់ប្តូរនីតិវិធី និងវប្បធម៌ ដែលចាំបាច់ក្នុងការបង្កើនការសង្កត់ធ្ងន់ទៅលើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ យើងក៏បានផ្តល់អនុសាសន៍ដល់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បង្កើនកិច្ចប្រឹងប្រែងរបស់ពួកគេក្នុងសកម្មភាពវិមជ្ឈការ និងបង្កើនការចូលរួមជាមួយឧត្តមសិក្សា។ ពួកគេអាចធ្វើឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមកម្លាំងគ្នាបន្ថែមជាងនេះទៀតដើម្បីជំរុញឱ្យមានការស្រាវជ្រាវវិទ្យាសាស្ត្រសង្គម។ ជារួម ការស្រាវជ្រាវក្នុងប្រទេសកម្ពុជាចាំបាច់ត្រូវតែផ្លាស់ទីទៅឆ្ងាយ

ពីការត្រួតពិនិត្យតាមដានមិនចេះចប់មិនចេះហើយលើការគាំទ្រពីខាងក្រៅនៃម្ចាស់ជំនួយ។ ដើម្បីទទួលបានជោគជ័យការងារទាំងនេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវតែផ្លាស់ទីទៅឆ្ងាយពីទម្រង់ម៉ូដនៃឈ្មួលសិក្សាអតិបរមា និងដាក់ការសង្កត់ធ្ងន់បន្ថែមលើការប្រកួតប្រជែងគ្នាតាមរយៈការអភិវឌ្ឍការស្រាវជ្រាវរបស់មនុស្ស។

## ៩. អនុសាសន៍ពីអ្នកចូលរួមរបស់យើង

អ្នកចូលរួមផ្តល់បទសម្ភាសន៍ និងស្ទាបស្ទង់មតិទាំងអស់ ត្រូវបានស្នើសុំឱ្យផ្តល់ជាអនុសាសន៍ ដើម្បីកែលម្អបរិយាកាសស្រាវជ្រាវក្នុងប្រទេសកម្ពុជា។ សរុបជារួមមក ភាគច្រើននៃការផ្តល់អនុសាសន៍ អាចបែងចែកជាបីប្រភេទធំៗ។ ប្រភេទទីមួយគឺផ្តោតទៅលើសកម្មភាពដោយរដ្ឋ ទីពីរសកម្មភាពដោយ សាកលវិទ្យាល័យ និងទីបីគឺដោយអង្គការសង្គមស៊ីវិល។

**សកម្មភាពដោយរដ្ឋ៖** រដ្ឋអាចដើរតួនាទីក្នុងការបង្កើតស្តង់ដារស្រាវជ្រាវ បង្កើតចំណាត់ថ្នាក់ តម្រូវការ សម្រាប់ផលិតផលស្រាវជ្រាវនៅកម្រិតសាកលវិទ្យាល័យ និងផ្តល់បទពិសោធន៍ការស្រាវជ្រាវនៅកម្រិត បឋមសិក្សា និងអនុវិទ្យាល័យ។ លើសពីនេះទៀត ពួកគេអាចផ្តល់ធនធានហិរញ្ញវត្ថុកាន់តែច្រើនតាម រយៈការប្រកួតប្រជែងហិរញ្ញវត្ថុរបស់ជាតិ។

**សកម្មភាពដោយសាកលវិទ្យាល័យ៖** សាកលវិទ្យាល័យអាចជំរុញការស្រាវជ្រាវតាមរយៈមានតួនាទីមុខ ងារស្រាវជ្រាវពេញម៉ោងជាវិជ្ជាជីវៈ ផ្តល់ជាហិរញ្ញវត្ថុ និងពួកគេអាចលើកទឹកចិត្តឱ្យមានកិច្ចសហ ប្រតិបត្តិការក្នុងក្របខ័ណ្ឌរវាងសាកលវិទ្យាល័យដូចគ្នា និងជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្រុមអ្នក ជំនួញជាមួយភ្នាក់ងាររដ្ឋាភិបាល។ សាកលវិទ្យាល័យអាចផ្តល់ឱកាសរៀនសូត្របន្ថែមសម្រាប់អ្នក ស្រាវជ្រាវដូចជា វគ្គសិក្សា សន្និសីទ សិក្ខាសាលា ជំនួយដល់ទម្រង់នៃរបៀបស្រាវជ្រាវ និងការវិភាគជា ភាសាអង់គ្លេស។ ពួកគេអាចកំណត់គោលការណ៍ដែលល្អប្រសើរជាងមុនសម្រាប់ការផ្សព្វផ្សាយនូវ ព័ត៌មានទាក់ទងទៅនឹងសកម្មភាពរបស់ពួកគេផ្ទាល់។

**សកម្មភាពដោយអង្គការមិនមែនរដ្ឋាភិបាល៖** អង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់ការបណ្តុះបណ្តាល ដល់បុគ្គលិកដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើអ្នកប្រឹក្សាយោបល់ខាងក្រៅ។ អង្គការមិនមែន រដ្ឋាភិបាលអាចបង្កើនគុណភាពនៃបណ្តាញទំនាក់ទំនងរបស់ពួកគេ ដើម្បីទទួលបានលទ្ធផលកាន់តែ ល្អប្រសើរក្នុងការស្រូបយកនូវគោលនយោបាយ បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអប់រំជាន់ ខ្ពស់កាន់តែខ្លាំងឡើង (ងាកមករកការប្រកួតប្រជែងសម្រាប់ធនធានមនុស្សចូលក្នុងកិច្ចសហការ បណ្តុះបណ្តាលនៃធនធានមនុស្ស)។ អង្គការក្រៅរដ្ឋាភិបាលគួរតែមានបំណងឆ្ពោះសំដៅរកការកាត់ បន្ថយពីម្ចាស់ជំនួយ ជំរុញនិយមន័យនៃឧបករណ៍ប្រើប្រាស់ការស្រាវជ្រាវ និងពង្រីកការសហការ ជាមួយភ្នាក់ងាររដ្ឋាភិបាលឱ្យមានតុល្យភាពនឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើការងារធម្មតា វិភាគ រិះគន់លើគោលការណ៍នយោបាយ។

ភាពតានតឹងមួយចំនួននៅទីនេះ គឺជាភ័ស្តុតាងយ៉ាងច្បាស់នៅក្នុងការយល់ឃើញរបស់ ប្រជាពលរដ្ឋពីតួនាទីដ៏សំខាន់ៗនៃតួអង្គទាំងបីទាំងនេះ។ ឧទាហរណ៍ គុណប្រយោជន៍នៃការស្រាវជ្រាវ ការតស៊ូមតិរបស់អង្គការមិនមែនរដ្ឋាភិបាល ធៀបនឹងការស្រាវជ្រាវបែបសិក្សា និងវិសាលភាពដែល

អង្គការមិនមែនរដ្ឋាភិបាលមានជាមួយនឹងសាកលវិទ្យាល័យនានា គួរតែត្រូវបានការសហការ ជាមួយនឹងរដ្ឋាភិបាល ឬរក្សាឱ្យបាននូវឯករាជភាព។ ដូចគ្នានេះផងដែរ ភាពតានតឹងមួយកើតមានរវាងផ្នត់គំនិតលើតួនាទីរដ្ឋាភិបាលគួរតែធ្វើ ប្រជាពលរដ្ឋដែលបានសម្តែងមតិ ទាំងការពេញចិត្តទៅលើតួនាទីរបស់រដ្ឋសម្រាប់ការគាំទ្រ និងការលើកទឹកចិត្តដល់ការស្រាវជ្រាវ ឬក៏រដ្ឋចូលរួមតិចជាងនេះក៏ដោយ ក៏កើតចេញពីការយកចិត្តទុកដាក់ដែលថា ការស្រាវជ្រាវគឺត្រូវបានក្លាយជាគោលនយោបាយរួចជាស្រេចទៅហើយ។ ភាពតានតឹងនេះផ្តល់ផលប៉ះពាល់ដល់បំណងប្រាថ្នាសម្រាប់ចង់ឱ្យមានស្តង់ដារជាតិមួយនៃក្រមសីលធម៌ស្រាវជ្រាវដែលបានផ្តល់ឱ្យ ដែលថា ស្តង់ដារមួយនឹងតម្រូវឱ្យមានសេចក្តីព្រាងនៃប្រធានបទដែលត្រូវហាមឃាត់ និងវិធីសាស្ត្រមួយចំនួនទៀត។

សេចក្តីព្រាងមួយនៃប្រធានបទសំខាន់ៗមួយចំនួន ដែលបានរួមបញ្ចូលគ្នាមកពីការស្រាវជ្រាវ គឺនឹងផ្តល់សេចក្តីលម្អិតបន្ថែមនៅផ្នែកខាងក្រោម។

**ការលើកទឹកចិត្តលើការស្រាវជ្រាវ**

ការលើកទឹកចិត្ត ត្រូវបានស្នើដោយអ្នកផ្តល់បទសម្ភាសន៍ រួមមាន ថវិកា ពេលវេលា ការជំនួយ និងសម្ភារៈជាច្រើនទៀតដូចជា ការកែលម្អសម្ភារៈក្នុងបណ្ណាល័យ និងក្នុងការិយាល័យ (ម៉ាស៊ីនត្រជាក់ និងប្រព័ន្ធអ៊ីនធើណិត)។ អនុសាសន៍ជាទូទៅ ភាគច្រើនគឺចង់ឱ្យពង្រឹងតួនាទីវិជ្ជាជីវៈស្រាវជ្រាវដោយការផ្តល់ប្រាក់បៀវត្សរ៍ ប្រសើរជាងប្រាក់ឈ្នួលការបង្រៀនជំនួយ (HEI:1, UBB:DR) និងធនធានហិរញ្ញវត្ថុកាន់តែប្រសើរ ក្នុងការលះបង់ដើម្បីការសិក្សាស្រាវជ្រាវ ទាំងតាមរយៈមូលនិធិស្រាវជ្រាវជាតិ (USEA:VPR) និងតាមរយៈជំនួយរបស់សាកលវិទ្យាល័យ (RULE:Dean1; DH) ដើម្បីធានាបាននូវហិរញ្ញវត្ថុ និងបង្កើតគុណភាពការស្រាវជ្រាវ។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ មានការយល់ស្របគ្នាលើការបង្កើតវប្បធម៌ស្រាវជ្រាវមួយ ប៉ុន្តែមានភាពផ្ទុយគ្នាចំពោះអ្នកដែលគួរតែទទួលខុសត្រូវចំពោះការងារទាំងនោះ។

អ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ពីតម្រូវការមួយសម្រាប់ការបង្កើនថវិការដ្ឋសម្រាប់ការស្រាវជ្រាវ ហើយតភ្ជាប់ការងារនេះ ជាមួយនឹងអត្ថប្រយោជន៍នៃការស្រាវជ្រាវដើម្បីការអភិវឌ្ឍជាតិ។ ការគាំទ្រផ្នែកស្រាវជ្រាវរដ្ឋរបស់កម្ពុជា មិនស័ក្តិសមនឹងប្រៀបធៀបទៅប្រទេសថៃបានទេ "ក្នុងប្រទេសថៃ ពួកគេបានប្រើ ៤% នៃផលិតផលក្នុងស្រុកសរុប (GDP) ដើម្បីចំណាយលើការស្រាវជ្រាវ ប៉ុន្តែពួកគេទទួលបានលទ្ធផលត្រឡប់មកវិញយ៉ាងខ្ពស់ និងផលិតផលក្នុងស្រុកសរុបរបស់ពួកគេបានកើនឡើងលើសពី ៤%" (USEA;F1)។ អ្នកស្រាវជ្រាវរបស់ USEA ម្នាក់ មានគំនិតស្រដៀងគ្នាដែលថា "រដ្ឋាភិបាលកម្ពុជាមិនគួរពឹងផ្អែកលើមូលនិធិបរទេសសម្រាប់ធ្វើការស្រាវជ្រាវនោះទេ [ពីព្រោះ]... ការស្រាវជ្រាវ គឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍ បើគ្មានការស្រាវជ្រាវ ក៏គ្មានការអភិវឌ្ឍដែរ" (USEA:VPR)។ អ្នកផ្តល់បទសម្ភាសន៍ជាច្រើននៅតាមខេត្តក៏យល់ដូច្នេះផងដែរថា

មូលនិធិរបស់រដ្ឋាភិបាលត្រូវបានផ្តោតការយកចិត្តទុកដាក់តែស្ថាប័នក្នុងក្រុងភ្នំពេញ និងថវិកាបន្ថែមគួរត្រូវបានត្រៀមទុកសម្រាប់សាកលវិទ្យាល័យថ្នាក់ខេត្ត (MCU:Dean1)។

អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវបានឱ្យដឹងផងដែរថា សាកលវិទ្យាល័យត្រូវការដើរតួនាទីមួយ រួមជាមួយនឹងរដ្ឋក្នុងការលើកទឹកចិត្តការអភិវឌ្ឍការស្រាវជ្រាវ។ សាកលវិទ្យាធិការម្នាក់បាននិយាយដោយសង្ខេបថា "គ្រប់សាកលវិទ្យាល័យទាំងអស់ គួរតែបង្កើតនូវកញ្ចប់ថវិកាមួយសម្រាប់សកម្មភាពស្រាវជ្រាវ រាប់បញ្ចូលទាំងថវិកាសម្រាប់ការបង្រៀនជំនាញស្រាវជ្រាវ វគ្គបណ្តុះបណ្តាលស្រាវជ្រាវ និងការបោះពុម្ពលើក្រដាសដើម្បីការបង្កើតនូវវប្បធម៌ស្រាវជ្រាវមួយ។ បន្ថែមលើសពីនេះទៀត សាកលវិទ្យាល័យគួរតែព្យាយាមទទួលយកឱកាសដើម្បីធ្វើការស្រាវជ្រាវឱ្យបានច្រើនតាមតែពួកគេអាចធ្វើទៅបាន (USEA:VPR; also RULE:Dean1;DH)។

ព្រឹទ្ធបុរសសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាម្នាក់បានស្នើលើកឡើងថា អាជីវកម្មរបស់អ្នកមាន គួរតែផ្តល់ប្រាក់ឧបត្ថម្ភដល់ការស្រាវជ្រាវ ហើយការអនុវត្តនេះ គួរនឹងត្រូវបានលើកទឹកចិត្តលើសពីនេះ ទៀតដោយរដ្ឋាភិបាល។ គាត់បានលើកឡើងថា តម្រូវការរបស់រដ្ឋាភិបាល និងវិស័យឯកជនដើម្បី"នាំមកនូវ ការលើកកម្ពស់កម្រិតស្មារតី នៃវប្បធម៌ស្រាវជ្រាវមួយ" (PUC:D1) រួមបញ្ចូលទាំង "ការធ្វើឱ្យពួកគេបាន យល់ពីតម្លៃ និងសារៈសំខាន់នៃការចែករំលែកត្រឡប់មកវិញដល់សហគមន៍ ពីព្រោះពួកគេកំពុងតែបង្កើត ប្រាក់ចំណេញពីសហគមន៍" ដើម្បីកសាង "ស្មារតីនៃការយកចិត្តទុកដាក់"។ អ្នកស្រាវជ្រាវសាកលវិទ្យាល័យ បាត់ដំបងម្នាក់បាននិយាយប្រហាក់ប្រហែលគ្នាដែរថា "វាគួរតែមាន ការផ្ទេរនូវបច្ចេកវិទ្យាមួយ ដោយមានកិច្ចសហការជាមួយក្រុមហ៊ុនឯកជន សម្រាប់រក្សានិរន្តរភាព និងការអភិវឌ្ឍយូរអង្វែងនៃការ ស្រាវជ្រាវ" (UBB-FR1)។ កើតចេញពីទស្សនៈនេះ ទោះបីជារដ្ឋមានការកំណត់មូលដ្ឋានគ្រឹះជាមួយនឹងក្របខ័ណ្ឌគោលនយោបាយ និងមូលនិធិសមស្រប និរន្តរភាពនៃការស្រាវជ្រាវគឺត្រូវបានរកឃើញតាមរយៈកិច្ចសហប្រតិបត្តិការជាមួយអ្នកដើរតួនៅលើទីផ្សារ។

អ្នកចូលរួមស្រាវជ្រាវជាច្រើនយល់ឃើញថា មានរបស់សំខាន់ពីរដែលត្រូវនឹងដោះដូរជំនួសដើម្បីលើកទឹកចិត្តក្រុមអ្នកស្រាវជ្រាវគឺ ពេលវេលានិងថវិកា។ ព្រឹទ្ធបុរសសាកលវិទ្យាល័យមួយរូបបានលើកឡើងបន្ទរដល់អ្នកផ្សេងៗទៀត ខណៈពេលដែលគាត់កត់សម្គាល់ឃើញថា យើងត្រូវការបង្កើនជំនួយសម្រាប់ការស្រាវជ្រាវ" គ្មានការចំណាយថវិកា គ្មានការស្រាវជ្រាវ.....ការលើកទឹកចិត្តគឺមានតែប្រាក់ឧបត្ថម្ភ" (NUM:DR)ខណៈពេលដែលអ្នកដទៃទៀត បានកត់សម្គាល់ថា ភាពចាំបាច់សម្រាប់ការកាត់បន្ថយក្នុងការបង្រៀន និងកាតព្វកិច្ចរដ្ឋបាល៖ "ប្រាក់ខែគួរតែត្រូវបានដំឡើងដើម្បីបំពេញតម្រូវការរបស់គ្រូបណ្តុះបណ្តាល ដូច្នេះពួកគេអាចកាត់បន្ថយម៉ោងបង្រៀនរបស់ពួកគេ ដើម្បីធ្វើការស្រាវជ្រាវ" (USEA:F3)។ អនុសាសន៍របស់ពួកយើងផ្ទាល់ដែលជាមន្ត្រីសាកលវិទ្យាល័យ បានថ្លែង

ផងដែរថា ការផ្តល់អាហារូបករណ៍សម្រាប់សិស្សបញ្ចប់ការសិក្សាស្រាវជ្រាវ វាជារឿងសំខាន់ណាស់ (UBB:FR2)។

អ្នកជំនាញជាន់ខ្ពស់មួយចំនួនកត់សម្គាល់ថា មានការបែងចែកវិស័យសាធារណៈឯកជន ក្នុងក្របខ័ណ្ឌសាកលវិទ្យាល័យ ជាមួយនឹងសាកលវិទ្យាល័យឯកជន ហ៊ានចំណាយប្រាក់ខែកាន់តែខ្ពស់សម្រាប់គ្រូបង្រៀន ប៉ុន្តែផ្តោតការយកចិត្តទុកដាក់លើសក្តានុពលដែលទទួលបានពីការបង្រៀនជាជាងការស្រាវជ្រាវ ចំណែកឯសាកលវិទ្យាល័យសាធារណៈ មើលឃើញយ៉ាងច្បាស់ពីការទទួលបានផលប្រយោជន៍ពីការស្រាវជ្រាវ ប៉ុន្តែជាមួយនឹងធនធានតិចតួចសម្រាប់ប្រាក់ខែគ្រូបង្រៀន។ បន្ថែមជាងនេះទៀត ទោះបីជាមានការផ្សព្វផ្សាយចង្អុលបង្ហាញថា របាំងហាមឃាត់នៃអ្នកស្រាវភាគច្រើនគឺដោយសារតែមានកង្វះខាតការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់អ្នកស្រាវជ្រាវម្នាក់ៗគួរកត់សម្គាល់ថា អ្នកស្រាវជ្រាវមួយចំនួនគួរតែធ្វើគម្រោងសេវាកម្មមួយ (សប្បុរសធម៌) គឺត្រូវបាននិយាយម្តងហើយម្តងទៀតដោយអ្នកឆ្លើយតបលើកដំបូងនៅស្ថាប័នឯកជន។

**ការបង្កើនឱកាសក្នុងការទទួលបានពីឃ្លាំងផ្ទុកទិន្នន័យ អក្សរសិល្ប៍ និងឯកសារ សិក្សាស្រាវជ្រាវ**

មតិមួយដែលបានផ្តល់ក្នុងការធ្វើបទសម្ភាសន៍ដើម្បីដោះស្រាយបញ្ហាដើម្បីទទួលបានព័ត៌មានគឺត្រូវតែបង្កើតបណ្តាញឃ្លាំងផ្ទុកទិន្នន័យថ្នាក់ជាតិតាមរយៈអ៊ីនធើណិតដែលរួមបញ្ចូលទាំងឃ្លាំងផ្ទុកទិន្នន័យ និងវេទិកាសម្រាប់គម្រោងសិក្សាស្រាវជ្រាវថ្នាក់ជាតិដើម្បីចែករំលែកលទ្ធផល។ គន្លឹះក្នុងការធានាឱ្យបាននូវការទទួលបានសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងដើម្បីជំរុញការប្រើប្រាស់សេចក្តីសង្ខេបដើម្បីតម្រង់ទិសផែនការសិក្សាស្រាវជ្រាវ (Z:F)។ ប្រធានផ្នែកសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌល DC-Cam បានបង្ហាញចំណាប់អារម្មណ៍ថា សាកលវិទ្យាល័យគួរតែបង្កើតបណ្ណាល័យធំៗ (DCCAM:DR) និងនិស្សិតបានបន្ថែមថា គម្រោងសិក្សាស្រាវជ្រាវគួរតែមានគេហទំព័រដែលអនុញ្ញាតឱ្យធ្វើការទាញយកឯកសារសិក្សាស្រាវជ្រាវដោយមិនគិតថ្លៃ (RULE:SRT)។ អ្នកចូលរួមធ្វើបទសម្ភាសន៍ពីសាកលវិទ្យាល័យជាតិគ្រប់គ្រងបានបញ្ជាក់ថា ការទទួលបានធនធានតាមបណ្តាញអ៊ីនធើណិត (NUM:Dean1) បណ្ណាល័យតាមប្រព័ន្ធអ៊ីនធើណិត (NUM:SRT) និងការវិនិយោគទុនថវិកាបន្ថែមដើម្បីផ្តល់ការទទួលបានពីឃ្លាំងផ្ទុកទិន្នន័យ (NUM:SRT) នឹងជួយបង្កើនការសហការគ្នា និងបណ្តាញទំនាក់ទំនងរវាងអ្នកសិក្សាស្រាវជ្រាវ (ទោះបីជាពួកគេមិនអាចបង្ហាញពីរបៀបដែលអាចជួយទៅដល់ការសហការគ្នារវាងអ្នកសិក្សាស្រាវជ្រាវ និងបង្កើតការជួយជ្រោមជ្រែងរវាងដៃគូ)។

ក្នុងពេលដែលមានតម្រូវការនូវបណ្ណាល័យល្អ និងធនធានឃ្លាំងផ្ទុកទិន្នន័យ ការផ្លាស់ប្តូរផ្នែកច្បាប់ក៏មានសារៈសំខាន់ក្នុងផ្តល់នូវការយល់ដឹងដល់ក្រសួង និងភ្នាក់ងាររដ្ឋាភិបាលពីកាតព្វកិច្ចដើម្បីបម្រើសាធារណជន ដោយផ្តល់នូវព័ត៌មានក្នុងពេលមានសំណើដែលទាក់ទងនឹងផ្នែកនៃសកម្មភាព

របស់ពួកគាត់។ អង្គភាពរដ្ឋាភិបាល អ្នកគាំពារអង្គការសង្គមស៊ីវិល បញ្ញវន្ត និងអ្នកសិក្សាស្រាវជ្រាវលើវិស័យឯកជនបានគូសបញ្ជាក់ពីបញ្ហាចម្បងដែលកើតឡើងមកពីការកង្វះខាតព័ត៌មានពីរដ្ឋាភិបាល (ទាំងដោយសារភ្នាក់ងាររដ្ឋមិនមានព័ត៌មានទាំងនោះ ឬពួកគាត់មិនចង់ផ្តល់ឱ្យ) ព្រមទាំងការពិបាកក្នុងការទទួលបានព័ត៌មានពីពាណិជ្ជកម្មឯកជន (SRU:F2,F3; RUPPIFL;SRT)។ យន្តការទាំងស្រុងក្នុងកិច្ចខិតខំប្រឹងប្រែងពីអ្នកចូលរួមសិក្សាស្រាវជ្រាវដើម្បីប្រមូល និងចែករំលែកព័ត៌មានអំពីបញ្ហា និងព្រឹត្តិការណ៍នៅក្នុងប្រទេសកម្ពុជាគឺត្រូវបានរាំងដោយស្ថានភាពនេះ និងកង្វះខាតឆន្ទៈនយោបាយក្នុងការផ្លាស់ប្តូរ។

**ការពង្រឹងកិច្ចសហការ**

"ខ្ញុំគិតថាសហប្រតិបត្តិការ និងការសហការគ្នានៅច្រើនថ្នាក់ក្នុងចំណោមអ្នកពាក់ព័ន្ធនានា រួមបញ្ចូលទាំងរដ្ឋាភិបាល វិស័យមិនមែនរដ្ឋាភិបាល ឧស្សាហកម្ម និងគ្រឹះស្ថានឧត្តមសិក្សា គួរតែបង្កើតឡើង។ (HU:S)។

អ្នកចូលរួមក្នុងការធ្វើបទសម្ភាសន៍បានស្នើសុំឱ្យមានការផ្តល់ដំបូន្មាន និងការសហការគ្នាជាច្រើនប្រភេទ រួមទាំងការជួយជ្រោមជ្រែងពីដៃគូពីអ្នកសិក្សាស្រាវជ្រាវដែលមានបទពិសោធន៍ ការផ្តល់ដំបូន្មានដល់និស្សិត ការសហការគ្នារវាងសាកលវិទ្យាល័យ និងការសហការគ្នារវាងអង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងាររដ្ឋ និងអ្នកសិក្សាស្រាវជ្រាវបរទេស។ ការជួយជ្រោមជ្រែងពីដៃគូត្រូវបានអ្នកឆ្លើយតបផ្តល់និយមន័យ ថាជាស្ថានភាពដែលអ្នកសិក្សាស្រាវជ្រាវដែលមានបទពិសោធន៍ រួមបញ្ចូលទាំងអ្នកដែលបានសិក្សានៅបរទេសនៅស្ថាប័នសិក្សាស្រាវជ្រាវថ្នាក់ខ្ពស់សហការជាមួយអ្នកសិក្សាស្រាវជ្រាវថ្នាក់តូចដើម្បីជំរុញកម្មវិធីសិក្សាស្រាវជ្រាវរបស់ពួកគេ។ នេះមានសារៈសំខាន់ដែលថា ទំនាក់ទំនងបែបនេះជាការផ្តល់ដំបូន្មានតាមរយៈការសួរសំណួរ ជាជាងប្រាប់ពួកគេក្នុងការធ្វើការសិក្សាស្រាវជ្រាវ។ វិធីសាស្រ្តចូលរួមបែបនេះអាចបន្ថែមគ្រឿងលើកទឹកចិត្តដល់និស្សិត និងផ្តល់ឱ្យពួកគេនូវអារម្មណ៍ពីការវិនិយោគទុនផ្ទាល់ខ្លួនក្នុងដំណើរការសិក្សា និងលទ្ធផលគម្រោង។ ឱកាសសម្រាប់ការជួយជ្រោមជ្រែងពីដៃគូត្រូវបានផ្សាភ្ជាប់ជាមួយនឹងសកម្មភាពសិក្ខាសិលា/ សន្និសីទ និងបង្កើនកន្លែងក្នុងការបោះពុម្ពផ្សាយ ព្រមទាំងចែករំលែកនូវលទ្ធផលសិក្សាស្រាវជ្រាវ។ ការជួយជ្រោមជ្រែងពីដៃគូ និងការចាប់ដៃគូសហការគ្នារយៈពេលវែង មានការចំបាច់សម្រាប់រដ្ឋាភិបាល គ្រឹះស្ថានអប់រំ សង្គមស៊ីវិល និងវិស័យឯកជន ទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

**ការសហការគ្នាតាមសាកលវិទ្យាល័យ**

អ្នកពាក់ព័ន្ធមួយចំនួន និងនិស្សិតបានស្នើថាការសហការសិក្សាស្រាវជ្រាវមានការចាំបាច់តាមសាកលវិទ្យាល័យ និងក្រសួង (អនុប្រធានកិច្ចការនិស្សិត PUC;RUPP:SRT; RUPP:DH) គ្រប់ស្ថាប័នទាំងអស់ ត្រូវតែធ្វើការជាមួយគ្នា "ពួកគេនិយាយថាពួកគេចូលចិត្តសហការ ប៉ុន្តែពួកគេប្រកួតប្រជែង"

(UBB:DR)។ ប្រធាននៃសាកលវិទ្យាល័យបាត់ដំបងបានប្រាប់នូវរឿងដ៏អាក្រក់មួយពីសាកលវិទ្យាល័យដែលប្រកួតប្រជែងនិយាយបង្ខូចចរិតរបស់និស្សិតសាកលវិទ្យាល័យបាត់ដំបង (UBB:PR)។ ភ័ស្តុតាងនេះបង្ហាញថា ខណៈទម្រង់នៃការសហការនៅក្នុងស្ថាប័នត្រូវបាននិងកំពុងបង្កើតនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន ការសហការគ្នារវាងគ្រឹះស្ថានឧត្តមសិក្សាមិនមាននៅឡើយ។ ប្រវត្តិនៃការមិនជឿទុកចិត្តគ្នា និងការមិនចូលចិត្តគ្នាដែលកើតចេញពីការប្រកួតប្រជែង ដែលជាភាពស្មោះត្រង់ទៅតាមការសម្គាល់ខ្លួនផ្នែកខាងក្នុងក្នុងចំណោមបុគ្គលិកពេញម៉ោង និងបុគ្គលិកគ្រប់គ្រង និងការផ្លាស់ប្តូរនៅក្នុងទីផ្សារបង្កឱ្យមានការប្រកួតប្រជែងសម្រាប់និស្សិត នឹងមិនអាចឱ្យមានការសហការគ្នារបស់គ្រឹះស្ថានឧត្តមសិក្សាក្រៅអំពីកិច្ចខិតខំប្រឹងប្រែងពិសេស។ ការពិចារណាមួយទៀតគឺថា គោលគំនិតអំពីការប្រើប្រាស់ការជួយជ្រោមជ្រែងការសិក្សាស្រាវជ្រាវពីអ្នកផ្តល់ជំនួយទៅកាន់សាកលវិទ្យាល័យ គឺថាវាអាចត្រូវបានប្រើប្រាស់ជាការផ្សព្វផ្សាយទីផ្សារពីសាកលវិទ្យាល័យដោយបង្ហាញពីគុណភាពខ្ពស់ទាក់ទងនឹងគ្រឹះស្ថានឧត្តមសិក្សាដទៃ។ មើលពីជ្រុងមួយទៀត គ្រឿងលើកទឹកចិត្តមូលដ្ឋានគ្រឹះសម្រាប់សាកលវិទ្យាល័យដើម្បីទទួលបានអំណោយសិក្សាស្រាវជ្រាវគឺមានភាពខុសគ្នាទៅនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីប្រើប្រាស់អំណោយទាំងនោះក្នុងការសហការគ្នា ឬជំរុញការសហការគ្នាជាទូទៅ។ ការជួយជ្រោមជ្រែងពីថ្នាក់ក្រសួងអាចជាកាតាលីករមួយសម្រាប់ការជំរុញការសហការគ្នា។ ឧទាហរណ៍ ក្រសួងអប់រំ យុវជន និងកីឡា អាចផ្តល់ការផ្លាស់ប្តូរការសិក្សា និងការប្រកួតប្រជែងដើម្បីធ្វើឱ្យប្រសើរឡើងនូវការសហការគ្នាថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ (UBB:FR2)។ អ្នករដ្ឋបាលសាកលវិទ្យាល័យខ្លះបានធ្វើការផ្លាស់ប្តូរទៅលើនិន្នាការនេះ ជាឧទាហរណ៍ ប្រធានសិក្សាការស្រាវជ្រាវនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាបានប្រាប់ថាគាត់បានបង្កើតការពិភាក្សាជាក្រុមជារៀងរាល់ខែ និងបណ្ណាល័យតាមអ៊ីនធើណិតដើម្បីលើកទឹកចិត្តក្នុងការសហការគ្នា។

អ្នកចូលមួយចំនួនបានធ្វើសេចក្តីស្នើឱ្យ HEIS គួរតែស្វែងរកកិច្ចសហប្រត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលសម្រាប់អភិវឌ្ឍសមត្ថភាពការស្រាវជ្រាវ ពីព្រោះអង្គការមិនមែនរដ្ឋាភិបាលមានថវិកាសម្រាប់ឧបត្ថម្ភការស្រាវជាវ ក៏ប៉ុន្តែអ្នកស្រាវជ្រាវខ្វះចំណេះដឹងខាងជំនាញនេះ"(Z-D1) អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ប្រាថ្នាចង់បានការធ្វើកិច្ចសហប្រត្តិការជាមួយ ESO គឺមានន័យថា ពួកគេអាចប្រមូលបាន នូវជំនួយថវិកាសម្រាប់ការស្រាវជ្រាវបានច្រើនតាមភ្នាក់ងារផ្សេងៗ។ CSOs ខ្លះបានចូលរួមផ្តល់យោបល់ថា អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់គួរតែយកការអនុវត្តតាម CSOs អ្នកខ្លះទៀតយល់ថាអ្នកស្រាវជ្រាវជាន់ខ្ពស់ និងCSOs មិនធ្វើការទំនាក់ទំនងគ្នា " ក៏ប៉ុន្តែអ្នកទាំងពីរគួរតែយល់គ្នាទៅវិញទៅមក" (CCHR: SR), " ដោយសារតែបរិយាកាសរវាងអ្នកចុះអនុវត្តផ្ទាល់ និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់គឺមានលក្ខណៈខុសគ្នាស្រឡះ។ មានន័យថា អ្នកស្រាវជ្រាវជាន់ខ្ពស់ គឺផ្តោតទៅលើទ្រឹស្តី ចំណែកឯCSO វិញការស្រាវជ្រាវផ្អែកលើការអនុវត្ត និងភាពជាក់ស្តែង" ។ (CCHR: SR) អ្នកផ្សេងទៀតឱ្យ

យោបល់ថា ការស្រាវជ្រាវគួរតែមានទ្រង់ទ្រាយពិតប្រាកដមួយដើម្បីបង្កើតនូវកិច្ចសហប្រតិបត្តិការ។ សារៈប្រយោជន៍នៃការធ្វើកិច្ចសហប្រតិបត្តិការជាមួយCSO គឺសម្រាប់ឱ្យមានថវិកាលើកទឹកចិត្ត នេះគឺជាយោបល់ដែលបានស្នើពេលធ្វើបទសម្ភាសន៍ជាមួយនិស្សិតនៃ RUPP ការបានថវិកាស្រាវជ្រាវពី NGOs សម្រាប់ធ្វើការស្រាវជ្រាវ ជាវិធីមួយអាចឱ្យអ្នកស្រាវជ្រាវ បង្កើននូវចំណេះដឹង និងជំនាញក្រោយគេបានបញ្ចប់ការសិក្សា និងជាជំនាញសម្រាប់ការងារទៅអនាគតឱ្យបានឋិតថេរ។ (RUPP: SRT)

សារៈប្រយោជន៍នៃការសហការឱ្យបានល្អគឺអ្នកស្រាវជ្រាវ និងស្ថាប័នដែលជាប់ពាក់ព័ន្ធពុំត្រូវឱ្យមានភាពតានតឹងដាក់គ្នាទៅវិញទៅមកឡើយ។ បើអាចធ្វើបែបដូច្នេះ សារៈប្រយោជន៍នៃការស្រាវជ្រាវគឺពង្រឹងសមត្ថភាពដោយអ្នកទាំងពីរនេះ ផ្តល់នូវវគ្គបណ្តុះបណ្តាលទៅតាមជំនាញរៀងៗខ្លួន ហើយអាចផ្តល់ឱកាស និងសារៈប្រយោជន៍ដល់និស្សិតថែមទៀតផង។ បន្ថែមពីនេះទៅទៀត ធនធានរបស់និស្សិតដែលបានបណ្តុះបណ្តាល និងការយល់ដឹងជាសាធារណៈ អាចបង្កើតនូវចំណេះដឹងនៅ HEIs និងធ្វើឱ្យពួកគេយល់ដឹងពីការស្វែងរកថវិកាដើម្បីធ្វើការស្រាវជ្រាវ និងបង្កើនចំណេះដឹងក្នុងរបៀបធ្វើការស្រាវជ្រាវថែមទៀតផង ដូចជាការវិភាគទិន្នន័យ ការឱ្យចម្លើយវិជ្ជមាន និងរបៀបគ្រប់គ្រងរវាងស្ថាប័នដែលជាប់ពាក់ព័ន្ធ។

ការសហប្រតិបត្តិការរវាងអ្នកស្រាវជ្រាវអន្តរជាតិ និងអ្នកស្រាវជ្រាវជាតិគឺមានសារៈសំខាន់ ក្រុមស្រាវជ្រាវល្អតម្រូវឱ្យមានបញ្ញវន្តជាជនជាតិខ្មែរ និងជនជាតិបរទេសរួមបញ្ចូលគ្នា ដើម្បីធ្វើឱ្យការស្រាវជ្រាវមានលក្ខណៈល្អប្រសើរ ព្រោះថា អ្នកស្រាវជ្រាវទាំងនោះប្រកបដោយចំណេះដឹងនិងជំនាញផ្សេងៗគ្នា។ វាមាន សារៈប្រយោជន៍ដែលអ្នកស្រាវជ្រាវមានគំរូការស្រាវជ្រាវទ្រឹស្តី និងសីលធម៌ក្នុងការស្រាវជ្រាវ និងបណ្តុះបណ្តាល។ ក៏ប៉ុន្តែ ការស្រាវជ្រាវតម្រូវឱ្យអ្នកស្រាវជ្រាវ យល់ដឹងនូវស្ថានភាពសង្គម និងវប្បធម៌ ដើម្បីឱ្យទំនាក់ទំនងរវាងស្ថាប័នផ្សេងៗ និងការស្រាវជ្រាវមានខ្លឹមសារ (ADB)។ និស្សិតRUPP មានមតិយោបល់ថា សារៈប្រយោជន៍នៃអ្នកស្រាវជ្រាវជាតិ និងអ្នកស្រាវជ្រាវអន្តរជាតិ គឺត្រូវការឱ្យមានការយល់យោគគ្នាទៅ វិញទៅមក ពីព្រោះ "អ្នកស្រាវជ្រាវអន្តរជាតិ ត្រូវយល់អំពីវប្បធម៌ខ្មែរមុនពេលធ្វើការស្រាវជ្រាវ"។ យើងត្រូវការស្ថាប័ន អ្នកស្រាវជ្រាវជាតិខ្មែរ និងអន្តរជាតិ ដើម្បីចែករំលែកចំណេះដឹង» (RUPP IFL: SRT)។

### ការបង្កើតស្តង់ដារថ្នាក់ជាតិក្នុងការស្រាវជ្រាវ

អ្នកចូលរួមកិច្ចសម្ភាសន៍បានចង្អុលបង្ហាញពីតម្រូវការក្នុងការជំរុញ និងលើកកម្ពស់បរិស្ថានស្រាវជ្រាវនៅថ្នាក់ជាតិ ស្តីអំពីស្តង់ដារ និងគោលនយោបាយជាតិ ដើម្បីប្រយោជន៍សាធារណៈ។ ជាឧទាហរណ៍ អ្នករដ្ឋបាលសាកលវិទ្យាល័យមួយបានប្រៀបធៀបប្រយោជន៍រួមទៅនឹងការស្មោះស្ម័គ្ររបស់ក្រុមមួយ ហើយបានបង្ហាញថា អ្នកស្រាវជ្រាវគួរគិតពីប្រយោជន៍ជាតិ ជាងប្រយោជន៍បក្ស (UBB:DR)។ កិច្ចខិតខំប្រឹងប្រែងជារួមមានភាពចាំបាច់រវាងភាគីពាក់ព័ន្ធ ហើយរដ្ឋគួរតែផ្តួចផ្តើម

(ដឹកនាំការស្រាវជ្រាវ) ដោយមានក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា។ ប៉ុន្តែ មន្ត្រីសំខាន់ៗនៅក្រសួងគិតថា មិនមានការគាំទ្រពីថ្នាក់លើ ពីព្រោះពួកគេមើលមិនឃើញពីតម្លៃក្នុងការសិក្សាស្រាវជ្រាវ។ ក្រសួងផែនការបានបញ្ជាក់ថា រដ្ឋត្រូវចាត់ទុកថាការស្រាវជ្រាវមានសារៈសំខាន់ និងមានតម្លៃក្នុងការអភិវឌ្ឍសង្គម។ រដ្ឋគួរតែផ្តល់ថវិកាក្នុងការធ្វើជំរឿន និងគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗផ្សេងៗ ព្រមទាំងផ្តល់ថវិកាមូលដ្ឋានក្នុងការអភិវឌ្ឍធនធានមនុស្ស (MOP1)។

ព្រឹទ្ធបុរសនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រមានណែនាំថា រដ្ឋាភិបាលគួរអភិវឌ្ឍស្តង់ដាររួមមួយសម្រាប់ការស្រាវជ្រាវគ្រប់សាកលវិទ្យាល័យ ដោយមាន″គំនិតបើកទូលាយ″ (PUC:Dean1)។ គោលនយោបាយស្រាវជ្រាវរបស់រដ្ឋាភិបាល ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡានៅមានកម្រិត ព្រោះវាមិនបានចែងអំពីលក្ខខណ្ឌច្បាស់លាស់ក្នុងការវាយតម្លៃកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឲ្យប្រសើរឡើងនូវការសិក្សាស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សា និងខ្វះការអនុវត្តស្តង់ដារដែលបានដាក់ចេញ (NUM:PR)។ នេះបង្ហាញយ៉ាងជាក់ច្បាស់ពីភាពខ្វះខាតសកម្មភាពរបស់ក្រសួង និងគោលនយោបាយដែលចងក្រងក្នុងឯកសាររបស់ក្រសួង ដូចបានវិភាគក្នុងការសិក្សាដែលមានស្រាប់។ ប្រធាននៃនាយកដ្ឋានសិក្សាអន្តរជាតិនៃវិទ្យាស្ថានភាសាបរទេសបានឲ្យយោបល់ថា ក្រសួងគួរបង្កើតក្រុមប្រឹក្សាភិបាលស្រាវជ្រាវ ដើម្បីធានាគុណភាព បង្កើតសេចក្តីណែនាំ និងក្រមសីលធម៌ និងការពិនិត្យនិងវាយតម្លៃគម្រោង (RUPPIFL:DH)។ អ្នកចូលរួមកិច្ចសម្ភាសន៍មួយចំនួនទៀតបានបង្ហាញពីតម្រូវការស្តីពីគោលនយោបាយរដ្ឋាភិបាលក្នុងការជំរុញការសិក្សាស្រាវជ្រាវដោយផ្តល់ការលើកទឹកចិត្ត ប៉ុន្តែធ្វើក្នុងលក្ខណៈមួយដែលមានវិមជ្ឈការ និងអនុញ្ញាតឲ្យគ្រឹះស្ថានឧត្តមសិក្សាធ្វើការស្រាវជ្រាវ និងបណ្តុះបណ្តាលនិស្សិតក្នុងការងារកិច្ចការងារសង្គមដោយគ្មានការបំភិតបំភ័យពីរដ្ឋ។

កិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឲ្យប្រសើរឡើងនូវស្តង់ដារគ្រប់គ្រងគុណភាព និងក្នុងពេលតែមួយផ្តល់គ្រឿងលើកទឹកចិត្តគឺអាចសម្រេចបានតាមរយៈគោលនយោបាយឧត្តមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា កំណត់តម្រូវការសម្រាប់សាកលវិទ្យាល័យដោយមានគោលដៅ និងពេលវេលាច្បាស់លាស់។ ព្រឹទ្ធបុរសនៃកិច្ចការសិក្សានិស្សិតរបស់ហ្សាម៉ាន់បាននិយាយថា "ពួកយើងត្រូវការជំនួយពីក្រសួងអប់រំ ដូចជាការបង្កើតការចាត់ថ្នាក់ស្រាវជ្រាវ ដែលចាត់ថ្នាក់សាកលវិទ្យាល័យផ្អែកទៅលើផលិតភាព ការសិក្សាស្រាវជ្រាវ។ ប្រសិនមានការលើកទឹកចិត្តក្នុងការសិក្សាស្រាវជ្រាវសាកលវិទ្យាល័យជាច្រើននឹងដណ្តើមយកចំណាត់ថ្នាក់លេខមួយសម្រាប់ការស្រាវជ្រាវ″ (Z:Dean2)។ ត្រូវមានការសិក្សាបន្ថែមក្នុងការបញ្ជាក់អំពីតួនាទីពីរ ដោយធ្វើឡើងដោយការសិក្សាស្រាវជ្រាវក្នុងចំណាត់ថ្នាក់របស់ ACC ដែលជាចំណុចមួយក្នុងការពិចារណាសម្រាប់គុណភាពឧត្តមសិក្សាទាំងមូល ប៉ុន្តែ ACC ត្រូវធ្វើការស្រាវជ្រាវផ្ទាល់ក្នុងការកសាងលក្ខខណ្ឌគុណភាព និងធ្វើឱ្យប្រសើរឡើងនូវតួនាទីរបស់ខ្លួនដោយរបៀបណា។ អង្គការសង្គមស៊ីវិលមួយបានផ្តល់ជាអនុសាសន៍ជាការអភិវឌ្ឍគ្រឹះនៅក្នុងការ

បង្កើតមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវថ្នាក់ជាតិ ដែលត្រូវបានគាំទ្រដោយកញ្ចប់ថវិកាជាតិ និងអនុម័តដោយរដ្ឋសភា។ កិច្ចការចម្បងរបស់មជ្ឈមណ្ឌលគឺត្រូវធ្វើការរួមគ្នាជាមួយទាំងសាកលវិទ្យាល័យ និងសង្គមស៊ីវិលក្នុងការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ (EC:PM)។

## ការបន្ថែមវគ្គបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងការកសាងសមត្ថភាព

អ្នកចូលរួមសិក្សាស្រាវជ្រាវតែងនិយាយអំពីសារៈសំខាន់នៃការបង្កើនឱកាសបណ្តុះបណ្តាលក្នុងការស្រាវជ្រាវ មានដូចជាវគ្គបណ្តុះបណ្តាលខ្លីៗស្តីអំពីវិធីសាស្ត្រស្រាវជ្រាវសម្រាប់ការសិក្សាក្នុងមហាវិទ្យាល័យ (MCU:Dean3) ផ្នែកហាត់ការសិក្សាស្រាវជ្រាវរបស់និស្សិត (MCU:SRT) ផ្តល់ថវិកាដល់និស្សិត និងមហាវិទ្យាល័យក្នុងការសិក្សាស្រាវជ្រាវ និងវគ្គបណ្តុះបណ្តាលនៅបរទេស (RUA:SRT) បង្កើនជម្រើសអាហារូបករណ៍ដល់និស្សិត និងការចូលរួមរបស់និស្សិតក្នុងការសិក្សាស្រាវជ្រាវ វគ្គបណ្តុះបណ្តាលដើម្បីរៀបចំគម្រោងថវិកា និងវិធីសិក្សាស្រាវជ្រាវ (UBB:FR2)។ ជាមួយគ្នានេះដែរ និស្សិតដែលបានចូលរួមការពិភាក្សាជាក្រុមនៅ PUC បានផ្តល់ជាអនុសាសន៍ថា ការប្រកួតប្រជែងការស្រាវជ្រាវរបស់និស្សិតអាចលើកកម្ពស់គុណភាពសិក្សាស្រាវជ្រាវ និងគួបផ្សំជាមួយសិក្ខាសិលា និងថ្នាក់បង្រៀនជំនាញសិក្សាស្រាវជ្រាវ និងការបង្កើតការិយាល័យ ដែលនិស្សិតអាចស្វែងរកជំនួនអំពីគម្រោងសិក្សាស្រាវជ្រាវដើម្បីលើកកម្ពស់គុណភាព។

បុគ្គលិករដ្ឋបាលជាច្រើននាក់បានបង្ហាញពីកង្វះខាតការយល់ដឹងអំពីការសិក្សាស្រាវជ្រាវ និងតម្លៃក្នុងការសិក្សាស្រាវជ្រាវរបស់រាជរដ្ឋាភិបាល។ មធ្យោបាយមួយដែលមានប្រសិទ្ធភាពគឺការលើកកម្ពស់ការស្រាវជ្រាវតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការ។ ព្រឹទ្ធបុរសមួយរូបនៅ PUC បានបង្កើតវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីនៃក្រសួងវប្បធម៌ និងទទួលបានលទ្ធផលល្អ។ មន្ត្រី ២០រូបបានចូលរួមហើយបានបង្កើតការសិក្សាស្រាវជ្រាវខ្លះ។ កម្មវិធីមួយនេះជាឧទាហរណ៍ថ្មី និងប្លែកដើម្បីបង្កើតសហប្រតិបត្តិការរវាងគ្រឹះស្ថានឧត្តមសិក្សា និងអ្នកបង្កើតគោលនយោបាយ។ នេះបានបង្កើតជាយន្តការវិជ្ជមានតាមរយៈបទពិសោធន៍ និងផលប្រយោជន៍រួមក្នុងសហប្រតិបត្តិការ។ នេះបង្ហាញយ៉ាងជាក់ច្បាស់ដល់អ្នកបង្កើតគោលនយោបាយអំពីប្រយោជន៍របស់ពួកគាត់ក្នុងការពង្រឹងគ្រឹះស្ថានឧត្តមសិក្សាក្នុងការស្រាវជ្រាវ ដើម្បីជួយពួកគាត់ក្នុងការសម្រេចគោលដៅរបស់ក្រសួង (PUC:D2)។

អ្នកដទៃទៀតបានផ្តល់យោបល់អំពីសារៈសំខាន់នៃ"ការបង្កើតវប្បធម៌នៃការស្រាវជ្រាវពីដំបូងមុនចូលសាកលវិទ្យាល័យ" (PUC:D1; UBB:DR)។ ក្នុងន័យនេះដែរ អ្នកចូលរួមមួយចំនួនយល់ថារដ្ឋាភិបាលគួរតែបង្កើតថ្នាក់ស្រាវជ្រាវក្នុងសាលារដ្ឋដើម្បីឲ្យនិស្សិតទទួលបានចំណេះវិជ្ជាក្នុងការស្រាវជ្រាវ មុននឹងចូលសាកលវិទ្យាល័យ។ ការធ្វើការស្រាវជ្រាវនៅថ្នាក់វិទ្យាល័យធ្វើឲ្យសិស្សមានទំនុកចិត្ត នៅពេលចូលសាកលវិទ្យាល័យ (Z:SRT)។ ចំពោះនិស្សិតវិញ ទាំងក្រសួងអប់រំ និងសាកលវិទ្យាល័យនីមួយៗត្រូវតែបង្កើតគោលនយោបាយ ដើម្បីលើកកម្ពស់សមត្ថភាព ដោយបង្កើតទំនុកទុក

ចិត្តរបស់គាត់។ ការគាំទ្រដោយសាស្ត្រាចារ្យក្នុងការពិនិត្យ និងណែនាំលើការស្រាវជ្រាវ (Z:SRT) អាចគួបផ្សំនឹងកិច្ចខិតខំប្រឹងប្រែងបន្តក្នុងការលុបបំបាត់ការលួចចម្លង (NUM:PR)។ ក្នុងកម្រិតវិទ្យាស្ថាន ការគាំទ្រផ្នែកភាសាអង់គ្លេសគឺមានភាពចាំបាច់សម្រាប់និស្សិតក្នុងការអាន និងសរសេរគម្រោងស្រាវជ្រាវ ហើយជាការប្រាថ្នារបស់មហាវិទ្យាល័យ ដើម្បីពួកគាត់ធ្វើការដាក់សំណើសុំជំនួយផ្នែកថវិកា និងលទ្ធផលសម្រាប់ការបោះពុម្ព (NUM:FR1)។

ផ្នែកសមត្ថភាពរបស់និស្សិត និងសាស្ត្រាចារ្យដែលមានកង្វះខាតជាងគេ គឺផ្នែកស្ថិតិ (NUM:FR1) និងវិធីសាស្ត្រសិក្សាស្រាវជ្រាវ។ មន្ត្រី COMFREL មួយរូបបាននិយាយថា ការអភិវឌ្ឍជំនាញស្ថិតិត្រូវមានស្តង់ដារមួយសម្រាប់អ្នកស្រាវជ្រាវខ្មែរនៅគ្រប់ស្ថាប័នផ្សេងៗ (Com:A)។ ការស្រង់មតិនៅគ្រឹះស្ថានឧត្តមសិក្សាដើម្បីស្វែងយល់ថាគ្រឹះស្ថានមួយណាត្រូវការស្រាវជ្រាវនៅកម្រិតសិក្សាផ្សេងៗមិនបានផ្តល់លទ្ធផលដែលអាចទទួលយកបានដោយសារក្នុងករណីជាច្រើន គោលនយោបាយរបស់ស្ថាប័នមិនត្រូវបានអនុវត្តបានខ្ជាប់ខ្ជួននៅឡើយ។ ក្នុងន័យនេះដែរ ការសម្ភាសជាមួយសាស្ត្រាចារ្យបានបង្ហាញថា ទោះបីជាមានការណែនាំរបស់សាកលវិទ្យាល័យចង្អុលបង្ហាញពីតម្រូវការការធ្វើសារណាដើម្បីបញ្ចប់ថ្នាក់អនុបណ្ឌិតក៏ដោយ ក៏នៅមាននិស្សិតមួយចំនួនបញ្ចប់ថ្នាក់អនុបណ្ឌិតរបស់ខ្លួនដោយមិនបានធ្វើការស្រាវជ្រាវទៅលើប្រធានបទដែលទាក់ទងនឹងជំនាញរបស់គាត់ដែរ (SRU:F1,F2,F3)។

ការកសាងសមត្ថភាពអាចពង្រីកទៅដល់ការគ្រប់គ្រងសាកលវិទ្យាល័យ និងការណែនាំការស្រាវជ្រាវរបស់និស្សិត។ និស្សិតថ្នាក់បណ្ឌិតបាននិយាយថាឱកាសនៃស្រាវជ្រាវដល់ទីកន្លែងអាចមានការរីកចម្រើន ប្រសិនបើសាកលវិទ្យាល័យផ្តល់ព័ត៌មានទំនាក់ទំនង និងការសម្របសម្រួលដល់អ្នកស្រាវជ្រាវក្នុងការប្រមូលទិន្នន័យ ដូចជាលិខិតរដ្ឋបាល (NUM:SRT)។ មតិយោបល់ទាំងនេះបង្ហាញពីបញ្ហាយ៉ាងជ្រៅនៅគ្រឹះស្ថានឧត្តមសិក្សា ដែលមិនមានបែបបទមូលដ្ឋានក្នុងការជួយដល់ដំណើរការស្រាវជ្រាវ។ នេះបានលើកជាសំណួរ ដែលយើងតែងជួបប្រទះជាញឹកញាប់ ថាតើមានបែបបទរួចរាល់ហើយ ឬមានរួចរាល់ហើយ តែមិនបានចែកចាយ ឬបង្ហាញឲ្យដឹងដល់បុគ្គលិក។

អ្នកចូលរួមផ្តល់បទសម្ភាសន៍បានបង្ហាញពីការអាក់អន់ចិត្តនឹងកង្វះខាតការចែកចាយការស្រាវជ្រាវ និងតម្រូវការនៃការណែនាំ និងការបណ្តុះបណ្តាលបន្ថែម និងកត់សម្គាល់ថា ការស្រាវជ្រាវគួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈ (RULE:SRT)។ អ្នកស្រាវជ្រាវគួរបោះពុម្ពផ្សាយឱ្យបានច្រើនក្នុងទិនានុប្បវត្តិគ្រប់ផ្នែក (RULE:Dean1)។ សហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធមានសារៈសំខាន់ណាស់។ ប្រសិនបើអ្នកស្រាវជ្រាវមិនមានទំនាក់ទំនងជិតស្និទ្ធទេ នោះការងាររបស់គាត់ក៏ត្រូវបានទទួលដោយក្រសួងដែរ និងមិនអាចទទួលព័ត៌មានគ្រប់ជ្រុងជ្រោយដែលពួកគាត់ត្រូវការ (ADB)។

# ១០.មតិយោបល់សម្រាប់ការសិក្សាស្រាវជ្រាវបន្ថែម ការអភិវឌ្ឍ និងការពង្រឹងសមត្ថភាព

គម្រោងចុះស្រាវជ្រាវដោយផ្ទាល់នេះបានបង្ហាញផ្នែកបន្ថែមមួយចំនួនដែលការសិក្សាស្រាវជ្រាវរយៈពេលវែងបន្ថែមទៀតគួរតែត្រូវបានធ្វើឡើងដើម្បីឆ្លុះបញ្ចាំងលើស្ថានភាពស្រាវជ្រាវនៅកម្ពុជា៖

- ពង្រឹងការវែកញែកបែបគុណភាពនិងបរិមាណដែលបង្ហាញយ៉ាងច្បាស់ពីកម្រិតគោលនយោបាយ និងការអនុវត្តនៅគ្រឹះស្ថានឧត្តមសិក្សានីមួយៗ។ តើអ្វីខ្លះជាគម្លាតរវាងគោលនយោបាយនិងការអនុវត្តជាក់ស្តែង? តើមានកម្រិតឯករាជភាពផ្នែកស្ថាប័នប៉ុន្មានដែលគ្រប់គ្រាន់ និងប៉ុន្មានទៀតដែលកំពុងត្រូវការ?
- តាមដានបន្ថែមលើឥទ្ធិពលរបស់ ACC ដែលបានទទួលស្គាល់ជាផ្លូវការ និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការសិក្សារៀនសូត្រដែលចាំបាច់។ សំណួរនៅតែបន្សល់ថាតើការកែប្រែទាំងនេះ នឹងអាចជះឥទ្ធិពល និងពាំនាំមកនូវឱកាសនៃការអភិវឌ្ឍដ៏មានប្រសិទ្ធភាពដែលអាចយកមកប្រើប្រាស់បានសម្រាប់បុគ្គលម្នាក់ៗក៏ដូចជាស្ថាប័ននានា រួមជាមួយការនាំយកនូវឱកាសផ្សេងៗសម្រាប់ការសិក្សាជាន់ខ្ពស់របស់និស្សិតគ្រប់រូបឬទេ?។
- ត្រួតពិនិត្យលើវិធីសាស្ត្រនិងសកម្មភាពជាសារៈសំខាន់ចំពោះការហ្វឹកហ្វឺនដែលកំពុងដំណើរការ និងផលិតកម្មនៃការស្រាវជ្រាវនូវរាល់ក្រសួងនីមួយៗ។ មានការបកស្រាយដោយលម្អិតនៃគោលដៅដែលមាន និងគំនូសចង្អុលបង្ហាញនៃការអនុវត្តគោលនយោបាយ។

តើការកែប្រែរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលនយោបាយរបស់ក្រសួងផែនការបានធ្វើឱ្យមានប្រសិទ្ធភាពនៃការស្រាវជ្រាវប្រសើរឡើងឬទេ?

- ស៊ើបអង្កេតលើការអនុវត្តដែលល្អនៃដំណើរការខិតខំប្រឹងប្រែង ដើម្បីផ្សារភ្ជាប់គ្រឹះស្ថានឧត្តមសិក្សា និងសង្គមស៊ីវិល។ តើកិច្ចការអ្វីខ្លះជំរុញឱ្យមានការទំនាក់ទំនងនិងសហប្រតិបត្តិការរវាងភាគីទាំងពីរ? ហេតុអ្វី?
- ស្រាវជ្រាវលើការបង្កើតយន្តការសម្រាប់ការគ្រប់គ្រងត្រួតពិនិត្យឡើងវិញរបស់ HEQIP ដែលបង្ហាញពីតម្លាភាព និងការចូលរួមដ៏ស្វះស្វែងពីថ្នាក់ក្រសួងនិងសម្រាប់ស្ថាប័ននានា។ តើមានភាពមិនសមស្របអ្វីខ្លះកើតឡើងរវាងគោលដៅ និងការវាយតម្លៃរបស់រដ្ឋាភិបាល ក៏ដូចជាអ្នកឧបត្ថម្ភទាំងនោះ?
- វាជាការចាំបាច់ក្នុងការចងក្រងឯកសារស្តីអំពីកម្រិតនៃការពឹងពាក់ទៅលើទីប្រឹក្សាខាងក្រៅបន្ទាប់មកចាប់ផ្តើមផ្តល់ឧទាហរណ៍ជាក់ស្តែង រួមជាមួយនឹងការពិភាក្សាប្រៀបធៀបដើម្បីឆ្ពោះទៅកាន់ការចងក្រងទ្រឹស្តីសម្រាប់បន្តពាំនាំមកនូវជំនាញ និងចំណេះដឹងដ៏មានប្រសិទ្ធភាព។ តើអ្វីខ្លះជាគុណសម្បត្តិនិងគុណវិបត្តិ? តើកត្តាអ្វីធ្វើឱ្យការបញ្ជូនចំណេះដឹងកើតមាន? ធ្វើ

ដូចម្តេចដើម្បីឱ្យមានការរីកចម្រើនស្របពេលមានការទប់ស្កាត់ការពឹងផ្អែកពីទីប្រឹក្សាខាងក្រៅ?

- ការកត់ត្រាជាក់លាក់ស្តីពីអ្នកប្រៀនប្រដៅ និងអ្នកហាត់ការតាមគ្រឹះស្ថានឧត្តមសិក្សា។ តើមានអ្វីដែលសិស្សានុសិស្ស និងសង្គមស៊ីវិលអាចយកមកប្រើប្រាស់បាន? តើមាននរណាខ្លះបានដឹងអំពីការកត់ត្រានេះ?
- ការកត់ត្រាជាក់លាក់ស្តីពីសិក្ខាសិលាដែលមានថ្មីៗ និងជិតកើតមាន។ តើមាននរណាខ្លះចូលរួម? តើមានសមិទ្ធផលអ្វីខ្លះត្រូវបានចងក្រងជាឯកសារ?
- ការបោះពុម្ពផ្សាយទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតសកម្មភាពសិក្សាស្រាវជ្រាវដែលមានលក្ខណៈសេដ្ឋកិច្ច ពាណិជ្ជកម្មជានិរន្តរ៍ដូចសង្គមស៊ីវិល និងផលប៉ះពាល់សម្រាប់គ្រឹះស្ថានឧត្តមសិក្សានឹងមានសារៈប្រយោជន៍សម្រាប់ការធ្វើផែនការគម្រោងសិក្សាស្រាវជ្រាវ និងការបណ្តុះបណ្តាលនៅគ្រឹះស្ថានឧត្តមសិក្សា។ តើការសិក្សាស្រាវជ្រាវអាចរួមបញ្ចូលទៅក្នុងគំរូពាណិជ្ជកម្មរបស់គ្រឹះស្ថានឧត្តមសិក្សាបានយ៉ាងដូចម្តេច? តើប្រភេទផ្សេងៗនៃការស្រាវជ្រាវអាចរួមបញ្ចូលយ៉ាងដូចម្តេច និងតើសក្តានុពលផ្នែកពាណិជ្ជកម្មរបស់ការសិក្សាស្រាវជ្រាវអាចឈានទៅមុខបានដោយមិនកាត់បន្ថយសេរីភាពឧត្តមសិក្សាទៅកាន់ផលប្រយោជន៍សង្គមយ៉ាងដូចម្តេច?
- សកម្មភាពទ្រទ្រង់ការស្រាវជ្រាវមានគោលបំណងទៅលើការជំរុញឱ្យរីកចម្រើននូវធនជានក្នុងសង្គមក៏ដូចជាការទទួលខុសត្រូវក្នុងសង្គម។ លក្ខខណ្ឌផ្សេងៗបង្កើតឡើងពីទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការដែលបានមកពីការស្វែងយល់ពីការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិលរួមទាំងយុវជនដើម្បីបង្កើនធ្វើការសម្រេចចិត្ត។ តើមូលហេតុអ្វីបានជាការខិតខំប្រឹងប្រែងពង្រីកសក្តានុពលធនជានក្នុងសង្គមមិនបាន សម្រេច? តើវាធ្វើឱ្យការអភិវឌ្ឍនូវមានកម្រិតយ៉ាងដូចម្តេច? តើ CSOs និង HEIs ធ្វើដូចម្តេចក្នុងការសហការគ្នាបង្កើនការយល់ដឹងពីការសិក្សារៀនសូត្រ ក៏ដូចជាការចូលរួមពីយុវជន និងការបង្កើតអ្នកស្រាវជ្រាវ សកម្មជំនាន់ថ្មី រួមទាំងការចូលរួមពីប្រជាជន?
- ស្រាវជ្រាវពីភាពជាអ្នកដឹកនាំដើម្បីពង្រឹងការខិតខំប្រឹងប្រែងឱ្យកាន់តែខ្លាំងឡើងជាមួយនឹង HEIs និងផ្សព្វផ្សាយចំណេះដឹងទាក់ទងទៅនឹងសេវាសាធារណៈ ឱកាសផ្សេងៗ និងការទទួលខុសត្រូវក្នុងការចូលរួមធ្វើការស្រាវជ្រាវគោលបំណងដើម្បីពង្រឹងធនជានក្នុងសង្គម និងការបង្កើនការផ្សព្វផ្សាយឱ្យបានប្រសើរឡើង។ តើអ្វីជាការកំណត់រចនាសម្ព័ន្ធសម្រាប់HEIs? តើពួកគេអាចកាត់បន្ថយយ៉ាងដូចម្តេច? តើមានឱកាសអ្វីខ្លះផ្តល់សម្រាប់ការរួបរួមសហការការខិតខំប្រឹងប្រែងស្រាវជ្រាវនៅលើស្ថាប័ននានាក្នុងលក្ខខណ្ឌ ខុសៗគ្នា?
- គោលបំណងនៃការស្រាវជ្រាវបែបអនុវត្តគឺដើម្បីបង្កើនធនជានមនុស្ស និងការទទួលខុសត្រូវរួម។ ការបង្កើតបរិយាកាសនៃការជឿទុកចិត្តគ្នា និងកិច្ចការសហប្រតិបត្តិការគឺបានមកពីការយល់ដឹងពីការចូលរួមយ៉ាងសកម្មរបស់សង្គមស៊ីវិល និងយុវជន ដើម្បីពង្រឹងការឆ្លើយតប

ដោយអ្នកធ្វើការសម្រេចចិត្ត។ តើហេតុអ្វីបានជាកិច្ចខិតខំប្រឹងប្រែងក្នុងពង្រីកធនធានមនុស្សបរាជ័យ ហើយតើវាបានធ្វើឲ្យការអភិវឌ្ឍធនធានមនុស្សនៅមានកម្រិតដោយរបៀបណា? តើសង្គមស៊ីវិល និងគ្រឹះស្ថានឧត្តមសិក្សាអាចសហការក្នុងការបង្កើនការអប់រំ ការយល់ដឹង និងការចូលរួមពីយុវជន និងបង្កើតអ្នកស្រាវជ្រាវសកម្មជំនាន់ថ្មី ដោយមានការចូលរួមអំពីប្រជាពលរដ្ឋយ៉ាងដូចម្តេច?

- ស្រាវជ្រាវលើភាពដឹកនាំដើម្បីពង្រឹងសីលធម៌នៅគ្រឹះស្ថានឧត្តមសិក្សា និងបន្ថែមការយល់ដឹងស្តីអំពីគុណសម្បត្តិ ឱកាស និងការទទួលខុសត្រូវដើម្បីចូលរួមក្នុងការស្រាវជ្រាវដែលមានប្រសិទ្ធភាព ក្នុងគោលបំណងលើកកម្ពស់ធនធានមនុស្ស និងចែករំលែកឲ្យបានទូលំទូលាយ។ តើមានឧបសគ្គដែលមានលក្ខណៈជាប្រព័ន្ធអ្វីខ្លះនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា? តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីកាត់បន្ថយឧបសគ្គទាំងនោះ និងមានឱកាសអ្វីខ្លះដើម្បីប្រមូលផ្តុំកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវរួមនៅស្ថាប័ន ដែលមានលក្ខខណ្ឌខុសៗគ្នា?
- ស្រាវជ្រាវលើការអនុវត្តល្អៗដើម្បីបង្កើនការចូលរួមជាមួយអ្នកបង្កើតគោលនយោបាយ ដើម្បីពង្រឹងសហប្រតិបត្តិការជាមួយអ្នកបង្កើតគោលនយោបាយ ដោយយកគោលជំហររឹងមាំមួយដែលយល់ថាសង្គមស៊ីវិលរក្សាកម្រិតប្រឆាំងនឹងរដ្ឋ (ក្នុងន័យស្ថាបនា)។ តើធ្វើដូចម្តេចឲ្យការស្រាវជ្រាវមានការរីកចម្រើន? តើមានឧបសគ្គអ្វីខ្លះ និងអ្នកណាខ្លះជាអ្នករារាំង? តើសង្គមស៊ីវិលអាចបង្កើនសហប្រតិបត្តិការ ដោយថៃរក្សាឯករាជភាព និងបង្កើនការយល់ដឹងជាសាធារណៈឲ្យបានច្រើនដោយរបៀបណា?
- បង្ហាញយ៉ាងជាក់ច្បាស់អំពីលក្ខណៈរបស់សេរីភាពឧត្តមសិក្សា ការទទួលបានព័ត៌មាន ផលប៉ះពាល់ទៅការអភិវឌ្ឍសមត្ថភាព និងសមត្ថភាពក្នុងការសម្រេចបានគោលដៅអភិវឌ្ឍជាតិ។ តើមានការផ្លាស់ប្តូរផ្នែកច្បាប់ និងនយោបាយអ្វីខ្លះដែលកំពុងកើតមានឡើង ហើយតើវាអាចប៉ះពាល់បរិយាកាសស្រាវជ្រាវ និងសក្តានុពលក្នុងការសម្រេចបានគោលដៅអភិវឌ្ឍជាតិដោយរបៀបណា?
- ផ្តោតលើកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ និងធនធានក្នុងការផ្សារភ្ជាប់ចន្លោះប្រហោងសម្រាប់ការរួមបញ្ចូលគ្រប់រូបភាពផ្នែកសង្គម ដូចជាគម្លាតជំនាន់ គម្លាតយេនឌ័រ និងគម្លាតរវាងក្រុងនិងជនបទ។ តើមានប្រភេទ និងកម្រិតនៃការរើសអើងអ្វីខ្លះ? តើមានផលប៉ះពាល់ជារួមអ្វីខ្លះទៅលើកម្លាំងនៃសហគមន៍ស្រាវជ្រាវ?

# ១១. សេចក្តីបញ្ចប់

លក្ខណៈស្នូលនៃការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាត្រូវបានបង្ហាញដោយកត្តាច្រើនដែលមានក្នុងរបាយការណ៍នេះ។ ចំណុចចម្បងនៃការផ្លាស់ប្តូរនៅក្នុងបរិស្ថាននេះមានការផ្លាស់ប្តូរពីជំនាន់មួយទៅជំនាន់មួយទៀត ដែលអាចមើលឃើញយ៉ាងច្បាស់នៅក្នុងភាពស្ទាក់ស្ទើរក្នុងការស្រាវជ្រាវរបស់អ្នកគ្រប់គ្រង ក្រសួងរដ្ឋាភិបាល និងសេចក្តីសាទរជាមួយក្រុមអ្នកស្រាវជ្រាវវ័យក្មេង និងនិស្សិតដែលចាប់យកលទ្ធភាពសម្រាប់ការស្រាវជ្រាវនេះ។ ការកាត់ផ្តាច់ទំនាក់ទំនងរវាងជំនាន់ចាស់ និងក្មេង និងរវាងអ្នកស្រាវជ្រាវនិងអ្នករដ្ឋបាលមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅលើសក្តានុពលបរិស្ថាននៃការស្រាវជ្រាវនេះ។ បើអ្នកគ្រប់គ្រងប្រព័ន្ធជឿថាគ្មានសមត្ថភាពនោះទេ និងបំណងប្រាថ្នាដើម្បីធ្វើការស្រាវជ្រាវ ពួកគេប្រហែលជាមិនបានផ្តល់ថវិកានោះទេ។ ស្របគ្នានេះដែរ ជំនឿនេះ (និងការស្រាវជ្រាវរបស់យើងបានបង្ហាញថាវាជាជំនឿមួយ) ដែលអ្នកស្រាវជ្រាវខ្វះសមត្ថភាពអាចរារាំងការផ្លាស់ប្តូររចនាសម្ព័ន្ធចាំបាច់ក្នុងការផ្តល់ឱ្យក្រុមអ្នកស្រាវជ្រាវទាំងពេលវេលានិងថវិកាដែលចាំបាច់ក្នុងការស្រាវជ្រាវ។ ការស្រាវជ្រាវរបស់យើងបានបង្ហាញអំពីភាពរីករាយសាទររបស់អ្នកបញ្ញវន្ត ដែលបានទទួលការបណ្តុះបណ្តាលនៅប្រទេសកម្ពុជាដែលមានទាំងសមត្ថភាពនិងបំណងប្រាថ្នាដើម្បីធ្វើការស្រាវជ្រាវប្រកបដោយគុណភាពនិងសិស្សដែលមានបំណងប្រាថ្នា និងសមត្ថភាពដើម្បីក្លាយជាអ្នកស្រាវជ្រាវ។ ទោះបីជាមិនមានការជាក់ជាក់ពីអ្នកគ្រប់គ្រង រដ្ឋបាល និងរដ្ឋមន្ត្រីក៏ដោយ ក៏មូលនិធិមួយចំនួនកំពុងត្រូវបានដឹកនាំ ឆ្ពោះទៅរកការសម្រួលចំពោះការស្រាវជ្រាវនៅក្នុងបរិបទឧត្តមសិក្សា។ ជំនួយទី១នៃការផ្តល់មូលនិធិនេះបានត្រូវបានផ្តល់ដោយធនាគារពិភពលោក ហើយត្រូវបានគេ អនុវត្តយ៉ាងបន្ទាន់ និងថវិកាមិនត្រូវបានប្រើប្រាស់ត្រឹមត្រូវដើម្បីពង្រឹងសមត្ថភាព។ ប៉ុន្តែវាជាសញ្ញាសំខាន់មួយនៃអន្តរកាលនៅថ្នាក់លើ បើមូលនិធិនេះត្រូវយកទៅប្រើប្រាស់ក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពរយៈពេលវែងសម្រាប់ផលិតកម្មនៃការស្រាវជ្រាវ និងការទំនាក់ទំនងអាចចាប់ផ្តើមដើម្បីបង្កើតភាពរស់រវើកច្រើនទៀតក្នុងបរិស្ថានស្រាវជ្រាវក្នុងសាកលវិទ្យាល័យ។

អង្គការសង្គមស៊ីវិល / អង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាមានដំណើរការល្អ ហើយអង្គការជាច្រើនត្រូវបានចូលរួមនៅក្នុងការតស៊ូមតិ "មានភស្តុតាងជាមូលដ្ឋាន"។ បុគ្គលិកនៃអង្គការទាំងនេះបានជួបប្រទះបទពិសោធន៍ នៅក្នុងការប្រមូលប្រភពទិន្នន័យចម្បង ការសរសេររបាយការណ៍ និងការផ្សព្វផ្សាយការរកឃើញរបស់ពួកគេ។ ពួកគេមានភាពជំនាញនៅក្នុងការជះឥទ្ធិពលពីគោលនយោបាយតាមរយៈភស្តុតាងបញ្ជាក់ការតស៊ូមតិ ហើយពួកគេផ្តល់នូវការយល់ដឹង និងសមត្ថភាពរបស់ខ្លួនតាមរយៈការរកឃើញរបស់ខ្លួន ទៅកាន់ការផ្សព្វផ្សាយជាសាធារណៈផងដែរ។ ទោះជាយ៉ាងណាក្តីក្រុមអ្នកស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះបានខ្វះខាតនូវមូលដ្ឋានវិធីសាស្ត្រមួយចំនួននៃការស្រាជ្រាវ និងទ្រឹស្តីវិធីសាស្ត្រជាមូលដ្ឋានទៅនឹងទិន្នន័យ ដែលទាំង

ពីនេះអាចជួយពួកគេដើម្បីគ្រប់គ្រងសកម្មភាពឱ្យប្រសើរជាងមុន។ ផលប៉ះពាល់ធំៗមួយចំនួនដល់សង្គម ចំពោះការប្រមូលទិន្នន័យនិងការតស៊ូមតិ ដែលក្នុងនោះការមានការរុករកទ្រឹស្តីវិទ្យាសាស្ត្រសង្គម (ដូចជារបៀបដែលធ្វើឱ្យមានអតុល្យភាពវណ្ណៈ អំណាចតែងតាំង និងថវិកា ដែលទាំងនេះអាចប៉ះពាល់ដល់ទាំងទិន្នន័យនិងសហគមន៍) មិនមែនសុទ្ធតែមានវត្តមាននៅក្នុងការអន្តរាគមន៍ពីអង្គការក្រៅរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលនោះទេ។ លើសពីនេះទៀត ទិន្នន័យផែនការស្ថិតិសិក្សាករណីនេះនឹងបន្ថែមទម្ងន់យ៉ាងសំខាន់ទៅលើការប្រមូលទិន្នន័យដោយអង្គការមិនមែនរដ្ឋាភិបាល / អង្គការសង្គមស៊ីវិលនៅទូទាំងប្រទេស។ ការសហការថ្មីរវាងគ្រឹះស្ថានឧត្តមសិក្សា និងអង្គការមិនមែនរដ្ឋាភិបាល / អង្គការសង្គមស៊ីវិលដែលបានដាក់បញ្ចូលជំនាញអ្នកស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សាក្នុងវិធីសាស្ត្រ និងទ្រឹស្តីដែលមានខាងជំនាញអង្គការសង្គមស៊ីវិល / អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងបទបង្ហាញទិន្នន័យនិងការទំនាក់ទំនងអាចមានផលប៉ះពាល់ធំលើការស្រូបយកគោលនយោបាយនៃការស្រាវជ្រាវ។

អង្គការម្ចាស់ជំនួយ និងវិទ្យាស្ថានស្រាវជ្រាវបានទទួលជោគជ័យជាពិសេសក្នុងការធ្វើការស្រាវជ្រាវជាច្រើន និងការទំនាក់ទំនងជាមួយនឹងអ្នកធ្វើគោលនយោបាយ។ ទោះជាយ៉ាងណាក៏ដោយវាគួរតែត្រូវបានគេកត់សម្គាល់ថា មិនមែនគោលនយោបាយចូលរួមទាំងអស់ គឺមានភាពវិជ្ជមាននោះទេទាំងអ្នកផ្តល់ជំនួយ និងវិទ្យាស្ថានស្រាវជ្រាវចូលរួមក្នុងការធ្វើការស្រាវជ្រាវមិនមែនជាការគំរាមកំហែង និងមិនបានបង្ហាញការរកឃើញដែលរសើបនៅក្នុងគោលបំណងដើម្បីឱ្យមានប៉ះពាល់ដល់អ្នកធ្វើគោលនយោបាយនោះដែរ។ នេះគឺជាធាតុនៃបញ្ហាមួយនៃបរិស្ថានស្រាវជ្រាវនេះនៅក្នុងប្រទេសកម្ពុជាដែលត្រូវការយកចិត្តទុកដាក់។ យ៉ាងណាក៏ដោយ ទោះជាមានការចាប់ពិរុទ្ធខ្លួនឯងចំពោះផលិតកម្មការស្រាវជ្រាវរបស់ពួកគេម្ចាស់ជំនួយ និងវិទ្យាស្ថានស្រាវជ្រាវគឺនៅក្នុងទីតាំងតែមួយគត់គឺដើម្បីលើកទឹកចិត្តដល់ក្រុមអ្នកស្រាវជ្រាវក្នុងតំបន់ដោយសារតែការផ្តល់មូលនិធិស្រាវជ្រាវពួកគេអាចដំណើរការបាន ប៉ុន្តែជាអកុសល ថវិកាទាំងនេះជាញឹកញាប់ត្រូវបានចំណាយលើការពិគ្រោះយោបល់របស់បរទេសជាជាងការចូលរួមរបស់ក្រុមអ្នកស្រាវជ្រាវក្នុងស្រុក។ កម្រិតសមត្ថភាពទាបនៃអ្នកស្រាវជ្រាវក្នុងស្រុកគឺជាការពន្យល់មួយដែលអាចសម្រេចបានតិចជាងអតីតកាល។ ទិន្នន័យស្ថិតិរបស់យើងបានបង្ហាញថា វាភាគច្រើនមិនមែនជាភាពខ្វះសមត្ថភាព តែកង្វះពេលវេលានិងការលើកទឹកចិត្តទៅវិញទេដែលបានរារាំងការចូលរួមរបស់អ្នកស្រាវជ្រាវ។

បញ្ហាជាមូលដ្ឋានគឺថាអ្នកស្រាវជ្រាវនៅប្រទេសកម្ពុជាមានការងារច្រើន ហើយកម្រៃដែលទទួលបាននៅមានកម្រិត។ នេះគឺជាភាពខុសគ្នាពីការខ្វះសមត្ថភាព។ យើងបានរកឃើញថា សូម្បីតែនៅក្នុងករណីដែលមូលនិធិ ប៉ុន្តែមិនមានសមត្ថភាពនៅក្នុងស្ថាប័ន ដើម្បីរៀបចំពេលវេលាសម្រាប់ការស្រាវជ្រាវ។ នេះមិនមានន័យថា កម្ពុជាជាអ្នកជំនាញក្នុងការស្រាវជ្រាវនោះទេ ប៉ុន្តែជាមួយនឹងកង្វះ

ខាតពេលវេលាដើម្បីធ្វើការស្រាវជ្រាវ ពួកគេនឹងមិនអាចក្លាយជាអ្នកស្រាវជ្រាវជំនាញនោះទេ។ បញ្ហាដែលពាក់ព័ន្ធគឺជាការពិតមួយដែលថាក្រុមអ្នកស្រាវជ្រាវដ៏តិចតួចរបស់ប្រទេសកម្ពុជា គឺខ្វះចំនួនអ្នកស្រាវជ្រាវជាស្ត្រី។ នេះគឺជាការផ្លាស់ប្តូរដែល៥០% នៃនិស្សិតនាពេលបច្ចុប្បន្នគឺជាស្ត្រី ប៉ុន្តែស្ត្រីភាគតិចណាស់ ដែលឈានទៅដល់ការបន្តការសិក្សាខ្ពស់ជាងនេះ។ ការលំបាកនេះស្ថិតនៅក្នុងផ្នែកមួយនៅក្នុងសម្ពាធវប្បធម៌ឆ្ពោះទៅរកការធ្វើជាមេផ្ទះ ប៉ុន្តែវាក៏មកពីការខ្វះខាតគំរូមួយសម្រាប់ពួកគាត់ដែរ។

ក្រុមស្រាវជ្រាវរបស់យើងមានឱកាសក្លាយទៅជាគំរូសម្រាប់និស្សិតមួយចំនួនធំទាំងតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលវិធីសាស្រ្តសិក្សាស្រាវជ្រាវ និងតាមរយៈការពិភាក្សាតុមូលរបស់សិស្ស។ ក្នុងអំឡុងពេលនៃការជួបទាំងនេះ យើងបានរកឃើញផលប៉ះពាល់យ៉ាងខ្លាំងមួយ លើការស្រាវជ្រាវនេះអាចមាននៅលើក្រុមទាំងអស់បានដែលចូលរួមនៅក្នុងដំណើរការស្រាវជ្រាវ។ ទង្វើនៃការស្រាវជ្រាវបានផលិតបរិស្ថានមួយដែលជាកន្លែងក្រុមអ្នកសម្ភាស និងអ្នកត្រូវបានសម្ភាសរបស់យើងបានកំពុងរំពៃគិតហើយជាការពិតបានបង្កើតលទ្ធភាពថ្មីសម្រាប់ការស្រាវជ្រាវ។ វាជាក្តីសង្ឃឹមរបស់យើងដែលថាតាមរយៈការចូលរួមជាមួយធនធានបណ្តាញរបស់យើងដែលនឹងអនុញ្ញាតឱ្យមានទំនាក់ទំនងរវាងក្រុមអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ និងការផ្តល់មូលនិធិ និងព័ត៌មាននៃឱកាសស្រាវជ្រាវ ដែលនេះហើយនិស្សិតវ័យក្មេងនៅក្នុងប្រទេសកម្ពុជានឹងត្រូវចាប់ផ្តើមទៅចូលរួមនៅក្នុងសិល្បៈនៃការធ្វើការស្រាវជ្រាវនេះ។

ជាចុងក្រោយ ក្រុមអ្នកបង្កើតគោលនយោបាយត្រូវតែយល់ថាការបែងចែកថវិកាក្នុងការលើកកម្ពស់និងធ្វើការស្រាវជ្រាវត្រូវបានវិនិយោគទៅក្នុងពេលអនាគត សម្រាប់គ្រឹះស្ថានឧត្តមសិក្សារបស់ប្រទេស។ ចំណុចសំខាន់នៅទីនេះគឺដើម្បីផ្លាស់ប្តូរផ្នត់គំនិត សម្លឹងមើលការអភិវឌ្ឍរយៈពេលវែងជាជាងការទទួលបានជោគជ័យរយៈពេលខ្លី។ ការដាក់កំហិតនៃការស្រាវជ្រាវសម្រាប់និស្សិតសាកលវិទ្យាល័យ និងសាស្រ្តាចារ្យមិនអាចជាគ្រាន់តែជាវិធីធម្មតាមួយនោះទេ ដូចជាស្ថាប័នមួយចាំបាច់ត្រូវស្វែងរកមូលនិធិរបស់ខ្លួន និងធ្វើឱ្យវាកើតឡើង។ វាត្រូវការការគាំទ្រពីរដ្ឋាភិបាល ការសហការគ្នារវាងគ្រឹះស្ថានឧត្តមសិក្សា បណ្តាញទំនាក់ទំនងជាមួយប្រទេសម្ចាស់ជំនួយធំៗ និងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធ
សំខាន់ៗ។

ខាងក្រោមនេះគឺជាផ្នែកមួយនៃមតិយោបល់ជោគជ័យជាច្រើន ដែលយើងទទួលបានពីការផ្សព្វផ្សាយការរកឃើញរបស់ពួកយើង៖

សូមអរគុណសម្រាប់ការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់អ្នកជាមួយសិស្សានុសិស្សរបស់យើង ដោយសារតែហេតុនេះហើយធ្វើឱ្យយើងបានរៀនអំពីរបៀបដែលសិស្សជា

ច្រើនមានចំណាប់អារម្មណ៍ក្នុងការស្រាវជ្រាវ និងយើងដឹងថាអ្វីដែលជាបញ្ហាប្រឈមក្នុងការធ្វើការស្រាវជ្រាវ។ ក្នុងនាមខ្ញុំជាអ្នកតំណាងកម្មវិធីឧត្តមសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ខ្ញុំពិតជាចង់ឱ្យសិស្សនិស្សិតរបស់យើងចូលរួមនៅក្នុងការស្រាវជ្រាវណាស់។ ដូចដែលអ្នកបានរៀបរាប់មកនេះ ការស្រាវជ្រាវអាចជួយបង្ហាញការពិតនៃបញ្ហា និងយើងអាចរកមើលឃើញពីដំណោះស្រាយដ៏ត្រឹមត្រូវ។

ព្រឹត្តិការណ៍នេះនឹងទទួលបានអត្ថប្រយោជន៍យ៉ាងខ្លាំងមិនត្រឹមតែនិស្សិតរបស់យើងប៉ុណ្ណោះទេ តែថែមទាំងសង្គមទាំងមូលផងដែរ។ ខ្ញុំសង្ឃឹមថា ការស្រាវជ្រាវរបស់អ្នកនឹងមានផលជាវិជ្ជមាន នឹងធ្វើឱ្យអ្នករៀបចំគោលនយោបាយបានដឹងពីសារៈសំខាន់ដ៏អស្ចារ្យនៃការស្រាវជ្រាវ។ ការស្រាវជ្រាវរបស់អ្នកបង្ហាញថា យើងកំពុងប្រឈមមុខនឹងបញ្ហាជាច្រើន ដូចជាធនធានមនុស្ស និងថវិកាមានកម្រិតដើម្បីគាំទ្រដល់ការស្រាវជ្រាវជាដើម។ ទាំងនេះគឺជាឧបសគ្គចម្បងដែលបានរាំងស្ទះទៅដល់ដំណើរការស្រាវជ្រាវ។

ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អ្នកដើម្បីលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវនៅក្នុងសង្គមរបស់យើង( RULE:Dean1 )។

# ឯកសារយោង

Abdon et al. (2007) "e-Learning in Higher Education Makes Its Debut in Cambodia: The Provincial Business Education Project", The International Review of Research in Open and Distributed Learning, Vol. 8, No. 1.

ACT Alliance (2011) *Shrinking Political Space for Civil Society Action*, available at: www.actalliance.org.

Advocacy and Policy Institute (2012) *Access to Information in Cambodia: Past Reflections,* Future Directions.

Asian Development Bank (2011) *Civil Society Briefs, Cambodia*, available at: www.adb.org/publications/civil-society-briefs-cambodia.

Asian Development Bank (2012) *Strengthening Participation for Development Results.*

Baaz, M. & M. Lilja (2014) "Understanding Hybrid Democracy in Cambodia: The Nexus Between Liberal Democracy, the State, Civil Society, and a 'Politics of Presence'", Asian Politics and Policy, Vol. 6, No. 1.

Babovic, M. & D. Vukovic (2014) "Social Accountability in Cambodia", JSRP Paper 19, Justice and Security Research Programme.

Banyopadhyay, K. & T. Khus (2013) "Changing Civil Society in Cambodia: In search of relevance", Development in Practice No. 23.

Berkvens, J.B.Y. & M. Kalyanpur & W. Kuiper & J. vd Akker (2012) "Improving adult learning and professional development in post-conflict area: The case of Cambodia", International Journal of Education Development, No. 32.

Berkvens, J.M.A. et al. (2012) "Improving adult learning and professional development in a post-conflict area: The case of Cambodia", International Journal of Educational Development No. 32, 241-251.

Bottomley, R. (2014) *The Role of Civil Society in Influencing Policy and Practice in Cambodia: Report for Oxfam Novib.*

Bruni, M. & L. Luch & S. Kuoch (2013) "Skill shortages and skill gaps in the Cambodian Labor market: Evidence from employer skills needs survey", ILO Asia-Pacific Working Paper Series, ILO.

Cambodian Center for Human Rights (2012) *Freedom of Expression and Academic Freedom,* CCHR.

Cambodian Center for Human Rights (2012) *Freedom of Information in Cambodia: A right to know or a culture of secrecy?* CCHR.

CAMFEBA (2008) *Youth and employment: Bridging the Gap, a Project paper prepared for*

*CAMFEBA*, Unpublished manuscript.

CDRI (2007) *Accountability and neo-patrimonialism in Cambodia: A critical literature review*, Cambodian Development Research Institute, Working Paper 34.

Chandler, D. (2008). A History of Cambodia. 4th ed. Boulder, Colo.: Westview Press.

Chea, C. & I. Nang & P. Whitehead & A. Thompson (2011) *Decentralized Governance of Irrigation Water in Cambodia: Matching Principles to Local Realities,* CDRI.

